# អនុសញ្ញា
# អង្គការសហប្រជាជាតិ
# ស្តីពីនីតិសមុទ្រ

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ

# ព្រះរាជក្រម

នស/រកម/០១២៦/០០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦ នាសម័យប្រជុំពេញអង្គវិសាមញ្ញ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិ
# ស្តីពីនីតិសមុទ្រ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១ ._**

អនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ដែលបានចុះហត្ថលេខា នៅទីក្រុងម៉ុងតេហ្គោបៃ ប្រទេសហ្សាម៉ាអ៊ីក នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ដែលចូលជាធរមាន នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ ._**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ។

**មាត្រា៣ ._**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ៥កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០២៦

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ពរស. ២៦០១. ១៥៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់ សុខុន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

ភាសាខ្មែរ

ភាសាអង់គ្លេស

# អនុសញ្ញាអង្គការសហប្រជាជាតិ
# ស្តីពី
# នីតិសមុទ្រ

# មាតិកា


**ជំពូកទី១ សេចក្តីផ្តើម**

**ជំពូកទី២ សមុទ្រដែនដីនិងតំបន់តភ្ជាប់**

ផ្នែកទី១ បទប្បញ្ញត្តិទូទៅ

ផ្នែកទី២ ដែនកំណត់នៃសមុទ្រដែនដី

ផ្នែកទី៣ ការឆ្លងកាត់ដោយមិនបំពានក្នុងសមុទ្រដែនដី

អនុផ្នែកទី១ វិធានអនុវត្តចំពោះនាវាគ្រប់ប្រភេទ

អនុផ្នែកទី២ វិធានអនុវត្តចំពោះនាវាជំនួញ និងនាវារដ្ឋាភិបាល ដែលប្រតិបត្តិការក្នុងគោលបំណងពាណិជ្ជកម្ម

អនុផ្នែកទី៣ វិធានអនុវត្តចំពោះនាវាចម្បាំង និងនាវារដ្ឋាភិបាលដទៃទៀត ដែលប្រតិបត្តិការក្នុងគោលបំណងមិនមែនពាណិជ្ជកម្ម

ផ្នែកទី៤ តំបន់តភ្ជាប់

**ជំពូកទី៣ ច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ**

ផ្នែកទី១ បទប្បញ្ញត្តិទូទៅ

ផ្នែកទី២ ដំណើរឆ្លងកាត់

ផ្នែកទី៣ ការឆ្លងកាត់ដោយមិនបំពាន

**ជំពូកទី៤ បណ្តារដ្ឋប្រជុំកោះ**

**ជំពូកទី៥ តំបន់សេដ្ឋកិច្ចផ្តាច់មុខ**

**ជំពូកទី៦ តំបន់ខ្ពង់រាបបាតសមុទ្រ**

**ជំពូកទី៧ លម្ហសមុទ្រអន្តរជាតិ**

ផ្នែកទី១ បទប្បញ្ញត្តិទូទៅ

ផ្នែកទី២ កិច្ចអភិរក្សនិងការគ្រប់គ្រងធនធានមានជីវិតនៅលម្ហសមុទ្រអន្តរជាតិ

**ជំពូកទី៨ របបកោះ**

**ជំពូកទី៩ សមុទ្របិទឬពាក់កណ្តាលបិទ**

**ជំពូកទី១០ សិទ្ធិរបស់រដ្ឋមិនជាប់ឆ្នេរក្នុងការចេញ-ចូលសមុទ្រនិងសេរីភាពនៃការឆ្លងកាត់**

**ជំពូកទី១១ តំបន់បាតសមុទ្រអន្តរជាតិ**

ផ្នែកទី១ បទប្បញ្ញត្តិទូទៅ

ផ្នែកទី២ គោលការណ៍គ្រប់គ្រងតំបន់បាតសមុទ្រអន្តរជាតិ

ផ្នែកទី៣ ការអភិវឌ្ឍធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិ

ផ្នែកទី៤ អាជ្ញាធរបាតសមុទ្រអន្តរជាតិ

អនុផ្នែកទី១ បទប្បញ្ញត្តិទូទៅ
អនុផ្នែកទី២ សន្និបាត
អនុផ្នែកទី៣ ក្រុមប្រឹក្សា
អនុផ្នែកទី៤ លេខាធិការដ្ឋាន
អនុផ្នែកទី៥ សហគ្រាស
អនុផ្នែកទី៦ ផែនការហិរញ្ញវត្ថុរបស់អាជ្ញាធរ
អនុផ្នែកទី៧ ស្ថានភាពគតិយុត្តិបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ
អនុផ្នែកទី៨ ការផ្អាកការអនុវត្តសិទ្ធិ និងឯកសិទ្ធិរបស់សមាជិក
ផ្នែកទី៥ ការដោះស្រាយវិវាទនិងយោបល់ទីប្រឹក្សា
**ជំពូកទី១២ ការការពារនិងការអភិរក្សបរិស្ថានសមុទ្រ**
ផ្នែកទី១ បទប្បញ្ញត្តិទូទៅ
ផ្នែកទី២ កិច្ចសហប្រតិបត្តិជាសកលនិងតំបន់
ផ្នែកទី៣ ជំនួយបច្ចេកទេស
ផ្នែកទី៤ ការតាមដាននិងការវាយតម្លៃបរិស្ថាន
ផ្នែកទី៥ វិធានអន្តរជាតិនិងនីតិកម្មជាតិដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ
ផ្នែកទី៦ ការពង្រឹងច្បាប់
ផ្នែកទី៧ ការការពារ
ផ្នែកទី៨ តំបន់គ្របដណ្តប់ដោយទឹកកក
ផ្នែកទី៩ ការទទួលខុសត្រូវនិងបន្ទុក
ផ្នែកទី១០ អភ័យឯកសិទ្ធិអធិបតេយ្យ
ផ្នែកទី១១ កាតព្វកិច្ចក្រោមអនុសញ្ញាដទៃទៀត ស្តីពីការការពារ និងការថែរក្សាបរិស្ថានសមុទ្រ
**ជំពូកទី១៣ ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ**
ផ្នែកទី១ បទប្បញ្ញត្តិទូទៅ
ផ្នែកទី២ កិច្ចសហប្រតិបត្តិការអន្តរជាតិ
ផ្នែកទី៣ ការប្រតិបត្តិនិងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ
ផ្នែកទី៤ បបនាការឬបរិក្ខារស្រាវជ្រាវវិទ្យាសាស្ត្រនៅក្នុងបរិស្ថានសមុទ្រ
ផ្នែកទី៥ ការទទួលខុសត្រូវនិងបន្ទុក
ផ្នែកទី៦ ការដោះស្រាយវិវាទនិងវិធានការបណ្តោះអាសន្ន

**ជំពូកទី១៤ ការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រ**
ផ្នែកទី១ បទប្បញ្ញត្តិទូទៅ
ផ្នែកទី២ កិច្ចសហប្រតិបត្តិការអន្តរជាតិ
ផ្នែកទី៣ មជ្ឈមណ្ឌលថ្នាក់ជាតិនិងថ្នាក់តំបន់ដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអំពីសមុទ្រ
ផ្នែកទី៤ កិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការអន្តរជាតិ
**ជំពូកទី១៥ ការដោះស្រាយវិវាទ**
ផ្នែកទី១ បទប្បញ្ញត្តិទូទៅ
ផ្នែកទី២ នីតិវិធីចាប់បង្ខំដែលនាំឱ្យមានសេចក្តីសម្រេចចងកាតព្វកិច្ច
ផ្នែកទី៣ ការកម្រិតនិងអញ្ញត្រកម្មនៃការអនុវត្តផ្នែកទី២
**ជំពូកទី១៦ បទប្បញ្ញត្តិទូទៅ**
**ជំពូកទី១៧ អវសានប្បញ្ញត្តិ**
**ឧបសម្ព័ន្ធទី១ ប្រភេទត្រីផ្លាស់ទីឆ្ងាយ**
**ឧបសម្ព័ន្ធទី២ គណៈកម្មការកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្រ**
**ឧបសម្ព័ន្ធទី៣ លក្ខខណ្ឌមូលដ្ឋាននៃការធ្វើបុរេសនា ការស្វែងរុករក និងការធ្វើអាជីវកម្ម**
**ឧបសម្ព័នទី៤ លក្ខន្តិកៈរបស់សហគ្រាស**
**ឧបសម្ព័ន្ធទី៥ ការផ្សះផ្សា**
ផ្នែកទី១ នីតិវិធីផ្សះផ្សាអនុលោមតាមផ្នែកទី១ នៃជំពូកទី១៥
ផ្នែកទី២ លក្ខខណ្ឌត្រូវចូលរួមនីតិវិធីផ្សះផ្សា អនុលោមតាមផ្នែកទី៣ នៃជំពូកទី១៥
**ឧបសម្ព័ន្ធទី៦ លក្ខន្តិកៈតុលាការអន្តរជាតិនីតិសមុទ្រ**
ផ្នែកទី១ អង្គការចាត់តាំងតុលាការ
ផ្នែកទី២ សមត្ថកិច្ច
ផ្នែកទី៣ នីតិវិធី
ផ្នែកទី៤ អង្គជំនុំជម្រះវិវាទបាតសមុទ្រ
ផ្នែកទី៥ វិសោធនកម្ម
**ឧបសម្ព័ន្ធទី៧ មជ្ឈត្តការ**
**ឧបសម្ព័ន្ធទី៨ មជ្ឈត្តការពិសេស**
**ឧបសម្ព័ន្ធទី៩ ការចូលរួមរបស់អង្គការអន្តរជាតិ**

រដ្ឋទាំងឡាយដែលជាភាគីនៃអនុសញ្ញានេះ

ដោយចេតនាចង់ដោះស្រាយរាល់បញ្ហាទាំងអស់ ដែលពាក់ព័ន្ធដល់នីតិសមុទ្រប្រកបដោយស្មារតីនៃការយោគយល់គ្នា និងសហការគ្នាទៅវិញទៅមក និងការយល់ដឹងអំពីសារៈសំខាន់ជាប្រវត្តិសាស្ត្រនៃអនុសញ្ញានេះ ដែលជាការរួមចំណែកដ៏សំខាន់មួយក្នុងការថែរក្សានូវសន្តិភាព យុត្តិធម៌ និងវឌ្ឍនភាព សម្រាប់ប្រជាជនទាំងអស់នៃពិភពលោក

ដោយសម្គាល់ឃើញថា ការអភិវឌ្ឍចាប់តាំងពីសន្និសីទអង្គការសហប្រជាជាតិ ស្តីពីនីតិសមុទ្រ ដែលបានប្រព្រឹត្តទៅនៅទីក្រុងហ្សឺណែវ ក្នុងឆ្នាំ១៩៥៨និងឆ្នាំ១៩៦០ បានគូសបញ្ជាក់ពីសេចក្តីត្រូវការនូវអនុសញ្ញាស្តីពីនីតិសមុទ្រថ្មីមួយ និងដែលអាចទទួលយកបានជាទូទៅ

ដោយយល់ឃើញថា បញ្ហាលម្ហមហាសមុទ្រ ជាបញ្ហាដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅវិញទៅមក និងចាំបាច់ដែលត្រូវចាត់ទុកជាបញ្ហាសកលមួយ

ដោយទទួលស្គាល់នូវបំណងប្រាថ្នានៃការបង្កើតឡើងនូវរបបគតិយុត្តពាក់ព័ន្ធនឹងសមុទ្រនិងមហាសមុទ្រតាមរយៈអនុសញ្ញានេះជាមួយនឹងការគោរពដល់អធិបតេយ្យនៃរដ្ឋទាំងអស់ ដែលនឹងសម្រួលដល់ការប្រាស្រ័យទាក់ទងជាអន្តរជាតិ និងជំរុញការប្រើប្រាស់សមុទ្រនិងមហាសមុទ្រប្រកបដោយសន្តិភាព ការប្រើប្រាស់ធនធានសមុទ្រនិងមហាសមុទ្រប្រកបដោយសមធម៌ និងស័ក្តិសិទ្ធិភាព ការអភិរក្សធនធានមានជីវិត ព្រមទាំងការសិក្សា ការការពារ និងការអភិរក្សនូវបរិស្ថានសមុទ្រ

ដោយចងចាំថា ការសម្រេចបាននូវគោលដៅទាំងនេះ នឹងរួមចំណែកដល់សមិទ្ធកម្មនៃសណ្តាប់ធ្នាប់សេដ្ឋកិច្ចអន្តរជាតិ ប្រកបដោយយុត្តិធម៌និងសមធម៌ ដែលនឹងគិតគូរដល់ផលប្រយោជន៍និងសេចក្តីត្រូវការនៃរដ្ឋកំពុងអភិវឌ្ឍន៍ មិនថាជារដ្ឋជាប់ឆ្នេរសមុទ្រ ឬក៏រដ្ឋមិនជាប់សមុទ្រ

ដោយគោលបំណងរបស់អនុសញ្ញានេះ ចង់អភិវឌ្ឍនូវគោលការណ៍ទាំងឡាយ ដូចមានចែងក្នុងសេចក្តីសម្រេចលេខ២៧៤៩(XXV) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧០ ដែលក្នុងនោះមហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាសជាឱឡារិកថា តំបន់បាតសមុទ្រនិងផ្ទៃបាតមហាសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ ដែលហួសពីដែនយុត្តាធិការជាតិ ព្រមទាំងធនធានសមុទ្រ គឺជាមរតករួមរបស់មនុស្សជាតិ ដែលការស្វែងរុករកនិងការធ្វើអាជីវកម្មត្រូវធ្វើឡើងសម្រាប់ផលប្រយោជន៍របស់មនុស្សជាតិទាំងមូល ដោយមិនគិតពីទីតាំងភូមិសាស្ត្រនៃរដ្ឋណាមួយឡើយ

ដោយជឿជាក់ថា ក្រមនីយកម្ម និងការអភិវឌ្ឍជាលំដាប់នៃនីតិសមុទ្រ ដែលបានសម្រេចក្នុងអនុសញ្ញានេះ នឹងរួមចំណែកដល់ការពង្រឹងសន្តិភាព សន្តិសុខ កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមិត្តភាពក្នុងចំណោមប្រជាជាតិទាំងអស់ ដោយអនុលោមតាមគោលការណ៍យុត្តិធម៌និងសិទ្ធិស្មើគ្នា និងលើកកម្ពស់ការរីកចម្រើនផ្នែកសេដ្ឋកិច្ចនិងសង្គមនៃប្រជាជនទាំងអស់ក្នុងពិភពលោក ដោយអនុលោមតាមគោលបំណងនិងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ

ដោយអះអាងថា រាល់បញ្ហាទាំងឡាយដែលមិនមានបទប្បញ្ញត្តិដោយអនុសញ្ញានេះ នឹងបន្តគ្រប់គ្រងដោយវិធាននិងគោលការណ៍នៃនីតិអន្តរជាតិទូទៅ

បានព្រមព្រៀងគ្នាដូចខាងក្រោម៖

# ជំពូកទី១
# សេចក្តីផ្តើម
## មាត្រា១
## ការប្រើប្រាស់វាក្យសព្ទនិងវិសាលភាព

១. សម្រាប់គោលបំណងនៃអនុសញ្ញានេះ៖

(១)"តំបន់បាតសមុទ្រអន្តរជាតិ" សំដៅដល់ បាតសមុទ្រ និងផ្ទៃបាតមហាសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ ដែលហួសពីដែនយុត្តាធិការជាតិ។

(២) "អាជ្ញាធរ" សំដៅដល់ អាជ្ញាធរបាតសមុទ្រអន្តរជាតិ។

(៣) "សកម្មភាពក្នុងតំបន់បាតសមុទ្រអន្តរជាតិ" សំដៅដល់ រាល់សកម្មភាពស្វែងរុករក និងធ្វើអាជីវកម្មធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

(៤) "ការបំពុលបរិស្ថានសមុទ្រ" សំដៅដល់ ការបញ្ចេញសារធាតុឬថាមពលដោយមនុស្ស ដោយផ្ទាល់ ឬប្រយោលទៅក្នុងបរិស្ថានសមុទ្រ រាប់ទាំងដែសមុទ្រដែលបណ្តាលឬអាចបណ្តាលឱ្យមានផលបំផ្លិចបំផ្លាញដូចជាគ្រោះថ្នាក់ដល់ធនធានមានជីវិតនិងសត្វសមុទ្រ គ្រោះថ្នាក់ដល់សុខភាពមនុស្ស ផលរំខានដល់សកម្មភាពនៅសមុទ្រ ដែលរួមមានការនេសាទនិងការប្រើប្រាស់សមុទ្រស្របច្បាប់ដទៃទៀត ការធ្វើឱ្យការប្រើប្រាស់ទឹកសមុទ្របាត់បង់គុណភាព និងធ្វើឱ្យសោភណភាពសមុទ្រថយចុះ។

(៥) (ក) "ការបោះចោលសំណល់" សំដៅដល់៖

(i) ការបោះចោលសំណល់ឬវត្ថុដទៃទៀត ដោយចេតនាពីនាវា អាកាសយាន រចនាសម្ព័ន្ធបូមប្រេង ឬរចនាសម្ព័ន្ធដទៃទៀតដែលមនុស្សបង្កើតនៅសមុទ្រ។

(ii) ការបោះចោលនាវា អាកាសយាន ទីតាំងបូមប្រេង ឬរចនាសម្ព័ន្ធដទៃទៀតដែលមនុស្សបង្កើតឡើងនៅសមុទ្រដោយចេតនា។

(ខ) "ការបោះចោលសំណល់" មិនរាប់បញ្ចូល៖

(i) ការបោះចោលសំណល់ឬវត្ថុធាតុដទៃទៀត ដោយសារតែឬកើតចេញពីប្រតិបត្តិការជាធម្មតារបស់នាវា អាកាសយាន ទីតាំងបូមប្រេង ឬរចនាសម្ព័ន្ធដទៃទៀតដែលមនុស្សបង្កើតឡើងនៅសមុទ្រ និងគ្រឿងបរិក្ខាររបស់នាវា អាកាសយាន ទីតាំងបូមប្រេង ឬរចនាសម្ព័ន្ធដែលមនុស្សបង្កើតឡើងដទៃទៀតដោយអចេតនា លើកលែងកាកសំណល់ឬវត្ថុធាតុដទៃទៀតដែលដឹកជញ្ជូនដោយឬទៅកាន់នាវា អាកាសយាន ទីតាំងបូមប្រេង ឬរចនាសម្ព័ន្ធដែលមនុស្សបង្កើតឡើងដទៃទៀតនៅសមុទ្រ ដែលធ្វើប្រតិបត្តិការបោះចោលវត្ថុធាតុនោះ ឬនៅក្នុងប្រតិបត្តិការសម្អាតកាកសំណល់ឬវត្ថុធាតុដទៃទៀតនៅលើនាវា អាកាសយាន ទីតាំងបូមប្រេង ឬរចនាសម្ព័ន្ធដែលមនុស្សបង្កើតឡើងដទៃទៀត។

(ii)ការទុកដាក់វត្ថុធាតុដើមក្នុងគោលបំណងណាមួយ ក្រៅពីគោលបំណងបោះចោលដរាបណាការទុកដាក់នោះ មិនផ្ទុយនឹងអនុសញ្ញានេះ។

២. (១) "រដ្ឋភាគី" សំដៅដល់ រដ្ឋដែលបានយល់ព្រមចងកាតព្វកិច្ចក្រោមអនុសញ្ញានេះ ហើយដែលអនុសញ្ញានេះចូលជាធរមានសម្រាប់រដ្ឋនោះ។

(២) អនុសញ្ញា ត្រូវយកមកអនុវត្តដូចគ្នាលើនីតិបុគ្គល ដូចមានចែងក្នុងមាត្រា៣០៥ កថាខណ្ឌទី១ (ខ) (គ) (ឃ) (ង) និង(ច)ដែលជាភាគីនៃអនុសញ្ញានេះអនុលោមតាមលក្ខខណ្ឌ ពាក់ព័ន្ធនឹងនីតិបុគ្គលនីមួយៗ និងក្នុងកម្រិតដែល "រដ្ឋភាគី" សំដៅលើនីតិបុគ្គលទាំងនោះ។

# ជំពូកទី២
# សមុទ្រដែនដីនិងតំបន់ជាប់

## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា២
### លក្ខន្តិកៈគតិយុត្តនៃសមុទ្រដែនដី ដែនអាកាសលើសមុទ្រដែនដី និងផ្ទៃបាតមហាសមុទ្រនិងដីក្រោមបាតសមុទ្រ

១. អធិបតេយ្យរបស់រដ្ឋជាប់ឆ្នេរសមុទ្រ លាតសន្ធឹងហួសពីដីគោក និងដែនទឹកផ្ទៃក្នុងរបស់ខ្លួន ហើយក្នុងករណីជារដ្ឋប្រជុំកោះ លាតសន្ធឹងហួសពីផ្ទៃទឹកប្រជុំកោះរបស់រដ្ឋ រហូតដល់ខ្សែក្រវាត់សមុទ្រជាប់គ្នា ដែលហៅថាសមុទ្រដែនដី។

២. អធិបតេយ្យនេះលាតសន្ធឹងដល់ដែនអាកាសលើសមុទ្រដែនដី ព្រមទាំងដល់បាតនិងស្រទាប់ដីក្រោមបាតសមុទ្ររបស់ខ្លួនផងដែរ។

៣. អធិបតេយ្យលើសមុទ្រដែនដី ត្រូវបានអនុវត្តដោយអនុលោមតាមអនុសញ្ញានេះ និងវិធានដទៃទៀតនៃនីតិអន្តរជាតិ។

## ផ្នែកទី២
## ដែនកំណត់នៃសមុទ្រដែនដី

### មាត្រា៣
### ប្រវែងទទឹងនៃសមុទ្រដែនដី

រដ្ឋទាំងអស់មានសិទ្ធិបង្កើតប្រវែងទទឹងនៃសមុទ្រដែនដីរបស់ខ្លួន រហូតដល់ដែនកំណត់មួយ ដែលមិនលើសពីចម្ងាយ១២ ម៉ែល៍សមុទ្រ ដែលវាស់ចេញពីខ្សែបន្ទាត់មូលដ្ឋាន ដែលបានកំណត់ដោយអនុលោមតាមអនុសញ្ញានេះ។

### មាត្រា៤
### ដែនកំណត់ព្រំដែនខាងក្រៅនៃសមុទ្រដែនដី

ដែនកំណត់ព្រំដែនខាងក្រៅនៃសមុទ្រដែនដី គឺជាខ្សែបន្ទាត់ដែលរាល់ចំណុចលើខ្សែបន្ទាត់នោះស្ថិតក្នុងចម្ងាយពីចំណុចជិតបំផុតនៃខ្សែបន្ទាត់មូលដ្ឋាន ដែលស្មើនឹងប្រវែងទទឹងនៃសមុទ្រដែនដី។

## មាត្រា៥
## ខ្សែបន្ទាត់មូលដ្ឋានធម្មតា

លើកលែងតែមានចែងផ្ទុយក្នុងអនុសញ្ញានេះ ខ្សែបន្ទាត់មូលដ្ឋានធម្មតាសម្រាប់វាស់ប្រវែងទទឹងនៃសមុទ្រដែនដី គឺខ្សែបន្ទាត់ទឹកនាចនៅតាមបណ្ដោយឆ្នេរសមុទ្រ ដូចដែលមានគូសនៅលើផែនទីសមុទ្រខ្នាតធំ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការដោយរដ្ឋជាប់ឆ្នេរសមុទ្រ។

## មាត្រា៦
## ថ្មប៉ប្រះទឹក

ក្នុងករណីកោះស្ថិតលើកោះផ្កាថ្ម ឬកោះដែលមានថ្មប៉ប្រះទឹក ខ្សែបន្ទាត់មូលដ្ឋានសម្រាប់វាស់ប្រវែងទទឹងនៃសមុទ្រដែនដី គឺខ្សែបន្ទាត់ទឹកនាចខាងសមុទ្រនៃថ្មប៉ប្រះទឹក ដូចដែលបង្ហាញដោយសញ្ញាសម្គាល់សមស្រប នៅលើផែនទីសមុទ្រ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការដោយរដ្ឋជាប់ឆ្នេរសមុទ្រ។

## មាត្រា៧
## ខ្សែបន្ទាត់មូលដ្ឋានត្រង់

១. នៅកន្លែងដែលខ្សែបន្ទាត់ឆ្នេរសមុទ្រចូលជ្រៅ និងស៊ីចូលក្នុង ឬប្រសិនបើមានកោះរាយប៉ាយ តាមឆ្នេរសមុទ្រក្នុងតំបន់ជាប់ក្បែរឆ្នេរ វិធីសាស្ត្រនៃខ្សែបន្ទាត់មូលដ្ឋានត្រង់ តភ្ជាប់ចំណុចសមស្របអាចត្រូវបានប្រើក្នុងការគូសខ្សែបន្ទាត់មូលដ្ឋាន ដែលពីចំណុចនោះប្រវែងទទឹងនៃសមុទ្រដែនដីត្រូវបានវាស់វែង។

២. ក្នុងករណីដីសណ្ដ និងស្ថានភាពធម្មជាតិដទៃទៀត ខ្សែបន្ទាត់ឆ្នេរសមុទ្រមានលក្ខណៈលម្អៀងខ្លាំង ចំណុចសមស្របអាចត្រូវបានជ្រើសយកតាមចំណុចឆ្ងាយបំផុតទៅសមុទ្រនៃខ្សែបន្ទាត់ទឹកនាច និងបើទោះបីជាខ្សែបន្ទាត់ទឹកនាចថយមកកន្លែងដើមវិញក៏ដោយ ក៏ខ្សែបន្ទាត់មូលដ្ឋានត្រង់នៅតែមានប្រសិទ្ធភាព រហូតទាល់តែមានការផ្លាស់ប្ដូរដោយរដ្ឋជាប់ឆ្នេរសមុទ្រ ដោយអនុលោមតាមអនុសញ្ញានេះ។

៣. ការគូសខ្សែបន្ទាត់មូលដ្ឋានត្រង់មិនត្រូវឆ្ពោះទៅចំណុចជាក់លាក់ណាមួយដែលងាកចេញពីទិសដៅទូទៅនៃឆ្នេរសមុទ្រ ហើយតំបន់សមុទ្រដែលស្ថិតក្នុងខ្សែបន្ទាត់មូលដ្ឋានត្រង់ ត្រូវតែភ្ជាប់ក្បែរគ្នាច្បាស់លាស់ទៅនឹងដីគោក ដែលស្ថិតនៅក្រោមរបបនៃដែនទឹកផ្ទៃក្នុង។

៤. ខ្សែបន្ទាត់មូលដ្ឋានត្រង់ មិនត្រូវគូសឆ្ពោះទៅឬចេញពីដីដុះ ប្រសិនបើគ្មានប៉មបំភ្លឺ ឬបរិក្ខារមានលក្ខណៈស្រដៀងគ្នាដែលនៅខ្ពស់ជាងកម្ពស់ទឹកសមុទ្រជាអចិន្ត្រៃយ៍ ត្រូវបានសាងសង់ឡើងនៅលើដីដុះនោះទេ ឬលើកលែងករណីដែលការគូសខ្សែបន្ទាត់មូលដ្ឋានឆ្ពោះទៅ/ចេញពីដីដុះបានទទួលការទទួលស្គាល់ទូទៅនិងជាអន្តរជាតិ។

៥. នៅក្នុងករណីដែលវិធីសាស្ត្រគូសខ្សែបន្ទាត់មូលដ្ឋានត្រង់ អាចអនុវត្តបានតាមកថាខណ្ឌទី១ ក្នុងការកំណត់ខ្សែបន្ទាត់មូលដ្ឋានណាមួយ អាចត្រូវពិចារណាលើផលប្រយោជន៍សេដ្ឋកិច្ចពិសេសចំពោះតំបន់ពាក់ព័ន្ធ ភាពពិតជាក់ស្ដែងនិងសារៈសំខាន់នៃផលប្រយោជន៍សេដ្ឋកិច្ច ដែលត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈការប្រើប្រាស់ជាយូរមកហើយ។

៦. ប្រព័ន្ធខ្សែបន្ទាត់មូលដ្ឋានត្រង់ មិនអាចត្រូវបានយកមកអនុវត្តដោយរដ្ឋណាមួយ ក្នុងលក្ខណៈដែលនាំឱ្យកាត់ផ្ដាច់សមុទ្រដែនដីរបស់រដ្ឋមួយទៀតពីសមុទ្រអន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្ដាច់មុខឡើយ។

## មាត្រា៨

## ដែនទឹកផ្ទៃក្នុង

១. លើកលែងតែមានចែងក្នុងជំពូកទី៤ ផ្ទៃទឹកទៅខាងដីគោកនៃខ្សែបន្ទាត់មូលដ្ឋាននៃសមុទ្រដែនដី គឺជាផ្នែកនៃដែនទឹកផ្ទៃក្នុងរបស់រដ្ឋ។

២. ក្នុងករណីដែលការកំណត់ខ្សែបន្ទាត់មូលដ្ឋានត្រង់ ដោយអនុលោមតាមវិធីសាស្ត្រដូចមានចែងក្នុងមាត្រា៧ មានអានុភាពបង្កើតជាតំបន់ដែនទឹកផ្ទៃក្នុង ដែលពីមុនមិនត្រូវបានចាត់ទុកបែបនេះ សិទ្ធិឆ្លងកាត់ដោយមិនបំពាន ដូចមានចែងក្នុងអនុសញ្ញានេះ នៅតែមានអត្ថិភាពក្នុងដែនទឹកនោះ។

## មាត្រា៩

## មាត់ច្រកនៃទន្លេ

ប្រសិនបើទន្លេមួយហូរផ្ទាល់ចូលទៅក្នុងសមុទ្រ ខ្សែបន្ទាត់មូលដ្ឋានត្រូវតែជាខ្សែបន្ទាត់ត្រង់កាត់មាត់ច្រកនៃទន្លេ តភ្ជាប់រវាងចំណុចនានាលើខ្សែបន្ទាត់ទឹកនាចនៃច្រាំងទន្លេនោះ។

## មាត្រា១០

## ឆកសមុទ្រ

១. មាត្រានេះទាក់ទងតែឆកសមុទ្រ ដែលឆ្នេរនៃឆកសមុទ្រនេះ ជាកម្មសិទ្ធិរបស់រដ្ឋមួយ។

២. ក្នុងគោលបំណងនៃអនុសញ្ញានេះ ឆកសមុទ្រ គឺជាកន្លែងផតដែលមើលឃើញច្បាស់ដោយផ្នែកលយចូលទៅដីគោក សមាមាត្រទៅនឹងទទឹងនៃមាត់ច្រកនៃឆកសមុទ្រនោះ បង្កើតបានជាផ្ទៃទឹកព័ទ្ធដោយដីគោក និងបង្កើតជាកំណោងខ្លាំងនៃឆ្នេរសមុទ្រ។ ប៉ុន្តែកន្លែងផតនេះ មិនត្រូវចាត់ទុកជាឆកសមុទ្រទេ ប្រសិនបើផ្ទៃរបស់វាមានទំហំស្មើ ឬធំជាងពាក់កណ្តាលរង្វង់ ដែលមានអង្កត់ផ្ចិតជាខ្សែបន្ទាត់គូសកាត់មាត់ច្រកនៃកន្លែងផតនោះ។

៣. ក្នុងគោលបំណងនៃការវាស់វែង ផ្ទៃនៃកន្លែងផត ត្រូវលាតសន្ធឹងចន្លោះចំណុចទឹកនាចជុំវិញច្រាំងនៃកន្លែងផតនោះ និងខ្សែបន្ទាត់តភ្ជាប់ចំណុចទឹកនាច នៃច្រកចូលធម្មជាតិរបស់វា។ ក្នុងករណីដែលកន្លែងផត មានមាត់ច្រើនដោយសារវត្តមានកោះ ពាក់កណ្តាលរង្វង់ត្រូវគូសលើខ្សែបន្ទាត់ ដែលមានប្រវែងស្មើនឹងប្រវែងសរុប នៃខ្សែបន្ទាត់កាត់មាត់ផ្សេងៗគ្នា។ កោះក្នុងកន្លែងផត ត្រូវបានរាប់បញ្ចូលដូចជាផ្នែកនៃដែនទឹកនៃកន្លែងដែលផតចូលនោះ។

៤. ប្រសិនបើចម្ងាយរវាងចំណុចទឹកនាចនៃច្រកចូលធម្មជាតិរបស់ឆកសមុទ្រ មិនលើសពី២៤ ម៉ៃល៍សមុទ្រនោះទេ ខ្សែបន្ទាត់បិទអាចត្រូវបានគូសរវាងចំណុចទឹកនាចពីរ ហើយផ្ទៃទឹកដែលហ៊ុមព័ទ្ធដោយខ្សែនោះ ត្រូវចាត់ទុកជា ដែនទឹកផ្ទៃក្នុង។

៥. នៅពេលចម្ងាយរវាងចំណុចទឹកនាចនៃច្រកចូលធម្មជាតិរបស់ឆកសមុទ្រ លើសពី២៤ ម៉ៃល៍សមុទ្រ ខ្សែបន្ទាត់មូលដ្ឋានត្រង់ដែលមានប្រវែង២៤ ម៉ៃល៍សមុទ្រ ត្រូវបានគូសក្នុងឆកសមុទ្រ ដោយធ្វើយ៉ាងណាដើម្បីព័ទ្ធបញ្ចូលផ្ទៃទឹកអតិបរមា ដែលអាចធ្វើទៅបានជាមួយនឹងប្រវែងខ្សែបន្ទាត់នោះ។

៦. បទប្បញ្ញត្តិខាងលើមិនត្រូវយកមកអនុវត្តចំពោះឆកសមុទ្រ ដែលហៅថា ឆកសមុទ្រ"ប្រវត្តិសាស្ត្រ" នោះទេ ឬក្នុងករណីដែលប្រព័ន្ធខ្សែបន្ទាត់មូលដ្ឋានត្រង់ដូចមានចែងក្នុងមាត្រា៧ ត្រូវបានយកមកអនុវត្ត។

## មាត្រា១១
## កំពង់ផែ

ក្នុងគោលបំណងកំណត់ព្រំដែននៃសមុទ្រដែនដី សកម្មភាពការងារទីសំចតអចិន្ត្រៃយ៍ផ្នែកក្រៅបំផុត ដែលបង្កើតជាផ្នែកសំខាន់នៃប្រព័ន្ធទីសំចត ត្រូវចាត់ទុកជាផ្នែកដែលបានបង្កើតឡើងនៃឆ្នេរសមុទ្រ។ ឋបនាការនៅឆ្ងាយពីឆ្នេរសមុទ្រនិងកោះសិប្បនិម្មិត មិនត្រូវចាត់ទុកជាសកម្មភាពការងារទីសំចតអចិន្ត្រៃយ៍ទេ។

## មាត្រា១២
## ផ្លូវចំណតនាវា

ព្រំដែនផ្លូវចំណតនាវាដែលជាទូទៅប្រើសម្រាប់ផ្ទេរផ្ទុក លើកដាក់ទំនិញ និងបោះយុថ្កានាវា និងស្ថិតនៅខាងក្រៅចំណុចចុងបំផុតនៃសមុទ្រដែនដី ត្រូវចាត់ទុកថាជាផ្នែកនៃសមុទ្រដែនដី។

## មាត្រា១៣
## ដីដុះ

១. ដីដុះ ជាផ្ទៃដីដែលកកើតឡើងដោយធម្មជាតិ ហ៊ុមព័ទ្ធដោយ និងមើលឃើញនៅពេលទឹកនាច ប៉ុន្តែលិចទៅវិញនៅពេលទឹកជោរ។ នៅពេលផ្នែកទាំងមូលឬផ្នែកណាមួយនៃដីដុះ ស្ថិតនៅចម្ងាយមិនលើសពីប្រវែងទទឹងនៃសមុទ្រដែនដី ដែលគិតពីដីគោកឬកោះ ខ្សែបន្ទាត់ទឹកនាចនៅលើដីដុះ អាចយកមកប្រើជាខ្សែបន្ទាត់មូលដ្ឋានដើម្បីវាស់ប្រវែងទទឹងនៃសមុទ្រដែនដីបាន។

២. នៅពេលដីដុះទាំងមូលស្ថិតនៅចម្ងាយឆ្ងាយជាងប្រវែងទទឹងនៃសមុទ្រដែនដីគិតពីដីគោកឬកោះ ដីដុះមិនមានសមុទ្រដែនដីរបស់ខ្លួនទេ។

## មាត្រា១៤
## វិធីសាស្ត្របញ្ចូលគ្នាសម្រាប់កំណត់ខ្សែបន្ទាត់មូលដ្ឋាន

រដ្ឋជាប់ឆ្នេរសមុទ្រ អាចកំណត់ខ្សែបន្ទាត់មូលដ្ឋានដោយវិធីសាស្ត្រណាមួយបន្តបន្ទាប់គ្នា ដូចមានចែងក្នុងមាត្រាខាងលើ ដើម្បីឆ្លើយតបទៅតាមលក្ខខណ្ឌផ្សេងៗគ្នា។

## មាត្រា១៥
## ការកំណត់ព្រំដែននៃសមុទ្រដែនដីរវាងរដ្ឋដែលមានឆ្នេរសមុទ្រទល់មុខគ្នាឬជាប់គ្នា

ក្នុងករណីដែលឆ្នេរសមុទ្ររបស់រដ្ឋពីរទល់មុខគ្នាឬជាប់គ្នា ប្រសិនបើគ្មានការព្រមព្រៀងផ្ទុយរវាងរដ្ឋទាំងពីរនោះទេ គ្មានរដ្ឋណាមួយមានសិទ្ធិពង្រីកសមុទ្រដែនដី ហួសពីចំណុចខ្សែមេដ្យាន ដែលរាល់ចម្ងាយស្មើគ្នាពីចំណុចជិតបំផុតលើខ្សែបន្ទាត់មូលដ្ឋាន ដែលប្រវែងទទឹងនៃសមុទ្រដែនដីនីមួយៗនៃរដ្ឋទាំងពីរ ត្រូវបានវាស់វែង។ ក៏ប៉ុន្តែបទប្បញ្ញត្តិខាងលើ មិនត្រូវយកមកអនុវត្តឡើយ ដោយឈរលើមូលហេតុកម្មសិទ្ធិជាប្រវត្តិសាស្ត្រឬកាលៈទេសៈពិសេសដទៃទៀត ក្នុងករណីចាំបាច់ ត្រូវកំណត់ព្រំដែនសមុទ្រដែនដីរបស់រដ្ឋទាំងពីរ ក្នុងរបៀបផ្សេងៗគ្នាទៅតាមកាលៈទេសៈទាំងនោះ។

## មាត្រា១៦

## ផែនទីសមុទ្រនិងបញ្ជីនិយាមកាភូមិសាស្ត្រ

១. ខ្សែបន្ទាត់មូលដ្ឋានសម្រាប់វាស់ប្រវែងទទឹងនៃសមុទ្រដែនដី ដោយអនុលោមតាមមាត្រា៧ មាត្រា៩ និងមាត្រា១០ ឬដែនកំណត់ដែលបានមកពីការវាស់នោះ និងខ្សែបន្ទាត់ព្រំដែនដែលគូសដោយអនុលោមតាមមាត្រា១២ និងមាត្រា១៥ ត្រូវបានបង្ហាញលើផែនទីសមុទ្រ ដែលមានមាត្រដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីទីតាំងទាំងនោះ។ ជាជម្រើសមួយទៀត បញ្ជីនិយាមកាភូមិសាស្ត្រនៃចំណុចនានាដែលបញ្ជាក់អំពីប្រព័ន្ធទិន្នន័យប្រឹថពីវិភាគ អាចយកមកប្រើជំនួសបាន។

២. រដ្ឋជាប់ឆ្នេរសមុទ្រ ត្រូវធ្វើការផ្សព្វផ្សាយអំពីផែនទីសមុទ្រឬបញ្ជីនិយាមកាភូមិសាស្ត្រឱ្យបានត្រឹមត្រូវ ហើយត្រូវតម្កល់ច្បាប់ចម្លងនៃផែនទីសមុទ្រឬបញ្ជីនោះមួយច្បាប់ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

# ផ្នែកទី៣

# ការឆ្លងកាត់ដោយមិនបំពានក្នុងសមុទ្រដែនដី

## អនុផ្នែកទី១

## វិធានអនុវត្តចំពោះនាវាគ្រប់ប្រភេទ

## មាត្រា១៧

## សិទ្ធិឆ្លងកាត់ដោយមិនបំពាន

ដោយអនុលោមតាមអនុសញ្ញានេះ នាវានៃរដ្ឋទាំងអស់ ទោះរដ្ឋជាប់ឆ្នេរសមុទ្រ ឬរដ្ឋមិនជាប់ឆ្នេរសមុទ្រ ត្រូវទទួលបានសិទ្ធិឆ្លងកាត់ដោយមិនបំពានតាមសមុទ្រដែនដី។

## មាត្រា១៨

## អត្ថន័យនៃការឆ្លងកាត់

១. ការឆ្លងកាត់សំដៅដល់ការធ្វើនាវាចរណ៍ឆ្លងកាត់សមុទ្រដែនដី ក្នុងគោលបំណង៖

(ក) ឆ្លងកាត់សមុទ្រដែនដីនោះ ដោយមិនចូលដែនទឹកផ្ទៃក្នុង ឬបោះយុថ្កានៅផ្លូវចំណតនាវា ឬបបនីយកណ្ឌផែ ដែលនៅខាងក្រៅដែនទឹកផ្ទៃក្នុង ឬ

(ខ) ចូលក្នុងឬចេញពីដែនទឹកផ្ទៃក្នុង ឬបោះយុថ្កានៅផ្លូវចំណតនាវា ឬបបនីយកណ្ឌផែ។

២. ការឆ្លងកាត់ត្រូវធ្វើឡើងដោយបន្តឥតបង្អង់និងដោយឆាប់រហ័ស។ បើទោះបីជាមានចែងដូចនេះក្តី ការឆ្លងកាត់នេះអាចឈប់ឬបោះយុថ្កាបាន ក្នុងករណីដែលនាវានោះជួបឧប្បត្តិហេតុដោយករណីប្រធានសក្តិឬគ្រាអាសន្ន ឬក្នុងគោលបំណងផ្តល់ជំនួយសង្គ្រោះជីវិតមនុស្ស នាវា ឬអាកាសយានដែលកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ឬគ្រាអាសន្ន។

## មាត្រា១៩

## អត្ថន័យនៃការឆ្លងកាត់ដោយមិនបំពាន

១. ការឆ្លងកាត់ដោយមិនបំពានដរាបណាវាមិនប៉ះពាល់ដល់សន្តិភាព សណ្តាប់ធ្នាប់ល្អ ឬសន្តិសុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រនោះឡើយ។ ការឆ្លងកាត់នេះត្រូវធ្វើឡើងដោយអនុលោមតាមអនុសញ្ញានេះ និងវិធានដទៃទៀតនៃច្បាប់អន្តរជាតិ។

២. ការឆ្លងកាត់របស់នាវាបរទេស ត្រូវចាត់ទុកថាប៉ះពាល់ដល់សន្តិភាព សណ្តាប់ធ្នាប់ល្អ ឬសន្តិសុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ប្រសិនបើនៅក្នុងសមុទ្រដែនដី នាវាបរទេសនោះធ្វើសកម្មភាព ដូចខាងក្រោម៖

(ក) គំរាមកំហែងឬប្រើប្រាស់កម្លាំងប្រឆាំងនឹងអធិបតេយ្យ បូរណភាពទឹកដី ឬឯករាជ្យភាពនយោបាយរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ឬរបៀបផ្សេងទៀតដែលរំលោភគោលការណ៍នីតិអន្តរជាតិ ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ។

(ខ) ការធ្វើសមយុទ្ធឬហ្វឹកហ្វឺនដោយប្រើប្រាស់អាវុធប្រភេទណាក៏ដោយ។

(គ) សកម្មភាពណាមួយ ដែលមានគោលបំណងប្រមូលព័ត៌មាន ដែលប៉ះពាល់ដល់វិស័យការពារជាតិ ឬសន្តិសុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ឃ) សកម្មភាពឃោសនាដែលមានចេតនាធ្វើឱ្យប៉ះពាល់ដល់វិស័យការពារជាតិ ឬសន្តិសុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ង) ការបង្ហោះ ចុះចត ឬទទួលផ្ទុកអាកាសយាន។

(ច) ការបង្ហោះ ចុះចត ឬទទួលផ្ទុកយុទ្ធោបករណ៍ ។

(ឆ) ការផ្ទេរផ្ទុក ឬលើកដាក់ទំនិញ រូបិយវត្ថុ ឬបុគ្គលល្មើសច្បាប់ និងបទបញ្ញា ស្តីពីគយ សារពើពន្ធ អន្តោប្រវេសន៍ ឬអនាម័យរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ជ) សកម្មភាពបំពុលធ្ងន់ធ្ងរ និងដោយចេតនា ដែលផ្ទុយនឹងអនុសញ្ញានេះ។

(ឈ) សកម្មភាពនេសាទ។

(ញ) ការធ្វើសកម្មភាពស្រាវជ្រាវ ឬប្រមូលទិន្នន័យ។

(ដ) សកម្មភាពដែលមានគោលបំណងជ្រៀតជ្រែកចូលប្រព័ន្ធទំនាក់ទំនង ឬឋបនីយកណ្ឌ ឬឋបនាការមូលដ្ឋានដទៃទៀតរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ឋ) សកម្មភាពដទៃទៀតដែលមិនមានទំនាក់ទំនងផ្ទាល់ដល់ការឆ្លងកាត់។

## មាត្រា២០

## នាវាមុជទឹក និងយានក្រោមទឹកដទៃទៀត

ក្នុងសមុទ្រដែនដី នាវាមុជទឹកនិងយានក្រោមទឹកដទៃទៀត ត្រូវធ្វើនាវាចរណ៍នៅលើផ្ទៃទឹក និងត្រូវបង្ហាញទង់ជាតិរបស់ខ្លួន។

## មាត្រា២១

## ច្បាប់និងបទបញ្ញានានារបស់រដ្ឋជាប់ឆ្នេរសមុទ្រទាក់ទងនឹងការឆ្លងកាត់ដោយមិនបំពាន

១. រដ្ឋជាប់ឆ្នេរសមុទ្រ អាចអនុម័តច្បាប់និងបទបញ្ញាដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ និងវិធានដទៃទៀតនៃនីតិអន្តរជាតិ ទាក់ទងនឹងការឆ្លងកាត់សមុទ្រដែនដីដោយមិនបំពាន ទាក់ទងនឹងចំណុចណាមួយ ឬទាំងអស់ ដូចខាងក្រោម៖

(ក) សុវត្ថិភាពនៃការធ្វើនាវាចរណ៍និងបទបញ្ញាធ្វើចរាចរណ៍លើផ្ទៃសមុទ្រ។

(ខ) ការការពារឋបនីយកណ្ឌ និងសញ្ញាជំនួយនាវាចរណ៍ និងឋបនីយកណ្ឌផ្សេងទៀត ឬឋបនាការដទៃទៀត។

(គ) ការការពារខ្សែកាបនិងបំពង់បង្ហូរ។

(ឃ) ការអភិរក្សធនធានមានជីវិតក្នុងសមុទ្រ។

(ង) ការបង្ការការរំលោភបំពានលើច្បាប់និងបទបញ្ញាជលផលរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ច) ការថែរក្សាបរិស្ថានរបស់រដ្ឋជាប់ឆ្នេរសមុទ្រ និងការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថាន។

(ឆ) ការស្រាវជ្រាវក្នុងសមុទ្រជាលក្ខណៈវិទ្យាសាស្ត្រ និងការប្រមូលទិន្នន័យបែបជលសាស្ត្រ។

(ជ) ការបង្ការការរំលោភបំពានលើច្បាប់និងបទបញ្ញា ស្តីពីគយ សារពើពន្ធ អន្តោប្រវេសន៍ ឬអនាម័យរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

២. ច្បាប់និងបទបញ្ញាទាំងនេះ មិនត្រូវអនុវត្តចំពោះប្លង់ ការសាងសង់ ការដាក់មនុស្សធ្វើការ ឬគ្រឿងបរិក្ខារនៃនាវាបរទេសទេ ប្រសិនបើច្បាប់និងបទបញ្ញានោះ មិនមានអានុភាពដល់វិធានឬស្តង់ដា ដែលត្រូវបានទទួលយកជាលក្ខណៈអន្តរជាតិ។

៣. រដ្ឋជាប់ឆ្នេរសមុទ្រ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានសមស្របនូវរាល់ច្បាប់និងបទបញ្ញាទាំងអស់នោះ។

៤. នាវាបរទេសដែលប្រើប្រាស់សិទ្ធិឆ្លងកាត់សមុទ្រដែនដីដោយមិនបំពាន ត្រូវគោរពតាមច្បាប់និងបទបញ្ញាទាំងអស់នោះ ព្រមទាំងបទប្បញ្ញត្តិទាំងអស់ ដែលត្រូវបានទទួលយកជាលក្ខណៈអន្តរជាតិទាក់ទងនឹងការបង្ការការប៉ះទង្គិចគ្នានៅសមុទ្រ។

## មាត្រា២២

## គន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ក្នុងសមុទ្រដែនដី

១. ក្នុងករណីចាំបាច់ទាក់ទងនឹងសុវត្ថិភាពធ្វើនាវាចរណ៍ រដ្ឋជាប់ឆ្នេរសមុទ្រអាចតម្រូវឱ្យនាវាបរទេសដែលប្រើប្រាស់សិទ្ធិឆ្លងកាត់សមុទ្រដែនដីដោយមិនបំពាន ត្រូវប្រើប្រាស់គន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ដែលខ្លួនអាចកំណត់ឬដាក់ចេញ ដើម្បីគ្រប់គ្រងលើការឆ្លងកាត់របស់នាវានោះ។

២. ជាពិសេស នាវាដឹកប្រេង នាវាប្រើថាមពលនុយក្លេអ៊ែរ និងនាវាដែលដឹកសារធាតុនុយក្លេអ៊ែរ ឬសារធាតុឬវត្ថុធាតុដទៃទៀតដែលបង្កគ្រោះថ្នាក់និងមានជាតិពុល អាចតម្រូវឱ្យរក្សាការឆ្លងកាត់របស់ខ្លួនតាមគន្លងផ្លូវសមុទ្រនេះ។

៣. ក្នុងការកំណត់គន្លងផ្លូវសមុទ្រនិងបង្កាប់គន្លងបែងចែកចរាចរណ៍តាមមាត្រានេះ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវពិចារណា៖

(ក) អនុសាសន៍របស់ស្ថាប័នអន្តរជាតិមានសមត្ថកិច្ច។

(ខ) ព្រែកដែលជាធម្មតាប្រើសម្រាប់ការធ្វើនាវាចរណ៍អន្តរជាតិ។

(គ) បច្ចេកលក្ខណៈពិសេសរបស់នាវា និងព្រែក។ និង

(ឃ) ដង់ស៊ីតេចរាចរណ៍។

៤. រដ្ឋជាប់ឆ្នេរសមុទ្រ ត្រូវចង្អុលបង្ហាញនូវគន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ឱ្យបានច្បាស់លាស់លើផែនទីដែលត្រូវផ្សព្វផ្សាយជាសាធារណៈ។

## មាត្រា២៣
## នាវាបរទេសប្រើថាមពលនុយក្លេអ៊ែរនិងនាវាដែលដឹកសារធាតុនុយក្លេអ៊ែរ ឬសារធាតុដទៃទៀតដែលបង្កគ្រោះថ្នាក់និងមានជាតិពុល

នៅពេលប្រើប្រាស់សិទ្ធិឆ្លងកាត់សមុទ្រដែនដីដោយមិនបំពាន នាវាបរទេសដែលប្រើថាមពលនុយក្លេអ៊ែរ និងនាវាដែលដឹកសារធាតុនុយក្លេអ៊ែរឬសារធាតុដទៃទៀតដែលបង្កគ្រោះថ្នាក់និងមានជាតិពុល ត្រូវមានឯកសារ និងគោរពវិធានការប្រុងប្រយ័ត្នពិសេសដែលចែងសម្រាប់នាវានោះ ដោយកិច្ចព្រមព្រៀងអន្តរជាតិ។

## មាត្រា២៤
## ករណីយកិច្ចរបស់រដ្ឋជាប់ឆ្នេរសមុទ្រ

១. រដ្ឋជាប់ឆ្នេរសមុទ្រ មិនត្រូវរារាំងការឆ្លងកាត់សមុទ្រដែនដីដោយមិនបំពានរបស់នាវាសមុទ្រ លើកលែងតែអនុលោមតាមអនុសញ្ញានេះ។ ជាពិសេស ក្នុងការអនុវត្តអនុសញ្ញានេះ ឬច្បាប់ និងបទបញ្ញាណាមួយដែលបានអនុម័តដោយអនុលោមតាមអនុសញ្ញានេះ រដ្ឋជាប់ឆ្នេរសមុទ្រមិនត្រូវ៖

(ក) ដាក់លក្ខខណ្ឌលើនាវាបរទេស ដែលការអនុវត្តនោះមានអានុភាពបដិសេធ ឬប៉ះពាល់ដល់សិទ្ធិឆ្លងកាត់ដោយមិនបំពាន។ ឬ

(ខ) រើសអើងក្នុងទម្រង់ឬតាមព្រឹត្តិន័យលើនាវារបស់រដ្ឋណាមួយឬនាវាដែលដឹកទំនិញទៅ មកពី ឬតាងនាមឱ្យរដ្ឋណាមួយឡើយ។

២. រដ្ឋជាប់ឆ្នេរសមុទ្រ ត្រូវធ្វើការផ្សព្វផ្សាយសមស្របអំពីគ្រោះថ្នាក់ដល់ការធ្វើនាវាចរណ៍ដែលរដ្ឋបានដឹងក្នុងសមុទ្រដែនដីរបស់ខ្លួន។

## មាត្រា២៥
## សិទ្ធិការពាររបស់រដ្ឋជាប់ឆ្នេរសមុទ្រ

១. រដ្ឋជាប់ឆ្នេរសមុទ្រ អាចចាត់វិធានការចាំបាច់ក្នុងសមុទ្រដែនដីរបស់ខ្លួន ដើម្បីរារាំងការឆ្លងកាត់ដែលបំពាន។

២. ក្នុងករណីនាវាចូលដែនទឹកផ្ទៃក្នុងឬឋបនីយកណ្តាលផែ ដែលនៅក្រៅដែនទឹកផ្ទៃក្នុង រដ្ឋជាប់ឆ្នេរសមុទ្រក៏មានសិទ្ធិចាត់វិធានការចាំបាច់ ដើម្បីបង្ការការរំលោភបំពានលក្ខខណ្ឌដែលបានអនុញ្ញាតឱ្យនាវានោះចូលដែនទឹកផ្ទៃក្នុង ឬចត។

៣. ដោយគ្មានការរើសអើងក្នុងទម្រង់ ឬតាមព្រឹត្តិន័យ រដ្ឋជាប់ឆ្នេរសមុទ្រអាចផ្អាកជាបណ្តោះអាសន្ន ចំពោះការឆ្លងកាត់ដោយមិនបំពានរបស់នាវាបរទេសក្នុងសមុទ្រដែនដីជាក់លាក់ណាមួយ ប្រសិនបើការផ្អាកនោះជាការចាំបាច់សម្រាប់ការការពារសន្តិសុខរបស់ខ្លួន ដែលរួមមានការធ្វើសមយុទ្ធសព្វាវុធ។ ការផ្អាកនេះត្រូវចូលជាធរមាន តែក្រោយពីការផ្សព្វផ្សាយត្រឹមត្រូវជាសាធារណៈប៉ុណ្ណោះ។

## មាត្រា២៦
## កម្រៃដែលអាចកំណត់លើនាវាបរទេស

១. គ្មានកម្រៃណាមួយអាចកំណត់លើនាវាបរទេស ដោយហេតុតែឆ្លងកាត់សមុទ្រដែនដីនោះឡើយ។

២. កម្រៃអាចកំណត់លើនាវាបរទេសដែលឆ្លងកាត់សមុទ្រដែនដីបាន ដែលការបង់ប្រាក់តែទៅលើសេវាជាក់លាក់ដែលផ្តល់ដល់នាវាប៉ុណ្ណោះ។ កម្រៃទាំងនេះត្រូវកំណត់ដោយគ្មានរើសអើង។

## អនុផ្នែកទី២
## វិធានដែលអនុវត្តលើនាវាពាណិជ្ជកម្ម និងនាវារដ្ឋាភិបាល ដែលប្រតិបត្តិការក្នុងគោលបំណងពាណិជ្ជកម្ម

## មាត្រា២៧
## យុត្តាធិការព្រហ្មទណ្ឌលើនាវាបរទេស

១. យុត្តាធិការព្រហ្មទណ្ឌរបស់រដ្ឋជាប់ឆ្នេរសមុទ្រ មិនគួរយកមកប្រើប្រាស់លើនាវាបរទេសដែលឆ្លងកាត់សមុទ្រដែនដី ដើម្បីចាប់ខ្លួនជនណាម្នាក់ឬធ្វើការស៊ើបអង្កេតលើបទល្មើសដែលបានប្រព្រឹត្តលើនាវាក្នុងអំឡុងពេលឆ្លងកាត់ឡើយ លើកលែងតែករណីដូចខាងក្រោម៖

(ក) ប្រសិនបើផលវិបាកនៃបទល្មើសបន្តប៉ះពាល់ដល់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ខ) ប្រសិនបើបទល្មើសជាប្រភេទបទល្មើសមួយដែលរំខានដល់សន្តិភាពរបស់ប្រទេស ឬសណ្តាប់ធ្នាប់ល្អនៃសមុទ្រដែនដី។

(គ) ប្រសិនបើមានការស្នើសុំជំនួយពីអាជ្ញាធរមូលដ្ឋានពីសំណាក់ម្ចាស់នាវា ឬភ្នាក់ងារការទូត ឬមន្ត្រីកុងស៊ុលរបស់រដ្ឋម្ចាស់សញ្ជាតិនាវា។ ឬ

(ឃ) ប្រសិនបើវិធានការនោះចាំបាច់ដើម្បីបង្ក្រាបការជួញដូរថ្នាំញៀនណាកូទីនឬសារធាតុប៉ះពាល់ផ្លូវចិត្តខុសច្បាប់។

២. បទប្បញ្ញត្តិខាងលើមិនប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ក្នុងការចាត់វិធានការណាមួយដែលអនុញ្ញាតដោយច្បាប់របស់ខ្លួន ក្នុងគោលបំណងចាប់ខ្លួនឬស៊ើបអង្កេតលើនាវាបរទេសដែលឆ្លងកាត់សមុទ្រដែនដីរបស់ខ្លួន បន្ទាប់ពីនាវាចាកចេញពីដែនទឹកផ្ទៃក្នុង។

៣. ក្នុងករណីដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ខាងលើ ប្រសិនបើនាយនាវាស្នើសុំរដ្ឋជាប់ឆ្នេរសមុទ្រ ត្រូវជូនដំណឹងដល់ភ្នាក់ងារការទូតឬមន្ត្រីកុងស៊ុលនៃរដ្ឋម្ចាស់សញ្ជាតិនាវា មុនពេលចាត់វិធានការណាមួយ និងត្រូវសម្រួលទំនាក់ទំនងរវាងភ្នាក់ងារការទូតឬមន្ត្រីកុងស៊ុលនោះជាមួយនឹងក្រុមនាវិក។ ក្នុងករណីបន្ទាន់ សេចក្តីជូនដំណឹងនេះអាចត្រូវបានប្រាស្រ័យទាក់ទងគ្នា ខណៈពេលកំពុងចាត់វិធានការ។

៤. ក្នុងការពិចារណាថាតើគួរធ្វើការចាប់ខ្លួនឬយ៉ាងណា ឬដោយរបៀបណា អាជ្ញាធរមូលដ្ឋានត្រូវគិតគូរពីផលប្រយោជន៍នៃការធ្វើនាវាចរណ៍។

៥. លើកលែងតែមានចែងក្នុងជំពូកទី១២ ឬទាក់ទងនឹងការរំលោភបំពានច្បាប់និងបទប្បញ្ញត្តិដែលអនុម័តដោយអនុលោមតាមជំពូកទី៥ រដ្ឋជាប់ឆ្នេរសមុទ្រមិនអាចចាត់វិធានការណាមួយលើនាវាបរទេសដែលឆ្លងកាត់សមុទ្រដែនដី ដើម្បីចាប់ខ្លួនមនុស្សណាម្នាក់ឬធ្វើការស៊ើបអង្កេតលើបទល្មើសដែលបានប្រព្រឹត្តមុនពេលនាវាចូលក្នុងសមុទ្រដែនដីរបស់ខ្លួន ប្រសិនបើនាវានោះធ្វើដំណើរពីកំពង់ផែបរទេស គ្រាន់តែឆ្លងកាត់សមុទ្រដែនដី ដោយមិនបានចូលក្នុងដែនទឹកផ្ទៃក្នុងទេនោះ។

## មាត្រា២៨
## យុត្តាធិការរដ្ឋប្បវេណីទាក់ទងនឹងនាវាបរទេស

១. រដ្ឋជាប់ឆ្នេរសមុទ្រ មិនគួរបញ្ឈប់ឬបង្វែរនាវាបរទេសដែលឆ្លងកាត់សមុទ្រដែនដីរបស់ខ្លួន ក្នុងគោលបំណងអនុវត្តយុត្តាធិការរដ្ឋប្បវេណីទាក់ទងនឹងជនណាម្នាក់នៅលើនាវាឡើយ។

២. រដ្ឋជាប់ឆ្នេរសមុទ្រមិនអាចអនុវត្តការរឹបអូសឬឃាត់នាវា ក្នុងគោលបំណងដើម្បីដំណើរការនីតិវិធីរដ្ឋប្បវេណីបានឡើយ លើកលែងតែធ្វើឡើងជាកាតព្វកិច្ចឬការទទួលខុសត្រូវដែលទទួលយក ឬដែលកើតឡើងដោយនាវាផ្ទាល់ក្នុងពេលធ្វើដំណើរ ឬក្នុងគោលបំណងឆ្លងកាត់ដែនទឹករបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

៣. កថាខណ្ឌទី២ខាងលើនេះ មិនប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ដោយអនុលោមតាមច្បាប់របស់ខ្លួន ក្នុងការអនុវត្តការរឹបអូសឬឃាត់នាវាដែលស្ថិតនៅក្នុងសមុទ្រដែនដី ឬឆ្លងកាត់សមុទ្រដែនដីបន្ទាប់ពីចាកចេញ។

## អនុផ្នែកទី៣
## វិធានអនុវត្តចំពោះនាវាចម្បាំងនិងនាវាដទៃទៀតរបស់រដ្ឋាភិបាល
## ដែលប្រតិបត្តិការក្នុងគោលបំណងមិនមែនពាណិជ្ជកម្ម

## មាត្រា២៩
## និយមន័យនាវាចម្បាំង

ក្នុងគោលបំណងនៃអនុសញ្ញានេះ "**នាវាចម្បាំង**" សំដៅដល់ នាវាដែលជាកម្មសិទ្ធិរបស់កងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ដែលសញ្ញាផ្នែកខាងក្រៅសម្គាល់សញ្ជាតិរបស់នាវា ស្ថិតក្រោមបញ្ជារបស់មន្ត្រីដែលទទួលភារកិច្ចត្រឹមត្រូវពីរដ្ឋាភិបាលរបស់រដ្ឋ និងដែលមានឈ្មោះក្នុងបញ្ជីកងទ័ពឬបញ្ជីសមមូលសមស្រប និងដំណើរការដោយក្រុមនាវិកដែលស្ថិតនៅក្រោមវិន័យរបស់កងកម្លាំងប្រដាប់អាវុធជាប្រចាំ។

## មាត្រា៣០
## ភាពមិនអនុលោមតាមច្បាប់និងបទបញ្ជារបស់រដ្ឋជាប់ឆ្នេរសមុទ្រដោយនាវាចម្បាំង

ប្រសិនបើនាវាចម្បាំងមិនគោរពតាមច្បាប់និងបទបញ្ជារបស់រដ្ឋជាប់ឆ្នេរសមុទ្រ ទាក់ទងនឹងការឆ្លងកាត់សមុទ្រដែនដី និងមិនគោរពតាមសំណើឱ្យគោរពតាមច្បាប់ និងបទបញ្ជានោះ រដ្ឋជាប់ឆ្នេរសមុទ្រអាចតម្រូវឱ្យនាវាចម្បាំងនោះចាកចេញពីសមុទ្រដែនដីភ្លាមៗ។

## មាត្រា៣១
## ការទទួលខុសត្រូវរបស់រដ្ឋម្ចាស់សញ្ជាតិនាវាចំពោះព្យសនកម្មដែលបង្កឡើងដោយនាវាចម្បាំងឬនាវាដទៃទៀតរបស់រដ្ឋាភិបាលដែលប្រតិបត្តិការក្នុងគោលបំណងមិនមែនពាណិជ្ជកម្ម

រដ្ឋម្ចាស់សញ្ជាតិនាវា ត្រូវទទួលខុសត្រូវជាលក្ខណៈអន្តរជាតិចំពោះការបាត់បង់ឬព្យសនកម្មរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ដែលបណ្តាលមកពីភាពមិនអនុលោមតាមច្បាប់និងបទបញ្ជារបស់រដ្ឋជាប់ឆ្នេរសមុទ្រដោយនាវាចម្បាំង ឬនាវាដទៃទៀតរបស់រដ្ឋាភិបាលទាក់ទងនឹងការឆ្លងកាត់សមុទ្រដែនដី ឬបទប្បញ្ញត្តិនៃអនុសញ្ញានេះ ឬវិធានដទៃទៀតនៃនីតិអន្តរជាតិ។

## មាត្រា៣២
## អភ័យឯកសិទ្ធិរបស់នាវាចម្បាំង និងនាវាដទៃទៀតរបស់រដ្ឋាភិបាល ដែលប្រតិបត្តិការក្នុងគោលបំណងមិនមែនពាណិជ្ជកម្ម

លើកលែងតែមានចែងក្នុងអនុផ្នែកទី១ និងក្នុងមាត្រា៣០និងមាត្រា៣១ខាងលើ គ្មានបទប្បញ្ញត្តិណាមួយក្នុងអនុសញ្ញានេះ ប៉ះពាល់ដល់អភ័យឯកសិទ្ធិរបស់នាវាចម្បាំង និងនាវាដទៃទៀតរបស់រដ្ឋាភិបាលដែលប្រតិបត្តិការក្នុងគោលបំណងមិនមែនពាណិជ្ជកម្មឡើយ។

## ផ្នែកទី៤
## តំបន់តភ្ជាប់
## មាត្រា៣៣
## តំបន់តភ្ជាប់

១. ក្នុងតំបន់ដែលជាប់សមុទ្រដែនដី ហៅថា តំបន់តភ្ជាប់ រដ្ឋជាប់ឆ្នេរសមុទ្រអាចធ្វើការគ្រប់គ្រងដែលចាំបាច់ដើម្បី៖

(ក) បង្ការការរំលោភបំពានលើច្បាប់ និងបទបញ្ជាផ្នែកគយ សារពើពន្ធ អន្តោប្រវេសន៍ អនាម័យក្នុងដែនដីឬសមុទ្រដែនដីរបស់រដ្ឋនោះ។

(ខ) ផ្តន្ទាទោសលើការរំលោភបំពានច្បាប់ និងបទបញ្ជាខាងលើ ដែលបានប្រព្រឹត្តក្នុងដែនដីឬសមុទ្រដែនដីរបស់ខ្លួន។

២. តំបន់តភ្ជាប់ មិនអាចមានចម្ងាយលើសពី២៤ ម៉ៃល៍សមុទ្រ ពីខ្សែបន្ទាត់មូលដ្ឋាន សម្រាប់វាស់ប្រវែងសមុទ្រដែនដីបានឡើយ។

## ជំពូកទី៣
## ច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ
## មាត្រា៣៤
## លក្ខន្តិកៈគតិយុត្តនៃផ្ទៃទឹកដែលបង្កើតបានជាច្រកសមុទ្របម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ

១. របបនៃការឆ្លងកាត់តាមច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិដូចមានកំណត់នៅក្នុងផ្នែកនេះ មិនត្រូវប៉ះពាល់ក្នុងលក្ខណៈណាមួយក៏ដោយដល់លក្ខន្តិកៈគតិយុត្តនៃផ្ទៃទឹកដែលបង្កើតបានជាច្រកសមុទ្របែបនោះ ឬការអនុវត្តរបស់រដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រនៅក្នុងដែនអធិបតេយ្យឬយុត្តាធិការរបស់ពួកគេលើផ្ទៃទឹកនោះ និងលំហអាកាស បាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្ររបស់វាឡើយ។

២. ដែនអធិបតេយ្យឬយុត្តាធិការរបស់រដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ ត្រូវអនុវត្តដោយអនុលោមតាមផ្នែកនេះ និងវិធានដទៃទៀតនៃនីតិអន្តរជាតិ។

## មាត្រា៣៥
## វិសាលភាពនៃផ្នែកនេះ

គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងផ្នែកនេះប៉ះពាល់ដល់៖

(ក) រាល់តំបន់ដែនទឹកផ្ទៃក្នុងនៅក្នុងច្រកសមុទ្រ លើកលែងតែការកំណត់នូវខ្សែបន្ទាត់មូលដ្ឋានត្រង់ ដែលបានធ្វើឡើងដោយអនុលោមតាមវិធីសាស្ត្រដូចមានចែងក្នុងមាត្រា៧នៃអនុសញ្ញានេះ មានអានុភាព ដាក់បញ្ចូលតំបន់ដែនទឹកផ្ទៃក្នុង ជាតំបន់ដែលពីមុនមកមិនត្រូវបានចាត់ទុកជាតំបន់បែបនោះ។

(ខ) លក្ខន្តិកៈគតិយុត្តិនៃដែនទឹកហួសសមុទ្រដែនដីរបស់រដ្ឋដែលមានព្រំដែនជាប់ច្រកសមុទ្រ ជាតំបន់ សេដ្ឋកិច្ចផ្តាច់មុខ ឬតំបន់សមុទ្រអន្តរជាតិ ឬ

(គ) របបគតិយុត្តនៃច្រកសមុទ្រដែលការឆ្លងកាត់ មានចែងទាំងស្រុងឬដោយផ្នែកនៅក្នុងអនុសញ្ញាអន្តរជាតិ ដែលមានយូរលង់ណាស់មកហើយ ដែលនៅជាធរមានយ៉ាងជាក់លាក់ ដែលទាក់ទងទៅនឹងច្រកសមុទ្រ បែបនោះ។

## មាត្រា៣៦
## ផ្លូវលម្ហសមុទ្រអន្តរជាតិ ឬផ្លូវឆ្លងកាត់តំបន់សេដ្ឋកិច្ចផ្តាច់មុខ ឆ្លងកាត់ច្រកសមុទ្រ ដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ

ជំពូកនេះមិនអនុវត្តចំពោះច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិនោះទេ ប្រសិនបើ តាមច្រកសមុទ្រទាំងនោះ មានផ្លូវឆ្លងកាត់សមុទ្រអន្តរជាតិឬឆ្លងកាត់តំបន់សេដ្ឋកិច្ចផ្តាច់មុខ ដែលមានភាពងាយ ស្រួលប្រហាក់ប្រហែលគ្នា ទាក់ទងទៅនឹងបច្ចេកលក្ខណៈនាវាចរណ៍និងជលសាស្ត្រ។ ចំពោះផ្លូវទាំងនោះ ផ្នែក ពាក់ព័ន្ធផ្សេងទៀតក្នុងអនុសញ្ញានេះ រាប់បញ្ចូលទាំងបទប្បញ្ញត្តិស្តីពីសេរីភាពនាវាចរណ៍និងការហោះហើរឆ្លងកាត់ ត្រូវយកមកអនុវត្ត។

# ផ្នែកទី២
# ដំណើរឆ្លងកាត់

## មាត្រា៣៧
## វិសាលភាពនៃផ្នែកនេះ

ផ្នែកនេះអនុវត្តចំពោះច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ រវាងផ្នែកមួយនៃសមុទ្រ អន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងផ្នែកមួយផ្សេងទៀតនៃសមុទ្រអន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខ។

## មាត្រា៣៨
## សិទ្ធិនៃដំណើរឆ្លងកាត់

១. ក្នុងច្រកសមុទ្រដូចមានចែងក្នុងមាត្រា៣៧ខាងលើ នាវានិងអាកាសយានទាំងអស់ ទទួលបានសិទ្ធិនៃ ដំណើរឆ្លងកាត់ ដោយមិនមានការរារាំងអ្វីទាំងអស់ លើកលែងតែថា ប្រសិនបើច្រកសមុទ្រនោះកើតឡើងពីកោះ របស់រដ្ឋដែលមានព្រំដែនជាប់ច្រកសមុទ្រនិងដីគោករបស់វា នោះដំណើរឆ្លងកាត់មិនត្រូវយកមកអនុវត្តនោះទេ ប្រសិនបើដីបែរទៅរកសមុទ្ររបស់កោះ មានផ្លូវឆ្លងកាត់សមុទ្រអន្តរជាតិឬឆ្លងកាត់តំបន់សេដ្ឋកិច្ចផ្តាច់មុខ ដែលមាន ភាពងាយស្រួលប្រហាក់ប្រហែលគ្នា ឬទាក់ទងទៅនឹងបច្ចេកលក្ខណៈនាវាចរណ៍និងជលសាស្ត្រ។

២. ដំណើរឆ្លងកាត់ មានន័យថា ការអនុវត្តដោយអនុលោមតាមផ្នែកនេះនូវសេរីភាពក្នុងការធ្វើនាវាចរណ៍ និងការហោះហើរ តែក្នុងគោលបំណងនៃការឆ្លងកាត់ឥតឈប់និងដោយរហ័សតាមច្រកសមុទ្រ នៅចន្លោះផ្នែកមួយនៃសមុទ្រអន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងផ្នែកមួយផ្សេងទៀតនៃសមុទ្រអន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ ទោះបីជាយ៉ាងណាក៏ដោយ លក្ខខណ្ឌតម្រូវនៃការឆ្លងកាត់ឥតឈប់និងដោយរហ័ស មិនរារាំងដល់ការឆ្លងកាត់តាមច្រកសមុទ្រ ដើម្បីចូល ចេញ ឬត្រឡប់មកវិញពីរដ្ឋដែលមានព្រំដែនជាប់ច្រកសមុទ្រ ដែលអនុលោមតាមលក្ខខណ្ឌក្នុងការចូលទៅក្នុងរដ្ឋនោះទេ។

៣. រាល់សកម្មភាពដែលមិនមែនជាការប្រើប្រាស់សិទ្ធិនៃដំណើរឆ្លងកាត់តាមច្រកសមុទ្រ ត្រូវរក្សាការគ្រប់គ្រងដោយបទប្បញ្ញត្តិជាធរមានផ្សេងទៀតនៃអនុសញ្ញានេះ។

## មាត្រា៣៩
## ករណីយកិច្ចរបស់នាវានិងអាកាសយានក្នុងពេលដំណើរឆ្លងកាត់

១. ក្នុងពេលប្រើប្រាស់សិទ្ធិនៃដំណើរឆ្លងកាត់ នាវានិងអាកាសយានត្រូវ៖

(ក) ធ្វើដំណើរតាមឬពីលើច្រកសមុទ្រ ដោយគ្មានការបង្អង់។

(ខ) ជៀសវាងបង្កការគំរាមកំហែង ឬប្រើប្រាស់កម្លាំងប្រឆាំងនឹងអធិបតេយ្យ បូរណភាពដែនដីឯករាជ្យភាពនយោបាយ របស់រដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ ឬក្នុងលក្ខណៈណាមួយដែលបំពានទៅលើគោលការណ៍នៃនីតិអន្តរជាតិ ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ។

(គ) ចៀសវាងធ្វើសកម្មភាពផ្សេងពីសកម្មភាពដែលជាលក្ខណៈធម្មតានៃដំណើរឆ្លងកាត់ដែលឥតឈប់និងរហ័ស លើកលែងតែត្រូវធ្វើឡើងជាចាំបាច់ ដោយសារករណីប្រធានសក្តិឬគ្រាអាសន្ន។

(ឃ) គោរពតាមបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតដូចមានចែងក្នុងជំពូកនេះ។

២. នាវាក្នុងដំណើរឆ្លងកាត់ត្រូវ៖

(ក) គោរពតាមបទបញ្ជា នីតិវិធី និងការអនុវត្តជាអន្តរជាតិដែលមានការទទួលយកជាទូទៅ ដើម្បីសុវត្ថិភាពតាមផ្លូវសមុទ្រ ដោយរាប់បញ្ចូលទាំងបទបញ្ជាអន្តរជាតិ សម្រាប់បង្ការការប៉ះទង្គិចនាវាតាមផ្លូវសមុទ្រ។

(ខ) គោរពតាមបទបញ្ជា នីតិវិធី និងការអនុវត្តជាអន្តរជាតិដែលមានការទទួលយកជាទូទៅ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា។

៣. អាកាសយានក្នុងដំណើរឆ្លងកាត់ត្រូវ៖

(ក) គោរពវិធានស្តីពីដែនអាកាសបង្កើតឡើងដោយអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដែលអនុវត្តចំពោះអាកាសយានស៊ីវិល។ ជាធម្មតា អាកាសយានរដ្ឋត្រូវគោរពទៅតាមវិធានការ ដើម្បីសុវត្ថិភាពទាំងនេះ ហើយជានិច្ចកាលត្រូវប្រតិបត្តិការដោយយកចិត្តទុកដាក់ទៅលើសុវត្ថិភាពក្នុងការហោះហើរ។

(ខ) គ្រប់ពេលទាំងអស់ តាមដានត្រួតពិនិត្យ ហ្វ្រេកង់វិទ្យុដែលកំណត់ដោយអាជ្ញាធរត្រួតពិនិត្យចរាចរណ៍ផ្លូវអាកាសមានសមត្ថកិច្ចដែលបានកំណត់ជាអន្តរជាតិ ឬ ហ្វ្រេកង់វិទ្យុសម្រាប់គ្រាអាសន្នជាអន្តរជាតិដែលសមស្រប។

## មាត្រា៤០
## សកម្មភាពស្រាវជ្រាវនិងការប្រមូលទិន្នន័យ

ក្នុងអំឡុងពេលនៃដំណើរឆ្លងកាត់ នាវាបរទេសរាប់បញ្ចូលទាំងនាវាស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ និងប្រមូលទិន្នន័យបែបជលសាស្ត្រ មិនអាចអនុវត្តសកម្មភាពស្រាវជ្រាវឬប្រមូលទិន្នន័យណាមួយដោយគ្មានការអនុញ្ញាតជាមុនពីបណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រនោះឡើយ។

## មាត្រា៤១
## គន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ក្នុងច្រកសមុទ្រដែលបម្រើដល់ការធ្វើនាវាចរណ៍អន្តរជាតិ

១. ដោយអនុលោមតាមជំពូកនេះ បណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រអាចកំណត់នូវគន្លងផ្លូវសមុទ្រ និងរៀបចំគន្លងបែងចែកចរាចរណ៍សម្រាប់ការធ្វើនាវាចរណ៍នៅក្នុងច្រកសមុទ្រតាមការចាំបាច់ ដើម្បីលើកកម្ពស់ការឆ្លងកាត់ប្រកបដោយសុវត្ថិភាពរបស់នាវា។

២. ក្នុងកាលៈទេសៈតម្រូវនិងបន្ទាប់ពីធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងត្រឹមត្រូវហើយនោះ បណ្តារដ្ឋទាំងនេះ អាចជំនួសគន្លងផ្លូវសមុទ្រឬគន្លងបែងចែកចរាចរណ៍ដែលខ្លួនបានកំណត់ឬរៀបចំកន្លងមក ដោយគន្លងផ្លូវសមុទ្រឬគន្លងបែងចែកចរាចរណ៍ផ្សេងទៀត។

៣. គន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ទាំងនេះ ត្រូវមានលក្ខណៈស្របទៅតាមបទបញ្ញាអន្តរជាតិដែលមានការទទួលយកជាទូទៅ។

៤. មុននឹងធ្វើការរៀបចំឬដាក់ជំនួសគន្លងផ្លូវសមុទ្រ ឬមុននឹងធ្វើការកំណត់ឬជំនួសគន្លងបែងចែកចរាចរណ៍ បណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ ត្រូវលើកសំណើអំពីការរៀបចំរបស់ខ្លួនទៅអង្គការអន្តរជាតិមានសមត្ថកិច្ច។ អង្គការអន្តរជាតិមានសមត្ថកិច្ចនេះ អាចអនុម័តតែចំពោះគន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍នៅពេលទទួលបានការព្រមព្រៀងពីបណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រនោះប៉ុណ្ណោះ បន្ទាប់មក បណ្តារដ្ឋអាចកំណត់ រៀបចំ ឬជំនួសគន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ទាំងនោះ។

៥. ទាក់ទងទៅនឹងច្រកសមុទ្រដែលមានគន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ តាមរយៈដែនទឹកសមុទ្ររបស់បណ្តារដ្ឋពីរឬច្រើនដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ ដែលបាននិងកំពុងស្នើឡើងនោះ បណ្តារដ្ឋដែលពាក់ព័ន្ធនឹងសំណើសុំនោះ ត្រូវសហការក្នុងការរៀបចំសំណើ ដោយពិគ្រោះយោបល់ជាមួយនឹងអង្គការអន្តរជាតិមានសមត្ថកិច្ច។

៦. បណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ ត្រូវចង្អុលបង្ហាញឱ្យបានច្បាស់លាស់អំពីគន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ទាំងអស់ដែលខ្លួនបានកំណត់ ឬបានរៀបចំនៅក្នុងផែនទីសមុទ្រ ដែលត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងត្រឹមត្រូវ។

៧. នាវាដែលធ្វើដំណើរឆ្លងកាត់ ត្រូវគោរពគន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ជាធរមាន ដែលត្រូវបានកំណត់ដោយអនុលោមតាមមាត្រានេះ។

## មាត្រា៤២

## ច្បាប់និងបទបញ្ជារបស់បណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រទាក់ទងនឹងដំណើរឆ្លងកាត់

១. ដោយអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកនេះ បណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ អាចអនុម័តច្បាប់និងបទបញ្ជាទាក់ទងនឹងដំណើរឆ្លងកាត់តាមច្រកសមុទ្រ ពាក់ព័ន្ធនឹងចំណុចទាំងអស់ឬចំណុចណាមួយដូចខាងក្រោម៖

(ក) សុវត្ថិភាពក្នុងការធ្វើនាវាចរណ៍ និងនិយ័តកម្មនៃការធ្វើចរាចរណ៍លើផ្ទៃសមុទ្រ ដូចមានចែងក្នុងមាត្រា៤១នៃអនុសញ្ញានេះ។

(ខ) ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុល តាមរយៈការអនុវត្តឱ្យមានប្រសិទ្ធភាពនូវបទបញ្ជាអន្តរជាតិជាធរមាន ទាក់ទងនឹងការបញ្ចេញប្រេង កាកសំណល់ជាតិប្រេង និងសារធាតុពុលផ្សេងទៀតក្នុងច្រកសមុទ្រ។

(គ) ពាក់ព័ន្ធនឹងនាវានេសាទ ការបង្ការផ្នែកនេសាទ រាប់បញ្ចូលទាំងការស្តុកទុកនូវឧបករណ៍នេសាទ។

(ឃ) ការផ្ទេរផ្ទុក ឬលើកដាក់ទំនិញ រូបិយវត្ថុ ឬបុគ្គល ដែលរំលោភបំពាន ច្បាប់ និងបទបញ្ជាស្តីពីគយ សារពើពន្ធ អន្តោប្រវេសន៍ ឬអនាម័យរបស់បណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ។

២. ច្បាប់និងបទបញ្ជាទាំងនេះ មិនត្រូវមានការរើសអើងក្នុងទម្រង់ឬតាមព្រឹត្តិន័យណាមួយក្នុងចំណោមនាវាបរទេស ឬក្នុងការអនុវត្តជាក់ស្តែង ដែលការអនុវត្តទាំងនោះមានអានុភាពបដិសេធ រារាំង ឬប៉ះពាល់ដល់សិទ្ធិនៃដំណើរឆ្លងកាត់ ដូចមានកំណត់ក្នុងផ្នែកនេះ។

៣. បណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈយ៉ាងត្រឹមត្រូវអំពីច្បាប់និងបទបញ្ជាទាំងអស់នោះ។

៤. នាវាបរទេសដែលអនុវត្តសិទ្ធិនៃដំណើរឆ្លងកាត់ត្រូវអនុវត្តឱ្យស្របតាមច្បាប់និងបទបញ្ជាទាំងនោះ។

៥. រដ្ឋម្ចាស់សញ្ជាតិនាវា ឬរដ្ឋដែលបានចុះបញ្ជីអាកាសយាន ដែលទទួលបានអភ័យឯកសិទ្ធិ ក្នុងការប្រព្រឹត្តផ្ទុយពីច្បាប់និងបទបញ្ជាទាំងនេះ ឬបទប្បញ្ញត្តិដទៃទៀត នៃជំពូកនេះ ត្រូវទទួលខុសត្រូវជាអន្តរជាតិចំពោះការបាត់បង់ឬព្យសនកម្មដែលកើតមានចំពោះបណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ។

## មាត្រា៤៣

## សញ្ញាជំនួយនាវាចរណ៍និងសញ្ញាសុវត្ថិភាព និងបសិដ្ឋកម្មផ្សេងទៀត និងការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុល

បណ្តារដ្ឋប្រើប្រាស់ និងបណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ អាចសហប្រតិបត្តិការតាមការព្រមព្រៀងគ្នាដូចខាងក្រោម៖

(ក) បង្កើតនិងថែទាំសញ្ញាជំនួយនាវាចរណ៍និងសញ្ញាសុវត្ថិភាពចាំបាច់ ឬបសិដ្ឋកម្មផ្សេងទៀតនៃសញ្ញាជំនួយនាវាចរណ៍អន្តរជាតិក្នុងច្រកសមុទ្រ និង

(ខ) បង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា។

## មាត្រា៤៤

## ករណីយកិច្ចរបស់បណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ

បណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រមិនត្រូវរំខានដំណើរឆ្លងកាត់ និងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យបានសមស្របអំពីគ្រោះថ្នាក់នានាដែលខ្លួនបានដឹងចំពោះការធ្វើនាវាចរណ៍ ឬការហោះហើរនៅក្នុង ឬនៅពីលើច្រកសមុទ្រ។ មិនត្រូវមានការផ្អាកចំពោះដំណើរឆ្លងកាត់ណាមួយឡើយ។

## ផ្នែកទី៣

## ការឆ្លងកាត់ដោយមិនបំពាន

## មាត្រា៤៥

## ការឆ្លងកាត់ដោយមិនបំពាន

១. របបនៃការឆ្លងកាត់ដោយមិនបំពាននៅក្នុងផ្នែកទី៣ នៃជំពូកទី២ ត្រូវយកមកអនុវត្តចំពោះច្រកសមុទ្រដែលត្រូវបានប្រើប្រាស់សម្រាប់ការធ្វើនាវាចរណ៍អន្តរជាតិ៖

(ក) មិនអនុវត្តចំពោះរបបនៃដំណើរឆ្លងកាត់ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣៨

(ខ) ចន្លោះផ្នែកមួយនៃលម្ហសមុទ្រអន្តរជាតិ ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងសមុទ្រដែនដីរបស់រដ្ឋបរទេសមួយ។

២. មិនត្រូវមានការផ្អាកចំពោះការឆ្លងកាត់ដោយមិនបំពានតាមច្រកសមុទ្រទាំងនេះឡើយ។

## ជំពូកទី៤

## បណ្តារដ្ឋប្រជុំកោះ

## មាត្រា៤៦

## ការប្រើប្រាស់វាក្យស័ព្ទ

សម្រាប់គោលបំណងនៃអនុសញ្ញានេះ៖

(ក) "**រដ្ឋប្រជុំកោះ**" សំដៅដល់ រដ្ឋមួយដែលកើតឡើងទាំងស្រុងដោយប្រជុំកោះមួយឬច្រើន និងអាចរាប់បញ្ចូលទាំងបណ្តាកោះផ្សេងទៀត។

(ខ) "**ប្រជុំកោះ**" សំដៅដល់ ក្រុមកោះ រាប់បញ្ចូលទាំងផ្នែកនៃកោះ ផ្ទៃទឹកដែលភ្ជាប់ក្រុមកោះទាំងនោះ និងរូបសណ្ឋានធម្មជាតិដទៃទៀត ដែលប្រទាក់គ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ដែលធ្វើឱ្យកោះ ផ្ទៃទឹក និងរូបសណ្ឋានធម្មជាតិទាំងអស់នោះ បង្កើតបានជាអង្គរួមមួយដែលមានលក្ខណៈភូមិសាស្ត្រ សេដ្ឋកិច្ច និងនយោបាយជាក់លាក់ឬដែលជាប្រវត្តិសាស្ត្រ ត្រូវបានចាត់ទុកថាមានលក្ខណៈទាំងនេះ។

## មាត្រា៤៧

## ខ្សែបន្ទាត់មូលដ្ឋាននៃប្រជុំកោះ

១. រដ្ឋប្រជុំកោះអាចគូសខ្សែបន្ទាត់មូលដ្ឋានត្រង់នៃប្រជុំកោះដោយភ្ជាប់ចំណុចក្រៅបំផុតនៃបណ្តាកោះដែលស្ថិតនៅខាងក្រៅបង្អស់ទៅនឹងថ្មប៉ប្រះទឹកមើលឃើញពេលទឹកនាចនៃប្រជុំកោះ ឱ្យតែនៅក្នុងខ្សែបន្ទាត់មូលដ្ឋាននោះបានរាប់បញ្ចូលនូវបណ្តាកោះចម្បងនិងតំបន់ដែលក្នុងនោះមានអនុបាតរវាងផ្ទៃទឹកនិងផ្ទៃដីរាប់បញ្ចូលទាំងអាតូលផងចន្លោះពី ១:១ និង ៩:១។

២. ប្រវែងនៃខ្សែបន្ទាត់មូលដ្ឋានទាំងនេះ មិនត្រូវលើសពី១០០ ម៉ៃល៍សមុទ្រ ប៉ុន្តែ៣ភាគរយយ៉ាងច្រើននៃខ្សែបន្ទាត់មូលដ្ឋានសរុបដែលព័ទ្ធជុំវិញប្រជុំកោះណាមួយអាចមានប្រវែងលើសពីនេះបានយ៉ាងច្រើនត្រឹម ១២៥ ម៉ៃល៍សមុទ្រ។

៣. ការគូសខ្សែបន្ទាត់មូលដ្ឋានទាំងនេះមិនត្រូវងាកចេញខ្លាំងពេកពីរូបសណ្ឋានទូទៅនៃប្រជុំកោះឡើយ។

៤. ខ្សែបន្ទាត់មូលដ្ឋានទាំងនេះ មិនត្រូវគូសឆ្ពោះទៅនិងចេញពីដីដុះនោះទេ លើកលែងតែមានប៉មបំភ្លឺឬ ឋបនាការស្រដៀងគ្នាដែលស្ថិតនៅជាអចិន្ត្រៃយ៍ខ្ពស់ជាងកម្ពស់ទឹកសមុទ្រត្រូវបានសាងសង់នៅលើនោះឬ ដីដុះនោះទាំងមូលឬផ្នែកណាមួយនៃដីដុះស្ថិតនៅចម្ងាយមិនលើសពីប្រវែងទទឹងនៃសមុទ្រដែនដីគិតពីកោះ ដែលនៅជិតបំផុត។

៥. ប្រព័ន្ធនៃខ្សែបន្ទាត់មូលដ្ឋាននេះមិនត្រូវយកមកអនុវត្តដោយរដ្ឋប្រជុំកោះណាមួយក្នុងលក្ខណៈដែលនាំឱ្យកាត់ផ្តាច់លម្ហសមុទ្រអន្តរជាតិឬតំបន់សេដ្ឋកិច្ចផ្តាច់មុខពីសមុទ្រដែនដីរបស់រដ្ឋមួយទៀតនោះទេ។

៦. ប្រសិនបើផ្នែកមួយនៃផ្ទៃទឹកប្រជុំកោះរបស់រដ្ឋប្រជុំកោះមួយ ស្ថិតនៅចន្លោះនៃដែនទឹកពីររបស់រដ្ឋជិតខាងដែលមានសមុទ្រជាប់គ្នា សិទ្ធិដែលមានស្រាប់និងផលប្រយោជន៍ស្របច្បាប់ផ្សេងទៀតទាំងអស់របស់រដ្ឋជិតខាងនេះដែលបាននិងកំពុងអនុវត្តជាប្រពៃណីក្នុងដែនទឹកនោះ និងសិទ្ធិទាំងអស់ដែលមានចែងក្នុងកិច្ចព្រមព្រៀងរវាងរដ្ឋទាំងនោះ ត្រូវបន្តនិងត្រូវគោរពតាម។

៧. ដើម្បីគណនាអនុបាតរវាងផ្ទៃទឹកនិងផ្ទៃដីដូចមានចែងក្នុងកថាខណ្ឌទី១ ផ្ទៃដីអាចបូកបញ្ចូលទាំងផ្ទៃទឹកដែលស្ថិតនៅក្នុងចង្កោមកោះថ្មប៉ប្រះទឹកនិងអាតូល ដោយរាប់បញ្ចូលផ្នែកនៃខ្ពង់រាបមហាសមុទ្រដែលមានច្រាំងចោទព័ទ្ធដោយឬស្ទើរតែព័ទ្ធដោយជួរកោះថ្មកំបោរនិងថ្មប៉ប្រះទឹកមើលឃើញពេលទឹកនាច ដែលស្ថិតនៅលើបរិមាត្រនៃខ្ពង់រាប។

៨. ខ្សែបន្ទាត់មូលដ្ឋាន ដែលបានគូសដោយអនុលោមតាមមាត្រានេះ ត្រូវបង្ហាញលើផែនទីសមុទ្រដែលមានមាត្រដ្ឋានណាមួយឬមានមាត្រដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ច្បាស់ពីទីតាំងទាំងនោះ។ ក្រៅពីនេះ បញ្ជីនិយាមកាភូមិសាស្ត្រនៃចំណុចនានាដែលបញ្ជាក់ទិន្នន័យប្រើចពីភិភាគអាចយកមកប្រើជំនួសបាន។

៩. រដ្ឋប្រជុំកោះត្រូវធ្វើការផ្សព្វផ្សាយផែនទីសមុទ្រឬបញ្ជីនិយាមកាភូមិសាស្ត្រឱ្យបានត្រឹមត្រូវ ហើយត្រូវតម្កល់ផែនទីឬបញ្ជីនិយាមកានោះមួយច្បាប់ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា៤៨

## ការវាស់វែងប្រវែងទទឹងសមុទ្រដែនដី តំបន់តភ្ជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងខ្ពង់រាបបាតសមុទ្រ

ប្រវែងទទឹងសមុទ្រដែនដី តំបន់តភ្ជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ខ្ពង់រាបបាតសមុទ្រ ត្រូវវាស់វែងចេញពីខ្សែបន្ទាត់មូលដ្ឋាននៃប្រជុំកោះដែលបានគូសដោយអនុលោមតាមមាត្រា៤៧។

## មាត្រា៤៩

## លក្ខន្តិកៈគតិយុត្តនៃផ្ទៃទឹកប្រជុំកោះ ដែនអាកាសពីលើផ្ទៃទឹកប្រជុំកោះ និងផ្ទៃបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្ររបស់ផ្ទៃទឹកប្រជុំកោះ

១. អធិបតេយ្យនៃរដ្ឋប្រជុំកោះលាតសន្ធឹងលើផ្ទៃទឹកដែលព័ទ្ធជុំវិញដោយខ្សែបន្ទាត់មូលដ្ឋាននៃប្រជុំកោះដែលបានគូសអនុលោមតាមមាត្រា៤៧ ដែលបានកំណត់ថាជាផ្ទៃទឹកប្រជុំកោះដោយមិនគិតពីជម្រៅឬចម្ងាយរបស់វាពីឆ្នេរសមុទ្រឡើយ។

២. អធិបតេយ្យនេះលាតសន្ធឹងដល់ដែនអាកាសពីលើផ្ទៃទឹកប្រជុំកោះ ក៏ដូចជាដល់បាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្ររបស់វា និងធនធានទាំងឡាយដែលមាននៅក្នុងនោះ។

៣. អធិបតេយ្យនេះត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងនៅក្នុងជំពូកនេះ។

៤. របបនៃការឆ្លងកាត់តាមគន្លងផ្លូវសមុទ្រប្រជុំកោះដែលបានបង្កើតនៅក្នុងជំពូកនេះ ទោះក្នុងទិដ្ឋភាពណាក៏ដោយ មិនប៉ះពាល់ដល់លក្ខន្តិកៈនៃផ្ទៃទឹកប្រជុំកោះ រួមទាំងគន្លងផ្លូវសមុទ្រ ឬការអនុវត្តសិទ្ធិរបស់រដ្ឋប្រជុំកោះនូវអធិបតេយ្យរបស់ខ្លួនលើផ្ទៃទឹកប្រជុំកោះទាំងនោះ និងដែនអាកាស បាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្ររបស់វា និងធនធានទាំងឡាយដែលមាននៅក្នុងនោះ។

## មាត្រា៥០

## ការកំណត់ព្រំដែននៃដែនទឹកផ្ទៃក្នុង

នៅក្នុងផ្ទៃទឹកប្រជុំកោះរបស់ខ្លួន រដ្ឋប្រជុំកោះអាចគូសខ្សែបិទដើម្បីកំណត់ព្រំដែននៃដែនទឹកផ្ទៃក្នុង ដោយអនុលោមតាមមាត្រា៩ មាត្រា១០ និងមាត្រា១១។

## មាត្រា៥១

## កិច្ចព្រមព្រៀងដែលមានស្រាប់ សិទ្ធិនេសាទជាលក្ខណៈប្រពៃណី និងខ្សែកាបនៅក្រោមសមុទ្រដែលមានស្រាប់

១. ដោយមិនប៉ះពាល់ដល់មាត្រា៤៩ រដ្ឋប្រជុំកោះត្រូវគោរពកិច្ចព្រមព្រៀងដែលមានស្រាប់ ជាមួយនឹងបណ្ដារដ្ឋផ្សេងទៀត និងត្រូវទទួលស្គាល់សិទ្ធិនេសាទជាលក្ខណៈប្រពៃណី ព្រមទាំងសកម្មភាពស្របច្បាប់ផ្សេងទៀតរបស់បណ្ដារដ្ឋជិតខាងដែលមានសមុទ្រជាប់គ្នាក្នុងតំបន់មួយចំនួន ដែលស្ថិតក្នុងផ្ទៃទឹកប្រជុំកោះ។ លក្ខខណ្ឌនិងបែបបទសម្រាប់ការអនុវត្តសិទ្ធិនិងសកម្មភាពទាំងនោះ រាប់បញ្ចូលចរិតលក្ខណៈ វិសាលភាព និងតំបន់ដែលអនុវត្តចំពោះ តាមសំណើរបស់រដ្ឋណាមួយដែលពាក់ព័ន្ធ ដែលត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងទ្វេភាគីរវាងរដ្ឋនិងរដ្ឋ។ សិទ្ធិនោះមិនត្រូវបានផ្ទេរ ឬចែករំលែកទៅឱ្យបណ្ដារដ្ឋទីបី ឬពលរដ្ឋរបស់រដ្ឋនោះឡើយ។

២. រដ្ឋប្រជុំកោះត្រូវគោរពនូវបណ្ដាញខ្សែកាបក្រោមសមុទ្រដែលមានស្រាប់ ដែលត្រូវបានពង្រាយដោយបណ្ដារដ្ឋផ្សេងទៀត និងដែលឆ្លងកាត់ដែនសមុទ្ររបស់ខ្លួនដោយមិនប៉ះប្រាំង។ រដ្ឋប្រជុំកោះត្រូវអនុញ្ញាតដល់ការថែទាំនិងផ្លាស់ប្ដូរខ្សែកាបទាំងនោះ បន្ទាប់ពីទទួលបានការជូនដំណឹងត្រឹមត្រូវអំពីទីតាំង និងគោលបំណងជួសជុលឬផ្លាស់ប្ដូរខ្សែកាបទាំងនោះ។

## មាត្រា៥២

## សិទ្ធិឆ្លងកាត់ដោយមិនបំពាន

១. ក្រោមលក្ខខណ្ឌនៃមាត្រា៥៣ និងដោយមិនប៉ះពាល់ដល់មាត្រា៥០ នាវានៃបណ្ដារដ្ឋទាំងអស់ មានសិទ្ធិឆ្លងកាត់ដោយមិនបំពាន កាត់តាមផ្ទៃទឹកប្រជុំកោះ ដោយអនុលោមតាមផ្នែកទី៣នៃជំពូកទី២។

២. រដ្ឋប្រជុំកោះ អាចផ្អាកជាបណ្ដោះអាសន្ននូវការឆ្លងកាត់ដោយមិនបំពានរបស់នាវាបរទេសក្នុងតំបន់ជាក់លាក់នៃផ្ទៃទឹកប្រជុំកោះរបស់ខ្លួន ដោយគ្មានការរើសអើងក្នុងទម្រង់ឬតាមព្រឹត្តិន័យក្នុងចំណោមនាវាបរទេស ប្រសិនបើការផ្អាកទាំងនេះមានសារៈសំខាន់សម្រាប់ការពារសន្តិសុខរបស់ខ្លួន។ ការផ្អាកទាំងនេះត្រូវមានប្រសិទ្ធភាពអនុវត្ត តែបន្ទាប់ពីបានជូនដំណឹងត្រឹមត្រូវជាសាធារណៈប៉ុណ្ណោះ។

## មាត្រា៥៣
## សិទ្ធិនៃការឆ្លងកាត់តាមគន្លងផ្លូវសមុទ្រប្រជុំកោះ

១. រដ្ឋប្រជុំកោះ អាចកំណត់គន្លងផ្លូវសមុទ្រនិងខ្សែផ្លូវអាកាសខាងលើ ដែលមានលក្ខណៈសក្តិសមសម្រាប់ការឆ្លងកាត់ដោយបន្តជាប់ឥតបង្អង់និងដោយឆាប់រហ័សរបស់នាវានិងអាកាសយានបរទេស កាត់តាមឬនៅពីលើផ្ទៃទឹកប្រជុំកោះរបស់ខ្លួននិងតំបន់សមុទ្រដែនដីដែលស្ថិតនៅជាប់នោះ។

២. នាវានិងអាកាសយានទាំងអស់ មានសិទ្ធិឆ្លងកាត់តាមគន្លងផ្លូវសមុទ្រប្រជុំកោះ ក្នុងគន្លងផ្លូវសមុទ្រនិងខ្សែផ្លូវអាកាសទាំងនេះ។

៣. ការឆ្លងកាត់តាមគន្លងផ្លូវសមុទ្រប្រជុំកោះ សំដៅដល់ការអនុវត្តដោយអនុលោមតាមអនុសញ្ញានេះនូវសិទ្ធិនៃការធ្វើនាវាចរណ៍និងការហោះហើរឆ្លងកាត់ តាមលក្ខណៈធម្មតាតែក្នុងគោលបំណងនៃដំណើរឆ្លងកាត់ដោយបន្តជាប់ឥតបង្អង់ ដោយឆាប់រហ័ស និងដោយគ្មានឧបសគ្គ រវាងផ្នែកមួយនៃលម្ហសមុទ្រអន្តរជាតិឬតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងផ្នែកមួយផ្សេងទៀតនៃលម្ហសមុទ្រអន្តរជាតិឬតំបន់សេដ្ឋកិច្ចផ្តាច់មុខប៉ុណ្ណោះ។

៤. គន្លងផ្លូវសមុទ្រ និងខ្សែផ្លូវអាកាសទាំងនេះ ត្រូវឆ្លងកាត់តាមផ្ទៃទឹកប្រជុំកោះ និងសមុទ្រដែនដីដែលស្ថិតនៅជាប់គ្នានោះ និងត្រូវរាប់បញ្ចូលទាំងផ្លូវឆ្លងកាត់ធម្មតាទាំងអស់ ដែលប្រើប្រាស់ជាផ្លូវសម្រាប់ការធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ឬការហោះហើរឆ្លងកាត់ កាត់តាម ឬពីលើផ្ទៃទឹកប្រជុំកោះនោះ។ ចំពោះនាវា ខ្សែផ្លូវទាំងនោះរួមបញ្ចូលគ្រប់ច្រកនាវាចរណ៍ធម្មតាទាំងអស់ និងមិនមានភាពចាំបាច់នៅក្នុងការបង្កើតខ្សែផ្លូវស្ទួនសម្រាប់ចំណុចចេញចូលតែមួយដែលផ្តល់ភាពងាយស្រួលដូចគ្នានោះទេ។

៥. គន្លងផ្លូវសមុទ្រនិងខ្សែផ្លូវអាកាសទាំងនេះ ត្រូវកំណត់ដោយខ្សែបន្ទាត់អ័ក្សជាប់ៗគ្នាជាបន្តបន្ទាប់ពីចំណុចចូលរបស់ផ្លូវឆ្លងកាត់ទៅចំណុចចេញ។ នាវានិងអាកាសយានដែលស្ថិតនៅក្នុងការឆ្លងកាត់តាមផ្លូវសមុទ្រប្រជុំកោះ មិនត្រូវងាកចេញពីបន្ទាត់អ័ក្សលើសពី២៥ម៉ៃល៍សមុទ្រទៅចំហៀងណាមួយនៃខ្សែបន្ទាត់អ័ក្សទាំងនេះក្នុងអំឡុងពេលនៃការឆ្លងកាត់ឡើយ ក្នុងលក្ខខណ្ឌដែលនាវានិងអាកាសយានទាំងនេះ មិនត្រូវបើកបរជិតឆ្នេរសមុទ្រក្នុងចម្ងាយតិចជាង១០ភាគរយនៃចម្ងាយរវាងចំណុចដែលស្ថិតនៅជិតបំផុតនៅលើបណ្តាកោះដែលជាប់នឹងគន្លងផ្លូវសមុទ្រនោះ។

៦. រដ្ឋប្រជុំកោះដែលកំណត់គន្លងផ្លូវសមុទ្រដូចមានចែងក្នុងមាត្រានេះ ក៏អាចកំណត់គន្លងបែងចែកចរាចរណ៍សម្រាប់ការឆ្លងកាត់របស់នាវាប្រកបដោយសុវត្ថិភាពកាត់តាមច្រកនាវាចរណ៍តូចចង្អៀត ដែលស្ថិតនៅក្នុងគន្លងផ្លូវសមុទ្រទាំងនេះបានដែរ។

៧. នៅក្នុងស្ថានភាពចាំបាច់ បន្ទាប់ពីធ្វើការផ្សព្វផ្សាយត្រឹមត្រូវជាសាធារណៈមក រដ្ឋប្រជុំកោះទាំងនេះអាចដាក់ឱ្យប្រើប្រាស់គន្លងផ្លូវសមុទ្រឬគន្លងបែងចែកចរាចរណ៍ផ្សេងទៀតជំនួសឱ្យគន្លងផ្លូវសមុទ្រឬគន្លងបែងចែកចរាចរណ៍ណាមួយ ដែលខ្លួនបានកំណត់ឬរៀបចំកន្លងមក។

៨. គន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ទាំងនេះ ត្រូវមានលក្ខណៈស្របទៅតាមបទប្បញ្ញត្តិអន្តរជាតិដែលមានការទទួលយកជាទូទៅ។

៩. នៅក្នុងការកំណត់ឬការដាក់ឱ្យប្រើប្រាស់គន្លងផ្លូវសមុទ្រជំនួស ឬការកំណត់ឬការដាក់ឱ្យប្រើប្រាស់គន្លងបែងចែកចរាចរណ៍ជំនួស រដ្ឋប្រជុំកោះត្រូវលើកសំណើសុំការអនុម័តទៅអង្គការអន្តរជាតិមានសមត្ថកិច្ច។ អង្គការនេះ អាចអនុម័តតែចំពោះគន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ណាដែលអាចទទួលបានការព្រមព្រៀងពីបណ្តារដ្ឋប្រជុំកោះនោះប៉ុណ្ណោះ ហើយបន្ទាប់ពីមានការព្រមព្រៀងនោះមក រដ្ឋប្រជុំកោះត្រូវកំណត់ រៀបចំ ឬដាក់ឱ្យប្រើប្រាស់ជំនួសនូវគន្លងផ្លូវសមុទ្រឬគន្លងបែងចែកចរាចរណ៍ទាំងនោះបាន។

១០. រដ្ឋប្រជុំកោះត្រូវបង្ហាញយ៉ាងច្បាស់លាស់អំពីអ័ក្សនៃគន្លងផ្លូវសមុទ្រនិងគន្លងបែងចែកចរាចរណ៍ដែលខ្លួនបានកំណត់ឬបានរៀបចំនៅលើផែនទីសមុទ្រដែលត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យបានត្រឹមត្រូវ។

១១. នាវាដែលស្ថិតនៅក្នុងការឆ្លងកាត់គន្លងផ្លូវសមុទ្រប្រជុំកោះ ត្រូវគោរពតាមគន្លងផ្លូវសមុទ្រ និងគន្លងបែងចែកចរាចរណ៍ជាធរមាន ដូចមានចែងក្នុងមាត្រានេះ។

១២. ប្រសិនបើរដ្ឋប្រជុំកោះមិនបានកំណត់គន្លងផ្លូវសមុទ្រ ឬខ្សែផ្លូវអាកាសទេនោះ សិទ្ធិនៃការឆ្លងកាត់តាមគន្លងផ្លូវសមុទ្រប្រជុំកោះ អាចត្រូវបានអនុវត្តដោយឆ្លងកាត់តាមគន្លងផ្លូវសមុទ្រដែលប្រើប្រាស់ជាធម្មតាសម្រាប់ការធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ។

### មាត្រា៥៤
### ករណីយកិច្ចរបស់នាវានិងអាកាសយានក្នុងអំឡុងពេលនៃការឆ្លងកាត់ សកម្មភាពស្រាវជ្រាវនិងប្រមូលទិន្នន័យរបស់នាវានិងអាកាសយាន ករណីយកិច្ចរបស់រដ្ឋប្រជុំកោះ និងច្បាប់និងបទប្បញ្ញត្តិរបស់រដ្ឋប្រជុំកោះដែលទាក់ទងនឹងការឆ្លងកាត់តាមគន្លងផ្លូវសមុទ្រប្រជុំកោះ

មាត្រា៣៩ មាត្រា៤០ មាត្រា៤២ និងមាត្រា៤៤ ត្រូវយកមកអនុវត្តដូចគ្នាចំពោះការឆ្លងកាត់តាមគន្លងផ្លូវសមុទ្រប្រជុំកោះ។

## ជំពូកទី៥
## តំបន់សេដ្ឋកិច្ចផ្តាច់មុខ

### មាត្រា៥៥
### របបគតិយុត្តដោយឡែកនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ

តំបន់សេដ្ឋកិច្ចផ្តាច់មុខ ជាតំបន់ដែលលាតសន្ធឹងហួសនិងជាប់នឹងសមុទ្រដែនដី ដែលអនុវត្តតាមរបបគតិយុត្តដោយឡែកដូចមានចែងនៅក្នុងជំពូកនេះ ដែលក្នុងនោះសិទ្ធិនិងយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរសមុទ្រនិងសិទ្ធិនិងសេរីភាពរបស់បណ្តារដ្ឋផ្សេងទៀត ត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ។

### មាត្រា៥៦
### សិទ្ធិ យុត្តាធិការ និងករណីយកិច្ចរបស់រដ្ឋជាប់ឆ្នេរសមុទ្រក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ

១. ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ រដ្ឋជាប់ឆ្នេរសមុទ្រមាន៖

(ក) សិទ្ធិអធិបតេយ្យសម្រាប់គោលបំណងក្នុងការស្វែងរុករកនិងការធ្វើអាជីវកម្ម ការអភិរក្សនិងការគ្រប់គ្រងធនធានធម្មជាតិ ទាំងមានជីវិតឬគ្មានជីវិត ក្នុងដែនទឹកដែលនៅពីលើបាតសមុទ្រ និងលើបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រ ហើយចំពោះ-សកម្មភាពផ្សេងទៀតសម្រាប់ការធ្វើអាជីវកម្មនិងការស្វែងរុករកផ្នែកសេដ្ឋកិច្ចក្នុងតំបន់នោះ ដូចជាផលិតកម្មថាមពលចេញពីទឹក ចរន្តទឹកហូរ និងខ្យល់ផងដែរ។

(ខ) យុត្តាធិការដូចមានចែងក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ ដែលទាក់ទងនឹង៖

(i) ការបង្កើតនិងការប្រើប្រាស់កោះសិប្បនិម្មិត បបនាការនិងរចនាសម្ព័ន្ធ។

(ii) ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ។

(iii) ការការពារនិងការថែរក្សាបរិស្ថានសមុទ្រ។

(គ) សិទ្ធិនិងករណីយកិច្ចផ្សេងទៀតដូចមានចែងក្នុងអនុសញ្ញានេះ។

២. ក្នុងការអនុវត្តសិទ្ធិនិងការអនុវត្តករណីយកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវផ្តល់ការយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវចំពោះសិទ្ធិនិងករណីយកិច្ចរបស់បណ្តារដ្ឋផ្សេងទៀត និងត្រូវធ្វើសកម្មភាពក្នុងលក្ខណៈមួយដែលស្របនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

៣. សិទ្ធិដែលបានកំណត់ក្នុងមាត្រានេះ ទាក់ទងនឹងបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រ ត្រូវអនុវត្តដោយអនុលោមតាមជំពូកទី៦។

## មាត្រា៥៧

## ប្រវែងទទឹងនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ

តំបន់សេដ្ឋកិច្ចផ្តាច់មុខ មិនត្រូវលាតសន្ធឹងហួសពី២០០ ម៉ែល៍សមុទ្រ គិតពីខ្សែបន្ទាត់មូលដ្ឋានដែលប្រវែងទទឹងនៃសមុទ្រដែនដី ត្រូវបានវាស់ចេញពីខ្សែបន្ទាត់មូលដ្ឋាននេះ។

## មាត្រា៥៨

## សិទ្ធិនិងករណីយកិច្ចរបស់បណ្តារដ្ឋផ្សេងទៀតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ

១. នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ បណ្តារដ្ឋទាំងអស់ ទោះជារដ្ឋជាប់ឆ្នេរសមុទ្រឬរដ្ឋមិនជាប់សមុទ្រក្តី ដោយអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ មានសិទ្ធិទទួលបាននូវសេរីភាពដូចមានចែងក្នុងមាត្រា៨៧ ពាក់ព័ន្ធនឹងការធ្វើនាវាចរណ៍និងការហោះហើរឆ្លងកាត់ ការដាក់ពង្រាយខ្សែកាបនិងបំពង់បង្ហូរនៅបាតសមុទ្រ និងការប្រើប្រាស់សមុទ្រដោយស្របនីតិអន្តរជាតិផ្សេងទៀតដែលទាក់ទងនឹងសេរីភាពទាំងនេះ ដូចជាសេរីភាពពាក់ព័ន្ធនឹងប្រតិបត្តិការនាវា អាកាសយាន ខ្សែកាបនិងបំពង់បង្ហូរនៅបាតសមុទ្រ និងសេរីភាពដែលស្របនឹងបទប្បញ្ញត្តិផ្សេងទៀតនៃអនុសញ្ញានេះ។

២. មាត្រា៨៨ ដល់មាត្រា១១៥ និងវិធានពាក់ព័ន្ធផ្សេងទៀតនៃច្បាប់អន្តរជាតិ ត្រូវអនុវត្តចំពោះតំបន់សេដ្ឋកិច្ចផ្តាច់មុខ ប្រសិនបើវិធានទាំងនោះមិនផ្ទុយនឹងបទប្បញ្ញត្តិនៃជំពូកនេះ។

៣. ក្នុងការអនុវត្តសិទ្ធិ និងការអនុវត្តករណីយកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ បណ្តារដ្ឋត្រូវផ្តល់ការយកចិត្តទុកដាក់ចំពោះសិទ្ធិនិងករណីយកិច្ចរបស់រដ្ឋជាប់ឆ្នេរសមុទ្រ និងត្រូវគោរពតាមច្បាប់និងបទបញ្ញាដែលអនុម័តដោយរដ្ឋជាប់ឆ្នេរសមុទ្រអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ និងវិធានផ្សេងទៀតនៃនីតិអន្តរជាតិ ប្រសិនបើវិធានទាំងនោះមិនផ្ទុយនឹងបទប្បញ្ញត្តិនៃជំពូកនេះ។

## មាត្រា៥៩

## មូលដ្ឋានសម្រាប់ការដោះស្រាយវិវាទទាក់ទងនឹងការផ្តល់សិទ្ធិនិងយុត្តាធិការក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ

ក្នុងករណីដែលអនុសញ្ញានេះមិនបានផ្តល់សិទ្ធិឬយុត្តាធិការដល់រដ្ឋជាប់ឆ្នេរសមុទ្រ ឬបណ្តារដ្ឋផ្សេងទៀតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ហើយមានវិវាទកើតឡើងទាក់ទងនឹងផលប្រយោជន៍របស់រដ្ឋជាប់ឆ្នេរសមុទ្រ និងរដ្ឋឬបណ្តារដ្ឋផ្សេងទៀត វិវាទនេះគួរត្រូវដោះស្រាយដោយផ្អែកលើគោលការណ៍សមធម៌ និងពិចារណាដល់គ្រប់ស្ថានភាពពាក់ព័ន្ធទាំងអស់ ដោយគិតគូរអំពីសារៈសំខាន់នៃផលប្រយោជន៍ពាក់ព័ន្ធចំពោះភាគីនីមួយៗ ក៏ដូចជាចំពោះសហគមន៍អន្តរជាតិទាំងមូល។

## មាត្រា៦០

## កោះសិប្បនិម្មិត បរិក្ខារ និងរចនាសម្ព័ន្ធនានានៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ

១. នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវមានសិទ្ធិផ្តាច់មុខដើម្បីសាងសង់ និងអនុញ្ញាត និងធ្វើនិយ័តកម្មលើការសាងសង់ ការធ្វើប្រតិបត្តិការ និងការប្រើប្រាស់៖

(ក) កោះសិប្បនិម្មិត។

(ខ) បរិក្ខារនិងរចនាសម្ព័ន្ធនានាសម្រាប់គោលបំណងដូចមានចែងក្នុងមាត្រា៥៦ និងសម្រាប់គោលបំណងសេដ្ឋកិច្ចផ្សេងទៀត ។

(គ) បរិក្ខារនិងរចនាសម្ព័ន្ធនានាដែលអាចរំខានដល់ការអនុវត្តសិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ។

២. រដ្ឋជាប់ឆ្នេរសមុទ្រ ត្រូវមានយុត្តាធិការផ្តាច់មុខលើកោះសិប្បនិម្មិត បរិក្ខារនិងរចនាសម្ព័ន្ធទាំងនេះ រាប់បញ្ចូលទាំងយុត្តាធិការដែលទាក់ទងនឹងច្បាប់និងបទបញ្ញាពាក់ព័ន្ធនឹងគយ សារពើពន្ធ សុខាភិបាល សុវត្ថិភាព និងអន្តោប្រវេសន៍។

៣. ការជូនដំណឹងអំពីការសាងសង់កោះសិប្បនិម្មិត បរិក្ខារនិងរចនាសម្ព័ន្ធទាំងនេះត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវ និងត្រូវរក្សាទុកនូវមធ្យោបាយអចិន្ត្រៃយ៍សម្រាប់ផ្តល់ព័ត៌មានព្រមានអំពីវត្តមាននៃការសាងសង់កោះសិប្បនិម្មិត បរិក្ខារនិងរចនាសម្ព័ន្ធទាំងនេះ។ រាល់បរិក្ខារឬរចនាសម្ព័ន្ធដែលត្រូវបានបោះបង់ចោល ឬឈប់ប្រើប្រាស់ ត្រូវរុះរើចេញ ដើម្បីធានាសុវត្ថិភាពក្នុងការធ្វើនាវាចរណ៍ ដោយអនុលោមតាមបទដ្ឋានអន្តរជាតិដែលមានការទទួលយកជាទូទៅដែលបានបង្កើតឡើងដោយអង្គការអន្តរជាតិមានសមត្ថកិច្ច។ ការរុះរើទាំងនេះក៏ត្រូវផ្តល់ការយកចិត្តទុកដាក់ចំពោះការធ្វើនេសាទ ការការពារបរិស្ថានសមុទ្រ ព្រមទាំងសិទ្ធិនិងករណីយកិច្ចរបស់បណ្តារដ្ឋផ្សេងទៀតផងដែរ។ ការផ្សព្វផ្សាយជាសាធារណៈត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវដោយមានបញ្ជាក់អំពីជម្រៅទឹក ទីតាំង និងវិមាត្ររបស់បរិក្ខារឬរចនាសម្ព័ន្ធដែលមិនត្រូវបានរុះរើចេញទាំងស្រុង។

៤. ប្រសិនបើចាំបាច់ រដ្ឋជាប់ឆ្នេរសមុទ្រអាចបង្កើតតំបន់សុវត្ថិភាពសមហេតុផលព័ទ្ធជុំវិញកោះសិប្បនិម្មិត បរិក្ខារនិងរចនាសម្ព័ន្ធដែលមាននៅក្នុងតំបន់ ដោយអាចចាត់វិធានការសមស្របដើម្បីធានាសុវត្ថិភាព ទាំងការធ្វើនាវាចរណ៍និងទាំងកោះសិប្បនិម្មិត បរិក្ខារនិងរចនាសម្ព័ន្ធទាំងនោះ។

៥. ទទឹងនៃតំបន់សុវត្ថិភាព ត្រូវកំណត់ដោយរដ្ឋជាប់ឆ្នេរសមុទ្រ ដោយអនុលោមតាមបទដ្ឋានអន្តរជាតិជាធរមាន។ តំបន់ទាំងនេះ ត្រូវរៀបចំឡើងដើម្បីធានាថា តំបន់ទាំងនេះមានលក្ខណៈសមហេតុផលទៅនឹងធម្មជាតិនិងមុខងាររបស់កោះសិប្បនិម្មិត បរិក្ខារឬរចនាសម្ព័ន្ធ និងមិនត្រូវមានចម្ងាយលើសពី–៥០០ម៉ែត្រព័ទ្ធជុំវិញកោះសិប្បនិម្មិត បរិក្ខារឬរចនាសម្ព័ន្ធទាំងនោះឡើយ ដោយត្រូវវាស់ចេញពីចំណុចនីមួយៗនៃគែមខាងក្រៅរបស់វា លើកលែងតែត្រូវបានអនុញ្ញាតដោយបទដ្ឋានអន្តរជាតិដែលមានការទទួលយកជាទូទៅដែលបានបង្កើតឡើងដោយអង្គការអន្តរជាតិមានសមត្ថកិច្ច។ ការជូនដំណឹងអំពីវិសាលភាពរបស់តំបន់សុវត្ថិភាព ត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវ។

៦.  នាវាទាំងអស់ ត្រូវគោរពតំបន់សុវត្ថិភាពទាំងនេះ និងត្រូវអនុវត្តតាមបទដ្ឋានអន្តរជាតិដែលទទួលយកជាទូទៅទាក់ទងនឹងការធ្វើនាវាចរណ៍ក្នុងបរិវេណកោះសិប្បនិម្មិត បបនាការនិងរចនាសម្ព័ន្ធ និងតំបន់សុវត្ថិភាពនោះ។

៧.  កោះសិប្បនិម្មិត បបនាការនិងរចនាសម្ព័ន្ធ និងតំបន់សុវត្ថិភាពព័ទ្ធជុំវិញ មិនអាចបង្កើតឡើងនៅកន្លែងដែលអាចបណ្តាលឱ្យមានការរំខានដល់ការប្រើប្រាស់គន្លងផ្លូវសមុទ្រដែលបានទទួលស្គាល់ និងដែលសំខាន់ចំពោះការធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិឡើយ។

៨.  កោះសិប្បនិម្មិត បបនាការនិងរចនាសម្ព័ន្ធ មិនមានលក្ខន្តិកៈជាកោះនោះទេ។ កោះសិប្បនិម្មិត បបនការនិងរចនាសម្ព័ន្ធទាំងនោះ មិនមានសមុទ្រដែនដីផ្ទាល់របស់ខ្លួនទេ ហើយវត្តមានរបស់វា មិនប៉ះពាល់ដល់ការកំណត់ព្រំដែននៃសមុទ្រដែនដី តំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬខ្ពង់រាបបាតសមុទ្រឡើយ។

## មាត្រា៦១

## ការអភិរក្សធនធានមានជីវិត

១.  រដ្ឋជាប់ឆ្នេរសមុទ្រត្រូវកំណត់បរិមាណផលនៃធនធានមានជីវិតដែលអនុញ្ញាតឱ្យធ្វើនេសាទនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន។

២.  ដោយផ្អែកលើភស្តុតាងផ្នែកវិទ្យាសាស្ត្រល្អបំផុតដែលខ្លួនមាន រដ្ឋជាប់ឆ្នេរសមុទ្រត្រូវធានាតាមរយៈវិធានការអភិរក្សនិងគ្រប់គ្រង  ថាការថែទាំធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខមិនត្រូវបានរងគ្រោះថ្នាក់ដោយការធ្វើអាជីវកម្មហួសកម្រិតឡើយ។ រដ្ឋជាប់ឆ្នេរសមុទ្រនិងអង្គការអន្តរជាតិមានសមត្ថកិច្ចទាំងថ្នាក់អនុតំបន់ថ្នាក់តំបន់ ឬសកលត្រូវសហប្រតិបត្តិការតាមភាពសមស្រប ដើម្បីបុព្វហេតុនេះ។

៣.  វិធានការទាំងនេះក៏ត្រូវបង្កើតឡើង ដើម្បីថែរក្សាឬស្តារនូវផលស្តុកនៃប្រភេទត្រីដែលបាននេសាទក្នុងកម្រិតដែលអាចផ្តល់នូវទិន្នផលនិរន្តរភាពអតិបរមាផ្អែកតាមកត្តាបរិស្ថាននិងសេដ្ឋកិច្ចពាក់ព័ន្ធ រាប់បញ្ចូលទាំងតម្រូវការសេដ្ឋកិច្ចរបស់សហគមន៍នេសាទតំបន់ឆ្នេរ និងតម្រូវការពិសេសរបស់រដ្ឋដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ហើយត្រូវគិតគូរដល់វិធីសាស្ត្រនៃការនេសាទ អន្តរនិស្សារភាពនៃស្តុកត្រីនិងស្តង់ដាអប្បបរមាជាអន្តរជាតិដែលជាអនុសាសន៍ទូទៅ ទាំងថ្នាក់អនុតំបន់ ថ្នាក់តំបន់ ឬសកល។

៤.  ក្នុងការអនុវត្តវិធានការទាំងនេះ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវពិចារណាអំពីផលប៉ះពាល់ទៅលើប្រភេទត្រីពាក់ព័ន្ធឬពឹងអាស្រ័យលើប្រភេទត្រីដែលនេសាទ ក្នុងទិសដៅថែរក្សាឬស្តារនូវផលស្តុកនៃប្រភេទត្រីពាក់ព័ន្ធឬពឹងអាស្រ័យទាំងនោះ ឱ្យបានលើកម្រិតដែលការបន្តពូជរបស់វាអាចរងការគំរាមកំហែងធ្ងន់ធ្ងរ។

៥.  ព័ត៌មានវិទ្យាសាស្ត្រ ស្ថិតិផលនេសាទនិងកម្លាំងនេសាទ និងទិន្នន័យផ្សេងទៀតពាក់ព័ន្ធនឹងការអភិរក្សផលស្តុកត្រីដែលមាន ត្រូវផ្តល់និងចែករំលែកយ៉ាងទៀងទាត់តាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ទាំងថ្នាក់អនុតំបន់ ថ្នាក់តំបន់ ឬសកល តាមភាពសមស្របនិងដោយមានការចូលរួមពីបណ្តារដ្ឋពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងបណ្តារដ្ឋដែលពលរដ្ឋខ្លួនត្រូវបានអនុញ្ញាតឱ្យធ្វើការនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ។

## មាត្រា៦២

## ការប្រើប្រាស់ធនធានមានជីវិត

១.  រដ្ឋជាប់ឆ្នេរសមុទ្រត្រូវលើកកម្ពស់គោលដៅនៃការប្រើប្រាស់ឱ្យបានល្អបំផុតនៃធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដោយមិនឱ្យប៉ះពាល់ដល់មាត្រា៦១។

២. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវកំណត់អំពីសមត្ថភាពរបស់ខ្លួនក្នុងការប្រមូលផលធនធានមានជីវិត ក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ។ ក្នុងករណីរដ្ឋជាប់ឆ្នេរសមុទ្រមិនមានសមត្ថភាពប្រមូលផលនេសាទដែលអនុញ្ញាតឱ្យនេសាទបានទាំងស្រុងនោះ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវផ្ដល់ជូនដល់បណ្ដារដ្ឋផ្សេងទៀតនូវសិទ្ធិក្នុងការប្រមូលផលនេសាទដែលលើសតម្រូវការ តាមរយៈកិច្ចព្រមព្រៀងឬការរៀបចំផ្សេងទៀត និងត្រូវអនុលោមតាមលក្ខខណ្ឌច្បាប់និងបទបញ្ជាដូចមានចែងក្នុងកថាខណ្ឌទី៤នៃមាត្រានេះ ដោយគិតគូរជាចម្បងលើបទប្បញ្ញត្តិនៃមាត្រា៦៩ និងមាត្រា៧០ ជាពិសេសទាក់ទងនឹងរដ្ឋដែលជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានលើកឡើងក្នុងមាត្រាទាំងនោះ។

៣. ក្នុងការផ្ដល់សិទ្ធិដល់បណ្ដារដ្ឋផ្សេងទៀតក្នុងការប្រមូលផលនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ខ្លួនស្របតាមមាត្រានេះ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវពិចារណាទៅលើកត្តាពាក់ព័ន្ធទាំងអស់ ដែលមានជាអាទិ៍ សារៈសំខាន់នៃធនធានមានជីវិតក្នុងតំបន់ចំពោះសេដ្ឋកិច្ចរបស់រដ្ឋជាប់ឆ្នេរសមុទ្រពាក់ព័ន្ធនិងផលប្រយោជន៍ជាតិផ្សេងទៀតរបស់ខ្លួន បទប្បញ្ញត្តិនៃមាត្រា៦៩ និងមាត្រា៧០ តម្រូវការរបស់រដ្ឋដែលជាប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងអនុតំបន់ឬតំបន់ពាក់ព័ន្ធនឹងការប្រមូលផលនេសាទដែលលើសតម្រូវការ និងតម្រូវការក្នុងការកាត់បន្ថយការប៉ះពាល់ដល់វេនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងបណ្ដារដ្ឋដែលពលរដ្ឋមានទម្លាប់នេសាទនៅក្នុងតំបន់ ឬដែលបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងការស្រាវជ្រាវនិងកំណត់អត្តសញ្ញាណរបស់ផលស្តុកត្រី។

៤. ពលរដ្ឋនៃបណ្ដារដ្ឋផ្សេងទៀតដែលនេសាទក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ ត្រូវគោរពតាមវិធានការអភិរក្សព្រមទាំងលក្ខខណ្ឌនិងបែបបទផ្សេងទៀតដែលកំណត់នៅក្នុងច្បាប់និងបទបញ្ជារបស់រដ្ឋជាប់ឆ្នេរសមុទ្រ។ ច្បាប់និងបទបញ្ជាទាំងនេះត្រូវស្របជាមួយនឹងអនុសញ្ញានេះ ហើយអាចពាក់ព័ន្ធជាអាទិ៍ដូចខាងក្រោម៖

(ក) ការផ្ដល់អាជ្ញាបណ្ណដល់ប្រជានេសាទ នាវានេសាទ និងការប្រើប្រាស់សម្ភារៈបរិក្ខារ រាប់បញ្ចូលទាំងការបង់ថ្លៃសេវានិងប្រាក់កម្រៃក្នុងទម្រង់ផ្សេងទៀត ដែលក្នុងករណីរដ្ឋជាប់ឆ្នេរសមុទ្រដែលជាប្រទេសកំពុងអភិវឌ្ឍន៍ អាចជាផលតបស្នងគ្រប់គ្រាន់ក្នុងវិស័យហិរញ្ញប្បទាន សម្ភារៈបរិក្ខារ និងបច្ចេកវិទ្យាទាក់ទងនឹងវិស័យនេសាទ។

(ខ) ការកំណត់ប្រភេទត្រីដែលអាចនេសាទបាននិងកំណត់អំពីបរិមាណកូតាផលនេសាទទាក់ទងទៅនឹងផលស្តុកនៃប្រភេទជាក់លាក់ឬក្រុមនៃផលស្តុក ឬផលនេសាទក្នុងមួយនាវាសម្រាប់រយៈពេលមួយ ឬទាក់ទងនឹងផលនេសាទដោយពលរដ្ឋរបស់រដ្ឋណាមួយក្នុងអំឡុងពេលកំណត់ជាក់លាក់។

(គ) ការកំណត់រដូវនេសាទនិងតំបន់នេសាទ ប្រភេទ ទំហំ និងចំនួនឧបករណ៍នេសាទ ព្រមទាំងប្រភេទ ទំហំ និងចំនួននាវានេសាទដែលអាចប្រើប្រាស់បាន។

(ឃ) ការកំណត់អាយុនិងទំហំត្រី និងប្រភេទត្រីផ្សេងទៀតដែលអាចនេសាទបាន។

(ង) ការកំណត់ព័ត៌មានដែលត្រូវការពីនាវានេសាទ រួមទាំងស្ថិតិផលនេសាទនិងកម្លាំងនេសាទព្រមទាំងរបាយការណ៍ទីតាំងនាវា។

(ច) ស្ថិតក្រោមការអនុញ្ញាតនិងការត្រួតពិនិត្យរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ការតម្រូវឱ្យមានការអនុវត្តកម្មវិធីស្រាវជ្រាវវិស័យជលផលជាក់លាក់និងការធ្វើនិយ័តកម្មលើការស្រាវជ្រាវ រាប់បញ្ចូលទាំងការយកសំណាកផលនេសាទ ការប្រើប្រាស់សំណាក និងការរាយការណ៍ពាក់ព័ន្ធនឹងទិន្នន័យវិទ្យាសាស្ត្រ។

(ឆ) ការរៀបចំឱ្យមានអ្នកសង្កេតការណ៍ឬសិក្ខាកាមនៅលើនាវាដោយរដ្ឋជាប់ឆ្នេរសមុទ្រ។

(ជ) ការឡើងផលនេសាទទាំងអស់ឬមួយផ្នែកពីនាវានេសាទទាំងនោះនៅកំពង់ផែនេសាទនៃរដ្ឋជាប់ឆ្នេរសមុទ្រ។

(ឈ) លក្ខខណ្ឌនិងបែបបទទាក់ទងនឹងការបណ្ដាក់ទុនរួមគ្នាឬកិច្ចសហប្រតិបត្តិការផ្សេងទៀត។

(ញ) លក្ខខណ្ឌសម្រាប់ការបណ្ដុះបណ្ដាលបុគ្គលិកនិងការផ្ទេរបច្ចេកវិទ្យាជលផល រាប់បញ្ចូលទាំងការពង្រឹងសមត្ថភាពរបស់រដ្ឋជាប់ឆ្នេរសមុទ្រក្នុងការអនុវត្តការស្រាវជ្រាវផ្នែកជលផល។

(ដ) នីតិវិធីនៃការអនុវត្តច្បាប់។

៥. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវជូនដំណឹងជាផ្លូវការអំពីច្បាប់និងបទបញ្ជានៃការអភិរក្សនិងការគ្រប់គ្រង។

## មាត្រា៦៣

## ផលស្តុកដែលមាននៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃរដ្ឋជាប់ឆ្នេរសមុទ្រពីរឬច្រើន ឬនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខផងនិងនៅក្នុងតំបន់លាតសន្ធឹងហួសពី និងនៅជាប់គ្នានឹងតំបន់សេដ្ឋកិច្ចផ្តាច់មុខផង

១. ក្នុងករណីដែលមានផលស្តុកដូចគ្នាឬផលស្តុកនៃប្រភេទត្រីពាក់ព័ន្ធគ្នានៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃរដ្ឋជាប់ឆ្នេរសមុទ្រពីរឬច្រើន បណ្ដារដ្ឋទាំងនេះត្រូវស្វែងរកការព្រមព្រៀងគ្នាដោយផ្ទាល់ឬតាមរយៈអង្គការអនុតំបន់ ឬថ្នាក់តំបន់សមស្រប ទៅលើវិធានការចាំបាច់ដើម្បីសម្របសម្រួលនិងធានាការអភិរក្សនិងការអភិវឌ្ឍផលស្តុកទាំងនេះ ដោយមិនប៉ះពាល់ទៅដល់បទប្បញ្ញត្តិផ្សេងទៀតនៃជំពូកនេះ។

២. ក្នុងករណីដែលមានផលស្តុកដូចគ្នាឬផលស្តុកនៃប្រភេទត្រីពាក់ព័ន្ធគ្នានៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខផងនិងនៅក្នុងតំបន់លាតសន្ធឹងហួសពីនិងនៅជាប់គ្នានឹងតំបន់សេដ្ឋកិច្ចផ្តាច់មុខនេះផង រដ្ឋជាប់ឆ្នេរសមុទ្រនិងរដ្ឋដែលនេសាទផលស្តុកទាំងនេះនៅក្នុងតំបន់នៅជាប់គ្នានោះ ត្រូវស្វែងរកការព្រមព្រៀងគ្នាដោយផ្ទាល់ឬតាមរយៈអង្គការអនុតំបន់ឬថ្នាក់តំបន់សមស្រប ទៅលើវិធានការចាំបាច់ដើម្បីអភិរក្ស ផលស្តុកទាំងនេះនៅក្នុងតំបន់ជាប់នោះ។

## មាត្រា៦៤

## ប្រភេទត្រីផ្លាស់ទីឆ្ងាយ

១. រដ្ឋជាប់ឆ្នេរសមុទ្រនិងបណ្ដារដ្ឋផ្សេងទៀតដែលមានពលរដ្ឋធ្វើការនេសាទក្នុងតំបន់ដែលមានប្រភេទត្រីផ្លាស់ទីឆ្ងាយ ដូចមានរាយប្រភេទក្នុងឧបសម្ព័ន្ធទី១ ត្រូវធ្វើសហប្រតិបត្តិការដោយផ្ទាល់ឬតាមរយៈអង្គការអន្តរជាតិសមស្រប ដើម្បីធានាឱ្យបាននូវការអភិរក្សនិងការលើកកម្ពស់គោលបំណងនៃការប្រើប្រាស់ឱ្យបានល្អបំផុតនូវប្រភេទត្រីទាំងនេះនៅក្នុងតំបន់ ទាំងក្នុងនិងក្រៅតំបន់សេដ្ឋកិច្ចផ្តាច់មុខ។ ក្នុងតំបន់ដែលពុំមានអង្គការអន្តរជាតិសមស្រប រដ្ឋជាប់ឆ្នេរសមុទ្រនិងបណ្ដារដ្ឋផ្សេងទៀតដែលមានពលរដ្ឋធ្វើការនេសាទប្រភេទត្រីទាំងនេះក្នុងតំបន់ត្រូវធ្វើសហប្រតិបត្តិការបង្កើតអង្គការបែបនេះ និងចូលរួមក្នុងកិច្ចការរបស់អង្គការនេះ។

២. បទប្បញ្ញត្តិនៃកថាខណ្ឌទី១ ត្រូវអនុវត្តបន្ថែមលើបទប្បញ្ញត្តិផ្សេងទៀតនៃជំពូកនេះ។

## មាត្រា៦៥

## ថនិកសត្វសមុទ្រ

គ្មានចំណុចណាមួយក្នុងផ្នែកនេះរារាំងដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រឬសមត្ថកិច្ចនៃអង្គការអន្តរជាតិតាមភាពសមស្រប ក្នុងការហាមឃាត់ ដាក់កម្រិត ឬធ្វើនិយ័តកម្មលើការធ្វើអាជីវកម្មថនិកសត្វសមុទ្រ ក្នុងកម្រិតមួយតឹងរ៉ឹងជាងបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកនេះឡើយ។ បណ្តារដ្ឋត្រូវធ្វើសហប្រតិបត្តិការដើម្បីអភិរក្សថនិកសត្វសមុទ្រ និងក្នុងករណីប្រភេទត្រីបាឡែនឬផ្សោតត្រូវធ្វើការងារជាពិសេសតាមរយៈអង្គការអន្តរជាតិសមស្របដើម្បីការអភិរក្ស ការគ្រប់គ្រង និងការសិក្សាលើពួកវា។

## មាត្រា៦៦

## ផលស្តុកប្រភេទត្រីសមុទ្រដែលពងកូននៅទឹកសាប

១. បណ្តារដ្ឋដែលផលស្តុកប្រភេទត្រីសមុទ្រដែលពងកូននៅទឹកសាបមានប្រភពពីព្រែកឬទន្លេរបស់រដ្ឋនោះ ត្រូវទទួលផលប្រយោជន៍ជាចម្បង និងទទួលខុសត្រូវទៅលើផលស្តុកទាំងនោះ។

២. រដ្ឋប្រភពដើមនៃផលស្តុកប្រភេទត្រីសមុទ្រដែលពងកូននៅទឹកសាបត្រូវធានាឱ្យបាននូវការអភិរក្សប្រភេទត្រីទាំងនោះដោយបង្កើតវិធានការគ្រប់គ្រងសមស្របសម្រាប់ការនេសាទនៅក្នុងដែនទឹកខាងក្នុងរហូតដល់ព្រំដែនខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន និងវិធានការសម្រាប់ការនេសាទដូចមានចែងក្នុងកថាខណ្ឌទី៣ (ខ)។ រដ្ឋប្រភពដើម បន្ទាប់ពីពិគ្រោះយោបល់ជាមួយបណ្តារដ្ឋផ្សេងទៀតដូចមានចែងក្នុងកថាខណ្ឌទី៣និងកថាខណ្ឌទី៤ដែលធ្វើការនេសាទនូវផលស្តុកប្រភេទត្រីទាំងនេះ អាចកំណត់បរិមាណផលសរុបដែលអនុញ្ញាតឱ្យនេសាទសម្រាប់ផលស្តុកដែលមានដើមកំណើតក្នុងព្រែកឬទន្លេរបស់ខ្លួន។

៣. (ក) ការនេសាទផលស្តុកប្រភេទត្រីសមុទ្រដែលពងកូននៅទឹកសាបត្រូវធ្វើឡើងតែក្នុងដែនទឹកខាងក្នុងរហូតដល់ព្រំដែនខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលបទប្បញ្ញត្តិនេះនាំឱ្យមានផលប៉ះពាល់ដល់វេទនាសម្ព័ន្ធសេដ្ឋកិច្ច របស់រដ្ឋដែលមិនមែនជារដ្ឋប្រភពដើមនៃផលស្តុក។ ទាក់ទងទៅនឹងការនេសាទហួសពីព្រំដែនខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខនោះ បណ្តារដ្ឋដែលពាក់ព័ន្ធត្រូវរក្សាការពិគ្រោះយោបល់គ្នា ដើម្បីសម្រេចឱ្យបាននូវកិច្ចព្រមព្រៀងស្តីពីលក្ខខណ្ឌនិងបែបបទនៃការនេសាទទាំងនេះ ដោយគោរពឱ្យបានត្រឹមត្រូវចំពោះលក្ខខណ្ឌអភិរក្ស និងតម្រូវការរបស់រដ្ឋប្រភពដើម ទាក់ទងទៅនឹងផលស្តុកប្រភេទត្រីទាំងនេះ។

(ខ) រដ្ឋប្រភពដើមត្រូវធ្វើកិច្ចសហប្រតិបត្តិការក្នុងការកាត់បន្ថយជាអប្បរមានូវផលប៉ះពាល់វេទនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងបណ្តារដ្ឋផ្សេងទៀតដែលនេសាទផលស្តុកប្រភេទត្រីទាំងនេះ ដោយពិចារណាទៅលើផលនេសាទជាប្រក្រតីនិងវិធីសាស្ត្រនេសាទរបស់បណ្តារដ្ឋទាំងនោះ ព្រមទាំងតំបន់ទាំងអស់ដែលមានការនេសាទបែបនេះកើតឡើង។

(គ) បណ្តារដ្ឋដូចមានចែងក្នុងកថាខណ្ឌរង(ខ)ដែលបានចូលរួមផ្តែកតាមកិច្ចព្រមព្រៀងជាមួយនឹងរដ្ឋប្រភពដើម ក្នុងការចាត់វិធានការស្តារឡើងវិញនូវផលស្តុកប្រភេទត្រីសមុទ្រដែលពងកូននៅទឹកសាប ជាពិសេសតាមរយៈការចំណាយ សម្រាប់គោលបំណងនៃការស្តារផលស្តុកនោះ ត្រូវទទួលបានការគិតគូរជាពិសេសពីរដ្ឋប្រភពដើម ក្នុងការអនុញ្ញាតឱ្យធ្វើការនេសាទផលស្តុកប្រភេទត្រីដែលបានពងកូននៅក្នុងព្រែកឬទន្លេរបស់ខ្លួន។

(ឃ) ការអនុវត្តបទបញ្ញាទាក់ទងនឹងផលស្តុកប្រភេទត្រីសមុទ្រដែលពងកូននៅទឹកសាបហួសពីតំបន់សេដ្ឋកិច្ចផ្តាច់មុខ ត្រូវធ្វើឡើងតាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋប្រភពដើមនៃផលស្តុកប្រភេទត្រី និងបណ្តារដ្ឋផ្សេងទៀតដែលពាក់ព័ន្ធ។

៤. ក្នុងករណីដែលផលស្តុកប្រភេទត្រីសមុទ្រដែលពងកូននៅទឹកសាបផ្លាស់ទីចូលទៅក្នុង ឬឆ្លងកាត់ដែនទឹកខាងក្នុងរហូតដល់ព្រំដែនខាងក្រៅតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃរដ្ឋមួយក្រៅពីរដ្ឋប្រភពដើមនោះ រដ្ឋនេះត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងរដ្ឋប្រភពដើមទាក់ទងនឹងការអភិរក្ស និងការគ្រប់គ្រងផលស្តុកប្រភេទត្រីទាំងនេះ។

៥. រដ្ឋប្រភពដើមនៃផលស្តុកប្រភេទត្រីសមុទ្រដែលពងកូននៅទឹកសាបនិងបណ្តារដ្ឋផ្សេងទៀតដែលនេសាទផលស្តុកប្រភេទត្រីទាំងនេះត្រូវរៀបចំធ្វើការអនុវត្តបទប្បញ្ញត្តិនៃមាត្រានេះ តាមរយៈអង្គការថ្នាក់តំបន់តាមភាពសមស្រប។

## មាត្រា៦៧

## ប្រភេទត្រីទឹកសាបដែលពងកូននៅសមុទ្រ

១. រដ្ឋជាប់ឆ្នេរសមុទ្រដែលមានប្រភេទត្រីទឹកសាបដែលពងកូននៅសមុទ្រចំណាយពេលនៃវដ្តជីវិតភាគច្រើនរបស់វានៅក្នុងដែនទឹកនៃរដ្ឋនោះ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងប្រភេទត្រីទាំងនេះ និងត្រូវធានាឱ្យមានច្រកចេញ-ចូលសម្រាប់ប្រភេទត្រីផ្លាស់ទីទាំងនោះ។

២. ការនេសាទប្រភេទត្រីទឹកសាបដែលពងកូននៅសមុទ្រត្រូវធ្វើឡើងតែក្នុងដែនទឹកខាងក្នុងនៃព្រំដែនខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខប៉ុណ្ណោះ។ នៅពេលដែលការនេសាទធ្វើឡើងក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ការនេសាទត្រូវអនុលោមទៅតាមមាត្រានេះ និងបទប្បញ្ញត្តិផ្សេងទៀតនៃអនុសញ្ញានេះដែលពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់ទាំងនេះ។

៣. ក្នុងករណីដែលប្រភេទត្រីទឹកសាបដែលពងកូននៅសមុទ្រធ្វើការផ្លាស់ទីចូលតាមតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋមួយផ្សេងទៀត មិនថាជាត្រីមិនទាន់ពេញវ័យឬពេញវ័យនោះទេ ការគ្រប់គ្រងរាប់បញ្ចូលរួមទាំងការនេសាទត្រីទាំងនេះ ត្រូវគ្រប់គ្រងដោយកិច្ចព្រមព្រៀងរវាងរដ្ឋដែលបានលើកឡើងក្នុងកថាខណ្ឌទី១ និងបណ្តារដ្ឋពាក់ព័ន្ធផ្សេងទៀត។ កិច្ចព្រមព្រៀងទាំងនេះត្រូវធានាឱ្យបាននូវការគ្រប់គ្រងយ៉ាងសមហេតុផលនូវប្រភេទត្រីទាំងនេះ និងយកចិត្តទុកដាក់ទៅលើការទទួលខុសត្រូវរបស់រដ្ឋដែលបានលើកឡើងក្នុងកថាខណ្ឌទី១សម្រាប់ការថែទាំប្រភេទត្រីទាំងនេះ។

## មាត្រា៦៨

## ប្រភេទភាវៈរស់នៅមួយកន្លែង

ជំពូកនេះមិនអនុវត្តចំពោះប្រភេទភាវៈរស់នៅមួយកន្លែង ដូចបានកំណត់ក្នុងកថាខណ្ឌទី៤ នៃមាត្រា៧៧ នោះទេ។

## មាត្រា៦៩
## សិទ្ធិរបស់បណ្តារដ្ឋមិនជាប់សមុទ្រ

១. ផ្អែកលើមូលដ្ឋានសមធម៌ បណ្តារដ្ឋមិនជាប់សមុទ្រមានសិទ្ធិចូលរួមធ្វើអាជីវកម្មពីធនធានមានជីវិតក្នុងលក្ខខណ្ឌសមស្រប ដែលលើសពីតម្រូវការនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រដែលស្ថិតនៅក្នុងអនុតំបន់ ឬតំបន់តែមួយ ដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ច និងភូមិសាស្ត្រពាក់ព័ន្ធរបស់រដ្ឋទាំងអស់ដែលពាក់ព័ន្ធ និងអនុលោមតាមមាត្រានេះ និងមាត្រា៦១និងមាត្រា៦២។

២. លក្ខខណ្ឌនិងទម្រង់នៃការចូលរួមនេះត្រូវកំណត់ដោយបណ្តារដ្ឋដែលពាក់ព័ន្ធ តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី កិច្ចព្រមព្រៀងអនុតំបន់ ឬកិច្ចព្រមព្រៀងតំបន់ ដោយពិចារណាជាអាទិ៍លើះ

(ក) ភាពចាំបាច់ក្នុងការបញ្ចៀសផលប៉ះពាល់អវិជ្ជមានលើសហគមន៍នេសាទ ឬឧស្សាហកម្មនេសាទរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ខ) អនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ វិសាលភាពរបស់រដ្ឋមិនជាប់សមុទ្រ ក្នុងការធ្វើអាជីវកម្មពីធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ត្រូវធ្វើតាមកិច្ចព្រមព្រៀងទ្វេភាគី កិច្ចព្រមព្រៀងអនុតំបន់ ឬកិច្ចព្រមព្រៀងតំបន់ដែលមានស្រាប់ ។

(គ) វិសាលភាពរបស់បណ្តារដ្ឋមិនជាប់សមុទ្រនិងបណ្តារដ្ឋដែលមានភូមិសាស្ត្រមិនអំណោយផលដែលកំពុងធ្វើអាជីវកម្មពីធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រ និងត្រូវបញ្ចៀសនូវបន្ទុកជាក់លាក់សម្រាប់រដ្ឋជាប់ឆ្នេរសមុទ្រណា ឬផ្នែកមួយរបស់រដ្ឋជាប់ឆ្នេរសមុទ្រនោះ។

(ឃ) តម្រូវការអាហារូបត្ថម្ភរបស់ប្រជាជនរបស់បណ្តារដ្ឋនីមួយៗ។

៣. នៅពេលសមត្ថភាពប្រមូលផលរបស់រដ្ឋជាប់ឆ្នេរសមុទ្រឈានដល់ចំណុចមួយដែលអាចប្រមូលផលបាននូវផលទាំងស្រុងនៃធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រនោះ រដ្ឋជាប់ឆ្នេរសមុទ្រនោះនិងបណ្តារដ្ឋផ្សេងទៀតដែលពាក់ព័ន្ធ ត្រូវសហការគ្នាប្រកបដោយសមធម៌ ដើម្បីរៀបចំកិច្ចព្រមព្រៀងទ្វេភាគី កិច្ចព្រមព្រៀងអនុតំបន់ ឬកិច្ចព្រមព្រៀងតំបន់ ដើម្បីអនុញ្ញាតដល់ការចូលរួមរបស់បណ្តារដ្ឋមិនជាប់សមុទ្រដែលជាប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងអនុតំបន់ ឬតំបន់តែមួយ ក្នុងការធ្វើអាជីវកម្មពីធនធានមានជីវិតតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រក្នុងអនុតំបន់ឬតំបន់ ហើយកិច្ចព្រមព្រៀងនេះត្រូវមានលក្ខខណ្ឌសមស្របនឹងស្ថានភាពជាក់ស្តែង និងសក្តិសមសម្រាប់ភាគីទាំងអស់។ ក្នុងការអនុវត្តបទប្បញ្ញត្តិនេះ ត្រូវពិចារណាកត្តាដែលបានចែងក្នុងកថាខណ្ឌទី២ នៃមាត្រានេះផងដែរ។

៤. តាមបទប្បញ្ញត្តិនៃមាត្រានេះ បណ្តារដ្ឋមិនជាប់សមុទ្រដែលជាប្រទេសអភិវឌ្ឍន៍មានសិទ្ធិធ្វើអាជីវកម្មពីធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រដែលជាប្រទេសអភិវឌ្ឍន៍ នៅក្នុងអនុតំបន់ ឬតំបន់តែមួយ ផ្អែកទៅតាមវិសាលភាពដែលរដ្ឋជាប់ឆ្នេរសមុទ្រនោះដោយពិចារណាទៅលើតម្រូវការក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានឱ្យតិចតួចបំផុតលើសហគមន៍នេសាទ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចដែលពលរដ្ឋមានទម្លាប់នេសាទក្នុងតំបន់នោះ។

៥. បទប្បញ្ញត្តិខាងលើនេះ មិនប៉ះពាល់ដល់កិច្ចព្រមព្រៀងអនុតំបន់ឬកិច្ចព្រមព្រៀងតំបន់ដែលរដ្ឋជាប់ឆ្នេរសមុទ្រអាចផ្តល់ជូនបណ្តារដ្ឋមិនជាប់សមុទ្រក្នុងអនុតំបន់ឬតំបន់តែមួយនូវសិទ្ធិស្មើគ្នាឬសិទ្ធិអនុគ្រោះលើសពីនេះ សម្រាប់ការធ្វើអាជីវកម្មពីតំបន់សេដ្ឋកិច្ចផ្តាច់មុខនោះឡើយ។

## មាត្រា៧០
## សិទ្ធិរបស់បណ្តារដ្ឋដែលមានភូមិសាស្ត្រមិនអំណោយផល

១. ផ្អែកលើមូលដ្ឋានសមធម៌ បណ្តារដ្ឋដែលមានភូមិសាស្ត្រមិនអំណោយផលមានសិទ្ធិចូលរួម ក្នុងការធ្វើអាជីវកម្មលើតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រដែលស្ថិតនៅក្នុងអនុតំបន់ឬតំបន់តែមួយ ដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ចនិងស្ថានភាពភូមិសាស្ត្ររបស់រដ្ឋទាំងអស់ដែលពាក់ព័ន្ធ និងអនុលោមទៅតាមមាត្រានេះ និងមាត្រា៦១និងមាត្រា៦២។

២. សម្រាប់គោលបំណងនៃផ្នែកនេះ "បណ្តារដ្ឋដែលមានភូមិសាស្ត្រមិនអំណោយផល" សំដៅដល់បណ្តារដ្ឋជាប់ឆ្នេរសមុទ្រ រួមទាំងបណ្តារដ្ឋដែលមានព្រំដែនជាប់នឹងសមុទ្របិទឬពាក់កណ្តាលបិទ ដែលមានស្ថានភាពភូមិសាស្ត្រពឹងផ្អែកទៅលើការធ្វើអាជីវកម្មលើតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់បណ្តារដ្ឋផ្សេងទៀតក្នុងអនុតំបន់ឬតំបន់ដើម្បីទទួលបានទិន្នផលត្រីគ្រប់គ្រាន់សម្រាប់ជាអាហារូបត្ថម្ភដល់ប្រជាជនខ្លួនឬមួយផ្នែកមួយនៃប្រជាជននោះ និងរដ្ឋជាប់ឆ្នេរសមុទ្រដែលមិនអាចទាមទារតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន។

៣. លក្ខខណ្ឌនិងទម្រង់នៃការចូលរួមនេះត្រូវកំណត់ដោយបណ្តារដ្ឋដែលពាក់ព័ន្ធ តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី កិច្ចសន្យាអនុតំបន់ ឬកិច្ចសន្យាតំបន់ ដោយពិចារណាជាអាទិ៍ទៅលើ៖

(ក) ភាពចាំបាច់ក្នុងការបញ្ចៀសផលប៉ះពាល់អវិជ្ជមានលើសហគមន៍នេសាទ ឬវិស័យនេសាទរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។

(ខ) អនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ វិសាលភាពដែលបណ្តារដ្ឋដែលមានភូមិសាស្ត្រមិនអំណោយផលដែលកំពុងធ្វើអាជីវកម្មឬមានសិទ្ធិធ្វើអាជីវកម្មលើធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរផ្សេងទៀត ក្រោមកិច្ចព្រមព្រៀងទ្វេភាគី កិច្ចព្រមព្រៀងអនុតំបន់ ឬកិច្ចព្រមព្រៀងតំបន់ដែលមានស្រាប់។

(គ) វិសាលភាពដែលបណ្តារដ្ឋដែលមានភូមិសាស្ត្រមិនអំណោយផលផ្សេងទៀតនិងបណ្តារដ្ឋមិនជាប់សមុទ្រកំពុងចូលរួមក្នុងការធ្វើអាជីវកម្មធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រនិងត្រូវបញ្ចៀសនូវបន្ទុកជាក់លាក់សម្រាប់រដ្ឋជាប់ឆ្នេរសមុទ្រណាមួយឬផ្នែកណាមួយរបស់រដ្ឋជាប់ឆ្នេរសមុទ្រនោះ។

(ឃ) តម្រូវការអាហារូបត្ថម្ភរបស់ប្រជាជនរបស់បណ្តារដ្ឋនីមួយៗ។

៤. នៅពេលសមត្ថភាពប្រមូលផលរបស់រដ្ឋជាប់ឆ្នេរសមុទ្រឈានដល់ចំណុចមួយដែលអាចប្រមូលផលបាននូវផលទាំងស្រុងនៃធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន នោះរដ្ឋជាប់ឆ្នេរសមុទ្រនិងបណ្តារដ្ឋផ្សេងទៀតដែលពាក់ព័ន្ធត្រូវសហការគ្នាប្រកបដោយសមធម៌ ដើម្បីរៀបចំកិច្ចព្រមព្រៀងទ្វេភាគី កិច្ចព្រមព្រៀងអនុតំបន់ ឬកិច្ចព្រមព្រៀងតំបន់ ដើម្បីអនុញ្ញាតដល់ការចូលរួមរបស់បណ្តារដ្ឋដែលមានភូមិសាស្ត្រមិនអំណោយផលដែលជាប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងអនុតំបន់ឬតំបន់តែមួយក្នុងការធ្វើអាជីវកម្មពីធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រក្នុងអនុតំបន់ឬ តំបន់ ហើយកិច្ចព្រមព្រៀងនេះត្រូវមានលក្ខខណ្ឌសមស្របនឹងស្ថានភាពជាក់ស្តែងនិងស័ក្តិសមសម្រាប់ភាគីទាំងអស់។ ក្នុងការអនុវត្តបទប្បញ្ញត្តិនេះ ត្រូវពិចារណាទៅលើកត្តាដែលបានលើកឡើងក្នុងកថាខណ្ឌទី៣ នៃមាត្រានេះផងដែរ។

៥. តាមបទប្បញ្ញត្តិនៃមាត្រានេះ រដ្ឋដែលមានភូមិសាស្ត្រមិនអំណោយផលដែលជាប្រទេសអភិវឌ្ឍន៍មានសិទ្ធិធ្វើអាជីវកម្មលើធនធានមានជីវិតក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់រដ្ឋជាប់ឆ្នេរសមុទ្រដែលជាប្រទេសអភិវឌ្ឍន៍នៅក្នុងអនុតំបន់ឬតំបន់តែមួយ ផ្អែកទៅតាមវិសាលភាពដែលរដ្ឋជាប់ឆ្នេរសមុទ្រនោះដោយពិចារណាទៅលើតម្រូវការក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានឱ្យនៅតិចតួចបំផុតលើសហគមន៍នេសាទ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចដែលពលរដ្ឋមានទម្លាប់នេសាទក្នុងតំបន់នោះ។

៦. បទប្បញ្ញត្តិខាងលើនេះ មិនប៉ះពាល់ដល់កិច្ចព្រមព្រៀងអនុតំបន់ឬកិច្ចព្រមព្រៀងតំបន់ដែលរដ្ឋជាប់ឆ្នេរសមុទ្រ អាចផ្ដល់ជូនបណ្ដារដ្ឋដែលមានភូមិសាស្ត្រមិនអំណោយផលក្នុងអនុតំបន់ឬតំបន់តែមួយនូវសិទ្ធិស្មើគ្នាឬសិទ្ធិអនុគ្រោះលើសពីនេះ សម្រាប់ការធ្វើអាជីវកម្មលើតំបន់សេដ្ឋកិច្ចផ្ដាច់មុខនោះឡើយ។

## មាត្រា៧១

## ការមិនអាចអនុវត្តបាននូវមាត្រា៦៩ និងមាត្រា៧០

បទប្បញ្ញត្តិនៃមាត្រា៦៩ និងមាត្រា៧០ មិនត្រូវយកមកអនុវត្តក្នុងករណីដែលរដ្ឋជាប់ឆ្នេរសមុទ្រមានសេដ្ឋកិច្ចពឹងផ្អែកយ៉ាងខ្លាំងទៅលើការធ្វើអាជីវកម្មពីធនធានមានជីវិតនៃតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់ខ្លួន។

## មាត្រា៧២

## ការរឹតបណ្ដឹងលើការផ្ទេរសិទ្ធិ

១. សិទ្ធិដូចមានចែងក្នុងមាត្រា៦៩ និងមាត្រា៧០ លើការធ្វើអាជីវកម្មលើធនធានមានជីវិត មិនត្រូវបានផ្ទេរទៅឱ្យភាគីរដ្ឋទីបីឬពលរដ្ឋនៃរដ្ឋនោះ ទោះដោយផ្ទាល់ឬប្រយោល មិនថាក្រោមភតិសន្យា ឬការផ្ដល់អាជ្ញាប័ណ្ណ ដោយការបង្កើតវិនិយោគរួម ឬតាមរូបភាពណាក៏ដោយដែលមានលក្ខណៈដូចការផ្ទេរសិទ្ធិ លុះត្រាតែមានការឯកភាពពីរដ្ឋដែលពាក់ព័ន្ធ។

២. បទប្បញ្ញត្តិខាងលើមិនត្រូវរារាំងដល់រដ្ឋដែលពាក់ព័ន្ធក្នុងការទទួលបានជំនួយផ្នែកបច្ចេកទេស ឬហិរញ្ញវត្ថុពីរដ្ឋទីបី ឬអង្គការអន្តរជាតិនានា ដើម្បីសម្រួលដល់ការអនុវត្តនូវសិទ្ធិដូចមានចែងក្នុងមាត្រា៦៩និងមាត្រា៧០ ដោយមិនបង្កើតលក្ខណៈដូចការផ្ទេរសិទ្ធិដូចមានចែងក្នុងកថាខណ្ឌទី១។

## មាត្រា៧៣

## ការអនុវត្តច្បាប់និងបទបញ្ញារបស់រដ្ឋជាប់ឆ្នេរសមុទ្រ

១. នៅក្នុងការអនុវត្តសិទ្ធិអធិបតេយ្យរបស់ខ្លួនដើម្បីស្វែងរុករក ធ្វើអាជីវកម្ម អភិរក្ស និងគ្រប់គ្រងធនធានមានជីវិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ រដ្ឋជាប់ឆ្នេរសមុទ្រអាចចាត់វិធានការ រួមមាន ការឡើងលើនាវា ការធ្វើអធិការកិច្ច ការចាប់ខ្លួន និងការធ្វើចំណាត់ការតុលាការដែលចាំបាច់ ដើម្បីធានា ការគោរពច្បាប់និងបទបញ្ញាដែលរដ្ឋជាប់ឆ្នេរសមុទ្របានអនុម័តស្របតាមអនុសញ្ញានេះ។

២. នាវានិងក្រុមនាវិកបម្រើការលើនាវាដែលត្រូវបានចាប់ខ្លួន ត្រូវដោះលែងជាបន្ទាន់ នៅពេលដែលមានការតម្កល់ប្រាក់ធានាឬឧបករណ៍ធានាផ្សេងទៀតដែលសមស្រប។

៣. ទណ្ឌកម្មរបស់រដ្ឋជាប់ឆ្នេរសមុទ្រពីបទរំលោភច្បាប់និងបទបញ្ញាស្ដីពីជលផលនៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ មិនត្រូវមានទោសជាប់ពន្ធនាគារនោះឡើយ លើកលែងតែមានកិច្ចព្រមព្រៀងបែបនេះ រវាងបណ្ដារដ្ឋពាក់ព័ន្ធ ឬទម្រង់ណាមួយផ្សេងទៀតនៃទណ្ឌកម្មលើរូបកាយ។

៤. ក្នុងករណីចាប់ឬឃាត់នាវាបរទេស រដ្ឋជាប់ឆ្នេរសមុទ្រត្រូវជូនដំណឹងជាបន្ទាន់ទៅរដ្ឋម្ចាស់សញ្ជាតិតាមរយៈមធ្យោបាយដែលសមស្រប អំពីចំណាត់ការនិងទណ្ឌកម្មដែលបានដាក់ជាបន្តបន្ទាប់។

### មាត្រា៧៤
### ការកំណត់ព្រំដែនតំបន់សេដ្ឋកិច្ចផ្តាច់មុខរវាងរដ្ឋដែលមានឆ្នេរទល់មុខគ្នាឬជាប់គ្នា

១. ការកំណត់ព្រំដែនតំបន់សេដ្ឋកិច្ចផ្តាច់មុខរវាងរដ្ឋដែលមានតំបន់ឆ្នេរទល់មុខគ្នាឬជាប់គ្នា អាចមានសុពលភាពលុះត្រាតែមានកិច្ចព្រមព្រៀងរវាងរដ្ឋទាំងនោះដោយឈរលើមូលដ្ឋានច្បាប់អន្តរជាតិ ដូចដែលមានកំណត់ក្នុងមាត្រា៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីទទួលបានដំណោះស្រាយដោយសមធម៌។

២. ក្នុងករណីមិនមានការព្រមព្រៀងគ្នាក្នុងរយៈពេលសមស្រប នោះរដ្ឋដែលពាក់ព័ន្ធត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងជំពូកទី១៥ នៃអនុសញ្ញានេះ។

៣. ខណៈដែលរង់ចាំកិច្ចព្រមព្រៀងដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ បណ្តារដ្ឋពាក់ព័ន្ធត្រូវព្យាយាមអស់ពីលទ្ធភាពក្នុងការស្វែងរកដំណោះស្រាយជាក់ស្តែងជាបណ្តោះអាសន្នមួយដោយឈរលើស្មារតីនៃការយោគយល់និងសហប្រតិបត្តិការ។ ក្នុងរយៈពេលអន្តរកាលនេះ បណ្តារដ្ឋពាក់ព័ន្ធមិនត្រូវធ្វើឱ្យប៉ះពាល់ឬរាំងស្ទះដល់ការចុះកិច្ចព្រមព្រៀងចុងក្រោយនោះទេ។ ការរៀបចំនេះនឹងមិនមានឥទ្ធិពលទៅលើការកំណត់ព្រំដែនចុងក្រោយនោះទេ។

៤. ក្នុងករណីដែលកិច្ចព្រមព្រៀងរវាងបណ្តារដ្ឋពាក់ព័ន្ធចូលជាធរមាន នោះបញ្ហាដែលទាក់ទងនឹងការកំណត់ព្រំដែនតំបន់សេដ្ឋកិច្ចផ្តាច់មុខនឹងត្រូវកំណត់ស្របទៅតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ។

### មាត្រា៧៥
### ផែនទីសមុទ្រនិងបញ្ជីនិយាមកាភូមិសាស្ត្រ

១. នៅក្នុងផ្នែកនេះ ខ្សែបន្ទាត់ខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងខ្សែបន្ទាត់ព្រំដែនដែលបាន គូសស្របតាមមាត្រា៧៤ ត្រូវបង្ហាញនៅលើផែនទីមាត្រដ្ឋានឬមាត្រដ្ឋានដែលអាចបញ្ជាក់ច្បាស់លាស់ពីចំណុចទីតាំងរបស់វាបានគ្រប់គ្រាន់។ តាមករណីដែលសមស្រប ប្រព័ន្ធទិន្នន័យប្រថពីវិភាគ អាចនឹងត្រូវបានប្រើជំនួសគំនូសខ្សែបន្ទាត់ព្រំដែនខាងក្រៅឬខ្សែបន្ទាត់ព្រំដែន។

២. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវធ្វើការផ្សព្វផ្សាយសាធារណៈអំពីផែនទីសមុទ្រនិងបញ្ជីនិយាមកាភូមិសាស្ត្រ និងត្រូវដាក់តម្កល់ផែនទីសមុទ្រនិងបញ្ជីនិយាមកាភូមិសាស្ត្រនោះមួយច្បាប់ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## ជំពូកទី៦
## តំបន់ខ្ពង់រាបបាតសមុទ្រ

### មាត្រា៧៦
### និយមន័យនៃតំបន់ខ្ពង់រាបបាតសមុទ្រ

១. តំបន់ខ្ពង់រាបបាតសមុទ្រនៃរដ្ឋជាប់ឆ្នេរសមុទ្រ រួមមានបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រនៃតំបន់បាតសមុទ្រ ដែលលាតសន្ធឹងហួសពីសមុទ្រដែនដីរបស់ខ្លួន គ្រប់ដណ្តប់លើពន្លយជាធម្មជាតិនៃដែនដីគោករហូតដល់គែមខាងក្រៅនៃរឹមខ្ពង់រាបបាតសមុទ្រ ឬលាតសន្ធឹងដល់ចម្ងាយ២០០ ម៉ៃល៍សមុទ្រ គិតពីខ្សែបន្ទាត់មូលដ្ឋានដែលទទឹងនៃសមុទ្រដែនដីត្រូវបានវាស់វែង ក្នុងករណីដែលគែមខាងក្រៅនៃបាតខ្ពង់រាបមានចម្ងាយតិចជាងនោះ។

២. តំបន់ខ្ពង់រាបបាតសមុទ្រនៃរដ្ឋជាប់ឆ្នេរសមុទ្រ មិនត្រូវលាតសន្ធឹងហួសពីដែនកំណត់ដូចមានចែងក្នុងកថាខណ្ឌទី៤ដល់កថាខណ្ឌទី៦នោះឡើយ។

៣. រឹមខ្ពង់រាបបាតសមុទ្ររួមមានពន្លយក្រោមទឹកនៃផ្ទៃដីនៃរដ្ឋជាប់ឆ្នេរសមុទ្រ និងរាប់បញ្ចូលតំបន់បាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រនៃតំបន់ខ្ពង់រាបបាតសមុទ្រ ទីជម្រាលនិងទីចំណោតបាតសមុទ្រ។ រឹមខ្ពង់រាបបាតសមុទ្រមិនរួមបញ្ចូលនូវផ្ទៃបាតមហាសមុទ្រជ្រៅនិងចង្កូរបាតសមុទ្រឬស្រទាប់ដីក្រោមបាតសមុទ្ររបស់វានោះទេ។

៤. (ក) សម្រាប់គោលបំណងនៃអនុសញ្ញានេះ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវកំណត់គែមខាងក្រៅនៃរឹមខ្ពង់រាបបាតសមុទ្រ ក្នុងករណីដែលតំបន់ខ្ពង់រាបបាតសមុទ្រនោះលាតសន្ធឹងលើពីប្រវែង២០០ ម៉ៃល៍សមុទ្រ គិតពីខ្សែបន្ទាត់មូលដ្ឋានដែលទទឹងនៃសមុទ្រដែនដីត្រូវបានវាស់វែង តាមរបៀបណាមួយដូចខាងក្រោម៖

(i) ខ្សែបន្ទាត់ដែលបានកំណត់ស្របតាមកថាខណ្ឌទី៧ ដោយយោងទៅតាមចំណុចដាក់លាក់នៅផ្នែកខាងក្រៅបំផុត ដែលតាមចំណុចនីមួយៗ កម្រាស់នៃកំណកថ្មត្រូវមានយ៉ាងតិចស្មើនឹង ១ភាគរយនៃរយៈចម្ងាយដែលជិតជាងគេបំផុតគិតចាប់ពីចំណុចនោះដល់ជើងនៃទីជម្រាលបាតសមុទ្រ ឬ

(ii) ខ្សែបន្ទាត់ដែលបានកំណត់ស្របតាមកថាខណ្ឌទី៧ យោងយោងទៅតាមចំណុចដាក់លាក់ដែលមានចម្ងាយមិនលើសពី៦០ ម៉ៃល៍សមុទ្រ គិតចាប់ពីជើងនៃទីជម្រាលបាតសមុទ្រ។

(ខ) ក្នុងករណីដែលពុំមានភស្តុតាងផ្ទុយពីនេះ នោះជើងនៃទីជម្រាលបាតសមុទ្រត្រូវកំណត់យកជាចំណុចនៃការផ្លាស់ប្ដូរជាអតិបរមានៃការប្រែប្រួលនៅបាតជម្រាលនោះ។

៥. ចំណុចដាក់លាក់ដែលរួមមានខ្សែបន្ទាត់នៃដែនកំណត់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រនៅខាងលើបាតសមុទ្រ ដែលត្រូវគូសស្របតាមកថាខណ្ឌទី៤(ក)(i)និង(ii) មិនត្រូវមានប្រវែងលើសពី ៣៥០ ម៉ៃល៍សមុទ្រ គិតពីខ្សែបន្ទាត់មូលដ្ឋានដែលទទឹងនៃសមុទ្រដែនដីត្រូវបានវាស់វែង ឬមិនត្រូវលើសពីប្រវែង១០០ ម៉ៃល៍សមុទ្រ គិតចាប់ពីជម្រៅទឹក ២៥០០ម៉ែត្រ ដែលជាខ្សែបន្ទាត់ភ្ជាប់ចំណុចនៃជម្រៅទឹក ២៥០០ ម៉ែត្រ។

៦. បើទោះជាមានបទប្បញ្ញត្តិចែងក្នុងកថាខណ្ឌទី៥ខាងលើក៏ដោយ អំពីចង្កូរក្រោមសមុទ្រ ដែនកំណត់ព្រំដែនខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រមិនត្រូវលាតសន្ធឹងហួសពី៣៥០ ម៉ៃល៍សមុទ្រ គិតចាប់ពីខ្សែបន្ទាត់មូលដ្ឋានដែលទទឹងនៃសមុទ្រដែនដីត្រូវបានវាស់វែង។ កថាខណ្ឌនេះមិនអនុវត្តចំពោះការឡើងកម្ពស់ក្រោមសមុទ្រ ដែលជាសមាសភាគតាមធម្មជាតិនៃរឹមខ្ពង់រាបបាតសមុទ្រដូចជា តំបន់ខ្ពង់រាប ទីចំណោទ កំពូលនៃខ្ពង់រាបបាតសមុទ្រ ច្រាំងនិងដៃសមុទ្រ។

៧. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវកំណត់ដែនកំណត់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួនក្នុងករណីដែលតំបន់ខ្ពង់រាបបាតសមុទ្រនោះលាតសន្ធឹងលើសពី២០០ ម៉ៃល៍សមុទ្រ គិតចាប់ពីចំណុចខ្សែបន្ទាត់មូលដ្ឋានដែលទទឹងនៃសមុទ្រដែនដីត្រូវបានវាស់វែង ដោយយកជាខ្សែបន្ទាត់ត្រង់ដែលមិនត្រូវមានចម្ងាយលើសពី ៦០ ម៉ៃល៍សមុទ្រ តភ្ជាប់ចំណុចដាក់លាក់ទាំងឡាយ និងត្រូវមានកំណត់ចំណុចនិយាមកានៃខ្សែរយៈទទឹងនិងខ្សែរយៈបណ្ដោយ។

៨. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវបញ្ជូនព័ត៌មានស្ដីពីដែនកំណត់តំបន់ខ្ពង់រាបបាតសមុទ្រដែលលាតសន្ធឹងលើសពី២០០ ម៉ែល៍សមុទ្រ គិតចាប់ពីចំណុចខ្សែបន្ទាត់មូលដ្ឋានដែលទទឹងនៃសមុទ្រដែនដីត្រូវបានវាស់វែងទៅឱ្យគណៈកម្មការកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្រដែលត្រូវបានបង្កើតឡើងក្នុងឧបសម្ព័ន្ធទី២ លើមូលដ្ឋាននៃភាពជាតំណាងតំបន់ភូមិសាស្ត្រប្រកបដោយសមធម៌។ គណៈកម្មការនេះត្រូវផ្ដល់អនុសាសន៍ដល់បណ្ដារដ្ឋជាប់ឆ្នេរសមុទ្រលើបញ្ហាដែលទាក់ទងនឹងការកំណត់ដែនកំណត់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្ររបស់បណ្ដារដ្ឋជាប់ឆ្នេរសមុទ្រ។ ដែនកំណត់នៃតំបន់ខ្ពង់រាបបាតសមុទ្រដែលត្រូវបានកំណត់ដោយរដ្ឋជាប់ឆ្នេរសមុទ្រដោយឈរលើមូលដ្ឋាននៃអនុសាសន៍ទាំងនេះ ត្រូវចាត់ទុកជាស្ថាពរនិងចងកាតព្វកិច្ច។

៩. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិនូវ ផែនទីសមុទ្រ និងព័ត៌មានដែលពាក់ព័ន្ធ រាប់បញ្ចូលទាំងទិន្នន័យផ្នែកប្រថពីវិភាគ ដែលរៀបរាប់ជាអចិន្ត្រៃយ៍អំពីដែនកំណត់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន។ អគ្គលេខាធិការត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យបានត្រឹមត្រូវនូវព័ត៌មានខាងលើ។

១០. បទប្បញ្ញត្តិនៃមាត្រានេះមិនប៉ះពាល់ដល់ការកំណត់តំបន់ខ្ពង់រាបបាតសមុទ្ររវាងរដ្ឋដែលមានឆ្នេរទល់មុខគ្នាឬជាប់គ្នានោះទេ។

## មាត្រា៧៧
## សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រលើតំបន់ខ្ពង់រាបបាតសមុទ្រ

១. រដ្ឋជាប់ឆ្នេរសមុទ្រមានសិទ្ធិអធិបតេយ្យលើតំបន់ខ្ពង់រាបបាតសមុទ្រ សម្រាប់គោលបំណងធ្វើការស្វែងរុករក និងការធ្វើអាជីវកម្មលើធនធានធម្មជាតិនៅក្នុងតំបន់នោះ។

២. សិទ្ធិដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ គឺជាសិទ្ធិផ្ដាច់មុខ។ ក្នុងករណីដែលរដ្ឋជាប់ឆ្នេរសមុទ្រមិនធ្វើការស្វែងរុករកក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ ឬមិនធ្វើអាជីវកម្មលើធនធានធម្មជាតិរបស់ខ្លួន គ្មានបុគ្គលណាអាចធ្វើសកម្មភាពទាំងនេះដោយមិនមានការយល់ព្រមជាក់លាក់ពីរដ្ឋជាប់ឆ្នេរសមុទ្រឡើយ។

៣. សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រលើតំបន់ខ្ពង់រាបបាតសមុទ្រ មិនអាស្រ័យលើការកាន់កាប់ដោយពិតប្រាកដ ឬដោយសន្មត ឬការអះអាងដោយជាក់លាក់នោះទេ។

៤. ធនធានធម្មជាតិដូចមានចែងនៅក្នុងជំពូកនេះ រួមមានធនធានរ៉ែនិងធនធានមិនមានជីវិតដទៃទៀតដែលមាននៅបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រ រួមទាំងពពួកភាវរស់ទាំងឡាយដែលស្ថិតក្នុងប្រភេទភាវរស់នៅមួយកន្លែង មានន័យថាពពួកសរីរាង្គដែលនៅក្នុងដំណាក់កាលអាចប្រមូលផលបាន មិនអាចចល័តបានឬពុំអាចធ្វើចលនាបានលុះត្រាតែនៅលើបាតសមុទ្រឬស្រទាប់ដីក្រោមបាតសមុទ្រ។

## មាត្រា៧៨
## លក្ខន្តិកៈគតិយុត្តនៃផ្ទៃទឹកខាងលើបាតសមុទ្រនិងដែនអាកាស ព្រមទាំងសិទ្ធិនិងសេរីភាពនៃរដ្ឋដទៃទៀត

១. សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រលើតំបន់ខ្ពង់រាបបាតសមុទ្រ មិនមានឥទ្ធិពលលើលក្ខន្តិកៈគតិយុត្តនៃដែនទឹកផ្នែកខាងលើឬដែនអាកាសដែលស្ថិតនៅខាងលើដែនទឹកទាំងនេះឡើយ។

២. ការប្រើប្រាស់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រលើតំបន់ខ្ពង់រាបបាតសមុទ្រ មិនត្រូវបំពានឬនាំឱ្យមានការជ្រៀតជ្រែកដោយពុំសមហេតុផលជាមួយនឹងការធ្វើនាវាចរណ៍និងសិទ្ធិនិងសេរីភាពផ្សេងៗរបស់រដ្ឋដទៃទៀតដូចមានចែងក្នុងអនុសញ្ញានេះ។

## មាត្រា៧៩

## បណ្ដាញខ្សែកាបនៅបាតសមុទ្រនិងបំពង់បង្ហូរលើតំបន់ខ្ពង់រាបបាតសមុទ្រ

១. បណ្ដារដ្ឋទាំងអស់មានសិទ្ធិពង្រាយបណ្ដាញកាបនៅបាតសមុទ្រនិងបំពង់បង្ហូរនៅលើតំបន់ខ្ពង់រាបបាតសមុទ្រស្របតាមបទប្បញ្ញត្តិនៃមាត្រានេះ។

២. អនុលោមតាមសិទ្ធិក្នុងការចាត់វិធានការដែលសមស្របសម្រាប់ការស្វែងរុករកក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ ការធ្វើអាជីវកម្មលើធនធានធម្មជាតិរបស់ខ្លួននិងការបង្ការ ការកាត់បន្ថយ និងការទប់ស្កាត់ការបំពុលដោយបំពង់បង្ហូរ រដ្ឋជាប់ឆ្នេរសមុទ្រមិនអាចបង្កការរាំងស្ទះដល់ការដាក់ពង្រាយឬការថែទាំបណ្ដាញខ្សែកាបឬបំពង់បង្ហូរទាំងនេះឡើយ។

៣. ការកំណត់គន្លងផ្លូវសម្រាប់ការដាក់ពង្រាយបំពង់បង្ហូរទាំងនេះនៅលើតំបន់ខ្ពង់រាបបាតសមុទ្រ ត្រូវមានការឯកភាពពីរដ្ឋជាប់ឆ្នេរសមុទ្រ។

៤. បទប្បញ្ញត្តិនៅក្នុងជំពូកនេះមិនមានអានុភាពទៅលើសិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រនៅក្នុងការបង្កើតលក្ខខណ្ឌសម្រាប់ការពង្រាយខ្សែកាបឬបំពង់បង្ហូរទាំងនេះទៅក្នុងដែនដី ឬសមុទ្រដែនដី ឬដែលខ្លួនមានយុត្តាធិការលើការសាងសង់ឬការប្រើប្រាស់បណ្ដាញខ្សែកាបនិងបំពង់បង្ហូរទាំងនេះ សម្រាប់បម្រើដល់គោលបំណងនៃការស្វែងរុករកតំបន់ខ្ពង់រាបបាតសមុទ្រ ឬការធ្វើអាជីវកម្មលើធនធានរបស់ខ្លួន ឬកិច្ចប្រតិបត្តិការកោះសិប្បនិម្មិត ឋបនាការនិងរចនាសម្ព័ន្ធនានាដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួននោះឡើយ។

៥. នៅពេលរដ្ឋនីមួយៗពង្រាយបណ្ដាញខ្សែកាបនៅបាតសមុទ្រឬបំពង់បង្ហូរ ត្រូវគោរពទីតាំងនៃបណ្ដាញខ្សែកាបឬបំពង់បង្ហូរដែលមានស្រាប់ ជាពិសេស មិនត្រូវប៉ះពាល់ដល់លទ្ធភាពក្នុងការជួសជុលបណ្ដាញខ្សែកាបឬបំពង់បង្ហូរមានស្រាប់នោះឡើយ។

## មាត្រា៨០

## កោះសិប្បនិម្មិត ឋបនាការនិងរចនាសម្ព័ន្ធនៅលើតំបន់ខ្ពង់រាបបាតសមុទ្រ

មាត្រា៦០ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះកោះសិប្បនិម្មិត ឋបនាការនិងរចនាសម្ព័ន្ធនៅលើតំបន់ខ្ពង់រាបបាតសមុទ្រ។

## មាត្រា៨១

## ការខួងនៅតំបន់ខ្ពង់រាបបាតសមុទ្រ

រដ្ឋជាប់ឆ្នេរសមុទ្រមានសិទ្ធិផ្ដាច់មុខនៅក្នុងការផ្ដល់សិទ្ធិនិងគ្រប់គ្រងលើសកម្មភាពខួងគ្រប់ប្រភេទនៅលើតំបន់ខ្ពង់រាបបាតសមុទ្រ។

## មាត្រា៨២

## ការបង់កម្រៃនិងវិភាគទានចំពោះការធ្វើអាជីវកម្មលើតំបន់ខ្ពង់រាបបាតសមុទ្រ ដែលលាតសន្ធឹងលើសពី២០០ ម៉ៃល៍សមុទ្រ

១. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវបង់កម្រៃឬវិភាគទានតាមរូបភាពណាមួយ លើការធ្វើអាជីវកម្មពីធនធានមិនមានជីវិតនៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្រដែលលាតសន្ធឹងលើសពី២០០ម៉ៃល៍សមុទ្រ គិតចាប់ពីចំណុចខ្សែបន្ទាត់មូលដ្ឋាននៃទទឹងសមុទ្រដែនដីដែលត្រូវបានវាស់វែង។

២. ការបង់កម្រៃនិងវិភាគទានទាំងនេះត្រូវធ្វើឡើងជារៀងរាល់ឆ្នាំសម្រាប់រាល់បរិមាណដែលផលិតបាននៅទីតាំង បន្ទាប់ពីចាប់ផ្តើមដំណើរការផលិតកម្មរយៈពេល៥ឆ្នាំដំបូងនៅទីតាំងនោះ។ អត្រាបង់កម្រៃ ឬវិភាគទាននៅឆ្នាំទី៦នឹងត្រូវបានកំណត់ចំនួន១ភាគរយ នៃតម្លៃឬបរិមាណធនធានដែលផលិតបាននៅក្នុងទីតាំងនោះ។ អត្រានេះនឹងត្រូវកើនឡើង១ភាគរយជារៀងរាល់ឆ្នាំនីមួយៗ រហូតដល់ឆ្នាំទី១២ និងត្រូវរក្សាអត្រា៧ភាគរយនៅឆ្នាំបន្តបន្ទាប់។ ដំណើរការផលិតកម្មពុំរាប់បញ្ចូលធនធានសម្រាប់ប្រើប្រាស់នៅក្នុងការធ្វើអាជីវកម្មនោះទេ។

៣. រដ្ឋដែលជាប្រទេសកំពុងអភិវឌ្ឍន៍ដែលនាំចូលសុទ្ធសាធនូវធនធានរ៉ែដែលទាញយកពីតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួនត្រូវបានលើកលែងពីការបង់កម្រៃឬវិភាគទានលើការទាញយកធនធានរ៉ែទាំងនេះ។

៤. ការបង់កម្រៃឬវិភាគទានត្រូវធ្វើឡើងតាមរយៈអាជ្ញាធរ ដែលនឹងបែងចែកទៅឱ្យបណ្តារដ្ឋភាគីនៃអនុសញ្ញានេះ ផ្អែកតាមលក្ខខណ្ឌនៃការបែងចែកចំណែកដោយផ្អែកលើគោលការណ៍សមធម៌ក្នុងចំណោមរដ្ឋទាំងនោះ ដោយពិចារណាលើផលប្រយោជន៍និងតម្រូវការនៃរដ្ឋដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តារដ្ឋដែលមានការអភិវឌ្ឍន៍តិចតួចបំផុតនិងរដ្ឋមិនជាប់សមុទ្រ។

## មាត្រា៨៣
## ការកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្ររវាងបណ្តារដ្ឋដែលមានតំបន់ឆ្នេរទល់មុខគ្នាឬជាប់គ្នា

១. ការកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្ររវាងរដ្ឋដែលមានតំបន់ឆ្នេរទល់មុខគ្នាឬជាប់គ្នា អាចមានសុពលភាពលុះត្រាតែមានកិច្ចព្រមព្រៀងរវាងរដ្ឋទាំងនោះដោយឈរលើមូលដ្ឋានច្បាប់អន្តរជាតិ ដូចដែលមានកំណត់ក្នុងមាត្រា៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីទទួលបានដំណោះស្រាយដោយសមធម៌។

២. ក្នុងករណីមិនមានការព្រមព្រៀងគ្នាក្នុងរយៈពេលសមស្រប នោះរដ្ឋដែលពាក់ព័ន្ធត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងជំពូកទី១៥នៃអនុសញ្ញានេះ។

៣. ខណៈដែលរង់ចាំកិច្ចព្រមព្រៀងដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ បណ្តារដ្ឋពាក់ព័ន្ធត្រូវព្យាយាមអស់ពីលទ្ធភាពក្នុងការស្វែងរកដំណោះស្រាយជាក់ស្តែងជាបណ្តោះអាសន្នមួយដោយឈរលើស្មារតីនៃការយោគយល់និងសហប្រតិបត្តិការ។ ក្នុងរយៈពេលអន្តរកាលនេះ បណ្តារដ្ឋពាក់ព័ន្ធមិនត្រូវធ្វើឱ្យប៉ះពាល់ឬរាំងស្ទះដល់ការចុះកិច្ចព្រមព្រៀងចុងក្រោយនោះទេ។ ការរៀបចំនេះនឹងមិនមានឥទ្ធិពលទៅលើការកំណត់ព្រំដែនចុងក្រោយនោះទេ។

៤. ក្នុងករណីដែលកិច្ចព្រមព្រៀងរវាងបណ្តារដ្ឋពាក់ព័ន្ធចូលជាធរមាន នោះបញ្ហាដែលទាក់ទងនឹងការកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្រនឹងត្រូវកំណត់ស្របទៅតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ។

## មាត្រា៨៤
## ផែនទីនិងបញ្ជីនិយាមកាភូមិសាស្ត្រ

១. នៅក្នុងផ្នែកនេះ ខ្សែបន្ទាត់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រនិងខ្សែបន្ទាត់ព្រំដែនដែលបានគូសស្របតាមមាត្រា៨៣ ត្រូវបង្ហាញនៅលើផែនទីមាត្រដ្ឋានឬមាត្រដ្ឋានដែលអាចបញ្ជាក់ច្បាស់លាស់ពីចំណុចទីតាំងរបស់វាបានគ្រប់គ្រាន់។ តាមករណីដែលសមស្រប ប្រព័ន្ធទិន្នន័យប្រថពីវិភាគ អាចនឹងត្រូវបានប្រើជំនួសគំនូសខ្សែបន្ទាត់ព្រំដែនខាងក្រៅឬខ្សែបន្ទាត់ព្រំដែន។

២. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យបានត្រឹមត្រូវអំពីផែនទីសមុទ្រ និងបញ្ជីនិយាមកាភូមិសាស្ត្រ និងត្រូវដាក់តម្កល់ផែនទីសមុទ្រនិងបញ្ជីនិយាមកាភូមិសាស្ត្រនោះមួយច្បាប់ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងអគ្គលេខាធិការនៃអាជ្ញាធរក្នុងករណីមានផែនទីឬបញ្ជីនិយាមកាភូមិសាស្ត្របង្ហាញខ្សែខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រ។

### មាត្រា៨៥
### ការជីករូងក្រោមដី

ជំពូកនេះមិននាំឱ្យប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រនៅក្នុងការធ្វើអាជីវកម្មលើស្រទាប់ដីក្រោមបាតសមុទ្រតាមមធ្យោបាយនៃការជីករូងក្រោមដីនោះទេ ទោះបីជាជម្រៅទឹកខាងលើស្រទាប់ដីក្រោមបាតសមុទ្រកម្រិតណាក៏ដោយ។

# ជំពូកទី៧
# លម្ហសមុទ្រអន្តរជាតិ
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា៨៦
### ការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ

បទប្បញ្ញត្តិនៃជំពូកនេះ អនុវត្តចំពោះផ្នែកទាំងអស់របស់សមុទ្រដែលមិនត្រូវបានរាប់បញ្ចូលក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៅក្នុងលម្ហសមុទ្រ ឬនៅក្នុងដែនទឹកផ្ទៃក្នុងរបស់រដ្ឋមួយ ឬនៅក្នុងផ្ទៃទឹកប្រជុំកោះនៃរដ្ឋប្រជុំកោះមួយ។ មាត្រានេះមិននាំឱ្យរដ្ឋទាំងអស់បាត់បង់សេរីភាពនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខអនុលោមតាមមាត្រា៥៨ នោះឡើយ។

### មាត្រា៨៧
### សេរីភាពលើលម្ហសមុទ្រអន្តរជាតិ

១. លម្ហសមុទ្រអន្តរជាតិត្រូវបានបើកចំហចំពោះរដ្ឋទាំងអស់ មិនថារដ្ឋជាប់ឆ្នេរសមុទ្រ ឬរដ្ឋមិនជាប់សមុទ្រ។ សេរីភាពលើលម្ហសមុទ្រអន្តរជាតិត្រូវបានអនុវត្តស្របតាមលក្ខខណ្ឌដូចមានចែងក្នុងអនុសញ្ញានេះ និងវិធាននៃនីតិអន្តរជាតិផ្សេងទៀត។ សេរីភាពទាំងនេះសម្រាប់ទាំងរដ្ឋជាប់ឆ្នេរសមុទ្រនិងរដ្ឋមិនជាប់សមុទ្រមានជាអាទិ៍ដូចតទៅ៖

(ក) សេរីភាពក្នុងការធ្វើនាវាចរណ៍

(ខ) សេរីភាពក្នុងការហោះហើរឆ្លងកាត់

(គ) សេរីភាពក្នុងការដាក់ពង្រាយខ្សែកាបនិងបំពង់បង្ហូរនៅបាតសមុទ្រស្របតាមបទប្បញ្ញត្តិនៃជំពូកទី៦។

(ឃ) សេរីភាពក្នុងការសាងសង់បណ្តាកោះសិប្បនិម្មិត និងបរិក្ខារដទៃទៀតដែលច្បាប់អន្តរជាតិអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃជំពូកទី៦

(ង) សេរីភាពក្នុងការនេសាទ ស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងផ្នែកទី២។

(ច) សេរីភាពក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ ស្របតាមបទប្បញ្ញត្តិនៃជំពូកទី៦និងជំពូកទី១៣។

២. រដ្ឋទាំងអស់ត្រូវអនុវត្តសេរីភាពទាំងនេះដោយយកចិត្តទុកដាក់ចំពោះផលប្រយោជន៍របស់រដ្ឋផ្សេងទៀតនៅក្នុងការអនុវត្តសេរីភាពនៃលម្ហសមុទ្រអន្តរជាតិ ព្រមទាំងយកចិត្តទុកដាក់ចំពោះសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញានេះ ដែលពាក់ព័ន្ធនឹងសកម្មភាពនានានៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

## មាត្រា៨៨

## កិច្ចអភិរក្សលម្ហសមុទ្រអន្តរជាតិសម្រាប់គោលបំណងសន្តិភាព

លម្ហសមុទ្រអន្តរជាតិត្រូវបានអភិរក្សសម្រាប់គោលបំណងសន្តិភាព។

## មាត្រា៨៩

## អសុពលភាពនៃការទាមទារអធិបតេយ្យភាពលើលម្ហសមុទ្រអន្តរជាតិ

គ្មានរដ្ឋណាមួយអាចទាមទារផ្នែកណាមួយនៃលម្ហសមុទ្រអន្តរជាតិឱ្យនៅក្រោមអធិបតេយ្យភាពរបស់ខ្លួនបានឡើយ។

## មាត្រា៩០

## សិទ្ធិនៃការធ្វើនាវាចរណ៍

រដ្ឋនីមួយៗ ទោះជារដ្ឋជាប់ឆ្នេរសមុទ្រឬរដ្ឋមិនជាប់សមុទ្រ មានសិទ្ធិឱ្យនាវាធ្វើនាវាចរណ៍ដោយលើកទង់ជាតិរបស់ខ្លួននៅលើលម្ហសមុទ្រអន្តរជាតិ។

## មាត្រា៩១

## សញ្ជាតិរបស់នាវា

១. រដ្ឋនីមួយៗ ត្រូវកំណត់លក្ខខណ្ឌសម្រាប់ការផ្តល់សញ្ជាតិរបស់ខ្លួនឱ្យនាវា សម្រាប់ការចុះបញ្ជីនាវានៅក្នុងដែនដីរបស់ខ្លួន និងសម្រាប់ផ្តល់សិទ្ធិដើម្បីលើកទង់ជាតិរបស់ខ្លួន។ នាវាត្រូវមានសញ្ជាតិនៃរដ្ឋដែលនាវានោះទទួលសិទ្ធិឱ្យលើកទង់ជាតិនៃរដ្ឋនោះ។ រដ្ឋនិងនាវា ត្រូវមានទំនាក់ទំនងនឹងគ្នាដោយពិតប្រាកដ។

២. រដ្ឋនីមួយៗ ត្រូវចេញឱ្យនាវាដែលខ្លួនបានផ្តល់សិទ្ធិឱ្យលើកទង់ជាតិរបស់ខ្លួននូវឯកសារដែលពាក់ព័ន្ធ។

## មាត្រា៩២

## លក្ខន្តិកៈរបស់នាវា

១. នាវា ត្រូវធ្វើនាវាចរណ៍ក្រោមទង់ជាតិនៃរដ្ឋតែមួយប៉ុណ្ណោះនិងត្រូវស្ថិតក្រោមយុត្តាធិការផ្តាច់មុខរបស់រដ្ឋនោះនៅលើលម្ហសមុទ្រអន្តរជាតិ លើកលែងតែករណីដូចមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិនានា ឬក្នុងអនុសញ្ញានេះ។ នាវាមិនអាចផ្លាស់ប្តូរទង់ជាតិរបស់ខ្លួនបានឡើយ នៅក្នុងអំឡុងពេលនាវាចរណ៍ ឬនៅក្នុងខណៈដែលស្ថិតនៅកំពង់ផែណាមួយដែលនាវាចូលចត លើកលែងតែក្នុងករណីដែលមានការផ្ទេរកម្មសិទ្ធិឬការផ្លាស់ប្តូរបញ្ជិកានាវាជាក់ស្តែង។

២. នាវាដែលធ្វើនាវាចរណ៍ក្រោមទង់ជាតិនៃរដ្ឋពីរឬច្រើនជាងនេះ ដោយប្រើប្រាស់ទង់ជាតិទាំងនោះដើម្បីឱ្យមានភាពងាយស្រួល មិនអាចទាមទារសញ្ជាតិណាមួយនៃរដ្ឋណាមួយបានឡើយ ហើយអាចត្រូវបានចាត់ទុកថាជានាវាដែលគ្មានសញ្ជាតិ។

## មាត្រា៩៣

## នាវាដែលពាក់ទង់របស់អង្គការសហប្រជាជាតិ ទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ និងទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ

បណ្តាមាត្រាខាងលើ មិនប៉ះពាល់ដល់នាវាដែលបម្រើការជាផ្លូវការរបស់អង្គការសហប្រជាជាតិ ឬទីភ្នាក់ងារឯកទេសណាមួយរបស់អង្គការសហប្រជាជាតិ ឬរបស់ទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ ដែលពាក់ទង់របស់អង្គការទាំងនេះឡើយ។

## មាត្រា៩៤
## ករណីយកិច្ចនៃរដ្ឋម្ចាស់សញ្ញាតិនាវា

១. រដ្ឋនីមួយៗ ត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុត្តាធិការនិងការត្រួតពិនិត្យរបស់ខ្លួនផ្នែករដ្ឋបាល ផ្នែកបច្ចេកទេស និងផ្នែកសង្គមកិច្ចចំពោះនាវាដែលលើកទង់ជាតិរបស់ខ្លួន។

២. ជាពិសេស រដ្ឋនីមួយៗត្រូវ៖

(ក) ថែរក្សាទុកនូវបញ្ជិកានាវា ដែលមានឈ្មោះនិងកិនភាគរបស់នាវាដែលពាក់ទង់ជាតិរបស់ខ្លួន លើកលែងតែនាវាដែលត្រូវលើកលែងពីបទបញ្ជាអន្តរជាតិដែលបានទទួលយកជាទូទៅ ដោយអាស្រ័យលើទំហំតូចរបស់នាវានោះ និង

(ខ) កំណត់យុត្តាធិការក្រោមបទបញ្ញាផ្ទៃក្នុងរបស់ខ្លួនលើនាវានីមួយៗដែលពាក់ទង់ជាតិរបស់ខ្លួន និងនាយនាវា នាយផ្នែកបើកបរ/នាយផ្នែកម៉ាស៊ីន និងក្រុមនាវិករបស់ខ្លួន ទាក់ទងនឹងផ្នែករដ្ឋបាល ផ្នែកបច្ចេកទេស និងផ្នែកសង្គមកិច្ចដែលពាក់ព័ន្ធនឹងនាវានោះ។

៣. រដ្ឋនីមួយៗ ត្រូវចាត់វិធានការចំពោះនាវាដែលលើកទង់ជាតិរបស់ខ្លួនដែលចាំបាច់ ដើម្បីធានាសុវត្ថិភាពនៅសមុទ្រ ដែលក្នុងចំណោមវិធានការទាំងនោះ ត្រូវផ្តោតទៅលើចំណុចជាអាទិ៍ដូចខាងក្រោម៖

(ក) ការសាងសង់ ឧបករណ៍ និងការធានាសុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវា។

(ខ) ការដាក់មនុស្សឱ្យធ្វើការលើនាវា លក្ខខណ្ឌការងារ និងការបណ្តុះបណ្តាលក្រុមនាវិក ដោយគិតគូរដល់លិខិតូបករណ៍អន្តរជាតិដែលមានជាធរមាន។

(គ) ការប្រើប្រាស់សញ្ញា ការរក្សាប្រព័ន្ធទាក់ទង និងការបង្ការការប៉ះទង្គិចនាវា។

៤. វិធានការទាំងនេះ ត្រូវរួមបញ្ចូលនូវវិធានការដែលចាំបាច់ ដើម្បីធានាថា៖

(ក) នាវានីមួយៗ នៅមុនពេលចុះបញ្ជីនិងបន្ទាប់ពីបានចុះបញ្ជីក្នុងរយៈពេលកំណត់សមស្រប ត្រូវដាក់ឱ្យត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាដែលមានគុណវុឌ្ឍិ ហើយត្រូវមាននៅលើនាវានោះនូវផែនទីសមុទ្រ ឯកសារបោះពុម្ពផ្សាយផ្នែកនាវាចរណ៍ ឧបករណ៍ និងសម្ភារនាវាចរណ៍ដែលសមស្របសម្រាប់ការធ្វើនាវាចរណ៍ដោយសុវត្ថិភាព។

(ខ) នាវានីមួយៗ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់នាយនាវា និងនាយផ្នែកបើកបរ/ផ្នែកម៉ាស៊ីនដែលមានគុណវុឌ្ឍិសមស្រប ជាពិសេសជំនាញបច្ចេកទេសខាងប្រតិបត្តិការនាវា ការធ្វើនាវាចរណ៍ ការទាក់ទង និងវិស្វកម្មខាងសមុទ្រ ហើយក្រុមនាវិកត្រូវមានគុណវុឌ្ឍិ និងចំនួនសមស្រប ទៅតាមប្រភេទ ទំហំ ម៉ាស៊ីន និងឧបករណ៍របស់នាវា។

(គ) នាយនាវា នាយផ្នែកបើកបរ/នាយផ្នែកម៉ាស៊ីន និងក្រុមនាវិក ដោយអាស្រ័យនឹងវិសាលភាពដែលសមស្រប ត្រូវមានការយល់ដឹងច្បាស់លាស់និងប្រតិបត្តិឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិអន្តរជាតិជាធរមាន ដែលទាក់ទងនឹងសុវត្ថិភាពនៃអាយុជីវិតនៅសមុទ្រ ការបង្ការការប៉ះទង្គិចនាវា ការទប់ស្កាត់ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលសមុទ្រ និងការរក្សាប្រព័ន្ធវិទ្យុទាក់ទង។

៥. នៅក្នុងការចាត់វិធានការដូចមានចែងនៅក្នុងកថាខណ្ឌទី៣និងកថាខណ្ឌទី៤ខាងលើ រដ្ឋនីមួយៗត្រូវគោរពតាមបទប្បញ្ញត្តិ នីតិវិធី និងការអនុវត្តជាអន្តរជាតិដែលទទួលយកជាទូទៅ និងត្រូវចាត់វិធានការដែលចាំបាច់ដើម្បីធានានូវការប្រតិបត្តិតាម។

៦. រដ្ឋណាមួយដែលមានមូលហេតុច្បាស់លាស់ដែលជឿជាក់ថាយុត្តាធិការនិងការត្រួតពិនិត្យលើនាវាមិនត្រូវបានអនុវត្តត្រឹមត្រូវ អាចរាយការណ៍អំពីហេតុការណ៍ពិតនោះទៅរដ្ឋម្ចាស់សញ្ជាតិនាវា។ បន្ទាប់ពីបានទទួលរបាយការណ៍នេះ រដ្ឋម្ចាស់សញ្ជាតិនាវា ត្រូវធ្វើការស៊ើបអង្កេតលើបញ្ហានោះ ហើយប្រសិនបើសមស្រប ត្រូវចាត់វិធានការដែលចាំបាច់ដើម្បីដោះស្រាយបញ្ហានោះ។

៧. រដ្ឋនីមួយៗ ត្រូវចាត់ចែងឱ្យមានការសាកសួរដែលធ្វើឡើងដោយឬនៅចំពោះមុខបុគ្គលណាម្នាក់ ឬច្រើននាក់ដែលមានគុណវុឌ្ឍិស័ក្តិសម អំពីគ្រោះថ្នាក់នីមួយៗនៅសមុទ្រឬឧប្បត្តិហេតុនៃការធ្វើនាវាចរណ៍នៅលើលម្ហសមុទ្រអន្តរជាតិ ដែលជាប់ពាក់ព័ន្ធនឹងនាវាដែលលើកទង់ជាតិរបស់ខ្លួន និងដែលបណ្តាលឱ្យមានការបាត់បង់អាយុជីវិត ឬរងរបួសធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋនៃរដ្ឋផ្សេងទៀត ឬព្យសនកម្មធ្ងន់ធ្ងរដល់នាវា ឬបរិក្ខារបស់រដ្ឋផ្សេងទៀត ឬដល់បរិស្ថានសមុទ្រ។ រដ្ឋម្ចាស់សញ្ជាតិនាវានិងរដ្ឋម្ខាងទៀត ត្រូវសហការគ្នានៅក្នុងការរៀបចំការសាកសួរអំពីគ្រោះថ្នាក់នៅសមុទ្រឬឧប្បត្តិហេតុនៃការធ្វើនាវាចរណ៍នោះដែលធ្វើឡើងដោយរដ្ឋម្ខាងទៀត។

## មាត្រា៩៥

## អភ័យឯកសិទ្ធិនៃនាវាចម្បាំងនៅលើលម្ហសមុទ្រអន្តរជាតិ

នាវាចម្បាំងនៅលើលម្ហសមុទ្រអន្តរជាតិ មានអភ័យឯកសិទ្ធិពេញលេញពីយុត្តាធិការនៃរដ្ឋផ្សេងៗ លើកលែងតែរដ្ឋម្ចាស់សញ្ជាតិនាវា។

## មាត្រា៩៦

## អភ័យឯកសិទ្ធិនៃនាវាដែលប្រើប្រាស់សម្រាប់តែសេវាកម្មរដ្ឋដោយមិនធ្វើពាណិជ្ជកម្ម

នាវាដែលជាកម្មសិទ្ធិឬធ្វើប្រតិបត្តិការដោយរដ្ឋ និងប្រើប្រាស់សម្រាប់តែសេវាកម្មរដ្ឋ ដោយមិនធ្វើពាណិជ្ជកម្មនៅលើលម្ហសមុទ្រអន្តរជាតិ មានអភ័យឯកសិទ្ធិពេញលេញពីយុត្តាធិការនៃរដ្ឋផ្សេងៗ លើកលែងតែរដ្ឋម្ចាស់សញ្ជាតិនាវា។

## មាត្រា៩៧

## យុត្តាធិការព្រហ្មទណ្ឌលើករណីនៃការប៉ះទង្គិចឬឧប្បត្តិហេតុផ្សេងទៀតនៃការធ្វើនាវាចរណ៍

១. ក្នុងព្រឹត្តិការណ៍នៃការប៉ះទង្គិចឬឧប្បត្តិហេតុផ្សេងទៀតនៃការធ្វើនាវាចរណ៍ ដែលទាក់ទងនឹងនាវានៅលើលម្ហសមុទ្រអន្តរជាតិ ដោយមានពាក់ព័ន្ធនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ឬខាងការដាក់ពិន័យចំពោះនាយនាវាឬបុគ្គលផ្សេងទៀតដែលធ្វើការនៅលើនាវានោះ គ្មានបណ្តឹងព្រហ្មទណ្ឌឬបណ្តឹងឱ្យដាក់ពិន័យណាមួយអាចត្រូវបានធ្វើឡើងចំពោះបុគ្គលទាំងនេះបានឡើយ លើកលែងតែត្រូវបានធ្វើឡើងនៅចំពោះមុខអាជ្ញាធរតុលាការ ឬរដ្ឋបាលនៃរដ្ឋម្ចាស់សញ្ជាតិនាវា ឬរដ្ឋដែលបុគ្គលនោះទទួលបានសញ្ជាតិ។

២. ក្នុងករណីនៃការដាក់ពិន័យ រដ្ឋដែលចេញវិញ្ញាបនបត្រឱ្យនាយនាវា ឬវិញ្ញាបនបត្របញ្ជាក់សមត្ថភាពជំនាញនាវិក ឬអាជ្ញាបណ្ណ ត្រូវជារដ្ឋមានសមត្ថកិច្ចតែមួយគត់ក្នុងការប្រកាសដកហូតវិញ្ញាបនបត្រទាំងនេះវិញ បើទោះជាសាមីខ្លួនមិនមែនជាប្រជាពលរដ្ឋនៃរដ្ឋដែលចេញវិញ្ញាបនបត្រទាំងនេះក៏ដោយ។

៣. គ្មាននាវាណាមួយត្រូវបានចាប់យកឬឃាត់ទុក ដែលធ្វើឡើងតាមការបញ្ជាពីអាជ្ញាធរណាមួយក្រៅពីអាជ្ញាធរនៃរដ្ឋម្ចាស់សញ្ជាតិនាវាឡើយ បើទោះបីជាការចាប់យកឬឃាត់ទុកនោះត្រូវបានអនុវត្តក្រោមវិធានការនៃការស៊ើបអង្កេតក៏ដោយ។

## មាត្រា៩៨
## ករណីយកិច្ចផ្តល់ជំនួយ

១. ដើម្បីកុំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់នាវា ក្រុមនាវិកឬអ្នកដំណើរលើនាវា រដ្ឋនីមួយៗ ត្រូវតម្រូវឱ្យនាយនាវានៃនាវាដែលលើកទង់ជាតិរបស់ខ្លួនធ្វើតាមលទ្ធភាពដែលនាយនាវានោះអាចធ្វើទៅបាន ដូចខាងក្រោម៖

(ក) ផ្តល់ជំនួយដល់បុគ្គលណាមួយដែលប្រទះឃើញនៅលើសមុទ្រកំពុងស្ថិតក្នុងគ្រោះថ្នាក់បាត់បង់ជីវិត។

(ខ) ធ្វើដំណើរក្នុងល្បឿនតាមដែលអាចធ្វើទៅបានឆ្ពោះទៅជួយសង្គ្រោះបុគ្គលដែលជួបគ្រោះអាសន្ន ប្រសិនបើបានទទួលព័ត៌មានអំពីតម្រូវការនៃការជួយសង្គ្រោះបុគ្គលទាំងនោះ ហើយដែលសកម្មភាពនោះអាចត្រូវបានគេរំពឹងថាមានហេតុផលសមរម្យ ដែលនាយនាវានោះត្រូវអនុវត្ត

(គ) ផ្តល់ជំនួយសង្គ្រោះដល់នាវាម្ខាងទៀត ក្រុមនាវិក និងអ្នកដំណើរនៅលើនាវានោះ បន្ទាប់ពីមានការប៉ះទង្គិចនាវា និងប្រសិនបើអាចធ្វើទៅបាន ត្រូវជូនដំណឹងទៅដល់នាវាម្ខាងទៀតអំពីឈ្មោះនៃនាវារបស់ខ្លួន កំពង់ផែចុះបញ្ជីនៃនាវា និងកំពង់ផែដែលនៅជិតបំផុតដែលនាវានោះនឹងត្រូវចូលចត។

២. រដ្ឋជាប់ឆ្នេរសមុទ្រនីមួយៗ ត្រូវជំរុញការបង្កើត ការធ្វើប្រតិបត្តិការ និងការរក្សាឱ្យមានសេវាកម្មរុករក និងសង្គ្រោះឱ្យបានគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាព ទាក់ទងនឹងសុវត្ថិភាពនៅតាមនិងនៅលើដែនសមុទ្រ និងក្នុងកាលៈទេសៈតម្រូវ ត្រូវសហការជាមួយនឹងបណ្តារដ្ឋជិតខាង តាមរយៈការរៀបចំកិច្ចសហការថ្នាក់តំបន់ទៅវិញទៅមក សម្រាប់គោលបំណងនេះ។

## មាត្រា៩៩
## ការហាមឃាត់ចំពោះការដឹកជញ្ជូនទាសករ

រដ្ឋនីមួយៗ ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីបង្ការនិងផ្តន្ទាទោសចំពោះការដឹកជញ្ជូនទាសករនៅក្នុងនាវាដែលទទួលបានការអនុញ្ញាតឱ្យលើកទង់ជាតិរបស់ខ្លួន និងដើម្បីបង្ការទប់ស្កាត់ការប្រើប្រាស់ទង់ជាតិរបស់ខ្លួនដោយខុសច្បាប់សម្រាប់គោលបំណងខាងលើនេះ។ ទាសករដែលជ្រកកោននៅលើនាវាណាមួយក៏ដោយដែលលើកទង់ជាតិរបស់ខ្លួនណាមួយក៏ដោយ ត្រូវតែដោះលែងឱ្យមានសេរីភាពដោយគ្មានលក្ខខណ្ឌ។

## មាត្រា១០០
## ករណីយកិច្ចសហប្រតិបត្តិការបង្ក្រាបអំពើចោរកម្មតាមលមុទ្រសមុទ្រអន្តរជាតិ

រដ្ឋទាំងអស់ ត្រូវចូលរួមសហការឱ្យអស់ពីលទ្ធភាពនៅក្នុងការបង្ក្រាបអំពើចោរកម្មតាមលមុទ្រសមុទ្រអន្តរជាតិ ឬនៅកន្លែងផ្សេងទៀតដែលស្ថិតនៅក្រៅដែនយុត្តាធិការរបស់រដ្ឋណាមួយ។

## មាត្រា១០១
## និយមន័យនៃអំពើចោរកម្មតាមសមុទ្រ

អំពីចោរកម្មសមុទ្រសំដៅដល់អំពើដូចមានចែងខាងក្រោម៖

(ក) អំពើហិង្សា ឬការឃុំឃាំងខុសច្បាប់ ឬអំពើបំផ្លិចបំផ្លាញណាមួយ ដែលត្រូវបានប្រព្រឹត្តដើម្បីជាផលប្រយោជន៍ឯកជន ដោយនាវិក អាកាសយានិក ឬអ្នកដំណើរនៃនាវាឯកជន ឬអាកាសយានឯកជនមួយ ហើយដែលសកម្មភាពនោះប្រព្រឹត្តឡើង៖

- (i) នៅលម្ហសមុទ្រអន្តរជាតិ ប្រឆាំងនឹងនាវាឬអាកាសយានផ្សេងទៀត ឬប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិនៅលើនាវាឬលើអាកាសយាននោះ។
- (ii) ប្រឆាំងនឹងនាវា អាកាសយាន បុគ្គល ឬទ្រព្យសម្បត្តិនៅកន្លែងដែលស្ថិតនៅក្រៅដែនយុត្តាធិការរបស់រដ្ឋណាមួយ។

(ខ) អំពើចូលរួមដោយស្ម័គ្រចិត្តនៅក្នុងប្រតិបត្តិការនាវាឬអាកាសយាន ដោយដឹងច្បាស់ថានាវាឬអាកាសយាននោះជានាវាឬអាកាសយានចោរកម្ម។

(គ) អំពើញុះញង់ឬផ្តល់មធ្យោបាយដោយចេតនាដល់ការប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងអនុកថាខណ្ឌ (ក) ឬ (ខ)។

## មាត្រា១០២
## អំពើចោរកម្មតាមសមុទ្រដោយនាវាចម្បាំង នាវារបស់រដ្ឋ ឬអាកាសយានរបស់រដ្ឋ ដោយក្រុមនាវិកឬក្រុមអាកាសយានិកដែលបះបោរ

អំពើចោរកម្មតាមសមុទ្រ ដូចមានចែងក្នុងមាត្រា១០១ ដែលបានប្រព្រឹត្តដោយនាវាចម្បាំង នាវារបស់រដ្ឋ ឬអាកាសយានរបស់រដ្ឋដែលក្រុមនាវិកឬក្រុមអាកាសយានិកបានបះបោរនិងបានគ្រប់គ្រងនាវា ឬអាកាសយាននោះ ត្រូវចាត់ទុកដូចជាអំពើចោរកម្មដែលប្រព្រឹត្តដោយនាវាឬអាកាសយានឯកជន។

## មាត្រា១០៣
## និយមន័យនៃនាវាឬអាកាសយានចោរកម្មតាមលម្ហសមុទ្រ

នាវាឬអាកាសយាន ត្រូវចាត់ទុកជានាវាឬអាកាសយានចោរកម្មតាមលម្ហសមុទ្រ ប្រសិនបើបុគ្គលដែលបានអំណាចគ្រប់គ្រងលើនាវាឬអាកាសយាននោះ មានចេតនាប្រើប្រាស់នាវាឬអាកាសយាននោះ ដើម្បីប្រព្រឹត្តអំពើណាមួយដូចមានចែងក្នុងមាត្រា១០១។ ការចាត់ទុកនេះ ក៏ត្រូវអនុវត្តដូចគ្នាទៅលើនាវាឬអាកាសយានដែលត្រូវបាននិងកំពុងប្រើប្រាស់ក្នុងគោលបំណងណាមួយខាងលើ ដរាបណានាវាឬអាកាសយាននោះ បន្តស្ថិតនៅក្រោមការគ្រប់គ្រងរបស់បុគ្គលដែលមានពិរុទ្ធនោះ។

## មាត្រា១០៤
## ការរក្សាឬដកសញ្ជាតិនៃនាវាឬអាកាសយានចោរកម្មតាមលម្ហសមុទ្រ

នាវាឬអាកាសយាន អាចរក្សាសញ្ជាតិរបស់ខ្លួនបានដដែល ទោះបីជានាវាឬអាកាសយាននោះបានក្លាយជានាវាឬអាកាសយានចោរកម្មតាមលម្ហសមុទ្រក៏ដោយ។ ការរក្សាឬដកសញ្ជាតិនៃនាវាឬអាកាសយានចោរកម្មត្រូវកំណត់ដោយច្បាប់របស់រដ្ឋដែលផ្តល់សញ្ជាតិនោះ។

## មាត្រា១០៥
## ការរឹបអូសនាវាឬអាកាសយានចោរកម្មតាមលម្ហសមុទ្រ

រដ្ឋនីមួយៗអាចរឹបអូសនាវាឬអាកាសយានចោរកម្មតាមលម្ហសមុទ្រ ឬនាវាឬអាកាសយានដែលបានប្លន់យក និងស្ថិតក្រោមការគ្រប់គ្រងរបស់ចោរសមុទ្រ និងចាប់ឃាត់ខ្លួនបុគ្គល និងរឹបអូសទ្រព្យសម្បត្តិ ដែលមាននៅក្នុងនាវា ឬអាកាសយាននោះ នៅក្នុងលម្ហសមុទ្រអន្តរជាតិ ឬនៅកន្លែងផ្សេងទៀតដែលស្ថិតនៅក្រៅដែនយុត្តាធិការរបស់រដ្ឋណាមួយ។ តុលាការនៃរដ្ឋដែលធ្វើការរឹបអូសនេះ អាចមានសិទ្ធិសម្រេចលើទោសទណ្ឌ និងមានសិទ្ធិកំណត់លើចំណាត់ការដែលត្រូវអនុវត្តលើនាវា អាកាសយាន ឬទ្រព្យសម្បត្តិ អាស្រ័យទៅលើសិទ្ធិរបស់តតិយជនសុចរិតនិងទៀងត្រង់។

## មាត្រា១០៦
## ការទទួលខុសត្រូវលើការរឹបអូសដោយគ្មានមូលដ្ឋានច្បាស់លាស់

ក្នុងករណីដែលមានការរឹបអូសនាវាឬអាកាសយាន ដោយផ្អែកលើការសង្ស័យអំពីអំពើចោរកម្មតាមលម្ហសមុទ្រដោយគ្មានមូលដ្ឋានត្រឹមត្រូវ រដ្ឋដែលធ្វើការរឹបអូសនេះត្រូវទទួលខុសត្រូវលើការបាត់បង់ ឬការខូចខាតដែលកើតឡើងពីការរឹបអូសនេះ ចំពោះរដ្ឋដែលជាម្ចាស់សញ្ជាតិនាវាឬអាកាសយាន។

## មាត្រា១០៧
## នាវានិងអាកាសយានដែលមានសិទ្ធិរឹបអូសដោយសារចោរកម្មតាមលម្ហសមុទ្រ

ការរឹបអូសនាវានិងអាកាសយានក្នុងករណីចោរកម្មតាមលម្ហសមុទ្រ អាចធ្វើឡើងបានដោយតែនាវាចម្បាំង ឬអាកាសយានយោធា ឬនាវាឬអាកាសយានផ្សេងទៀតដែលមានសញ្ញាសម្គាល់និងអាចសម្គាល់បានច្បាស់លាស់ថាជានាវាឬអាកាសយានដែលកំពុងបំពេញការងារផ្លូវការរបស់រដ្ឋនិងត្រូវបានអនុញ្ញាតឱ្យធ្វើការរឹបអូស។

## មាត្រា១០៨
## ចរាចរណ៍ខុសច្បាប់នូវថ្នាំញៀនណាកូទិក ឬសារធាតុមានឥទ្ធិពលលើប្រព័ន្ធប្រសាទ

១. រដ្ឋទាំងអស់ ត្រូវសហការគ្នាក្នុងការបង្ក្រាបចរាចរណ៍ថ្នាំញៀនណាកូទិក និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធប្រសាទដែលប្រព្រឹត្តដោយនាវានៅលម្ហសមុទ្រអន្តរជាតិដែលផ្ទុយនឹងអនុសញ្ញាអន្តរជាតិ។

២. រដ្ឋណាមួយដែលមានមូលដ្ឋានសមស្របក្នុងការជឿជាក់ថាមាននាវាដែលលើកទង់ជាតិរបស់ខ្លួនបានចរាចរខុសច្បាប់នូវថ្នាំញៀនណាកូទិកឬសារធាតុមានឥទ្ធិពលលើប្រព័ន្ធប្រសាទ អាចស្នើសុំការសហការពីរដ្ឋផ្សេងទៀតដើម្បីបង្ក្រាបចរាចរណ៍ខុសច្បាប់នោះ។

## មាត្រា១០៩
## ការផ្សព្វផ្សព្វផ្សាយដោយគ្មានការអនុញ្ញាតនៅលម្ហសមុទ្រអន្តរជាតិ

១. រដ្ឋទាំងអស់ត្រូវសហការក្នុងការបង្ក្រាបការផ្សព្វផ្សព្វផ្សាយដោយគ្មានការអនុញ្ញាតនៅលម្ហសមុទ្រអន្តរជាតិ។

២. សម្រាប់គោលបំណងនៃអនុសញ្ញានេះ "ការផ្សព្វផ្សាយដោយគ្មានការអនុញ្ញាត" មានន័យថា ការបញ្ជូនសំឡេងតាមវិទ្យុឬការផ្សព្វផ្សព្វផ្សាយតាមទូរទស្សន៍ចេញពីនាវា ឬបបនាការនៅលម្ហសមុទ្រអន្តរជាតិដែលមានចេតនាដើម្បីឱ្យសាធារណជនទូទៅទទួលបាននូវការផ្សាយដែលផ្ទុយពីបទប្បញ្ញត្តិអន្តរជាតិ វៀរលែងតែការបញ្ជូនព័ត៌មាននៃការហៅជួយសង្គ្រោះក្នុងគ្រាអាសន្ន។

៣.  បុគ្គលទាំងឡាយណាដែលបានធ្វើការផ្សព្វផ្សាយដោយគ្មានការអនុញ្ញាត អាចត្រូវរងការផ្តន្ទាទោសនៅចំពោះមុខតុលាការនៃ៖

(ក)  រដ្ឋម្ចាស់សញ្ជាតិនៃនាវានោះ

(ខ)  រដ្ឋចុះបញ្ជីនៃឋបនាការនោះ

(គ)  រដ្ឋដែលបុគ្គលនោះមានសញ្ជាតិ

(ឃ)  រដ្ឋណាមួយដែលបានទទួលការផ្សព្វផ្សាយដោយគ្មានការអនុញ្ញាតនោះ ឬ

(ង)  រដ្ឋណាមួយដែលប្រព័ន្ធវិទ្យុទាក់ទងស្របច្បាប់របស់ខ្លួនបានទទួលរងការរំខាននោះ។

៤.  រដ្ឋដែលមានយុត្តាធិការដូចមានចែងក្នុងកថាខណ្ឌទី៣ អាចចាប់ខ្លួនបុគ្គល ឬនាវាណាមួយដែលបានធ្វើការផ្សព្វផ្សព្វផ្សាយដោយគ្មានការអនុញ្ញាត និងរឹបអូសឧបករណ៍បរិក្ខារទាំងនោះ នៅលម្ហសមុទ្រអន្តរជាតិដោយអនុលោមតាមមាត្រា១១០។

## មាត្រា១១០

## សិទ្ធិចុះត្រួតពិនិត្យ

១.  លើកលែងតែអំពើនៃការរំខានកើតចេញពីសិទ្ធអំណាចផ្តល់ឱ្យដោយសន្ធិសញ្ញាណាមួយ នាវាចម្បាំងដែលជួបប្រទះនាវាបរទេសមួយទៀតនៅលម្ហសមុទ្រអន្តរជាតិ ក្រៅពីនាវាដែលមានអភ័យឯកសិទ្ធពេញលេញស្របតាមមាត្រា៩៥ និងមាត្រា៩៦ មិនមានយុត្តិកម្មនៅក្នុងការឡើងលើនាវានោះទេ លើកលែងតែមានមូលហេតុសមរម្យក្នុងការសង្ស័យថា៖

(ក)  នាវានោះមានជាប់ពាក់ព័ន្ធនឹងអំពើចោរកម្មតាមលម្ហសមុទ្រ

(ខ)  នាវានោះមានជាប់ពាក់ព័ន្ធនឹងការជួញដូរទាសករ

(គ)  នាវានោះមានជាប់ពាក់ព័ន្ធនឹងការផ្សព្វផ្សាយព័ត៌មានដោយគ្មានការអនុញ្ញាត ហើយរដ្ឋម្ចាស់សញ្ជាតិនៃវាចម្បាំងមានយុត្តាធិការស្របតាមមាត្រា១០៩

(ឃ)  នាវានោះគ្មានសញ្ជាតិ ឬ

(ង)  ទោះបីជាលើកទង់ជាតិបរទេសឬបដិសេធក្នុងការបង្ហាញទង់ជាតិរបស់ខ្លួនក៏ដោយ នាវានោះជាក់ស្តែងមានសញ្ជាតិដូចគ្នានឹងនាវាចម្បាំងដែរ។

២.  ក្នុងករណីដូចមានចែងក្នុងកថាខណ្ឌទី១ នាវាចម្បាំងអាចធ្វើការផ្ទៀងផ្ទាត់សិទ្ធិរបស់នាវានោះ ក្នុងការលើកទង់ជាតិរបស់ខ្លួន។ ក្នុងន័យនេះ នាវាចម្បាំងអាចនឹងបញ្ជូនទូកមួយគ្រឿងក្រោមការដឹកនាំ–របស់មន្ត្រីម្នាក់ទៅកាន់នាវាដែលសង្ស័យនោះ។ ប្រសិនបើនៅតែមានការសង្ស័យបន្ទាប់ពីបានពិនិត្យឯកសាររួច នាវាចម្បាំងនោះអាចបន្តឡើងលើនាវានោះដើម្បីបន្តការពិនិត្យ ប៉ុន្តែត្រូវគិតពិចារណាគ្រប់ទិដ្ឋភាពទាំងអស់។

៣.  ប្រសិនបើរកឃើញថាគ្មានភស្តុតាងបញ្ជាក់ការសង្ស័យនោះទេ និងក្នុងលក្ខខណ្ឌដែលនាវា ដែលត្រូវបានពិនិត្យពុំបានប្រព្រឹត្តសកម្មភាពណាមួយដែលបញ្ជាក់អំពីការសង្ស័យនោះ នាវានោះត្រូវទទួលបានសំណងសម្រាប់ការបាត់បង់ឬព្យសនកម្មដែលបានកើតឡើង។

៤.  បទប្បញ្ញត្តិទាំងនេះ ត្រូវអនុវត្តដូចគ្នាចំពោះអាកាសយានយោធា។

៥.  បទប្បញ្ញត្តិទាំងនេះ ក៏ត្រូវអនុវត្តផងដែរចំពោះនាវាឬអាកាសយានផ្សេងទៀតដែលទទួលបានសិទ្ធិចុះត្រួតពិនិត្យ ដែលមានសញ្ញាសម្គាល់និងអាចសម្គាល់បានច្បាស់លាស់ថាកំពុងបំពេញការងារផ្លូវការរបស់រដ្ឋ។

## មាត្រា១១១
## សិទ្ធិដេញប្រផាប់ចាប់ប្រកីង

១. ការដេញប្រផាប់ចាប់ប្រកីងនូវនាវាបរទេស អាចអនុវត្តបាននៅពេលដែលអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋជាប់ឆ្នេរសមុទ្រ មានហេតុផលត្រឹមត្រូវដែលជឿជាក់ថានាវានោះបានបំពានច្បាប់និងបទ បទបញ្ជារបស់រដ្ឋនោះ។ ការដេញប្រផាប់ចាប់ប្រកីងនេះ ត្រូវចាប់ផ្តើមនៅពេលដែលនាវាបរទេសឬទូកមួយរបស់នាវានោះ ស្ថិតនៅក្នុងដែនទឹកផ្ទៃក្នុង ផ្ទៃទឹកប្រជុំកោះ សមុទ្រដែនដី ឬតំបន់តភ្ជាប់របស់រដ្ឋដែលធ្វើការដេញចាប់នោះ ហើយអាចបន្តបាននៅក្រៅសមុទ្រដែនដីឬតំបន់តភ្ជាប់ប្រសិនបើការដេញចាប់នោះមិនត្រូវបានបង្អាក់។ នៅពេលដែលនាវាបរទេសស្ថិតនៅក្នុងសមុទ្រដែនដីឬតំបន់តភ្ជាប់ទទួលការបញ្ជាឱ្យឈប់ មិនមានការចាំបាច់ណាមួយដែលនាវាចេញការបញ្ជានោះត្រូវស្ថិតនៅក្នុងសមុទ្រដែនដីឬតំបន់តភ្ជាប់ដែរនោះទេ។ ប្រសិនបើនាវាបរទេសស្ថិតនៅក្នុងតំបន់តភ្ជាប់ដូចមានចែងក្នុងមាត្រា៣៣ នោះការដេញចាប់អាចធ្វើឡើងបានតែក្នុងករណីដែលមានការរំលោភបំពានសិទ្ធិនៅតំបន់ដែលបានបង្កើតការ ការពារប៉ុណ្ណោះ។

២. សិទ្ធិដេញប្រផាប់ចាប់ប្រកីង ត្រូវអនុវត្តដូចគ្នា ចំពោះការរំលោភបំពានដែលកើតមានឡើងនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬខ្ពង់រាបបាតសមុទ្រ រួមទាំងក្នុងតំបន់សុវត្ថិភាពជុំវិញបំរនាការនៅខ្ពង់រាបបាតសមុទ្រដែលរំលោភបំពានច្បាប់និងបទបញ្ជាជាធរមានរបស់រដ្ឋជាប់ឆ្នេរសមុទ្រដែលត្រូវបានដាក់ចេញស្របតាមអនុសញ្ញានេះទាក់ទងនឹងតំបន់សេដ្ឋកិច្ចផ្តាច់មុខឬខ្ពង់រាបបាតសមុទ្រ និងតំបន់សុវត្ថិភាព។

៣. សិទ្ធិដេញប្រផាប់ចាប់ប្រកីង ត្រូវបញ្ចប់នៅពេលដែលនាវាដែលត្រូវបានដេញចាប់នោះ បានចូលទៅក្នុងសមុទ្រដែនដីនៃរដ្ឋខ្លួនឬរដ្ឋទីបី។

៤. ការដេញប្រផាប់ចាប់ប្រកីង មិនត្រូវបានចាត់ទុកថាចាប់ផ្តើមឡើយ វៀរលែងតែនាវាដេញចាប់បានប្រាកដដោយខ្លួនឯង តាមរយៈមធ្យោបាយអនុវត្តន៍ដែលអាចបញ្ជាក់ច្បាស់ថា នាវាដែលត្រូវបានដេញចាប់ ឬទូកមួយក្នុងចំណោមទូកជាច្រើន ឬយានផ្សេងទៀតដែលនាវានោះកំពុងធ្វើការជាក្រុមនិងកំពុងប្រើប្រាស់នាវាដែលត្រូវបានដេញចាប់ជានាវាមេ ស្ថិតនៅក្នុងព្រំដែននៃសមុទ្រដែនដី ឬក្នុងករណីដែលអាចកើតមាន កំពុងស្ថិតនៅក្នុងតំបន់តភ្ជាប់ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬខាងលើខ្ពង់រាបបាតសមុទ្រ។ ការដេញចាប់អាចចាប់ផ្តើមបាន បន្ទាប់ពីមានសញ្ញាដែលអាចមើលឃើញឬស្តាប់ឮឱ្យឈប់ ត្រូវបានផ្តល់ពីរយៈចំងាយដែលអាចមើលឃើញឬស្តាប់ឮដោយនាវាបរទេស។

៥. សិទ្ធិដេញប្រផាប់ចាប់ប្រកីង អាចត្រូវអនុវត្តបានតែដោយនាវាចម្បាំង ឬអាកាសយានយោធា ឬនាវាឬអាកាសយានផ្សេងទៀតដែលមានសញ្ញាសម្គាល់ និងអាចសម្គាល់បានច្បាស់លាស់ថាជានាវាឬអាកាសយានដែលបំពេញការងារផ្លូវការរបស់រដ្ឋ ហើយមានសិទ្ធិក្នុងការដេញចាប់នេះ។

៦. ក្នុងករណីដែលការដេញប្រផាប់ចាប់ប្រកីង ធ្វើឡើងដោយប្រើអាកាសយាន៖

(ក) បទប្បញ្ញត្តិនៃកថាខណ្ឌទី១ដល់កថាខណ្ឌទី៤ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ។

(ខ) អាកាសយានដែលចេញបញ្ជាឱ្យឈប់ ត្រូវសកម្មក្នុងការដេញចាប់នាវាដោយខ្លួនឯង រហូតដល់មាននាវាឬអាកាសយានផ្សេងទៀតរបស់រដ្ឋជាប់ឆ្នេរសមុទ្រទៅដល់ តាមរយៈការកោះហៅដោយអាកាសយាននោះ ដើម្បីធ្វើការដេញចាប់បន្ត វៀរលែងតែអាកាសយាននោះអាចចាប់នាវាបានដោយខ្លួនឯង។ មិនមានមូលហេតុគ្រប់គ្រាន់នោះទេ ដើម្បីជាមូលដ្ឋានក្នុងការចាប់នាវាដែលស្ថិតនៅក្រៅសមុទ្រដែនដី ក្នុងករណីដែលនាវានោះត្រូវបានមើលពីចម្ងាយ

ដោយអាកាសយាន ថាបានប្រព្រឹត្តបទល្មើសឬសង្ស័យថាបានប្រព្រឹត្តបទល្មើស ប្រសិនបើនាវានោះមិនបានទទួលការបញ្ជាឱ្យឈប់ឬដេញចាប់ដោយអាកាសយាននោះ ឬអាកាសយាន ឬនាវាផ្សេងទៀត ដែលបន្តការដេញចាប់ដោយគ្មានការបង្អាក់។

៧. ចំពោះនាវាដែលត្រូវបានចាប់នៅក្នុងយុត្តាធិការរបស់រដ្ឋមួយនិងដែលត្រូវបាននាំទៅកំពង់ផែនៃរដ្ឋនោះ ក្នុងគោលបំណងដើម្បីសាកសួរដោយអាជ្ញាធរមានសមត្ថកិច្ច មិនអាចទាមទារឱ្យមានការដោះលែងនោះទេ ដោយផ្អែកត្រឹមតែលើមូលហេតុដែលនាវានោះ ក្នុងពេលធ្វើដំណើរ ត្រូវបាននាំឆ្លងកាត់តាមតំបន់សេដ្ឋកិច្ចផ្ដាច់មុខ ឬលម្ហសមុទ្រអន្តរជាតិមួយផ្នែក ប្រសិនបើមានករណីចាំបាច់ដែលត្រូវធ្វើដូចនេះ។

៨. ក្នុងករណីដែលនាវាត្រូវបានបញ្ឈប់ ឬបានចាប់នៅក្រៅសមុទ្រដែនដីក្នុងកាលៈទេសៈដែលមិនមានមូលដ្ឋានក្នុងការអនុវត្តនូវសិទ្ធិដេញប្រដាប់ចាប់ប្រកីង នាវានោះត្រូវទទួលបានសំណងសម្រាប់ការខាតបង់ឬការខូចខាតដែលបានកើតឡើង។

## មាត្រា១១២
## សិទ្ធិក្នុងការដាក់ពង្រាយខ្សែកាបនិងបំពង់បង្ហូរនៅបាតសមុទ្រ

១. រដ្ឋទាំងអស់ មានសិទ្ធិដាក់ពង្រាយខ្សែកាបនិងបំពង់បង្ហូរនៅបាតសមុទ្រនៅបាតសមុទ្រ នៃលម្ហសមុទ្រអន្តរជាតិដែលស្ថិតនៅហួសពីខ្ពង់រាបបាតសមុទ្រ។

២. កថាខណ្ឌទី៥ នៃមាត្រា៧៩ ត្រូវអនុវត្តចំពោះខ្សែកាបនិងបំពង់បង្ហូរទាំងនេះ។

## មាត្រា១១៣
## ការបែកបាក់ ឬការខូចខាតខ្សែកាប ឬបំពង់បង្ហូរនៅបាតសមុទ្រ

រដ្ឋទាំងអស់ត្រូវអនុម័តច្បាប់និងបទបញ្ញាដែលចាំបាច់ក្នុងការកំណត់ថាការបែកបាក់ឬការខូចខាតខ្សែកាប នៅក្នុងសមុទ្រនៃលម្ហសមុទ្រអន្តរជាតិ ដែលបង្កឡើងដោយចេតនាឬការធ្វេសប្រហែសធ្ងន់ធ្ងរ ដោយនាវាដែលមានសញ្ជាតិរបស់ខ្លួនឬបុគ្គលដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន ក្នុងលក្ខណៈដែលនាំឱ្យមានការទទួលខុសត្រូវចំពោះការបង្អាក់ឬរារាំងដល់ប្រព័ន្ធទូរគមនាគមន៍តាមទូរលេខឬទូរស័ព្ទ និងចំពោះការបែកបាក់ឬការខូចខាតដល់បំពង់បង្ហូរនៅបាតសមុទ្រឬខ្សែកាបថាមពលតង់ស្យុងខ្ពស់នៅក្នុងសមុទ្រ ត្រូវចាត់ទុកជាបទល្មើស។ បទប្បញ្ញត្តិនេះត្រូវអនុវត្តចំពោះសកម្មភាពដែលប៉ុនប៉ង ឬដែលអាចនាំឱ្យមានបែកបាក់ឬការខូចខាតនោះ។ ទោះជាយ៉ាងណាក៏ដោយ បញ្ញត្តិនេះមិនត្រូវអនុវត្តចំពោះរាល់ការបែកបាក់ឬការខូចខាតបង្កឡើងដោយបុគ្គលដែលធ្វើសកម្មភាពក្នុងគោលបំណងស្របច្បាប់ដើម្បីសង្គ្រោះជីវិតឬនាវារបស់ខ្លួន ក្រោយពីបានចាត់វិធានការប្រុងប្រយ័ត្នចាំបាច់ដើម្បីជៀសវាងការបែកបាក់ឬការខូចខាតនេះ។

## មាត្រា១១៤
## ការបែកបាក់ឬខូចខាតបង្កឡើងដោយម្ចាស់ខ្សែកាបឬបំពង់បង្ហូរ នៅបាតសមុទ្រចំពោះខ្សែកាបឬបំពង់បង្ហូរនៅបាតសមុទ្ររបស់អ្នកដទៃ

រដ្ឋទាំងអស់ត្រូវអនុម័តច្បាប់និងបទបញ្ញាដែលចាំបាច់ក្នុងការកំណត់ថា ប្រសិនបើបុគ្គលដែល ស្ថិតក្រោមយុត្តាធិការរបស់ខ្លួនជាម្ចាស់ខ្សែកាបឬបំពង់បង្ហូរនៅបាតសមុទ្រនៃលម្ហសមុទ្រអន្តរជាតិ ក្នុងពេលពង្រាយឬជួសជុលខ្សែកាបឬបំពង់បង្ហូរនោះ បង្កឱ្យមានការបែកបាក់ឬការខូចខាតចំពោះខ្សែកាបឬបំពង់បង្ហូររបស់អ្នកដទៃ បុគ្គលនោះត្រូវទទួលបន្ទុកលើការចំណាយសម្រាប់ការជួសជុល។

## មាត្រា១១៥
## សំណងលើការខូចខាតដែលកើតមានក្នុងការបញ្ចៀសការខូចខាតដល់ខ្សែកាបឬបំពង់បង្ហូរនៅបាតសមុទ្រ

រដ្ឋទាំងអស់ត្រូវអនុម័តច្បាប់និងបទបញ្ញាដែលចាំបាច់ក្នុងការធានាថា ម្ចាស់នាវាដែលអាចផ្ដល់ភស្តុតាងបញ្ជាក់អំពីការលះបង់យុថ្កា សំណាញ់ ឬឧបករណ៍នេសាទផ្សេងទៀតដើម្បីបញ្ចៀសការខូចខាតដល់ខ្សែកាបឬបំពង់បង្ហូរនៅបាតសមុទ្រ ត្រូវទទួលបាននូវសំណងពីម្ចាស់ខ្សែកាបឬបំពង់បង្ហូរនៅបាតសមុទ្រនោះ ក្នុងលក្ខខណ្ឌដែលម្ចាស់នាវាបានចាត់វិធានការប្រុងប្រយ័ត្នសមស្របទាំងឡាយជាមុន។

# ផ្នែកទី២
# កិច្ចអភិរក្សនិងការគ្រប់គ្រងធនធានមានជីវិតនៅលម្ហសមុទ្រអន្តរជាតិ

## មាត្រា១១៦
## សិទ្ធិធ្វើនេសាទនៅលម្ហសមុទ្រអន្តរជាតិ

រដ្ឋទាំងអស់មានសិទ្ធិឱ្យពលរដ្ឋរបស់ខ្លួនធ្វើការនេសាទនៅលម្ហសមុទ្រអន្តរជាតិ ដោយត្រូវគោរពតាម៖

(ក) កាតព្វកិច្ចក្រោមសន្ធិសញ្ញារបស់ខ្លួន

(ខ) សិទ្ធិនិងករណីកិច្ច ព្រមទាំងអត្ថប្រយោជន៍នៃរដ្ឋជាប់ឆ្នេរសមុទ្រ ដូចមានចែងជាអាទិ៍ក្នុងកថាខណ្ឌទី២ នៃមាត្រា៦៣ និងមាត្រា៦៤ដល់មាត្រា៦៧ និង

(គ) បទប្បញ្ញត្តិនៃផ្នែកនេះ។

## មាត្រា១១៧
## ករណីកិច្ចរបស់រដ្ឋក្នុងការអនុម័តវិធានការចំពោះពលរដ្ឋរបស់ខ្លួនសម្រាប់ការអភិរក្សធនធានមានជីវិតនៅលម្ហសមុទ្រអន្តរជាតិ

រដ្ឋទាំងអស់មានករណីកិច្ចក្នុងការចាត់វិធានការឬធ្វើសហប្រតិបត្តិការជាមួយរដ្ឋដទៃក្នុងការអនុវត្តវិធានការលើពលរដ្ឋរបស់ខ្លួនតាមការចាំបាច់ក្នុងការអភិរក្សធនធានមានជីវិតនៅលម្ហសមុទ្រអន្តរជាតិ។

## មាត្រា១១៨
## កិច្ចសហប្រតិបត្តិការនៃបណ្ដារដ្ឋក្នុងការអភិរក្សនិងគ្រប់គ្រងធនធានមានជីវិត

បណ្ដារដ្ឋត្រូវធ្វើសហប្រតិបត្តិការជាមួយគ្នាក្នុងការអភិរក្សនិងគ្រប់គ្រងធនធានមានជីវិតនៅក្នុងតំបន់នៃលម្ហសមុទ្រអន្តរជាតិ។ រដ្ឋដែលមានប្រជាពលរដ្ឋខ្លួនធ្វើអាជីវកម្មលើធនធានមានជីវិតប្រភេទដូចគ្នា ឬធនធានមានជីវិតប្រភេទខុសគ្នានៅក្នុងតំបន់តែមួយ ត្រូវចូលរួមចរចា ដើម្បីចាត់វិធានការចាំបាច់លើការអភិរក្សធនធានមានជីវិតដែលពាក់ព័ន្ធ។ រដ្ឋទាំងនោះត្រូវធ្វើសហប្រតិបត្តិការជាមួយគ្នាដើម្បីបង្កើតអង្គការជលផលថ្នាក់អនុតំបន់ឬថ្នាក់តំបន់ តាមភាពសមស្រប។

## មាត្រា១១៩
## កិច្ចអភិរក្សធនធានមានជីវិតនៅលម្ហសមុទ្រអន្តរជាតិ

១. ក្នុងការកំណត់បរិមាណផលដែលអនុញ្ញាតឱ្យធ្វើការនេសាទនិងការបង្កើតវិធានការអភិរក្សធនធានមានជីវិតនៅលម្ហសមុទ្រអន្តរជាតិ រដ្ឋទាំងអស់ត្រូវ៖

(ក) ចាត់វិធានការដែលបានកំណត់ ផ្អែកលើភស្តុតាងវិទ្យាសាស្ត្រល្អបំផុតដែលមាន សម្រាប់រដ្ឋពាក់ព័ន្ធ ដើម្បីរក្សាឬស្តារផលស្តុកនៃប្រភេទត្រីដែលបាននេសាទ ក្នុងកម្រិតដែលផ្តល់នូវទិន្នផលនិរន្តរភាពអតិបរមាផ្អែកតាមកត្តាបរិស្ថាននិងសេដ្ឋកិច្ច រាប់បញ្ចូលទាំងលក្ខខណ្ឌពិសេសៗនៃបណ្តារដ្ឋដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងគិតគូរដល់វិធីសាស្ត្រនៃការនេសាទអន្តរនិស្សភាពនៃស្តុកត្រីនិងស្តង់ដារអន្តរជាតិអប្បបរិមាដែលជាអនុសាសន៍ទូទៅ ថ្នាក់អនុតំបន់ ថ្នាក់តំបន់ ឬសកល។

(ខ) ពិចារណាអំពីផលប៉ះពាល់ទៅលើប្រភេទត្រីពាក់ព័ន្ធឬពឹងអាស្រ័យលើប្រភេទត្រីដែលនេសាទ ក្នុងគោលបំណងថែរក្សាឬស្តារផលស្តុកនៃប្រភេទត្រីពាក់ព័ន្ធឬពឹងអាស្រ័យទាំងនោះឱ្យបានលើកម្រិតដែលការបន្តពូជរបស់វាអាចរងការគំរាមកំហែងធ្ងន់ធ្ងរ។

២. ព័ត៌មានវិទ្យាសាស្ត្រ ស្ថិតិផលនេសាទនិងកម្លាំងនេសាទ និងទិន្នន័យផ្សេងទៀតពាក់ព័ន្ធនឹងការអភិរក្សស្តុកត្រី ដែលមាន ត្រូវផ្តល់និងចែករំលែកយ៉ាងទៀងទាត់តាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ចទាំងថ្នាក់អនុតំបន់ ថ្នាក់តំបន់ ឬសកល តាមភាពសមស្រប និងដោយមានការចូលរួមពីបណ្តារដ្ឋពាក់ព័ន្ធ។

៣. បណ្តារដ្ឋពាក់ព័ន្ធត្រូវធានាថាវិធានការអភិរក្សនិងការអនុវត្តវិធានការរបស់ខ្លួនមិនមានការរើសអើងទាំងក្នុងទម្រង់ឬតាមព្រឹត្តិន័យប្រឆាំងទៅនឹងប្រជានេសាទនៃរដ្ឋណាមួយឡើយ។

### មាត្រា១២០

### ថនិកសត្វសមុទ្រ

មាត្រា ៦៥ ក៏ត្រូវអនុវត្តលើការអភិរក្សនិងការគ្រប់គ្រងថនិកសត្វសមុទ្រនៅលម្ហសមុទ្រអន្តរជាតិផងដែរ។

## ជំពូកទី៨

## របបកោះ

### មាត្រា១២១

### របបកោះ

១. កោះមានសណ្ឋានជាដីដុះបែបធម្មជាតិហ៊ុំព័ទ្ធទៅដោយទឹក និងស្ថិតលើទឹកជោរ។

២. លើកលែងតែមានចែងក្នុងកថាខណ្ឌទី៣ សមុទ្រដែនដី តំបន់ជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ខ្ពង់រាបបាតសមុទ្រនៃកោះមួយ ត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះដែលអនុវត្តចំពោះដែនដីគោកផ្សេងទៀត។

៣. ថ្មដែលមិនអាចឱ្យមនុស្សតាំងលំនៅឋានបានឬប្រកបជីវភាពសេដ្ឋកិច្ចបាន មិនមានតំបន់សេដ្ឋកិច្ចផ្តាច់មុខឬតំបន់ខ្ពង់រាបបាតសមុទ្រឡើយ។

## ជំពូកទី៩
## សមុទ្របិទឬពាក់កណ្តាលបិទ
### មាត្រា១២២
### និយមន័យ

សម្រាប់គោលបំណងនៃអនុសញ្ញានេះ "**សមុទ្របិទឬពាក់កណ្តាលបិទ**" សំដៅដល់ឈូងសមុទ្រ អាងទឹក ឬសមុទ្រព័ទ្ធជុំវិញដោយរដ្ឋពីរឬច្រើន និងតភ្ជាប់ទៅកាន់សមុទ្រផ្សេងទៀតឬមហាសមុទ្រ ដែលមានច្រកចេញតូចចង្អៀត ឬមានសមុទ្រដែនដីនិងតំបន់សេដ្ឋកិច្ចផ្តាច់មុខទាំងមូលឬមួយផ្នែកសំខាន់របស់រដ្ឋជាប់ឆ្នេរចំនួនពីរ ឬច្រើន។

### មាត្រា១២៣
### កិច្ចសហប្រតិបត្តិការរវាងបណ្តារដ្ឋដែលមានព្រំដែនជាប់សមុទ្របិទឬពាក់កណ្តាលបិទ

បណ្តារដ្ឋដែលមានព្រំដែនជាប់សមុទ្របិទឬពាក់កណ្តាលបិទគួរសហការជាមួយគ្នានៅក្នុងការបំពេញករណីយកិច្ចនិងក្នុងការអនុវត្តសិទ្ធិក្រោមអនុសញ្ញានេះ។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋទាំងនេះត្រូវប្រឹងប្រែងដោយផ្ទាល់ឬតាមរយៈអង្គការក្នុងតំបន់ដែលសមស្រប ដើម្បីៈ

(ក) សម្របសម្រួលនូវការគ្រប់គ្រង អភិរក្ស ការស្វែងរុករក និងការធ្វើអាជីវកម្មធនធានមានជីវិតនៅក្នុងសមុទ្រ។

(ខ) សម្របសម្រួលការអនុវត្តនូវសិទ្ធិនិងករណីយកិច្ចទាក់ទងនឹងការការពារនិងថែរក្សាបរិស្ថានសមុទ្រ។

(គ) សម្របសម្រួលគោលនយោបាយស្រាវជ្រាវវិទ្យាសាស្ត្រនិងរៀបចំកម្មវិធីស្រាវជ្រាវវិទ្យាសាស្ត្ររួមគ្នាក្នុងពេលសមស្រប។

(ឃ) អញ្ជើញបណ្តារដ្ឋឬអង្គការអន្តរជាតិផ្សេងទៀតដែលចាប់អារម្មណ៍ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយខ្លួនក្នុងការអនុវត្តបន្ថែមនូវមាត្រានេះ តាមការសមស្រប។

## ជំពូកទី១០
## សិទ្ធិរបស់រដ្ឋមិនជាប់សមុទ្រក្នុងការចេញ-ចូលសមុទ្រនិងសេរីភាពនៃការឆ្លងកាត់
### មាត្រា១២៤
### ការប្រើប្រាស់វាក្យសព្ទ

១. សម្រាប់គោលបំណងនៃអនុសញ្ញានេះៈ

(ក) "**រដ្ឋមិនជាប់សមុទ្រ**" សំដៅដល់ រដ្ឋដែលគ្មានឆ្នេរសមុទ្រ។

(ខ) "**រដ្ឋឆ្លងកាត់**" សំដៅដល់ រដ្ឋដែលមានឬគ្មានឆ្នេរសមុទ្រដែលស្ថិតនៅចន្លោះរដ្ឋមិនជាប់សមុទ្រនិងសមុទ្រ ដែលដែនដីរបស់ខ្លួនមានចរាចរណ៍ឆ្លងកាត់។

(គ) "**ចរាចរណ៍ឆ្លងកាត់**" សំដៅដល់ ការឆ្លងកាត់របស់មនុស្ស ឥវ៉ាន់ ទំនិញ និងមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ដែនដីនៃរដ្ឋឆ្លងកាត់មួយឬច្រើន នៅពេលដំណើរឆ្លងកាត់ដែនដីនោះ ដោយមានឬគ្មានការដឹកជញ្ជូនបន្ត ការស្តុកទំនិញ ការដឹកជញ្ជូនជាផ្នែក ឬការផ្លាស់ប្តូរមធ្យោបាយដឹកជញ្ជូន ដែលជាផ្នែកមួយប៉ុណ្ណោះនៃការធ្វើដំណើរទាំងមូលដែលចាប់ផ្តើមឬបញ្ចប់នៅក្នុងដែនដីនៃរដ្ឋមិនជាប់សមុទ្រ។

(ឃ) **"មធ្យោបាយដឹកជញ្ជូន"** សំដៅដល់៖

(i) យានរត់លើផ្លូវដែក យានធ្វើដំណើរតាមសមុទ្រ បឹង និងទន្លេ និងយានរត់លើផ្លូវ។

(ii) អ្នកលីសែងនិងសត្វដឹកជញ្ជូនតាមស្ថានភាពតំបន់តម្រូវ

២. រដ្ឋមិនជាប់សមុទ្រនិងរដ្ឋឆ្លងកាត់ តាមរយៈកិច្ចព្រមព្រៀង អាចរាប់បញ្ចូលបំពង់បង្ហូរប្រេង ឬឧស្ម័ន ថាជាមធ្យោបាយដឹកជញ្ជូន និងមធ្យោបាយដឹកជញ្ជូនដទៃទៀតក្រៅពីមធ្យោបាយដូចមានចែងនៅក្នុងកថាខណ្ឌទី១។

## មាត្រា១២៥

## សិទ្ធិក្នុងការចេញ-ចូលសមុទ្រនិងសេរីភាពនៃការឆ្លងកាត់

១. រដ្ឋមិនជាប់សមុទ្រមានសិទ្ធិចេញចូលសមុទ្រសម្រាប់គោលបំណងអនុវត្តសិទ្ធិចែងក្នុងអនុសញ្ញានេះ រាប់បញ្ចូលសិទ្ធិទាក់ទងនឹងសេរីភាពលើលម្ហសមុទ្រអន្តរជាតិ និងបេតិកភណ្ឌមនុស្សជាតិ។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋមិនជាប់សមុទ្រមានសេរីភាពឆ្លងកាត់តាមរយៈដែនដីរបស់រដ្ឋឆ្លងកាត់ តាមរយៈមធ្យោបាយដឹកជញ្ជូនទាំងអស់។

២. លក្ខខណ្ឌ និងបែបបទសម្រាប់ការអនុវត្តសេរីភាពឆ្លងកាត់ត្រូវមានការព្រមព្រៀងរវាងរដ្ឋមិនជាប់សមុទ្រនិងរដ្ឋឆ្លងកាត់ដែលពាក់ព័ន្ធ តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី អនុតំបន់ ឬតំបន់។

៣. នៅក្នុងការអនុវត្តអធិបតេយ្យភាពពេញលេញទៅលើដែនដីរបស់ខ្លួន រដ្ឋឆ្លងកាត់មានសិទ្ធិចាត់វិធានការចាំបាច់ទាំងអស់ក្នុងការធានាថា សិទ្ធិនិងបទបញ្ញត្តិនានាដូចមានចែងក្នុងជំពូកនេះសម្រាប់រដ្ឋមិនជាប់សមុទ្រ មិនត្រូវបំពានផលប្រយោជន៍ស្របច្បាប់របស់ខ្លួនឡើយ។

## មាត្រា១២៦

## ការមិនអនុវត្តនូវ «ឧបែង» ស្តីពីប្រទេសទទួលបានឋានៈអនុគ្រោះបំផុត

បទប្បញ្ញត្តិនៃអនុសញ្ញានេះ ព្រមទាំងកិច្ចព្រមព្រៀងពិសេសទាក់ទងនឹងការអនុវត្តសិទ្ធិចេញនិងចូលសមុទ្រ ដែលបង្កើតជាសិទ្ធិ និងបទបញ្ញត្តិផ្អែកតាមទីតាំងភូមិសាស្ត្រពិសេសនៃរដ្ឋមិនជាប់សមុទ្រ ត្រូវបានលើកលែងពីការអនុវត្តនូវឧបែងស្តីពីប្រទេសទទួលបានឋានៈអនុគ្រោះបំផុត។

## មាត្រា១២៧

## ពន្ធ អាករ និងបន្ទុកចំណាយផ្សេងៗ

១. ចរាចរណ៍ឆ្លងកាត់មិនត្រូវស្ថិតក្រោមបន្ទុកពន្ធគយ អាករ ឬបន្ទុកចំណាយដទៃទៀត លើកលែងតែបន្ទុកចំណាយលើសេវាកម្មពិសេសផ្តល់ជូនពាក់ព័ន្ធនឹងការធ្វើចរាចរណ៍នេះ។

២. មធ្យោបាយដឹកជញ្ជូនឆ្លងកាត់ និងបទបញ្ញត្តិដែលផ្តល់ជូននិងប្រើប្រាស់ដោយរដ្ឋមិនជាប់សមុទ្រ មិនត្រូវស្ថិតក្រោមពន្ធ អាករ ឬបន្ទុកចំណាយខ្ពស់ជាងបន្ទុកដែលដាក់លើការប្រើប្រាស់មធ្យោបាយដឹកជញ្ជូននៃរដ្ឋឆ្លងកាត់នោះទេ។

## មាត្រា១២៨
## តំបន់សេរី និងឋបនីយកណ្ឌផ្នែកគយដទៃទៀត

ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការធ្វើចរាចរណ៍ឆ្លងកាត់ តំបន់សេរីឬឋបនីយកណ្ឌផ្នែកគយដទៃទៀត អាចត្រូវបានផ្ដល់នៅច្រកកំពង់ផែចេញ-ចូលក្នុងរដ្ឋឆ្លងកាត់ តាមរយៈកិច្ចព្រមព្រៀងរវាងរដ្ឋទាំងនោះជាមួយរដ្ឋមិនជាប់សមុទ្រ។

## មាត្រា១២៩
## កិច្ចសហប្រតិបត្តិការក្នុងការសាងសង់ និងការធ្វើឱ្យប្រសើរឡើងនូវមធ្យោបាយដឹកជញ្ជូន

ក្នុងករណីមិនមានមធ្យោបាយដឹកជញ្ជូនក្នុងរដ្ឋឆ្លងកាត់ក្នុងការអនុវត្តសេរីភាពក្នុងការឆ្លងកាត់បាន ឬក្នុងករណីដែលមធ្យោបាយដែលមានស្រាប់រាប់បញ្ចូលឋបនកណ្ឌនិងបរិក្ខារកំពង់ផែពុំមានគ្រប់គ្រាន់ក្នុង រដ្ឋឆ្លងកាត់និងរដ្ឋមិនជាប់សមុទ្រពាក់ព័ន្ធ អាចសហការក្នុងការសាងសង់ឬធ្វើឱ្យប្រសើរឡើងនូវមធ្យោបាយដឹកជញ្ជូនទាំងនោះតាមរបៀបណាក៏បាន។

## មាត្រា១៣០
## វិធានការក្នុងការបញ្ចៀស ឬលុបបំបាត់ភាពយឺតយ៉ាវឬការលំបាកផ្សេងៗផ្នែកបច្ចេកទេសចរាចរណ៍ឆ្លងកាត់

១. រដ្ឋឆ្លងកាត់ ត្រូវចាត់វិធានការសមស្របទាំងអស់ក្នុងការបញ្ចៀសភាពយឺតយ៉ាវឬភាពលំបាកដទៃទៀតផ្នែកបច្ចេកទេសក្នុងចរាចរណ៍ឆ្លងកាត់។

២. ក្នុងករណីដែលមានការយឺតយ៉ាវឬឧបសគ្គនានាកើតមាន អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋឆ្លងកាត់និងរដ្ឋមិនជាប់សមុទ្រពាក់ព័ន្ធត្រូវសហការគ្នាឆ្ពោះទៅការលុបបំបាត់ឱ្យបានឆាប់រហ័ស។

## មាត្រា១៣១
## ប្រព្រឹត្តិកម្មដោយស្មើភាពនៅក្នុងកំពង់ផែសមុទ្រ

នាវាដែលលើកទង់ជាតិរបស់រដ្ឋមិនជាប់សមុទ្រ ត្រូវទទួលបានប្រព្រឹត្តិកម្មដោយស្មើភាពដូចប្រព្រឹត្តិកម្មដែលផ្ដល់ដល់នាវាបរទេសនៅក្នុងកំពង់ផែសមុទ្រ។

## មាត្រា១៣២
## ការផ្ដល់នូវឋបនីយកណ្ឌឆ្លងកាត់ដែលប្រសើរជាង

អនុសញ្ញានេះមិនបានតម្រូវឱ្យធ្វើការដកហូតនូវឋបនីយកណ្ឌឆ្លងកាត់ដែលប្រសើរជាងអ្វីដែលបានផ្ដល់ជូនក្រោមអនុសញ្ញានេះ និងដែលបានព្រមព្រៀងរវាងរដ្ឋភាគីនៃអនុសញ្ញានេះ ឬដែលផ្ដល់ដោយរដ្ឋភាគីណាមួយឡើយ។ អនុសញ្ញានេះមិនបានបដិសេធនូវការផ្ដល់ឋបនីយកណ្ឌប្រសើរជាងនាពេលអនាគតនោះទេ។

# ជំពូកទី១១
# តំបន់បាតសមុទ្រអន្តរជាតិ
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ
### មាត្រា១៣៣
### ការប្រើប្រាស់វាក្យសព្ទ

សម្រាប់គោលបំណងនៃជំពូកនេះ៖

(ក) "ធនធាន" សំដៅដល់ រាល់ធនធានរ៉ែជាអង្គធាតុរឹង រាវ ឬឧស្ម័ន ដែលស្ថិតក្នុងទីតាំងដើម នៅតំបន់បាតសមុទ្រអន្តរជាតិ ដែលស្ថិតនៅឬក្រោមបាតសមុទ្រ រួមមានដុំរ៉ែពហុលោហធាតុ។

(ខ) ធនធានដែលទាញយកពីតំបន់បាតសមុទ្រអន្តរជាតិ ត្រូវបានកំណត់ហៅថា "រ៉ែ"។

### មាត្រា១៣៤
### វិសាលភាពនៃជំពូកនេះ

១. ជំពូកនេះអនុវត្តលើតំបន់បាតសមុទ្រអន្តរជាតិ។

២. សកម្មភាពនានានៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃជំពូកនេះ។

៣. លក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការតម្កល់និងការផ្សព្វផ្សាយជាសាធារណៈនូវផែនទីសមុទ្រ ឬបញ្ជីនិយាមកាភូមិសាស្ត្រដែលបង្ហាញអំពីដែនកំណត់យោងក្នុងកថាខណ្ឌទី១(១) នៃមាត្រា ១ ត្រូវបានកំណត់ក្នុងជំពូកទី៦។

៤. គ្មានបទប្បញ្ញត្តិណាមួយនៃមាត្រានេះ នាំឱ្យប៉ះពាល់ដល់ការបង្កើតដែនកំណត់ខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រដោយអនុលោមតាមជំពូកទី៦ ឬសុពលភាពនៃកិច្ចព្រមព្រៀងនានាស្តីពីការកំណត់ព្រំដែនរវាងរដ្ឋដែលមានឆ្នេរនៅទល់មុខគ្នាឬនៅជាប់គ្នានោះទេ។

### មាត្រា១៣៥
### លក្ខន្តិកៈគតិយុត្តនៃផ្ទៃទឹកខាងលើនិងដែនអាកាស

ជំពូកនេះឬសិទ្ធិណាមួយដែលត្រូវបានផ្តល់ឱ្យអនុវត្តតាមជំពូកនេះ នឹងមិនប៉ះពាល់ដល់លក្ខន្តិកៈគតិយុត្តនៃផ្ទៃទឹកខាងលើតំបន់បាតសមុទ្រអន្តរជាតិ ឬដែនអាកាសដែលនៅលើផ្ទៃទឹកទាំងនោះឡើយ។

## ផ្នែកទី២
## គោលការណ៍គ្រប់គ្រងតំបន់បាតសមុទ្រអន្តរជាតិ
### មាត្រា១៣៦
### បេតិកភណ្ឌរួមរបស់មនុស្សជាតិ

តំបន់បាតសមុទ្រអន្តរជាតិនិងធនធានក្នុងតំបន់នេះ ជាបេតិកភណ្ឌរួមរបស់មនុស្សជាតិ។

## មាត្រា១៣៧
## លក្ខន្តិកៈគតិយុត្តនៃតំបន់បាតសមុទ្រអន្តរជាតិនិងធនធានក្នុងតំបន់នេះ

១. គ្មានរដ្ឋណាមួយអាចទាមទារឬអនុវត្តអធិបតេយ្យឬសិទ្ធិអធិបតេយ្យលើផ្នែកណាមួយនៃតំបន់បាតសមុទ្រអន្តរជាតិឬធនធានក្នុងតំបន់នេះ ហើយក៏គ្មានរដ្ឋ ឬរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយអាចកាន់កាប់ផ្នែកណាមួយបានឡើយ។ គ្មានការទាមទារ ឬការអនុវត្តអធិបតេយ្យ ឬសិទ្ធិអធិបតេយ្យ ឬការកាន់កាប់ណាមួយត្រូវបានទទួលស្គាល់នោះទេ។

២. សិទ្ធិទាំងអស់លើធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិ ត្រូវបានផ្តល់ជូនមនុស្សជាតិទាំងមូលដែលមានអាជ្ញាធរជាតំណាងដើម្បីអនុវត្ត។ ធនធានទាំងនេះមិនអាចជាកម្មវត្ថុនៃការផ្ទេរកម្មសិទ្ធិបានឡើយ។ ដោយឡែកធនធានដែលត្រូវបានទាញយកពីតំបន់បាតសមុទ្រអន្តរជាតិត្រូវផ្ទេរបានដោយអនុលោមតាមជំពូកនេះ និងវិធាន បទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរ។

៣. គ្មានរដ្ឋ ឬរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ទាមទារ ទទួលបាន ឬអនុវត្តសិទ្ធិពាក់ព័ន្ធនឹងរ៉ែ ដែលទាញយកបានពីតំបន់បាតសមុទ្រអន្តរជាតិបានឡើយ លើកលែងតែអនុលោមតាមបទប្បញ្ញត្តិនៃជំពូកនេះ។ បើមិនដូច្នេះទេ ការទាមទារ ការទទួលបាន ឬការអនុវត្តសិទ្ធិប្រភេទនេះនឹងមិនត្រូវបានទទួលស្គាល់ឡើយ។

## មាត្រា១៣៨
## ប្រតិបត្តិការទូទៅនៃបណ្តារដ្ឋនានាទាក់ទងនឹងតំបន់បាតសមុទ្រអន្តរជាតិ

ប្រតិបត្តិការទូទៅនៃបណ្តារដ្ឋនានាទាក់ទងនឹងតំបន់បាតសមុទ្រអន្តរជាតិ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃជំពូកនេះ គោលការណ៍ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងវិធានច្បាប់អន្តរជាតិដទៃទៀតដែលបម្រើដល់ប្រយោជន៍ក្នុងការរក្សាបាននូវសន្តិសុខនិងសន្តិភាព និងជំរុញឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិនិងការយោគយល់គ្នាទៅវិញទៅមក។

## មាត្រា១៣៩
## ការទទួលខុសត្រូវដើម្បីធានាអនុលោមភាពនិងការទទួលខុសត្រូវលើការខូចខាត

១. បណ្តារដ្ឋភាគី ត្រូវមានកាតព្វកិច្ចធានាថា សកម្មភាពនានានៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ មិនថាធ្វើឡើងដោយបណ្តារដ្ឋភាគី ឬសហគ្រាសរដ្ឋ ឬរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិនៃបណ្តារដ្ឋភាគីឬដែលត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដោយពួកគេ ឬពលរដ្ឋរបស់ខ្លួន ត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិនៃជំពូកនេះ។ ការទទួលខុសត្រូវដូចគ្នានេះ ក៏អនុវត្តលើអង្គការអន្តរជាតិដែលធ្វើសកម្មភាពនានានៅក្នុងតំបន់បាតសមុទ្រអន្តរជាតិនេះផងដែរ។

២. ដោយមិនប៉ះពាល់ដល់វិធាននៃច្បាប់អន្តរជាតិ និងមាត្រា ២២ នៃឧបសម្ព័ន្ធទី៣ ការខូចខាត ដែលបង្កឡើងដោយការខកខានរបស់រដ្ឋភាគីឬអង្គការអន្តរជាតិក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួន ក្រោមជំពូកនេះ តម្រូវឱ្យមានការទទួលខុសត្រូវលើការខូចខាត ហើយបណ្តារដ្ឋភាគីឬអង្គការអន្តរជាតិដែលធ្វើសកម្មភាពរួមគ្នាត្រូវទទួលខុសត្រូវដោយរួមគ្នាផងនិងដោយឡែកផង។ ប៉ុន្តែ រដ្ឋភាគីមិនត្រូវទទួលខុសត្រូវលើការខូចខាតដែលបង្កឡើងដោយការខកខានណាមួយក្នុងការបំពេញតាមជំពូកនេះ ដោយបុគ្គលណាមួយដែលទទួលបានការគាំទ្រឬធានាពីរដ្ឋភាគីក្រោមកថាខណ្ឌទី២(ខ) នៃមាត្រា១៥៣ ប្រសិនបើរដ្ឋភាគីនោះបានចាត់វិធានការចាំបាច់និងសមស្របទាំងអស់ដើម្បីធានាបាននូវការអនុវត្តដោយប្រសិទ្ធភាពក្រោមកថាខណ្ឌទី៤ នៃមាត្រា១៥៣ ព្រមទាំងកថាខណ្ឌទី៤ នៃមាត្រា៤ នៃឧបសម្ព័ន្ធទី៣។

៣. បណ្តារដ្ឋភាគីដែលជាសមាជិកអង្គការអន្តរជាតិ ត្រូវចាត់វិធានការសមស្របដើម្បីធានាការអនុវត្តមាត្រានេះ តាមប្រភេទនៃអង្គការនោះ។

## មាត្រា១៤០

## អត្ថប្រយោជន៍នៃមនុស្សជាតិ

១. បណ្តាសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិដូចមានចែងជាពិសេសក្នុងជំពូកនេះ ត្រូវធ្វើឡើងដើម្បីជាអត្ថប្រយោជន៍នៃមនុស្សជាតិទាំងមូល ដោយមិនគិតពីទីតាំងភូមិសាស្ត្ររបស់រដ្ឋថាជារដ្ឋជាប់ឆ្នេរសមុទ្រ ឬមិនជាប់សមុទ្រនោះឡើយ និងដោយពិចារណាជាពិសេសលើអត្ថប្រយោជន៍និងតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រជាជាតិដែលមិនទាន់ទទួលបានឯករាជ្យពេញលេញ ឬស្ថានភាពស្វយ័តផ្សេងទៀតដែលទទួលស្គាល់ដោយអង្គការសហប្រជាជាតិអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ១៥១៤ (១៥) និងសេចក្តីសម្រេចពាក់ព័ន្ធផ្សេងទៀតរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ។

២. អាជ្ញាធរត្រូវផ្តល់ចំណែកប្រកបដោយសមធម៌នូវអត្ថប្រយោជន៍ហិរញ្ញវត្ថុនិងសេដ្ឋកិច្ចផ្សេងទៀតដែលទទួលបានពីបណ្តាសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ តាមរយៈយន្តការសមស្របណាមួយដោយឈរលើមូលដ្ឋានមិនរើសអើងស្របតាមកថាខណ្ឌទី ២(ច)(i) នៃមាត្រា ១៦០។

## មាត្រា១៤១

## ការប្រើប្រាស់តំបន់បាតសមុទ្រអន្តរជាតិសម្រាប់តែគោលបំណងសន្តិភាព

តំបន់បាតសមុទ្រអន្តរជាតិ ត្រូវបើកសម្រាប់រដ្ឋទាំងអស់ មិនថាជារដ្ឋជាប់ឆ្នេរសមុទ្រឬរដ្ឋមិនជាប់សមុទ្រ ប្រើប្រាស់តំបន់បាតសមុទ្រអន្តរជាតិ សម្រាប់តែគោលបំណងសន្តិភាព ដោយគ្មានការរើសអើង និងពុំប៉ះពាល់ដល់បទប្បញ្ញត្តិផ្សេងទៀតនៃជំពូកនេះ។

## មាត្រា១៤២

## សិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់រដ្ឋជាប់ឆ្នេរសមុទ្រ

១. បណ្តាសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិដែលទាក់ទងនឹងជម្រកធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិដែលលាតសន្ធឹងចូលទៅយុត្តាធិការជាតិ ត្រូវអនុវត្តដោយពិចារណាដល់សិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់រដ្ឋជាប់ឆ្នេរសមុទ្រណាមួយដែលជម្រកធនធានលាតសន្ធឹងចូលក្នុងយុត្តាធិការនោះ។

២. ការពិគ្រោះយោបល់ រួមទាំងប្រព័ន្ធជូនដំណឹងជាមុន ត្រូវធ្វើឡើងជាប្រចាំជាមួយរដ្ឋដែលពាក់ព័ន្ធក្នុងគោលបំណងជៀសវាងការរំលោភបំពានលើសិទ្ធិនិងផលប្រយោជន៍ទាំងនេះ។ ក្នុងករណីដែលបណ្តាសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិអាចនាំទៅដល់ការធ្វើអាជីវកម្មធនធានលាតសន្ធឹងនៅក្នុងយុត្តាធិការជាតិ ត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋជាប់ឆ្នេរសមុទ្រដែលពាក់ព័ន្ធ។

៣. ជំពូកនេះឬសិទ្ធិណាមួយដែលត្រូវបានផ្តល់ឱ្យ ឬអនុវត្តទៅតាមជំពូកនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រក្នុងការចាត់វិធានការស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃជំពូកទី១២ ដែលចាំបាច់ដើម្បីបង្ការ កាត់បន្ថយ ឬលុបបំបាត់នូវគ្រោះថ្នាក់បន្ទាន់និងធ្ងន់ធ្ងរមកលើឆ្នេរសមុទ្រឬផលប្រយោជន៍ពាក់ព័ន្ធពីការបំពុល ឬការគំរាមកំហែង ឬព្រឹត្តិការណ៍ដែលបង្កគ្រោះថ្នាក់ផ្សេងទៀត បង្កឡើងពីឬដោយបណ្តាសកម្មភាពណាមួយនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

## មាត្រា១៤៣
## ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ

១. ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ត្រូវអនុវត្តសម្រាប់តែគោលបំណងសន្តិភាពនិងផលប្រយោជន៍របស់មនុស្សជាតិទាំងមូល អនុលោមតាមជំពូកទី១៣។

២. អាជ្ញាធរអាចអនុវត្តនូវការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រទាក់ទងនឹងតំបន់បាតសមុទ្រអន្តរជាតិ និងធនធានរបស់វា និងអាចចុះកិច្ចសន្យាសម្រាប់គោលបំណងនេះបាន។ អាជ្ញាធរត្រូវលើកកម្ពស់និងជម្រុញសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងត្រូវសម្របសម្រួល ព្រមទាំងផ្សព្វផ្សាយលទ្ធផលនៃការវិភាគនិងស្រាវជ្រាវដែលមាន។

៣. រដ្ឋភាគីអាចធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។ រដ្ឋភាគីត្រូវលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ តាមរយៈ៖

(ក) ការចូលរួមក្នុងកម្មវិធីអន្តរជាតិនិងការជំរុញកិច្ចសហប្រតិបត្តិការនៅក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដោយបុគ្គលិកមកពីបណ្តាប្រទេសផ្សេងៗនិងមកពី អាជ្ញាធរ។

(ខ) ការធានាថា កម្មវិធីត្រូវបានរៀបចំតាមរយៈអាជ្ញាធរឬអង្គការអន្តរជាតិដទៃទៀតដែលសមស្របសម្រាប់ផលប្រយោជន៍នៃប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសដែលមានការអភិវឌ្ឍតិចតួចផ្នែកបច្ចេកវិទ្យា ក្នុងគោលបំណងដើម្បី៖

(i) ពង្រឹងសមត្ថភាពស្រាវជ្រាវរបស់ពួកគេ។

(ii) បណ្តុះបណ្តាលបុគ្គលិកនៃរដ្ឋទាំងនោះនិងបុគ្គលិកអាជ្ញាធរ អំពីបច្ចេកទេសនិងការអនុវត្តការស្រាវជ្រាវ។

(iii) ធ្វើឱ្យប្រសើរឡើងនូវការងាររបស់បុគ្គលិកដែលមានគុណវុឌ្ឍិក្នុងវិស័យស្រាវជ្រាវនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

(គ) ផ្សព្វផ្សាយយ៉ាងមានប្រសិទ្ធភាពនូវលទ្ធផលវិភាគស្រាវជ្រាវដែលមានតាមរយៈអាជ្ញាធរឬបណ្តាញអន្តរជាតិផ្សេងៗទៀតដែលសមស្រប។

## មាត្រា១៤៤
## ការផ្ទេរបច្ចេកវិទ្យា

១. អាជ្ញាធរត្រូវចាត់វិធានការឱ្យបានសមស្របតាមអនុសញ្ញានេះ ដើម្បី៖

(ក) ទទួលបានបច្ចេកវិទ្យា និងចំណេះដឹងខាងវិទ្យាសាស្ត្រទាក់ទងនឹងសកម្មភាពនៅក្នុងតំបន់។ និង

(ខ) ជំរុញលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងខាងវិទ្យាសាស្ត្រទាំងនេះទៅដល់បណ្តារដ្ឋកំពុងអភិវឌ្ឍន៍ ដើម្បីជាប្រយោជន៍ដល់រដ្ឋទាំងអស់។

២. ដើម្បីសម្រេចនូវគោលបំណងនេះ អាជ្ញាធរ និងរដ្ឋភាគីទាំងអស់ត្រូវសហការគ្នាក្នុងការជំរុញលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រទាក់ទងនឹងសកម្មភាពនៅក្នុងតំបន់ ដើម្បីជាប្រយោជន៍ដល់សហគ្រាស និងរដ្ឋភាគីទាំងអស់។ ជាពិសេសត្រូវផ្តួចផ្តើម និងលើកកម្ពស់៖

(ក) កម្មវិធីផ្ទេរបច្ចេកវិទ្យាទៅដល់សហគ្រាស និងរដ្ឋកំពុងអភិវឌ្ឍន៍ពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់ មានជាអាទិ៍ការសម្របសម្រួលឱ្យសហគ្រាស និងរដ្ឋកំពុងអភិវឌ្ឍន៍ទទួលបានបច្ចេកវិទ្យាពាក់ព័ន្ធក្រោមលក្ខខណ្ឌសមស្រប និងប្រកបដោយយុត្តិធម៌។

(ខ) វិធានការសំដៅលើកកម្ពស់បច្ចេកវិទ្យារបស់សហគ្រាស និងបច្ចេកវិទ្យាក្នុងស្រុករបស់រដ្ឋកំពុងអភិវឌ្ឍន៍ឱ្យរីកចម្រើន ជាពិសេសតាមរយៈការផ្តល់ឱកាសជូនបុគ្គលិកពីសហគ្រាស និងពីរដ្ឋកំពុងអភិវឌ្ឍន៍ឱ្យទទួលបានការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យា និងវិទ្យាសាស្ត្រសមុទ្រ និងការចូលរួមក្នុងសកម្មភាពនៅក្នុងតំបន់បានយ៉ាងពេញលេញ។

## មាត្រា១៤៥

## ការការពារបរិស្ថានសមុទ្រ

ដោយអនុលោមតាមអនុសញ្ញានេះ វិធានការចាំបាច់ដែលពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិនឹងត្រូវចាត់ឡើង ដើម្បីធានានូវការការពារបរិស្ថានសមុទ្រពីផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់ដែលអាចនឹងកើតចេញពីសកម្មភាពទាំងនេះឱ្យមានប្រសិទ្ធភាព។ ដើម្បីសម្រេចនូវគោលបំណងនេះ អាជ្ញាធរត្រូវអនុម័តវិធានបទបញ្ញា និងនីតិវិធីសមស្រប រួមមានជាអាទិ៍៖

(ក) ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងលើការបំពុល និងគ្រោះថ្នាក់ផ្សេងៗ ចំពោះបរិស្ថានសមុទ្រ រាប់ទាំងឆ្នេរសមុទ្រ និងលើការប៉ះពាល់ដល់លំនឹងអេកូឡូស៊ីនៃបរិស្ថានសមុទ្រដោយយកចិត្តទុកដាក់ ជាពិសេសទៅលើតម្រូវការក្នុងការការពារពីផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់ ដែលកើតចេញពីសកម្មភាពដូចជា ការខួង ការបូម ការជីកកកាយ ការចាក់ចោលសំណល់ ការសាងសង់និងប្រតិបត្តិការ ឬការថែទាំបរិក្ខារបំពង់បង្ហូរ និងឧបករណ៍ផ្សេងទៀតដែលទាក់ទងនឹងសកម្មភាពទាំងនោះ។

(ខ) ការការពារ និងការអភិរក្សធនធានធម្មជាតិនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងការបង្ការភាពអន្តរាយដល់រុក្ខជាតិ និងសត្វនៅក្នុងបរិស្ថានសមុទ្រ។

## មាត្រា១៤៦

## ការការពារជីវិតមនុស្ស

វិធានការពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ត្រូវចាត់ឡើងជាចាំបាច់ ដើម្បីធានាការការពារជីវិតមនុស្សប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្រេចនូវគោលដៅនេះ អាជ្ញាធរត្រូវអនុម័តវិធានបទបញ្ញា និងនីតិវិធីសមស្របបន្ថែមលើច្បាប់អន្តរជាតិជាធរមាន ដូចមានចែងនៅក្នុងសន្ធិសញ្ញាពាក់ព័ន្ធ។

## មាត្រា១៤៧

## ការសម្របសម្រួលសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិនិងបរិស្ថានសមុទ្រ

១. សកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ត្រូវបានអនុវត្តឱ្យបានសមស្របចំពោះសកម្មភាពផ្សេងៗនៅក្នុងបរិស្ថានសមុទ្រ។

២. បរិក្ខារដែលប្រើប្រាស់សម្រាប់អនុវត្តសកម្មភាពនានានៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ត្រូវបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោមនេះ៖

(ក) បបនាការត្រូវសាងសង់ ដំឡើង និងរុះរើស្របតាមជំពូកនេះ និងដោយត្រូវអនុលោមតាមវិធាន បទបញ្ញា និងនីតិវិធីរបស់អាជ្ញាធរ។ ការសាងសង់ ការដំឡើង និងការរុះរើបបនាការត្រូវមានជូនដំណឹងជាផ្លូវការ ហើយត្រូវមានសញ្ញាសម្គាល់អចិន្ត្រៃយ៍បញ្ជាក់ពីវត្តមាននៃបបនាការនោះ។

(ខ) បបនាការមិនត្រូវបង្កើតឡើងនៅកន្លែងណាដែលប៉ះពាល់ដល់គន្លងផ្លូវសមុទ្រដែលទទួលស្គាល់មានសារៈសំខាន់ចំពោះនាវាចរណ៍អន្តរជាតិ ឬក្នុងតំបន់ដែលមានសកម្មភាពនេសាទមមាញឹក។

(គ) តំបន់សុវត្ថិភាពត្រូវបង្កើតឡើងនៅជុំវិញបបនាការ ដោយមានការដាក់សញ្ញាសម្គាល់សមស្រប ដើម្បីធានាសុវត្ថិភាពទាំងសម្រាប់នាវាចរណ៍ និងបបនាការ។ ការរៀបចំទីតាំងតំបន់សុវត្ថិភាព មិនត្រូវបង្កើតជាតំបន់ក្រវ៉ាត់ ដែលនាំឱ្យរាំងស្ទះដល់នាវាធ្វើដំណើរចេញចូលស្របច្បាប់ទៅកាន់ដែនសមុទ្រណាមួយ ឬដល់នាវាចរណ៍នៅតាមគន្លងផ្លូវសមុទ្រអន្តរជាតិឡើយ។

(ឃ) បបនាការត្រូវប្រើប្រាស់តែក្នុងបំណងសន្តិភាពប៉ុណ្ណោះ។

(ង) បបនាការមិនត្រូវចាត់ទុកជាកោះទេ។ បបនាការមិនមានសមុទ្រដែនដីផ្ទាល់ ហើយវត្តមានរបស់វាមិនត្រូវប៉ះពាល់ដល់ការកំណត់ព្រំដែននៃសមុទ្រដែនដី តំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬខ្ពង់រាបបាតសមុទ្រឡើយ។

៣. សកម្មភាពផ្សេងៗទៀតនៅក្នុងបរិស្ថានសមុទ្រ ត្រូវអនុវត្តឱ្យបានសមស្របទៅលើសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ។

## មាត្រា១៤៨

## ការចូលរួមរបស់រដ្ឋកំពុងអភិវឌ្ឍន៍នៅក្នុងសកម្មភាពក្នុងតំបន់បាតសមុទ្រអន្តរជាតិ

ត្រូវជំរុញឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីរដ្ឋកំពុងអភិវឌ្ឍន៍នៅក្នុងសកម្មភាពក្នុងតំបន់បាតសមុទ្រអន្តរជាតិ ដូចមានចែងនៅក្នុងជំពូកនេះ ដោយផ្អែកលើផលប្រយោជន៍និងតម្រូវការពិសេសរបស់រដ្ឋនោះ ហើយក្នុងករណីពិសេសត្រូវផ្អែកតាមតម្រូវការពិសេសរបស់រដ្ឋមិនជាប់សមុទ្រ និងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល ដើម្បីបញ្ចៀសឧបសគ្គដែលកើតចេញពីទីតាំងមិនអំណោយផលរបស់រដ្ឋនោះ រួមទាំងតំបន់នៅឆ្ងាយពីតំបន់បាតសមុទ្រអន្តរជាតិ និងការពិបាកក្នុងធ្វើដំណើរចេញ-ចូលតំបន់បាតសមុទ្រអន្តរជាតិនេះ។

## មាត្រា១៤៩

## បុរាណវត្ថុនិងវត្ថុប្រវត្តិសាស្ត្រ

រាល់វត្ថុមានលក្ខណៈជាបុរាណវត្ថុ និងវត្ថុប្រវត្តិសាស្ត្រដែលប្រទះឃើញនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ នឹងត្រូវអភិរក្ស ឬផ្ទេរសម្រាប់ជាផលប្រយោជន៍មនុស្សជាតិទាំងមូលដោយពិចារណាជាពិសេសទៅលើសិទ្ធិអាទិភាពរបស់រដ្ឋ ឬប្រទេសជាប្រភពកំណើត ឬរដ្ឋជាប្រភពវប្បធម៌ ឬរដ្ឋជាប្រភពប្រវត្តិសាស្ត្រ ឬបុរាណសាស្ត្រនៃវត្ថុទាំងនោះ។

## ផ្នែកទី៣
## ការអភិវឌ្ឍធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិ
### មាត្រា១៥០
### គោលនយោបាយទាក់ទងនឹងសកម្មភាពក្នុងតំបន់បាតសមុទ្រអន្តរជាតិ

សកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិដូចមានចែងនៅក្នុងជំពូកនេះ ត្រូវអនុវត្តក្នុងលក្ខណៈណាមួយដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកឱ្យបានល្អ និងការលូតលាស់ពាណិជ្ជកម្មអន្តរជាតិប្រកបដោយតុល្យភាព និងដើម្បីជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិវឌ្ឍជារួមរបស់ប្រទេសទាំងអស់ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ ដើម្បីធានា៖

(ក) ការអភិវឌ្ឍធនធាននៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

(ខ) ការគ្រប់គ្រងធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិឱ្យមានសណ្តាប់ធ្នាប់ សុវត្ថិភាព និងភាពសមស្រប រួមទាំងការអនុវត្តសកម្មភាពក្នុងតំបន់បាតសមុទ្រអន្តរជាតិប្រកបដោយប្រសិទ្ធភាព និងបញ្ចៀសនូវសំណល់ដែលមិនចាំបាច់ស្របតាមគោលការណ៍អភិរក្ស។

(គ) ការពង្រីកនូវឱកាសចូលរួមក្នុងសកម្មភាពស្របតាមមាត្រា១៤៤ និង មាត្រា១៤៨។

(ឃ) ការចូលរួមទទួលបានចំណូលតាមរយៈអាជ្ញាធរបាតសមុទ្រអន្តរជាតិ និងការផ្ទេរបច្ចេកវិទ្យាទៅឱ្យសហគ្រាស និងរដ្ឋកំពុងអភិវឌ្ឍន៍ ដូចមានចែងក្នុងអនុសញ្ញានេះ។

(ង) ការបង្កើនលទ្ធភាពធ្វើអាជីវកម្មរ៉ែ ដែលបានមកពីតំបន់បាតសមុទ្រអន្តរជាតិ ដោយផ្សារភ្ជាប់នឹងរ៉ែ ដែលបានមកពីប្រភពផ្សេងៗ ដើម្បីធានានូវការផ្គត់ផ្គង់ជូនអ្នកប្រើប្រាស់រ៉ែ។

(ច) ការជំរុញឱ្យមានតម្លៃសមរម្យ និងមានស្ថិរភាពសម្រាប់ផលិតករ និងយុត្តិធម៌សម្រាប់អ្នកប្រើប្រាស់រ៉ែ ដែលបានពីតំបន់បាតសមុទ្រអន្តរជាតិ និងពីប្រភពផ្សេងៗ និងជំរុញសមតុល្យយូរអង្វែងការផ្គត់ផ្គង់ និងតម្រូវការ។

(ឆ) ការជំរុញឱ្យរដ្ឋភាគីទាំងអស់ទទួលបានឱកាសចូលរួមនៅក្នុងការអភិវឌ្ឍធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងការបង្ការការអនុវត្តសកម្មភាពផ្តាច់មុខតែម្នាក់ឯងនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ដោយមិនគិតពីប្រព័ន្ធសង្គម និងសេដ្ឋកិច្ច ឬទីតាំងភូមិសាស្ត្រនៃរដ្ឋទាំងនោះឡើយ។

(ជ) ការការពារប្រទេសកំពុងអភិវឌ្ឍន៍ពីឥទ្ធិពលអវិជ្ជមានទៅលើសេដ្ឋកិច្ច ឬផលពីការនាំចេញរបស់ ពួកគេ ដោយសារតែការធ្លាក់ចុះនៃតម្លៃរ៉ែដែលរងផលប៉ះពាល់ ឬនៃបរិមាណនាំចេញរ៉ែ ក្នុងកម្រិតដែលការធ្លាក់ចុះនេះបណ្តាលមកពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ដូចមានចែងក្នុងមាត្រា១៥១។

(ឈ) ការអភិវឌ្ឍបេតិកភណ្ឌរួម សម្រាប់ផលប្រយោជន៍មនុស្សជាតិទាំងមូល។

(ញ) លក្ខខណ្ឌនៃការចូលទីផ្សារសម្រាប់ការនាំចេញរ៉ែដែលផលិតបានពីធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងសម្រាប់ការនាំចូលទំនិញដែលផលិតចេញពីរ៉ែទាំងនោះ មិនត្រូវមានភាពអនុគ្រោះច្រើនជាងភាពអនុគ្រោះខ្ពស់បំផុតសម្រាប់ការនាំចូលពីប្រភពផ្សេងៗទៀតឡើយ។

## មាត្រា១៥១
## គោលនយោបាយផលិតកម្ម

១. (ក) ដោយមិនប៉ះពាល់ដល់កម្មវត្ថុដូចមានចែងក្នុងមាត្រា១៥០ និងសម្រាប់គោលបំណងនៃការអនុវត្តកថាខណ្ឌរង(ជ) នៃមាត្រានោះ និងក្នុងនាមតំណាងតាមរយៈវេទិកាមានស្រាប់ ឬការរៀបចំថ្មី ឬកិច្ចព្រមព្រៀងណាមួយដែលសមស្រប ដែលក្នុងនោះ ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងផលិតករនិងអ្នកប្រើប្រាស់ដែលចូលរួមផង អាជ្ញាធរបាតសមុទ្រអន្តរជាតិ ត្រូវចាត់វិធានការចាំបាច់ដើម្បីជំរុញកំណើនប្រសិទ្ធភាព និងស្ថេរភាពនៃទីផ្សារសម្រាប់ទំនិញដែលផលិតពីរ៉ែដែលបានមកពីតំបន់បាតសមុទ្រអន្តរជាតិនៅក្នុងតម្លៃសមស្របសម្រាប់ផលិតករ និងយុត្តិធម៌សម្រាប់អ្នកប្រើប្រាស់។ រដ្ឋភាគីទាំងអស់ត្រូវសហការគ្នា ដើម្បីសម្រេចនូវគោលបំណងនេះ។

(ខ) អាជ្ញាធរបាតសមុទ្រអន្តរជាតិមានសិទ្ធិចូលរួមរាល់សន្និសីទស្តីពីទំនិញ ដែលទាក់ទងនឹងទំនិញទាំងនោះ ដោយមានការចូលរួមពីផលិតករ និងអ្នកប្រើប្រាស់។ អាជ្ញាធរបាតសមុទ្រអន្តរជាតិមានសិទ្ធិក្លាយជាភាគីនៃការរៀបចំ ឬការព្រមព្រៀងដែលកើតចេញពីសន្និសីទនោះ។ ការចូលរួមរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិនៅក្នុងអង្គការណាមួយដែលបានបង្កើតឡើង នៅក្នុងការរៀបចំ ឬការព្រមព្រៀងទាំងនោះ ត្រូវពាក់ព័ន្ធនឹងផលិតកម្មនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងស្របតាមវិធានដែលពាក់ព័ន្ធរបស់ស្ថាប័នទាំងនោះ។

(គ) អាជ្ញាធរបាតសមុទ្រអន្តរជាតិ ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមការរៀបចំ ឬការព្រមព្រៀងដូចមានចែងនៅក្នុងកថាខណ្ឌនេះ ក្នុងលក្ខណៈណាសមួយដែលធានានូវការអនុវត្ត ក្នុងទម្រង់ដូចគ្នា ដោយគ្មានការរើសអើង ពាក់ព័ន្ធនឹងរាល់ផលិតកម្មរ៉ែនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។ នៅក្នុងការអនុវត្តនេះ អាជ្ញាធរបាតសមុទ្រអន្តរជាតិ ត្រូវធ្វើសកម្មភាពឱ្យបានសមស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា ដែលមានស្រាប់ និងផែនការការងាររបស់សហគ្រាសដែលបានអនុម័ត។

២. (ក) នៅក្នុងអំឡុងពេលបណ្តោះអាសន្នដូចមានចែងនៅក្នុងកថាខណ្ឌទី៣ ផលិតកម្មសម្រាប់គោលបំណងពាណិជ្ជកម្ម មិនត្រូវអនុវត្តតាមផែនការការងារដែលត្រូវបានអនុម័តរួចនោះទេ លុះត្រាតែប្រតិបត្តិករបានដាក់ពាក្យស្នើសុំ និងទទួលបានការអនុញ្ញាតឱ្យផលិតពីអាជ្ញាធរបាតសមុទ្រអន្តរជាតិជាមុនសិន។ ការស្នើសុំ ឬការអនុញ្ញាតឱ្យធ្វើផលិតកម្មនេះ មិនត្រូវលើសពីរយៈពេលប្រាំឆ្នាំ នៅមុនពេលនៃការចាប់ផ្តើមការងារផលិតកម្មសម្រាប់គោលបំណងពាណិជ្ជកម្ម តាមផែនការការងារ លុះត្រាតែអាជ្ញាធរបាតសមុទ្រអន្តរជាតិកំណត់ពេលវេលាផ្សេងពីនេះ ដោយផ្អែកលើប្រភេទ និងពេលវេលានៃការអភិវឌ្ឍគម្រោង វិធាន បទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ។

(ខ) នៅក្នុងការដាក់ពាក្យសុំការអនុញ្ញាតផលិត ប្រតិបត្តិករត្រូវបញ្ជាក់ពីបរិមាណនីកែល ដែលរំពឹងថានឹងផលិតបានក្នុងមួយឆ្នាំៗ នៅក្រោមផែនការការងារដែលបានអនុម័ត។ ពាក្យសុំក៏ត្រូវបញ្ចូលនូវកាលវិភាគចំណាយរបស់ប្រតិបត្តិករ ក្រោយពេលទទួលបានការអនុញ្ញាត ដែលត្រូវបានគណនាយ៉ាងលម្អិត ដើម្បីអាចចាប់ផ្តើមការផលិតសម្រាប់គោលបំណងពាណិជ្ជកម្ម នៅកាលបរិច្ឆេទផែនការកំណត់។

(គ) សម្រាប់គោលបំណងនៃកថាខណ្ឌរង (ក) និង (ខ) អាជ្ញាធរបាតសមុទ្រអន្តរជាតិត្រូវបង្កើតលក្ខខណ្ឌប្រតិបត្តិការសមស្រប ស្របតាមឧបសម្ព័ន្ធទី៣ មាត្រា១៧។

(ឃ) អាជ្ញាធរបាតសមុទ្រអន្តរជាតិត្រូវផ្តល់ការអនុញ្ញាតលើការផលិតក្នុងកម្រិតផលិតកម្មដែលបានស្នើសុំ លើកលែងតែកម្រិតផលិតកម្មសរុបនៃកម្រិតផលិតកម្មនេះ និងកម្រិតផលិតកម្មដែលបានអនុញ្ញាតមុនៗ លើសពីបរិមាណអតិបរមានៃផលិតកម្មនីកែល ដែលផលិតបាននៅក្នុងឆ្នាំដែលផ្តល់ការអនុញ្ញាត ដូចដែលបានគណនាស្របតាមកថាខណ្ឌទី៤ នៅក្នុងអំឡុងឆ្នាំផែនការផលិត សម្រាប់រយៈពេលបណ្តោះអាសន្ន។

(ង) នៅពេលផ្តល់ការអនុញ្ញាត ការអនុញ្ញាតផលិតកម្ម និងពាក្យសុំដែលត្រូវបានអនុម័តនឹងក្លាយជាផ្នែកមួយនៃផែនការការងារដែលបានអនុម័ត។

(ច) ប្រសិនបើពាក្យសុំការអនុញ្ញាតផលិតកម្មរបស់ប្រតិបត្តិករត្រូវបានបដិសេធ ដោយអនុលោមតាមកថាខណ្ឌរង(ឃ)នោះ ប្រតិបត្តិករអាចដាក់ពាក្យសុំជាថ្មីម្តងទៀតទៅកាន់អាជ្ញាធរបាតសមុទ្រអន្តរជាតិ នៅពេលណាក៏បាន។

៣. រយៈពេលបណ្តោះអាសន្ន គឺជារយៈពេលប្រាំឆ្នាំមុនថ្ងៃទី១ ខែមករា នៃឆ្នាំដែលគម្រោង ផលិតកម្មដំបូង សម្រាប់គោលបំណងពាណិជ្ជកម្មចាប់ផ្តើមដំណើរការ តាមផែនការការងារដែលបានអនុម័ត។ ប្រសិនបើផលិតកម្ម សម្រាប់គោលបំណងពាណិជ្ជកម្មដំបូងត្រូវអូសបន្លាយហួសពីឆ្នាំផែនការដំបូង រយៈពេលចាប់ផ្តើមនៃរយៈពេលបណ្តោះអាសន្ន និងបរិមាណអតិបរមានៃផលិតកម្មដែលគណនារួច នឹងត្រូវកែសម្រួលទៅតាមនោះ។ រយៈពេលបណ្តោះអាសន្នអាចនឹងមានរយៈពេល ២៥ ឆ្នាំ ឬបន្តរហូតដល់ចប់សន្និសីទបូកសរុបការងារដូចមានចែងក្នុងមាត្រា១៥៥ ឬរហូតដល់ថ្ងៃដែលការរៀបចំ ឬការព្រមព្រៀងថ្មីដូចមានចែងនៅក្នុងកថាខណ្ឌទី១ ចូលជាធរមាន ដោយជ្រើសរើសយករយៈពេលណាមួយដែលឆាប់ជាងគេ។ អាជ្ញាធរបាតសមុទ្រអន្តរជាតិត្រូវបន្តមានអំណាច ដូចមានចែងក្នុងមាត្រានេះ សម្រាប់រយៈពេលបណ្តោះអាសន្នដែលនៅសល់ ប្រសិនបើការរៀបចំ ឬការព្រមព្រៀងទាំងនោះអស់សុពលភាព ឬគ្មានប្រសិទ្ធភាព ទោះដោយសារហេតុផលណាក៏ដោយ។

៤. (ក) បរិមាណផលិតអតិបរមានៃឆ្នាំនីមួយៗនៅក្នុងរយៈពេលបណ្តោះអាសន្ន គឺជាបរិមាណនៃ៖

(i) លំអៀងរវាងតម្លៃតាមខ្សែបន្ទាត់និន្នាការនៃការប្រើប្រាស់នីកែល ដូចដែលបានគណនាតាមកថាខណ្ឌរង(ខ) នៅក្នុងឆ្នាំ មុនឆ្នាំផលិតកម្មសម្រាប់គោលបំណងពាណិជ្ជកម្មដំបូង និងនៅក្នុងឆ្នាំ មុនការចាប់ផ្តើមរយៈពេលបណ្តោះអាសន្ន និង

(ii) ហុកសិបភាគរយនៃលំអៀងរវាងតម្លៃតាមខ្សែបន្ទាត់និន្នាការនៃការប្រើប្រាស់នីកែល ដូចដែលបានគណនាតាមកថាខណ្ឌរង(ខ) នៅក្នុងឆ្នាំស្នើសុំការអនុញ្ញាតផលិតកម្ម និងនៅក្នុងឆ្នាំ មុនឆ្នាំផលិតកម្មសម្រាប់គោលបំណងពាណិជ្ជកម្មដំបូង។

(ខ) សម្រាប់គោលបំណងនៃកថាខណ្ឌរង(ក) ខាងលើ៖

(i) តម្លៃតាមខ្សែបន្ទាត់និន្នាការ សម្រាប់គណនាបរិមាណអតិបរមានីកែលដែលផលិតបាន គឺជាតម្លៃប្រើប្រាស់នីកែលប្រចាំឆ្នាំ ផ្អែកតាមខ្សែបន្ទាត់និន្នាការដែលបានគណនា នៅក្នុងអំឡុងឆ្នាំដែលទទួលការអនុញ្ញាតឱ្យផលិត។ ខ្សែបន្ទាត់និន្នាការ គឺជាលទ្ធផលនៃលំដាប់ថយចុះរបស់លីនេអ៊ែរឡូការីត នៃការប្រើប្រាស់នីកែលជាក់ស្តែងនៅក្នុងរយៈពេល១៥ឆ្នាំចុងក្រោយដែលមានទិន្នន័យពេលវេលាជាអថេរឯករាជ្យ។ ខ្សែបន្ទាត់និន្នាការនេះ ហៅថាខ្សែបន្ទាត់និន្នាការដើម។

(ii) ប្រសិនបើអត្រាកើនឡើងប្រចាំឆ្នាំនៃខ្សែបន្ទាត់និន្នាការដើមតិចជាង៣ ភាគរយ នោះខ្សែបន្ទាត់និន្នាការដែលយកមកកំណត់បរិមាណដែលកំណត់នៅក្នុងកថាខណ្ឌរង(ក) ត្រូវជំនួយដោយខ្សែបន្ទាត់ដែលកាត់តាមខ្សែបន្ទាត់និន្នាការដើមនៅត្រង់តម្លៃក្នុងឆ្នាំទី១ នៃរយៈពេល១៥ឆ្នាំ ដែលពាក់ព័ន្ធ ហើយដែលកើនឡើងចំនួន៣ ភាគរយក្នុងមួយឆ្នាំៗ ក្នុងលក្ខខណ្ឌដែលពិដានផលិតកម្មដែលបង្កើតឡើងសម្រាប់ឆ្នាំណាមួយ នៅក្នុងអំឡុងពេលបណ្តោះអាសន្ន មិនត្រូវលើសពីលំអៀងរវាងតម្លៃតាមខ្សែបន្ទាត់និន្នាការដើមក្នុងឆ្នាំនោះ និងតម្លៃតាមខ្សែបន្ទាត់និន្នាការដើមសម្រាប់ឆ្នាំនៅមុនពេលចាប់ផ្តើមរយៈពេលបណ្តោះអាសន្ន។

៥. សម្រាប់ផលិតកម្មដំបូងរបស់ខ្លួន អាជ្ញាធរបាតសមុទ្រអន្តរជាតិ ត្រូវបម្រុងទុកជូនសហគ្រាសនូវបរិមាណនីកែល ៣៨.០០០តោនពីបរិមាណផលិតកម្មអតិបរមាដែលមាន និងបានគណនាតាមកថាខណ្ឌទី៤។

៦. (ក) នៅក្នុងឆ្នាំនីមួយៗ ប្រតិបត្តិករអាចផលិតតិច ឬច្រើនជាងរហូតដល់៨ ភាគរយ ពីកម្រិតផលិតកម្មប្រែប្រចាំឆ្នាំ ចេញពីដុំប៉ូលីមេតាលិក ដែលបានកំណត់នៅក្នុងលិខិតអនុញ្ញាតផលិតកម្មរបស់ខ្លួន ក្នុងលក្ខខណ្ឌដែលបរិមាណសរុបនៃផលិតកម្មនោះ មិនលើសពីបរិមាណដែលបានកំណត់នៅក្នុងលិខិតអនុញ្ញាត។ ក្នុងករណីផលិតលើសពី៨ ភាគរយ រហូតដល់២០ភាគរយនៅក្នុងឆ្នាំណាមួយ ឬផលិតលើសនៅក្នុងឆ្នាំទី១ និងឆ្នាំបន្តបន្ទាប់ក្រោយពីបានផលិតលើសរយៈពេលពីរឆ្នាំជាប់គ្នា ប្រតិបត្តិករត្រូវចរចា ជាមួយអាជ្ញាធរបាតសមុទ្រអន្តរជាតិ ដែលអាចនឹងទាមទារឱ្យប្រតិបត្តិករស្នើសុំការអនុញ្ញាតផលិតបន្ថែមសម្រាប់ការផលិតលើសនោះ។

(ខ) អាជ្ញាធរបាតសមុទ្រអន្តរជាតិអាចពិចារណាលើពាក្យសុំការអនុញ្ញាតផលិតបន្ថែមបាន តែនៅក្រោយពេលដែលពាក្យសុំមិនទាន់សម្រេចទាំងអស់របស់ប្រតិបត្តិករ ដែលពុំទាន់ទទួលបានការអនុញ្ញាតឱ្យផលិតនៅឡើយ ត្រូវបានពិនិត្យពិចារណាផ្តល់លទ្ធភាពទៅអ្នកដាក់ពាក្យស្នើសុំដែលសមស្រប។ អាជ្ញាធរបាតសមុទ្រអន្តរជាតិត្រូវគោរពតាមគោលការណ៍ដែលលើសពីផលិតកម្មសរុប ដែលបានអនុញ្ញាតនៅក្រោមបរិមាណផលិតកម្មអតិបរមា នៅក្នុងឆ្នាំណាមួយនៃរយៈពេលបណ្តោះអាសន្ន។ អាជ្ញាធរបាតសមុទ្រអន្តរជាតិមិនត្រូវអនុញ្ញាតឱ្យផលិតកម្ម នៅក្រោមផែនការការងារណាមួយដែលមានបរិមាណផលិតនីកែលលើសពី៤៦.៥០០តោនក្នុងមួយឆ្នាំទេ។

៧. កម្រិតផលិតកម្មលោហៈផ្សេងៗ រួមមាន ទង់ដែង កូបាល់ និងម៉ង់កាណែស ដែលផលិតចេញពីបណ្តុំប៉ូលីមេតាលិកក្រោមការអនុញ្ញាតផលិតកម្ម មិនត្រូវលើសពីកម្រិតផលិតកម្មដែលប្រតិបត្តិករបានផលិតនីកែលក្នុងកម្រិតអតិបរមាពីបណ្តុំប៉ូលីមេតាលិក ស្របតាមមាត្រានេះ។ អាជ្ញាធរបាតសមុទ្រអន្តរជាតិត្រូវបង្កើតវិធាន បទបញ្ជា និងនីតិវិធី ស្របតាមឧបសម្ព័ន្ធទី៣ មាត្រា១៧ ក្នុងការអនុវត្តបទប្បញ្ញត្តិនៃកថាខណ្ឌនេះ។

៨. សិទ្ធិ និងកាតព្វកិច្ច ដែលទាក់ទងនឹងការអនុវត្តសេដ្ឋកិច្ចដោយគ្មានភាពយុត្តិធម៌ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីពាក់ព័ន្ធ ត្រូវអនុវត្តលើការរុករក និងការធ្វើអាជីវកម្មរ៉ែពីតំបន់បាតសមុទ្រអន្តរជាតិ។ នៅក្នុងការដោះស្រាយវិវាទដែលកើតចេញពីបទប្បញ្ញត្តិនេះ រដ្ឋភាគីដែលជាភាគីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី ត្រូវប្រើប្រាស់នីតិវិធីដោះស្រាយវិវាទ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងទាំងនោះ។

៩. អាជ្ញាធរបាតសមុទ្រអន្តរជាតិមានអំណាចកំណត់កម្រិតនៃការផលិតរ៉ែពីតំបន់បាតសមុទ្រអន្តរជាតិ លើកលែងតែរ៉ែដែលផលិតចេញពីបណ្តុំប៉ូលីមេតាលិក នៅក្រោមលក្ខខណ្ឌទាំងនេះ និងដោយអនុវត្តវិធីសាស្ត្រសមស្រប តាមរយៈការអនុវត្តបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៦១ កថាខណ្ឌទី៨ ។

១០. ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សាផ្អែកលើការផ្តល់យោបល់ពីគណៈកម្មការផែនការសេដ្ឋកិច្ច សន្និបាតត្រូវបង្កើតប្រព័ន្ធទូទាត់សំណង ឬចាត់វិធានផ្តល់ជំនួយសម្របសម្រួលផ្នែកសេដ្ឋកិច្ចផ្សេងៗ រួមទាំងកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារឯកទេស ឬអង្គការអន្តរជាតិផ្សេងៗ ដើម្បីជួយប្រទេសកំពុងអភិវឌ្ឍន៍ដែលរងគ្រោះពីឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរទៅលើផលពីការនាំចេញ ឬសេដ្ឋកិច្ចរបស់ពួកគេ ដែលបណ្តាលមកពីការធ្លាក់ចុះនៃតម្លៃរ៉ែដែលរងផលប៉ះពាល់ ឬការធ្លាក់ចុះនៃបរិមាណនាំចេញរ៉ែ ក្នុងកម្រិតដែលការធ្លាក់ចុះបណ្តាលមកពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។ នៅពេលមានការស្នើសុំ អាជ្ញាធរបាតសមុទ្រអន្តរជាតិត្រូវផ្តួចផ្តើមធ្វើការសិក្សាអំពីបញ្ហារបស់រដ្ឋទាំងនោះ ដែលអាចនឹងរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុត ដើម្បីកាត់បន្ថយផលលំបាករបស់ពួកគេឱ្យនៅកម្រិតអប្បបរមានិងជួយសម្របសម្រួលដល់បញ្ហាសេដ្ឋកិច្ចនៃរដ្ឋនោះ។

## មាត្រា១៥២

## ការអនុវត្តអំណាចនិងមុខងាររបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

១. អាជ្ញាធរត្រូវអនុវត្តអំណាច និងមុខងាររបស់ខ្លួនដោយគ្មានការរើសអើង រួមទាំងការផ្តល់ឱកាសអនុវត្តសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

២. ទោះជាយ៉ាងណាក្តី ការពិចារណាជាលក្ខណៈពិសេសសម្រាប់រដ្ឋកំពុងអភិវឌ្ឍន៍ រួមទាំងការពិចារណាជាលក្ខណៈពិសេសសម្រាប់រដ្ឋមិនជាប់សមុទ្រ ឬរដ្ឋមានទីតាំងភូមិសាស្ត្រមិនអំណោយផល ដូចមានចែងនៅក្នុងជំពូកនេះ នឹងត្រូវបានអនុញ្ញាត។

## មាត្រា១៥៣

## ប្រព័ន្ធរុករកនិងធ្វើអាជីវកម្ម

១. សកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ នឹងត្រូវរៀបចំ អនុវត្ត និងគ្រប់គ្រងដោយអាជ្ញាធរក្នុងនាមមនុស្សជាតិទាំងមូល ស្របតាមមាត្រានេះ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗនៅក្នុងជំពូកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធនឹងវិធាន បទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរ។

២. សកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិត្រូវអនុវត្ត ដូចមានចែងនៅក្នុងកថាខណ្ឌទី៣៖

(ក) ដោយសហគ្រាស និង

(ខ) ដោយរដ្ឋភាគី ឬសហគ្រាសរបស់រដ្ឋ ឬរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិ របស់រដ្ឋភាគី ឬដែលត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពដោយរដ្ឋភាគី ឬពលរដ្ឋរបស់រដ្ឋភាគី នៅពេលដែលទទួលបានការឧបត្ថម្ភពីរដ្ឋ ឬក្រុមខាងលើណាមួយដែលបំពេញបានតាមលក្ខខណ្ឌតម្រូវ ដូចមានចែងនៅក្នុងជំពូកនេះ និងឧបសម្ព័ន្ធទី៣ ក្រោមកិច្ចសហការជាមួយអាជ្ញាធរ។

៣. សកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិត្រូវអនុវត្ត ស្របតាមផែនការការងារផ្លូវការជាលាយលក្ខណ៍អក្សរ ដែលត្រូវបានរៀបចំឡើងស្របតាមឧបសម្ព័ន្ធទី៣ និងអនុម័តដោយក្រុមប្រឹក្សា ក្រោយពីគណៈកម្មការនីតិកម្ម និងបច្ចេកទេសបានពិនិត្យរួច។ ក្នុងករណីដែលសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិត្រូវបានអនុវត្ត ដោយអង្គភាពដូចមានចែងនៅក្នុងកថាខណ្ឌទី២ (ខ) ក្រោមការអនុញ្ញាតដោយអាជ្ញាធរ នោះ ផែនការការងារត្រូវមានទម្រង់ជាកិច្ចសន្យា ស្របតាមឧបសម្ព័ន្ធទី៣ មាត្រា៣។ កិច្ចសន្យាទាំងនេះចែងអំពីការរៀបចំរួមគ្នា ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៣ មាត្រា១១។

៤. អាជ្ញាធរត្រូវគ្រប់គ្រងលើសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិតាមការចាំបាច់ ដើម្បីធានានូវការគោរពតាម បទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុងជំពូកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធ និងវិធាន បទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរ និងផែនការការងារដែលត្រូវបានអនុម័ត ស្របតាមកថាខណ្ឌទី៣។ បណ្តារដ្ឋភាគីត្រូវជួយអាជ្ញាធរដោយចាត់រាល់វិធានការដែលចាំបាច់ ដើម្បីធានាការគោរពតាមមាត្រា១៣៩ ។

៥. អាជ្ញាធរមានសិទ្ធិចាត់វិធានការ ដូចមានចែងនៅក្នុងផ្នែកនេះបានគ្រប់ពេលវេលា ដើម្បីធានានូវការគោរពតាមបទប្បញ្ញត្តិនៅក្នុងជំពូកនេះ និងការអនុវត្តមុខងារគ្រប់គ្រង និងនិយតកម្មដែលខ្លួនបានទទួលក្រោមផ្នែកនេះ ឬនៅក្រោមកិច្ចសន្យា។ អាជ្ញាធរមានសិទ្ធិត្រួតពិនិត្យលើរាល់បរិក្ខារនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ដែលត្រូវបានប្រើប្រាស់ពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

៦. កិច្ចសន្យាដូចមានចែងនៅក្នុងកថាខណ្ឌទី៣ ត្រូវចែងអំពីសន្តិសុខនៃភាពជាម្ចាស់កម្មសិទ្ធិផងដែរ។ ហេតុដូច្នេះ កិច្ចសន្យានេះមិនអាចធ្វើការកែសម្រួល ព្យួរ ឬបញ្ចប់បានឡើយ លើកលែងតែធ្វើឡើងស្របតាមឧបសម្ព័ន្ធទី៣ មាត្រា១៨ និង មាត្រា១៩ ប៉ុណ្ណោះ។

## មាត្រា១៥៤
## ការត្រួតពិនិត្យជាប្រចាំ

រៀងរាល់ប្រាំឆ្នាំម្តងគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ សន្និបាតត្រូវរៀបចំធ្វើការត្រួតពិនិត្យជាទូទៅ និងជាប្រព័ន្ធតាមរបៀបមួយ ដែលក្នុងនោះ របបអន្តរជាតិនៃតំបន់បាតសមុទ្រអន្តរជាតិដែលបានបង្កើតឡើងក្រោមអនុសញ្ញានេះ ត្រូវបានអនុវត្ត។ ដោយផ្អែកលើការត្រួតពិនិត្យនេះ សន្និបាតអាចចាត់វិធានការ ឬស្នើឱ្យស្ថាប័នដទៃទៀតចាត់វិធានការ ស្របតាមបទប្បញ្ញត្តិ និងនីតិវិធីនៃជំពូកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធ សំដៅធ្វើឱ្យប្រសើរឡើងនូវការអនុវត្តរបបអន្តរជាតិនេះ។

## មាត្រា១៥៥
## សន្និសីទត្រួតពិនិត្យឡើងវិញ

១. រយៈពេលដប់ប្រាំឆ្នាំគិតចាប់ពីថ្ងៃទី១ខែមករានៃឆ្នាំដែលផលិតកម្មសម្រាប់គោលបំណងពាណិជ្ជកម្មដំបូងចាប់ផ្តើមអនុវត្តនៅក្រោមផែនការការងារដែលត្រូវបានអនុម័ត សន្និបាតត្រូវកោះប្រជុំសន្និសីទ ដើម្បីត្រួតពិនិត្យបទប្បញ្ញត្តិនៃជំពូកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងប្រព័ន្ធនៃការរុករក និងការធ្វើអាជីវកម្មធនធាននៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។ សន្និសីទនេះត្រូវពិចារណាលម្អិត ដោយផ្អែកលើបទពិសោធ ដែលទទួលបាននៅក្នុងអំឡុងពេលនោះ ដើម្បីកំណត់ដូចខាងក្រោម៖

(ក) តើបទប្បញ្ញត្តិនៃជំពូកនេះដែលគ្រប់គ្រងប្រព័ន្ធនៃការរុករក និងការធ្វើអាជីវកម្មធនធាននៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ សម្រេចបានតាមគោលបំណងនៅគ្រប់ទិដ្ឋភាព រួមទាំងថាតើការរុករក និងការធ្វើអាជីវកម្មនេះបានផ្តល់ផលប្រយោជន៍ដល់មនុស្សជាតិទាំងមូលដែរឬយ៉ាងណា។

(ខ) តើនៅក្នុងអំឡុងពេល១៥ឆ្នាំ តំបន់បម្រុងទុកត្រូវបានធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងតុល្យភាពដែរឬយ៉ាងណា បើប្រៀបធៀបទៅនឹងតំបន់មិនបម្រុងទុក។

(គ) តើការអភិវឌ្ឍ និងការប្រើប្រាស់តំបន់បាតសមុទ្រអន្តរជាតិ និងធនធានក្នុងតំបន់នេះ ត្រូវបានធ្វើឡើង តាមលក្ខណៈដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកឱ្យបានល្អ និងកំណើននៃពាណិជ្ជកម្មអន្តរជាតិប្រកបដោយតុល្យភាពដែរឬយ៉ាងណា។

(ឃ) តើការអនុវត្តសកម្មភាពផ្តាច់មុខនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិត្រូវបានបង្ការកុំឱ្យកើតមានឡើងដែរឬយ៉ាងណា។

(ង) តើគោលនយោបាយដូចមានចែងក្នុងមាត្រា១៥០ និងមាត្រា១៥១ ត្រូវបានបំពេញដែរ ឬយ៉ាងណា និង

(ច) តើប្រព័ន្ធនោះផ្តល់ការបែងចែកផលប្រយោជន៍បានមកពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិប្រកបដោយស្មើភាព ជាពិសេសទៅលើអត្ថប្រយោជន៍និងតម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍន៍ដែរឬយ៉ាងណា។

២. សន្និសីទនេះត្រូវធានារក្សាឱ្យបាននូវគោលការណ៍កេរ្តិ៍តំណែលរួមរបស់មនុស្សលោក របបអន្តរជាតិដែលបង្កើតឡើង ដើម្បីធានានូវការធ្វើអាជីវកម្មធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិប្រកបដោយស្មើភាពសម្រាប់បម្រើផលប្រយោជន៍របស់ប្រទេសទាំងអស់ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ និងអាជ្ញាធរ ដើម្បីរៀបចំអនុវត្ត និងគ្រប់គ្រងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។ សន្និសីទនេះក៏ធានារក្សាឱ្យបាននូវគោលការណ៍ដូចមានចែងនៅក្នុងជំពូកនេះ ទាក់ទងនឹងការមិនអនុញ្ញាតឱ្យទាមទារ ឬអនុវត្តអធិបតេយ្យលើផ្នែកណាមួយនៃតំបន់បាតសមុទ្រអន្តរជាតិ សិទ្ធិរបស់រដ្ឋនិងការអនុវត្តជាទូទៅទាក់ទងនឹងតំបន់បាតសមុទ្រអន្តរជាតិ និងការចូលរួមរបស់បណ្តារដ្ឋនៅក្នុងសកម្មភាពក្នុងតំបន់បាតសមុទ្រអន្តរជាតិស្របតាមអនុសញ្ញានេះ ការបង្ការការអនុវត្តសកម្មភាពផ្តាច់មុខនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ការប្រើប្រាស់តំបន់បាតសមុទ្រអន្តរជាតិដោយផ្តាច់មុខក្នុងគោលបំណងសន្តិភាព ទិដ្ឋភាពសេដ្ឋកិច្ចនៃសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ការផ្ទេរបច្ចេកវិទ្យា ការការពារបរិស្ថានសមុទ្រ ការការពារជីវិតមនុស្ស សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រ លក្ខន្តិកៈគតិយុត្តក្នុងដែនសមុទ្រក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងលំហអាកាសលើដែនសមុទ្រនោះ និងការសម្របសម្រួលរវាងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងសកម្មភាពផ្សេងៗទៀតនៅក្នុងបរិស្ថានសមុទ្រ។

៣. នីតិវិធីធ្វើសេចក្តីសម្រេចចិត្តដែលត្រូវអនុវត្តនៅក្នុងសន្និសីទត្រួតពិនិត្យនេះ ត្រូវធ្វើដូចគ្នានឹងនីតិវិធីដែលធ្វើឡើងនៅសន្និសីទអង្គការសហប្រជាជាតិលើកទីបីស្តីពីនីតិសមុទ្រ។ សន្និសីទនេះត្រូវខិតខំប្រឹងប្រែងគ្រប់យ៉ាងដើម្បីសម្រេចនូវការព្រមព្រៀងលើការធ្វើវិសោធនកម្មតាមសំឡេងជាឯកច្ឆន្ទ ហើយមិនមានការបោះឆ្នោតលើបញ្ហាទាំងនោះទេ លុះត្រាតែការខិតខំប្រឹងប្រែងគ្រប់យ៉ាងដើម្បីទទួលបានសំឡេងជាឯកច្ឆន្ទនោះមិនបានសម្រេច។

៤. ប្រសិនបើរយៈពេលប្រាំឆ្នាំក្រោយពេលចាប់ផ្តើមសន្និសីទត្រួតពិនិត្យពុំអាចឈានដល់ការព្រមព្រៀងលើប្រព័ន្ធនៃការរុករក និងការធ្វើអាជីវកម្មធនធាននៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ សន្និសីទអាចសម្រេចចិត្តដោយសំឡេងភាគច្រើនបីភាគបួននៃរដ្ឋភាគី នៅក្នុងរយៈពេល១២ខែ ដើម្បីអនុម័តនិងបញ្ជូនឱ្យរដ្ឋភាគីផ្តល់សច្ចាប័ន ឬភ្ជាប់ខ្លួនចូលជាភាគីនូវការធ្វើវិសោធនកម្ម ដើម្បីផ្លាស់ប្តូរ ឬកែប្រែប្រព័ន្ធនោះទៅតាមការចាំបាច់ និងសមស្រប។ វិសោធនកម្មទាំងនេះ ត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីទាំងអស់ ក្នុងរយៈពេល ១២ខែ ក្រោយពីបានតម្កល់លិខិតូបករណ៍សច្ចាប័ន ឬលិខិតូបករណ៍ភ្ជាប់ខ្លួនចូលជាភាគី ដោយចំនួនបីភាគបួននៃរដ្ឋភាគី។

៥. រាល់វិសោធនកម្មដែលអនុម័តដោយសន្និសីទត្រួតពិនិត្យឡើងវិញក្រោមមាត្រានេះ មិនត្រូវប៉ះពាល់ដល់សិទ្ធិដែលទទួលបានក្នុងកិច្ចសន្យាមានស្រាប់នោះឡើយ។

## ផ្នែកទី៤
## អាជ្ញាធរបាតសមុទ្រអន្តរជាតិ
## ផ្នែករង ក
## បទប្បញ្ញត្តិទូទៅ

### មាត្រា១៥៦
### ការបង្កើតអាជ្ញាធរបាតសមុទ្រអន្តរជាតិ

១. អាជ្ញាធរត្រូវបានបង្កើតឡើងនិងត្រូវអនុវត្តមុខងារ ស្របតាមជំពូកនេះ។

២. រដ្ឋភាគីទាំងអស់ត្រូវក្លាយជាសមាជិកនៃអាជ្ញាធរដោយស្វ័យប្រវត្ត។

៣. អ្នកសង្កេតការណ៍នៅក្នុងសន្និសីទអង្គការសហប្រជាជាតិលើកទី៣ ស្តីពីនីតិសមុទ្រ ដែលបានចុះហត្ថលេខាលើអត្ថបទច្បាប់ចុងក្រោយ និងមិនមានចែងក្នុងមាត្រា៣០៥ កថាខណ្ឌទី១(គ)(ឃ)(ង) ឬ(ច) មានសិទ្ធិចូលរួមក្នុងអាជ្ញាធរក្នុងនាមជាអ្នកសង្កេតការណ៍ ស្របតាមវិធានបទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរ។

៤. អាជ្ញាធរ មានទីស្នាក់ការកណ្តាលស្ថិតនៅក្នុងប្រទេសហ្សាម៉ៃកា។

៥. អាជ្ញាធរអាចបង្កើតមជ្ឈមណ្ឌល ឬការិយាល័យប្រចាំតំបន់ ប្រសិនបើខ្លួនយល់ថាចាំបាច់ ដើម្បីអនុវត្តមុខងាររបស់ខ្លួន។

### មាត្រា១៥៧
### លក្ខណៈនិងគោលការណ៍មូលដ្ឋានរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

១. អាជ្ញាធរគឺជាអង្គការ ដែលតាមរយៈអង្គការនេះ រដ្ឋភាគីត្រូវរៀបចំ និងគ្រប់គ្រងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តជាតិ ជាពិសេសគ្រប់គ្រងធនធាននៅក្នុងតំបន់បាតសមុទ្រអន្តជាតិ ដោយអនុលោមតាមជំពូកនេះ។

២. អំណាច និងមុខងាររបស់អាជ្ញាធរជាអំណាចនិងមុខងារ ដូចមានចែងក្នុងអនុសញ្ញានេះ។ អាជ្ញាធរក៏មានអំណាចបន្ថែម ដែលមានចែងដោយប្រយោល ស្របតាមអនុសញ្ញានេះ និងភាពចាំបាច់ សម្រាប់ការអនុវត្តអំណាច និងមុខងារទាំងឡាយពាក់ព័ន្ធនឹងសកម្មភាពនានានៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

៣. អាជ្ញាធរបាតសមុទ្រអន្តរជាតិ ត្រូវគោរពគោលការណ៍អធិបតេយ្យស្មើភាពរបស់សមាជិកទាំងអស់របស់ខ្លួន។

៤. សមាជិកទាំងអស់របស់អាជ្ញាធរ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្រោមជំពូក នេះ ដោយសុទ្ធចិត្ត ដើម្បីធានាថា ពួកគេទាំងអស់ទទួលបានសិទ្ធិ និងផលប្រយោជន៍ពីសមាជិកភាព។

### មាត្រា១៥៨

### អង្គការរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

១. អង្គការសំខាន់ៗរបស់អាជ្ញាធរ ដែលត្រូវបង្កើតឡើង រួមមានសន្និបាតក្រុមប្រឹក្សានិងលេខាធិការដ្ឋាន។

២. សហគ្រាសដែលជាអង្គការមួយរបស់អាជ្ញាធរនឹងត្រូវបានបង្កើតឡើង ដើម្បីអនុវត្តមុខងារ ដូចមានចែងក្នុងមាត្រា១៧០ កថាខណ្ឌទី១។

៣. អង្គការគាំទ្រផ្សេងៗអាចត្រូវបង្កើតឡើងតាមការចាំបាច់ ដោយអនុលោមតាមជំពូកនេះ។

៤. អង្គការសំខាន់ៗរបស់អាជ្ញាធរនិងសហគ្រាស ត្រូវទទួលខុសត្រូវលើការអនុវត្តអំណាច និងមុខងារដែលត្រូវបានប្រគល់ឱ្យខ្លួន។ នៅក្នុងការអនុវត្តអំណាចនិងមុខងារទាំងនោះ អង្គការនីមួយៗ មិនត្រូវធ្វើសកម្មភាពណាមួយ ដែលអាចធ្វើឱ្យប៉ះពាល់ឬបន្ថយបង្អាក់ដល់ការអនុវត្តអំណាច និងមុខងាររបស់អង្គការផ្សេងឡើយ។

## អនុផ្នែកទី២

## សន្និបាត

### មាត្រា១៥៩

### សមាសភាព នីតិវិធី និងការបោះឆ្នោត

១. សន្និបាតត្រូវមានសមាសភាពចូលរួមដោយសមាជិកទាំងអស់របស់អាជ្ញាធរ។ សមាជិកនីមួយៗ ត្រូវមានតំណាងមួយរូបនៅក្នុងសន្និបាតដែលអាចអមដោយសមាជិកប្រតិភូនិងទីប្រឹក្សា។

២. សន្និបាតត្រូវបើកសម័យប្រជុំប្រចាំឆ្នាំជាទៀងទាត់និងសម័យប្រជុំពិសេសដែលអាចសម្រេចរៀបចំដោយសន្និបាត ឬកោះប្រជុំដោយអគ្គលេខាធិការតាមសំណើរបស់ក្រុមប្រឹក្សា ឬសមាជិកភាគច្រើនរបស់អាជ្ញាធរ។

៣. សម័យប្រជុំត្រូវរៀបចំធ្វើនៅឯទីស្នាក់ការកណ្តាលរបស់អាជ្ញាធរ លើកលែងតែសន្និបាត បានសម្រេចផ្ទុយពីនេះ។

៤. សន្និបាតត្រូវអនុម័តវិធានស្តីពីនីតិវិធីរបស់ខ្លួន។ នៅពេលចាប់ផ្តើមសម័យប្រជុំជាទៀងទាត់នីមួយៗ សន្និបាតត្រូវបោះឆ្នោតជ្រើសរើសប្រធាននិងមន្ត្រីផ្សេងៗទៀតតាមការចាំបាច់។ ប្រធាន និងមន្ត្រីទាំងនេះ ត្រូវកាន់មុខតំណែងរបស់ខ្លួនរហូតដល់ពេលប្រធាន និងមន្ត្រីថ្មីត្រូវបានបោះឆ្នោតឱ្យចូលកាន់តំណែងជំនួសនៅសម័យប្រជុំបន្ទាប់។

៥. សមាជិកភាគច្រើននៃសន្និបាតត្រូវបានកំណត់ជាកូរ៉ុមសម្រាប់សម័យប្រជុំ។

៦. សមាជិកនីមួយៗនៃសន្និបាតមានសំឡេងឆ្នោតមួយ។

៧. សេចក្តីសម្រេចចិត្តលើបញ្ហានីតិវិធី រួមទាំងសេចក្តីសម្រេចចិត្តដើម្បីកោះប្រជុំពិសេសនៃសន្និបាត ត្រូវធ្វើឡើងដោយសំឡេងឆ្នោតសមាជិកភាគច្រើនដែលមានវត្តមាន និងបានបោះឆ្នោត។

៨. សេចក្តីសម្រេចចិត្តលើបញ្ហាមាតិកាត្រូវធ្វើឡើងដោយសំឡេងឆ្នោតពីរភាគបីនៃសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត ដោយសំឡេងឆ្នោតភាគច្រើននេះជាសំឡេងឆ្នោតរបស់សមាជិកភាគច្រើនដែលបានចូលរួមនៅក្នុងកិច្ចប្រជុំ។ នៅពេលដែលមានបញ្ហាកើតឡើងទាក់ទងនឹងថាតើបញ្ហាមួយជាបញ្ហាមាតិកា ឬមិនមែននោះ បញ្ហានេះនឹងត្រូវចាត់ទុកជាបញ្ហាខ្លឹមសារ លើកលែងតែសន្និបាតបានសម្រេចផ្ទុយពីនេះ តាមសំឡេងភាគច្រើនដែលចាំបាច់សម្រាប់ធ្វើសេចក្តីសម្រេចចិត្តលើ បញ្ហាមាតិកាប៉ុណ្ណោះ។

៩. នៅពេលដែលមានបញ្ហាមាតិកាកើតឡើងសម្រាប់ការបោះឆ្នោតជាលើកដំបូងប្រធានសន្និបាត អាច ពន្យារពេលមិនបោះឆ្នោតលើបញ្ហានេះរយៈពេលយ៉ាងយូរប្រាំថ្ងៃនៃថ្ងៃប្រតិទិន ប្រសិនបើមានសំណើពីសមាជិកយ៉ាងតិចមួយភាគប្រាំនៃសមាជិកសន្និបាត។ វិធីនេះអាចឱ្យអនុវត្តតែមួយដងគត់ ចំពោះបញ្ហានីមួយៗដែលកើតឡើង ហើយមិនត្រូវអនុវត្តវិធីនេះ ដើម្បីពន្យារពេលបញ្ហាឱ្យកន្លងផុតពីសម័យប្រជុំនោះទេ។

១០. នៅពេលមានសំណើជាលាយលក្ខណ៍អក្សរ ដែលមានការគាំទ្រពីសមាជិកយ៉ាងតិចមួយភាគបួននៃសមាជិកសន្និបាតផ្ញើទៅកាន់ប្រធានសន្និបាត ដើម្បីស្នើសុំយោបល់អំពីអនុលោមភាពនៃអនុសញ្ញានេះ នៅចំពោះមុខសន្និបាតលើបញ្ហាណាមួយ សន្និបាតត្រូវស្នើឱ្យសភាវិវាទបាតសមុទ្រនៃសាលាក្តីអន្តរជាតិផ្នែកនីតិសមុទ្រ ផ្តល់នូវយោបល់អំពីលក្ខណៈស្របច្បាប់នៃសំណើនោះ ហើយត្រូវពន្យារពេលបោះឆ្នោតលើសំណើនោះ ដោយរង់ចាំទទួលយោបល់ពីសភាវិវាទជាមុនសិន។ ប្រសិនបើមិនទទួលបានយោបល់នៅមុនសប្តាហ៍ចុងក្រោយនៃសម័យប្រជុំ ដែលសំណើត្រូវបានលើកឡើងទេនោះ សន្និបាតត្រូវធ្វើសេចក្តីសម្រេចចិត្តនៅពេលប្រជុំបោះឆ្នោតលើសំណើដែលពន្យារពេលនោះ។

## មាត្រា១៦០
## អំណាចនិងមុខងារ

១. ក្នុងនាមជាអង្គការតែមួយគត់របស់អាជ្ញាធរ ដែលមានសមាសភាពចូលរួមដោយសមាជិកទាំងអស់ សន្និបាតត្រូវបានចាត់ទុកជាអង្គការកំពូលរបស់អាជ្ញាធរ ដែលមានអង្គការសំខាន់ៗផ្សេងទៀតទទួលខុសត្រូវតាមមុខជំនាញដូចមានចែងនៅក្នុងអនុញ្ញានេះចំពោះមុខអង្គការនេះ។ សន្និបាតមានអំណាចបង្កើតគោលនយោបាយរួមដែលអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ សម្រាប់រាល់បញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរ។

២. ទន្ទឹមនឹងនេះ សន្និបាតមានអំណាច និងមុខងារដូចខាងក្រោម៖

(ក) បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាស្របតាមមាត្រា១៦១ ។

(ខ) បោះឆ្នោតជ្រើសរើសអគ្គលេខាធិការពីក្នុងចំណោមបេក្ខជន ដែលស្នើឡើងដោយក្រុមប្រឹក្សា។

(គ) បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលសហគ្រាសនិងអគ្គនាយកសហគ្រាស ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សា។

(ឃ) បង្កើតអង្គការគាំទ្រដែលខ្លួនយល់ថាចាំបាច់ ដើម្បីអនុវត្តមុខងាររបស់ខ្លួន ស្របតាមជំពូកនេះ។ នៅក្នុងសមាសភាពនៃអង្គការគាំទ្រ ទាំងនេះ ត្រូវគិតគូរឱ្យបានសមស្របទៅលើគោលការណ៍បែងចែកតាមភូមិសាស្ត្រដោយស្មើភាព និងគិតគូរដល់ផលប្រយោជន៍ពិសេសរបស់សមាជិក និងសេចក្តីត្រូវការរបស់សមាជិកដែលមានគុណវុឌ្ឍិ និងសមត្ថភាពលើបញ្ហាបច្ចេកទេសពាក់ព័ន្ធរបស់អង្គការទាំងនោះ។

(ង) កំណត់ចំនួនទឹកប្រាក់វិភាគទានដែលសមាជិកត្រូវបង់ចូលថវិការដ្ឋបាលរបស់អាជ្ញាធរ ស្របតាមកម្រិតនៃការកំណត់ដែលបានព្រមព្រៀងគ្នា ដោយផ្អែកលើកម្រិតដែលត្រូវបានប្រើប្រាស់សម្រាប់ថវិកាទូទៅរបស់អង្គការសហប្រជាជាតិរហូតដល់ពេលដែលអាជ្ញាធរមានចំណូលគ្រប់គ្រាន់ពីប្រភពផ្សេងៗ សម្រាប់បំពេញតាមការចំណាយលើផ្នែករដ្ឋបាលរបស់ខ្លួន។

(ច) (i) ពិចារណា និងអនុម័តលើវិធាន បទបញ្ញា និងនីតិវិធីស្តីពីការបែងចែកផលប្រយោជន៍ហិរញ្ញវត្ថុ និងផលប្រយោជន៍សេដ្ឋកិច្ចផ្សេងៗ ដែលបានមកពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងទឹកប្រាក់វិភាគទានដែលទូទាត់តាមមាត្រា៨២ ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សា ដោយពិចារណាយ៉ាងជិតដល់ទៅលើផលប្រយោជន៍ និងតម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍន៍ និងប្រជាជនដែលមិនទាន់ទទួលបានឯករាជ្យពេញលេញ ឬឋានៈស្វ័យគ្រប់គ្រងផ្សេងទៀត។ ប្រសិនបើ សន្និបាតមិនអនុម័តលើអនុសាសន៍របស់ក្រុមប្រឹក្សា សន្និបាតត្រូវប្រគល់អនុសាសន៍ទាំងនោះទៅឱ្យក្រុមប្រឹក្សាពិចារណាជាថ្មីឡើងវិញ ដោយផ្អែកលើយោបល់របស់សន្និបាត។

(ii) ពិចារណា និងអនុម័តលើវិធាន បទបញ្ញា និងនីតិវិធីរបស់អាជ្ញាធរ និងវិសោធនកម្មទាំងឡាយ ដែលត្រូវបានអនុម័តជាបណ្តោះអាសន្នដោយក្រុមប្រឹក្សា ស្របតាមមាត្រា១៦២ កថាខណ្ឌទី២ (ណ)(ii)។ វិធាន បទបញ្ញា និងនីតិវិធីទាំងនេះត្រូវទាក់ទងនឹងការធ្វើបុរេសនា ការរុករក និងការធ្វើអាជីវកម្មរ៉ែនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលផ្ទៃក្នុងរបស់អាជ្ញាធរ និងការផ្ទេរមូលនិធិពីសហគ្រាសទៅកាន់អាជ្ញាធរ ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សាភិបាលសហគ្រាស។

(ឆ) ធ្វើការសម្រេចចិត្តលើការបែងចែកផលប្រយោជន៍ហិរញ្ញវត្ថុ និងផលប្រយោជន៍សេដ្ឋកិច្ចផ្សេងៗ ដែលបានមកពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិដោយស្មើភាពស្របតាមអនុសញ្ញានេះ វិធាន បទបញ្ញា និងនីតិវិធីរបស់អាជ្ញាធរ។

(ជ) ពិបារណោនិងអនុម័តលើសំណើថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរដែលក្រុមប្រឹក្សាបានបញ្ជូនមកឱ្យ។

(ឈ) ពិនិត្យរបាយការណ៍ជាប្រចាំដែលផ្ញើពីក្រុមប្រឹក្សា និងពីសហគ្រាស និងរបាយការណ៍ពិសេសដែលស្នើពីក្រុមប្រឹក្សា ឬអង្គការចំណុះនានារបស់អាជ្ញាធរ។

(ញ) ផ្តួចផ្តើមអនុវត្តការសិក្សានិងផ្តល់អនុសាសន៍ សម្រាប់គោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងជំរុញឱ្យមានការបង្កើតច្បាប់អន្តរជាតិដែលពាក់ព័ន្ធ និងចងក្រងជាក្រុមតែមួយឱ្យបានកាន់តែល្អប្រសើរ។

(ង) ពិចារណាលើបញ្ហាដែលមានលក្ខណៈទូទៅពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិដែលបានកើតឡើងជាពិសេសចំពោះរដ្ឋកំពុងអភិវឌ្ឍន៍ ព្រមទាំងបញ្ហាដែលពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិចំពោះរដ្ឋនានា ដោយសារកត្តាទីតាំងភូមិសាស្ត្រ ជាពិសេសរដ្ឋមិនជាប់សមុទ្រ និងរដ្ឋមានទីតាំងភូមិសាស្ត្រមិនអំណោយផល។

(ច) បង្កើតប្រព័ន្ធផ្តល់សំណង ឬវិធានការផ្តល់ជំនួយសម្របសម្រួលផ្នែកសេដ្ឋកិច្ចផ្សេងៗទៀតដូចមានចែងក្នុងមាត្រា១៥១ កថាខណ្ឌទី១០ ស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សាដែលផ្អែកលើយោបល់ពីគណៈកម្មការ ផែនការសេដ្ឋកិច្ច។

(ឆ) ព្យួរការអនុវត្តសិទ្ធិ និងបុព្វសិទ្ធិសមាជិកភាព ស្របតាមមាត្រា១៨៥ ។

(ជ) ពិភាក្សាអំពីបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរ និងធ្វើការសម្រេចចិត្តថា តើអង្គការណាមួយរបស់អាជ្ញាធរ ត្រូវដោះស្រាយបញ្ហាដែលពុំបានផ្តល់ទៅឱ្យអង្គការណាមួយច្បាស់លាស់ដោយអនុលោមតាមការបែងចែកអំណាច និងមុខងារក្នុងចំណោមអង្គការចំណុះរបស់អាជ្ញាធរ។

## អនុផ្នែកទី៣

## ក្រុមប្រឹក្សា

### មាត្រា១៦១

### សមាសភាព នីតិវិធី និងការបោះឆ្នោត

១. សមាសភាពក្រុមប្រឹក្សានេះមានសមាជិក៣៦របស់អាជ្ញាធរ ដែលត្រូវបានជ្រើសរើស តាមរយៈការបោះឆ្នោតដោយសន្និបាតតាមលំដាប់ដូចខាងក្រោមនេះ ៖

(ក) សមាជិកបួនរូបពីក្នុងចំណោមរដ្ឋភាគីដែលនៅក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនៃស្ថិតិដែលបានប្រើប្រាស់ច្រើនជាង២ ភាគរយនៃការប្រើប្រាស់សរុបនៅលើពិភពលោក ឬបាននាំចូលច្រើនជាង២ ភាគរយនៃការនាំចូលសុទ្ធសរុបនៅលើពិភពលោកនូវទំនិញដែលផលិតបានពីប្រភេទរ៉ែដែលបានមកពីតំបន់បាតសមុទ្រអន្តរជាតិ ហើយនៅគ្រប់ករណីទាំងអស់រួមមានរដ្ឋសង្គមនិយមមួយពីតំបន់អឺរ៉ុបខាងកើត ព្រមទាំងរដ្ឋដែលបានប្រើប្រាស់ទំនិញច្រើនជាងគេផងដែរ។

(ខ) សមាជិកបួនរូបពីក្នុងចំណោមរដ្ឋភាគីទាំងប្រាំបី ដែលបានរួមចំណែកច្រើនជាងគេនៅក្នុងការរៀបចំ និងការអនុវត្តសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ មិនថាដោយផ្ទាល់ ឬតាមរយៈពលរដ្ឋរបស់ពួកគេ ដោយក្នុងនោះយ៉ាងតិចក៏ត្រូវមានរដ្ឋសង្គមនិយមមួយពីតំបន់អឺរ៉ុបខាងកើតផងដែរ។

(គ) សមាជិកបួនរូបពីក្នុងចំណោមរដ្ឋភាគីដែលផ្អែកលើផលិតកម្មនៅក្នុងតំបន់ស្ថិតក្រោមយុត្តាធិការរបស់ពួកគេ គឺជារដ្ឋនាំចេញសុទ្ធធំបំផុតនូវប្រភេទរ៉ែដែលនឹងយកចេញពីតំបន់បាតសមុទ្រអន្តរជាតិ ដោយក្នុងនោះយ៉ាងតិចក៏ត្រូវមានរដ្ឋកំពុងអភិវឌ្ឍន៍ចំនួនពីរ ដែលការនាំចេញរ៉ែរបស់ពួកគេមានចំណែកធំធេងទៅលើសេដ្ឋកិច្ចរបស់ខ្លួន។

(ឃ) សមាជិកប្រាំមួយរូបពីក្នុងចំណោមរដ្ឋភាគីកំពុងអភិវឌ្ឍន៍ ដែលតំណាងឱ្យផលប្រយោជន៍ពិសេស។ ផលប្រយោជន៍ពិសេសដែលត្រូវមានតំណាងទាំងនោះ រួមមានផលប្រយោជន៍របស់រដ្ឋដែលមានប្រជាជនច្រើន រដ្ឋមិនជាប់ឆ្នេរ សមុទ្រ ឬរដ្ឋមានទីតាំងភូមិសាស្ត្រមិនអំណោយផល រដ្ឋនាំចូលធំៗនៃប្រភេទរ៉ែដែលនឹងត្រូវទាញចេញពីតំបន់បាតសមុទ្រអន្តរជាតិ រដ្ឋមានសក្តានុពលខ្ពស់ក្នុងការផលិតរ៉ែទាំងនោះ និងរដ្ឋដែលមានការអភិវឌ្ឍតិចតួចបំផុត។

(ង) សមាជិកដប់ប្រាំបីរូបដែលត្រូវបានបោះឆ្នោតជ្រើសរើសតាមគោលការណ៍ធានាការបែងចែកអាសនៈនៅក្នុងក្រុមប្រឹក្សាទាំងមូលតាមភូមិសាស្ត្រដោយស្មើភាព ដោយតំបន់ភូមិសាស្ត្រនីមួយៗត្រូវមានសមាជិកយ៉ាងតិចមួយរូបដែលត្រូវបានបោះឆ្នោតជ្រើសរើសនៅក្រោមកថាខណ្ឌនេះ។ សម្រាប់គោលបំណងនេះ តំបន់ភូមិសាស្ត្រទាំងនេះ រួមមានអាហ្វ្រិក អាស៊ី អឺរ៉ុបខាងកើតដែលជាប្រទេសសង្គមនិយម អាមេរិកឡាទីន អឺរ៉ុបខាងលិច និងតំបន់ផ្សេងៗទៀត។

២. នៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិករបស់ក្រុមប្រឹក្សាស្របតាមកថាខណ្ឌទី១ សន្និបាតត្រូវធានាថា៖

(ក) រដ្ឋមិនជាប់ឆ្នេរសមុទ្រ និងរដ្ឋមានភូមិសាស្ត្រមិនអំណោយផលទទួលបានភាពជាតំណាងក្នុងកម្រិតមួយ ដែលសមមាត្រទៅនឹងភាពជាតំណាងរបស់ពួកគេនៅក្នុងសន្និបាត។

(ខ) រដ្ឋជាប់ឆ្នេរសមុទ្រជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ ដែលពុំមានលក្ខណៈសម្បត្តិក្រោមកថាខណ្ឌទី១(ក)(ខ)(គ) ឬ(ឃ) ទទួលបានភាពជាតំណាងក្នុងកម្រិតមួយ ដែលសមមាត្រទៅនឹងភាពជាតំណាងរបស់ពួកគេនៅក្នុងសន្និបាត។

(គ) ប្រសិនបើមាន ក្រុមនីមួយៗនៃរដ្ឋភាគីដែលនឹងទទួលបានភាពជាតំណាងនៅក្នុងក្រុមប្រឹក្សាត្រូវមានសមាជិកតំណាងឱ្យខ្លួនដែលត្រូវជ្រើសតាំងដោយក្រុមខ្លួន។

៣. ការបោះឆ្នោតត្រូវរៀបចំធ្វើនៅក្នុងសម័យប្រជុំជាទៀងទាត់របស់សន្និបាត។ សមាជិកនីមួយៗនៃក្រុមប្រឹក្សានឹងត្រូវបោះឆ្នោតជ្រើសរើសសម្រាប់រយៈពេលបួនឆ្នាំ។ ទោះជាយ៉ាងណាក្តីនៅក្នុងការបោះឆ្នោតលើកទី១ អាណត្តិរបស់សមាជិកពាក់កណ្តាលនៃក្រុមនីមួយៗដូចមានចែងនៅក្នុងកថាខណ្ឌទី១មានរយៈពេលតែពីរឆ្នាំប៉ុណ្ណោះ។

៤. សមាជិកក្រុមប្រឹក្សាមានសិទ្ធិឈរឈ្មោះបោះឆ្នោតជាថ្មី ប៉ុន្តែត្រូវយកចិត្តទុកដាក់ឱ្យបានសមស្របទៅលើបំណងចង់បានការផ្លាស់វេនសមាជិកភាព។

៥. ក្រុមប្រឹក្សាត្រូវអនុវត្តមុខងារនៅឯទីស្នាក់ការរបស់អាជ្ញាធរ ហើយត្រូវកោះប្រជុំឱ្យញឹកញាប់ទៅតាមតម្រូវការការងាររបស់អាជ្ញាធរ ប៉ុន្តែមិនត្រូវប្រជុំតិចជាងបីដងក្នុងមួយឆ្នាំទេ។

៦. សមាជិកភាគច្រើននៃក្រុមប្រឹក្សាត្រូវបង្កើតបានជាកូរ៉ុម។

៧. សមាជិកនីមួយៗនៃក្រុមប្រឹក្សាត្រូវមានសំឡេងឆ្នោតមួយ។

៨. (ក) សេចក្តីសម្រេចចិត្តលើបញ្ហានីតិវិធីត្រូវធ្វើឡើងដោយសំឡេងឆ្នោតសមាជិកភាគច្រើនដែលមានវត្តមាន និងបានបោះឆ្នោត។

(ខ) សេចក្តីសម្រេចចិត្តលើបញ្ហាមាតិកាដែលបានកើតឡើងនៅក្រោមបទប្បញ្ញត្តិខាងក្រោម ត្រូវធ្វើឡើងដោយសំឡេងឆ្នោតពីរភាគបីនៃសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត ដោយសំឡេងឆ្នោតភាគច្រើននេះ ជាសំឡេងឆ្នោតរបស់សមាជិកភាគច្រើននៃក្រុមប្រឹក្សា ៖ បទប្បញ្ញត្តិនៃមាត្រា១៦២ កថាខណ្ឌទី២ កថាខណ្ឌរង (ច) (ឆ)(ជ)(ឈ)(ឍ) (ត)(ផ) និងមាត្រា១៩១ ផងដែរ។

(គ) សេចក្តីសម្រេចចិត្តលើបញ្ហាមាតិកាដែលបានកើតឡើង ស្របតាមបទប្បញ្ញត្តិខាងក្រោម ត្រូវធ្វើឡើងដោយសំឡេងឆ្នោតបីភាគបួននៃសមាជិកដែលមានវត្តមាន និងបានបោះឆ្នោត ដោយសំឡេងឆ្នោតភាគច្រើននេះ រួមមានទាំងសំឡេងឆ្នោតរបស់សមាជិកភាគច្រើននៃក្រុមប្រឹក្សា ៖ បទប្បញ្ញត្តិនៃមាត្រា១៦២ កថាខណ្ឌទី១ មាត្រា១៦២ កថាខណ្ឌទី២ កថាខណ្ឌរង(ក)(ខ)(គ)(ឃ)(ង)(ឋ)(ត)(ថ) (ទ)(ធ)(ន)(ប) ក្នុងករណីមិនគោរពតាមកិច្ចសន្យាដោយអ្នកម៉ៅការ ឬម្ចាស់ឧបត្ថម្ភ កថាខណ្ឌរង (ព) ដោយបទបញ្ជាដែលចេញតាមកថាខណ្ឌរងនេះ អាចចងកាតព្វកិច្ចរយៈពេលយ៉ាងយូរ៣០ថ្ងៃ លើកលែងតែមានការបញ្ជាក់ដោយសេចក្តីសម្រេចដែលធ្វើឡើងស្របតាមកថាខណ្ឌរង(ឃ) មាត្រា១៦២ កថាខណ្ឌទី២ កថាខណ្ឌរង (ភ)(ម)(យ) មាត្រា ១៦៣ កថាខណ្ឌទី២ មាត្រា១៧៤ កថាខណ្ឌទី៣ ឧបសម្ព័ន្ធទី៤ មាត្រា១១។

(ឃ) សេចក្តីសម្រេចចិត្តលើបញ្ហាមាតិកាដែលបានកើតឡើងស្របតាមបទប្បញ្ញត្តិខាងក្រោម ត្រូវធ្វើឡើងដោយសំឡេងឯកច្ឆន្ទ៖ បទប្បញ្ញត្តិនៃមាត្រា១៦២ កថាខណ្ឌទី២ (ឌ) និង (ណ) ការអនុម័តវិសោធនកម្មលើផ្នែកទី៩។

(ង) សម្រាប់គោលបំណងនៃកថាខណ្ឌរង (ឃ)(ច) និង(ឆ) "សំឡេងឯកច្ឆន្ទ" មានន័យថា ពុំមានសំឡេងជំទាស់ជាផ្លូវការ។ នៅចន្លោះរយៈពេល១៤ថ្ងៃ ក្រោយថ្ងៃដាក់សំណើទៅកាន់ក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវកំណត់ថា តើនឹងមាន ឬគ្មានការជំទាស់ ជាផ្លូវការទៅលើការអនុម័តសំណើនោះដែរឬយ៉ាងណា។ ប្រសិនបើប្រធានក្រុមប្រឹក្សាកំណត់ថានឹងមានការជំទាស់នោះ ប្រធានក្រុមប្រឹក្សាត្រូវរៀបចំកោះប្រជុំគណៈកម្មាធិការផ្សះផ្សាមួយនៅក្នុងរយៈពេល៣ថ្ងៃ ក្រោយពេលកំណត់ខាងលើ ដែលមានសមាសភាពយ៉ាងច្រើនបំផុតសមាជិកប្រាំបួនរូបនៃក្រុមប្រឹក្សាដោយប្រធានក្រុមប្រឹក្សាមានតួនាទីជាប្រធានគណៈកម្មាធិការនេះ ក្នុងគោលបំណងផ្សះផ្សាការខ្វែងគំនិត និងបង្កើតសំណើមួយដែលអាចឱ្យមានការអនុម័តជាឯកច្ឆន្ទ។ ប្រសិនបើគណៈកម្មាធិការមិនអាចលើកជាសំណើណាមួយ ដែលអាចឱ្យមានការអនុម័តជាឯកច្ឆន្ទទេនោះ គណៈកម្មាធិការត្រូវបញ្ចូលមូលហេតុនៃការជំទាស់លើសំណើនេះទៅក្នុងរបាយការណ៍របស់ខ្លួន។

(ច) សេចក្តីសម្រេចចិត្តលើបញ្ហាពុំមានចែងខាងលើ ដែលក្រុមប្រឹក្សាមានសិទ្ធិធ្វើការសម្រេចតាមវិធាន បទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរ ឬឯកសារផ្សេងទៀត ត្រូវធ្វើឡើងស្របតាមកថាខណ្ឌរងនៃកថាខណ្ឌនេះ ដូចបានកំណត់នៅក្នុងវិធាន បទបញ្ជា និងនីតិវិធី ឬ

ប្រសិនបើពុំមានកំណត់នៅក្នុងឯកសារទាំងនោះទេ នោះត្រូវធ្វើឡើងស្របតាមកថាខណ្ឌរង ដែលកំណត់ដោយក្រុមប្រឹក្សាតាមសំឡេងឯកច្ឆន្ទជាមុន ប្រសិនអាចធ្វើទៅបាន។

(ឆ) នៅពេលដែលបញ្ហាមួយលេចឡើងដោយគេមិនដឹងថា បញ្ហានេះស្ថិតក្នុងកថាខណ្ឌរង(ក) (ខ) (គ) ឬ (ឃ) នោះបញ្ហានេះនឹងត្រូវចាត់ទុកជាបញ្ហាស្ថិតក្នុងកថាខណ្ឌរង មួយណាដែលទាមទារសំឡេងអនុម័តភាគច្រើនខ្ពស់ជាងគេ ឬសំឡេងឯកច្ឆន្ទទៅតាមករណីជាក់ស្តែង លើកលែងតែក្រុមប្រឹក្សាបានសម្រេចផ្ទុយពីនេះ ដោយសំឡេងភាគច្រើន ឬដោយសំឡេងឯកច្ឆន្ទ។

៩. ក្រុមប្រឹក្សាត្រូវបង្កើតនីតិវិធីមួយ ដែលអនុញ្ញាតឱ្យសមាជិកអាជ្ញាធរ ដែលពុំមានតំណាងនៅក្នុងក្រុមប្រឹក្សា អាចបញ្ជូនតំណាងមួយរូបទៅចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សា នៅពេលដែលសមាជិករូបនោះដាក់សំណើ ឬនៅពេលមានបញ្ហាប៉ះពាល់ណាមួយដែលកំពុងស្ថិតក្នុងការពិចារណា។ អ្នកតំណាងរូបនេះមានសិទ្ធិចូលរួមក្នុងកិច្ចពិភាក្សា តែពុំមានសិទ្ធិបោះឆ្នោតទេ។

## មាត្រា១៦២
## អំណាចនិងមុខងារ

១. ក្រុមប្រឹក្សាជាអង្គការប្រតិបត្តិរបស់អាជ្ញាធរ។ ដោយអនុលោមតាមអនុសញ្ញានេះ និងគោលនយោបាយទូទៅដែលបានបង្កើតឡើងដោយសន្និបាតក្រុមប្រឹក្សាមានអំណាចបង្កើតគោលនយោបាយជាក់លាក់ពាក់ព័ន្ធនឹងចម្ងល់និងបញ្ហាក្នុងសមត្ថកិច្ចរបស់អាជ្ញាធរសម្រាប់ឱ្យអាជ្ញាធរអនុវត្ត។

២. ទន្ទឹមនឹងនេះ សន្និបាតមានអំណាចនិងមុខងារដូចខាងក្រោម៖

(ក) ពិនិត្យនិងសម្របសម្រួលការអនុវត្តបទប្បញ្ញត្តិនៅក្នុងជំពូកនេះទាក់ទងនឹងរាល់បញ្ហាដែលស្ថិតក្នុងយុត្តាធិការរបស់អាជ្ញាធរ និងត្រូវស្នើឱ្យសន្និបាតពិចារណាទៅលើករណីនៃការមិនបំពេញតាមលក្ខខណ្ឌ។

(ខ) ដាក់សំណើបញ្ជីឈ្មោះបេក្ខជនទៅកាន់សន្និបាតសម្រាប់ការបោះឆ្នោតជ្រើសរើសអគ្គលេខាធិការ។

(គ) ផ្តល់អនុសាសន៍ជូនសន្និបាតអំពីបេក្ខជន ដែលត្រូវបោះឆ្នោតជ្រើសរើសជាសមាជិកក្រុមប្រឹក្សាភិបាល សហគ្រាស និងអគ្គនាយកសហគ្រាស។

(ឃ) បង្កើតអង្គការចំណុះដែលខ្លួនយល់ថាចាំបាច់ឱ្យបានសមស្រប ដោយគិតគូរម៉ត់ចត់អំពីសេដ្ឋកិច្ច និងប្រសិទ្ធផល ដើម្បីអនុវត្តមុខងាររបស់ខ្លួនស្របតាមជំពូកនេះ។ នៅក្នុងសមាសភាពនៃអង្គការចំណុះទាំងនេះ ត្រូវយកចិត្តទុកដាក់ខ្ពស់ទៅលើតម្រូវការរបស់សមាជិកដែលមានគុណវុឌ្ឍិ និងសមត្ថភាពលើការដោះស្រាយបញ្ហាបច្ចេកទេសពាក់ព័ន្ធរបស់អង្គការទាំងនោះ ដោយបានគិតគូរដិតដល់ទៅលើគោលការណ៍បែងចែកតាមភូមិសាស្រ្តដោយស្មើភាពនិងផលប្រយោជន៍ពិសេសរបស់សមាជិក។

(ង) អនុវត្តវិធានស្តីពីនីតិវិធី រួមទាំងវិធីសាស្រ្តជ្រើសរើសប្រធានក្រុមប្រឹក្សាផងដែរ។

(ច) ចុះកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ឬអង្គការអន្តរជាតិជំនួសមុខអាជ្ញាធរ និងក្នុងយុត្តាធិការរបស់ខ្លួនបន្ទាប់ពីទទួលបានការអនុម័តពីសន្និបាត។

(ឆ) ពិចារណាលើរបាយការណ៍របស់សហគ្រាស និងបញ្ជូនរបាយការណ៍ទៅសន្និបាត ដោយអមជាមួយនឹងអនុសាសន៍។

(ជ) ដាក់របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ពិសេសទៅកាន់សន្និបាតនៅពេលមានសំណើពីសន្និបាត។

(ឈ) ចេញសេចក្តីណែនាំទៅកាន់សហគ្រាសស្របតាមមាត្រា១៧០។

(ញ) អនុម័តផែនការការងារស្របតាមឧបសម្ព័ន្ធទី៣ មាត្រា៦។ ក្រុមប្រឹក្សាត្រូវធ្វើសកម្មភាពលើផែនការការងារនីមួយៗនៅក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពីថ្ងៃគណៈកម្មការនីតិកម្ម និងបច្ចេកទេសបានដាក់ផែនការការងារនៅក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សា ស្របតាមនីតិវិធីខាងក្រោម៖

(i) ប្រសិនបើគណៈកម្មការផ្តល់អនុសាសន៍ឱ្យអនុម័តផែនការការងារណាមួយ នោះត្រូវចាត់ទុកថា ក្រុមប្រឹក្សាបានអនុម័តលើផែនការនេះ ប្រសិនបើគ្មានសមាជិកណាមួយនៃក្រុមប្រឹក្សាបានដាក់លិខិតជំទាស់ទៅកាន់ប្រធានក្រុមប្រឹក្សានៅក្នុងរយៈពេល ១៤ថ្ងៃ ដោយចោទប្រកាន់ពីករណីមិនគោរពតាមលក្ខខណ្ឌតម្រូវនៃឧបសម្ព័ន្ធទី៣ មាត្រា៦ ទេនោះ។ ប្រសិនបើមានការជំទាស់នោះ ត្រូវអនុវត្តតាមនីតិវិធីផ្សះផ្សា ដូចមានចែងក្នុងមាត្រា១៦១ កថាខណ្ឌទី៨(ង)។ ប្រសិនបើនៅចុងបញ្ចប់នៃនីតិវិធីផ្សះផ្សានេះ ការជំទាស់នៅតែបន្តមាននោះ ផែនការការងារនឹងត្រូវចាត់ទុកថាបានអនុម័តដោយក្រុមប្រឹក្សា។ ប្រសិនបើក្រុមប្រឹក្សាពុំបានច្រានចោលផែនការនេះដោយសំឡេងឯកច្ឆន្ទក្នុងចំណោមសមាជិកក្រុមប្រឹក្សា ដោយពុំរាប់បញ្ចូលរដ្ឋដែលដាក់ពាក្យជំទាស់ ឬរដ្ឋគាំទ្រភាគីដាក់ពាក្យជំទាស់។

(ii) ប្រសិនបើគណៈកម្មការផ្តល់អនុសាសន៍ឱ្យច្រានចោលផែនការការងារ ឬមិនបានផ្តល់អនុសាសន៍ណាមួយទេ នោះក្រុមប្រឹក្សាអាចអនុម័តផែនការងារនេះ ដោយសំឡេងឆ្នោតបីភាគបួនរបស់សមាជិកដែលមានវត្តមាន និងបានបោះឆ្នោតដោយសំឡេងឆ្នោតភាគច្រើននេះក៏ត្រូវមានសំឡេងរបស់សមាជិកភាគច្រើនដែលបានចូលរួមនៅក្នុងកិច្ចប្រជុំផងដែរ។

(ដ) អនុម័តផែនការការងារដែលដាក់ជូនដោយសហគ្រាសស្របតាមឧបសម្ព័ន្ធទី៤ មាត្រា១២ ដោយត្រូវអនុវត្តដូចគ្នាតាម នីតិវិធីដូចមានចែងនៅក្នុងកថាខណ្ឌរង(ញ)។

(ឋ) អនុវត្តការត្រួតពិនិត្យលើសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ស្របតាមមាត្រា១៥៣ កថាខណ្ឌទី៤ និងវិធាន បទបញ្ញានិងនីតិវិធីរបស់អាជ្ញាធរ។

(ឌ) ចាត់វិធានការចាំបាច់និងសមស្របស្របតាមមាត្រា១៥០ កថាខណ្ឌរង (ជ) ដោយផ្អែកលើអនុសាសន៍របស់គណៈកម្មការ ផែនការសេដ្ឋកិច្ច ដើម្បីផ្តល់ការការពារពីផលប៉ះពាល់សេដ្ឋកិច្ចអវិជ្ជមានដូចមានចែងនៅក្នុងកថាខណ្ឌរងនោះ។

(ឍ) ផ្តល់អនុសាសន៍ជូនសន្និបាត ដោយផ្អែកលើយោបល់របស់គណៈកម្មការផែនការសេដ្ឋកិច្ច អំពីការបង្កើតប្រព័ន្ធផ្តល់សំណង ឬវិធានការផ្តល់ជំនួយសម្របសម្រួលផ្នែកសេដ្ឋកិច្ចផ្សេងៗទៀត ដូចមានចែងក្នុងមាត្រា១៥១ កថាខណ្ឌទី១០។

(ណ) (i) ផ្តល់អនុសាសន៍ជូនសន្និបាតអំពីវិធាន បទបញ្ជា និងនីតិវិធីស្តីពីការបែងចែកផលប្រយោជន៍ហិរញ្ញវត្ថុ និងផលប្រយោជន៍សេដ្ឋកិច្ចផ្សេងៗដែលបានមកពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងទឹកប្រាក់វិភាគទានដែលទូទាត់ស្របតាមមាត្រា៨២ ដោយផ្អែកលើអនុសាសន៍របស់ក្រុមប្រឹក្សា ដោយពិចារណាយ៉ាងពិសេសទៅលើផលប្រយោជន៍ និងតម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍន៍ និងប្រជាជន ដែលមិនទាន់ទទួលបានឯករាជ្យពេញលេញ ឬឋានៈស្វ័យគ្រប់គ្រងផ្សេងទៀត។

(ii) អនុម័តនិងអនុវត្តជាបណ្តោះអាសន្ន ដោយរង់ចាំការអនុម័តពីសន្និបាតនូវវិធាន បទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរ និងរាល់វិសោធនកម្មទាំងឡាយ ដោយពិចារណាលើអនុសាសន៍របស់គណៈកម្មការនីតិកម្មនិងបច្ចេកទេស ឬអង្គការដែលពាក់ព័ន្ធផ្សេងទៀត។ វិធាន បទបញ្ជា និងនីតិវិធីទាំងនេះ ត្រូវទាក់ទងនឹងការធ្វើបុរេសនា ការរុករក និងការធ្វើអាជីវកម្មរ៉ែនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលផ្ទៃក្នុងរបស់អាជ្ញាធរ។ អាទិភាព ត្រូវផ្តល់ទៅលើការអនុម័ត វិធាន បទបញ្ជា និងនីតិវិធី ស្តីពីការរុករក និងការធ្វើអាជីវកម្មបណ្តុំលោហៈប៉ូលីមេតាលិក។ វិធាន បទបញ្ជា និងនីតិវិធីស្តីពីការរុករក និងការធ្វើអាជីវកម្មធនធានក្រៅពីបណ្តុំលោហៈប៉ូលីមេតាលិក ត្រូវអនុម័តនៅក្នុងរយៈពេលបីឆ្នាំ គិតចាប់ពីថ្ងៃដែលសមាជិកណាមួយរបស់ខ្លួនដាក់សំណើទៅកាន់អាជ្ញាធរ ដែលស្នើឱ្យអនុម័តវិធាន បទបញ្ជា និងនីតិវិធី ដែលពាក់ព័ន្ធនឹងធនធានទាំងនោះ។ រាល់វិធាន បទបញ្ជា និងនីតិវិធីនៅបន្តមានប្រសិទ្ធភាពជាបណ្តោះអាសន្នរហូតដល់ពេលមានការអនុម័តពីសន្និបាត ឬការធ្វើវិសោធនកម្មរបស់ក្រុមប្រឹក្សាតាមយោបល់របស់សន្និបាត។

(ត) ពិនិត្យលើការប្រមូលប្រាក់ចំណាយដែលធ្វើឡើងដោយ ឬទៅកាន់អាជ្ញាធរពាក់ព័ន្ធនឹងប្រតិបត្តិការស្របតាមជំពូកនេះ។

(ថ) ធ្វើការជ្រើសរើសចេញពីក្នុងចំណោមបេក្ខជនដាក់ពាក្យសុំការអនុញ្ញាតផលិតកម្មស្របតាមឧបសម្ព័ន្ធទី៣ មាត្រា៧ ប្រសិនបើបទប្បញ្ញត្តិនោះទាមទារឱ្យមានការជ្រើសរើស។

(ទ) បញ្ជូនសំណើថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរទៅឱ្យសន្និបាតអនុម័ត។

(ធ) ផ្តល់អនុសាសន៍ជូនសន្និបាតពាក់ព័ន្ធនឹងគោលនយោបាយស្តីពីបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរ។

(ន) ផ្តល់អនុសាសន៍ជូនសន្និបាតពាក់ព័ន្ធនឹងការពន្យារពេលក្នុងអនុវត្តសិទ្ធិ និងបុព្វសិទ្ធិសមាជិកភាពស្របតាមមាត្រា១៨៥។

(ប) ផ្តួចផ្តើមនីតិវិធីបណ្តឹងក្នុងនាមអាជ្ញាធរ ទៅកាន់សភាវិវាទបាតសមុទ្រ ក្នុងករណីមានការរំលោភបំពានណាមួយ។

(ផ) ជូនដំណឹងដល់សន្និបាត នៅពេលដែលសភាវិវាទបាតសមុទ្រចេញសេចក្តីសម្រេចនៅក្នុងនីតិវិធីបណ្តឹងដែលធ្វើឡើងក្រោមកថាខណ្ឌរង(ប) និងផ្តល់អនុសាសន៍ ដែលខ្លួនយល់ថា សមស្របពាក់ព័ន្ធនឹងវិធានការដែលត្រូវចាត់ឡើងនាពេលបន្ទាប់។

(ព) ចេញដីកាបន្ទាន់ ដែលអាចរួមមានទាំងដីកាពន្យារពេល ឬកែប្រែប្រតិបត្តិការផង ដើម្បីការពារផលប៉ះពាល់ធ្ងន់ធ្ងរទៅលើបរិស្ថានសមុទ្រ ដែលកើតឡើងដោយសារសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

(ភ) មិនផ្តល់ការអនុម័តលើតំបន់ធ្វើអាជីវកម្មដោយក្រុមហ៊ុនម៉ៅការ ឬសហគ្រាសក្នុងករណីដែលមានភស្តុតាងច្បាស់លាស់បង្ហាញពីហានិភ័យនៃគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះបរិស្ថានសមុទ្រ។

(ម) បង្កើតអង្គការណាមួយដើម្បីពន្យល់ពិស្តារអំពីសេចក្តីព្រាង វិធានហិរញ្ញវត្ថុ បទបញ្ញានិងនីតិវិធីដែលពាក់ព័ន្ធនឹង៖

(i) ការគ្រប់គ្រងហិរញ្ញវត្ថុស្របតាមមាត្រា១៧១ ដល់មាត្រា១៧៥ និង

(ii) ការគ្រប់គ្រងហិរញ្ញវត្ថុស្របតាមឧបសម្ព័ន្ធទី៣ មាត្រា១៣ និងមាត្រា១៧ កថាខណ្ឌទី១(គ)។

(យ) បង្កើតយន្តការសមស្របសម្រាប់ដឹកនាំ និងត្រួតពិនិត្យបុគ្គលិកក្រុមអធិការកិច្ច ដែលត្រួតពិនិត្យសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ដើម្បីកំណត់អំពីការគោរពតាមជំពូកនេះ វិធាន បទបញ្ញា និងនីតិវិធីរបស់អាជ្ញាធរ និងលក្ខខណ្ឌក្នុងកិច្ចសន្យាជាមួយអាជ្ញាធរនេះ ។

## មាត្រា១៦៣

## អង្គការរបស់ក្រុមប្រឹក្សា

១. អង្គការរបស់ក្រុមប្រឹក្សា ដែលត្រូវបង្កើតឡើងរួមមាន៖

(ក) គណៈកម្មការ ផែនការសេដ្ឋកិច្ច

(ខ) គណៈកម្មការនីតិកម្មនិងបច្ចេកទេស

២. គណៈកម្មការនីមួយៗមានសមាជិក១៥ រូប ដែលត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត ដោយក្រុមប្រឹក្សានៅក្នុងចំណោមបេក្ខជនដែលស្នើឡើងដោយរដ្ឋភាគី។ ទោះជាយ៉ាងណាក្តី ប្រសិនបើចាំបាច់ក្រុមប្រឹក្សាអាចសម្រេចបង្កើនទំហំគណៈកម្មការនីមួយៗ ក្រោយពីបានពិចារណាយ៉ាងដិតដល់ទៅលើស្ថានភាពសេដ្ឋកិច្ច និងប្រសិទ្ធផល។

៣. សមាជិកគណៈកម្មការនីមួយៗត្រូវមានគុណវុឌ្ឍិសមស្របនៅក្នុងផ្នែកនៃសមត្ថកិច្ចរបស់គណៈកម្មការ។ រដ្ឋភាគីត្រូវស្នើបេក្ខជនដែលមានស្តង់ដារសមត្ថភាពនិងវិជ្ជាជីវៈខ្ពស់បំផុត រួមជាមួយនឹងគុណវុឌ្ឍិក្នុងផ្នែកដែលពាក់ព័ន្ធ ដើម្បីធានានូវការអនុវត្តមុខងាររបស់គណៈកម្មការបានដោយមានប្រសិទ្ធភាពខ្ពស់។

៤. នៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនីមួយៗ ត្រូវយកចិត្តទុកដាក់ឱ្យបានសមស្របទៅលើតម្រូវការបែងចែកតាមភូមិសាស្ត្រប្រកបដោយសមភាព និងភាពជាតំណាងឱ្យផលប្រយោជន៍ពិសេស។

៥. គ្មានរដ្ឋភាគីណាមួយអាចស្នើបេក្ខជនលើសពីមួយរូបសម្រាប់គណៈកម្មការតែមួយនោះទេ។ គ្មានបុគ្គលណាម្នាក់ត្រូវបានបោះឆ្នោតឱ្យបម្រើការនៅក្នុងគណៈកម្មការលើសពីមួយនោះដែរ។

៦. សមាជិកគណៈកម្មការមានអាណត្តិរយៈពេលប្រាំឆ្នាំ។ ពួកគេមានសិទ្ធិឈរឈ្មោះបោះឆ្នោតជាថ្មីសម្រាប់មួយអាណត្តិបន្តទៀត។

៧. ក្នុងករណីមរណភាព អសមត្ថភាព ឬលាលែងពីតំណែងរបស់សមាជិកណាម្នាក់ពីគណៈកម្មការ នៅមុនពេលផុតអាណត្តិ ក្រុមប្រឹក្សាត្រូវបោះឆ្នោតជ្រើសរើសសមាជិកមួយរូបពីតំបន់ភូមិសាស្ត្រ ឬផ្នែកដដែល មកបន្តការងារសម្រាប់អាណត្តិដែលនៅសល់។

៨. សមាជិកគណៈកម្មការគ្មានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុនៅក្នុងសកម្មភាពណាមួយ ដែលទាក់ទងនឹងការរុករក និងការធ្វើអាជីវកម្មធនធាននៅក្នុងតំបន់នោះទេ។ ដោយផ្អែកលើការទទួលខុសត្រូវរបស់សមាជិកចំពោះគណៈកម្មការដែលពួកគេបម្រើការ សមាជិកមិនត្រូវលាតត្រដាងនូវការសម្ងាត់ផ្នែកឧស្សាហកម្ម ទិន្នន័យស្តីពីកម្មសិទ្ធិដែលត្រូវបានផ្ទេរទៅឱ្យអាជ្ញាធរ ស្របតាមមឧបសម្ព័ន្ធទី៣ មាត្រា១៤ ឬព័ត៌មានសម្ងាត់ផ្សេងៗទៀតដែលពួកគេបានដឹងតាមរយៈការបំពេញភារកិច្ចជូនអាជ្ញាធរឡើយ សូម្បីតែនៅក្រោយពេលដែលពួកគេឈប់ធ្វើការ។

៩. គណៈកម្មការនីមួយៗត្រូវអនុវត្តមុខងាររបស់ខ្លួនស្របតាមសេចក្តីណែនាំនិងសរាចរណ៍ ដែលក្រុមប្រឹក្សាអាចនឹងអនុម័តឱ្យអនុវត្ត។

១០. គណៈកម្មការនីមួយៗត្រូវរៀបចំវិធាន និងបទបញ្ញា ដែល ចាំបាច់ ដើម្បីអនុវត្តមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព រួចដាក់ជូនក្រុមប្រឹក្សាអនុម័ត។

១១. នីតិវិធីធ្វើសេចក្តីសម្រេចចិត្តរបស់គណៈកម្មការ ត្រូវបង្កើតឡើងដោយវិធាន បទបញ្ញា និងនីតិវិធីរបស់អាជ្ញាធរ។ ប្រសិនបើចាំបាច់ការផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាត្រូវអមមកជាមួយនឹងសេចក្តីសង្ខេបស្តីពីយោបល់ផ្សេងៗគ្នារបស់សមាជិកនៅក្នុងគណៈកម្មការ។

១២. គណៈកម្មការនីមួយៗត្រូវបំពេញមុខងារជាធម្មតានៅឯទីស្នាក់ការរបស់អាជ្ញាធរ ហើយត្រូវជួបប្រជុំឱ្យបានញឹកញាប់ទៅតាមការចាំបាច់ ដើម្បីអនុវត្តមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

១៣. នៅក្នុងការអនុវត្តមុខងាររបស់ខ្លួន គណៈកម្មការនីមួយៗអាចពិគ្រោះយោបល់ជាមួយគ្នាទៅវិញទៅមក ឬជាមួយអង្គការមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ ឬជាមួយទីភ្នាក់ងារបច្ចេកទេសរបស់ខ្លួនឬជាមួយអង្គការអន្តរជាតិផ្សេងៗ ដែលមានសមត្ថកិច្ចលើកម្មវត្ថុនៃការពិគ្រោះយោបល់ទៅតាមករណីជាក់ស្តែង។

## មាត្រា១៦៤
## គណៈកម្មការផែនការសេដ្ឋកិច្ច

១. សមាជិកគណៈកម្មការផែនការសេដ្ឋកិច្ចត្រូវមានគុណវុឌ្ឍិសមស្របរួមមានគុណវុឌ្ឍិ ដែលទាក់ទងនឹងដំណើរការទាញយករ៉ែ ការគ្រប់គ្រងសកម្មភាពធនធានរ៉ែ ពាណិជ្ជកម្មអន្តរជាតិ ឬសេដ្ឋកិច្ចអន្តរជាតិ។ ក្រុមប្រឹក្សាត្រូវខិតខំធានាឱ្យបានថា សមាជិកភាពនៅក្នុងគណៈកម្មការនេះ ឆ្លុះបញ្ចាំងនូវរាល់គុណវុឌ្ឍិដែលសមស្របទាំងអស់។ សមាសភាពគណៈកម្មការត្រូវមានសមាជិកយ៉ាងតិចពីររូបមកពីរដ្ឋកំពុងអភិវឌ្ឍន៍ ដែលការនាំចេញប្រភេទរ៉ែយកចេញពីតំបន់របស់រដ្ឋពួកគេ មានចំណែកធំធេងទៅលើសេដ្ឋកិច្ចរបស់រដ្ឋពួកគេ។

២. គណៈកម្មការនេះត្រូវ៖

(ក) លើកសំណើស្តីពីវិធានការដែលត្រូវអនុវត្តសេចក្តីសម្រេចចិត្តទាក់ទងនឹងសកម្មភាព នៅក្នុងតំបន់បាតសមុទ្រអន្តរជាតិដែលត្រូវបានសម្រេចឡើងស្របតាមអនុសញ្ញានេះ ដោយផ្អែកលើសំណើរបស់ក្រុមប្រឹក្សា។

(ខ) ត្រួតពិនិត្យនិន្នាការ និងកត្តាដែលប៉ះពាល់ដល់ការផ្គត់ផ្គង់តម្រូវការ និងតម្លៃរ៉ែ ដែលអាចនឹងទាញចេញពីតំបន់បាតសមុទ្រអន្តរជាតិ ដោយគិតគូរដល់ផលប្រយោជន៍របស់ប្រទេសនាំចូល និងប្រទេសនាំចេញ ជាពិសេសផលប្រយោជន៍របស់រដ្ឋកំពុងអភិវឌ្ឍន៍។

(គ) ត្រួតពិនិត្យស្ថានការណ៍ដែលអាចនាំឱ្យកើតមានឥទ្ធិពលអវិជ្ជមាន ដូចមានចែងនៅក្នុងមាត្រា១៥០ កថាខណ្ឌ(ជ) ដែលរដ្ឋភាគីពាក់ព័ន្ធមួយ ឬច្រើនបានលើកមកឱ្យ ពិចារណា និងផ្តល់អនុសាសន៍ សមស្របជូនក្រុមប្រឹក្សា។

(ឃ) ស្នើក្រុមប្រឹក្សាឱ្យបញ្ជូនទៅកាន់សន្និបាតដូចមានចែងក្នុងមាត្រា១៥១ កថាខណ្ឌទី១០ នូវប្រព័ន្ធផ្តល់សំណង ឬវិធានការផ្តល់ជំនួយសម្របសម្រួលផ្នែកសេដ្ឋកិច្ចផ្សេងៗទៀតសម្រាប់រដ្ឋកំពុងអភិវឌ្ឍន៍ ដែលបានរងគ្រោះពីឥទ្ធិពលអវិជ្ជមានដែលបណ្តាលមកពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។ គណៈកម្មការត្រូវផ្តល់ជូនក្រុមប្រឹក្សានូវអនុសាសន៍ដែលចាំបាច់សម្រាប់ការអនុវត្តប្រព័ន្ធ ឬវិធានការផ្សេងៗដែលត្រូវបានអនុម័តដោយសន្និបាតនៅក្នុងករណីជាក់ស្តែងនីមួយៗ។

## មាត្រា១៦៥
## គណៈកម្មការនីតិកម្មនិងបច្ចេកទេស

១. សមាជិកគណៈកម្មការនីតិកម្មនិងបច្ចេកទេសត្រូវមានគុណវុឌ្ឍិសមស្របរួមមានគុណវុឌ្ឍិ ដែលទាក់ទងនឹងដំណើរការរុករក និងធ្វើអាជីវកម្មរ៉ែ ដំណើការកែច្នៃធនធានរ៉ែ សាគរសាស្ត្រ ការការពារបរិស្ថាន សមុទ្រ ឬបញ្ហាសេដ្ឋកិច្ច បញ្ហាច្បាប់ដែលទាក់ទងនឹងការទាញយករ៉ែនៅក្នុងមហាសមុទ្រ និងជំនាញឯកទេសពាក់ព័ន្ធផ្សេងៗ។ ក្រុមប្រឹក្សាត្រូវខិតខំធានាឱ្យបានថា សមាជិកភាពនៅក្នុងគណៈកម្មការ នេះឆ្លុះបញ្ចាំងនូវរាល់គុណវុឌ្ឍិដែលសមស្របទាំងអស់។

២. គណៈកម្មការនេះត្រូវ៖

(ក) ផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការអនុវត្តមុខងាររបស់អាជ្ញាធរ ដោយផ្អែកលើសំណើរបស់ក្រុមប្រឹក្សា។

(ខ) ពិនិត្យផែនការការងារផ្លូវការជាលាយលក្ខណ៍អក្សរសម្រាប់សកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ស្របតាមមាត្រា១៥៣ កថាខណ្ឌទី៣ និងដាក់អនុសាសន៍សមស្របទៅកាន់ក្រុមប្រឹក្សា។ អនុសាសន៍របស់គណៈកម្មការត្រូវផ្អែកទៅលើមូលដ្ឋានដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៣តែប៉ុណ្ណោះ ហើយគណៈកម្មការត្រូវរាយការណ៍អំពីមូលដ្ឋានទាំងនេះជូនទៅក្រុមប្រឹក្សាឱ្យបានពេញលេញ។

(គ) ត្រួតពិនិត្យសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិឱ្យបានសមស្រប ដោយពិគ្រោះយោបល់ និងសហការជាមួយអង្គភាពដែលអនុវត្តសកម្មភាពទាំងនោះ ឬជាមួយរដ្ឋដែលពាក់ព័ន្ធ ដោយផ្អែកលើសំណើរបស់ក្រុមប្រឹក្សារួចរាយការណ៍អំពីលទ្ធផលត្រួតពិនិត្យជូនទៅក្រុមប្រឹក្សា។

(ឃ) រៀបចំការវាយតម្លៃលើបញ្ហាបរិស្ថានដែលកើតចេញពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

(ង) ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាស្តីពីការការពារបរិស្ថានសមុទ្រ ក្រោយពីបានពិចារណាទៅលើយោបល់របស់អ្នកជំនាញដែលមានការទទួលស្គាល់នៅក្នុងវិស័យនេះ។

(ច) បង្កើត និងដាក់ជូនក្រុមប្រឹក្សានូវវិធាន បទបញ្ជា និងនីតិវិធីដូចមានចែងក្នុងមាត្រា១៦២ កថាខណ្ឌទី២(ណ) ក្រោយពីបានពិចារណាលើរាល់កត្តាពាក់ព័ន្ធទាំងអស់ រួមមានដូចជាការវាយតម្លៃបញ្ហាបរិស្ថានដែលកើតចេញពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

(ឆ) ត្រួតពិនិត្យវិធាន បទបញ្ជា និងនីតិវិធីជាប្រចាំ ហើយផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាអំពីការធ្វើវិសោធនកម្មលើវិធាន បទបញ្ជា និងនីតិវិធីទាំងនោះ ទៅតាមការដែលខ្លួនយល់ថាចាំបាច់ ឬចង់បាន។

(ជ) ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាពាក់ព័ន្ធនឹងការបង្កើតកម្មវិធីត្រួតពិនិត្យតាមដានមួយដើម្បីអង្កេតវាស់វែង វាយតម្លៃ និងវិភាគហានិភ័យ ឬឥទ្ធិពលនៃការបំពុល បរិស្ថានសមុទ្រដែលកើតចេញពីសកម្មភាពនៅក្នុងតំបន់បាទសមុទ្រអន្តរជាតិដោយប្រើប្រាស់វិធីសាស្ត្រ វិទ្យាសាស្ត្រ ដែលមានការទទួលស្គាល់ជាទៀងទាត់ ដើម្បីធានាថា បទប្បញ្ញត្តិដែលមានស្រាប់មានចំនួនគ្រប់គ្រាន់ ហើយត្រូវបានអនុវត្ត និងសម្របសម្រួលការអនុវត្តកម្មវិធីត្រួតពិនិត្យតាមដាន ក្រោយពីទទួលបានការអនុម័តពីក្រុមប្រឹក្សា។

(ឈ) ផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាផ្តួចផ្តើមដាក់ពាក្យបណ្តឹង ទៅកាន់សភាវិវាទបាតសមុទ្រជំនួសមុខឱ្យអាជ្ញាធរដោយអនុលោមតាមជំពូកនេះ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធ ក្រោយពីបានពិចារណាយ៉ាងល្អិតល្អន់ទៅលើមាត្រា១៨៧ ។

(ញ) ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាពាក់ព័ន្ធនឹងវិធានការដែលត្រូវចាត់ឡើង ដោយផ្អែកលើសេចក្តីសម្រេចរបស់សភាវិវាទបាតសមុទ្រ នៅក្នុងដំណើរការជំនុំជម្រះលើពាក្យបណ្តឹងដែលដាក់ឡើងស្របតាមកថាខណ្ឌរង (ឈ) ។

(ដ) ផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាចេញដីកាបន្ទាន់ ដែលអាចមានរួមទាំងដីកាផ្អាក ឬកែតម្រូវប្រតិបត្តិការ ដើម្បីបង្ការគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះបរិស្ថានសមុទ្រ ដែលកើតចេញពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។ ក្រុមប្រឹក្សាត្រូវអនុម័តលើអនុសាសន៍ទាំងនេះ ដោយផ្អែកលើគោលការណ៍អាទិភាព។

(ឋ) ផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាមិនផ្តល់ការអនុម័តលើតំបន់ធ្វើអាជីវកម្ម ដោយក្រុមហ៊ុនម៉ៅការ ឬសហគ្រាស ក្នុងករណីដែលមានភស្តុតាងច្បាស់លាស់បង្ហាញពីហានិភ័យនៃគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះ បរិស្ថានសមុទ្រ។

(ឌ) ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាពាក់ព័ន្ធនឹងការដឹកនាំ និងត្រួតពិនិត្យបុគ្គលិកក្រុមអធិការកិច្ចដែលត្រួតពិនិត្យសកម្មភាពនៅក្នុងតំបន់បាទសមុទ្រ ដើម្បីកំណត់អំពីការគោរពតាមផ្នែកនេះ វិធាន បទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរ និងលក្ខខណ្ឌក្នុងកិច្ចសន្យាជាមួយអាជ្ញាធរនេះ។

(ឍ) គណនាកម្រិតផលិតកម្មអតិបរមា និងចេញលិខិតអនុញ្ញាតផលិតកម្មក្នុងនាមអាជ្ញាធរ ស្របតាមមាត្រា១៥១ កថាខណ្ឌទី២ ដល់កថាខណ្ឌទី៧ ក្រោយពីក្រុមប្រឹក្សាបានជ្រើសរើសពីក្នុងចំណោមបេក្ខជន ស្នើសុំលិខិតអនុញ្ញាតផលិតកម្ម ស្របតាមឧបសម្ព័ន្ធ៣ មាត្រា៧ ។

៣. នៅពេលមានសំណើពីរដ្ឋភាគី ឬភាគីផ្សេងទៀតដែលពាក់ព័ន្ធសមាជិកគណៈកម្មការត្រូវមានតំណាងមួយរូបរបស់រដ្ឋ ឬភាគីពាក់ព័ន្ធនោះអមដំណើរជាមួយខ្លួន នៅពេលកំពុងអនុវត្តមុខងារត្រួតពិនិត្យ និងអង្កេតរបស់ខ្លួន។

## អនុផ្នែកទី៤
## លេខាធិការដ្ឋាន
### មាត្រា១៦៦
### លេខាធិការដ្ឋាន

១. សមាសភាពលេខាធិការដ្ឋានរបស់អាជ្ញាធរ រួមមានអគ្គលេខាធិការមួយរូបនិងបុគ្គលិកផ្សេងៗ ដែលអាជ្ញាធរនេះ ត្រូវការ។

២. អគ្គលេខាធិការត្រូវបានជ្រើសរើសពីក្នុងចំណោមបេក្ខជន ដែលស្នើឡើងដោយក្រុមប្រឹក្សា តាមរយៈការបោះឆ្នោតដោយសន្និបាតសម្រាប់រយៈពេលបួនឆ្នាំ និងអាចឈរឈ្មោះបោះឆ្នោតជាថ្មី។

៣. អគ្គលេខាធិការ គឺជាប្រធានមន្ត្រីរដ្ឋបាលនៃអាជ្ញាធរ និងត្រូវដើរតួនាទី ក្នុងនាមជាប្រធានមន្ត្រីរដ្ឋបាលនៅក្នុងរាល់កិច្ចប្រជុំរបស់សន្និបាតក្រុមប្រឹក្សា និងអង្គការចំណុះផ្សេងៗ ហើយត្រូវបំពេញមុខងាររដ្ឋបាលផ្សេងៗទៀត ដែលអង្គការចំណុះទាំងនេះបានផ្តល់ទៅឱ្យអគ្គលេខាធិការ។

៤. អគ្គលេខាធិការត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីការងាររបស់អាជ្ញាធរជូនសន្និបាតបាតសមុទ្រអន្តរជាតិ។

## មាត្រា១៦៧
## បុគ្គលិករបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

១. បុគ្គលិកអាជ្ញាធរ រួមមានបុគ្គលិកផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស និងបុគ្គលិកមានគុណវុឌ្ឍិដទៃទៀត ដែលត្រូវការ ដើម្បីអនុវត្តមុខងាររដ្ឋបាលរបស់អាជ្ញាធរនេះ។

២. ការពិចារណាខ្ពស់បំផុតនៅក្នុងការជ្រើសរើស និងការផ្តល់ការងារដល់បុគ្គលិកនិងក្នុងការកំណត់លក្ខខណ្ឌការងារ ជាកត្តាចាំបាច់ក្នុងការធានានូវការទទួលបានស្តង់ដាប្រសិទ្ធភាព សមត្ថភាព និងវិជ្ជាជីវៈខ្ពស់បំផុត។ នៅពេលធ្វើការពិចារណាលើបញ្ហានេះ ត្រូវយកចិត្តទុកដាក់សមស្របទៅលើសារៈសំខាន់នៃការជ្រើសរើសបុគ្គលិកដែលផ្អែកលើមូលដ្ឋានភូមិសាស្ត្រទូលំទូលាយបំផុត។

៣. បុគ្គលិកត្រូវទទួលបានការតែងតាំងដោយអគ្គលេខាធិការ។ លក្ខខណ្ឌស្តីពីការតែងតាំង ការផ្តល់ភាគលាភ និងការបណ្តេញបុគ្គលិកចេញពីតំណែង ត្រូវឡើងស្របតាមវិធាន បទបញ្ញា និងនីតិវិធីរបស់អាជ្ញាធរ។

## មាត្រា១៦៨
## ចរិតលក្ខណៈជាអន្តរជាតិនៃលេខាធិការដ្ឋាន

១. នៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន អគ្គលេខាធិការ និងបុគ្គលិកមិនត្រូវស្វែងរកឬទទួលយកសេចក្តីណែនាំពីរដ្ឋាភិបាលណាមួយ ឬពីប្រភពផ្សេងក្រៅពីអាជ្ញាធរឡើយ។ ពួកគេមិនត្រូវអនុវត្តសកម្មភាពណាមួយដែលអាចនាំឱ្យប៉ះពាល់ដល់ឋានៈរបស់ខ្លួន ក្នុងនាមជាមន្ត្រីអន្តរជាតិទទួលបន្ទុកតែចំពោះមុខអាជ្ញាធរ។ រដ្ឋភាគីនីមួយៗ យល់ព្រមគោរពចរិតលក្ខណៈជាអន្តរជាតិទាំងស្រុងចំពោះការទទួលខុសត្រូវរបស់អគ្គលេខាធិការ និងបុគ្គលិក ហើយមិនត្រូវព្យាយាមជ្រៀតជ្រែកការបំពេញភារកិច្ចទទួលខុសត្រូវរបស់ពួកគេឡើយ។ រាល់ករណីបំពានលើការទទួលខុសត្រូវណាមួយរបស់បុគ្គលិក ត្រូវបញ្ជូនទៅសាលាក្តីរដ្ឋបាលដែលសមស្រប ដូចមានចែងនៅក្នុងវិធាន បទបញ្ញា និងនីតិវិធីរបស់រាជ្ញាធរ។

២. អគ្គលេខាធិការ និងបុគ្គលិកគ្មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុនៅក្នុងសកម្មភាពណាមួយ ដែលទាក់ទងនឹងការរុករក និងការធ្វើអាជីវកម្មធនធាននៅក្នុងតំបន់បាតសមុទ្រអន្តរជាតិនោះឡើយ។ ដោយផ្អែកលើការទទួលខុសត្រូវរបស់បុគ្គលិកចំពោះអាជ្ញាធរនេះ បុគ្គលិកមិនត្រូវលាតត្រដាងនូវការសម្ងាត់ផ្នែកឧស្សាហកម្ម ទិន្នន័យស៊ីពីកម្មសិទ្ធិដែលត្រូវបានផ្ទេរទៅឱ្យអាជ្ញាធរនេះ ស្របតាមឧបសម្ព័ន្ធទី៣ មាត្រា១៤ ឬព័ត៌មានសម្ងាត់ផ្សេងៗទៀត ដែលពួកគេបានដឹងតាមរយៈការបំពេញភារកិច្ចជូនអាជ្ញាធរនេះឡើយ សូម្បីតែនៅក្រោយពេលដែលពួកគេឈប់ធ្វើការ។

៣. ករណីបំពានលើកាតព្វកិច្ចរបស់បុគ្គលិកអាជ្ញាធរនេះដូចមានចែងនៅក្នុងកថាខណ្ឌទី២ ត្រូវបញ្ជូនពាក្យបណ្តឹងចំពោះបុគ្គលិកដែលពាក់ព័ន្ធរូបនោះទៅកាន់សាលាក្តី ដែលកំណត់ដោយវិធាន បទបញ្ញា និងនីតិវិធីរបស់អាជ្ញាធរនេះ ដោយផ្អែកលើសំណើរបស់រដ្ឋភាគីដែលរងផលប៉ះពាល់ពីការបំពាននោះ ឬសំណើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលគាំទ្រដោយរដ្ឋភាគីមួយ ដូចមានចែងក្នុងមាត្រា១៥៣ កថាខណ្ឌទី២(ខ) ដែលរងផលប៉ះពាល់ពីការបំពាននោះ។ ភាគីដែលរងផលប៉ះពាល់មានសិទ្ធិចូលរួមក្នុងដំណើរការជំនុំជម្រះបាន។ ប្រសិនបើសាលាក្តីផ្តល់អនុសាសន៍អគ្គលេខាធិការត្រូវបណ្តេញបុគ្គលិកដែលពាក់ព័ន្ធរូបនោះ ចេញពីតំណែង។

៤. វិធាន បទបញ្ញា និងនីតិវិធីរបស់អាជ្ញាធរនេះ ក៏ត្រូវរួមមានទាំងបទប្បញ្ញត្តិដែលចាំបាច់ សម្រាប់អនុវត្តមាត្រានេះផងដែរ។

## មាត្រា១៦៩

## ការពិគ្រោះយោបល់និងកិច្ចសហការជាមួយអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល

១. ដោយមានការអនុម័តពីក្រុមប្រឹក្សា អគ្គលេខាធិការត្រូវរៀបចំឱ្យបានសមស្របនូវការពិគ្រោះយោបល់ និងកិច្ចសហការជាមួយអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដែលទទួលស្គាល់ដោយ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិស្ដីពីបញ្ហាដែលស្ថិតក្នុងសមត្ថកិច្ចរបស់អាជ្ញាធរនេះ ។

២. អង្គការដែលអគ្គលេខាធិការបានចុះកិច្ចព្រមព្រៀងជាមួយខ្លួនក្រោមកថាខណ្ឌទី១ខាងលើ អាចចាត់តាំងតំណាងទៅចូលរួមកិច្ចប្រជុំរបស់អង្គការចំណុះនៃអាជ្ញាធរក្នុងនាមជាអ្នកសង្កេតការណ៍ ស្របតាមវិធានស្ដីពីនីតិវិធីរបស់អង្គការចំណុះទាំងនេះ។ នីតិវិធីនឹងត្រូវបង្កើតឡើង ដើម្បីស្នើសុំយោបល់ពីអង្គការចំណុះនៅក្នុងករណីសមស្រប។

៣. អគ្គលេខាធិការអាចចែកចាយជូនបណ្ដារដ្ឋភាគីនូវរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលអង្គការក្រៅរដ្ឋាភិបាលដូចមានចែងនៅក្នុងកថាខណ្ឌទី១ បានដាក់ជូនស្ដីពីកម្មវត្ថុដែលពួកគេមានសមត្ថភាព ពិសេស និងដែលទាក់ទងនឹងការងាររបស់អាជ្ញាធរនេះ។

## អនុផ្នែកទី៥

## សហគ្រាស

## មាត្រា១៧០

## សហគ្រាស

១. សហគ្រាស ជាអង្គការចំណុះរបស់អាជ្ញាធរ ដែលត្រូវអនុវត្តសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ដោយផ្ទាល់ ស្របតាមមាត្រា១៥៣ កថាខណ្ឌទី២(ក) ព្រមទាំងការដឹកជញ្ជូន ការកែច្នៃ និងធ្វើទីផ្សាររ៉ែ ដែលទាញចេញពីតំបន់នេះ។

២. នៅក្នុងក្របខ័ណ្ឌនៃនិតិបុគ្គលអន្តរជាតិរបស់អាជ្ញាធរនេះ សហគ្រាសត្រូវមានភាពជាតំណាងស្របច្បាប់ ដូចមានចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ស្របតាមឧបសម្ព័ន្ធ៤ ផងដែរ។ សហគ្រាសត្រូវធ្វើសកម្មភាពស្របតាម អនុសញ្ញានេះ និងវិធាន បទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរនេះ ព្រមទាំងគោលនយោបាយទូទៅ ដែលត្រូវបានសន្និបាត បង្កើតឡើង និងត្រូវគោរពតាមសារាចរណ៍ណែនាំ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សា។

៣. សហគ្រាសមានទីស្នាក់ការមេ ស្ថិតនៅទីស្នាក់ការរបស់អាជ្ញាធរនេះ។

៤. សហគ្រាស ត្រូវផ្ដល់ជូននូវមូលនិធិដែលសហគ្រាសត្រូវការ ដើម្បីអនុវត្តមុខងាររបស់ខ្លួន ស្របតាម មាត្រា១៧៣ កថាខណ្ឌទី២ និងឧបសម្ព័ន្ធ៤ មាត្រា១១ ហើយត្រូវទទួលបានបច្ចេកវិទ្យា ដូចមានចែងនៅក្នុង មាត្រា ១៤៤ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងអនុសញ្ញានេះ។

## អនុផ្នែកទី៦
## ការរៀបចំហិរញ្ញវត្ថុរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

### មាត្រា១៧១
### មូលនិធិរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

ប្រភពនៃមូលនិធិរបស់អាជ្ញាធររួមមានៈ

(ក) ប្រាក់វិភាគទានដែលកំណត់ឱ្យសមាជិកអាជ្ញាធរនេះត្រូវចូលរួមបង់ តាមមាត្រា១៦០ កថាខណ្ឌទី២ (ង)។

(ខ) មូលនិធិដែលអាជ្ញាធរនេះទទួលបានតាមឧបសម្ព័ន្ធទី៣ មាត្រា១៣ ពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ។

(គ) មូលនិធិដែលផ្ទេរមកពីសហគ្រាសស្របតាមឧបសម្ព័ន្ធទី៤ មាត្រា១០ ។

(ឃ) មូលនិធិកម្ចីតាមមាត្រា១៧៤ ។

(ង) ប្រាក់វិភាគទានស្ម័គ្រចិត្តដែលបង់ដោយសមាជិក ឬអង្គភាពផ្សេងៗ។

(ច) ប្រាក់បង់ចូលមូលនិធិសំណង ស្របតាមមាត្រា១៥១ កថាខណ្ឌទី១០ ដែលគណៈកម្មការ ផែនការសេដ្ឋកិច្ចនឹងផ្តល់អនុសាសន៍អំពីប្រភពទឹកប្រាក់នេះ។

### មាត្រា១៧២
### ថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

អគ្គលេខាធិការត្រូវរៀបចំសេចក្តីព្រាងសំណើថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរនេះ និងដាក់ជូនក្រុមប្រឹក្សា។ ក្រុមប្រឹក្សាត្រូវពិនិត្យពិចារណាលើសំណើថវិកាប្រចាំឆ្នាំនិងដាក់ជូនសន្និបាត ដោយអមជាមួយនឹងអនុសាសន៍អំពីសំណើនេះ។ សន្និបាតត្រូវពិចារណា និងអនុម័តលើសំណើថវិកាប្រចាំឆ្នាំដោយអនុលោមតាមមាត្រា១៦០ កថាខណ្ឌទី២ (ជ)។

### មាត្រា១៧៣
### ការចំណាយរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

១. ប្រាក់វិភាគទានដូចមានចែងក្នុងមាត្រា១៧១ កថាខណ្ឌរង (ក) ត្រូវបង់ចូលក្នុងគណនីពិសេសសម្រាប់បំពេញការចំណាយផ្នែកហិរញ្ញវត្ថុរបស់អាជ្ញាធរ រហូតដល់ពេលដែលអាជ្ញាធរ មានមូលនិធិគ្រប់គ្រាន់ពីប្រភពផ្សេងៗទៀត ដើម្បីបំពេញការចំណាយទាំងនោះ។

២. ការចំណាយផ្នែករដ្ឋបាលរបស់អាជ្ញាធរ ជាអាទិភាពចម្បងសម្រាប់ការប្រើប្រាស់មូលនិធិរបស់អាជ្ញាធរ។ លើកលែងតែប្រាក់វិភាគទានដែលបានកំណត់ និងមានចែងក្នុងមាត្រា១៧១ កថាខណ្ឌរង(ក) ចេញ មូលនិធិដែលនៅសល់ក្រោយពីការទូទាត់ការចំណាយផ្នែករដ្ឋបាល ត្រូវ ៖

(ក) បែងចែកស្របតាមមាត្រា១៤០ និងមាត្រា ១៦០ កថាខណ្ឌទី ២(ឆ)។

(ខ) ប្រើប្រាស់ដើម្បីផ្តល់ឱ្យសហគ្រាសនូវមូលនិធិស្របតាមមាត្រា១៧០ កថាខណ្ឌទី៤។

(គ) ប្រើប្រាស់ដើម្បីផ្តល់សំណងជូនរដ្ឋកំពុងអភិវឌ្ឍន៍ស្របតាមមាត្រា១៥១ កថាខណ្ឌទី១០ និងមាត្រា១៦០ កថាខណ្ឌទី២ (ឋ)។

## មាត្រា១៧៤
## អំណាចខ្ចីប្រាក់របស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

១. អាជ្ញាធរមានអំណាចក្នុងការខ្ចីប្រាក់។

២. សន្និបាតត្រូវកំណត់កម្រិតលើអំណាចខ្ចីប្រាក់របស់អាជ្ញាធរនៅក្នុងបទប្បញ្ញត្តិស្តីពីហិរញ្ញវត្ថុ ដែលអនុម័តស្របតាមមាត្រា១៦០ មាត្រា២ (ច)។

៣. ក្រុមប្រឹក្សាត្រូវអនុវត្តអំណាចខ្ចីប្រាក់របស់អាជ្ញាធរ។

៤. រដ្ឋភាគីមិនទទួលខុសត្រូវលើបំណុលរបស់អាជ្ញាធរទេ។

## មាត្រា១៧៥
## សវនកម្មប្រចាំឆ្នាំ

បញ្ជី សៀវភៅ និងគណនីរបស់អាជ្ញាធរ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវធ្វើសវនកម្មជារៀងរាល់ឆ្នាំដោយសវនករឯករាជ្យដែលទទួលបានការតែងតាំងដោយសន្និបាត។

## អនុផ្នែកទី៧
## លក្ខន្តិកៈគតិយុត្តិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

## មាត្រា១៧៦
## លក្ខន្តិកៈគតិយុត្តិ

អាជ្ញាធរ ត្រូវមានលក្ខណៈជានិតិបុគ្គលអន្តរជាតិ និងសមត្ថភាពស្របច្បាប់ដែលចាំបាច់ដើម្បីអនុវត្តមុខងាររបស់ខ្លួន និងសម្រេចគោលបំណងរបស់ខ្លួន។

## មាត្រា១៧៧
## បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ

ដើម្បីអាចឱ្យអាជ្ញាធរអនុវត្តនូវមុខងាររបស់ខ្លួនបាន អាជ្ញាធរត្រូវមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៅក្នុងដែនដីនៃរដ្ឋភាគីនីមួយៗ ដូចមានចែងនៅក្នុងអនុផ្នែកនេះ។ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលទាក់ទងនឹងសហគ្រាសជាបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៤ មាត្រា១៣។

## មាត្រា១៧៨
## អភ័យឯកសិទ្ធិរួចផុតពីដំណើរការក្តី

អាជ្ញាធរ អចលនទ្រព្យ និងទ្រព្យសកម្មរបស់របស់ខ្លួន ត្រូវទទួលបាននូវអភ័យឯកសិទ្ធិរួចផុតពីដំណើរការក្តីលើកលែងតែអាជ្ញាធរបានបញ្ជាក់អំពីការបោះបង់អភ័យឯកសិទ្ធិនេះក្នុងករណីពិសេសណាមួយ។

## មាត្រា១៧៩
## អភ័យឯកសិទ្ធិរួចពីការឆែកឆេរនិងរួចពីការរឹបអូសគ្រប់រូបភាព

អចលនទ្រព្យ និងទ្រព្យសកម្មរបស់អាជ្ញាធរ ទោះមានទីតាំងនៅកន្លែងក្តី ឬកាន់កាប់ដោយជនណាក្តី ត្រូវទទួលបានអភ័យឯកសិទ្ធិរួចផុតពីការឆែកឆេរ ការទាមទារ ការដកហូត អស្សាមិករណ៍ ឬការរឹបអូសក្នុងទម្រង់ណាមួយដោយសកម្មភាពផ្នែកនីតិប្រតិបត្តិ ឬនីតិប្បញ្ញត្តិឡើយ។

### មាត្រា១៨០
### ការលើកលែងពីការដាក់កំហិត បទប្បញ្ញត្តិ ការគ្រប់គ្រង និងការបង្ខាក់

អចលនទ្រព្យ និងទ្រព្យសកម្មរបស់អាជ្ញាធរ ត្រូវលើកលែងពីការដាក់កំហិត បទប្បញ្ញត្តិ ការគ្រប់គ្រង និងការបង្ខាក់ក្នុងទម្រង់នានា។

### មាត្រា១៨១
### បណ្ណាសារ និងការផ្សព្វផ្សាយជាផ្លូវការរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

១. បណ្ណាសាររបស់អាជ្ញាធរ ទោះមានទីតាំងនៅកន្លែងណាក្តី ត្រូវរួចផុតពីការបំពាន។

២. ទិន្នន័យជាកម្មសិទ្ធិ អាថ៌កំបាំងផ្នែកឧស្សាហកម្ម ឬព័ត៌មានស្រដៀងគ្នានេះ និងបញ្ជីបុគ្គលិក មិនត្រូវរក្សាទុកនៅក្នុងបណ្ណាសារ ដែលបើកឱ្យមានការចូលពិនិត្យជាសាធារណៈនោះឡើយ។

៣. ទាក់ទងនឹងការផ្សព្វផ្សាយផ្លូវការរបស់ខ្លួន អាជ្ញាធរត្រូវទទួលបានការព្រមព្រៀងពីរដ្ឋភាគី នីមួយៗមិនតិចជាងអ្វីដែលបានព្រមព្រៀងដោយរដ្ឋនោះ ចំពោះអង្គការអន្តរជាតិដទៃទៀតឡើយ។

### មាត្រា១៨២
### បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់បុគ្គលមួយ
### ចំនួនដែលទាក់ទងជាមួយនឹងអាជ្ញាធរបាទសមុទ្រអន្តរជាតិ

តំណាងរបស់រដ្ឋភាគីដែលអញ្ជើញទៅចូលរួមកិច្ចប្រជុំមហាសន្និបាត កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ឬអង្គការចំណុះរបស់មហាសន្និបាត ឬអង្គការចំណុះរបស់ក្រុមប្រឹក្សា អគ្គលេខាធិការ និងបុគ្គលិករបស់អាជ្ញាធរ ដែលប្រារព្ធធ្វើនៅក្នុងបូរណភាពដែនដីរបស់រដ្ឋភាគី ត្រូវទទួលបាន ៖

(ក) អភ័យឯកសិទ្ធិពីដំណើរការក្តីទាក់ទងទៅនឹងសកម្មភាពដែលពួកគេអនុវត្ត ដើម្បីបំពេញមុខងាររបស់ខ្លួន លើកលែងតែក្នុងករណីដែលរដ្ឋដែលខ្លួនធ្វើជាតំណាង ឬអាជ្ញាធរ បញ្ជាក់អំពីការបោះបង់អភ័យឯកសិទ្ធិនេះ ក្នុងករណីពិសេសណាមួយ។

(ខ) ប្រសិនបើពួកគេមិនមែនជាពលរដ្ឋរបស់រដ្ឋភាគីនោះ ពួកគេក៏ទទួលបានការលើកលែងឱ្យរួចផុតដូចគ្នានេះដែរ ពីការដាក់កំហិតផ្នែកអន្តោប្រវេសន៍ លក្ខខណ្ឌចុះបញ្ជីជនបរទេស និងកាតព្វកិច្ចផ្នែកសេវាកម្មជាតិ លក្ខខណ្ឌសម្របសម្រួលដូចគ្នាលើការដាក់កំហិតទៅវិញទៅមក និងការផ្លាស់ប្តូរដូចគ្នាពាក់ព័ន្ធនឹងការសម្របសម្រួលក្នុងការធ្វើដំណើរដែលបានផ្តល់ដោយរដ្ឋនោះ ទៅតំណាងមន្ត្រី និងបុគ្គលិក ស្របតាមឋានៈប្រហាក់ប្រហែលនៃបណ្តារដ្ឋភាគីផ្សេងទៀត។

### មាត្រា១៨៣
### ការលើកលែងឱ្យរួចផុតពីពន្ធនិងពន្ធនាំចូល

១. នៅក្នុងវិសាលភាពនៃសកម្មភាពផ្លូវការរបស់ខ្លួន អាជ្ញាធរ ទ្រព្យសកម្ម និងអចលនទ្រព្យ ចំណូល និងប្រតិបត្តិការ និងកិច្ចការជំនួយរបស់ខ្លួនដែលអនុញ្ញាតក្រោមអនុសញ្ញានេះ ត្រូវលើកលែងពីពន្ធនាំចូលទាំងអស់ ហើយទំនិញដែលនាំចូល ឬនាំចេញសម្រាប់ការប្រើប្រាស់ជាផ្លូវការរបស់ខ្លួនរួច ត្រូវលើកលែងពន្ធទាំងអស់។ អាជ្ញាធរ មិនត្រូវទាមទារការរួចពន្ធដែលមិនច្រើនជាងថ្លៃសម្រាប់សេវាកម្ម ដែលផ្តល់ជូននោះឡើយ។

២. នៅពេលទិញទំនិញ ឬសេវាកម្មមានតម្លៃខ្ពស់ដែលចាំបាច់សម្រាប់សកម្មភាពជាផ្លូវការរបស់អាជ្ញាធរ ដែលបានធ្វើឡើងដោយ ឬក្នុងនាមអាជ្ញាធរ ហើយនៅពេលតម្លៃទំនិញ ឬសេវាកម្មនោះ មាននូវពន្ធ ឬពន្ធគយ បណ្ដារដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីផ្តល់ការលើកលែងពន្ធឱ្យ ឬពន្ធគយទាំងនោះ ឬផ្តល់នូវសំណងទៅអាជ្ញាធរវិញ។ ទំនិញដែលបាននាំចូល ឬទិញក្រោមការលើកលែងឱ្យពន្ធដូចមានចែង ក្នុងមាត្រានេះ មិនត្រូវលក់ ឬក៏ផ្ទេរចេញ នៅក្នុងដែនដីរបស់រដ្ឋភាគីដែលបានផ្តល់នូវការលើកលែងនោះ វៀលែងតែមាន លក្ខខណ្ឌដែលរដ្ឋភាគីនោះបានព្រមព្រៀង។

៣. រដ្ឋភាគីមិនត្រូវដាក់បន្ទុកពន្ធណាមួយទៅលើ ឬទាក់ទងនឹងប្រាក់បៀវត្ស និងប្រាក់ឈ្នួល ឬទម្រង់ប្រាក់ផ្សេងទៀតដែលអាជ្ញាធរទូទាត់ជូនអគ្គលេខាធិការ និងបុគ្គលិករបស់អាជ្ញាធរ ក៏ដូចជាជូនអ្នកជំនាញ ដែលអនុវត្តបេសកកម្មសម្រាប់អាជ្ញាធរ ដែលមិនមែនជាពលរដ្ឋរបស់រដ្ឋភាគីនោះ។

## **អនុផ្នែកទី៨**

## **ការព្យួរការអនុវត្តសិទ្ធិនិងឯកសិទ្ធិរបស់សមាជិក**

### មាត្រា១៨៤

### **ការព្យួរការអនុវត្តសិទ្ធិបោះឆ្នោត**

រដ្ឋភាគីដែលនៅជំពាក់មិនទាន់បានបង់ប្រាក់វិភាគទានហិរញ្ញវត្ថុរបស់ខ្លួនជូនដល់អាជ្ញាធរ មិនត្រូវមានសិទ្ធិបោះឆ្នោតទេ ប្រសិនបើចំនួនទឹកប្រាក់ដែលនៅជំពាក់នោះស្មើនឹង ឬលើសពីចំនួនទឹកប្រាក់វិភាគទានដែលខ្លួនត្រូវបង់សម្រាប់រយៈពេលពេញពីរឆ្នាំមុន។ ទោះបីជាយ៉ាងណាក៏ដោយ មហាសន្និបាតអាចអនុញ្ញាតឱ្យសមាជិកនោះបោះឆ្នោតបាន ប្រសិនបើខ្លួនគិតថា ការខកខានក្នុងការបង់វិភាគទាននោះ បណ្តាលមកពីស្ថានភាពដែលហួសពីការគ្រប់គ្រងរបស់សមាជិកនោះ។

### មាត្រា១៨៥

### **ការព្យួរការអនុវត្តសិទ្ធិនិងអភ័យឯកសិទ្ធិសមាជិកភាព**

១. រដ្ឋភាគីដែលបានបំពានយ៉ាងធ្ងន់ធ្ងរ ម្តងហើយម្តងទៀតលើបទប្បញ្ញត្តិនៃជំពូកនេះ ត្រូវព្យួរ ការអនុវត្តសិទ្ធិ និងអភ័យឯកសិទ្ធិសមាជិកភាពដោយមហាសន្និបាត ដោយផ្អែកលើអនុសាសន៍របស់ក្រុមប្រឹក្សា។

២. គ្មានចំណាត់ការណាមួយ ត្រូវបានអនុវត្តក្រោមកថាខណ្ឌទី១ឡើយ លុះត្រាតែអង្គជំនុំជម្រះវិវាទបាតសមុទ្ររកឃើញថា រដ្ឋភាគីបានបំពានយ៉ាងធ្ងន់ធ្ងរម្តងហើយម្តងទៀតលើបទប្បញ្ញត្តិនៃជំពូកនេះ។

## **ផ្នែកទី៥**

## **ការដោះស្រាយវិវាទនិងយោបល់ប្រឹក្សា**

### មាត្រា១៨៦

### **អង្គជំនុំជម្រះវិវាទបាតសមុទ្រនៃតុលាការអន្តរជាតិនីតិសមុទ្រ**

ការបង្កើតអង្គជំនុំជម្រះ និងលក្ខណៈដែលអង្គជំនុំជម្រះ នេះត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃផ្នែកនេះ ជំពូកទី១៥ និងឧបសម្ព័ន្ធទី៦។

## មាត្រា១៨៧
## យុត្តាធិការរបស់អង្គជំនុំជម្រះវិវាទបាតសមុទ្រ

អង្គជំនុំជម្រះ ត្រូវមានយុត្តាធិការក្រោមជំពូកនេះ និងឧបសម្ព័ន្ធនានាដែលពាក់ព័ន្ធនឹងជំពូក ក្នុងករណីមានវិវាទទាក់ទងនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិតាមចំណាត់ថ្នាក់ ដូចខាងក្រោម ៖

(ក) វិវាទរវាងរដ្ឋភាគី ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តជំពូកនេះ និងឧបសម្ព័ន្ធនានាដែលពាក់ព័ន្ធនឹងជំពូកនេះ។

(ខ) វិវាទរវាងរដ្ឋភាគីនិងអាជ្ញាធរទាក់ទងនឹង៖

(១) ទង្វើ ឬការធ្វេសប្រហែសរបស់អាជ្ញាធរ ឬរបស់រដ្ឋភាគី ដែលត្រូវបានចោទប្រកាន់ថា ជាការបំពានលើជំពូកនេះ ឬឧបសម្ព័ន្ធដែលពាក់ព័ន្ធ ឬលើវិធាន បទបញ្ញា និងនីតិវិធីរបស់អាជ្ញាធរដែលបានរៀបចំឡើងអនុលោមតាមជំពូកផនេះ ឬឧបសម្ព័ន្ធដែលពាក់ព័ន្ធនោះ ឬ

(២) ទង្វើរបស់អាជ្ញាធរដែលត្រូវបានចោទប្រកាន់ថាហួសពីយុត្តាធិការ ឬជាការប្រើប្រាស់ អំណាចមិនបានត្រឹមត្រូវ។

(គ) វិវាទរវាងភាគីនៃកិច្ចសន្យា ក្នុងនាមជារដ្ឋភាគី អាជ្ញាធរ ឬសហគ្រាស សហគ្រាសរដ្ឋ និងរូបវន្ត ឬនីតិបុគ្គលដូចមានចែងក្នុងមាត្រា១៥៣ កថាខ័ណ្ឌ២(ខ) ទាក់ទងនឹង៖

(១) ការបកស្រាយ ឬការអនុវត្តកិច្ចសន្យា ឬផែនការការងារដែលពាក់ព័ន្ធ ឬ

(២) ទង្វើ ឬការធ្វេសប្រហែសរបស់ភាគីនៃកិច្ចសន្យាទាក់ទងនឹងសកម្មភាពក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងភាគីផ្សេងទៀត ឬការប៉ះពាល់ដោយផ្ទាល់លើផលប្រយោជន៍ស្របច្បាប់របស់ភាគីនោះ។

(ឃ) វិវាទរវាងអាជ្ញាធរ និងភាគីចុះកិច្ចសន្យា ដែលទទួលការធានាពីរដ្ឋមួយដូចមានចែងក្នុងមាត្រា១៥៣ កថាខណ្ឌទី២ (ខ) និងបានបំពេញយ៉ាងត្រឹមត្រូវនូវលក្ខខណ្ឌដូចមានចែងក្នុងឧបសម្ព័ន្ធទី៣ មាត្រា៤ កថាខណ្ឌទី៦ និងមាត្រា១៣ កថាខណ្ឌទី២ ទាក់ទងទៅនឹងការចរចា និងបដិសេធកិច្ចសន្យា ឬបញ្ហាផ្លូវច្បាប់ដែលកើតចេញពីការចរចាកិច្ចសន្យា។

(ង) វិវាទរវាងអាជ្ញាធរ និងរដ្ឋភាគី សហគ្រាសរដ្ឋ រូបវន្ត ឬនីតិបុគ្គលដែលធានាដោយរដ្ឋភាគី ដូចមានចែងក្នុងមាត្រា១៥៣ កថាខណ្ឌទី២ (ខ) ដែលទទួលការចោទប្រកាន់ថា អាជ្ញាធរបានបង្កើតនូវបន្ទុកដូចមានចែងក្នុងឧបសម្ព័ន្ធទី៣ មាត្រា២២។

(ច) វិវាទផ្សេងទៀតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះដូចមានចែងយ៉ាងច្បាស់លាស់ក្នុងអនុសញ្ញានេះ។

## មាត្រា១៨៨
## ការបញ្ជូនវិវាទទៅអង្គជំនុំជម្រះពិសេសនៃសាលាក្តីអន្តរជាតិនីតិសមុទ្រ ឬអង្គជំនុំជម្រះចំពោះកិច្ចនៃអង្គជំនុំជម្រះវិវាទបាតសមុទ្រ ឬទៅមជ្ឈត្តកម្មពាណិជ្ជកម្មដែលមានសមត្ថកិច្ច

១. វិវាទរវាងរដ្ឋភាគីដូចមានចែងក្នុងមាត្រា១៨៧ កថាខណ្ឌរង (ក) អាចត្រូវបញ្ជូនទៅ៖

(ក) អង្គជំនុំជម្រះពិសេសនៃសាលាក្តីអន្តរជាតិនីតិសមុទ្រ ដែលត្រូវបង្កើតឡើងក្រោម ឧបសម្ព័ន្ធទី៦ មាត្រា១៥ និងមាត្រា១៧ តាមសំណើរបស់ភាគីវិវាទ ឬ

(ខ) អង្គជំនុំជម្រះចំពោះកិច្ចនៃអង្គជំនុំជម្រះវិវាទបាតសមុទ្រ ដែលត្រូវបង្កើតឡើងក្រោមឧបសម្ព័ន្ធទី៦ មាត្រា៣៦ តាមសំណើរបស់ភាគីវិវាទណាមួយ។

២. (ក) វិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តកិច្ចសន្យា ដូចមានចែងក្នុងមាត្រា១៨៧ កថាខណ្ឌរង(គ)(១) ត្រូវបញ្ជូនទៅតាមសំណើរបស់ភាគីវិវាទណាមួយទៅមជ្ឈត្តកម្មពាណិជ្ជកម្មមានសមត្ថកិច្ច លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងទៀតពីភាគីវិវាទ។ មជ្ឈត្តកម្មពាណិជ្ជកម្ម ដែលបានទទួលវិវាទមិនមានយុត្តាធិការក្នុងការសម្រេចរាល់បញ្ហានានាការបកស្រាយអនុសញ្ញានេះទេ។ នៅពេលវិវាទមានទាក់ទងទៅនឹងបញ្ហាបកស្រាយជំពូកទី១១ និងឧបសម្ព័ន្ធដែលពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ដែលបញ្ហានោះ ត្រូវបញ្ជូនទៅអង្គជំនុំជម្រះវិវាទបាតសមុទ្រដើម្បីសម្រេច។

(ខ) នៅពេលចាប់ផ្ដើម ឬក្នុងពេលដំណើរការមជ្ឈត្តកម្ម ប្រសិនបើអង្គមជ្ឈត្តកម្មកំណត់ទៅតាមសំណើរបស់ភាគីវិវាទណាមួយ ឬកំណត់ដោយខ្លួនឯងថា សេចក្ដីសម្រេចរបស់ខ្លួនអាស្រ័យទៅតាមសេចក្ដីសម្រេចរបស់សភាវិវាទបាតសមុទ្រនោះ អង្គមជ្ឈត្តកម្មត្រូវបញ្ជូនបញ្ហានោះទៅអង្គជំនុំជម្រះវិវាទបាតសមុទ្រដើម្បីសម្រេច។ អង្គមជ្ឈត្តកម្មត្រូវដំណើរការ និងចេញសេចក្ដីបង្គាប់ ស្របទៅតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះវិវាទបាតសមុទ្រ។

(គ) ក្នុងករណីពុំមានខចែងក្នុងកិច្ចសន្យាអំពីនីតិវិធីមជ្ឈត្តកម្ម ដែលត្រូវរនុវត្តក្នុងការដោះស្រាយវិវាទនោះ មជ្ឈត្តកម្មត្រូវអនុវត្តតាមវិធានរបស់គណៈកម្មការអង្គការសហប្រជាជាតិស្ដីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ឬវិធានមជ្ឈត្តកម្មផ្សេងទៀតដូចមានចែងក្នុងវិធាន បទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរ លើកលែងតែភាគីវិវាទព្រមព្រៀងផ្សេងពីនេះ។

## មាត្រា១៨៩

## ការកំណត់យុត្តាធិការទាក់ទងនឹងសេចក្ដីសម្រេចរបស់អាជ្ញាធរ

អង្គជំនុំជម្រះវិវាទបាតសមុទ្រមិនមានយុត្តាធិការលើការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់អាជ្ញាធរដោយអនុលោមទៅតាមជំពូកនេះ។ ទោះក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះវិវាទបាតសមុទ្រមិនត្រូវប្រើឆន្ទានុសិទ្ធិរបស់ខ្លួនលើឆន្ទានុសិទ្ធិរបស់អាជ្ញាធរទេ។ ដោយមិនប៉ះពាល់ដល់មាត្រា១៩១ ក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួនអនុលោមទៅតាមមាត្រា១៨៧ អង្គជំនុំជម្រះវិវាទបាតសមុទ្រមិនត្រូវប្រកាសខ្លួនឯងអំពីបញ្ហាដែលថា តើវិធាន បទបញ្ជា និងនីតិវិធីរបស់អាជ្ញាធរ មានឬមិនមានអនុលោមភាពស្របតាមអនុសញ្ញានេះទេ ហើយក៏មិនត្រូវប្រកាសថា វិធាន បទបញ្ជា និងនីតិវិធីទាំងនេះមានឬមិនមានសុពលភាពឡើយ។ ក្នុងករណីនេះ យុត្តាធិការរបស់អង្គជំនុំជម្រះវិវាទបាតសមុទ្រមានកម្រិតដោះស្រាយ ការទាមទារអំពីការអនុវត្តវិធាន បទបញ្ជា និងវិធីរបស់អាជ្ញាធរតាមករណីនីមួយៗ ដែលបានធ្វើផ្ទុយទៅនឹងកាតព្វកិច្ចនៃកិច្ចសន្យារបស់ភាគីវិវាទ ឬកាតព្វកិច្ចរបស់ភាគីវិវាទក្រោមអនុសញ្ញានេះ ការទាមទារទាក់ទងនឹងការប្រើអំណាចហួសពីយុត្តាធិការ ឬការប្រើអំណាចខុស និងការទាមទារព្យសនកម្មដែលត្រូវទទួលសំណង ឬទទួលការដោះស្រាយផ្សេងទៀតទៅភាគីពាក់ព័ន្ធ ចំពោះការខកខានរបស់ភាគីវិវាទផ្សេងទៀតក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ឬកាតព្វកិច្ចរបស់ខ្លួនក្រោមអនុញ្ញានេះ។

## មាត្រា១៩០
## ការចូលរួមនិងការបង្ហាញខ្លួន
## របស់រដ្ឋភាគីដែលផ្តល់ការធានានៅក្នុងដំណើរការក្តី

១. ប្រសិនបើរូបវន្ត ឬនីតិបុគ្គលជាភាគីវិវាទដូចមានចែងក្នុងមាត្រា១៨៧ រដ្ឋដែលផ្តល់ការធានា ត្រូវទទួលបានការជូនដំណឹងអំពីការធានានោះ និងត្រូវមានសិទ្ធិចូលរួមក្នុងដំណើរការក្តី តាមរយៈការបញ្ជូនសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរឬដោយផ្ទាល់មាត់។

២. ប្រសិនបើបណ្តឹងត្រូវបានធ្វើឡើងចំពោះរដ្ឋភាគីដោយរូបវន្ត ឬនីតិបុគ្គលដែលធានាដោយរដ្ឋភាគីផ្សេងមួយទៀតនៅក្នុងវិវាទដូចមានចែងក្នុងមាត្រ១៨៧ កថាខណ្ឌ(គ) នោះរដ្ឋចុងបណ្តឹងអាចស្នើឱ្យរដ្ឋដែលធានាបុគ្គលនោះចូលខ្លួនដោះស្រាយនៅក្នុងដំណើរការក្តីជំនួសមុខឱ្យបុគ្គលនោះ។ ក្នុងករណីមានការខកខានក្នុងការចូលខ្លួន នោះរដ្ឋចុងបណ្តឹងអាចរៀបចំឱ្យមាននីតិបុគ្គលណាមួយដែលមានសញ្ជាតិខ្លួនធ្វើជាតំណាងរបស់ខ្លួនក្នុងដំណើរការក្តីបាន។

## មាត្រា១៩១
## យោបល់ប្រឹក្សា

អង្គជំនុំជម្រះវិវាទបាតសមុទ្រត្រូវផ្តល់យោបល់ប្រឹក្សាតាមការស្នើសុំរបស់សន្និបាត ឬក្រុមប្រឹក្សាលើបញ្ហាច្បាប់ដែលកើតចេញវិសាលភាពនៃសកម្មភាពរបស់ពួកគេ។ យោបល់ប្រឹក្សានេះ ត្រូវផ្តល់ជូនជាបន្ទាន់។

# ជំពូកទី១២
# ការការពារ និង ការថែរក្សាបរិស្ថានសមុទ្រ
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

## មាត្រា១៩២
## កាតព្វកិច្ចទូទៅ

បណ្តារដ្ឋមានកាតព្វកិច្ចការពារ និងថែរក្សាបរិស្ថានសមុទ្រ។

## មាត្រា១៩៣
## សិទ្ធិអធិបតេយ្យរបស់បណ្តារដ្ឋក្នុងការធ្វើអាជីវកម្មធនធានធម្មជាតិរបស់ខ្លួន

បណ្តារដ្ឋមានសិទ្ធិអធិបតេយ្យក្នុងការប្រើប្រាស់ធនធានធម្មជាតិរបស់ខ្លួន ដោយអនុលោមទៅតាមគោលនយោបាយស្តីពីបរិស្ថានរបស់ខ្លួន និងអនុលោមទៅតាមកាតព្វកិច្ចរបស់ពួកគេក្នុងការការពារ និងអភិរក្សបរិស្ថានសមុទ្រ។

## មាត្រា១៩៤
## វិធានការបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ

១. បណ្តារដ្ឋត្រូវចាត់វិធានការចាំបាច់និងសមស្របដោយខ្លួនឯង ឬដោយសហការជាមួយរដ្ឋផ្សេងទៀតស្របតាមអនុសញ្ញានេះ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីប្រភពនានា ដោយប្រើមធ្យោបាយដែលល្អបំផុតសម្រាប់គោលបំណងនេះ តាមសមត្ថភាពរបស់ខ្លួន ហើយត្រូវប្រឹងប្រែងធ្វើសុខដុមនីយកម្មគោលនយោបាយរបស់ខ្លួនឱ្យស្របនឹងអនុសញ្ញានេះ។

២. បណ្តារដ្ឋត្រូវចាត់គ្រប់វិធានការចាំបាច់នានាដើម្បីធានាថា សកម្មភាពដែលនៅក្រោមយុត្តាធិការ ឬការគ្រប់គ្រងរបស់ខ្លួន ត្រូវធ្វើយ៉ាងណាកុំឱ្យមានការខូចខាតដោយសារការបំពុលទៅរដ្ឋផ្សេងទៀត និងបរិស្ថានរបស់រដ្ឋទាំងនោះ ព្រមទាំងត្រូវធានាថា ការបំពុលដែលកើតមានដោយសារឧប្បត្តិហេតុ ឬសកម្មភាពនានាក្រោមយុត្តាធិការ ឬការគ្រប់គ្រងរបស់ខ្លួនមិនសាយភាយហួសពីតំបន់ដែលបណ្តារដ្ឋនោះ អនុវត្តសិទ្ធិអធិបតេយ្យស្របក្រោមអនុសញ្ញានេះទេ។

៣. វិធានការដែលអនុវត្តក្រោមជំពូកនេះ ត្រូវអនុវត្តលើរាល់ប្រភពនៃការបំពុលបរិស្ថានសមុទ្រ។ វិធានការទាំងនេះរួមមានជាអាទិ៍ រាល់វិធានការទាំងឡាយដែលរៀបចំឡើង ដើម្បីកាត់បន្ថយជាអតិបរិមានូវទំហំនៃការបំពុលដូចខាងក្រោម៖

(ក) ការបញ្ចេញសារធាតុពុល ឬគ្រោះថ្នាក់ ជាពិសេសសារធាតុទាំងឡាយណាដែលមិនងាយរលាយមានប្រភពនៅនឹងដី ឬតាមរយៈបរិយាកាស ឬតាមរយៈការចាក់ចោលសំណល់។

(ខ) ការបំពុលពីនាវា ជាពិសេសវិធានការបង្ការគ្រោះថ្នាក់ និងដោះស្រាយចំពោះស្ថានភាពបន្ទាន់ដែលធានាបាននូវសុវត្ថិភាពប្រតិបត្តិការក្នុងសមុទ្រ បង្ការការបញ្ចេញចោលនូវសំណល់ដោយចេតនានិងដោយអចេតនា ព្រមទាំងធ្វើនិយ័តកម្មលើការរៀបចំប្លង់ ការសាងសង់ការបំពាក់ឧបករណ៍ ការប្រតិបត្តិការ និងការដាក់នាវិកបម្រើការងារនៅលើនាវា។

(គ) ការបំពុលពីបបនាការ និងឧបករណ៍ផ្សេងៗដែលប្រើប្រាស់នៅក្នុងការរុករក ឬការធ្វើអាជីវកម្មធនធានធម្មជាតិនៅក្នុងបរិស្ថានសមុទ្រ ដីស្រទាប់ក្រោមនៃបាតសមុទ្រ ជាពិសេសវិធានការទាំងឡាយសម្រាប់ទប់ស្កាត់គ្រោះថ្នាក់ និងឆ្លើយតបនឹងស្ថានភាពបន្ទាន់ ដើម្បីធានាសុវត្ថិភាពប្រតិបត្តិការក្នុងសមុទ្រ ព្រមទាំងធ្វើនិយ័តកម្មលើការរៀបចំប្លង់ ការសាងសង់ ការបំពាក់ឧបករណ៍ ការប្រតិបត្តិការ និងការដាក់កម្លាំងមនុស្សបម្រើការងារនៅលើបបនាការ ឬឧបករណ៍ទាំងនោះ។

(ឃ) ការបំពុលពីបបនាការ និងឧបករណ៍ផ្សេងទៀតដែលធ្វើប្រតិបត្តិការក្នុងបរិស្ថានសមុទ្រ ជាពិសេសវិធានការទាំងឡាយសម្រាប់ទប់ស្កាត់គ្រោះថ្នាក់ និងឆ្លើយតបនឹងស្ថានភាពបន្ទាន់ ដើម្បីធានាសុវត្ថិភាពប្រតិបត្តិការក្នុងសមុទ្រ ព្រមទាំងធ្វើនិយ័តកម្មលើការរៀបចំប្លង់ ការសាងសង់ ការបំពាក់ឧបករណ៍ ការប្រតិបត្តិការ និងការដាក់កម្លាំងមនុស្សបម្រើការងារនៅលើបបនាការ ឬឧបករណ៍ទាំងនោះ។

៤. ក្នុងការអនុវត្តវិធានការបង្ការ កាត់បន្ថយ ឬគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ បណ្តារដ្ឋត្រូវជៀសវាងពីការជ្រៀតជ្រែកដោយគ្មានហេតុផលដល់សកម្មភាពដែលបណ្តារដ្ឋផ្សេងទៀតអនុវត្តស្របទៅតាមសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេអនុលោមទៅតាមអនុសញ្ញានេះ។

៥. វិធានការដែលអនុវត្តក្រោមជំពូកនេះ ត្រូវរាប់បញ្ចូលទាំងវិធានការដែលចាំបាច់ក្នុងការការពារ និងថែរក្សាប្រព័ន្ធអេកូឡូស៊ីកម្រៗឬងាយខូចខាត ក៏ដូចជាជម្រកសត្វនិងរុក្ខជាតិជិតផុតពូជឬរងការគំរាមកំហែងឬស្ថិតក្នុងភាពគ្រោះថ្នាក់ និងទម្រង់ផ្សេងទៀតនៃជីវិតក្នុងសមុទ្រ។

## មាត្រា១៩៥
## ករណីយកិច្ចមិនផ្ទេរការខូចខាត ឬគ្រោះថ្នាក់ ឬបំលែងការបំពុលពីប្រភេទមួយទៅជាប្រភេទផ្សេងមួយទៀត

ក្នុងការអនុវត្តវិធានការបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ បណ្តារដ្ឋត្រូវអនុវត្តយ៉ាងណាកុំឱ្យមានការផ្ទេរដោយផ្ទាល់ ឬដោយប្រយោលនូវការខូចខាត ឬគ្រោះថ្នាក់ពីតំបន់មួយទៅតំបន់មួយផ្សេងទៀត ឬបំលែងការបំពុលពីប្រភេទមួយទៅជាប្រភេទមួយផ្សេងទៀត។

## មាត្រា១៩៦
## ការប្រើប្រាស់បច្ចេកវិទ្យាឬការដាក់បញ្ចូលនូវប្រភេទនាំចូលឬថ្មី

១. បណ្តារដ្ឋត្រូវអនុវត្តរាល់វិធានការដែលចាំបាច់នានា ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ដែលបង្កឡើងដោយសារការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងយុត្តាធិការ ឬការគ្រប់គ្រងរបស់ខ្លួន ឬដោយសារការដាក់បញ្ចូលដោយចេតនា ឬដោយចៃដន្យនូវប្រភេទនាំចូល ឬថ្មីទៅក្នុងផ្នែកណាមួយនៃបរិស្ថានសមុទ្រ ដែលបណ្តាលឱ្យមានការផ្លាស់ប្តូរនិងគ្រោះថ្នាក់យ៉ាងខ្លាំងដល់បរិស្ថានសមុទ្រនោះទេ។

២. មាត្រានេះ មិនប៉ះពាល់ដល់ការអនុវត្តអនុសញ្ញានេះ ទាក់ទងនឹងការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ។

# ផ្នែកទី២
# កិច្ចសហប្រតិបត្តិការសកលនិងតំបន់

## មាត្រា១៩៧
## កិច្ចសហប្រតិបត្តិការផ្អែកលើមូលដ្ឋានជាសកលឬក្នុងតំបន់

បណ្តារដ្ឋត្រូវសហប្រតិបត្តិការជាសកលនិងក្នុងតំបន់ ដោយផ្ទាល់ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ដើម្បីរៀបចំតាក់តែងវិធាន បទដ្ឋានអន្តរជាតិ ព្រមទាំងនិយាមប្រតិបត្តិនិងនីតិវិធីស្របតាមអនុសញ្ញានេះ សម្រាប់ការពារ និងអភិរក្សបរិស្ថានសមុទ្រដោយផ្តោតលក្ខណៈពិសេសរបស់តំបន់នីមួយៗ។

## មាត្រា១៩៨
## ការជូនដំណឹងអំពីការខូចខាតជាក់ស្តែងឬការខូចខាតដែលនឹងកើតមាន

នៅពេលរដ្ឋមួយ បានដឹងពីករណីបរិស្ថានសមុទ្រកំពុងរងគ្រោះថ្នាក់និងខូចខាតធ្ងន់ធ្ងរដោយសារការបំពុល រដ្ឋនោះ ត្រូវជូនដំណឹងភ្លាមៗដល់រដ្ឋផ្សេងទៀត ដែលខ្លួនគិតថា អាចនឹងទទួលរងផលប៉ះពាល់ពីការខូចខាតនោះ រួមទាំងអង្គការអន្តរជាតិមានសមត្ថកិច្ច។

## មាត្រា១៩៩
## ផែនការបង្ការការបំពុល

ក្នុងករណីដូចមានចែងក្នុងមាត្រា១៩៨ និងផ្អែកលើសមត្ថភាពរបស់ខ្លួន បណ្តារដ្ឋដែលមានតំបន់រងផលប៉ះពាល់ និងអង្គការអន្តរជាតិមានសមត្ថកិច្ច ត្រូវសហការគ្នាឱ្យបានខ្លាំងក្លាបំផុតក្នុងការលុបបំបាត់ផលប៉ះពាល់ពីការបំពុល និងបង្ការ ឬកាត់បន្ថយការខូចខាតជាអតិបរិមា។ ដើម្បីសម្រេចគោលបំណងនេះ បណ្តារដ្ឋត្រូវរួមគ្នារៀបចំ និងជម្រុញឱ្យមានផែនការបង្ការសម្រាប់ឆ្លើយតបទៅនឹងឧប្បត្តិហេតុនៃការបំពុលក្នុងបរិស្ថានសមុទ្រ។

## មាត្រា២០០
## ការសិក្សា កម្មវិធីស្រាវជ្រាវ និងការផ្លាស់ប្តូរព័ត៌មាន និងទិន្នន័យ

បណ្តារដ្ឋត្រូវសហការគ្នាដោយផ្ទាល់ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ដើម្បីលើកកម្ពស់ការសិក្សា អនុវត្តកម្មវិធីស្រាវជ្រាវវិទ្យាសាស្ត្រ និងលើកទឹកចិត្តដល់ការផ្លាស់ប្តូរព័ត៌មាននិងទិន្នន័យដែលទទួលបានស្តីពីការបំពុលបរិស្ថានសមុទ្រ។ បណ្តារដ្ឋទាំងនោះត្រូវប្រឹងប្រែងចូលរួមសកម្មក្នុងកម្មវិធីកម្រិតតំបន់និងសកល ដើម្បីទទួលបានចំណេះដឹងសម្រាប់ការវាយតម្លៃអំពីលក្ខណៈ និងទំហំនៃការបំពុល ការប្រឈមនិងលំនាំផ្លូវ ហានិភ័យ និងដំណោះស្រាយ។

## មាត្រា២០១
## លក្ខណៈវិនិច្ឆ័យផ្នែកវិទ្យាសាស្ត្រសម្រាប់និយ័តកម្ម

ផ្អែកតាមព័ត៌មាននិងទិន្នន័យដែលទទួលបានស្របតាមមាត្រា២០០ បណ្តារដ្ឋត្រូវសហការដោយផ្ទាល់ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ដើម្បីរៀបចំបង្កើតលក្ខណៈវិនិច្ឆ័យផ្នែកវិទ្យាសាស្ត្រសម្រាប់ការតាក់តែង និងពន្យល់អំពីវិធាន បទដ្ឋាន និងការអនុវត្តនិងនីតិវិធីដែលបានណែនាំសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ។

# ផ្នែកទី៣
# ជំនួយបច្ចេកទេស

## មាត្រា២០២
## ការផ្តល់ជំនួយវិទ្យាសាស្ត្រនិងបច្ចេកទេសដល់បណ្តារដ្ឋកំពុងអភិវឌ្ឍន៍

បណ្តារដ្ឋត្រូវដោយផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ត្រូវ៖

(ក) លើកកំពស់កម្មវិធីផ្តល់ជំនួយវិទ្យាសាស្ត្រ អប់រំ បច្ចេកទេស និងជំនួយផ្សេងទៀតដល់រដ្ឋកំពុងអភិវឌ្ឍន៍សម្រាប់ការការពារនិងការអភិរក្សបរិស្ថានសមុទ្រ និងការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលសមុទ្រ។ ជំនួយទាំងនោះរួមមានជាអាទិ៍៖

- (១) ការបណ្តុះបណ្តាលបុគ្គលិកផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេស។
- (២) ការសម្របសម្រួលដល់ការចូលរួមរបស់ពួកគេក្នុងកម្មវិធីអន្តរជាតិពាក់ព័ន្ធ។
- (៣) ការផ្តល់ជូនពួកគេនូវបរិក្ខារនិងទីកន្លែងចាំបាច់នានា។
- (៤) ការបង្កើតសមត្ថភាពរបស់ពួកគេក្នុងការផលិតបរិក្ខារទាំងនោះ។
- (៥) ប្រឹក្សាយោបល់អំពី និងការអភិវឌ្ឍទីកន្លែងសម្រាប់កម្មវិធីស្រាវជ្រាវ តាមដាន អប់រំ និងកម្មវិធីផ្សេងទៀត។

(ខ) ផ្តល់ជំនួយសមស្រប ជាពិសេសដល់រដ្ឋកំពុងអភិវឌ្ឍន៍ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ពីឧប្បត្តិហេតុធំៗដែលអាចបង្កឱ្យការបំពុលធ្ងន់ធ្ងរដល់បរិស្ថានសមុទ្រ។

(គ) ផ្តល់ជំនួយសមស្រប ជាពិសេសដល់រដ្ឋកំពុងអភិវឌ្ឍន៍ទាក់ទងនឹងការរៀបចំត្រៀមសម្រាប់ការវាយតម្លៃបរិស្ថាន។

## មាត្រា២០៣
## ការផ្តល់លក្ខខណ្ឌអនុគ្រោះសម្រាប់បណ្តារដ្ឋកំពុងអភិវឌ្ឍន៍

ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ឬកាត់បន្ថយផលប៉ះពាល់នៃការបំពុលនោះ រដ្ឋកំពុងអភិវឌ្ឍន៍ត្រូវទទួលបានលក្ខខណ្ឌអនុគ្រោះពីអង្គការអន្តរជាតិសម្រាប់៖

(ក) ការបែងចែកសមស្របនូវមូលនិធិ និងជំនួយបច្ចេកទេស និង

(ខ) ការប្រើប្រាស់សេវាកម្មឯកទេសរបស់ពួកគេ។

# ផ្នែកទី៤
# ការតាមដាន និងការវាយតម្លៃបរិស្ថាន

## មាត្រា២០៤
## ការតាមដានហានិភ័យឬផលប៉ះពាល់នៃការបំពុល

១. ដោយមិនប៉ះពាល់ដល់សិទ្ធិរបស់បណ្តារដ្ឋផ្សេងទៀត បណ្តារដ្ឋត្រូវខិតខំឱ្យអស់ពីសមត្ថភាព ដោយផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ក្នុងការសង្កេត វាស់វែង វាយតម្លៃ និងវិភាគ តាមវិធីសាស្ត្រ វិទ្យាសាស្ត្រ ដែលមានការទទួលស្គាល់ អំពីហានិភ័យឬផលប៉ះពាល់ពីការបំពុលបរិស្ថានសមុទ្រ។

២. ជាពិសេសបណ្តារដ្ឋត្រូវរក្សាការឃ្លាំមើលផលប៉ះពាល់ពីរាល់សកម្មភាពដែលពួកគេបានអនុញ្ញាត ឬដែលពួកគេចូលរួម ដើម្បីកំណត់ថាតើសកម្មភាពទាំងនេះអាចនឹងបំពុលបរិស្ថានសមុទ្រដែរឬទេ។

## មាត្រា២០៥
## ការបោះពុម្ពផ្សាយរបាយការណ៍

បណ្តារដ្ឋត្រូវបោះពុម្ពផ្សាយរបាយការណ៍ស្តីពីលទ្ធផល ដែលទទួលបានស្របតាមមាត្រា២០៤ ឬផ្តល់របាយការណ៍នោះក្នុងចន្លោះពេលសមស្របដល់អង្គការអន្តរជាតិមានសមត្ថកិច្ច ដែលអាចផ្សព្វផ្សាយរបាយការណ៍នេះដល់បណ្តារដ្ឋទាំងអស់។

## មាត្រា២០៦
## ការវាយតម្លៃអំពីសក្តានុពលនៃផលប៉ះពាល់របស់សកម្មភាព

នៅពេលដែលបណ្តារដ្ឋមានមូលដ្ឋានសមហេតុផលក្នុងការជឿថាសកម្មភាពដែលបានគ្រោងទុកក្រោមយុត្តាធិការ ឬការគ្រប់គ្រងរបស់ខ្លួនអាចបង្កឱ្យមានការបំពុលធ្ងន់ធ្ងរ ឬការផ្លាស់ប្តូរសំខាន់ៗ និងមានគ្រោះថ្នាក់ដល់បរិស្ថានសមុទ្រ បណ្តារដ្ឋនោះតាមដែលអាចធ្វើទៅបាន ត្រូវធ្វើការវាយតម្លៃអំពីសក្តានុពលនៃផលប៉ះពាល់របស់សកម្មភាពទាំងនោះទៅលើបរិស្ថានសមុទ្រនិងត្រូវផ្តល់របាយការណ៍នៃលទ្ធផលពីការវាយតម្លៃនោះ តាមវិធីដូចមានចែងក្នុងមាត្រា២០៥។

## ផ្នែកទី៥
## វិធានអន្តរជាតិ និងច្បាប់ជាតិដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ

### មាត្រា២០៧
### ការបំពុលដែលមានប្រភពពីដីគោក

១. បណ្តារដ្ឋត្រូវអនុម័តច្បាប់និងបទបញ្ជា ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ដែលមានប្រភពពីដីគោក ដោយរាប់បញ្ចូលទាំងទន្លេ ពាមសមុទ្រ បំពង់បង្ហូរ និងសំណង់បង្ហូរទឹកដោយពិចារណាទៅលើវិធាន បទដ្ឋាន និងការអនុវត្តនិងនីតិវិធីដែលបានណែនាំ ដែលបានព្រមព្រៀងជាអន្តរជាតិ។

២. បណ្តារដ្ឋត្រូវចាត់វិធានការផ្សេងទៀតតាមដែលចាំបាច់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលទាំងនោះ។

៣. បណ្តារដ្ឋត្រូវប្រឹងប្រែង ដើម្បីធ្វើសុខដុមនីយកម្មគោលនយោបាយរបស់ខ្លួនពាក់ព័ន្ធនឹងករណីនេះនៅកម្រិតតំបន់ដែលសមស្រប។

៤. បណ្តារដ្ឋត្រូវធ្វើសកម្មភាព ជាពិសេសតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ចឬសន្និសីទការទូត ប្រឹងប្រែងរៀបចំនូវវិធាន បទដ្ឋាន ព្រមទាំងនិងការអនុវត្តនិងនីតិវិធីដែលបានណែនាំកម្រិតតំបន់និងសកល ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រដែលមានប្រភពពីដីគោក ដោយពិចារណាទៅលើលក្ខណៈពិសេសរបស់តំបន់ សមត្ថភាពសេដ្ឋកិច្ចរបស់រដ្ឋកំពុងអភិវឌ្ឍន៍ និងតំរូវការរបស់ពួកគេនូវការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច។ វិធាន បទដ្ឋាន ព្រមទាំងការអនុវត្តនិងនីតិវិធីដែលបានណែនាំទាំងនេះ ត្រូវបានពិនិត្យឡើងវិញជាបន្តបន្ទាប់ទៅតាមការចាំបាច់។

៥. ច្បាប់ បទបញ្ជា វិធានការ វិធាន បទដ្ឋាន ព្រមទាំងការអនុវត្តនិងនីតិវិធីដែលបានណែនាំ ដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៤ ត្រូវមានបញ្ចូលនូវការរៀបចំដើម្បីកាត់បន្ថយជាអតិបរិមានូវការសាយភាយនូវសារធាតុពុលគ្រោះថ្នាក់ ឬជាតិពិស ជាពិសេសសារធាតុដែលមានផលប៉ះពាល់យូរអង្វែងទៅក្នុងបរិស្ថានសមុទ្រ។

### មាត្រា២០៨
### ការបំពុលពីសកម្មភាពនៅបាតសមុទ្រដែលស្ថិតក្រោមយុត្តាធិការជាតិ

១. បណ្តារដ្ឋជាប់ឆ្នេរត្រូវអនុម័តច្បាប់និងបទបញ្ជា ដើម្បីការពារ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ដែលកើតចេញពី ឬពាក់ព័ន្ធនឹងសកម្មភាពនៅបាតសមុទ្រ ដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន និងពីកោះសប្បនិម្មិត បរិក្ខារ និងរចនាសម្ព័ន្ធដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួនអនុលោមតាមមាត្រា៦០ និង៨០។

២. បណ្តារដ្ឋត្រូវចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលទាំងនោះ។

៣. ច្បាប់ បទបញ្ជា និងវិធានការត្រូវមានអនុភាពមិនតិចជា វិធាន បទដ្ឋាន ព្រមទាំងការអនុវត្តនិងនីតិវិធីដែលបានណែនាំជាអន្តរជាតិ។

៤. បណ្តារដ្ឋត្រូវប្រឹងប្រែងធ្វើសុខដុមនីយកម្មគោលនយោបាយរបស់ខ្លួនពាក់ព័ន្ធនឹងករណីនេះ នៅកម្រិតតំបន់ដែលសមស្រប។

៥. បណ្តារដ្ឋត្រូវ ធ្វើសកម្មភាពជាពិសេសតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ចឬសន្និសីទការទូតប្រឹងប្រែងរៀបចំនូវវិធាន បទដ្ឋាន ព្រមទាំងនិងការអនុវត្តនិងនីតិវិធីដែលបានណែនាំ កម្រិតតំបន់និងសកល ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ដូចមានចែងក្នុងកថាខណ្ឌទី១។ វិធាន បទដ្ឋាន ព្រមទាំងការអនុវត្តនិងនីតិវិធីដែលបានណែនាំទាំងនេះ ត្រូវបានពិនិត្យឡើងវិញជាបន្តបន្ទាប់ទៅតាមការចាំបាច់។

## មាត្រា២០៩

## ការបំពុលពីសកម្មភាពនៅតំបន់បាតសមុទ្រអន្តរជាតិ

១. វិធាន បទប្បញ្ញត្តិ និងនីតិវិធីអន្តរជាតិត្រូវតែរៀបចំឡើងដោយអនុលោមតាមជំពូកទី១១ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីសកម្មភាពក្នុងតំបន់បាតសមុទ្រអន្តរជាតិ។ វិធាន បទប្បញ្ញត្តិ និងនីតិវិធីទាំងនេះនឹងត្រូវពិនិត្យឡើងវិញជាបន្តបន្ទាប់ទៅតាមការចាំបាច់។

២. ក្រោមបទប្បញ្ញត្តិពាក់ព័ន្ធនៃជំពូកនេះ បណ្តារដ្ឋត្រូវអនុម័តច្បាប់ និងបទបញ្ជា ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ដែលបង្កឡើងដោយនាវា បបនាការ រចនាសម្ព័ន្ធ និងឧបករណ៍ផ្សេងទៀតដែលពាក់ទង់ជាតិរបស់រដ្ឋនោះ ឬបានចុះបញ្ជីជាមួយនឹងរដ្ឋនោះ ឬមានប្រតិបត្តិការក្រោមសមត្ថកិច្ចរបស់រដ្ឋនោះ ទៅតាមករណីដែលអាចកើតឡើងជាយថាហេតុ។ លក្ខខណ្ឌនៃច្បាប់និងបទបញ្ជាទាំងនោះ មិនត្រូវមានអនុភាពគតិយុត្តក្រោមវិធាន បទបញ្ជា និងនីតិវិធីអន្តរជាតិដូចមានចែងក្នុងកថាខណ្ឌទី១។

## មាត្រា២១០

## ការបំពុលដោយការចាក់កាកសំណល់

១. បណ្តារដ្ឋត្រូវអនុម័តច្បាប់ និងបទបញ្ជា ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីការចាក់កាកសំណល់។

២. បណ្តារដ្ឋត្រូវចាត់វិធានការផ្សេងទៀតតាមការចាំបាច់ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការ បំពុលទាំងនោះ។

៣. ច្បាប់ បទបញ្ជា និងវិធានការទាំងនោះត្រូវធានាថា មិនមានការចាក់កាកសំណល់ណាមួយទេ ដែលធ្វើឡើងដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋនោះ។

៤. បណ្តារដ្ឋ ត្រូវប្រឹងប្រែងរៀបចំបង្កើតនូវវិធានស្តង់ដានិងគោលការណ៍ណែនាំសម្រាប់ការអនុវត្ត និងនីតិវិធីជាលក្ខណៈសកលនិងក្នុងតំបន់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលទាំងនោះ ជាពិសេសនៅពេលដែលរដ្ឋនោះធ្វើសកម្មភាពតាមរយៈក្របខ័ណ្ឌអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ឬសន្និសីទការទូត។

៥. មិនត្រូវមានចាក់កាកសំណល់ក្នុងសមុទ្រដែនដីនិងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬនៅលើតំបន់ខ្ពង់រាបបាតសមុទ្រនោះទេប្រសិនដោយគ្មានការយល់ព្រមជាមុនយ៉ាងច្បាស់លាស់ពីរដ្ឋជាប់ឆ្នេរសមុទ្រ ដែលជារដ្ឋមានសិទ្ធិអនុញ្ញាតធ្វើនិយ័តកម្ម និងគ្រប់គ្រងលើការចាក់កាកសំណល់ទាំងនោះ បន្ទាប់ពីមានការពិចារណាយ៉ាងច្បាស់លាស់អំពីបញ្ហានេះជាមួយនឹងរដ្ឋផ្សេងទៀតដែលអាចទទួលរងការប៉ះពាល់មិនល្អ ដោយសារស្ថានភាពភូមិសាស្ត្ររបស់ពួកគេឡើយ។

៦. ច្បាប់ បទបញ្ជា និងវិធានការជាតិ មិនត្រូវមានអនុភាពគតិយុត្តក្រោមវិធាននិងស្តង់ដាអន្តរជាតិក្នុងការបង្ការ កាត់បន្ថយ និងគ្រប់គ្រងលើការបំពុលទាំងនោះ។

## មាត្រា២១១
## ការបំពុលចេញពីនាវា

១. បណ្តារដ្ឋនៅពេលដែលធ្វើសកម្មភាពតាមរយៈក្របខ័ណ្ឌអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ឬសន្និសីទការទូត ត្រូវរៀបចំបង្កើតនូវវិធាននិងស្តង់ដាជាលក្ខណៈសកលដើម្បីបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលចេញពីនាវា ហើយនៅក្នុងក្របខ័ណ្ឌដដែលនេះនិងកាលៈទេសៈសមស្រប រដ្ឋត្រូវជម្រុញការអនុម័តនូវប្រព័ន្ធគន្លងនាវាចរណ៍ដែលធ្វើឡើងក្នុងគោលបំណងកាត់បន្ថយការគ្រោះថ្នាក់ដែលអាចឈានទៅដល់ការបំពុលបរិស្ថានសមុទ្ររួមទាំងខ្សែបន្ទាត់ឆ្នេរ និងការខូចខាតដែលកើតដោយការបំពុលផ្សេងទៀតទៅដល់ផលប្រយោជន៍ពាក់ព័ន្ធរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។ វិធាននិងស្តង់ដាទាំងនេះត្រូវនៅក្នុងក្របខ័ណ្ឌដដែលត្រូវពិនិត្យឡើងវិញជាបន្តបន្ទាប់តាមការចាំបាច់។

២. បណ្តារដ្ឋត្រូវអនុម័តច្បាប់ និងបទបញ្ញាសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រដែលចេញពីនាវាដែលលើកទង់ជាតិរបស់ខ្លួន ឬដែលមានក្នុងបញ្ជិការរបស់ខ្លួន។ ច្បាប់ និងបទបញ្ញាទាំងនោះត្រូវមានអនុភាពគតិយុត្តយ៉ាងហោចណាស់ស្មើគ្នាទៅនឹងវិធាននិងស្តង់ដាអន្តរជាតិដែលទទួលស្គាល់ជាទូទៅ ហើយបានបង្កើតឡើងតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតទូទៅ។

៣. បណ្តារដ្ឋដែលបង្កើតលក្ខខណ្ឌជាក់លាក់ក្នុងការអនុញ្ញាតឱ្យនាវាបរទេសចូលចតក្នុងកំពង់ផែ ឬចូលសមុទ្រដែនទឹកផ្ទៃក្នុងរបស់ខ្លួនឬការចតឆ្ងាយពីច្រាំងរបស់ពួកគេ ត្រូវផ្សព្វផ្សាយជាសាធារណៈនិងជូនដំណឹងទៅអង្គការអន្តរជាតិមានសមត្ថកិច្ចនូវលក្ខខណ្ឌសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ។ នៅពេលដែលលក្ខខណ្ឌទាំងនេះមានទម្រង់ដូចគ្នានឹងរដ្ឋជាប់សមុទ្រ២ឬច្រើនជាងនេះ នៅក្នុងគោលបំណងនៃគោលនយោបាយសុខដុមនីយកម្ម ការជូនដំណឹងនេះត្រូវបញ្ជាក់ថារដ្ឋណាដែលចូលរួមក្នុងកិច្ចសហប្រតិបត្តិការនេះខ្លះ។ នៅពេលដែលធ្វើដំណើរនៅក្នុងសមុទ្រដែនដីនៃរដ្ឋមួយនៃកិច្ចសហប្រតិបត្តិការនេះ រដ្ឋនីមួយៗត្រូវតម្រូវឱ្យបរិបាលនាវាដែលលើកទង់ជាតិរបស់ខ្លួន ឬចុះបញ្ជិកាជាមួយខ្លួនផ្តល់ពត៌មានតបតាមសំណើររបស់រដ្ឋនោះថាតើនាវាកំពុងធ្វើនាវាចរណ៍ទៅរដ្ឋមួយដែលនៅក្នុងតំបន់នោះ ហើយប្រសិនបើដូច្នេះមែនត្រូវបង្ហាញថា តើនាវានោះបំពេញតាមលក្ខខណ្ឌក្នុងការចូលចតក្នុងកំពង់ផែរបស់រដ្ឋនោះហើយឬយ៉ាងណា។ មាត្រានេះមិនប៉ះពាល់ដល់ការអនុវត្តសិទ្ធិរបស់នាវាក្នុងការឆ្លងកាត់ដោយគ្មានការបំពានរបស់ខ្លួន ឬដល់ការអនុវត្តមាត្រា២៥ កថាខណ្ឌទី២ឡើយ។

៤. ក្នុងការអនុវត្តអធិបតេយ្យភាពក្នុងសមុទ្រដែនដីរបស់ខ្លួន បណ្តារដ្ឋជាប់ឆ្នេរអាចអនុម័តច្បាប់ និងបទបញ្ញាសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលសមុទ្រ ពីនាវាបរទេស រួមទាំងនាវាដែលអនុវត្តសិទ្ធិឆ្លងកាត់ដោយគ្មានការបំពានផងដែរ។ ច្បាប់ និងបទបញ្ញាទាំងនោះ មិនត្រូវរំខានដល់ការឆ្លងកាត់ ដោយគ្មានការបំពានរបស់នាវាបរទេសឡើយ ដោយអនុលោមតាមផ្នែកទី៣ នៃជំពូកទី២។

៥. សម្រាប់ការអនុវត្តដូចមានចែងក្នុងផ្នែកទី៦ ទាក់ទងនឹងតំបន់សេដ្ឋកិច្ចផ្តាច់មុខ បណ្តារដ្ឋជាប់ឆ្នេរសមុទ្រអាចរៀបចំច្បាប់ និងបទបញ្ញាសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលចេញពីនាវា ដែលសមស្រប និងផ្តល់សុពលភាពដល់វិធាន និងបទដ្ឋានអន្តរជាតិដែលមានការទទួលស្គាល់ទូទៅ និងត្រូវបានបង្កើតឡើងតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ឬសន្និសីទការទូតទូទៅ។

៦. (ក) ក្នុងករណីដែលវិធាន និងបទដ្ឋានអន្តរជាតិដូចមានចែងក្នុងកថាខណ្ឌទី១ មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការឆ្លើយតបកាលៈទេសៈពិសេសនោះទេ ហើយរដ្ឋជាប់ឆ្នេរសមុទ្រមានមូលដ្ឋានសមស្របដែលអាចជឿបានថា តំបន់ដែលបានកំណត់ច្បាស់លាស់មួយនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួនជាតំបន់ដែលស្ថិតក្រោមវិធានការពិសេសសម្រាប់បង្ការការបំពុលចេញពីនាវាតម្រូវឱ្យមានការទទួលស្គាល់ ដោយមូលហេតុបច្ចេកទេសពាក់ព័ន្ធទៅនឹងស្ថានភាពភូមិសាស្ត្រសមុទ្រនិងអេកូឡូស៊ី រួមទាំងការប្រើប្រាស់ ឬការការពារធនធានរបស់ខ្លួន និងលក្ខណៈនៃចរាចរណ៍រដ្ឋជាប់ឆ្នេរក្រោយពីបានធ្វើការពិគ្រោះយោបល់សមស្រប តាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ជាមួយបណ្តារដ្ឋផ្សេងទៀត ចំពោះតំបន់នោះអាចធ្វើការទំនាក់ទំនងដោយផ្ទាល់ទៅកាន់ស្ថាប័ននោះ បញ្ជូនភស្តុតាងបច្ចេកទេស និងវិទ្យាសាស្ត្រ ដើម្បីគាំទ្រនឹងព័ត៌មានដែលចាំបាច់សម្រាប់ការសម្របសម្រួល។ ក្នុងអំឡុងពេល ១២ខែក្រោយពីទទួលបានសំណើស្ថាប័ននោះ ត្រូវសម្រេចថា តើស្ថានភាពនៅក្នុងតំបន់នោះឆ្លើយតបទៅនឹងលក្ខខណ្ឌដែលតម្រូវនោះដែរឬទេ? ប្រសិន បើស្ថាប័ននោះ សម្រេចបានជាវិជ្ជមានសម្រាប់តំបន់នោះ រដ្ឋជាប់ឆ្នេរអាចអនុម័តច្បាប់សម្រាប់ការបង្ការ ការកាត់បន្ថយនិងការគ្រប់គ្រងការបំពុលពីនាវាតាមរយៈការអនុវត្តវិធាននិងបទដ្ឋាន ឬការអនុវត្តចំពោះនាវាចរណ៍អន្តរជាតិជាធរមានតាមរយៈស្ថាប័ននោះសម្រាប់តំបន់ពិសេសនោះ។ ច្បាប់ និងបទបញ្ញាទាំងនេះមិនត្រូវចូលជាធរមានចំពោះនាវាបរទេសនោះទេរហូតដល់ ១៥ខែក្រោយពីការដាក់សំណើទៅស្ថាប័ន។

(ខ) រដ្ឋជាប់ឆ្នេរសមុទ្រត្រូវបោះពុម្ពផ្សាយនូវការកម្រិតចំពោះតំបន់ដែលបានកំណត់ជាក់លាកនិងច្បាស់លាស់។

(គ) ប្រសិនបើរដ្ឋជាប់ឆ្នេរសមុទ្រនានាមានចេតនាអនុម័តច្បាប់ និងបទបញ្ញាបន្ថែមសម្រាប់តំបន់ដូចគ្នាសម្រាប់ការការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រចេញពីនាវាពួកគេត្រូវនៅពេលដែលដាក់សំណើរទំនាក់ទំនងដែលបានលើកឡើងមុននេះ ត្រូវជូនដំណឹងទៅអង្គការនោះផងដែរ។ ច្បាប់ និងបទបញ្ញាបន្ថែមនេះអាចពាក់ព័ន្ធនឹងការបញ្ចេញចោលកាកសំណល់ ឬការអនុវត្តនៃនាវាចរណ៍ ប៉ុន្តែរដ្ឋទាំងនោះមិនអាចតម្រូវឱ្យនាវាបរទេសពិនិត្យមើលការរៀបចំ ការសាងសង់ ការរៀបចំស្លងជានៃក្រុមនាវិកឬឧបករណ៍ លុះត្រាតែជាវិធាននិងស្តង់ដាអន្តរជាតិនោះទេតែច្បាប់និងបទបញ្ញាទាំងនោះអាចអនុវត្តបាន១៥ខែបន្ទាប់ពីនាវាបរទេសពីដាក់សំណើនៃការទំនាក់ទំនងទៅកាន់អង្គការនោះក្នុងលក្ខខណ្ឌថាអង្គការនោះឯកភាពក្នុងអំឡុពេល១២ខែបន្ទាប់ពីការដាក់សំណើនៃការទំនាក់ទំនង។

៧. វិធាននិងបទដ្ឋានអន្តរជាតិ និងស្តង់ដាសំដៅក្នុងមាត្រានេះត្រូវរាប់បញ្ចូល ជាអាទិ៍នូវរាល់ចំណុចទាំងឡាយដែលទាក់ទងនឹងការជូនដំណឹងជាបន្ទាន់ដល់បណ្តារដ្ឋជាប់ឆ្នេរ ដែលមានខ្សែបន្ទាត់ឆ្នេរ ឬផលប្រយោជន៍ទាក់ទងអាចរងការប៉ះពាល់ពីឧប្បត្តិហេតុ រួមទាំងគ្រោះថ្នាក់នៅសមុទ្រ ដែលរួមមានបញ្ចេញសារជាតុ ឬលទ្ធភាពអាចដែលមានការបញ្ចេញសារជាតុ។

## មាត្រា២១២

## ការបំពុលពីឬតាមរយៈបរិយាកាស

១. បណ្តារដ្ឋត្រូវអនុម័តច្បាប់និងបទបញ្ញា ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពី ឬតាមរយៈបរិយាកាស ដើម្បីអនុវត្តលើលំហអាកាស ក្រោមអធិបតេយ្យភាពរបស់ខ្លួន និងលើនាវាដែលលើកទង់ជាតិរបស់ខ្លួន ឬនាវាឬអាកាសយាន ដែលបានចុះបញ្ជីជាមួយខ្លួន ដោយសារវិធាន បទដ្ឋាន និងនិយាម និងនីតិវិធី និងគោលការណ៍ណែនាំដែលបានព្រមព្រៀងជាអន្តរជាតិនិងសុវត្ថិភាពនៃការនាំផ្លូវអាកាស។

២. បណ្តារដ្ឋត្រូវចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលទាំងនោះ។

៣. បណ្តារដ្ឋ ជាពិសេសតាមរយៈក្របខ័ណ្ឌអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ឬសន្និសីទការទូតត្រូវខិតខំរៀបចំបង្កើត វិធាន បទដ្ឋាននិងនិយាម និងនីតិវិធីក្រោមការណែនាំជាថ្នាក់សកល និងថ្នាក់តំបន់ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលទាំងនោះ។

## ផ្នែកទី៦

## ការអនុវត្ត

## មាត្រា២១៣

## ការអនុវត្តច្បាប់ចំពោះការបំពុលពីប្រភពដីគោក

បណ្តារដ្ឋត្រូវអនុវត្តច្បាប់និងបទបញ្ញារបស់ខ្លួនអនុម័តដោយអនុលោមតាមមាត្រា២០៧ និងត្រូវអនុម័តច្បាប់និងបទបញ្ញា និងចាត់វិធានការផ្សេងទៀតដែលចាំបាច់ ដើម្បីអនុវត្តវិធាននិងបទដ្ឋានអន្តរជាតិជាធរមាន និងស្តង់ដាដែលបានបង្កើតឡើងតាមរយៈក្របខ័ណ្ឌអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ឬសន្និសីទការទូត ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីប្រភពដីគោក។

## មាត្រា២១៤

## ការអនុវត្តច្បាប់ចំពោះការបំពុលចេញពីសកម្មភាពនៅបាតសមុទ្រ

បណ្តារដ្ឋត្រូវអនុវត្តច្បាប់និងបទបញ្ញារបស់ខ្លួន ដែលបានអនុម័តដោយអនុលោមតាមមាត្រា២០៨ និងត្រូវអនុម័តច្បាប់និងបទបញ្ញា និងចាត់វិធានការផ្សេងទៀតដែលចាំបាច់ ដើម្បីអនុវត្តវិធាននិងបទដ្ឋានអន្តរជាតិជាធរមាន ដែលបានបង្កើតឡើងតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ឬសន្និសីទការទូតដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រដែលកើតចេញពី ឬមានទំនាក់ទំនងសកម្មភាពជាមួយបាតសមុទ្រអនុលោមទៅតាមយុត្តាធិការរបស់ខ្លួននិងពីកោះសប្បនិម្មិត បបនាការ និងរចនាសម្ព័ន្ធក្រោមយុត្តាធិការរបស់ខ្លួនអនុលោមទៅតាមមាត្រា៦០និងមាត្រា៨០។

## មាត្រា២១៥

## ការអនុវត្តច្បាប់ចំពោះការបំពុលពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ

ការអនុវត្តច្បាប់ បទបញ្ញា និងនីតិវិធីអន្តរជាតិ ដែលបង្កើតឡើងដោយអនុលោមទៅតាមជំពូកទី១១ ដើម្បីបង្ការ កាត់បន្ថយ និងគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិត្រូវគ្រប់គ្រងដោយជំពូកនោះ។

## មាត្រា២១៦
## ការអនុវត្តច្បាប់ទាក់ទងនឹងការបំពុលដោយការចាក់កាកសំណល់

១. ច្បាប់និងបទបញ្ញាដែលត្រូវបានអនុម័តដោយអនុលោមតាមអនុសញ្ញានេះ និងវិធាននិងបទដ្ឋានអន្តរជាតិជាធរមានដែលត្រូវបានបង្កើតឡើងតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតសម្រាប់ការទប់ស្កាត់ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រដោយ
ការចាក់កាកសំណល់ ត្រូវអនុវត្តៈ

(ក) ដោយរដ្ឋជាប់ឆ្នេរសមុទ្រទាក់ទងនឹងការចាក់កាកសំណល់នៅក្នុងសមុទ្រដែន ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខឬនៅលើតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន។

(ខ) ដោយរដ្ឋម្ចាស់សញ្ជាតិទាក់ទងនឹងនាវាដែលពាក់ទង់ជាតិរបស់ខ្លួន ឬនាវា ឬអាកាសយានដែលចុះបញ្ជីជាមួយខ្លួន។

(គ) ដោយរដ្ឋណាមួយទាក់ទងនឹងសកម្មភាពនៃការផ្ទុកកាកសំណល់ឬរូបធាតុផ្សេងទៀតដែលធ្វើឡើងនៅក្នុងដែនដីរបស់ខ្លួន ឬនៅទីលានចំណតដែលស្ថិតនៅឆ្ងាយច្រាំងរបស់ខ្លួន។

២. តាមខ្លឹមសារនៃមាត្រានេះ គ្មានរដ្ឋណាមួយត្រូវមានកាតព្វកិច្ចធ្វើនីតិវិធីបណ្តឹង នៅពេលរដ្ឋមួយផ្សេងទៀតបានធ្វើនីតិវិធីបណ្តឹងរួចហើយនោះទេ ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ។

## មាត្រា២១៧
## ការអនុវត្តច្បាប់ដោយរដ្ឋម្ចាស់សញ្ជាតិនាវា

១. បណ្តារដ្ឋត្រូវធានាឱ្យនាវាដែលពាក់ទង់ជាតិឬដែលបានចុះបញ្ជីរបស់ខ្លួន គោរពតាមវិធាននិងបទដ្ឋានអន្តរជាតិជាធរមាន ដែលបានបង្កើតឡើងដោយអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតទូទៅ ព្រមទាំងច្បាប់និងបទបញ្ញារបស់ខ្លួនដែលត្រូវបានអនុម័តដោយអនុលោមតាមអនុសញ្ញានេះសម្រាប់ការទប់ស្កាត់ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីនាវានិងត្រូវអនុម័តច្បាប់និងបទបញ្ញា ស្របតាមវិធាននិងបទដ្ឋានអន្តរជាតិទាំងនោះ និងចាត់វិធានការទាំងឡាយដែលចាំបាច់សម្រាប់ការអនុវត្តរបស់ខ្លួន។ បណ្តារដ្ឋម្ចាស់សញ្ជាតិនាវាត្រូវធានាដល់ការអនុវត្តឱ្យមានប្រសិទ្ធភាពនូវវិធាន បទដ្ឋាន ច្បាប់ និងបទបញ្ញាទាំងនេះ ទោះបីជាការរំលោភបទប្បញ្ញត្តិទាំងនេះកើតមាននៅទីណាក៏ដោយ។

២. ក្នុងករណីពិសេស បណ្តារដ្ឋត្រូវចាត់វិធានការសមស្របដើម្បីធានាថា នាវាដែលពាក់ទង់ជាតិឬដែលបានចុះបញ្ជីរបស់ខ្លួន ត្រូវបានបរាមឃាត់មិនឱ្យធ្វើនាវាចរណ៍ រហូតដល់នាវាទាំងនោះ-អាចធ្វើដំណើរនៅដែនសមុទ្រដោយគោរពតាមលក្ខខណ្ឌនៃវិធាននិងបទដ្ឋានអន្តរជាតិ ដូចមានចែងក្នុងកថាខណ្ឌទី១ ដោយរាប់បញ្ចូលទាំងលក្ខខណ្ឌដែលទាក់ទងនឹងប្លង់នាវា ការសាងសង់ ឧបករណ៍ និងការដាក់មនុស្សឱ្យធ្វើការនៅលើនាវា។

៣. បណ្តារដ្ឋត្រូវធានាថា នាវាដែលពាក់ទង់ជាតិឬដែលបានចុះបញ្ជីរបស់ខ្លួនដាក់ជាប់នៅតាមនាវានូវវិញ្ញាបនបត្រដែលតម្រូវនិងចេញដោយអនុលោមតាមវិធាន និងបទដ្ឋានអន្តរជាតិ ដូចមានចែងក្នុងកថាខណ្ឌទី១។ បណ្តារដ្ឋត្រូវធានាថា នាវាដែលពាក់ទង់ជាតិរបស់ខ្លួន ត្រូវបានត្រួតពិនិត្យលក្ខណៈបច្ចេកទេសតាមខួប ដើម្បីផ្ទៀងផ្ទាត់ថា វិញ្ញាបនបត្រទាំងនេះ មានលក្ខណៈស្របទៅតាមស្ថានភាពជាក់ស្តែងរបស់នាវា។ វិញ្ញាបនបត្រទាំងនេះត្រូវទទួលយកដោយបណ្តារដ្ឋផ្សេងទៀត ទុកជាភស្តុតាងបញ្ជាក់អំពីលក្ខខណ្ឌរបស់នាវា និងត្រូវចាត់ទុកថាមានអានុភាពអនុវត្តន៍ដូចគ្នាទៅនឹងវិញ្ញាបនបត្រ-ដែលចេញឱ្យដោយបណ្តារដ្ឋផ្សេងទៀតនោះ លើកលែងតែមានមូលហេតុច្បាស់លាស់ដែលជឿជាក់ថា លក្ខខណ្ឌរបស់នាវាមិនឆ្លើយតបជាសារវន្តទៅនឹងកិនភាគនៃនាវាដែលមានក្នុងវិញ្ញានបត្រទាំងនោះ។

៤. ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់មាត្រា២១៨ មាត្រា២២០ និងមាត្រា២២៨ ប្រសិនបើនាវាបំពានលើវិធាននិងបទដ្ឋានដែលបានបង្កើតឡើងដោយអង្គការអន្តរជាតិមានសមត្ថកិច្ចឬសន្និសីទការទូតទូទៅ នោះរដ្ឋម្ចាស់សញ្ជាតិនាវា ត្រូវធ្វើការស៊ើបអង្កេតភ្លាមៗ ហើយនៅទីណាដែលសមស្រប អាចធ្វើនីតិវិធីបណ្ដឹងទាក់ទងនឹងការបំពានដែលបានចោទប្រកាន់ មិនថាការបំពាននោះ បានកើតឡើងនៅទីកន្លែងណា ឬការបំពុលដែលបង្កឡើងដោយការបំពាននេះបានកើតឡើងឬបានរកឃើញនៅទីកន្លែងណានោះទេ។

៥. បណ្ដារដ្ឋម្ចាស់សញ្ជាតិនាវាដែលធ្វើការស៊ើបអង្កេតលើការបំពានអាចស្នើសុំជំនួយពីរដ្ឋផ្សេងទៀតដែលកិច្ចសហប្រតិបត្តិការនេះអាចមានប្រយោជន៍ក្នុងការបំភ្លឺអំពីអង្គហេតុនៃករណីនោះ។ បណ្ដារដ្ឋទាំងនោះត្រូវខិតខំប្រឹងប្រែងបំពេញតាមការស្នើសុំរបស់រដ្ឋម្ចាស់សញ្ជាតិនាវាទាំងឡាយឱ្យសមស្រប។

៦. ដោយមានការស្នើសុំជាលាយលក្ខណ៍អក្សរពីរដ្ឋណាមួយ បណ្ដារដ្ឋត្រូវធ្វើការស៊ើបអង្កេតលើការបំពានណាមួយ ដែលបានចោទប្រកាន់ថាបានប្រព្រឹត្តដោយនាវាដែលពាក់ទង់ជាតិរបស់ខ្លួន។ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ដែលអាចដំណើរការនីតិវិធីបណ្ដឹងដែលទាក់ទងនឹងការបំពានដែលបានចោទប្រកាន់នោះ បណ្ដារដ្ឋម្ចាស់សញ្ជាតិនាវាត្រូវធ្វើនីតិវិធីបណ្ដឹងដោយអនុលោមតាមច្បាប់របស់ខ្លួនដោយគ្មានការពន្យារពេល។

៧. បណ្ដារដ្ឋម្ចាស់សញ្ជាតិនាវាត្រូវជូនដំណឹងជាបន្ទាន់ដល់រដ្ឋស្នើសុំ និងអង្គការអន្តរជាតិមានសមត្ថកិច្ចអំពីចំណាត់ការដែលបានធ្វើរួចនិងលទ្ធផលដែលទទួលបាន។ ព័ត៌មានទាំងនោះត្រូវដាក់ឱ្យបណ្ដារដ្ឋទាំងអស់អាចស្វែងរកបាន។

៨. ទណ្ឌកម្មដូចមានចែងក្នុងច្បាប់និងបទបញ្ញារបស់បណ្ដារដ្ឋចំពោះនាវាដែលពាក់ទង់ជាតិរបស់ខ្លួន ត្រូវមានទម្ងន់ទោសគ្រប់គ្រាន់ ដើម្បីបង្ការកុំឱ្យមានការបំពានាកើតឡើង ទោះនៅទីណាក៏ដោយ។

## មាត្រា២១៨
## ការអនុវត្តច្បាប់ដោយរដ្ឋម្ចាស់កំពង់ផែ

១. នៅពេលនាវាស្ថិតនៅក្នុងកំពង់ផែ ឬទីលានចំណតដែលស្ថិតនៅឆ្ងាយច្រាំងរបស់រដ្ឋមួយដោយខ្លួនឯង រដ្ឋនោះអាចធ្វើការស៊ើបអង្កេត និងនៅពេលដែលមានភស្តុតាងរឹងមាំ រដ្ឋនោះអាចធ្វើនីតិវិធីបណ្ដឹងទាក់ទងនឹងការបញ្ចេញកាកសំណល់ពីនាវានោះទៅខាងក្រៅដែនទឹកផ្ទៃក្នុង សមុទ្រដែនដី ឬតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់រដ្ឋនោះដោយបំពានវិធាននិងបទដ្ឋានអន្តរជាតិជាធរមានដែលបានបង្កើតឡើងដោយអង្គការអន្តរជាតិមានសមត្ថកិច្ចឬសន្និសីទការទូតទូទៅ។

២. ដោយអនុលោមតាមកថាខណ្ឌទី១ គ្មាននីតិវិធីបណ្ដឹងណាមួយត្រូវបានធ្វើឡើងទាក់ទងនឹងការបំពានដោយការបញ្ចេញកាកសំណល់ក្នុងដែនទឹកផ្ទៃក្នុង សមុទ្រដែនដី ឬតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់រដ្ឋផ្សេងទៀតឡើយ វៀរលែងតែមានការស្នើសុំដោយរដ្ឋនោះ រដ្ឋម្ចាស់សញ្ជាតិនាវា ឬរដ្ឋដែលរងព្យសនកម្មឬរងការគំរាមកំហែងពីការបំពាននោះ ឬវៀរលែងតែការបំពាននោះបានបណ្ដាល ឬអាចនឹងបណ្ដាលឱ្យមានការបំពុលនៅក្នុងដែនទឹកផ្ទៃក្នុង សមុទ្រដែនដី ឬតំបន់សេដ្ឋកិច្ចផ្ដាច់មុខរបស់រដ្ឋដែលធ្វើនីតិវិធីបណ្ដឹង។

៣. នៅពេលដែលនាវាស្ថិតនៅក្នុងកំពង់ផែ ឬទីលានចំណតនាវាដែលស្ថិតនៅឆ្ងាយច្រាំងរបស់រដ្ឋមួយដោយខ្លួនឯងតាមដែលអាចអនុវត្តទៅបាន រដ្ឋនោះត្រូវគោរពតាមសំណើពីរដ្ឋផ្សេងទៀតដែលសុំឱ្យមានការស៊ើបអង្កេតលើការបំពានដោយការបញ្ចេញចោលកាកសំណល់ដូចមានចែងក្នុងកថាខណ្ឌទី១ ដែលបានជឿជាក់ថាបានកើតឡើងនៅក្នុងបានបង្កឱ្យមាន ឬបានគំរាមកំហែងឱ្យមានការខូចខាតដល់ដែនទឹកផ្ទៃក្នុង សមុទ្រដែនដី ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋស្នើសុំ។ ដូចគ្នានេះដែរតាមដែលអាចអនុវត្តទៅបាន រដ្ឋនោះត្រូវគោរពតាមសំណើពីរដ្ឋម្ចាស់សញ្ជាតិនាវាដែលសុំឱ្យមានការស៊ើបអង្កេតលើការបំពានទាំងនេះ ទោះបីជាការបំពាននោះបានកើតឡើងនៅទីកន្លែងណាក៏ដោយ។

៤. កំណត់ត្រានៃការស៊ើបអង្កេតដែលបានធ្វើឡើងដោយរដ្ឋម្ចាស់កំពង់ផែអនុលោមតាមមាត្រានេះ ត្រូវបញ្ជូនទៅរដ្ឋម្ចាស់សញ្ជាតិនាវា ឬទៅរដ្ឋជាប់ឆ្នេរសមុទ្រ បន្ទាប់ពីមានការស្នើសុំពីរដ្ឋទាំងនោះ។ នីតិវិធីបណ្តឹងដែលបានធ្វើឡើងដោយរដ្ឋម្ចាស់កំពង់ផែ ដោយផ្អែកលើមូលដ្ឋាននៃការស៊ើបអង្កេតនោះ អនុលោមតាមផ្នែកទី៧ អាចត្រូវបានផ្អាកតាមសំណើរបស់រដ្ឋរដ្ឋជាប់ឆ្នេរសមុទ្រ នៅពេលដែលការបំពាននោះបានកើតឡើងនៅក្នុងដែនទឹកផ្ទៃក្នុង សមុទ្រដែនដី ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន។ ក្នុងករណីនេះ ភស្តុតាងនិងកំណត់ត្រាអំពីសំណុំរឿង រួមទាំងប័ណ្ណបំណុល ឬ ប្រាក់តម្កល់ជានាផ្សេងទៀតដែលតម្កល់ទុកនៅអាជ្ញាធរនៃរដ្ឋម្ចាស់កំពង់ផែត្រូវបានបញ្ជូនទៅឱ្យរដ្ឋរដ្ឋជាប់ឆ្នេរសមុទ្រ។ ការបញ្ជូននេះត្រូវមានអានុភាពលុបចោលនូវការបន្តនីតិវិធីបណ្តឹងក្នុងរដ្ឋម្ចាស់កំពង់ផែ។

## មាត្រា២១៩

## វិធានការទាក់ទងនឹងសុវត្ថិភាពរបស់នាវាដើម្បីជៀសវាងការបំពុល

ដោយអនុលោមតាមផ្នែកទី៧ បន្ទាប់ពីទទួលបានសំណើឬតាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន បណ្តារដ្ឋដែលប្រាកដថានាវានៅក្នុងកំពង់ផែមួយក្នុងចំណោមកំពង់ផែនានារបស់ខ្លួន ឬទីលានចំណតនាវាមួយក្នុងចំណោមទីលានចំណតនាវារបស់ខ្លួនដែលស្ថិតនៅឆ្ងាយពីឆ្នេរសមុទ្របំពានវិធាននិងបទដ្ឋានអន្តរជាតិជាធរមានទាក់ទងនឹងសុវត្ថិភាពរបស់នាវានិងគំរាមកំហែង ដែលបង្កឱ្យមានព្យសនកម្មដល់បរិស្ថានសមុទ្រ ត្រូវចាត់វិធានការរដ្ឋបាលដើម្បីទប់ស្កាត់កុំឱ្យនាវានោះធ្វើនាវាចរណ៍តាមដែលអាចអនុវត្តទៅបាន។ បណ្តារដ្ឋទាំងនេះអាចអនុញ្ញាតឱ្យនាវាធ្វើដំណើរតែទៅកាន់យានដ្ឋានជួសជុលសមស្របដែលស្ថិតនៅជិតបំផុតប៉ុណ្ណោះ និងបន្ទាប់ពីការដកចេញនូវមូលហេតុនៃការបំពាន ត្រូវអនុញ្ញាតឱ្យនាវាបន្តដំណើរជាបន្ទាន់។

## មាត្រា២២០

## ការអនុវត្តច្បាប់ដោយរដ្ឋជាប់ឆ្នេរសមុទ្រ

១. ក្នុងករណីដែលនាវាបានចូលមកកំពង់ផែឬស្ថានីយ៍ក្រៅឆ្នេររបស់រដ្ឋមួយដោយស្ម័គ្រចិត្តរដ្ឋនោះ ដោយអនុលោមតាមផ្នែកទី៧ អាចចាប់ផ្តើមដំណើរការនីតិវិធីពាក់ព័ន្ធការរំលោភបំពានច្បាប់ និងបទបញ្ញារបស់ខ្លួនដែលបានអនុម័តស្របតាមអនុសញ្ញានេះឬវិធាន និងបទដ្ឋានអន្តរជាតិជាធរមាន សម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលពីនាវា ក្នុងករណីដែលការរំលោភបំពាននេះកើតឡើងនៅក្នុងសមុទ្រ ដែនដីឬតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃរដ្ឋនោះ។

២. ក្នុងករណីដែលមានមូលដ្ឋានច្បាស់លាស់ដើម្បីជឿថានាវាដែលធ្វើដំណើរនៅក្នុងសមុទ្រដែនដីរបស់រដ្ឋមួយ ដែលក្នុងអំឡុងពេលធ្វើដំណើរនោះបានរំលោភបំពានច្បាប់និងបទបញ្ជារបស់រដ្ឋនោះស្រប តាមអនុសញ្ញានេះឬវិធាន និងបទដ្ឋានអន្តរជាតិជាធរមានសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលពីនាវា រដ្ឋនោះដោយមិនប៉ះពាល់ដល់ការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធក្នុងផ្នែកទី៣ ជំពូកទី២ អាចធ្វើការត្រួតពិនិត្យនាវាដោយផ្ទាល់ពាក់ព័ន្ធនឹងការរំលោភបំពាន និងក្នុងករណីដែលមានភស្តុតាងច្បាស់លាស់ រដ្ឋនោះអាចចាប់ផ្តើមដំណើរការនីតិវិធីរួមទាំងការការឃាត់នាវា ស្របតាមច្បាប់របស់ខ្លួន ដែលអនុលោមតាម បទប្បញ្ញត្តិនៃផ្នែកទី៧។

៣. ក្នុងករណីដែលមានមូលដ្ឋានច្បាស់លាស់ដើម្បីជឿថានាវាដែលធ្វើដំណើរនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខឬសមុទ្រដែនដីរបស់រដ្ឋមួយ ដែលនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខបានរំលោភបំពានវិធាន និងបទដ្ឋានអន្តរជាតិជាធរមានសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលពីនាវា ឬច្បាប់និងបទបញ្ជារបស់រដ្ឋនោះដែលផ្តល់អនុលោមភាពនិងអនុភាពដល់វិធាននិងបទដ្ឋាននោះ ដែលរដ្ឋអាចតម្រូវឱ្យនាវានោះផ្តល់ព័ត៌មានអំពីអត្តសញ្ញាណរបស់ខ្លួន និងកំពង់ផែដែលបានចុះបញ្ជី កំពង់ផែដែលខ្លួនចតចុងក្រោយបង្អស់និងបន្ទាប់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតចាំបាច់ដើម្បីកំណត់ថាតើការ មានការរំលោភបំពានដែរឬទេ។

៤. បណ្តារដ្ឋត្រូវអនុម័តច្បាប់និងបទបញ្ជានិងត្រូវចាត់វិធានការផ្សេងទៀត ដើម្បីធ្វើយ៉ាងណាឱ្យនាវាដែលបំពាក់ទង់ជាតិរបស់ខ្លួនអនុវត្តតាមសំណើរក្នុងការផ្តល់ព័ត៌មានស្របតាមកថាខ័ណ្ឌទី៣។

៥. ក្នុងករណីដែលមានមូលដ្ឋានច្បាស់លាស់ដើម្បីជឿថានាវាដែលធ្វើដំណើរនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខឬសមុទ្រដែនដីរបស់រដ្ឋមួយដែលនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខបានរំលោភបំពានដូចដូចមានចែងនៅក្នុងកថាខ័ណ្ឌទី៣ ដែលបង្កឱ្យការបញ្ចេញសារធាតុច្រើននាំឱ្យមានឬអាចបង្កឱ្យមានការបំពុលធ្ងន់ធ្ងរដល់បរិស្ថានសមុទ្រ រដ្ឋនោះអាចធ្វើការត្រួតពិនិត្យនាវាដោយផ្ទាល់ពាក់ព័ន្ធនឹងការរំលោភបំពាន ប្រសិនបើនាវានោះបដិសេធក្នុងផ្តល់ព័ត៌មានឬប្រសិនបើព័ត៌មានដែលបានផ្តល់ដោយនាវានោះមានលក្ខណៈ ខុសគ្នាពីស្ថានភាពជាក់ស្តែង និងប្រសិនបើកាលៈទេសៈនៃករណីនោះតម្រូវឱ្យមានការត្រួតពិនិត្យ។

៦. ក្នុងករណីមានភស្តុតាងច្បាស់លាស់ថានាវាដែលធ្វើដំណើរក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខឬសមុទ្រដែនដីរបស់រដ្ឋមួយ ដែលនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខបានរំលោភបំពានដូចដូចមានចែងនៅក្នុង កថាខ័ណ្ឌទី៣ ដែលកើតឡើងពីការបញ្ចេញសារធាតុបង្កឱ្យមានការខូចខាតឬការគំរាមកំហែងធ្ងន់ធ្ងរដល់ខ្សែបន្ទាត់ឆ្នេរ ឬពាក់ព័ន្ធនឹងអត្ថប្រយោជន៍របស់រដ្ឋជាប់ឆ្នេរសមុទ្រនោះ ឬដល់រាល់ធនធាននៅសមុទ្រដែនដី ឬតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋនោះ រដ្ឋនោះអាចស្របតាមផ្នែកទី៧ ក្នុងលក្ខខណ្ឌដែលមានភស្តុតាងច្បាស់ លាស់ ចាប់ផ្តល់ដំណើរនីតិវិធីរួមទាំងការឃាត់ទុកនាវានោះស្របតាមច្បាប់របស់ខ្លួន។

៧. ទោះបីជាមានចែងនៅក្នុងបទប្បញ្ញត្តិនៃកថាខ័ណ្ឌទី៦ នៅពេលដែលនីតិវិធីសមស្របមួយត្រូវបានបង្កើតឡើង ទោះបីជាតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬតាមរយៈការព្រមព្រៀងផ្សេងពីនេះ ក្នុងករណីដែលមានការអនុវត្តតាមលក្ខខណ្ឌតម្រូវឱ្យផ្តល់ការធានា ឬការធានាជាហិរញ្ញវត្ថុដែលសមស្របត្រូវ បានផ្តល់រដ្ឋជាប់ឆ្នេរសមុទ្រ ប្រសិនបើចងកាតព្វកិច្ចដោយនីតិវិធីនេះ ត្រូវអនុវត្តឱ្យនាវានោះបន្តដំណើរ។

៨. បទប្បញ្ញត្តិនៃកថាខ័ណ្ឌទី៣ កថាខ័ណ្ឌទី៤ កថាខ័ណ្ឌទី៥ កថាខ័ណ្ឌទី៦ និងកថាខ័ណ្ឌទី៧ ត្រូវអនុវត្តផងដែរចំពោះច្បាប់និងបទបញ្ជាជាតិ ដែលអនុម័តស្របតាមកថាខ័ណ្ឌទី៦ នៃមាត្រា២១១។

## មាត្រា២២១

## វិធានការដើម្បីបញ្ចៀសការបំពុលដែលកើតចេញពីគ្រោះថ្នាក់នៅសមុទ្រ

១. គ្មានបទប្បញ្ញត្តិណាមួយក្នុងជំពូកនេះប៉ះពាល់ដល់សិទ្ធិរបស់បណ្តារដ្ឋ ស្របតាមតាមច្បាប់អន្តរជាតិ ដែលមានទាំងច្បាប់ទំនៀមទំលាប់និងច្បាប់ជាលក្ខណ៍អក្សរ ដើម្បីចាត់និងអនុវត្តវិធាន លាតសន្ធឹងហួសសមុទ្រដែនដី ដែលសមាមាត្រទៅការខូចខាតជាក់ស្តែង ឬការគំរាមគំហែងខូចខាត ដើម្បីការងារខ្សែបន្ទាត់ឆ្នេរ ឬអត្ថប្រយោជន៍ពាក់ព័ន្ធ រួមទាំងការនេសាទ ពីការបំពុល ឬការគំរាមគំហែងនៃការ បំពុលដែលកើតមានឡើងពីគ្រោះថ្នាក់នៅសមុទ្រ ឬសកម្មភាពពាក់ព័ន្ធនឹងគ្រោះថ្នាក់នោះ ដែលអាចកើតមាន ដោយសមហេតុផលនូវគ្រោះថ្នាក់ធ្ងន់ធ្ងរ។

២. សម្រាប់គោលបំណងនៃមាត្រានេះ «គ្រោះថ្នាក់នៅសមុទ្រ» សំដៅដល់ការប៉ះទង្គិចរវាងនាវា ការជាប់គៀង ឬឧប្បត្តិហេតុផ្សេងទៀតនៃនាវាចរណ៍ ឬហេតុការណ៍ផ្សេងទៀតដែលកើតឡើងនៅលើនាវា ឬខាងក្រៅនាវានោះ ដែលបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរ ឬការគំរាមកំហែងចំពោះមុខចំពោះការខូចខាតធ្ងន់ធ្ងរដល់នាវា ឬទំនិញ។

## មាត្រា២២២

## ការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការបំពុលពីឬតាមបរិយាកាស

បណ្តារដ្ឋត្រូវអនុវត្ត នៅក្នុងដែនអាកាសក្រោមអធិបតេយ្យភាពរបស់ខ្លួនឬចំពោះនាវាពាក់ទង់ជាតិរបស់ខ្លួន ឬនាវាឬអាកាសយានដែលខ្លួនបានចុះបញ្ជីនូវច្បាប់និងបទបញ្ជារបស់រដ្ឋនោះស្របតាមកថាខ័ណ្ឌ ទ១ នៃមាត្រា ២១២ និងចំពោះបទប្បញ្ញត្តិផ្សេងទៀតរបស់អនុសញ្ញានេះ និងត្រូវអនុម័តច្បាប់និងបទបញ្ជា និងចាត់វិធានការចាំបាច់ដើម្បីអនុវត្តវិធាននិងបទដ្ឋានអន្តរជាតិជាធរមាន ដែលបានបង្កើតឡើងតាមរយៈ អង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសិទការទូត សម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រង ការបំពុលបរិស្ថានសមុទ្រពីឬតាមបរិយាកាស ដោយស្របតាមរាល់វិធាននិងបទដ្ឋានអន្តរជាតិពាក់ព័ន្ធ ទាំងអស់ស្តីពីសុវត្ថិភាពនៃការនាំផ្លូវអាកាស។

# ផ្នែកទី៧

# វិធានការការពារ

## មាត្រា២២៣

## វិធានការក្នុងការសម្រួលនីតិវិធី

ក្នុងនីតិវិធីដែលផ្តើមឡើងអនុលោមទៅតាមជំពូកនេះ បណ្តារដ្ឋត្រូវចាត់វិធានការដើម្បីសម្រួលនូវការសួរសាក្សី និងការទទួលយកភស្តុតាងដែលដាក់ដោយអាជ្ញាធរនៃរដ្ឋមួយទៀត ឬដាក់ដោយអង្គការអន្តរជាតិដែលមានសមត្ថកិច្ច និងត្រូវសម្រួលដល់ការចូលរួមនៅក្នុងនីតិវិធីទាំងនេះដោយអ្នកតំណាងផ្លូវការរបស់អង្គការអន្តរជាតិដែលមានសមត្ថកិច្ច រដ្ឋម្ចាស់សញ្ជាតិ និងរដ្ឋណាមួយដែលរងការប៉ះពាល់ពីការបំពុលបរិស្ថានដែលកើតចេញពីការរំលោភបំពាននោះ។ តំណាងផ្លូវការដែលចូលរួមក្នុងនីតិវិធីនេះត្រូវមានសិទ្ធិ និងករណីយកិច្ចដូចដែលចែងដោយច្បាប់និងបទប្បញ្ញត្តិជាតិ ឬនីតិអន្តរជាតិ។

## មាត្រា២២៤

## ការប្រើប្រាស់អំណាចក្នុងការអនុវត្តវិធានការ

អំណាចក្នុងការអនុវត្តវិធានការប្រឆាំងនឹងនាវាបរទេសក្រោមជំពូកនេះ អាចត្រូវអនុវត្តដោយមន្ត្រី ឬដោយនាវាចម្បាំង អាកាសយានយោធា ឬនាវា ឬអាកាសយានផ្សេងទៀតដែលមានសញ្ញា និងអាចកំណត់អំពីអត្តសញ្ញាណបានយ៉ាងច្បាស់ថា កំពុងបំពេញការងារឱ្យរដ្ឋាភិបាល និងទទួលបានសិទ្ធិក្នុងការអនុវត្តនេះតែប៉ុណ្ណោះ។

## មាត្រា២២៥
## ករណីយកិច្ចដើម្បីជៀសវាងនូវផលវិបាកអវិជ្ជមានក្នុងការអនុវត្តអំណាច

ក្នុងការអនុវត្តនូវអំណាចរបស់ខ្លួន ប្រឆាំងនឹងនាវាបរទេសក្រោមអនុសញ្ញានេះ បណ្តារដ្ឋមិនត្រូវបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពក្នុងការធ្វើនាវាចរណ៍ ឬបង្កើតនូវគ្រោះថ្នាក់ណាមួយដល់នាវា ឬនាំនាវានោះទៅកាន់កំពង់ផែ ឬបោះយុថ្កាចតដោយគ្មានសុវត្ថិភាព ឬបង្កឱ្យបរិស្ថានសមុទ្រប្រឈមទៅនឹងហានិភ័យមិនសមហេតុផល។

## មាត្រា២២៦
## ការស៊ើបអង្កេតលើនាវាបរទេស

១. (ក) បណ្តារដ្ឋ មិនត្រូវពន្យារពេលលើសពីរយៈពេលចាំបាច់សម្រាប់គោលបំណងនៃការស៊ើបអង្កេតលើនាវាបរទេសដូចមានចែងក្នុងមាត្រា២១៦ មាត្រា២១៨ និងមាត្រា២២០ នោះឡើយ។ រាល់ការពិនិត្យជារូបវន្តលើនាវាបរទេស ត្រូវកំណត់ត្រឹមការពិនិត្យលើវិញ្ញាបនបត្រ កំណត់ត្រា ឬឯកសារផ្សេងទៀតដែលនាវាចាំបាច់ត្រូវមាន តម្រូវដោយវិធាននិងបទដ្ឋានដែលទទួលស្គាល់ជាអន្តរជាតិ ឬការពិនិត្យលើឯកសារស្រដៀងគ្នាផ្សេងទៀតដែលនាវាមាន។ ការត្រួតពិនិត្យជារូបវន្តបន្ថែមទៀតលើនាវា អាចត្រូវបានធ្វើក្រោយពីការពិនិត្យ និងត្រូវធ្វើឡើងតែក្នុងករណីខាងក្រោម ៖

(i) មានមូលហេតុច្បាស់លាស់ដែលអាចជឿជាក់ថា លក្ខខណ្ឌនៃនាវាឬឧបករណ៍របស់នាវាមិនឆ្លើយតបខ្លាំងទៅនឹងភិនភាគដែលបានក្នុងឯកសារ។

(ii) មាតិកានៃឯកសារទាំងនោះមិនគ្រប់គ្រាន់ក្នុងការបញ្ជាក់ ឬផ្ទៀងផ្ទាត់ពីការបំពានដែលបានសង្ស័យ ឬ

(iii) នាវាមិនបានយកតាមនូវវិញ្ញាបនបត្រ និងកំណត់ត្រាដែលមានសុពលភាព។

(ខ) ប្រសិនបើការស៊ើបអង្កេតបង្ហាញថា មានការបំពានច្បាប់និងបទប្បញ្ញត្តិជាតិ ឬវិធាននិងបទដ្ឋានអន្តរជាតិសម្រាប់ការការពារ និងការថែរក្សាបរិស្ថានសមុទ្រនោះការដោះលែងនាវានោះត្រូវធ្វើឡើងភ្លាមៗតាមនីតិវិធីសមស្រប ដូចជាការបង់ប្រាក់កក់ឬការតម្កល់មូលប្បទានប័ត្រជានាផ្សេងទៀត។

(គ) ដោយមិនប៉ះពាល់ដល់វិធាននិងបទដ្ឋានអន្តរជាតិជាធរមានពាក់ព័ន្ធនឹងភាពស័ក្តិសមក្នុងការធ្វើនាវាចរណ៍តាមសមុទ្ររបស់នាវា ក្នុងករណីដែលបង្ហាញថាមានការគំរាមកំហែងបង្កការខូចខាតមិនសមហេតុផលដល់បរិស្ថានសមុទ្រ ការដោះលែងនាវា ត្រូវបានបដិសេធ ឬត្រូវបានកំណត់លក្ខខណ្ឌឱ្យធ្វើដំណើរទៅកាន់យានដ្ឋានជួសជុលនាវាសមស្របដែលនៅជិតបំផុត។ក្នុងករណីដែលការដោះលែងត្រូវបានបដិសេធ ឬត្រូវបានកំណត់លក្ខខណ្ឌរដ្ឋម្ចាស់សញ្ជាតិនាវាត្រូវទទួលបានការជូនដំណឹងជាបន្ទាន់ និងអាចស្វែងរកការដោះលែងនាវានោះ ដោយអនុលោមតាមជំពូកទី១៥។

២. បណ្តារដ្ឋត្រូវសហការគ្នាបង្កើតនីតិវិធីសម្រាប់ជៀសវាងការត្រួតពិនិត្យជារូបវន្តដែលមិនចាំបាច់លើនាវានៅសមុទ្រ។

## មាត្រា២២៧
## ការមិនរើសអើងចំពោះនាវាបរទេស

ក្នុងការអនុវត្តសិទ្ធិនិងករណីយកិច្ចរបស់ខ្លួនក្រោមជំពូកនេះ បណ្តារដ្ឋមិនត្រូវរើសអើងក្នុងទម្រង់ឬតាមព្រឹត្តិន័យណាមួយចំពោះនាវារបស់រដ្ឋផ្សេងណាមួយឡើយ។

## មាត្រា២២៨
## ការផ្អាកនិងការកម្រិតលើការផ្តើមនីតិវិធី

១. នីតិវិធីក្នុងការដាក់ពិន័យចំពោះការបំពានច្បាប់និងបទញ្ញាជាតិ ឬវិធាននិងបទដ្ឋានអន្តរជាតិជាធរមានទាក់ទងនឹងការបង្ការ ការកាត់បន្ថយ និងគ្រប់គ្រងការបំពុលពីនាវា ដែលបានប្រព្រឹត្តឡើងដោយនាវាបរទេសនៅហួសពីសមុទ្រដែនដីរបស់រដ្ឋដែលផ្តើមនីតិវិធីត្រូវបានផ្អាកបន្ទាប់ពីអនុវត្តនីតិវិធីក្នុងការដាក់ពិន័យជាប្រាក់ដោយរដ្ឋម្ចាស់សញ្ជាតិក្នុងរយៈពេលប្រាំមួយខែនៃកាលបរិច្ឆេទដែលនីតិវិធីដំបូងបានចាប់ផ្តើម លើកលែងតែនីតិវិធីទាំងនោះទាក់ទងនឹងករណីការខូចខាតធ្ងន់ធ្ងរទៅលើរដ្ឋជាប់ឆ្នេរសមុទ្រ ឬរដ្ឋម្ចាស់សញ្ជាតិនោះ ដោយមិនយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចរបស់ខ្លួនម្តងហើយម្តងទៀត ក្នុងការអនុវត្តដោយប្រកបដោយប្រសិទ្ធភាពនូវវិធាននិងបទដ្ឋានអន្តរជាតិជាធរមានដែលទាក់ទងនឹងការបំពានដែលបានប្រព្រឹត្តដោយនាវារបស់ខ្លួន។ រដ្ឋម្ចាស់សញ្ជាតិត្រូវផ្តល់ទៅរដ្ឋផ្តើមនីតិវិធីឱ្យទាន់ពេលវេលានូវសំណុំរឿងពេញលេញនិងកំណត់ហេតុនៃនីតិវិធី នៅពេលដែលរដ្ឋម្ចាស់សញ្ជាតិនោះបានស្នើសុំឱ្យមានការផ្អាកនីតិវិធី អនុលោមតាមមាត្រានេះ។ នៅពេលដែលនីតិវិធីផ្តើមដោយរដ្ឋម្ចាស់សញ្ជាតិបានឈានដល់ការធ្វើសេចក្តីសម្រេច នោះនីតិវិធិដែលបានផ្អាកនោះត្រូវបញ្ចប់។ បន្ទាប់ពីបានបង់ប្រាក់ចំណាយទាក់ទងនឹងនីតិវីធិនេះរួច ប្រាក់កក់ឬមូលប្បទានប័ត្រធានាដែលបានតម្កល់ទាក់ទងនឹងនីតិវិធីដែលបានផ្អាកនោះត្រូវប្រគល់ជូនវិញដោយរដ្ឋជាប់ឆ្នេរសមុទ្រ។

២. នីតិវិធីក្នុងការដាក់ពិន័យលើនាវាបរទេសមិនត្រូវផ្តើម បន្ទាប់ពីផុតសុពលភាព៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលការបំពានត្រូវបានប្រព្រឹត្តឡើង និងមិនត្រូវអនុវត្តដោយរដ្ឋណាមួយឡើយក្នុងករណីដែលនីតិវិធីបានផ្តើមធ្វើដោយរដ្ឋមួយផ្សេងទៀតស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌទី១។

៣. បទប្បញ្ញត្តិនៃមាត្រានេះ មិនប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋម្ចាស់សញ្ជាតិក្នុងការចាត់វិធានការណាមួយរួមមាននីតិវិធីក្នុងការដាក់ពិន័យស្របតាមច្បាប់របស់ខ្លួន ដោយមិនគិតពីនីតិវិធីពីមុនដែលធ្វើឡើងដោយរដ្ឋណាមួយផ្សេងទៀត។

## មាត្រា២២៩
## ការចាប់ផ្តើមដំណើរការនីតិវិធីរដ្ឋប្បវេណី

គ្មានបទប្បញ្ញត្តិណាមួយក្នុងអនុសញ្ញានេះ ប៉ះពាល់ដល់ការចាប់ផ្តើមដំណើរការនីតិវិធីរដ្ឋប្បវេណីទាក់ទងនឹងការទាមទារសំណងលើការបាត់បង់ ឬការខូចខាតដែលបង្កឡើងពីការបំពុលបរិស្ថានសមុទ្រឡើយ។

## មាត្រា២៣០
## ការពិន័យជាប្រាក់និងការគោរពសិទ្ធិរបស់ជនជាប់ចោទ

១. ការពិន័យជាប្រាក់ អាចធ្វើឡើងតែចំពោះការបំពានច្បាប់និងបទបញ្ញាជាតិ ឬវិធាននិងបទដ្ឋានអន្តរជាតិ ជាធរមានសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ដែលបានប្រព្រឹត្តដោយនាវាបរទេសនៅហួសពីសមុទ្រដែនដីប៉ុណ្ណោះ។

២. ការពិន័យជាប្រាក់ អាចធ្វើឡើងតែចំពោះការបំពានច្បាប់ និងបទបញ្ញាជាតិ ឬវិធាននិងបទដ្ឋានអន្តរជាតិ ជាធរមានសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រ ដែលបានប្រព្រឹត្តដោយនាវាបរទេសនៅក្នុងសមុទ្រដែនដី លើកលែងតែក្នុងករណីនៃសកម្មភាពបំពុលដែលត្រូវបានប្រព្រឹត្តធ្ងន់ធ្ងរ និងដោយចេតនានៅក្នុងសមុទ្រដែនដីនេះ។

៣. ក្នុងការអនុវត្តដំណើរការនីតិវិធីពាក់ព័ន្ធនឹងការបំពាននោះដោយនាវាបរទេស ដែលអាចបង្កឱ្យមានការដាក់ពិន័យ សិទ្ធិរបស់ជនជាប់ចោទ ត្រូវតែបានគោរព។

## មាត្រា២៣១
## ការជូនដំណឹងដល់រដ្ឋម្ចាស់សញ្ជាតិនិងបណ្តារដ្ឋពាក់ព័ន្ធ

បណ្តារដ្ឋត្រូវជូនដំណឹងជាបន្ទាន់ដល់រដ្ឋម្ចាស់សញ្ជាតិនិងរដ្ឋពាក់ព័ន្ធអំពីវិធានការដែលបានអនុវត្តលើនាវាបរទេសដោយអនុលោមតាមផ្នែកទី៦ និងត្រូវផ្ញើជូនទៅរដ្ឋម្ចាស់សញ្ជាតិនូវរបាយការណ៍ផ្លូវការទាំងអស់ដែលពាក់ព័ន្ធនឹងវិធានការទាំងនោះ។ ប៉ុន្តែ ករណីមានការបំពានដែលបានប្រព្រឹត្តក្នុងសមុទ្រដែនដី កាតព្វកិច្ចបន្តរបស់រដ្ឋជាប់ឆ្នេរសមុទ្រអាចអនុវត្តត្រឹមវិធានការដែលត្រូវធ្វើឡើងក្នុងដំណើរការក្តីប៉ុណ្ណោះ។ មន្ត្រីការទូត ឬមន្ត្រីកុងស៊ុល និងក្នុងករណីខ្លះអាជ្ញាធរនាវាចរណ៍របស់រដ្ឋម្ចាស់សញ្ជាតិ ត្រូវទទួលការជូនដំណឹងជាបន្ទាន់អំពីវិធានការ ដែលបានអនុវត្តលើនាវាបរទេសដោយអនុលោមតាមផ្នែកទី៦។

## មាត្រា២៣២
## ការទទួលខុសត្រូវរបស់បណ្តារដ្ឋដែលកើតចេញពីវិធានការអនុវត្ត

បណ្តារដ្ឋត្រូវទទួលខុសត្រូវសងលើការខូចខាតឬការបាត់បង់ ដែលត្រូវកំណត់មកលើបណ្តារដ្ឋនោះ ដែលកើតចេញ ពីវិធានការដែលបានអនុវត្តដោយអនុលោមតាមផ្នែកទី៦ នៅពេលដែលវិធានការទាំងនេះ មិនស្របច្បាប់ ឬលើសពីអ្វីដែលសមស្របនិងចាំបាច់ ផ្អែកតាមព័ត៌មានដែលមាន។ បណ្តារដ្ឋ ត្រូវទទួលខុសត្រូវចំពោះមុខតុលាការរបស់ខ្លួនចំពោះសកម្មភាពដែលទាក់ទងនឹងការខូចខាត ឬការបាត់បង់ទាំងនេះ។

## មាត្រា២៣៣
## ការការពារចំពោះច្រកសមុទ្រដែលប្រើប្រាស់សម្រាប់ការធ្វើនាវាចរណ៍អន្តរជាតិ

គ្មានបទប្បញ្ញត្តិណាមួយក្នុងផ្នែកទី៥ ផ្នែកទី៦ និងផ្នែកទី៧ មានអនុភាពលើរបបច្បាប់នៃច្រកសមុទ្រដែលប្រើប្រាស់សម្រាប់ការធ្វើនាវាចរណ៍អន្តរជាតិឡើយ។ ប៉ុន្តែ ក្នុងករណីនាវាបរទេសនក្រៅពីនាវាដែលមានកំណត់ក្នុងផ្នែកទី១០ បានបំពានច្បាប់និងបទបញ្ញាដូចមានចែងក្នុងចំណុច(ក) និងចំណុច(ខ) កថាខណ្ឌទី១ នៃមាត្រា៤២ ដែលបង្កឬគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់បរិស្ថានសមុទ្រនៃច្រកសមុទ្រ បណ្តារដ្ឋដែលមានព្រំដែនជាប់នឹងច្រកសមុទ្រ អាចចាត់វិធានការអនុវត្តដែលសមស្រប ហើយត្រូវគោរពតាមបទប្បញ្ញត្តិនៃជំពូកនេះផងដែរ។

## ផ្នែកទី៨
## តំបន់គ្របដណ្តប់ដោយទឹកកក
### មាត្រា២៣៤
### តំបន់គ្របដណ្តប់ដោយទឹកកក

បណ្តារដ្ឋជាប់ឆ្នេរសមុទ្រមានសិទ្ធិអនុម័តនិងអនុវត្ត ច្បាប់និងបទបញ្ជាដោយគ្មានការរើសអើងសម្រាប់ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុលបរិស្ថានសមុទ្រពីនាវាក្នុងតំបន់គ្របដណ្តប់ដោយទឹកកក នៅក្នុងដែនកំណត់នៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដែលលក្ខខណ្ឌអាកាសធាតុមានសភាពធ្ងន់ធ្ងរជាពិសេស ហើយវត្តមាននៃទឹកកកដែលគ្របដណ្តប់លើតំបន់នោះ ស្ទើរតែជារៀងរាល់ឆ្នាំបង្កើតឱ្យមានឧបសគ្គ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ការធ្វើនាវាចរ ហើយការបំពុលបរិស្ថានសមុទ្រអាចបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរឬការរំខានដែលមិនអាចកែតម្រូវបានចំពោះតុល្យភាពអេកូសាស្ត្រ។ ច្បាប់និងបទបញ្ជាទាំងនេះត្រូវធ្វើឡើងដោយពិចារណាយ៉ាងត្រឹមត្រូវទៅលើការធ្វើនាវាចរនិងការការពារ និងការថែរក្សាបរិស្ថានសមុទ្រ ផ្អែកលើភស្តុតាង វិទ្យាសាស្ត្រ ល្អបំផុតដែលមាន។

## ផ្នែកទី៩
## ភារកិច្ច និងការទទួលខុសត្រូវ
### មាត្រា២៣៥
### ភារកិច្ចនិងការទទួលខុសត្រូវ

១. បណ្តារដ្ឋត្រូវទទួលខុសត្រូវលើការបំពេញកាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួនពាក់ព័ន្ធនឹងការការពារ និងការថែរក្សាបរិស្ថានសមុទ្រ។ ពួកគេត្រូវទទួលខុសត្រូវ អនុលោមតាមច្បាប់អន្តរជាតិ។

២. បណ្តារដ្ឋត្រូវធានាបានថា មានការសម្របសម្រួលដោយអនុលោមតាមប្រព័ន្ធច្បាប់របស់ខ្លួន ក្នុងការផ្តល់សំណងទាន់ពេលវេលានិងពេញលេញ ឬដំណោះស្រាយផ្សេងទៀត ចំពោះការខូចខាតដោយសារការបំពុលបរិស្ថានសមុទ្រ ដោយរូបវន្តបុគ្គលឬនីតិបុគ្គល ក្រោមយុត្តាធិការរបស់រដ្ឋនោះ។

៣. ជាមួយនឹងគោលបំណងធានានូវការផ្តល់សំណងទាន់ពេលវេលានិងពេញលេញចំពោះការខូចខាតទាំងអស់ ដែលបណ្តាលមកពីការបំពុលបរិស្ថានសមុទ្រ បណ្តារដ្ឋត្រូវធ្វើកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់អន្តរជាតិជាធរមាន និងការរៀបចំបន្ថែមទៀតនូវច្បាប់អន្តរជាតិទាក់ទងនឹងភារកិច្ចនិងការទទួលខុសត្រូវ លើការវាយតម្លៃ និងការផ្តល់សំណងចំពោះការខូចខាត និងការដោះស្រាយវិវាទពាក់ព័ន្ធ ប្រសិនបើអាចធ្វើទៅបានរៀបចំលក្ខណៈវិនិច្ឆ័យនិងនីតិវិធីសម្រាប់ការទូទាត់សំណងពេញលេញ ដូចជាការធានារ៉ាប់រងចាំបាច់ឬមូលនិធិប្រាក់សំណង។

## ផ្នែកទី១០
## អភ័យឯកសិទ្ធិអធិបតេយ្យ
### មាត្រា២៣៦
### អភ័យឯកសិទ្ធិអធិបតេយ្យ

បទប្បញ្ញត្តិនៃអនុសញ្ញានេះពាក់ព័ន្ធនឹងការការពារនិងការអភិរក្សបរិស្ថានសមុទ្រមិនអនុវត្តចំពោះ នាវាចំបាំង នាវាជំនួយ នាវាឬអាកាសយានផ្សេងទៀតដែលជាកម្មសិទ្ធិឬប្រតិបត្តិការដោយរដ្ឋ និងត្រូវបានប្រើប្រាស់ក្នុងពេលនោះសម្រាប់តែក្នុងគោលបំណងបម្រើឱ្យរដ្ឋាភិបាលដែលពុំមែនជាលក្ខណៈពាណិជ្ជកម្ម។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋត្រូវធានាថានាវាឬអាកាសយានដែលខ្លួនជាម្ចាស់និងប្រតិបត្តិការ ត្រូវធ្វើសកម្មភាពស្របតាមអនុសញ្ញានេះ ក្នុងវិសាលភាពមួយសមហេតុផលនិងអាចអនុវត្តបានតាមរយៈការចាត់វិធានការសមស្រប ដោយមិនបង្កការខូចខាតដល់ប្រតិបត្តិការឬសមត្ថភាពប្រតិបត្តិរបស់នាវាឬអាកាសយាននោះ។

### ផ្នែកទី១១
### កាតព្វកិច្ចក្រោមអនុសញ្ញាផ្សេងទៀតស្តីពីការការពារនិងការអភិរក្សបរិស្ថានសមុទ្រ

មាត្រា២៣៧

**កាតព្វកិច្ចក្រោមអនុសញ្ញាផ្សេងទៀតស្តីពីការការពារនិងការអភិរក្សបរិស្ថានសមុទ្រ**

១. បទប្បញ្ញត្តិនៃជំពូកនេះ មិនប៉ះពាល់ដល់កាតព្វកិច្ចជាក់លាក់របស់បណ្តារដ្ឋក្រោមអនុសញ្ញា និងកិច្ចព្រមព្រៀងពិសេស ដែលបានធ្វើឡើងកន្លងមកទាក់ទងទៅនឹងការការពារនិងការអភិរក្សបរិស្ថានសមុទ្រ និងកិច្ចព្រមព្រៀងដែលអាចធ្វើឡើងបន្ថែមលើគោលការណ៍ទូទៅដែលបានកំណត់ក្នុងអនុសញ្ញានេះ។

២. កាតព្វកិច្ចជាក់លាក់របស់បណ្តារដ្ឋក្រោមអនុសញ្ញាពិសេសទាក់ទងទៅនឹងការការពារ និងការអភិរក្សបរិស្ថានសមុទ្រ ត្រូវអនុវត្តស្របតាមគោលការណ៍ទូទៅនិងគោលបំណងនៃអនុសញ្ញានេះ។

## ជំពូកទី១៣
## ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ
### ផ្នែកទី១
### បទប្បញ្ញត្តិទូទៅ

មាត្រា២៣៨

**សិទ្ធិធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ**

មាត្រា២៣៩

**ការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ**

បណ្តារដ្ឋនិងអង្គការអន្តរជាតិមានសមត្ថកិច្ចត្រូវលើកកម្ពស់និងសម្របសម្រួលដល់ការរៀបចំនិងធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រដោយអនុលោមតាមអនុសញ្ញានេះ។

មាត្រា២៤០

**គោលការណ៍ទូទៅសម្រាប់ធ្វើការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសមុទ្រ**

ក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ត្រូវអនុវត្តគោលការណ៍ខាងក្រោម៖

(ក) ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រត្រូវធ្វើឡើងតែក្នុងគោលបំណងប្រកបដោយសន្តិភាពប៉ុណ្ណោះ។

(ខ) ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រត្រូវធ្វើឡើងតាមវិធីសាស្ត្រជាលក្ខណៈវិទ្យាសាស្ត្រ និងមធ្យោបាយស្របតាមអនុសញ្ញានេះ។

(គ) ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រមិនត្រូវមានការរំខានដោយមិនសមហេតុផលដល់ការប្រើប្រាស់សមុទ្រជាលក្ខណៈស្របច្បាប់ផ្សេងទៀតស្របតាមអនុសញ្ញានេះ និងត្រូវគោរពយ៉ាងត្រឹមត្រូវក្នុងរយៈពេលនៃការប្រើប្រាស់នេះ។

(ឃ) ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រត្រូវធ្វើឡើងដោយអនុលោមតាមបទបញ្ញាពាក់ព័ន្ធដែលបានអនុម័តទាំងអស់ស្របតាមអនុសញ្ញានេះ ដែលរួមបញ្ចូលនូវការការពារ និងការថែរក្សាបរិស្ថានសមុទ្រផងដែរ។

មាត្រា២៤១

**ការមិនទទួលស្គាល់សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ដែលជាមូលដ្ឋានហេតុគតិយុត្តសម្រាប់ការទាមទារ**

សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ មិនត្រូវបង្កើតជាមូលដ្ឋានគតិយុត្តសម្រាប់ការទាមទារផ្នែកណាមួយនៃបរិស្ថានសមុទ្រឬធនធានរបស់វានោះឡើយ។

## ផ្នែកទី២
## កិច្ចសហប្រតិបត្តិការអន្តរជាតិ

### មាត្រា២៤២
### ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ

១. បណ្តារដ្ឋនិងអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ត្រូវជំរុញលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ នៅក្នុងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រក្នុងគោលបំណងសន្តិភាព ស្របតាមគោលការណ៍គោរពអធិបតេយ្យភាព និងយុត្តាធិការនិងដោយផ្អែកលើផលប្រយោជន៍រួម។

២. នៅក្នុងបរិបទនេះ ដោយមិនត្រូវប៉ះពាល់ដល់សិទ្ធិនិងករណីកិច្ចនៃបណ្តារដ្ឋដែលស្ថិតក្រោមអនុសញ្ញានេះ ដោយអនុវត្តតាមជំពូកនេះរដ្ឋមួយត្រូវផ្តល់តាមភាពសមស្របនូវឱកាសសមហេតុផលឱ្យរដ្ឋដទៃ ដើម្បីទទួលបានពីរដ្ឋនោះឬតាមរយៈកិច្ចសហប្រតិបត្តិការជាមួយរដ្ឋនោះ នូវព័ត៌មានដែលចាំបាច់ដើម្បីបង្ការនិងទប់ស្កាត់ផលប៉ះពាល់ចំពោះសុខភាពនិងសុវត្ថិភាពរបស់មនុស្សនិងបរិស្ថានសមុទ្រ។

### មាត្រា២៤៣
### ការបង្កើតលក្ខខណ្ឌអនុគ្រោះ

បណ្តារដ្ឋនិងអង្គការអន្តរជាតិដែលមានសមត្ថកិច្ច ត្រូវធ្វើកិច្ចសហការប្រតិបត្តិការតាមរយៈការចុះកិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគី ដើម្បីបង្កើតនូវលក្ខខណ្ឌអនុគ្រោះសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ នៅក្នុងបរិស្ថានសមុទ្រ និងដើម្បីធ្វើសមាហរណកម្មកិច្ចខិតខំប្រឹងប្រែងរបស់អ្នកវិទ្យាសាស្ត្រ ក្នុងការសិក្សាអំពីលក្ខណៈសំខាន់នៃបាតុភូត និងដំណើរការដែលកំពុងកើតឡើងនៅក្នុងបរិស្ថានសមុទ្រនិងអំពីអន្តរទំនាក់ទំនង រវាងបាតុភូតនិងដំណើរការនោះ។

### មាត្រា២៤៤
### ការបោះពុម្ពនិងផ្សព្វផ្សាយព័ត៌មាននិងចំណេះដឹង

១. បណ្តារដ្ឋនិងអង្គការអន្តរជាតិដែលមានសមត្ថកិច្ចដោយស្របតាមអនុសញ្ញានេះ ត្រូវធ្វើការបោះពុម្ពនិងផ្សព្វផ្សាយព័ត៌មានតាមរយៈមធ្យោបាយសមស្របអំពីកម្មវិធីសំខាន់ៗដែលបានស្នើឡើងនិងកម្មវត្ថុនៃកម្មវិធីទាំងនោះ ព្រមទាំងចំណេះដឹងដែលទទួលបានពីការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ។

២. សម្រាប់គោលបំណងនេះ បណ្តារដ្ឋត្រូវធ្វើការយ៉ាងសកម្មដោយខ្លួនឯងផ្ទាល់និងដោយសហការជាមួយរដ្ឋផ្សេងៗនិង អង្គការអន្តរជាតិដែលមានសមត្ថកិច្ចជំរុញនូវលំហូទិន្នន័យនិងព័ត៌មានវិទ្យាសាស្ត្រ និងការផ្ទេរចំណេះដឹងដែលបានមកពីការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រ ជាពិសេសទៅដល់បណ្តារដ្ឋកំពុងអភិវឌ្ឍន៍ ព្រមទាំងពង្រឹងសមត្ថភាពស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រដោយស្វ័យតភាពរបស់បណ្តារដ្ឋកំពុងអភិវឌ្ឍន៍ តាមរយៈជាអាទិ៍ កម្មវិធីអប់រំនិងបណ្តុះបណ្តាលដល់បុគ្គលិកផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសរបស់រដ្ឋទាំងនោះឱ្យបានគ្រប់គ្រាន់។

## ផ្នែកទី៣
## ការប្រតិបត្តិនិងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ

### មាត្រា២៤៥
### ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងសមុទ្រដែនដីសមុទ្រដែនដី

នៅក្នុងការអនុវត្តសិទ្ធិអធិបតេយ្យភាពរបស់ខ្លួន រដ្ឋជាប់ឆ្នេរមានសិទ្ធិផ្តាច់មុខក្នុងការគ្រប់គ្រងអនុញ្ញាតនិងអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងសមុទ្រដែនដីរបស់ខ្លួន។ រាល់ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងសមុទ្រដែនដីរបស់រដ្ឋជាប់ឆ្នេរ ត្រូវមានការអនុញ្ញាតច្បាស់លាស់និងស្ថិតក្រោមលក្ខខណ្ឌកំណត់របស់រដ្ឋជាប់ឆ្នេរនោះ។

## មាត្រា២៤៦
## ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រ

១. នៅក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួន រដ្ឋជាប់ឆ្នេរសមុទ្រមានសិទ្ធិក្នុងការគ្រប់គ្រង ផ្តល់ការអនុញ្ញាត និង អនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ។

២. ការអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រ ត្រូវមានការអនុញ្ញាតពីរដ្ឋជាប់ឆ្នេរសមុទ្រ។

៣. នៅក្នុងកាលៈទេសៈធម្មតា រដ្ឋជាប់ឆ្នេរសមុទ្រត្រូវផ្តល់ការអនុញ្ញាតរបស់ខ្លួនសម្រាប់គម្រោងស្រាវជ្រាវ វិទ្យាសាស្ត្រអំពីសមុទ្ររបស់រដ្ឋដទៃឬរបស់អង្គការអន្តរជាតិមានសមត្ថកិច្ចនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនិង តំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ដែលត្រូវអនុវត្តស្របតាមអនុសញ្ញានេះ តែសម្រាប់គោលបំណងសន្តិភាព និងដើម្បីបង្កើនចំណេះដឹងវិទ្យាសាស្ត្រអំពីបរិស្ថានសមុទ្រ សម្រាប់បម្រើផលប្រយោជន៍មនុស្សជាតិទាំងមូល។ សម្រាប់គោលបំណងនេះ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវបង្កើតវិធាននិងនីតិវិធី ដើម្បីធានាថានឹងពុំមានការពន្យារពេល ឬការបដិសេធមិនផ្តល់ការអនុញ្ញាតដោយគ្មានហេតុផលសមស្របនោះទេ។

៤. សម្រាប់គោលបំណងនៃការអនុវត្តកថាខណ្ឌទី៣ខាងលើ កាលៈទេសៈធម្មតាក៏អាចមានអត្ថិភាពផងដែរ ទោះបីជារដ្ឋជាប់ឆ្នេរសមុទ្រនិងរដ្ឋស្រាវជ្រាវ មិនមានទំនាក់ទំនងការទូតជាមួយគ្នាក៏ដោយ។

៥. ទោះជាយ៉ាងណាក្តី រដ្ឋជាប់ឆ្នេរសមុទ្រមានសិទ្ធិសម្រេចមិនផ្តល់ការអនុញ្ញាតរបស់ខ្លួនសម្រាប់គម្រោង ស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្ររបស់រដ្ឋដទៃឬរបស់អង្គការអន្តរជាតិមានសមត្ថកិច្ច នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ប្រសិនបើគម្រោងនោះ៖

(ក) សម្រាប់គោលបំណងក្នុងការស្វែងរុករកនិងធ្វើអាជីវកម្មធនធានធម្មជាតិ មិនថាធនធាន មានជីវិតឬធនធានគ្មានជីវិតដោយផ្ទាល់។

(ខ) មានការខួងចូលតំបន់ខ្ពង់រាបបាតសមុទ្រ ការប្រើប្រាស់គ្រឿងផ្ទុះ ឬការបញ្ចូលសារធាតុគ្រោះថ្នាក់ ទៅក្នុងបរិស្ថានសមុទ្រ។

(គ) មានការសាងសង់ ប្រតិបត្តិការ ឬការប្រើប្រាស់កោះសិប្បនិម្មិត បបនកណ្ឌ និងរចនាសម្ព័ន្ធ ដូចមានចែងក្នុងមាត្រា៦០និងមាត្រា៨០នៃអនុសញ្ញានេះ។

(ឃ) មានព័ត៌មានដែលត្រូវបានជូនដំណឹងស្របតាមមាត្រា២៤៨នៃអនុសញ្ញានេះ ពាក់ព័ន្ធនឹង លក្ខណៈនិងកម្មវត្ថុនៃគម្រោងដែលពុំមានភាពច្បាស់លាស់ ឬប្រសិនបើរដ្ឋស្រាវជ្រាវឬអង្គការ អន្តរជាតិមានសមត្ថកិច្ចនោះមានកាតព្វកិច្ចត្រូវអនុវត្តចំពោះរដ្ឋជាប់ឆ្នេរសមុទ្រដែលបន្សល់ទុក ពីគម្រោងស្រាវជ្រាវមុនៗ។

៦. ទោះបីជាមានបទប្បញ្ញត្តិចែងដូចក្នុងកថាខណ្ឌទី៥ក៏ដោយ ក៏រដ្ឋជាប់ឆ្នេរសមុទ្រមិនអាចអនុវត្តសិទ្ធិសម្រេចរបស់ខ្លួន ក្នុងការមិនផ្តល់ការអនុញ្ញាតតាមកថាខណ្ឌរង(ក)នៃកថាខណ្ឌនោះ ពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដែលត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃជំពូកនេះ នៅក្នុងតំបន់ខ្ពង់រាបបាតសមុទ្រដែលមានចម្ងាយលើសពី២០០ម៉ែល៍សមុទ្រ គិតចាប់ពីខ្សែបន្ទាត់មូលដ្ឋាននៃរង្វាស់ផ្ទៃទទឹងសមុទ្រ នៅខាងក្រៅតំបន់ជាក់លាក់ ដែលរដ្ឋជាប់ឆ្នេរសមុទ្រអាចកំណត់ជាសាធារណៈថាជាតំបន់ដែលមានការធ្វើអាជីវកម្មធនធានឬមានប្រតិបត្តិការស្វែងរុករកលម្អិតកំពុងកើតឡើងឬនឹងកើតឡើងនៅក្នុងរយៈពេលសមស្រប។ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវជូនដំណឹងឱ្យបានសមស្របអំពីការកំណត់តំបន់ទាំងនោះ ព្រមទាំងអំពីការកែប្រែណាមួយ ប៉ុន្តែមិនមានកាតព្វកិច្ចផ្តល់ព័ត៌មានលម្អិតអំពីប្រតិបត្តិការដែលមាននៅក្នុងតំបន់ទាំងនោះ នោះទេ។

៧. បទប្បញ្ញត្តិនៃកថាខណ្ឌទី៦ខាងលើ មិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រលើតំបន់ខ្ពង់រាបបាតសមុទ្រដែលបង្កើតឡើងក្រោមមាត្រា៧៧នៃអនុសញ្ញានេះឡើយ។

៨. សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដូចមានចែងក្នុងមាត្រានេះ ទោះជាដោយប្រការណាក៏ដោយ មិនត្រូវបង្កការរំខានដល់សកម្មភាពរបស់រដ្ឋជាប់ឆ្នេរសមុទ្រនៅក្នុងការអនុវត្តសិទ្ធិអធិបតេយ្យនិងយុត្តាធិការរបស់ខ្លួនដូចមានចែងក្នុងអនុសញ្ញានេះឡើយ។

## មាត្រា២៤៧

## គម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដែលអនុវត្ត ដោយអង្គការអន្តរជាតិឬស្ថិតក្រោមការឧបត្ថម្ភរបស់អង្គការអន្តរជាតិ

រដ្ឋជាប់ឆ្នេរសមុទ្រដែលជាសមាជិកអង្គការអន្តរជាតិឬបានចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយអង្គការអន្តរជាតិ ហើយអង្គការអន្តរជាតិនោះចង់អនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដោយខ្លួនផ្ទាល់ឬតាមរយៈការជួយឧបត្ថម្ភនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខឬតំបន់ខ្ពង់រាបបាតសមុទ្ររបស់រដ្ឋនោះ ត្រូវចាត់ទុកថាបានផ្តល់ការអនុញ្ញាតឱ្យអនុវត្តគម្រោងនោះ ស្របតាមលក្ខខណ្ឌជាក់លាក់ដែលបានព្រមព្រៀង ប្រសិនបើរដ្ឋនោះបានអនុម័តគម្រោងលម្អិតនៅពេលដែលអង្គការអន្តរជាតិបានសម្រេចចិត្តអនុវត្តគម្រោងឬមានឆន្ទៈចូលរួមក្នុងគម្រោងនិងមិនបានជំទាស់នៅក្នុងរយៈពេលបួនខែ គិតចាប់ពីពេលដែលអង្គការអន្តរជាតិបានជូនដំណឹងឱ្យរដ្ឋជាប់ឆ្នេរសមុទ្រនោះបានជ្រាបអំពីគម្រោងទេនោះ។

## មាត្រា២៤៨

## ករណីយកិច្ចផ្តល់ព័ត៌មានដល់រដ្ឋជាប់ឆ្នេរសមុទ្រ

រដ្ឋនិងអង្គការអន្តរជាតិមានសមត្ថកិច្ច ដែលមានបំណងអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខឬតំបន់ខ្ពង់រាបបាតសមុទ្ររបស់រដ្ឋជាប់ឆ្នេរសមុទ្រ ត្រូវរៀបចំដោយលម្អិតអំពីចំណុចខាងក្រោម នៅក្នុងរយៈពេលមិនលើសពីប្រាំមួយខែ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមអនុវត្តគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ៖

(ក) លក្ខណៈនិងកម្មវត្ថុនៃគម្រោង។

(ខ) វិធីសាស្ត្រ និងមធ្យោបាយដែលប្រើប្រាស់ រាប់បញ្ចូលទាំងឈ្មោះ ទម្ងន់ ប្រភេទ និងចំណាត់ថ្នាក់នៃនាវា និងសេចក្តីបរិយាយអំពីបរិក្ខារវិទ្យាសាស្ត្រ។

(គ) តំបន់ភូមិសាស្ត្រជាក់លាក់ដែលគម្រោងត្រូវអនុវត្ត។

(ឃ) កាលបរិច្ឆេទរំពឹងទុកអំពីការមកដល់ដំបូងនិងការចាកចេញចុងក្រោយរបស់នាវាឬការដាក់ពង្រាយនិងការរុះរើបរិក្ខារតាមករណីដែលសមស្រប។

(ង) ឈ្មោះស្ថាប័នដែលគាំទ្រ ប្រធានស្ថាប័ន និងបុគ្គលទទួលខុសត្រូវលើគម្រោង។

(ច) វិសាលភាពដែលកំណត់ថា រដ្ឋជាប់ឆ្នេរសមុទ្រមួយអាចនឹងចូលរួមឬឱ្យគេតំណាងខ្លួននៅក្នុងគម្រោង។

## មាត្រា២៤៩
## ករណីយកិច្ចគោរពតាមលក្ខខណ្ឌជាក់លាក់

១. នៅពេលអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខឬតំបន់ខ្ពង់រាបបាតសមុទ្ររបស់រដ្ឋជាប់ឆ្នេរសមុទ្រ រដ្ឋនិងអង្គការអន្តរជាតិមានសមត្ថកិច្ចត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

(ក) ធានានូវការគោរពសិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រ តាមដែលរដ្ឋមានបំណងដូច្នោះ ក្នុងការចូលរួមឬឱ្យគេតំណាងនៅក្នុងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ជាពិសេសការឡើងលើនាវាស្រាវជ្រាវនិងអាកាសយានឬបរិក្ខារស្រាវជ្រាវវិទ្យាសាស្ត្រផ្សេងៗ ផ្អែកតាមស្ថានភាពជាក់ស្តែងដោយពុំចាំបាច់បង់លាភការដល់អ្នកវិទ្យាសាស្ត្រនៃរដ្ឋជាប់ឆ្នេរសមុទ្រ និងដោយពុំចាំបាច់មានកាតព្វកិច្ចជួយចេញការចំណាយនៃគម្រោង។

(ខ) ផ្តល់របាយការណ៍បឋមឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននិងលទ្ធផល ព្រមទាំងសេចក្តីសន្និដ្ឋានចុងក្រោយ ក្រោយពេលបញ្ចប់ការងារស្រាវជ្រាវជូនដល់រដ្ឋជាប់ឆ្នេរសមុទ្រតាមសំណើ។

(គ) យល់ព្រមផ្តល់លទ្ធភាពដល់រដ្ឋជាប់ឆ្នេរសមុទ្រទទួលបានរាល់ទិន្នន័យ និងវត្ថុភាគដែលបានមកពីគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រតាមសំណើ និងផ្តល់ឱ្យរដ្ឋជាប់ឆ្នេរសមុទ្រនូវទិន្នន័យដែលអាចថតចម្លង និងសំណាកដែលអាចបែងចែក ដោយពុំនាំឱ្យប៉ះពាល់ដល់តម្លៃវិទ្យាសាស្ត្រនៃទិន្នន័យនិងសំណាកទាំងនោះ។

(ឃ) ប្រសិនបើមានសំណើ ត្រូវផ្តល់ឱ្យរដ្ឋជាប់ឆ្នេរសមុទ្រនូវការវាយតម្លៃលើទិន្នន័យ សំណាក និងលទ្ធផលស្រាវជ្រាវឬផ្តល់ជំនួយនៅក្នុងការវាយតម្លៃនិងការបកស្រាយ។

(ង) ធានាដោយអនុលោមតាមកថាខណ្ឌទី២ថា លទ្ធផលស្រាវជ្រាវត្រូវបានផ្សព្វផ្សាយជាអន្តរជាតិតាមរយៈបណ្តាញជាតិឬអន្តរជាតិឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន។

(ច) ជូនដំណឹងដល់រដ្ឋជាប់ឆ្នេរសមុទ្រជាបន្ទាន់អំពីរាល់ការផ្លាស់ប្តូរជាចម្បងនៅក្នុងកម្មវិធីស្រាវជ្រាវរបស់ខ្លួន។

(ឆ) រុះរើបនាការឬបរិក្ខារស្រាវជ្រាវវិទ្យាសាស្ត្រ នៅពេលដែលការស្រាវជ្រាវបានបញ្ចប់ លើកលែងតែមានការព្រមព្រៀងផ្ទុយពីនេះ។

២. មាត្រានេះពុំប៉ះពាល់ដល់លក្ខខណ្ឌដែលបង្កើតឡើងដោយច្បាប់និងបទបញ្ញារបស់រដ្ឋជាប់ឆ្នេរសមុទ្រ សម្រាប់ការអនុវត្តសិទ្ធិសម្រេចរបស់ខ្លួននៅក្នុងការផ្តល់ឬមិនផ្តល់ការអនុញ្ញាតតាមមាត្រា២៤៦ កថាខណ្ឌទី៥ រួមបញ្ចូលទាំងការតម្រូវឱ្យមានកិច្ចព្រមព្រៀងជាមុន សម្រាប់ការផ្សព្វផ្សាយជាអន្តរជាតិនូវលទ្ធផលស្រាវជ្រាវគម្រោង ដែលមានគោលបំណងតែសម្រាប់ការស្វែងរុករកនិងធ្វើអាជីវកម្មធនធានធម្មជាតិដោយផ្ទាល់ឡើយ។

## មាត្រា២៥០

## ការប្រាស្រ័យទាក់ទងពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ

ពល់ការប្រាស្រ័យទាក់ទងពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ត្រូវធ្វើឡើងតាមរយៈ មធ្យោបាយជាផ្លូវការដែលសមស្រប លើកលែងតែមានការព្រមព្រៀងគ្នាផ្ទុយពីនេះ។

## មាត្រា២៥១

## លក្ខណវិនិច្ឆ័យនិងសេចក្តីណែនាំទូទៅ

រដ្ឋត្រូវខិតខំជំរុញការបង្កើតនូវលក្ខណវិនិច្ឆ័យនិងសេចក្តីណែនាំទូទៅ ដើម្បីជួយដល់រដ្ឋនៅក្នុងការស្វែង យល់អំពីលក្ខណៈនិងភាពស្មុគស្មាញនៃការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ តាមរយៈអង្គការអន្តរជាតិមាន សមត្ថកិច្ច។

## មាត្រា២៥២

## ការព្រមព្រៀងដោយតុណ្ហីភាព

រដ្ឋឬអង្គការអន្តរជាតិមានសមត្ថកិច្ច អាចដំណើរការគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្របានក្នុង រយៈពេលប្រាំមួយខែគិតចាប់ពីថ្ងៃដែលផ្តល់ព័ត៌មាន តាមការតម្រូវក្រោមមាត្រា២៤៨នៃអនុសញ្ញានេះ ទៅដល់ រដ្ឋជាប់ឆ្នេរសមុទ្រ លើកលែងតែរដ្ឋជាប់ឆ្នេរសមុទ្របានជូនដំណឹងដល់រដ្ឋឬអង្គការអន្តរជាតិដែលធ្វើការស្រាវជ្រាវ នោះឱ្យបានជ្រាបវិញនៅក្នុងរយៈពេលបួនខែ ក្រោយពីខ្លួនបានទទួលព័ត៌មានទាំងនោះថា៖

(ក) ខ្លួនមិនផ្តល់ការអនុញ្ញាតជូនតាមមាត្រា២៤៦ទេ។ ឬ

(ខ) ព័ត៌មានដែលផ្តល់ដោយរដ្ឋឬអង្គការអន្តរជាតិពាក់ព័ន្ធនឹងលក្ខណៈឬកម្មវត្ថុនៃគម្រោង មិនសមស្របនឹងអង្គហេតុជាក់ស្តែងដែលមិនអាចប្រកែកបាន។ ឬ

(គ) ខ្លួនត្រូវការព័ត៌មានបន្ថែមពាក់ព័ន្ធនឹងលក្ខខណ្ឌនិងព័ត៌មានដូចមានចែងក្នុងមាត្រា២៤៨ និង មាត្រា២៤៩។ ឬ

(ឃ) នៅមានកាតព្វកិច្ចត្រូវអនុវត្តនៅឡើយពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ លើកមុនដែលរដ្ឋឬអង្គការអន្តរជាតិនោះបានអនុវត្តកន្លងមកពាក់ព័ន្ធនឹងលក្ខខណ្ឌដូចមានចែង ក្នុងមាត្រា២៤៩ ។

## មាត្រា២៥៣

## ការផ្អាកឬការបញ្ឈប់សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ

១. រដ្ឋជាប់ឆ្នេរសមុទ្រមានសិទ្ធិទាមទារឱ្យមានការផ្អាកសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដែលកំពុងដំណើរការនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន ប្រសិនបើ៖

(ក) សកម្មភាពស្រាវជ្រាវទាំងនោះ មិនត្រូវបានអនុវត្តស្របតាមព័ត៌មានដែលបានផ្តល់ជូន ដូចមានចែងក្នុងមាត្រា២៤៨ដែលតម្រូវឱ្យមានការអនុញ្ញាតពីរដ្ឋជាប់ឆ្នេរសមុទ្រ។ ឬ

(ខ) រដ្ឋឬអង្គការអន្តរជាតិមានសមត្ថកិច្ចដែលអនុវត្តសកម្មភាពស្រាវជ្រាវទាំងនោះ ពុំបានគោរពតាមបទប្បញ្ញត្តិនៃមាត្រា២៤៩ស្តីពីសិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រទៅលើគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ។

២. រដ្ឋជាប់ឆ្នេរសមុទ្រមានសិទ្ធិទាមទារឱ្យមានការបញ្ឈប់សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រក្នុងករណីមានការរំលោភបំពានលើបទប្បញ្ញត្តិនៃមាត្រា២៤៨ ដែលនាំឱ្យមានការប្រែប្រួលគួរកត់សម្គាល់នៃគម្រោងស្រាវជ្រាវឬសកម្មភាពស្រាវជ្រាវ។

៣. រដ្ឋជាប់ឆ្នេរសមុទ្រក៏អាចទាមទារឱ្យមានការបញ្ឈប់សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រផងដែរ ប្រសិនបើពុំមានការកែតម្រូវស្ថានភាពដូចមានចែងនៅក្នុងកថាខណ្ឌទី១ខាងលើ នៅក្នុងរយៈពេលសមស្របទេនោះ។

៤. ក្រោយពីរដ្ឋជាប់ឆ្នេរសមុទ្របានជូនដំណឹងអំពីការសម្រេចចិត្តឱ្យផ្អាកឬបញ្ឈប់សកម្មភាពស្រាវជ្រាវ រដ្ឋឬអង្គការអន្តរជាតិមានសមត្ថកិច្ចដែលត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ត្រូវបញ្ចប់សកម្មភាពស្រាវជ្រាវដែលជាកម្មវត្ថុនៃការជូនដំណឹង។

៥. រដ្ឋជាប់ឆ្នេរសមុទ្រត្រូវដកបញ្ជាឱ្យផ្អាកក្រោមកថាខណ្ឌទី១ខាងលើវិញ ហើយសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រត្រូវអនុញ្ញាតឱ្យបន្តដំណើរការវិញ នៅពេលដែលរដ្ឋឬអង្គការអន្តរជាតិមានសមត្ថកិច្ចដែលអនុវត្តការស្រាវជ្រាវនោះ បានគោរពតាមលក្ខខណ្ឌដែលតម្រូវតាមមាត្រា២៤៨ និងមាត្រា២៤៩វិញ។

### មាត្រា២៥៤

### សិទ្ធិរបស់រដ្ឋមិនជាប់សមុទ្រនិងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល

១. រដ្ឋឬអង្គការអន្តរជាតិមានសមត្ថកិច្ច ដែលបានដាក់សំណើសុំអនុវត្តគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រទៅកាន់រដ្ឋជាប់ឆ្នេរសមុទ្រ ដូចមានចែងក្នុងមាត្រា២៤៦ កថាខណ្ឌទី៣ ត្រូវជូនដំណឹងដល់រដ្ឋមិនជាប់សមុទ្រនិងរដ្ឋមានភូមិសាស្ត្រមិនអំណោយផលស្តីពីសំណើអនុវត្តគម្រោងស្រាវជ្រាវនោះ ហើយត្រូវជូនដំណឹងដល់រដ្ឋជាប់ឆ្នេរសមុទ្រអំពីការជូនដំណឹងនេះផងដែរ។

២. ក្រោយពីរដ្ឋជាប់ឆ្នេរសមុទ្រដែលពាក់ព័ន្ធបានផ្តល់ការអនុញ្ញាតទៅលើសំណើសុំអនុវត្តគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដូចមានចែងក្នុងមាត្រា២៤៦ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗនៃអនុសញ្ញានេះ រដ្ឋឬអង្គការអន្តរជាតិដែលអនុវត្តគម្រោង ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធដូចមានចែងក្នុងមាត្រា២៤៨និងមាត្រា២៤៩ កថាខណ្ឌទី១(ច) ទៅដល់បណ្តារដ្ឋមិនជាប់សមុទ្រនិងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល តបតាមសំណើរបស់ពួកគេ នៅពេលសមស្រប។

៣. បណ្តារដ្ឋមិនជាប់សមុទ្រនិងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល ត្រូវបានផ្តល់ឱកាសឱ្យចូលរួមតបតាមសំណើរបស់ខ្លួន (នៅពេលដែលអាចធ្វើទៅបាន) នៅក្នុងគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដែលបានស្នើឡើងតាមរយៈអ្នកជំនាញការដែលមានគុណវុឌ្ឍិ ដែលរដ្ឋទាំងនោះបានចាត់តាំង និងដោយគ្មានការជំទាស់ពីរដ្ឋជាប់ឆ្នេរសមុទ្រស្របតាមលក្ខខណ្ឌដែលរដ្ឋជាប់ឆ្នេរសមុទ្រពាក់ព័ន្ធនិងរដ្ឋឬអង្គការអន្តរជាតិមានសមត្ថកិច្ច ដែលអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ បានព្រមព្រៀងគ្នាឡើងសម្រាប់គម្រោងនោះ ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

៤. រដ្ឋឬអង្គការអន្តរជាតិមានសមត្ថកិច្ច ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវផ្តល់ព័ត៌មាន និងជំនួយដូចមានចែងក្នុងមាត្រា២៤៩ កថាខណ្ឌទី១(ឃ) ជូនដល់រដ្ឋមិនជាប់សមុទ្រនិងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល តបតាមសំណើរបស់ពួកគេ ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា២៤៩ កថាខណ្ឌទី២។

## មាត្រា២៥៥
## វិធានការដើម្បីសម្របសម្រួលការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ និងដើម្បីជួយនាវាស្រាវជ្រាវ

បណ្តារដ្ឋត្រូវខិតខំប្រឹងប្រែងអនុម័តវិធាន បទប្បញ្ញត្តិ និងនីតិវិធីដែលសមស្របដើម្បីជំរុញនិងសម្របសម្រួលការងារស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដែលត្រូវបានអនុវត្តស្របតាមអនុសញ្ញានេះនៅក្រៅសមុទ្រដែនដីរបស់ខ្លួន និងផ្តល់ការសម្របសម្រួលឱ្យបានសមស្របតាមបទប្បញ្ញត្តិនៃច្បាប់និងបទបញ្ជារបស់ខ្លួន នូវលទ្ធភាពចូលចតនៅកំពង់ផែរបស់ខ្លួន និងជំរុញការងារផ្តល់ជំនួយសម្រាប់នាវាស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ដែលបានគោរពតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃជំពូកនេះ។

## មាត្រា២៥៦
## ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ

ដោយពុំគិតអំពីទីតាំងភូមិសាស្ត្រ បណ្តារដ្ឋនិងអង្គការអន្តរជាតិមានសមត្ថកិច្ចមានសិទ្ធិអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃជំពូកទី១១។

## មាត្រា២៥៧
## ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងដែនទឹក ហួសពីដែននៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ

ដោយពុំគិតអំពីទីតាំងភូមិសាស្ត្រ បណ្តារដ្ឋ និងអង្គការអន្តរជាតិមានសមត្ថកិច្ចមានសិទ្ធិអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងដែនទឹកហួសពីដែននៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

# ផ្នែកទី៤
# បវបនាការឬបរិក្ខារស្រាវជ្រាវវិទ្យាសាស្ត្រនៅក្នុងបរិស្ថានសមុទ្រ

## មាត្រា២៥៨
## ការពង្រាយនិងការប្រើប្រាស់

ការពង្រាយនិងការប្រើប្រាស់ប្រភេទបវបនាការឬបរិក្ខារស្រាវជ្រាវវិទ្យាសាស្ត្រនៅក្នុងតំបន់ណាមួយនៃបរិស្ថានសមុទ្រត្រូវគោរពតាមលក្ខខណ្ឌដូចគ្នាដូចមានចែងក្នុងអនុសញ្ញានេះ សម្រាប់ការអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនៅក្នុងតំបន់ទាំងនោះផងដែរ។

## មាត្រា២៥៩
## លក្ខន្តិកៈគតិយុត្ត

បវបនាការឬឧបករណ៍ដូចមានចែងក្នុងផ្នែកនេះ មិនមានលក្ខន្តិកៈជាកោះនោះទេ។ បវបនាការឬឧបករណ៍ទាំងនោះ មិនមានសមុទ្រដែនដីផ្ទាល់នោះទេ ហើយវត្តមានរបស់ពួកវាក៏មិននាំឱ្យប៉ះពាល់ដល់ការកំណត់ព្រំដែននៃសមុទ្រដែនដីតំបន់សេដ្ឋកិច្ចផ្តាច់មុខឬតំបន់ខ្ពង់រាបបាតសមុទ្រនោះដែរ។

## មាត្រា ២៦០
## តំបន់សុវត្ថិភាព

តំបន់សុវត្ថិភាពដែលមានប្រវែងទទឹងសមស្របមិនលើសពីចម្ងាយ៥០០ម៉ែត្រ អាចនឹងត្រូវបង្កើតឡើងនៅជុំវិញបរិក្ខារស្រាវជ្រាវវិទ្យាសាស្ត្រ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ។ បណ្តារដ្ឋត្រូវធានាថា នាវារបស់ខ្លួនត្រូវគោរពតំបន់សុវត្ថិភាពទាំងនេះ។

## មាត្រា២៦១
## ការមិនរំខានដល់ផ្លូវនាវាចរណ៍

ការពង្រាយនិងការប្រើប្រាស់ប្រភេទបរិក្ខារឬឧបករណ៍ស្រាវជ្រាវវិទ្យាសាស្ត្រ មិនត្រូវបង្កើតជាឧបសគ្គណាមួយចំពោះផ្លូវនាវាចរណ៍អន្តរជាតិដែលត្រូវបានបង្កើតឡើងនោះទេ។

## មាត្រា២៦២
## សញ្ញាសម្គាល់និងសញ្ញាព្រមាន

បរិក្ខារឬឧបករណ៍ដូចមានចែងក្នុងផ្នែកនេះ ត្រូវមានសញ្ញាសម្គាល់ដែលបង្ហាញពីរដ្ឋចុះបញ្ជីឬអង្គការអន្តរជាតិជាម្ចាស់កម្មសិទ្ធិ និងត្រូវមានសញ្ញាព្រមានដែលបានព្រមព្រៀងគ្នាជាអន្តរជាតិឱ្យបានគ្រប់គ្រាន់ ដើម្បីធានាសុវត្ថិភាពនៅសមុទ្រនិងសុវត្ថិភាពនៃការនាំផ្លូវអាកាស ដោយពិចារណាទៅលើវិធាននិងបទដ្ឋានដែលកំណត់ដោយអង្គការអន្តរជាតិមានសមត្ថកិច្ច។

## ផ្នែកទី៥
## ការទទួលខុសត្រូវនិងបន្ទុក
## មាត្រា២៦៣
## ការទទួលខុសត្រូវនិងបន្ទុក

១. រដ្ឋនិងអង្គការអន្តរជាតិមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវក្នុងការធានាថា ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រត្រូវបានអនុវត្តស្របតាមអនុសញ្ញានេះ មិនថាត្រូវបានអនុវត្តដោយខ្លួនផ្ទាល់ឬដោយតំណាងរបស់ខ្លួននោះទេ។

២. រដ្ឋនិងអង្គការអន្តរជាតិមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវនិងទទួលបន្ទុកផ្តល់សំណងចំពោះវិធានការដែលខ្លួនបានប្រកាន់យក ដោយរំលោភបំពានលើអនុសញ្ញានេះ ទាក់ទងនឹងការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដែលត្រូវបានអនុវត្តដោយរដ្ឋដទៃ រូបវន្តបុគ្គល ឬនីតិបុគ្គលរបស់រដ្ឋទាំងនោះ ឬដោយអង្គការអន្តរជាតិមានសមត្ថកិច្ច ហើយត្រូវជួសជុលព្យសនកម្មដែលបណ្តាលមកពីវិធានការទាំងនោះ។

៣. រដ្ឋនិងអង្គការអន្តរជាតិមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវនិងទទួលបន្ទុកផ្តល់សំណងស្របតាមមាត្រា២៣៥ ចំពោះព្យសនកម្មបណ្តាលមកពីការបំពុលបរិស្ថានសមុទ្រ ដែលបានកើតឡើងដោយសារការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដែលអនុវត្តដោយខ្លួនផ្ទាល់ឬតំណាងរបស់ខ្លួន។

## ផ្នែកទី៦
## ការដោះស្រាយវិវាទនិងវិធានការបណ្ដោះអាសន្ន

### មាត្រា២៦៤
### ការដោះស្រាយវិវាទ

រាល់វិវាទទាក់ទងនឹងការបកស្រាយឬការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះដែលពាក់ព័ន្ធនឹងការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ត្រូវដោះស្រាយតាមជំពូកទី១៥ ផ្នែកទី២និងផ្នែកទី៣។

### មាត្រា២៦៥
### វិធានការបណ្ដោះអាសន្ន

នៅពេលរង់ចាំការដោះស្រាយវិវាទតាមជំពូកទី១៥ ផ្នែកទី២និងផ្នែកទី៣ រដ្ឋឬអង្គការអន្តរជាតិមានសមត្ថកិច្ចដែលត្រូវបានអនុញ្ញាតឱ្យអនុវត្តគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ មិនត្រូវអនុញ្ញាតឱ្យចាប់ផ្ដើមឬបន្តសកម្មភាពស្រាវជ្រាវ ដោយគ្មានការអនុញ្ញាតជាក់លាក់ពីរដ្ឋជាប់ឆ្នេរសមុទ្រដែលពាក់ព័ន្ធនោះឡើយ។

# ជំពូកទី១៤
# ការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រ

## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា២៦៦
### ការជំរុញការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រ

១. តាមរយៈខ្លួនផ្ទាល់ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច បណ្ដារដ្ឋត្រូវសហការគ្នាជំរុញការអភិវឌ្ឍនិងការផ្ទេរវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអំពីសមុទ្រឱ្យសកម្ម ទៅតាមសមត្ថភាពរបស់រដ្ឋនីមួយៗ ដោយផ្អែកលើលក្ខខណ្ឌសមស្របនិងយុត្តិធម៌។

២. បណ្ដារដ្ឋត្រូវជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រអំពីសមុទ្រនិងសមត្ថភាពផ្នែកបច្ចេកវិទ្យារបស់រដ្ឋដែលត្រូវការឬបានស្នើសុំជំនួយបច្ចេកទេសនៅក្នុងវិស័យនេះ ជាពិសេសបណ្ដារដ្ឋកំពុងអភិវឌ្ឍន៍ រាប់បញ្ចូលទាំងរដ្ឋមិនជាប់សមុទ្រនិងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល ពាក់ព័ន្ធនឹងការស្វែងរុករក ការធ្វើអាជីវកម្ម ការអភិរក្សនិងការគ្រប់គ្រងធនធានសមុទ្រ ការការពារនិងការអភិរក្សបរិស្ថានសមុទ្រ ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រនិងសកម្មភាពនៅក្នុងបរិស្ថានសមុទ្រផ្សេងៗទៀត ដែលស្របតាមអនុសញ្ញានេះ ដើម្បីពន្លឿនដំណើរការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចរបស់រដ្ឋកំពុងអភិវឌ្ឍន៍ទាំងនោះ។

៣. បណ្ដារដ្ឋត្រូវខិតខំកែលម្អលក្ខខណ្ឌសេដ្ឋកិច្ចនិងលក្ខខណ្ឌគតិយុត្តឱ្យមានភាពអនុគ្រោះសម្រាប់ការផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រ ដើម្បីបម្រើផលប្រយោជន៍របស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដោយផ្អែកលើមូលដ្ឋានសមធម៌។

### មាត្រា២៦៧
### ការការពារអត្ថប្រយោជន៍ធម្មានុរូប

នៅក្នុងការជំរុញកិច្ចសហប្រតិបត្តិការដូចមានចែងក្នុងមាត្រា២៦៦នៃអនុសញ្ញានេះ បណ្ដារដ្ឋត្រូវគិតគូរឱ្យបានម៉ត់ចត់ទៅលើអត្ថប្រយោជន៍ធម្មានុរូបទាំងអស់ មានជាអាទិ៍ សិទ្ធិនិងករណីយកិច្ចរបស់ម្ចាស់កម្មសិទ្ធិ អ្នកផ្ដល់និងអ្នកទទួលបច្ចេកវិទ្យាអំពីសមុទ្រ។

## មាត្រា២៦៨
## កម្មវត្ថុជាមូលដ្ឋាន

តាមរយៈខ្លួនផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច បណ្តារដ្ឋត្រូវសហការគ្នាជំរុញ៖

(ក) ការទទួលបាន ការវាយតម្លៃ និងការផ្សព្វផ្សាយចំណេះដឹងបច្ចេកវិទ្យាអំពីសមុទ្រ និងសម្របសម្រួលលទ្ធភាពក្នុងការទទួលបានព័ត៌មាននិងទិន្នន័យទាំងនោះ។

(ខ) ការអភិវឌ្ឍបច្ចេកវិទ្យាអំពីសមុទ្រសមស្រប។

(គ) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាដែលចាំបាច់ដើម្បីសម្របសម្រួលការផ្ទេរបច្ចេកវិទ្យា។

(ឃ) ការអភិវឌ្ឍធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលនិងការអប់រំពលរដ្ឋនៃរដ្ឋនិងរដ្ឋកំពុងអភិវឌ្ឍន៍ ជាពិសេសពលរដ្ឋនៃរដ្ឋ និងរដ្ឋមានការអភិវឌ្ឍតិចតួចជាងគេ។

(ង) កិច្ចសហប្រតិបត្តិការអន្តរជាតិនៅគ្រប់កម្រិត ជាពិសេសនៅកម្រិតតំបន់ អនុតំបន់ និងទ្វេភាគី។

## មាត្រា២៦៩
## វិធានការដើម្បីសម្រេចបាននូវកម្មវត្ថុជាមូលដ្ឋាន

ដើម្បីសម្រេចបានតាមកម្មវត្ថុដូចមានចែងក្នុងមាត្រា២៦៨ខាងលើ បណ្តារដ្ឋត្រូវខិតខំប្រឹងប្រែងតាមរយៈខ្លួនផ្ទាល់ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ចដើម្បីជាអាទិ៍៖

(ក) បង្កើតកម្មវិធីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដើម្បីទទួលបាននូវប្រសិទ្ធភាពក្នុងការផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រគ្រប់ប្រភេទទៅឱ្យបណ្តារដ្ឋដែលត្រូវការ ឬបានស្នើសុំជំនួយបច្ចេកទេសនៅក្នុងវិស័យនេះ ជាពិសេសបណ្តារដ្ឋកំពុងអភិវឌ្ឍន៍មិនជាប់សមុទ្រ និងមានភូមិសាស្ត្រមិនអំណោយផល ព្រមទាំងបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ផ្សេងៗទៀត ដែលពុំមានសមត្ថភាពបង្កើតឬអភិវឌ្ឍសមត្ថភាពផ្នែកបច្ចេកវិទ្យាអំពីវិទ្យាសាស្ត្រសមុទ្រ ការស្វែងរុករក និងការធ្វើអាជីវកម្មធនធានសមុទ្រផ្ទាល់ខ្លួនឬពុំមានសមត្ថភាពអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែកបច្ចេកវិទ្យានេះបាន។

(ខ) ជំរុញឱ្យមានលក្ខខណ្ឌអនុគ្រោះសម្រាប់ការចុះកិច្ចព្រមព្រៀង កិច្ចសន្យា និងកិច្ចសម្របសម្រួលប្រហាក់ប្រហែលផ្សេងៗទៀត នៅក្រោមលក្ខខណ្ឌសមធម៌និងសមស្រប។

(គ) រៀបចំសន្និសីទ សិក្ខាសាលា និងកិច្ចប្រជុំស្តីពីប្រធានបទវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជាពិសេសស្តីពីគោលនយោបាយនិងវិធីសាស្ត្រសម្រាប់ការផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រ។

(ឃ) ជំរុញការផ្លាស់ប្តូរអ្នកវិទ្យាសាស្ត្រ អ្នកជំនាញបច្ចេកវិទ្យា និងអ្នកឯកទេសផ្សេងៗទៀត។

(ង) អនុវត្តគម្រោងនិងជំរុញគម្រោងរួមគ្នា ព្រមទាំងទម្រង់ផ្សេងៗទៀតនៃកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី។

# ផ្នែកទី២
# កិច្ចសហប្រតិបត្តិការអន្តរជាតិ

## មាត្រា២៧០
## វិធីនិងមធ្យោបាយនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រ ត្រូវអនុវត្តទៅតាមការដែលអាចធ្វើទៅបាននិងសមស្របតាមរយៈកម្មវិធីទ្វេភាគី កម្មវិធីថ្នាក់តំបន់ ឬពហុភាគីដែលមានស្រាប់ និងកម្មវិធីថ្មីៗ និងពង្រីកបន្ថែម ដើម្បីសម្របសម្រួលការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ការផ្ទេរបច្ចេកអំពីវិទ្យាសមុទ្រ ជាពិសេសនៅក្នុងវិស័យថ្មីៗ និងមូលនិធិអន្តរជាតិសមស្របសម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍអំពីមហាសមុទ្រ។

## មាត្រា២៧១
## សេចក្តីណែនាំ លក្ខណវិនិច្ឆ័យ និងស្តង់ដា

តាមរយៈខ្លួនផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច បណ្តារដ្ឋត្រូវជំរុញការបង្កើតនូវសេចក្តីណែនាំ លក្ខណវិនិច្ឆ័យ និងស្តង់ដាដែលត្រូវបានទទួលស្គាល់ជាទូទៅសម្រាប់ការផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រ ដោយផ្អែកលើមូលដ្ឋានទ្វេភាគី ឬនៅក្នុងក្របខ័ណ្ឌអង្គការអន្តរជាតិ និងវេទិកាផ្សេងៗទៀត ដោយគិតគូរជាពិសេសទៅលើអត្ថប្រយោជន៍ និងតម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍន៍។

## មាត្រា២៧២
## ការសម្របសម្រួលកម្មវិធីអន្តរជាតិ

នៅក្នុងវិស័យផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រ បណ្តារដ្ឋត្រូវខិតខំធានាថា អង្គការអន្តរជាតិមានសមត្ថកិច្ចត្រូវសម្របសម្រួលនូវសកម្មភាពរបស់ខ្លួន រួមទាំងកម្មវិធីថ្នាក់តំបន់ឬថ្នាក់សាកល ដោយគិតគូរទៅលើអត្ថប្រយោជន៍ និងតម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍន៍ ជាពិសេសរដ្ឋមិនជាប់សមុទ្រ និងរដ្ឋមានភូមិសាស្ត្រមិនអំណោយផល។

## មាត្រា២៧៣
## កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិនិងអាជ្ញាធរបាតសមុទ្រអន្តរជាតិ

បណ្តារដ្ឋត្រូវសហការយ៉ាងសកម្មជាមួយអង្គការអន្តរជាតិមានសមត្ថកិច្ច និងអាជ្ញាធរបាតសមុទ្រអន្តរជាតិ ដើម្បីជំរុញ និងសម្របសម្រួលការផ្ទេរជំនាញនិងបច្ចេកវិទ្យាអំពីសមុទ្រ ដែលពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិទៅឱ្យរដ្ឋកំពុងអភិវឌ្ឍន៍និងពលរដ្ឋរបស់ខ្លួន និងសហគ្រាស។

## មាត្រា២៧៤
## កម្មវត្ថុរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ

ទាក់ទងនឹងអត្ថប្រយោជន៍ធម្មានុរូប រួមមានជាអាទិ៍ សិទ្ធិនិងករណីយកិច្ចរបស់ម្ចាស់សិទ្ធិ អ្នកផ្តល់ និងអ្នកទទួលបច្ចេកវិទ្យា ដែលពាក់ព័ន្ធនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ អាជ្ញាធរបាតសមុទ្រអន្តរជាតិត្រូវធានាថា៖

(ក) ពលរដ្ឋរបស់រដ្ឋកំពុងអភិវឌ្ឍន៍ មិនថារដ្ឋជាប់ឆ្នេរសមុទ្រ រដ្ឋមិនជាប់សមុទ្រ ឬរដ្ឋមានភូមិសាស្ត្រមិនអំណោយផល ត្រូវបានយកមកពិចារណាសម្រាប់គោលបំណងបណ្តុះបណ្តាលជាសមាជិកនៃក្រុមបុគ្គលិកផ្នែកគ្រប់គ្រង ផ្នែកស្រាវជ្រាវ និងផ្នែកបច្ចេកទេសសម្រាប់អនុវត្តការងាររបស់ខ្លួនដោយផ្អែកលើគោលការណ៍បែងចែកភូមិសាស្ត្រដោយសមធម៌។

(ខ) ឯកសារបច្ចេកទេសស្តីពីឧបករណ៍ គ្រឿងម៉ាស៊ីន បរិក្ខារ និងដំណើរការ ដែលពាក់ព័ន្ធ ត្រូវបានផ្សព្វផ្សាយដល់រដ្ឋទាំងអស់ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ ដែលអាចត្រូវការ និងស្នើសុំជំនួយបច្ចេកទេសនៅក្នុងវិស័យនេះ។

(គ) ជំនួយគ្រប់គ្រាន់ត្រូវបានផ្តល់ដោយអាជ្ញាធរបាតសមុទ្រអន្តរជាតិ ដើម្បីសម្របសម្រួលឱ្យមានការទទួលបាននូវជំនួយផ្នែកបច្ចេកទេសនៅក្នុងវិស័យបច្ចេកវិទ្យាអំពីសមុទ្រដោយរដ្ឋដែលអាចត្រូវការ និងស្នើសុំជំនួយនេះ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ និងការទទួលបានដោយពលរដ្ឋរបស់រដ្ឋទាំងនោះនូវជំនាញនិងចំណេះធ្វើដែលចាំបាច់ រាប់បញ្ចូលទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។

(ឃ) បណ្តារដ្ឋដែលអាចត្រូវការ និងស្នើសុំជំនួយបច្ចេកទេសនៅក្នុងវិស័យនេះ ជាពិសេសរដ្ឋកំពុងអភិវឌ្ឍន៍ ត្រូវបានជួយជ្រោមជ្រែងឱ្យទទួលបាននូវឧបករណ៍ដំណើរការរោងចក្រ និងចំណេះធ្វើផ្នែកបច្ចេកទេសផ្សេងៗទៀត តាមរយៈកិច្ចសម្របសម្រួលផ្នែកហិរញ្ញវត្ថុ ដូចមានចែងក្នុងអនុសញ្ញានេះ។

## ផ្នែកទី៣

## មជ្ឈមណ្ឌលថ្នាក់ជាតិនិងថ្នាក់តំបន់ ទាក់ទងនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអំពីសមុទ្រ

### មាត្រា២៧៥

### ការបង្កើតមជ្ឈមណ្ឌលថ្នាក់ជាតិ

១. តាមរយៈខ្លួនផ្ទាល់ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច និងអាជ្ញាធរបាតសមុទ្រអន្តរជាតិ បណ្តារដ្ឋត្រូវជំរុញឱ្យមានការបង្កើតនូវមជ្ឈមណ្ឌលថ្នាក់ជាតិទាក់ទងនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអំពីសមុទ្រ ជាពិសេសនៅតាមបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ជាប់ឆ្នេរសមុទ្រ និងជំរុញការពង្រឹងមជ្ឈមណ្ឌលជាតិដែលមានស្រាប់ ដើម្បីជំរុញនិងបង្កើនការអនុវត្ត ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដែលធ្វើឡើងដោយរដ្ឋកំពុងអភិវឌ្ឍន៍ជាប់ឆ្នេរសមុទ្រឱ្យបានប្រសើរ និងលើកកម្ពស់សមត្ថភាពថ្នាក់ជាតិរបស់រដ្ឋទាំងនោះ ដើម្បីប្រើប្រាស់និងអភិរក្សធនធានសមុទ្រសម្រាប់បម្រើផលប្រយោជន៍សេដ្ឋកិច្ចរបស់ពួកគេ។

២. តាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច និងអាជ្ញាធរបាតសមុទ្រអន្តរជាតិ បណ្តារដ្ឋត្រូវផ្តល់ការគាំទ្រឱ្យបានគ្រប់គ្រាន់ ដើម្បីសម្របសម្រួលការបង្កើត និងការពង្រឹងមជ្ឈមណ្ឌលជាតិទាំងនោះ ដើម្បីផ្តល់នូវបេបនីយកណ្តុបណ្តុះបណ្តាលទំនើប និងឧបករណ៍ ជំនាញ និងចំណេះធ្វើដែលចាំបាច់ ព្រមទាំងជំនាញបច្ចេកទេសទៅឱ្យរដ្ឋដែលត្រូវការនិងស្នើសុំជំនួយទាំងនេះ។

### មាត្រា២៧៦

### ការបង្កើតមជ្ឈមណ្ឌលថ្នាក់តំបន់

១. តាមរយៈការសម្របសម្រួលជាមួយអង្គការអន្តរជាតិមានសមត្ថកិច្ច អាជ្ញាធរបាតសមុទ្រអន្តរជាតិ ស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអំពីសមុទ្រថ្នាក់ជាតិ បណ្តារដ្ឋត្រូវជំរុញឱ្យមានការបង្កើតនូវមជ្ឈមណ្ឌលវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអំពីសមុទ្រថ្នាក់តំបន់ ជាពិសេសនៅក្នុងបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ ដើម្បីជំរុញនិងបង្កើនការអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដែលធ្វើឡើងដោយរដ្ឋកំពុងអភិវឌ្ឍន៍ជាប់ឆ្នេរសមុទ្រឱ្យបានប្រសើរនិងលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រ។

២. បណ្តារដ្ឋនៅក្នុងតំបន់ត្រូវសហការជាមួយមជ្ឈមណ្ឌលថ្នាក់តំបន់ដូចមានចែងក្នុងអនុសញ្ញានេះ ដើម្បីធានានូវការសម្រេចបានតាមកម្មវត្ថុរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

### មាត្រា២៧៧

### មុខងាររបស់មជ្ឈមណ្ឌលថ្នាក់តំបន់

មជ្ឈមណ្ឌលថ្នាក់តំបន់មានមុខងារជាច្រើនរួមមានជាអាទិ៍៖

(ក) កម្មវិធីបណ្តុះបណ្តាលអប់រំនៅគ្រប់កម្រិតស្តីពីកត្តាផ្សេងៗនៃការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអំពីសមុទ្រ ជាពិសេសជីវវិទ្យាសមុទ្ររាប់បញ្ចូលទាំងការអភិរក្ស និងការគ្រប់គ្រងធនធានមានជីវិត សាគរសាស្ត្រ ជលសាស្ត្រ វិស្វកម្ម ការស្វែងរុករកភូមិសាស្ត្រនៅបាតសមុទ្រ បច្ចេកវិទ្យាទាញយករ៉ែ និងបច្ចេកវិទ្យាបន្សាបជាតិអំបិល។

(ខ) ការសិក្សាគ្រប់គ្រង។

(គ) ការសិក្សាកម្មវិធីដែលទាក់ទងនឹងការការពារ និងការអភិរក្សបរិស្ថានសមុទ្រ ការបង្ការ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុល។

(ឃ) រៀបចំសន្និសីទ សិក្ខាសាលា និងកិច្ចប្រជុំថ្នាក់តំបន់។

(ង) ការទទួលបាន និងដំណើរការព័ត៌មាន និងទិន្នន័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអំពីសមុទ្រ។

(ច) ផ្សព្វផ្សាយឱ្យបានជាបន្ទាន់នូវលទ្ធផលនៃការស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាអំពីសមុទ្រ នៅក្នុងច្បាប់បោះពុម្ពផ្សាយដែលមានស្រាប់។

(ឆ) ផ្សព្វផ្សាយគោលនយោបាយជាតិដែលពាក់ព័ន្ធនឹងការផ្ទេរបច្ចេកវិទ្យាអំពីសមុទ្រ និងការសិក្សាប្រៀបធៀបអំពីគោលនយោបាយទាំងនោះជាប្រព័ន្ធ។

(ជ) ចងក្រងនិងរៀបចំជាប្រព័ន្ធនូវព័ត៌មានស្តីពីទីផ្សារបច្ចេកវិទ្យា និងកិច្ចសន្យា និងកិច្ចសម្របសម្រួលផ្សេងៗដែលទាក់ទងនឹងប្រកាសនីយបត្រតក្កកម្ម។

(ឈ) កិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយបណ្តារដ្ឋផ្សេងៗទៀតក្នុងតំបន់។

## ផ្នែកទី៤

## កិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការអន្តរជាតិ

### មាត្រា២៧៨

### កិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការអន្តរជាតិ

អង្គការអន្តរជាតិមានសមត្ថកិច្ចដូចមានចែងក្នុងជំពូកនេះ និងជំពូកទី១៣ ត្រូវចាត់វិធានការសមស្របទាំងឡាយ ដើម្បីធានាថាមុខងារ និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងជំពូកនេះត្រូវបានអនុវត្តឱ្យមានប្រសិទ្ធភាព មិនថាដោយខ្លួនផ្ទាល់ក្តី ឬដោយកិច្ចសហប្រតិបត្តិការជិតស្និទ្ធក្នុងចំណោមអង្គការអន្តរជាតិក្តី។

## ជំពូកទី១៥

## ការដោះស្រាយវិវាទ

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

### មាត្រា២៧៩

### កាតព្វកិច្ចដោះស្រាយវិវាទដោយសន្តិវិធី

បណ្តារដ្ឋភាគីត្រូវដោះស្រាយរាល់វិវាទដែលកើតឡើងរវាងរដ្ឋភាគីទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដោយសន្តិវិធីស្របតាមមាត្រា២ កថាខណ្ឌទី៣ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ហើយដើម្បីសម្រេចបានតាមគោលបំណងនេះ រដ្ឋភាគីត្រូវស្វែងរកដំណោះស្រាយ ដោយមធ្យោបាយដូចមានចែងក្នុងមាត្រា៣៣ កថាខណ្ឌទី១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

## មាត្រា២៨០

## ការដោះស្រាយវិវាទដោយសន្តិវិធីណាមួយដែលជ្រើសរើសដោយភាគីវិវាទ

គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងជំពូកនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋភាគី នៅក្នុងការព្រមព្រៀងគ្នានៅពេលណាក៏បាន ដើម្បីដោះស្រាយវិវាទរវាងរដ្ឋភាគីដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដោយសន្តិវិធី ដែលរដ្ឋភាគីបានជ្រើសរើសដោយខ្លួនផ្ទាល់។

## មាត្រា២៨១

## នីតិវិធីក្នុងករណីដែលភាគីវិវាទមិនអាចដោះស្រាយវិវាទរបស់ខ្លួនបាន

១. ប្រសិនបើរដ្ឋភាគីជាភាគីវិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ បានព្រមព្រៀងគ្នាស្វែងរកដំណោះស្រាយវិវាទដោយសន្តិវិធីដែលរដ្ឋភាគីបានជ្រើសរើសផ្ទាល់ នោះនីតិវិធីដូចមានចែងក្នុងជំពូកនេះត្រូវមានប្រសិទ្ធភាពអនុវត្តតែក្នុងករណីដែលពុំមានដំណោះស្រាយ តាមរយៈការប្រើប្រាស់មធ្យោបាយដោយសន្តិវិធីនោះប៉ុណ្ណោះ ហើយការព្រមព្រៀងរវាងភាគីវិវាទមិនបានប្រានចោលនូវនីតិវិធីផ្សេងៗទៀតនោះទេ។

២. ប្រសិនបើភាគីវិវាទក៏បានព្រមព្រៀងគ្នាអំពីរយៈពេលកំណត់ផងដែរ នោះកថាខណ្ឌទី១ខាងលើ អាចអនុវត្តបានតែនៅក្រោយពេលផុតកំណត់នៃរយៈពេលកំណត់នោះប៉ុណ្ណោះ។

## មាត្រា២៨២

## កាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងទូទៅ តំបន់ និងទ្វេភាគី

ប្រសិនបើរដ្ឋភាគីជាភាគីវិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ បានព្រមព្រៀងគ្នាតាមរយៈកិច្ចព្រមព្រៀងទូទៅ កិច្ចព្រមព្រៀងតំបន់ ឬកិច្ចព្រមព្រៀងទ្វេភាគី ឬកិច្ចព្រមព្រៀងផ្សេងៗទៀតថា នៅពេលមានសំណើពីភាគីណាមួយនៃវិវាទស្នើសុំឱ្យបញ្ជូនវិវាទនោះទៅដោះស្រាយតាមនីតិវិធីមួយ ដើម្បីសម្រេចបាននូវសេចក្តីសម្រេចមួយដែលចងកាតព្វកិច្ច នោះនីតិវិធីនោះត្រូវអនុវត្តជំនួសឱ្យនីតិវិធីដូចមានចែងនៅក្នុងជំពូកនេះ លើកលែងតែភាគីវិវាទព្រមព្រៀងគ្នាផ្សេងពីនេះ។

## មាត្រា២៨៣

## កាតព្វកិច្ចផ្លាស់ប្តូរទស្សនៈ

១. នៅពេលវិវាទកើតឡើងរវាងរដ្ឋភាទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ នោះភាគីវិវាទត្រូវប្រញាប់ផ្លាស់ប្តូរទស្សនៈគ្នាអំពីការដោះស្រាយវិវាទតាមរយៈការចរចា ឬតាមរយៈមធ្យោបាយដោយសន្តិវិធីផ្សេងៗទៀត។

២. ភាគីវិវាទក៏ត្រូវប្រញាប់ផ្លាស់ប្តូរទស្សនៈគ្នា ក្នុងករណីដែលនីតិវិធីមួយសម្រាប់ដោះស្រាយវិវាទត្រូវបានបញ្ចប់ដោយពុំមានដំណោះស្រាយ ឬក្នុងករណីដែលអាចសម្រេចបាននូវដំណោះស្រាយមួយ តែកាលៈទេសៈតម្រូវឱ្យមានការពិគ្រោះយោបល់គ្នាអំពីរបៀបដែលត្រូវអនុវត្តដំណោះស្រាយនោះ។

## មាត្រា២៨៤
## ការផ្សះផ្សា

១. រដ្ឋភាគីដែលជាភាគីមួយនៃវិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ អាចអញ្ជើញភាគីម្ខាងទៀតឱ្យបញ្ជូនវិវាទទៅផ្សះផ្សាគ្នា ស្របតាមនីតិវិធីដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៥ ផ្នែកទី១ ឬនីតិវិធីផ្សះផ្សាផ្សេងទៀត។

២. ប្រសិនបើការអញ្ជើញត្រូវបានទទួលយក និងប្រសិនបើភាគីវិវាទបានឯកភាពគ្នាលើនីតិវិធីផ្សះផ្សាដែលត្រូវអនុវត្ត នោះភាគីនីមួយៗអាចបញ្ជូនវិវាទទៅដោះស្រាយតាមនីតិវិធីនោះបាន។

៣. ប្រសិនបើការអញ្ជើញមិនត្រូវបានទទួលយក ឬភាគីវិវាទមិនបានឯកភាពគ្នាលើនីតិវិធីផ្សះផ្សាទេ នោះដំណើរការផ្សះផ្សាត្រូវចាត់ទុកថាត្រូវបានបញ្ចប់។

៤. នៅពេលដែលវិវាទត្រូវបានបញ្ជូនទៅផ្សះផ្សា នោះដំណើរការផ្សះផ្សាអាចបញ្ចប់បានតែតាមនីតិវិធីផ្សះផ្សាដែលបានឯកភាពគ្នានោះប៉ុណ្ណោះ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ។

## មាត្រា២៨៥
## ការអនុវត្តផ្នែកនេះសម្រាប់វិវាទដែលត្រូវបានបញ្ជូនស្របតាមជំពូកទី១១

ផ្នែកនេះអនុវត្តចំពោះវិវាទទាំងឡាយណាដែលស្របតាមជំពូកទី១១ ផ្នែកទី៥ ត្រូវបានដោះស្រាយតាមនីតិវិធីដូចមានចែងក្នុងជំពូកនេះ។ ប្រសិនបើនីតិបុគ្គលណាមួយក្រៅពីរដ្ឋភាគី ជាភាគីមួយនៃវិវាទ នោះផ្នែកនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ។

# ផ្នែកទី២
# នីតិវិធីចាប់បង្ខំដែលនាំឱ្យមានសេចក្តីសម្រេចចងកាតព្វកិច្ច

## មាត្រា២៨៦
## ការអនុវត្តនីតិវិធីក្រោមផ្នែកនេះ

អនុលោមតាមផ្នែកទី៣ ក្នុងករណីដែលវិវាទណាមួយកើតឡើងទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ ហើយដែលពុំមានដំណោះស្រាយដោយផ្អែកតាមផ្នែកទី១ នោះករណីវិវាទនេះត្រូវបញ្ជូនទៅតុលាការ ឬសាលាជម្រះក្តីដែលមានសមត្ថកិច្ចក្រោមផ្នែកនេះ តាមការស្នើសុំពីភាគីណាមួយ។

## មាត្រា២៨៧
## ជម្រើសនៃនីតិវិធី

១. នៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័ន ឬការចូលជាភាគីលើអនុសញ្ញានេះ ឬនៅពេលបន្ទាប់ពីនេះ នោះរដ្ឋមានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយមួយ ឬលើសពីមួយដូចខាងក្រោម តាមរយៈសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដើម្បីដោះស្រាយវិវាទដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ៖

(ក) ដំណោះស្រាយតាមរយៈតុលាការអន្តរជាតិនីតិសមុទ្រ ដែលបានបង្កើតឡើងស្របតាមឧបសម្ព័ន្ធទី៦។

(ខ) តាមរយៈតុលាការយុត្តិធម៌អន្តរជាតិ។

(គ) តុលាការមជ្ឈត្តការដែលបង្កើតឡើងស្របតាមឧបសម្ព័ន្ធទី៧។

(ឃ) តុលាការមជ្ឈត្តការពិសេសមួយដែលបង្កើតឡើងស្របតាមឧបសម្ព័ន្ធទី៨ សម្រាប់ប្រភេទវិវាទមួយ ឬច្រើនដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៨នេះ។

២. សេចក្តីប្រកាសដែលធ្វើឡើងតាមកថាខណ្ឌទី១ខាងលើ មិនត្រូវប៉ះពាល់ ឬរងការប៉ះពាល់ដោយសារកាតព្វកិច្ចរបស់រដ្ឋភាគីមួយនៅក្នុងការទទួលយកយុត្តាធិការរបស់សភាវិវាទបាតសមុទ្រ នៃតុលាការអន្តរជាតិនីតិសមុទ្រ នៅក្នុងវិសាលភាព និងលក្ខណៈណាមួយដូចមានចែងក្នុងជំពូកទី១១ ផ្នែកទី៥ឡើយ។

៣. រដ្ឋភាគីដែលជាភាគីមួយនៃវិវាទដែលមិនមានចែងនៅក្នុងសេចក្តីប្រកាសជាធរមាន ត្រូវបានចាត់ទុកថាបានទទួលយក មជ្ឈត្តការដោយអនុលោមតាមឧបសម្ព័ន្ធទី៧។

៤. ប្រសិនបើភាគីវិវាទបានទទួលយកនីតិវិធីដូចគ្នាសម្រាប់ការដោះស្រាយវិវាទ នោះករណីវិវាទនេះ អាចត្រូវបានបញ្ជូនទៅដោះស្រាយតែទៅតាមនីតិវិធីនោះប៉ុណ្ណោះ លើកលែងតែភាគីវិវាទព្រមព្រៀងគ្នាផ្សេងពីនេះ។

៥. ប្រសិនបើភាគីវិវាទពុំទទួលយកនីតិវិធីដូចគ្នាសម្រាប់ការដោះស្រាយវិវាទ នោះករណីវិវាទនេះ អាចត្រូវបានបញ្ជូនតែទៅមជ្ឈត្តការប៉ុណ្ណោះដោយអនុលោមតាមឧបសម្ព័ន្ធទី៧ លើកលែងតែភាគីវិវាទព្រមព្រៀងគ្នាផ្សេងពីនេះ។

៦. សេចក្តីប្រកាសដែលធ្វើឡើងតាមកថាខណ្ឌទី១ខាងលើ ត្រូវនៅមានអានុភាពរហូតដល់រយៈពេលបីខែ ទោះបីជាមានលិខិតជូនដំណឹងអំពីការដកសេចក្តីប្រកាសនេះដែលបានតម្កល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិក៏ដោយ។

៧. សេចក្តីប្រកាសថ្មី លិខិតជូនដំណឹងអំពីការដកសេចក្តីប្រកាស ឬការផុតសុពលភាពនៃសេចក្តីប្រកាស មិនត្រូវប៉ះពាល់ដោយប្រការណាមួយចំពោះដំណើរការនីតិវិធីដែលមិនទាន់ជំនុំជម្រះនៅតុលាការ ឬសាលាជំនុំជម្រះដែលមានយុត្តាធិការតាមមាត្រានេះឡើយ លើកលែងតែភាគីវិវាទព្រមព្រៀងគ្នាផ្សេងពីនេះ។

៨. សេចក្តីប្រកាសនិងលិខិតជូនដំណឹងដូចមានចែងក្នុងមាត្រានេះ ត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិដែលទទួលបន្ទុកបញ្ជូនសេចក្តីចម្លងនៃលិខិតទាំងនេះទៅកាន់បណ្តារដ្ឋភាគី។

## មាត្រា២៨៨
## យុត្តាធិការ

១. តុលាការ ឬសាលាជម្រះក្តីដូចមានចែងក្នុងមាត្រា២៨៧ខាងលើ ត្រូវមានយុត្តាធិការលើរាល់វិវាទដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ ដែលត្រូវបានបញ្ជូនមកខ្លួន ដោយអនុលោមតាមជំពូកនេះ។

២. តុលាការ ឬសាលាជម្រះក្តីដូចមានចែងក្នុងមាត្រា២៨៧ខាងលើ ក៏ត្រូវមានយុត្តាធិការផងដែរលើរាល់វិវាទដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិដែលទាក់ទងនឹងគោលបំណងនៃអនុសញ្ញានេះ ដែលត្រូវបានបញ្ជូនមកខ្លួនដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ ស្របតាមនីតិវិធីដែលបានកំណត់ស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ។

៣. សភាវិវាទបាតសមុទ្រនៃ តុលាការអន្តរជាតិនីតិសមុទ្រដែលត្រូវបានបង្កើតឡើងស្របតាមឧបសម្ព័ន្ធទី៦ និងសភា ឬតុលាការមជ្ឈត្តការផ្សេងទៀតដូចមានចែងក្នុងជំពូកទី១១ ផ្នែកទី៥ ត្រូវមានយុត្តាធិការលើគ្រប់រឿងក្តីដែលត្រូវបានបញ្ជូនមកខ្លួនដោយអនុលោមតាមបទប្បញ្ញត្តិទាំងនេះ។

៤. ក្នុងករណីមានវិវាទក្នុងការកំណត់ថាតើរឿងក្តីស្ថិតក្នុងយុត្តាធិការរបស់តុលាការ ឬសាលាជម្រះក្តី រឿងក្តីនោះត្រូវដោះស្រាយតាមការសម្រេចរបស់តុលាការ ឬសាលាជម្រះក្តីនោះ។

## មាត្រា២៨៩
## អ្នកជំនាញ

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងវិស័យវិទ្យាសាស្ត្រ ឬបច្ចេកទេស នោះតុលាការឬសាលាជម្រះក្តីដែលមានយុត្តាធិការក្រោមផ្នែកនេះ តាមការស្នើសុំពីភាគីណាមួយ ឬតាមគំនិតផ្តួចផ្តើមរបស់តុលាការឬសាលាជម្រះក្តី អាចធ្វើការជ្រើសរើសក្រុមអ្នកវិទ្យាសាស្ត្រ ឬអ្នកបច្ចេកទេសយ៉ាងតិចពីររូបដោយការពិគ្រោះយោបល់ជាមួយបណ្តាភាគី ជាពិសេសជ្រើសរើសចេញពីបញ្ជីឈ្មោះដែលពាក់ព័ន្ធ ដែលត្រូវបានរៀបចំឡើងដោយអនុលោមតាមឧបសម្ព័ន្ធទី៨ មាត្រា២ ដើម្បីចូលរួមសវនាការជាមួយតុលាការ ឬសាលាជម្រះក្តី ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតឡើយ។

## មាត្រា២៩០
## វិធានការបណ្តោះអាសន្ន

១. ប្រសិនបើវិវាទមួយត្រូវបានបញ្ជូនត្រឹមត្រូវទៅតុលាការឬសាលាជម្រះក្តីដែលខ្លួនយល់ជាបឋមថាមានយុត្តាធិការតាមជំពូកនេះឬជំពូកទី១១ ផ្នែកទី៥ តុលាការឬសាលាជម្រះក្តីអាចចេញវិធានការបណ្តោះអាសន្នណាមួយតាមដែលខ្លួនយល់ថាសមស្របតាមកាលៈទេសៈ ដើម្បីរក្សាការពារនូវសិទ្ធិរបស់ភាគីវិវាទ ឬដើម្បីបង្ការព្យសនកម្មធ្ងន់ធ្ងរដល់បរិស្ថានសមុទ្រ ដោយរង់ចាំការសម្រេចដល់អង្គសេចក្តី។

២. វិធានការបណ្តោះអាសន្នទាំងនេះអាចនឹងត្រូវបានកែប្រែឬលុបចោលវិញ នៅពេលដែលកាលៈទេសៈប្រែប្រួលឬលែងមាន។

៣. វិធានការបណ្តោះអាសន្នអាចនឹងត្រូវបានចេញ កែប្រែ ឬលុបចោលវិញ តាមមាត្រានេះ តែក្នុងករណីដែលមានភាគីមួយនៃវិវាទស្នើសុំ និងបន្ទាប់ពីភាគីវិវាទទាំងអស់ត្រូវបានផ្តល់ឱកាសដើម្បីការពារខ្លួន។

៤. តុលាការ ឬសាលាជម្រះក្តីត្រូវជូនដំណឹងភ្លាមៗទៅដល់ភាគីវិវាទ និងទៅដល់រដ្ឋភាគីដទៃទៀតតាមដែលខ្លួនយល់ថាសមស្រប ស្តីពីការចេញ ការកែប្រែ ឬការលុបចោលនូវវិធានការបណ្តោះអាសន្នទាំងនោះ។

៥. ខណៈដែលរង់ចាំការបង្កើតតុលាការមជ្ឈត្តការដែលទទួលវិវាទតាមផ្នែកនេះ តុលាការ ឬសាលាជម្រះក្តីដែលព្រមព្រៀងដោយភាគីវិវាទ ក្នុងករណីមិនមានការព្រមព្រៀងគ្នានៅក្នុងរយៈពេលពីរសប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទដាក់បណ្តឹងសុំឱ្យចេញវិធានការបណ្តោះអាសន្ន តុលាការអន្តរជាតិនីតិសមុទ្រ ឬសភាវិវាទបាតសមុទ្រចំពោះករណីដែលទាក់ទងនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិអាចចេញ កែប្រែ ឬលុបចោលនូវវិធានការបណ្តោះអាសន្នតាមមាត្រានេះ ប្រសិនបើខ្លួនយល់ជាបឋមថាសាលាជម្រះក្តីដែលនឹងត្រូវបង្កើតឡើងនោះ អាចមានយុត្តាធិការ ហើយប្រសិនបើខ្លួនយល់ថាមានស្ថានភាពបន្ទាន់បែបនោះ។ នៅពេលបង្កើតឡើង សាលាជម្រះក្តីដែលទទួលវិវាទនោះអាចកែប្រែ លុបចោល ឬតម្កល់វិធានការបណ្តោះអាសន្ន ដោយអនុលោមតាមកថាខណ្ឌទី១ ដល់កថាខណ្ឌទី៤ខាងលើ។

៦. ភាគីវិវាទត្រូវអនុវត្តជាបន្ទាន់តាមវិធានការបណ្តោះអាសន្នដែលចេញតាមមាត្រានេះ។

## មាត្រា២៩១
## សិទ្ធិចូលរួម

១. បណ្តារដ្ឋភាគីមានសិទ្ធិចូលរួមរាល់នីតិវិធីដោះស្រាយវិវាទដូចមានចែងក្នុងជំពូកនេះ។

២. បណ្តានីតិបុគ្គលក្រៅពីបណ្តារដ្ឋភាគីមានសិទ្ធិចូលរួមរាល់នីតិវិធីដោះស្រាយវិវាទ ដូចមានចែងក្នុងជំពូកនេះ លុះត្រាតែអនុសញ្ញានេះមានចែងយ៉ាងជាក់លាក់។

## មាត្រា២៩២
## ការដោះលែងនាវានិងក្រុមនាវិកភ្លាមៗ

១. ក្នុងករណីដែលអាជ្ញាធរនៃរដ្ឋភាគីមួយបានឃាត់ទុកនាវាដែលប្រើទង់ជាតិរបស់រដ្ឋភាគីមួយផ្សេងទៀត ហើយក្នុងករណីដែលមានការចោទប្រកាន់ថា រដ្ឋដែលធ្វើការឃាត់ទុកនាវាមិនបានអនុវត្តទៅតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះដែលចែងពីការដោះលែងនាវាឬក្រុមនាវិកភ្លាមៗ ក្រោយពីបានតម្កល់ប្រាក់ធានាសមរម្យឬការធានាផ្នែកហិរញ្ញវត្ថុផ្សេងទៀត នោះសំណុំរឿងនៃការដោះលែងពីការឃាត់ទុកឬការឃុំខ្លួនអាចត្រូវបញ្ជូនទៅតុលាការឬសាលាជម្រះក្តីណាមួយ ដែលភាគីបានព្រមព្រៀងគ្នា ឬក្នុងករណីដែលពុំមានការព្រមព្រៀងគ្នា ក្នុងរយៈពេល១០ថ្ងៃបន្ទាប់ពីការឃាត់ទុកឬការឃុំខ្លួន សំណុំរឿងនេះអាចបញ្ជូនទៅ តុលាការឬសាលាជម្រះក្តីណាមួយដែលទទួលស្គាល់ដោយរដ្ឋដែលធ្វើការឃាត់ទុកនាវាឬឃុំខ្លួនក្រុមនាវិក ស្របតាមមាត្រា២៨៧ ឬអាចបញ្ជូនទៅកាន់តុលាការអន្តរជាតិនីតិសមុទ្រ លើកលែងតែភាគីមានការព្រមព្រៀងគ្នាផ្សេងពីនេះ។

២. ការដាក់ពាក្យសុំដោះលែងអាចធ្វើឡើងបានដោយរដ្ឋម្ចាស់សញ្ជាតិនាវាឬក្នុងនាមរដ្ឋម្ចាស់សញ្ជាតិនាវានោះតែប៉ុណ្ណោះ។

៣. តុលាការឬសាលាជម្រះក្តីត្រូវដោះស្រាយលើពាក្យសុំដោះលែងដោយគ្មានការពន្យារពេលនិងត្រូវដោះស្រាយតែទៅលើបញ្ហាទាក់ទងនឹងការដោះលែងប៉ុណ្ណោះ ដោយមិននាំឱ្យប៉ះពាល់ដល់អង្គសេចក្តីនៃសំណុំរឿងមុនពេលមានដំណោះស្រាយសមស្របណាមួយក្នុងស្រុកប្រឆាំងនឹងនាវា ម្ចាស់នាវា ឬក្រុមនាវិក។ ដោយឡែកអាជ្ញាធរនៃរដ្ឋដែលធ្វើការឃាត់ទុកនាវានៅតែមានសមត្ថកិច្ចក្នុងការដោះលែងនាវាឬនាវិកនៅលើនាវាបានគ្រប់ពេល។

៤. នៅពេលដែលមានការតម្កល់ប្រាក់ធានា ឬការធានាផ្នែកហិរញ្ញវត្ថុផ្សេងទៀតដែលតុលាការឬសាលាជម្រះក្តីបានកំណត់ នោះអាជ្ញាធរនៃរដ្ឋដែលធ្វើការឃាត់នាវាឬឃុំខ្លួនក្រុមនាវិកត្រូវអនុវត្តភ្លាមៗតាមដីកាសម្រេចរបស់តុលាការឬសាលាជម្រះក្តីលើបញ្ហាឱ្យដោះលែងនាវាឬក្រុមនាវិក។

## មាត្រា២៩៣
## ច្បាប់ដែលត្រូវយកមកអនុវត្តន៍

១. តុលាការឬសាលាជម្រះក្តីដែលមានយុត្តាធិការតាមផ្នែកនេះ ត្រូវអនុវត្តអនុសញ្ញានេះនិងវិធានផ្សេងទៀតនៃនីតិអន្តរជាតិ ដែលមិនផ្ទុយនឹងអនុសញ្ញានេះ។

២. កថាខណ្ឌទី១ខាងលើមិនត្រូវប៉ះពាល់ដល់អំណាចរបស់តុលាការឬសាលាជម្រះក្តីដែលមានយុត្តាធិការតាមផ្នែកនេះ នៅក្នុងការសម្រេចសេចក្តី ដោយផ្អែកលើគោលការណ៍ត្រឹមត្រូវនិងសមធម៌ ប្រសិនបើភាគីវិវាទយល់ព្រមទទួលយកការសម្រេចបែបនេះ។

## មាត្រា២៩៤
## នីតិវិធីបឋម

១. តុលាការឬសាលាជម្រះក្តីដូចមានចែងក្នុងមាត្រា២៨៧ខាងលើ ដែលទទួលពាក្យសុំទាក់ទងនឹងវិវាទដូចមានចែងក្នុងមាត្រា២៩៧ ត្រូវធ្វើការសម្រេចតាមការស្នើសុំរបស់ភាគីម្ខាង ឬអាចធ្វើការសម្រេចដោយគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ថាតើការទាមទារនេះ រំលោភបំពានដល់ដំណើរការផ្លូវច្បាប់ ឬសម្រេចជាបឋមថាតើការទាមទារនេះមានមូលដ្ឋានត្រឹមត្រូវដែរឬទេ។ ប្រសិនបើតុលាការ ឬសាលាជម្រះក្តីសម្រេចថាការទាមទារនោះជាការរំលោភបំពានលើដំណើរការផ្លូវច្បាប់ ឬជាបឋមពុំមានមូលដ្ឋានត្រឹមត្រូវទេនោះ តុលាការឬសាលាជម្រះក្តីមិនត្រូវបន្តកិច្ចនីតិវិធីទៀតចំពោះរឿងក្តីនេះទៀតឡើយ។

២. នៅពេលដែលទទួលបានពាក្យសុំ តុលាការឬសាលាជម្រះក្តី ត្រូវជូនដំណឹងភ្លាមៗដល់ភាគីម្ខាងទៀត ឬភាគីដទៃទៀតនៃពាក្យសុំ និងត្រូវកំណត់រយៈពេលសមស្របដែល ដែលអាចអនុញ្ញាតឱ្យភាគីវិវាទ ស្នើសុំទៅតុលាការ ឬសាលាជម្រះក្តីដើម្បីសម្រេចដោយអនុលោមតាមកថាខណ្ឌទី១ខាងលើ។

៣. គ្មានបទប្បញ្ញត្តិណាមួយក្នុងមាត្រានេះ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយនៃវិវាទ ដំទាស់ដាបឋម ដោយអនុលោមតាមវិធាននីតិវិធីជាធរមាន។

## មាត្រា២៩៥

## ការប្រើប្រាស់យន្តការដោះស្រាយវិវាទក្នុងស្រុកឱ្យអស់ពីលទ្ធភាព

រាល់វិវាទរវាងបណ្តារដ្ឋភាគីទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ អាចដាក់តាមនីតិវិធីដូចមានចែងក្នុងផ្នែកនេះបានលុះត្រាតែមានការប្រើប្រាស់យន្តការដោះស្រាយវិវាទក្នុងស្រុកអស់លទ្ធភាព ដែលជាលក្ខខណ្ឌតម្រូវដោយនីតិអន្តរជាតិ។

## មាត្រា២៩៦

## សេចក្តីសម្រេចស្ថាពរនិងអានុភាពចាប់បង្ខំ

១. រាល់សេចក្តីសម្រេចរបស់តុលាការឬសាលាជម្រះក្តីដែលមានយុត្តាធិការតាមផ្នែកនេះ ត្រូវជាសេចក្តីសម្រេចស្ថាពរ ហើយដែលភាគីវិវាទត្រូវអនុវត្តតាម។

២. សេចក្តីសម្រេចទាំងនេះមានអានុភាពចាប់បង្ខំ ចំពោះតែភាគីវិវាទនិងចំពោះតែរឿងក្តីនោះប៉ុណ្ណោះ។

# ផ្នែកទី៣

# ការកម្រិតនិងអញ្ញត្រកម្មនៃការអនុវត្តផ្នែកទី២

## មាត្រា២៩៧

## ការកម្រិតចំពោះការអនុវត្តផ្នែកទី២

១. រាល់វិវាទដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់នូវសិទ្ធិអធិបតេយ្យ ឬយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ដូចមានចែងក្នុងអនុសញ្ញានេះ ត្រូវអនុវត្តដោយអនុលោមតាមនីតិវិធីដូចមានចែងក្នុងផ្នែកទី២ ក្នុងករណីដូចខាងក្រោម៖

(ក) នៅពេលដែលមានការចោទប្រកាន់ថា រដ្ឋជាប់ឆ្នេរសមុទ្រមួយបានប្រព្រឹត្តអំពើណាមួយដែលផ្ទុយទៅនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះពាក់ព័ន្ធនឹងសេរីភាព និងសិទ្ធិនៃការធ្វើនាវាចរណ៍ ការហោះហើរឆ្លងកាត់សមុទ្រ ឬការតភ្ជាប់បណ្តាញខ្សែកាប និងបំពង់បង្ហូរក្រោមបាតសមុទ្រ ឬដែលទាក់ទងនឹងការប្រើប្រាស់ស្របច្បាប់ជាអន្តរជាតិផ្សេងទៀតនៃសមុទ្រដូចមានចែងក្នុងមាត្រា៥៨នៃអនុសញ្ញានេះ។

(ខ) នៅពេលដែលមានការចោទប្រកាន់ថា រដ្ឋមួយនៅក្នុងការអនុវត្តនូវសេរីភាព សិទ្ធិ ឬការប្រើប្រាស់ដូចបានរៀបរាប់ខាងលើ បានប្រព្រឹត្តនូវអំពើផ្ទុយនឹង អនុសញ្ញានេះ ឬច្បាប់ ឬបទបញ្ជាត្រូវបានអនុម័តដោយរដ្ឋជាប់ឆ្នេរសមុទ្រ ដែលស្របតាមអនុសញ្ញានេះ និងវិធាននៃនីតិអន្តរជាតិដទៃទៀត ដែលមិនផ្ទុយនឹងអនុសញ្ញានេះ ឬ

(គ) នៅពេលដែលមានការចោទប្រកាន់ថា រដ្ឋជាប់ឆ្នេរសមុទ្របានប្រព្រឹត្តនូវអំពើផ្ទុយនឹងវិធាន និងស្តង់ដាអន្តរជាតិជាក់លាក់ស្តីពីកិច្ចការពារ និងអភិរក្សបរិស្ថានសមុទ្រ ដែលអនុវត្តចំពោះរដ្ឋជាប់ឆ្នេរសមុទ្រ ហើយដែលបង្កើតឡើងដោយអនុសញ្ញានេះ ឬតាមរយៈអង្គការអន្តរជាតិមានសមត្ថកិច្ច ឬសន្និសីទការទូតនានា ដោយអនុលោមតាមអនុសញ្ញានេះ។

២.	(ក)	រាល់វិវាទទាក់ទងនឹងការបកស្រាយ ឬអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះដែលពាក់ព័ន្ធនឹងការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ត្រូវដោះស្រាយដោយអនុលោមតាមផ្នែកទី២នេះ លើកលែងតែក្នុងករណីដែលរដ្ឋជាប់ឆ្នេរសមុទ្រមិនមានកាតព្វកិច្ចក្នុងការទទួលយកសំណុំរឿងដែលបានដាក់ដើម្បីធ្វើការដោះស្រាយវិវាទនានា ដែលបណ្តាលមកពី៖

(i) ការអនុវត្តសិទ្ធិ ឬឆន្ទានុសិទ្ធិណាមួយដែលធ្វើឡើងដោយរដ្ឋជាប់ឆ្នេរសមុទ្រ ដោយអនុលោមតាមមាត្រា២៤៦ ឬ

(ii) ការសម្រេចរបស់រដ្ឋជាប់ឆ្នេរសមុទ្របង្គាប់ឱ្យផ្អាកជាបណ្ដោះអាសន្ន ឬបញ្ឈប់ការអនុវត្តគម្រោងស្រាវជ្រាវ ដោយអនុលោមតាមមាត្រា ២៥៣។

(ខ)	វិវាទដែលកើតចេញពីការចោទប្រកាន់របស់រដ្ឋដែលធ្វើការស្រាវជ្រាវទាក់ទងនឹងគម្រោងជាក់លាក់ណាមួយដែលរដ្ឋជាប់ឆ្នេរសមុទ្រមិនអនុវត្តសិទ្ធិរបស់ខ្លួន ដូចមានចែងក្នុងមាត្រា២៤៦ និងមាត្រា២៥៣ ដោយអនុលោមតាមអនុសញ្ញានេះ វិវាទនោះត្រូវបញ្ជូនតាមការស្នើសុំពីភាគីណាមួយឱ្យធ្វើការផ្សះផ្សាតាមឧបសម្ព័ន្ធទី៥ ផ្នែកទី២ ក្នុងលក្ខខណ្ឌដែលគណៈកម្មការផ្សះផ្សាមិនបានកោះហៅធ្វើការសាកសួរពីការអនុវត្តឆន្ទានុសិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រ ដើម្បីឱ្យកំណត់អំពីតំបន់ជាក់លាក់ដូចមានចែងក្នុងមាត្រា២៤៦ កថាខណ្ឌទី៦ ឬការអនុវត្តនូវឆន្ទានុសិទ្ធិរបស់រដ្ឋនោះ ដោយមិនផ្តល់ការយល់ព្រម ដែលអនុលោមតាមមាត្រា២៤៦ កថាខណ្ឌទី៥ ។

៣.	(ក)	រាល់វិវាទទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលពាក់ព័ន្ធនឹងវិស័យជលផល ត្រូវដោះស្រាយដោយអនុលោមតាមផ្នែកទី២ លើកលែងតែរដ្ឋជាប់ឆ្នេរសមុទ្រពុំមានកាតព្វកិច្ចទទួលយកបណ្តឹងឱ្យដោះស្រាយវិវាទទាក់ទងនឹងសិទ្ធិអធិបតេយ្យរបស់ខ្លួនពាក់ព័ន្ធនឹងធនធានមានជីវិតដែលមាននៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬទាក់ទងនឹងការអនុវត្តនូវសិទ្ធិអធិបតេយ្យ រាប់បញ្ចូលទាំងអំណាចឆន្ទានុសិទ្ធិនៅក្នុងការកំណត់អំពីទិន្នផលនេសាទដែលអាចប្រមូលបាន សមត្ថភាពប្រមូលទិន្នផលនេសាទរបស់ខ្លួន ការបែងចែកទិន្នផលដែលលើសទៅដល់រដ្ឋដទៃទៀត និងការអនុវត្តនូវលក្ខខណ្ឌ ដូចមានចែងក្នុងច្បាប់និងបទបញ្ញាត្តិពីការអភិរក្សនិងការគ្រប់គ្រងធនធានរបស់រដ្ឋនោះ។

(ខ)	នៅក្នុងករណីដែលពុំមានដំណោះស្រាយ ដោយផ្អែកតាមផ្នែកទី១ នៃជំពូកនេះ វិវាទនោះត្រូវបញ្ជូនឱ្យដោះស្រាយតាមរយៈការផ្សះផ្សា តាមឧបសម្ព័ន្ធទី៥ ផ្នែកទី២ តាមសំណើរបស់ភាគីណាមួយនៃវិវាទ នៅពេលដែលមានការចោទប្រកាន់ថា៖

(i) រដ្ឋជាប់ឆ្នេរសមុទ្រមួយខកខានយ៉ាងច្បាស់លាស់ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមរយៈវិធានការអភិរក្សនិងវិធានការគ្រប់គ្រងសមស្រប ដើម្បីធានាថាធនធានមានជីវិតនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខមិនរងមហន្តរាយធ្ងន់ធ្ងរ។

(ii) រដ្ឋជាប់ឆ្នេរសមុទ្រមួយបានបដិសេធដោយទំនើងចិត្ត បើទោះបីមានការស្នើសុំពីរដ្ឋមួយផ្សេងទៀត នៅក្នុងការកំណត់អំពីទិន្នផលនេសាទដែលអាចប្រមូលបាន និងសមត្ថភាពក្នុងការប្រមូលទិន្នផលធនធានមានជីវិតរបស់ខ្លួន នូវស្តុកផលនេសាទដែលដែលរដ្ឋដទៃមានចំណាប់អារម្មណ៍ក្នុងការនេសាទ ឬ

(iii) រដ្ឋជាប់ឆ្នេរសមុទ្រមួយបានបដិសេធដោយទំនើងចិត្តក្នុងការបែងចែកទៅឱ្យរដ្ឋដទៃទៀត តាមមាត្រា៦២ មាត្រា៦៩ និងមាត្រា៧០ និងក្រោមលក្ខខណ្ឌ ដែលបង្កើតឡើងដោយរដ្ឋជាប់ឆ្នេរសមុទ្រនោះ ដោយមានសង្គតិភាពជាមួយ អនុសញ្ញានេះ នូវទិន្នផលដែលលើសទាំងស្រុង ឬមួយផ្នែកដែលរដ្ឋជាប់ឆ្នេរសមុទ្រនោះបានប្រកាសថាមាន។

(គ) ទោះជានៅក្នុងករណីណាក៏ដោយ គណៈកម្មការផ្សះផ្សាមិនត្រូវប្រើចន្ទានុសិទ្ធិរបស់ខ្លួន ជំនួសរដ្ឋជាប់ឆ្នោតសមុទ្រឡើយ។

(ឃ) របាយការណ៍ផ្សះផ្សារបស់គណៈកម្មការផ្សះផ្សា ត្រូវបញ្ជូនទៅបណ្តាអង្គការអន្តរជាតិ ដែលពាក់ព័ន្ធ។

(ង) នៅក្នុងការចរចាលើកិច្ចព្រមព្រៀង ស្របតាមមាត្រា៦៩ និងមាត្រា៧០ រដ្ឋភាគីត្រូវដាក់បញ្ចូល នូវប្រការស្តីពីវិធានការដែលត្រូវប្រកាន់យក លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ដើម្បីកាត់បន្ថយដល់កម្រិតអប្បបរមានូវលទ្ធភាពនៃការខ្វែងគំនិតគ្នាដែលទាក់ទងនឹង ការបកស្រាយឬការអនុវត្តកិច្ចព្រមព្រៀងនេះ និងអំពីការដាក់ឱ្យដំណើរការនូវវិធានការ ទាំងនោះ ក្នុងករណីដែលមានការខ្វែងគំនិតគ្នា ។

## មាត្រា២៩៨

## អញ្ញត្រកម្មជាជម្រើសនៃការអនុវត្តផ្នែកទី២

១. នៅពេលចុះហត្ថលេខាផ្តល់សច្ចាប័ន ឬចូលជាភាគីនៃអនុសញ្ញានេះ ឬនៅពេលក្រោយមកទៀត រដ្ឋមួយ អាចធ្វើសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរដោយមិនប៉ះពាល់ដល់កាតព្វកិច្ចដូចមានចែងក្នុងផ្នែកទី១ថាខ្លួនពុំ ទទួលយកនូវនីតិវិធីមួយ ឬច្រើនដូចមានចែងក្នុងផ្នែកទី២ ពាក់ព័ន្ធនឹងប្រភេទវិវាទមួយ ឬច្រើនដូចខាងក្រោម ៖

(ក) (i) វិវាទដែលទាក់ទងនឹងការបកស្រាយ ឬការអនុវត្តមាត្រា១៥ មាត្រា៧៤ និងមាត្រា៨៣ ពាក់ព័ន្ធនឹងការកំណត់ព្រំដែនសមុទ្រឬវិវាទដែលទាក់ទងនឹងឆកសមុទ្រឬកម្មសិទ្ធិ ជាប្រវត្តិសាស្ត្រ ក្នុងលក្ខខណ្ឌដែលរដ្ឋធ្វើសេចក្តីប្រកាសនោះត្រូវទទួលយកបណ្តឹង ដើម្បីផ្សះផ្សាស្របតាមឧបសម្ព័ន្ធទី៥ ផ្នែកទី២ នៅពេលវិវាទបានកើតឡើង ក្រោយការចូលជាធរមាននៃអនុសញ្ញានេះ និងក្នុងករណីដែលគ្មានការព្រមព្រៀង ណាមួយកើតឡើង ក្នុងរយៈពេលសមស្រប ក្នុងកិច្ចចរចារវាងភាគីវិវាទ តាមសំណើ របស់ភាគីវិវាទណាមួយ និងលើសពីនេះទៅទៀតក្នុងលក្ខខណ្ឌដែលវិវាទណាមួយ ដែលជាប់ពាក់ព័ន្ធជាចាំបាច់ជាមួយនឹងការពិនិត្យពិចារណាក្នុងពេលតែមួយនូវវិវាទ ដែលមិនបានដោះស្រាយទាក់ទងនឹងអធិបតេយ្យ ឬសិទ្ធិផ្សេងទៀតលើដែនដីគោក ឬដែនកោះ ត្រូវបានដកចេញពីបណ្តឹងវិវាទបែបនេះ។

(ii) ក្រោយពេលដែលគណៈកម្មការផ្សះផ្សាបានចេញរបាយការណ៍របស់ខ្លួនដែល បញ្ជាក់អំពីសំអាងហេតុ នោះភាគីវិវាទត្រូវចរចាគ្នាលើកិច្ចព្រមព្រៀងដោយយក របាយការណ៍នេះជាគោល ហើយប្រសិនបើការចរចា នេះមិនឈានដល់ការ ព្រមព្រៀងគ្នាបាន នោះភាគីវិវាទតាមការព្រមព្រៀងគ្នាទៅវិញទៅមក អាចបញ្ជូន វិវាទនេះទៅដោះស្រាយតាមនីតិវិធីណាមួយ ដូចមានចែងនៅក្នុងផ្នែកទី២ លើកលែងតែភាគីវិវាទព្រមព្រៀងគ្នាផ្សេងពីនេះ។

(iii) កថាខណ្ឌរងនេះមិនអនុវត្តចំពោះវិវាទអំពីព្រំដែនសមុទ្រ ដែលត្រូវ បានដោះស្រាយ ជាស្ថាពរតាមរយៈការព្រមព្រៀងគ្នារវាងភាគីវិវាទ ឬចំពោះវិវាទទាំងឡាយដែល ត្រូវដោះស្រាយដោយអនុលោមតាមកិច្ចព្រមព្រៀងទ្វេភាគីឬពហុភាគី ដែលចង កាតព្វកិច្ចចំពោះភាគីវិវាទនោះទេ។

(ខ) វិវាទទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពយោធា រាប់បញ្ចូលទាំងសកម្មភាពយោធា របស់នាវា និងអាកាសយានរបស់រដ្ឋាភិបាលដែលធ្វើប្រតិបត្តិការបេសកកម្ម ក្នុងគោលបំណង មិនមែនពាណិជ្ជកម្ម និងវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពអនុវត្តច្បាប់ពាក់ព័ន្ធ នឹងការប្រើប្រាស់នូវសិទ្ធិអធិបតេយ្យ ឬយុត្តាធិការដាច់ដោយឡែកពីយុត្តាធិការរបស់ តុលាការឬសាលាជម្រះក្តី ដូចមានចែងក្នុងមាត្រា២៩៧ កថាខណ្ឌទី២ ឬកថាខណ្ឌទី៣ ខាងលើ។

(គ) វិវាទពាក់ព័ន្ធនឹងការបំពេញមុខងាររបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលប្រគល់ដោយធម្មនុញ្ញអង្គការសហប្រជាជាតិ លើកលែងតែក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សម្រេចដកបញ្ហានេះចេញពីរបៀបវារៈរបស់ខ្លួន ឬកោះហៅភាគីវិវាទឱ្យធ្វើការដោះស្រាយវិវាទនោះ តាមរយៈមធ្យោបាយដូចមានចែងក្នុងអនុសញ្ញានេះ។

២. រដ្ឋភាគីដែលធ្វើសេចក្តីប្រកាសតាមកថាខណ្ឌទី១ខាងលើ អាចដកសេចក្តីប្រកាសនេះវិញបានគ្រប់ពេល ឬអាចព្រមព្រៀងបញ្ជូនវិវាទដែលមិនរាប់បញ្ចូលដោយសេចក្តីប្រកាសខាងលើ ដើម្បីដោះស្រាយតាមនីតិវិធីណាមួយដូចមានចែងក្នុងអនុសញ្ញានេះ។

៣. រដ្ឋភាគីដែលធ្វើសេចក្តីប្រកាសតាមកថាខណ្ឌទី១ខាងលើ មិនមានសិទ្ធិបញ្ជូនវិវាទដែលស្ថិតក្នុងប្រភេទវិវាទដែលជាអញ្ញត្រកម្ម ដើម្បីធ្វើការដោះស្រាយតាមនីតិវិធីណាមួយដូចមានចែងក្នុងអនុសញ្ញានេះប្រឆាំងនឹងរដ្ឋភាគីមួយផ្សេងទៀតដោយគ្មានការព្រមព្រៀងពីភាគីនោះបានឡើយ។

៤. ប្រសិនបើរដ្ឋភាគីមួយបានធ្វើសេចក្តីប្រកាសតាមកថាខណ្ឌទី១(ក) នោះរដ្ឋភាគីដទៃទៀតមានសិទ្ធិបញ្ជូនវិវាទដែលស្ថិតក្នុងប្រភេទវិវាទដែលជាអញ្ញត្រកម្ម ដើម្បីធ្វើការដោះស្រាយស្របតាមនីតិវិធីដូចមានចែងក្នុងសេចក្តីប្រកាសប្រឆាំងនឹងភាគីដែលធ្វើសេចក្តីប្រកាសនេះបាន។

៥. សេចក្តីប្រកាសថ្មី ឬការដកសេចក្តីប្រកាសមកវិញមិនប៉ះពាល់ដោយប្រការណាមួយដល់កិច្ចដំណើរការនីតិវិធី មិនទាន់ជំនុំជម្រះនៅតាមតុលាការ ឬសាលាជម្រះក្តី ដោយអនុលោមតាមមាត្រានេះឡើយ លើកលែងតែភាគីវិវាទព្រមព្រៀងគ្នាផ្សេងពីនេះ។

៦. សេចក្តីប្រកាស និងលិខិតជូនដំណឹងអំពីការដកសេចក្តីប្រកាសដែលធ្វើឡើងតាមមាត្រានេះ ត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវបញ្ជូនសេចក្តីចម្លងនៃឯកសារ ទាំងនេះទៅដល់បណ្តារដ្ឋភាគី។

### មាត្រា២៩៩
### សិទ្ធិរបស់ភាគីក្នុងការព្រមព្រៀងលើនីតិវិធី

១. វិវាទដែលត្រូវបានដកចេញដោយអនុលោមតាមមាត្រា២៩៧ ឬវិវាទដែលដកចេញដោយសេចក្តីប្រកាសដែលធ្វើឡើងដោយអនុលោមតាមមាត្រា២៩៨ ពីនីតិវិធីដោះស្រាយវិវាទដូចមានចែងក្នុងផ្នែកទី២ អាចត្រូវបានបញ្ជូនឱ្យដោះស្រាយស្របតាមនីតិវិធីដែលភាគីវិវាទមានការព្រមព្រៀងគ្នាតែប៉ុណ្ណោះ។

២. គ្មានបទប្បញ្ញត្តិណាមួយនៃផ្នែកនេះ ប៉ះពាល់ដល់សិទ្ធិរបស់ភាគីវិវាទក្នុងការព្រមព្រៀងគ្នាលើនីតិវិធីដទៃទៀតក្នុងការដោះស្រាយវិវាទ ឬដើម្បីឈានដល់ដំណោះស្រាយក្នុងលក្ខណៈមិត្តភាពនោះឡើយ។

## ជំពូកទី១៦
## បទប្បញ្ញត្តិទូទៅ

### មាត្រា៣០០
### សុចរិតភាពនិងការរំលោភសិទ្ធិ

បណ្តារដ្ឋភាគីត្រូវបំពេញកាតព្វកិច្ចដោយសុចរិតភាពដូចមានចែងក្នុងអនុសញ្ញានេះ និងត្រូវប្រើប្រាស់នូវសិទ្ធិ សមត្ថកិច្ច និងសេរីភាពដែលទទួលស្គាល់តាមអនុសញ្ញានេះ តាមលក្ខណៈដែលមិនមានការរំលោភសិទ្ធិ ណាមួយឡើយ។

### មាត្រា៣០១
### ការប្រើប្រាស់សមុទ្រដោយសន្តិវិធី

នៅក្នុងការប្រើប្រាស់សិទ្ធិនិងករណីយកិច្ចរបស់ខ្លួនតាមអនុសញ្ញានេះ បណ្តារដ្ឋភាគីត្រូវវៀរចាកពីអំពើគំរាមកំហែង ឬការប្រើកម្លាំងប្រឆាំងនឹងបូរណភាពដែនដី ឬឯករាជ្យភាពនយោបាយរបស់រដ្ឋណាមួយ ឬក្នុងលក្ខណៈណាមួយដែលមិនស្របនឹងគោលការណ៍នៃនីតិអន្តរជាតិដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ។

## មាត្រា៣០២
## ការលាតត្រដាងព័ត៌មាន

ដោយមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋភាគីក្នុងការប្រើប្រាស់នីតិវិធីដោះស្រាយវិវាទ ដូចមានចែងក្នុងអនុសញ្ញានេះ គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះត្រូវបានចាត់ទុកថា ជាការតម្រូវឱ្យរដ្ឋភាគីនោះបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់ព័ត៌មានតាមអនុសញ្ញានេះ ដែលការលាតត្រដាងព័ត៌មាននេះគឺជាការអនុវត្តផ្ទុយ នឹងផលប្រយោជន៍ជាសារវន្តផ្នែកសន្តិសុខរបស់ខ្លួន។

## មាត្រា៣០៣
## បុរាណវត្ថុនិងវត្ថុបន្សល់ពីប្រវត្តិសាស្ត្រ ដែលប្រទះឃើញនៅសមុទ្រ

១. បណ្តារដ្ឋមានករណីយកិច្ចការពារបុរាណវត្ថុនិងវត្ថុបន្សល់ទុកពីប្រវត្តិសាស្ត្រ ដែលប្រទះឃើញនៅសមុទ្រ និងត្រូវផ្តល់កិច្ចសហប្រតិបត្តិការក្នុងគោលបំណងនេះ។

២. ដើម្បីគ្រប់គ្រងការជួញដូរវត្ថុទាំងនេះ ដោយអនុវត្តតាមមាត្រា៣៣ រដ្ឋជាប់ឆ្នេរសមុទ្រអាចសន្មតថាការយកវត្ថុទាំងនេះចេញពីបាតសមុទ្រនៅក្នុងតំបន់ដូចមានចែងក្នុងមាត្រាខាងលើ ដោយគ្មានការអនុញ្ញាតពីខ្លួន ជាការរំលោភបំពានច្បាប់និងបទបញ្ជាដូចមានចែងក្នុងមាត្រានោះ នៅក្នុងដែនដីឬសមុទ្រដែនដីរបស់ខ្លួន។

៣. គ្មានបទប្បញ្ញត្តិណាមួយក្នុងមាត្រានេះ ប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់កម្មសិទ្ធិដែលអាចកំណត់អត្តសញ្ញាណបាន ច្បាប់ស្តីពីការស្រង់យកមកវិញ ឬវិធានដទៃទៀតនៃនាវាចរណ៍តាមសមុទ្រ ឬច្បាប់និងការអនុវត្ត ពាក់ព័ន្ធនឹងការផ្លាស់ប្តូរ វប្បធម៌។

៤. មាត្រានេះមិនប៉ះពាល់ដល់កិច្ចព្រមព្រៀងអន្តរជាតិនិងវិធាននៃនីតិអន្តរជាតិដទៃទៀតពាក់ព័ន្ធនឹងកិច្ចការពារបុរាណវត្ថុនិងវត្ថុបន្សល់ពីប្រវត្តិសាស្ត្រនោះឡើយ។

## មាត្រា៣០៤
## ការទទួលខុសត្រូវនិងបន្ទុកលើការខូចខាត

បទប្បញ្ញត្តិនៃអនុញ្ញានេះ ពាក់ព័ន្ធនឹងការទទួលខុសត្រូវនិងបន្ទុកលើការខូចខាត មិនមានប៉ះពាល់ដល់ការអនុវត្តវិធានជាធរមាន និងវិធានដែលកំពុងបង្កើតបន្ថែមទៀតពាក់ព័ន្ធនឹងការទទួលខុសត្រូវនិងបន្ទុកនានាតាមនីតិអន្តរជាតិនោះឡើយ។

# ជំពូកទី១៧
# អវសានបញ្ញត្តិ

## មាត្រា៣០៥
## ការចុះហត្ថលេខា

១. អនុសញ្ញានេះ បើកឱ្យមានការចុះហត្ថលេខាដោយៈ

(ក) រដ្ឋទាំងអស់។

(ខ) ណាមីប៊ី ដែលតំណាងដោយក្រុមប្រឹក្សាអង្គការសហប្រជាជាតិសម្រាប់ណាមីប៊ី។

(គ) រដ្ឋចងសម្ព័ន្ធទាំងអស់ដែលមានស្វ័យភាពដែលបានជ្រើសរើសយកឋានៈនេះ ក្នុងកិច្ចស្វ័យសម្រេចក្រោមការត្រួតពិនិត្យនិងអនុម័តដោយអង្គការសហប្រជាជាតិ ដោយអនុលោមតាមដំណោះស្រាយលេខ១៥១៤(ចំណុចទី១៥) របស់មហាសន្និបាតអង្គការសហប្រជាជាតិ ហើយដែលមានសមត្ថកិច្ចលើរាល់បញ្ហាដែលគ្របដណ្តប់ ដោយអនុសញ្ញានេះរាប់បញ្ចូលទាំងសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញាពាក់ព័ន្ធនឹងបញ្ហាទាំងនោះ។

(ឃ) ដោយអនុលោមតាមលិខិតូបករណ៍សម្ព័ន្ធរបស់ខ្លួន រដ្ឋចងសម្ព័ន្ធទាំងអស់ដែលមានស្វ័យភាព ដែលមានសមត្ថកិច្ចលើរាល់បញ្ហាដែលគ្របដណ្តប់ដោយអនុសញ្ញានេះរាប់បញ្ចូលទាំងសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញាពាក់ព័ន្ធនឹងបញ្ហាទាំងនោះ។

(ង) ដែនដីទាំងអស់ដែលមានស្វ័យភាពផ្ទៃក្នុងពេញលេញដែលត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ប៉ុន្តែមិនទាន់ទទួលបានឯករាជ្យភាពពេញលេញដោយអនុលោមតាមដំណោះស្រាយលេខ១៥១៤(ចំណុចទី១៥) ហើយដែលមានសមត្ថកិច្ចលើរាល់បញ្ហាដែលគ្របដណ្ដប់ដោយអនុសញ្ញានេះរាប់បញ្ចូលទាំងសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញាពាក់ព័ន្ធនឹងបញ្ហាទាំងនោះ។

(ច) បណ្ដាអង្គការអន្តរជាតិដោយអនុលោមតាមឧបសម្ព័ន្ធទី៩។

២. អនុសញ្ញានេះនៅតែបើកឱ្យមានការចុះហត្ថលេខារហូតដល់ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨៤ នៅក្រសួងការបរទេសនៃប្រទេសហ្សាម៉ាអ៊ីក និងចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៨៣ រហូតដល់ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨៤ នាទីស្នាក់ការកណ្ដាលអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក។

## មាត្រា៣០៦
## ការផ្ដល់សច្ចាប័ននិងការបញ្ជាក់ជាផ្លូវការ

អនុសញ្ញានេះត្រូវដាក់ឱ្យផ្ដល់សច្ចាប័នដោយបណ្ដារដ្ឋនិងនីតិបុគ្គលដទៃទៀត ដូចមានចែងក្នុងមាត្រា៣០៥ កថាខណ្ឌទី១ (ខ)(គ)(ឃ) និង(ង) និងការផ្ដល់ការបញ្ជាក់ជាផ្លូវការដោយអនុលោមតាមឧបសម្ព័ន្ធទី៩ ដោយបណ្ដានីតិបុគ្គល ដូចមានចែងក្នុងមាត្រា៣០៥ កថាខណ្ឌទី១(ច)។ លិខិតូបករណ៍សច្ចាប័ននិងលិខិតូបករណ៍បញ្ជាក់ជាផ្លូវការ ត្រូវតម្កល់ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា៣០៧
## ការចូលជាភាគី

អនុសញ្ញានេះនៅតែបើកឱ្យមានការចូលជាភាគីដោយបណ្ដារដ្ឋនិងនីតិបុគ្គលដទៃទៀត ដូចមានចែងក្នុងមាត្រា៣០៥។ ការចូលជាភាគីដោយនីតិបុគ្គល ដូចមានចែងក្នុងមាត្រា៣០៥ កថាខណ្ឌទី១(ច) ត្រូវធ្វើឡើងដោយអនុលោមតាមឧបសម្ព័ន្ធទី៩។ លិខិតូបករណ៍ចូលជាភាគី ត្រូវតម្កល់ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា៣០៨
## ការចូលជាធរមាន

១. អនុសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល១២ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់ទុកនូវលិខិតូបករណ៍សច្ចាប័នឬលិខិតូបករណ៍ចូលជាភាគីទីហុកសិប។

២. ចំពោះរដ្ឋនីមួយៗដែលផ្ដល់សច្ចាប័នឬចូលជាភាគីនៃអនុសញ្ញានេះ ក្រោយការតម្កល់ទុកនូវលិខិតូបករណ៍សច្ចាប័នឬលិខិតូបករណ៍ចូលជាភាគីទីហុកសិប អនុសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល សាមសិបថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់ទុកនូវលិខិតូបករណ៍សច្ចាប័នឬលិខិតូបករណ៍ចូលជាភាគីរបស់ខ្លួន ស្របតាមកថាខណ្ឌទី១។

៣. សន្និបាតរបស់អាជ្ញាធរបាតសមុទ្រអន្តរជាតិ ត្រូវជួបប្រជុំគ្នានៅកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ ហើយត្រូវបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាជ្ញាធរបាតសមុទ្រអន្តរជាតិ។ ក្រុមប្រឹក្សាដំបូងត្រូវបានបង្កើតឡើងក្នុងលក្ខណៈមួយស្របតាមគោលបំណងនៃមាត្រា១៦១ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមិនអាចយកមកអនុវត្តតឹងរ៉ឹងទេនោះ។

៤. វិធាន បទបញ្ញា និងនីតិវិធីដែលព្រាងដោយគណៈកម្មការត្រៀមរៀបចំ ត្រូវយកមកអនុវត្តជាបណ្ដោះអាសន្នសិន ដោយរង់ចាំការអនុម័តជាផ្លូវការពីអាជ្ញាធរបាតសមុទ្រអន្តរជាតិដោយអនុលោមតាមជំពូកទី១១។

៥.អាជ្ញាធរបាតសមុទ្រអន្តរជាតិនិងស្ថាប័នរបស់ខ្លួន ត្រូវបំពេញតួនាទីដោយអនុលោមតាមដំណោះស្រាយទី២ របស់សន្និសីទលើកទីបីរបស់អង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ ដែលទាក់ទងនឹងការវិនិយោគពីមុន និងតាមសេចក្ដីសម្រេចរបស់គណៈកម្មការត្រៀមរៀបចំ ដែលធ្វើឡើងស្របតាមដំណោះស្រាយខាងលើ។

## មាត្រា៣០៩
## ខរក្សាសិទ្ធិនិងអញ្ញត្រកម្ម

ពុំមានខរក្សាសិទ្ធិឬអញ្ញត្រកម្មណាមួយត្រូវបានធ្វើឡើងចំពោះអនុសញ្ញានេះឡើយ លើកលែងតែមានការអនុញ្ញាតជាក់លាក់ដោយមាត្រាដទៃទៀតនៃអនុសញ្ញានេះ។

## មាត្រា៣១០
## សេចក្តីប្រកាសនិងសេចក្តីថ្លែងការណ៍

នៅពេលចុះហត្ថលេខាផ្តល់សច្ចាប័នឬចូលជាភាគីនៃអនុសញ្ញានេះ មាត្រា៣០៩ មិនបានហាមឃាត់រដ្ឋណាមួយក្នុងការធ្វើសេចក្តីប្រកាសឬសេចក្តីថ្លែងការណ៍ ទោះបីជាតាក់តែងជាឃ្លាណាក៏ដោយ ឬមានឈ្មោះអ្វីក៏ដោយ ក្នុងគោលបំណងជាអាទិ៍ ធ្វើឱ្យមានសុខដុមនីយកម្មនៃច្បាប់និងបទបញ្ជារបស់ខ្លួនជាមួយនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះឡើយ ប្រសិនបើសេចក្តីប្រកាសឬសេចក្តីថ្លែងការណ៍នោះមិនមានគោលបំណងបដិសេធ ឬកែប្រែអានុភាពគតិយុត្តនៃបទប្បញ្ញត្តិរបស់អនុសញ្ញានេះ នៅក្នុងការអនុវត្តបទប្បញ្ញត្តិទាំងនេះចំពោះរដ្ឋសាមី។

## មាត្រា៣១១
## ទំនាក់ទំនងជាមួយនឹងអនុសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត

១. សម្រាប់បណ្តារដ្ឋភាគី អនុសញ្ញានេះត្រូវមានឧត្តមានុភាពលើអនុសញ្ញាទីក្រុងហ្សឺណែវស្តីពីនីតិមុទ្រ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៥៨។

២. អនុសញ្ញានេះមិនកែប្រែសិទ្ធិនិងកាតព្វកិច្ចរបស់រដ្ឋភាគី ដែលកើតចេញពីកិច្ចព្រមព្រៀងដទៃទៀតស្របតាមអនុសញ្ញានេះ ហើយដែលមិនប៉ះពាល់ដល់ការទទួលបានសិទ្ធិដោយរដ្ឋភាគីដទៃ ឬការបំពេញកាតព្វកិច្ចរបស់រដ្ឋទាំងនោះតាមអនុសញ្ញានេះឡើយ។

៣. រដ្ឋភាគីពីរឬច្រើនអាចចុះកិច្ចព្រមព្រៀង ដើម្បីកែប្រែឬផ្អាកការអនុវត្តនូវបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលអនុវត្តបានតែចំពោះទំនាក់ទំនងរវាងរដ្ឋទាំងនោះប៉ុណ្ណោះ ក្នុងលក្ខខណ្ឌដែលកិច្ចព្រមព្រៀងទាំងនេះមិនទាក់ទងនឹងបដិប្បញ្ញត្តិដែលមិនស្របនឹងការអនុវត្តប្រកបដោយប្រសិទ្ធភាព តាមកម្មវត្ថុនិងគោលបំណងនៃអនុសញ្ញានេះ និងលើសពីនេះទៅទៀត ក្នុងលក្ខខណ្ឌដែលកិច្ចព្រមព្រៀងទាំងនេះមិនប៉ះពាល់ដល់ការអនុវត្តគោលការណ៍ជាសារវន្តដូចមានចែងក្នុងអនុសញ្ញានេះ និងក្នុងលក្ខខណ្ឌដែលបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងទាំងនេះមិនប៉ះពាល់ដល់ការទទួលបានសិទ្ធិដោយរដ្ឋភាគីដទៃ ឬការបំពេញកាតព្វកិច្ចរបស់រដ្ឋទាំងនោះតាមអនុសញ្ញានេះឡើយ។

៤. បណ្តារដ្ឋភាគីដែលមានបំណងចុះកិច្ចព្រមព្រៀង ដូចមានចែងក្នុងកថាខណ្ឌទី៣ខាងលើត្រូវជូនដំណឹងដល់រដ្ឋភាគីដទៃទៀតតាមរយៈអ្នកតម្កល់ឯកសារអនុសញ្ញានេះ អំពីចេតនារបស់ខ្លួនក្នុងការចុះកិច្ចព្រមព្រៀងនេះ និងអំពីការកែប្រែឬការផ្អាកអនុវត្តនូវបទប្បញ្ញត្តិនោះ។

៥. មាត្រានេះមិនប៉ះពាល់ដល់កិច្ចព្រមព្រៀងអន្តរជាតិ ដែលត្រូវបានអនុញ្ញាតឬរក្សាទុកយ៉ាងជាក់លាក់ដោយមាត្រាដទៃទៀតនៃអនុសញ្ញានេះឡើយ។

៦. បណ្តារដ្ឋភាគីព្រមព្រៀងគ្នាថាមិនធ្វើវិសោធនកម្មណាមួយចំពោះគោលការណ៍ជាសារវន្ត ទាក់ទងនឹងបេតិកភណ្ឌរួមនៃមនុស្សជាតិ ដូចមានចែងក្នុងមាត្រា១៣៦ និងថាខ្លួនមិនចូលជាភាគីនៃកិច្ចព្រមព្រៀងណាមួយដែលផ្ទុយនឹងគោលការណ៍ជាសារវន្តនេះឡើយ។

## មាត្រា៣១២
## វិសោធនកម្ម

១. បន្ទាប់ពីផុតកំណត់រយៈពេល១០ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមាន តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ រដ្ឋភាគីមួយអាចស្នើសុំឱ្យមានការធ្វើវិសោធនកម្មជាក់លាក់ទៅលើអនុសញ្ញានេះ លើកលែងតែវិសោធនកម្មណាដែលទាក់ទងនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងអាចស្នើឱ្យកោះប្រជុំសន្និសីទ ដើម្បីពិនិត្យពិចារណាទៅលើសំណើសុំធ្វើវិសោធនកម្មខាងលើបាន។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវថតចម្លងផ្សព្វផ្សាយលិខិតជូនដំណឹងនេះទៅកាន់បណ្តារដ្ឋភាគីទាំងអស់។ ក្នុងរយៈពេល១២ខែបន្ទាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយលិខិតជូនដំណឹងនេះ ប្រសិនបើរដ្ឋជាភាគីមិនតិចជាងពាក់កណ្តាលឆ្លើយតបជាវិជ្ជមានចំពោះសំណើនេះ នោះអគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះប្រជុំសន្និសីទនេះឡើង។

២. នីតិវិធីនៃការសម្រេចដែលយកមកអនុវត្តនៅក្នុងសន្និសីទធ្វើវិសោធនកម្មនេះ ត្រូវយកមកអនុវត្តដូចគ្នាទៅនឹងនីតិវិធីនៅក្នុងសន្និសីទលើកទីបីរបស់អង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រផងដែរ លើកលែងតែអង្គសន្និសីទសម្រេចផ្សេងពីនេះ។ អង្គសន្និសីទត្រូវខិតខំព្យាយាមដើម្បីឱ្យមានការព្រមព្រៀងគ្នាជាឯកច្ឆន្ទលើការធ្វើវិសោធនកម្មណាមួយ ហើយនឹងគ្មានការបោះឆ្នោតចំពោះវិសោធនកម្មឡើយ បើគ្មានការខិតខំព្យាយាមរកការព្រមព្រៀងគ្នាជាឯកច្ឆន្ទទេ។

## មាត្រា៣១៣
## ការធ្វើវិសោធនកម្មតាមនីតិវិធីសាមញ្ញ

១. តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ លើកលែងតែការធ្វើវិសោធនកម្មដែលទាក់ទងទៅនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ រដ្ឋភាគីណាមួយអាចដាក់សំណើធ្វើវិសោធនកម្មលើអនុសញ្ញានេះបាន ហើយវិសោធនកម្មនេះត្រូវអនុម័តតាមនីតិវិធីសាមញ្ញដូចមានចែងក្នុងមាត្រានេះ ដោយពុំចាំបាច់ធ្វើការកោះប្រជុំសន្និសីទឡើយ។ អគ្គលេខាធិការត្រូវផ្សព្វផ្សាយលិខិតជូនដំណឹងនេះទៅដល់រដ្ឋភាគីទាំងអស់។

២. ក្នុងរយៈពេល១២ខែបន្ទាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយលិខិតជូនដំណឹងខាងលើ ប្រសិនបើរដ្ឋភាគីណាមួយជំទាស់នឹងសំណើធ្វើវិសោធនកម្មនេះឬជំទាស់នឹងការអនុម័តលើសំណើសុំធ្វើវិសោធនកម្មតាមនីតិវិធីសាមញ្ញ នោះវិសោធនកម្មនឹងត្រូវចាត់ទុកថាត្រូវបានបដិសេធ។ ក្នុងករណីនេះ អគ្គលេខាធិការត្រូវជូនដំណឹងភ្លាមទៅរដ្ឋភាគីទាំងអស់។

៣. ក្នុងរយៈពេល១២ខែបន្ទាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយលិខិតជូនដំណឹងនេះ ប្រសិនបើគ្មានរដ្ឋភាគីណាមួយបដិសេធនឹងសំណើសុំធ្វើវិសោធនកម្មឬជំទាស់នឹងការអនុម័តលើសំណើសុំធ្វើវិសោធនកម្មតាមនីតិវិធីសាមញ្ញ នោះសំណើសុំធ្វើវិសោធនកម្មនឹងត្រូវចាត់ទុកថាត្រូវបានអនុម័ត។ អគ្គលេខាធិការត្រូវជូនដំណឹងទៅដល់រដ្ឋភាគីទាំងអស់ថាសំណើសុំធ្វើវិសោធនកម្មនេះត្រូវបានអនុម័តរួចរាល់។

## មាត្រា៣១៤
## ការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលទាក់ទងជាពិសេសនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ

១. តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អគ្គលេខាធិការនៃអាជ្ញាធរបាតសមុទ្រអន្តរជាតិ រដ្ឋភាគីមួយអាចស្នើសុំធ្វើវិសោធនកម្មលើបទប្បញ្ញត្តិនានានៃអនុសញ្ញានេះ ដែលទាក់ទងជាពិសេសទៅនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ ដោយរាប់បញ្ចូលទាំងឧបសម្ព័ន្ធទី៦នៃផ្នែកទី៤ផង។ អគ្គលេខាធិការត្រូវផ្សព្វផ្សាយលិខិតជូនដំណឹងនេះទៅរដ្ឋភាគីទាំងអស់។ សំណើសុំធ្វើវិសោធនកម្មនេះ ត្រូវដាក់ជូនសន្និបាតដើម្បីអនុម័ត បន្ទាប់ពីមានការអនុម័តយល់ព្រមដោយក្រុមប្រឹក្សា។ តំណាងរបស់រដ្ឋភាគីនៅក្នុងស្ថាប័នទាំងនេះមានអំណាចពេញលេញក្នុងការពិនិត្យ និងអនុម័តយល់ព្រមលើសំណើសុំធ្វើវិសោធនកម្មនេះ។ សំណើសុំធ្វើវិសោធនកម្មដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សានិងសន្និបាត ត្រូវចាត់ទុកថាត្រូវបានអនុម័ត។

២. មុនពេលអនុម័តយល់ព្រមលើវិសោធនកម្មណាមួយតាមកថាខណ្ឌទី១ខាងលើ ក្រុមប្រឹក្សានិងសន្និបាតត្រូវជឿជាក់ថាវិសោធនកម្មមិនប៉ះពាល់ដល់ប្រព័ន្ធនៃការស្វែងរុករកនិងការធ្វើអាជីវកម្មធនធានក្នុងតំបន់បាតសមុទ្រអន្តរជាតិដោយរង់ចាំរហូតដល់សន្និសីទត្រួតពិនិត្យឡើងវិញ ដោយអនុលោមតាមមាត្រា១៥៥។

## មាត្រា៣១៥
## ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការចូលជាភាគី និងអត្ថបទយថាភូតនៃវិសោធនកម្ម

១. នៅពេលដែលត្រូវបានអនុម័តរួច វិសោធនកម្មលើអនុសញ្ញានេះ ត្រូវបើកឱ្យមានការចុះហត្ថលេខាដោយបណ្តារដ្ឋភាគី នាទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ក្នុងរយៈពេលពេល ១២ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអនុម័ត លើកលែងតែវិសោធនកម្មចែងផ្សេងពីនេះ។

២. មាត្រា៣០៦ មាត្រា៣០៧ និងមាត្រា៣២០ ត្រូវយកមកអនុវត្តចំពោះវិសោធនកម្មទាំងអស់នៃអនុសញ្ញានេះ។

## មាត្រា៣១៦
## ការចូលជាធរមាននៃវិសោធនកម្ម

១. ក្រៅពីវិសោធនកម្មដូចមានចែងក្នុងកថាខណ្ឌទី៥ វិសោធនកម្មលើអនុសញ្ញានេះ ត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីដែលបានផ្តល់សច្ចាប័ន ឬចូលជាភាគីក្នុងរយៈពេលសាមសិបថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតូបករណ៍សច្ចាប័នឬលិខិតូបករណ៍ចូលជាភាគីដោយរដ្ឋភាគីចំនួនពីរភាគបី ឬដោយរដ្ឋភាគីចំនួន៦០ ដោយជ្រើសរើសយកជម្រើសណាមួយដែលច្រើនជាង។ វិសោធនកម្មទាំងនេះ មិនប៉ះពាល់ដល់ការទទួលបានសិទ្ធិដោយរដ្ឋភាគីដទៃ ឬការបំពេញកាតព្វកិច្ចរបស់រដ្ឋទាំងនោះតាមអនុសញ្ញានេះឡើយ។

២. វិសោធនកម្មមួយ អាចចែងថាចំនួននៃការផ្តល់សច្ចាប័ន ឬការចូលជាភាគីត្រូវមានចំនួនច្រើនជាងចំនួនដែលមាត្រានេះតម្រូវ ដើម្បីអាចចូលជាធរមាន។

៣. ចំពោះរដ្ឋនីមួយៗដែលផ្តល់សច្ចាប័នឬចូលជាភាគីនៃវិសោធនកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ បន្ទាប់ពីការតម្កល់ទុកនូវលិខិតូបករណ៍សច្ចាប័នឬលិខិតូបករណ៍ចូលជាភាគីក្នុងចំនួនដែលត្រូវបានតម្រូវសម្រាប់ធ្វើវិសោធនកម្ម វិសោធនកម្មនេះត្រូវចូលជាធរមានក្នុងរយៈពេលសាមសិបថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់ទុកនូវលិខិតូបករណ៍សច្ចាប័នឬលិខិតូបករណ៍ចូលជាភាគីរបស់ខ្លួន។

៤. រដ្ឋណាមួយដែលក្លាយជាភាគីមួយនៃអនុសញ្ញានេះ ក្រោយពេលដែលវិសោធនកម្មនៃអនុសញ្ញានេះចូលជាធរមានដោយអនុលោមតាមកថាខណ្ឌទី១ខាងលើ ហើយដែលពុំបានបញ្ជាក់ពីចេតនាផ្សេងពីនេះ ក្នុងករណីនេះ រដ្ឋខាងលើត្រូវៈ

(ក) ចាត់ទុកថាជាភាគីមួយនៃអនុសញ្ញាតាមអត្ថន័យដែលបានធ្វើវិសោធនកម្មនោះ និង

(ខ) ចាត់ទុកថាជាភាគីមួយនៃអនុសញ្ញាដែលពុំបានធ្វើវិសោធនកម្មក្នុងទំនាក់ទំនងជាមួយរដ្ឋភាគីណាមួយដែលពុំជាប់កាតព្វកិច្ចដោយវិសោធនកម្ម។

៥. វិសោធនកម្មណាមួយដែលទាក់ទងជាពិសេសទៅនឹងសកម្មភាពនៅក្នុងតំបន់បាតសមុទ្រអន្តរជាតិ និងវិសោធនកម្មលើឧបសម្ព័ន្ធទី៦ ត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីទាំងអស់ក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់ទុកលិខិតលិខិតូបករណ៍សច្ចាប័នឬលិខិតូបករណ៍ចូលជាភាគី ដោយរដ្ឋភាគីចំនួនបីភាគបួន។

៦. រដ្ឋណាមួយដែលក្លាយជាភាគីនៃអនុសញ្ញានេះ ក្រោយការចូលជាធរមាននៃវិសោធនកម្មដែលធ្វើឡើងដោយអនុលោមតាមកថាខណ្ឌទី៥ ត្រូវបានចាត់ទុកថាជាភាគីមួយនៃអនុសញ្ញាតាមអត្ថន័យ ដែលបានធ្វើវិសោធនកម្ម។

## មាត្រា៣១៧

## ការប្រកាសដកខ្លួន

១. តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ រដ្ឋភាគីមួយអាចប្រកាសដកខ្លួនចេញពីអនុសញ្ញានេះ ហើយអាចបញ្ជាក់ហេតុផលរបស់ខ្លួន។ ការខកខានមិនបានបញ្ជាក់អំពីហេតុផលមិនប៉ះពាល់ដល់សុពលភាពនៃការប្រកាសដកខ្លួននេះឡើយ។ ការប្រកាសដកខ្លួននេះត្រូវមានអានុភាពក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតជូនដំណឹងនេះ លើកលែងតែលិខិតជូនដំណឹងបានកំណត់កាលបរិច្ឆេទលើសពីមួយឆ្នាំ។

២. ទោះជាមានហេតុផលនៃការប្រកាសដកខ្លួនក៏ដោយ ក៏រដ្ឋមួយមិនត្រូវបានរួចផុតពីកាតព្វកិច្ចហិរញ្ញវត្ថុ និងកាតព្វកិច្ចកិច្ចសន្យានៅពេលដែលរដ្ឋនោះនៅជាភាគីនៃអនុសញ្ញា ហើយការប្រកាសដកខ្លួននេះក៏មិនប៉ះពាល់ដល់សិទ្ធិ កាតព្វកិច្ច ឬស្ថានភាពគតិយុត្ត ដែលរដ្ឋនោះបានបង្កើតឡើងក្នុងការអនុវត្តអនុសញ្ញានេះ មុនពេលដែលអនុសញ្ញាលែងមានអានុភាពចំពោះរដ្ឋនោះ។

៣. ការប្រកាសដកខ្លួននេះមិនធ្វើឱ្យប៉ះពាល់ដោយប្រការណាមួយដល់ករណីកិច្ចរបស់រដ្ឋភាគីក្នុងការបំពេញកាតព្វកិច្ចដូចមានចែងក្នុងអនុសញ្ញានេះ ល្គឹកណាដែលរដ្ឋនោះនៅតែស្ថិតក្រោមអានុភាពនៃនីតិអន្តរជាតិដែលឯករាជ្យពីអនុសញ្ញានេះ។

## មាត្រា៣១៨

## ឋានៈនៃឧបសម្ព័ន្ធ

បណ្តាឧបសម្ព័ន្ធត្រូវតែជាផ្នែកទាំងមូលនៃអនុសញ្ញានេះ ហើយលើកលែងតែមានការចែងជាក់លាក់ផ្សេងពីនេះ ការយោងលើអនុសញ្ញានេះ ឬផ្នែកណាមួយនៃអនុសញ្ញានេះ ត្រូវរាប់បញ្ចូលទាំងឧបសម្ព័ន្ធដែលពាក់ព័ន្ធផងដែរ។

## មាត្រា៣១៩
## អ្នកតម្កល់ឯកសារ

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវតែជាអ្នកតម្កល់ឯកសារអនុសញ្ញានិងវិសោធនកម្មនៃអនុសញ្ញានេះ។

២. បន្ថែមពីលើមុខងារជាអ្នកតម្កល់ឯកសារ អគ្គលេខាធិការត្រូវ៖

(ក) រាយការណ៍ដល់រដ្ឋភាគីទាំងអស់ អាជ្ញាធរបាតសមុទ្រអន្តរជាតិ និងបណ្ដាអង្គការអន្តរជាតិមានសមត្ថកិច្ចអំពីបញ្ហាទូទៅដែលបានកើតឡើងទាក់ទងនឹងអនុសញ្ញានេះ។

(ខ) ជូនដំណឹងដល់អាជ្ញាធរបាតសមុទ្រអន្តរជាតិអំពីការផ្ដល់សច្ចាប័ន ការបញ្ជាក់ជាផ្លូវការ ការចូលជាភាគីនៃអនុសញ្ញានេះ និងវិសោធនកម្មលើអនុសញ្ញា ព្រមទាំងការប្រកាសដកខ្លួនចេញពីអនុសញ្ញានេះ។

(គ) ជូនដំណឹងដល់បណ្ដារដ្ឋភាគីអំពីកិច្ចព្រមព្រៀងដែលបានធ្វើឡើងដោយអនុលោមតាមមាត្រា៣១១ កថាខណ្ឌទី៤។

(ឃ) ផ្សព្វផ្សាយវិសោធនកម្មដែលត្រូវបានអនុម័តដោយអនុលោមតាមអនុសញ្ញានេះ ទៅដល់បណ្ដារដ្ឋភាគី សម្រាប់ការផ្ដល់សច្ចាប័នឬការចូលជាភាគី។

(ង) កោះអញ្ជើញបណ្ដារដ្ឋភាគីចូលរួមកិច្ចប្រជុំដែលចាំបាច់ ដោយអនុលោមតាមអនុសញ្ញានេះ។

៣. (ក) អគ្គលេខាធិការអង្គការសហប្រជាជាតិក៏ត្រូវបញ្ជូនផងដែរ ដល់អ្នកសង្កេតការណ៍ ដូចមានចែងក្នុងមាត្រា១៥៦ នូវ៖

(i) របាយការណ៍ដូចមានចែងក្នុងកថាខណ្ឌទី ២(ក)

(ii) លិខិតជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌទី២ (ខ) និង(គ) និង

(iii) អត្ថបទវិសោធនកម្មដូចមានចែងក្នុងកថាខណ្ឌទី២ (ឃ) ដើម្បីជូនជ្រាបជាព័ត៌មាន។

(ខ) អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវអញ្ជើញអ្នកសង្កេតការណ៍ទាំងនោះផងដែរឱ្យចូលរួមក្នុងនាមជាអ្នកសង្កេតការណ៍ក្នុងកិច្ចប្រជុំបណ្ដារដ្ឋភាគី ដូចមានចែងក្នុងកថាខណ្ឌទី២(ង)។

## មាត្រា៣២០
## អត្ថបទយថាភូត

ឯកសារច្បាប់ដើមនៃអនុសញ្ញានេះដែលធ្វើឡើងជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដែលមានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្របតាមមាត្រា៣០៥កថាខណ្ឌទី២។

ដើម្បីជាសក្ខីភាព តំណាងពេញសមត្ថភាព ដែលត្រូវបានអនុញ្ញាតត្រឹមត្រូវតាមផ្លូវច្បាប់បានចុះហត្ថលេខាលើអនុសញ្ញានេះ។

ធ្វើនៅទីក្រុងម៉ុងតេហ្គោបេ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២។

# ឧបសម្ព័ន្ធទី១
## ពូជត្រីដែលផ្លាស់ប្តូរទីកន្លែងរស់នៅឆ្ងាយ

| | |
|---|---|
| ១- ត្រីធូណាព្រុយវែង | : Thunnus alalunga |
| ២- ត្រីធូណាព្រុយខៀវ | : Thunnus thynnus |
| ៣- ត្រីធូណាភ្នែកធំ | : Thunnus obesus |
| ៤- ត្រីធូណាឆ្នូត | : Katsuwonus pelamis |
| ៥- ត្រីធូណាព្រុយលឿង | : Thunnus albacares |
| ៦- ត្រីធូណាព្រុយខ្មៅ | : Thunnus atlanticus |
| ៧- ត្រីធូណាតូច | : Euthynnus alletteratus; Euthynnus affinis |
| ៨- ត្រីធូណាព្រុយខៀវភាគខាងត្បូង | : Thunnus maccoyii |
| ៩- ត្រីកាឡាំង | : Auxis thazard; Auxis rochei |
| ១០- អំបូរត្រីចាប | : Family Bramidae |
| ១១- ក្រុមត្រីបេកាជំរី | : Tetrapturus angustirostris; Tetrapturus belone; Tetrapturus pfluegeri; Tetrapturus albidus; Tetrapturus audax; Tetrapturus georgei; Makaira mazara; Makaira indica; Makaira nigricans |
| ១២- ត្រីបេកាជំរីព្រុយវែង | : Istiophorus platypterus; Istiophorus albicans |
| ១៣- ត្រីដាវ | : Xiphias gladius |
| ១៤- ក្រុមត្រីផ្ទោង | : Scomberesox saurus; Cololabis saira; Cololabis adocetus; Scomberesox saurus scombroides |
| ១៥- ផ្សោត | : Coryphaena hippurus; Coryphaena equiselis |
| ១៦- អំបូរត្រីឆ្លាម | : Hexanchus griseus; Cetorhinus maximus; Family Alopiidae; Rhincodon typus; Family Carcharhinidae; Family Sphyrnidae; Family Isuridae |
| ១៧- អំបូរត្រីបាឡែន | : Families: Physeteridae; Balaenopteridae; Balaenidae; Eschrichtiidae; Monodontidae; Ziphiidae; Delphinidae |

## ឧបសម្ព័ន្ធទី២
## គណៈកម្មការកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្រ

### មាត្រា១

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៧៦ គណៈកម្មការកំណត់ព្រំដែនតំបន់ខ្ពង់រាបបាតសមុទ្រដែលលាតសន្ធឹងលើសពី២០០ ម៉ៃល៍សមុទ្រ ត្រូវបានបង្កើតឡើងស្របតាមមាត្រាខាងក្រោម។

### មាត្រា២

១. គណៈកម្មការនេះត្រូវមានសមាជិកចំនួន២១រូប ដែលជាអ្នកជំនាញលើផ្នែកភូគព្ភសាស្ត្រ ភូគព្ភរូបវន្ត ឬផ្នែកជលសាស្ត្រ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយរដ្ឋភាគីនៃអនុសញ្ញានេះ ចេញពីក្នុងចំណោមពលរដ្ឋរបស់ខ្លួន ក្នុងទិសដៅដើម្បីឆ្លើយតបនឹងតម្រូវការក្នុងការធានាឱ្យមានតំណាងប្រកបដោយសមធម៌មកពីតំបន់នានាដែលត្រូវបម្រើការងារទៅតាមសមត្ថភាពផ្ទាល់របស់ពួកគេ។

២. ដំណើរការបោះឆ្នោតដំបូងនឹងត្រូវប្រារព្ធឡើងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប៉ុន្តែមិនត្រូវលើសពីរយៈពេល១៨ខែ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាននោះទេ។ យ៉ាងហោចណាស់រយៈពេលបីខែ នៅមុនកាលបរិច្ឆេទបោះឆ្នោតជ្រើសរើសនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនលិខិតអញ្ជើញមួយទៅកាន់រដ្ឋភាគីទាំងអស់ ស្នើសុំឱ្យធ្វើការចាត់តាំងតំណាងរបស់ខ្លួនក្នុងរយៈពេលបីខែ បន្ទាប់ពីមានការពិគ្រោះយោបល់យ៉ាងសមស្របនៅថ្នាក់តំបន់។ អគ្គលេខាធិការត្រូវរៀបចំបញ្ជីឈ្មោះរាល់បេក្ខជនដែលចាត់តាំងឡើងតាមលំដាប់អក្ខរក្រម និងត្រូវបញ្ជូនបញ្ជីឈ្មោះនេះដល់រាល់រដ្ឋភាគីទាំងអស់។

៣. ការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មការ ត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំរដ្ឋភាគី នៅទីស្នាក់ការអង្គការសហប្រជាជាតិ តាមការកោះអញ្ជើញពីអគ្គលេខាធិការ។ នៅក្នុងកិច្ចប្រជុំនេះ ពីភាគបីនៃរដ្ឋភាគីទាំងអស់នឹងបង្កើតបានជាកូរ៉ុម ហើយបេក្ខជនដែលត្រូវបានបោះឆ្នោតជ្រើសតាំងក្នុងគណៈកម្មការនេះ ត្រូវទទួលសិទ្ធិជាតំណាងដែលមានសំឡេងឆ្នោតភាគច្រើន ពីភាគបីនៃតំណាងរបស់រដ្ឋភាគីដែលមាន វត្តមាននៅក្នុងកិច្ចប្រជុំ និងនៅក្នុងការបោះឆ្នោត។

៤. សមាជិកគណៈកម្មការដែលជាប់ឆ្នោត ត្រូវកាន់មុខតំណែងសម្រាប់អាណត្តិប្រាំឆ្នាំ។ ដោយឡែក សមាជិកគ្រប់រូបអាចមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសម្រាប់អាណត្តិបន្ទាប់ទៀតបាន។

៥. រដ្ឋភាគីដែលបានបញ្ជូនឈ្មោះបេក្ខជនឱ្យឈរឈ្មោះជាសមាជិករបស់គណៈកម្មការ ត្រូវទទួលបន្ទុកការចំណាយរបស់សមាជិករូបនោះ ខណៈដែលបំពេញភារកិច្ចការងារនៅក្នុងគណៈកម្មការ។ រដ្ឋជាប់ឆ្នេរសមុទ្រដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកការចំណាយទាក់ទងនឹងការណែនាំ ដូចមានចែងក្នុងកថាខណ្ឌទី១(ខ) ក្រោមមាត្រា៣នៃឧបសម្ព័ន្ធនេះ។ លេខាធិការដ្ឋានរបស់គណៈកម្មការនឹងត្រូវផ្តល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

### មាត្រា៣

១. គណៈកម្មការមានមុខងារដូចខាងក្រោម៖

(ក) ពិនិត្យទិន្នន័យ និងសម្ភារឯកសារផ្សេងទៀតដែលរដ្ឋជាប់ឆ្នេរបានផ្តល់ឱ្យទាក់ទងនឹងដែនខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រនៅក្នុងតំបន់ដែលព្រំដែនទាំងនោះលាតសន្ធឹងលើសពី២០០ ម៉ែល៍សមុទ្រ និងផ្តល់អនុសាសន៍ដោយអនុលោមតាមមាត្រា៧៦ និងសេចក្តីថ្លែងការណ៍នៃការយោគយល់ដែលបានអនុម័តនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៨០ នៅក្នុងអង្គសន្និសីទសហប្រជាជាតិ លើកទី៣ ស្តីពីនីតិសមុទ្រ។

(ខ) ផ្តល់ការណែនាំផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេស កាលបើមានការស្នើសុំពីរដ្ឋជាប់ឆ្នេរសមុទ្រដែលពាក់ព័ន្ធនៅក្នុងការរៀបចំទិន្នន័យដូចមានចែងក្នុងកថាខណ្ឌរង (ក)។

២. គណៈកម្មការអាចធ្វើការសហការក្នុងកម្រិតមួយដែលយល់ថាចាំបាច់និងមានសារប្រយោជន៍ ជាមួយនឹងគណៈកម្មការអន្តររដ្ឋាភិបាលទទួលបន្ទុកភូមិសាស្ត្រមហាសមុទ្ររបស់អង្គការយូណេស្កូ អង្គការជលសាស្ត្រអន្តរជាតិ និងបណ្តាអង្គការអន្តរជាតិមានសមត្ថកិច្ចដទៃទៀត ក្នុងទិសដៅធ្វើការផ្លាស់ប្តូរទៅវិញទៅមកនូវព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេស ដែលអាចជាប្រយោជន៍ដល់ការបំពេញភារកិច្ចរបស់គណៈកម្មការ។

### មាត្រា៤

ក្នុងករណីដែលរដ្ឋជាប់ឆ្នេរសមុទ្រមួយមានបំណងបង្កើតនូវព្រំដែនខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួនដែលលាតសន្ធឹងលើសពី២០០ ម៉ែល៍សមុទ្រ ស្របតាមមាត្រា៧៦ សាមីរដ្ឋត្រូវផ្តល់សេចក្តីលម្អិតឱ្យបានច្បាស់លាស់អំពីព្រំដែនទាំងនោះមកគណៈកម្មការ រួមជាមួយនឹងទិន្នន័យវិទ្យាសាស្ត្រនិងបច្ចេកទេសសម្រាប់ជាសំអាងផងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ប៉ុន្តែទោះជាក្នុងករណីណាក៏ដោយ មិនត្រូវលើសពីរយៈពេល១០ឆ្នាំ គិតចាប់ពីអនុសញ្ញានេះចូលជាធរមានសម្រាប់រដ្ឋភាគីនោះឡើយ។ ទន្ទឹមនឹងនោះដែរ រដ្ឋជាប់ឆ្នេរសមុទ្រត្រូវផ្តល់ឈ្មោះសមាជិករបស់គណៈកម្មការណាមួយដែលបានផ្តល់ឱ្យរដ្ឋនោះនូវការណែនាំផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេស។

### មាត្រា៥

លើកលែងតែមានការសម្រេចផ្ទុយពីនេះដោយគណៈកម្មការ គណៈកម្មការត្រូវបំពេញមុខងារតាមរយៈអនុគណៈកម្មការដែលមានសមាសភាពសមាជិកចំនួនប្រាំពីររូប ដែលត្រូវបានជ្រើសតាំងឡើងដោយរដ្ឋភាគី ដោយមានតុល្យភាពជាមួយនឹងសមាសភាពជាក់លាក់របស់អនុគណៈកម្មការនីមួយៗនៃសំណើនីមួយៗរបស់រដ្ឋជាប់ឆ្នេរសមុទ្រ។ ពលរដ្ឋនៃរដ្ឋជាប់ឆ្នេរសមុទ្រដាក់បញ្ជូនសំណើដែលជាសមាជិករបស់គណៈកម្មការ និងសមាជិកគណៈកម្មការណាមួយដែលបានជួយដល់រដ្ឋជាប់ឆ្នេរសមុទ្រដោយផ្តល់ការណែនាំផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសទាក់ទងនឹងការកំណត់ខ្សែបន្ទាត់ព្រំដែន មិនត្រូវជាសមាជិករបស់អនុគណៈកម្មការទទួលបន្ទុកដោះស្រាយសំណើដែលបានដាក់ជូនឡើយ គឺមានសិទ្ធិត្រឹមតែចូលរួមក្នុងនាមជាសមាជិកមួយរូប នៅក្នុងកិច្ចដំណើរការរបស់គណៈកម្មការទាក់ទងនឹងសំណើដែលបានដាក់ជូនប៉ុណ្ណោះ។ រដ្ឋជាប់ឆ្នេរសមុទ្រដែលបានដាក់បញ្ជូនសំណើមកគណៈកម្មការអាចចាត់បញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមនៅក្នុងកិច្ចដំណើរការពាក់ព័ន្ធបាន ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតនោះទេ។

## មាត្រា៦

១. អនុគណៈកម្មការត្រូវដាក់បញ្ជូនអនុសាសន៍របស់ខ្លួនបកគណៈកម្មការ។

២. ការអនុម័តរបស់គណៈកម្មការលើអនុសាសន៍ដែលផ្ដល់ដោយអនុគណៈកម្មការ ត្រូវមានសំឡេងគាំទ្រភាគច្រើន ពីរភាគបីនៃសមាជិកគណៈកម្មការទាំងអស់ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ និងមានសិទ្ធិបោះឆ្នោត។

៣. អនុសាសន៍របស់គណៈកម្មការត្រូវដាក់បញ្ជូនជាលាយលក្ខណ៍អក្សរទៅកាន់រដ្ឋជាប់ឆ្នេរសមុទ្រដែលបានដាក់សំណើ និងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា៧

រដ្ឋជាប់ឆ្នេរសមុទ្រត្រូវបង្កើតនូវព្រំដែនខាងក្រៅនៃតំបន់ខ្ពង់រាបបាតសមុទ្រ ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៧៦ កថាខណ្ឌទី៨ និងដោយអនុលោមតាមនីតិវិធីសមស្របរបស់ប្រទេសនីមួយៗ។

## មាត្រា៨

ក្នុងករណីដែលមានការជំទាស់របស់រដ្ឋជាប់ឆ្នេរសមុទ្រទៅលើអនុសាសន៍របស់គណៈកម្មការ នោះរដ្ឋជាប់ឆ្នេរសមុទ្រ ត្រូវធ្វើការពិនិត្យឡើងវិញ ឬដាក់សំណើថ្មីទៅកាន់គណៈកម្មការនៅក្នុងរយៈពេលដែលសមស្រប។

## មាត្រា៩

ចំណាត់ការរបស់គណៈកម្មការនឹងមិនប៉ះពាល់ដល់បញ្ហាទាក់ទងនឹងការកំណត់ព្រំដែនសមុទ្ររវាងរដ្ឋដែលមានតំបន់ឆ្នេរទល់គ្នាឬជាប់គ្នានោះទេ។

## ឧបសម្ព័ន្ធទី៣
## លក្ខខណ្ឌមូលដ្ឋាននៃការធ្វើបុរេសេនា ការស្វែងរុករក និងការធ្វើអាជីវកម្ម

### មាត្រា១
### កម្មសិទ្ធិលើរ៉ែ

កម្មសិទ្ធិលើរ៉ែត្រូវផ្តល់ជូននៅពេលទាញយកបាន អនុលោមតាមអនុសញ្ញានេះ។

### មាត្រា២
### ការធ្វើបុរេសេនា

១. (ក) អាជ្ញាធរត្រូវជំរុញឱ្យមានការធ្វើបុរេសេនានៅក្នុងតំបន់។

(ខ) ការធ្វើបុរេសេនាត្រូវធ្វើឡើងតែក្នុងករណីដែលអាជ្ញាធរទទួលបានការសន្យាជាលាយលក្ខណ៍អក្សរដែលសមស្របថា អ្នកស្នើសុំធ្វើបុរេសេនាដែលដាក់សំណើសុំធ្វើបុរេសេនាយល់ព្រមគោរពតាមខ្លឹមសារអនុសញ្ញានេះ រួមទាំងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីដែលពាក់ព័ន្ធរបស់អាជ្ញាធរ ទាក់ទងនឹងកិច្ចសហប្រតិបត្តិការលើកម្មវិធីបណ្តុះបណ្តាលដូចមានចែងក្នុងមាត្រា១៤៣ និងមាត្រា១៤៤ និងការការពារបរិស្ថានសមុទ្រ និងយល់ព្រមឱ្យមានការត្រួតពិនិត្យលើការប្រតិបត្តិពីសំណាក់អាជ្ញាធរ។ ទន្ទឹមនឹងនេះដែរ បុគ្គលដែលស្នើសុំធ្វើបុរេសេនាត្រូវជូនដំណឹងដល់អាជ្ញាធរ អំពីផ្ទៃក្រឡាប្រហាក់ប្រហែល ឬអំពីតំបន់ដែលត្រូវធ្វើបុរេសេនា។

(គ) ការធ្វើបុរេសេនាអាចធ្វើឡើងដោយអ្នកធ្វើបុរេសេនាលើសពីមួយបានក្នុងពេលជំណាលគ្នានៅក្នុងតំបន់តែមួយឬច្រើនតំបន់។

២. ការធ្វើបុរេសេនាមិនមែនជាការផ្តល់សិទ្ធិឱ្យអ្នកធ្វើបុរេសេនានូវសិទ្ធិណាមួយលើធនធាននោះទេ។ ដោយឡែក អ្នកធ្វើបុរេសេនាអាចទាញយករ៉ែក្នុងចំនួនដែលសមស្រប សម្រាប់បម្រើឱ្យគោលបំណងនៃការពិសោធ។

### មាត្រា៣
### ការស្វែងរុករកនិងការធ្វើអាជីវកម្ម

១. សហគ្រាស រដ្ឋភាគី និងអង្គភាពដទៃទៀតដូចមានចែងក្នុងកថាខណ្ឌទី២(ខ) នៃមាត្រា១៥៣ អាចដាក់ពាក្យមកអាជ្ញាធរ ស្នើសុំការអនុម័តលើផែនការការងារសម្រាប់សកម្មភាពផ្សេងៗនៅក្នុងតំបន់បាន។

២. សបគ្រាសអាចដាក់ពាក្យស្នើសុំលើផ្នែកណាមួយនៃតំបន់បាន ដោយឡែក ការដាក់ពាក្យស្នើសុំដោយអង្គភាពដទៃទៀតទាក់ទងនឹងតំបន់បម្រុងទុក ត្រូវស្ថិតក្រោមលក្ខខណ្ឌបន្ថែមដូចមានចែងក្នុងមាត្រា៩ នៃឧបសម្ព័ន្ធនេះ។

៣. ការស្វែងរុករកនិងការធ្វើអាជីវកម្ម អាចអនុវត្តបានតែនៅក្នុងតំបន់ដែលបានកំណត់ច្បាស់លាស់នៅក្នុងផែនការការងារ ដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា១៥៣ តែប៉ុណ្ណោះ និងត្រូវអនុម័តដោយអាជ្ញាធរស្របតាមខ្លឹមសារនៃអនុសញ្ញានេះ រួមទាំងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមានរបស់អាជ្ញាធរ។

៤. រាល់ផែនការការងារដែលបានអនុម័តត្រូវ៖

(ក) គោរពតាមខ្លឹមសារនៃអនុសញ្ញានេះ រួមទាំងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

(ខ) ផ្តល់សិទ្ធិឱ្យអាជ្ញាធរធ្វើការត្រួតពិនិត្យទៅលើសកម្មភាពនៅក្នុងតំបន់ ស្របតាមកថាខណ្ឌទី៤ នៃមាត្រា១៥៣។

(គ) ផ្តល់ឱ្យប្រតិបត្តិករនូវសិទ្ធិផ្តាច់មុខនៅក្នុងការស្វែងរុករកនិងធ្វើអាជីវកម្មប្រភេទធនធានដាក់លាក់នៅក្នុងតំបន់ដែលបានកំណត់ក្នុងផែនការការងារ ស្របតាមវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។ ទោះជាយ៉ាងនេះក្តី ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំដាក់សំណើសុំការអនុម័តផែនការការងារដែលគ្របដណ្តប់តែលើដំណាក់កាលនៃការស្វែងរុករក ឬធ្វើអាជីវកម្មនោះ ផែនការការងារដែលបានអនុម័តនឹងត្រូវទទួលបានសិទ្ធិផ្តាច់មុខសម្រាប់តែសកម្មភាពការងារដែលគ្របដណ្តប់នៅក្នុងដំណាក់កាលនោះប៉ុណ្ណោះ។

៥. នៅពេលដែលទទួលបានការអនុម័តពីអាជ្ញាធរ គ្រប់ផែនការការងារទាំងអស់ លើកលែងតែផែនការការងារទាំងឡាយដែលដាក់ដោយសហគ្រាស ត្រូវមានទម្រង់ជាកិច្ចសន្យាធ្វើឡើងរវាងរាជ្ញាធរ និងអ្នកដាក់ពាក្យស្នើសុំមួយ ឬច្រើន។

## មាត្រា៤
## លក្ខណសម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំ

១. អ្នកដាក់ពាក្យស្នើសុំដែលមិនមែនជាសហគ្រាស ត្រូវបានចាត់ទុកថាមានលក្ខណសម្បត្តិគ្រប់គ្រាន់ ប្រសិនបើគេមានសញ្ជាតិ ឬស្ថិតក្រោមការត្រួតពិនិត្យនិងការធានាតាមការតម្រូវក្រោមកថាខណ្ឌទី២(ខ) នៃមាត្រា១៥៣ និងប្រសិនបើគេអនុវត្តបានត្រឹមត្រូវតាមនីតិវិធី និងបំពេញតាមបទដ្ឋានកំណត់ពីលក្ខណសម្បត្តិដូចមានចែងនៅក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

២. លើកលែងតែមានចែងក្នុងកថាខណ្ឌទី៦ បទដ្ឋានកំណត់ពីលក្ខណសម្បត្តិនេះត្រូវមានទំនាក់ទំនងជាមួយនឹងសមត្ថភាពផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសរបស់អ្នកដាក់ពាក្យស្នើសុំ និងការអនុវត្តរបស់សាមីខ្លួន នៅក្នុងកិច្ចសន្យាមុនៗដែលធ្វើឡើងជាមួយអាជ្ញាធរ។

៣. អ្នកដាក់ពាក្យស្នើសុំត្រូវទទួលការធានាពីរដ្ឋភាគីរបស់ខ្លួន លើកលែងតែអ្នកដាក់ពាក្យស្នើសុំមានសញ្ជាតិលើសពីមួយ ដូចជានៅក្នុងករណីក្រុមហ៊ុនសហកម្មសិទ្ធិ ឬសម្ព័ន្ធអាជីវកម្មពីបណ្តារដ្ឋជាច្រើន ដែលក្នុងករណីនេះ គ្រប់រដ្ឋភាគីដែលពាក់ព័ន្ធត្រូវផ្តល់ការធានាលើពាក្យស្នើសុំ ឬលុះត្រាតែអ្នកដាក់ពាក្យស្នើសុំស្ថិតក្រោមអានុភាពគ្រប់គ្រងរបស់រដ្ឋភាគីមួយផ្សេងទៀត ឬពលរដ្ឋរបស់រដ្ឋនោះ ហើយក្នុងករណីនេះ រដ្ឋភាគីទាំងពីរត្រូវផ្តល់ការធានារួមគ្នាលើពាក្យស្នើសុំ។ លក្ខណវិនិច្ឆ័យនិងនីតិវិធីអនុវត្តលក្ខខណ្ឌនៃការធានា ត្រូវបានកំណត់នៅក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

៤. រដ្ឋមួយឬច្រើនដែលផ្តល់ការធានា ស្របតាមមាត្រា១៣៩ ត្រូវទទួលខុសត្រូវក្នុងការធានាក្រោមក្របខ័ណ្ឌប្រព័ន្ធច្បាប់របស់ខ្លួនថា អ្នកចុះកិច្ចសន្យាដែលមានការធានាត្រូវអនុវត្តសកម្មភាពនៅក្នុងតំបន់ ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា និងកាតព្វកិច្ចរបស់ខ្លួនដែលបានកំណត់ក្នុងអនុសញ្ញានេះ។ ទោះជាយ៉ាងនេះក្តី រដ្ឋដែលផ្តល់ការធានានឹងមិនទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយដែលបណ្តាលមកពីអ្នកចុះកិច្ចសន្យាដែលមានការធានាមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួននោះទេ ប្រសិនបើរដ្ឋភាគីនោះបានអនុម័តច្បាប់និងបទប្បញ្ញត្តិ ព្រមទាំងបានចាត់វិធានការផ្នែករដ្ឋបាលក្រោមក្របខ័ណ្ឌនៃប្រព័ន្ធច្បាប់របស់ខ្លួន ផ្តល់មូលហេតុសមស្របក្នុងការជំរុញការធានាលើការប្រតិបត្តិរបស់បុគ្គលដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន។

៥. នីតិវិធីក្នុងការកំណត់និងវាយតម្លៃលើលក្ខណសម្បត្តិរបស់រដ្ឋភាគីដែលជាអ្នកដាក់ពាក្យស្នើសុំត្រូវពិចារណាទៅលើចរិតលក្ខណៈជារដ្ឋ របស់រដ្ឋនោះ។

៦. បទដ្ឋានកំណត់ពីលក្ខណសម្បត្តិកំណត់ថា សម្រាប់ជាផ្នែកមួយនៃការដាក់ពាក្យស្នើសុំ អ្នកដាក់ពាក្យស្នើសុំទាំងអស់ដោយមិនលើកលែង ត្រូវសន្យាដូចខាងក្រោម៖

(ក) យល់ព្រមអនុវត្តនិងបំពេញតាមកាតព្វកិច្ចជាធរមាន ដូចមានចែងនៅក្នុងផ្នែកទី១១ វិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ សេចក្តីសម្រេចរបស់អង្គភាពនៃអាជ្ញាធរ ព្រមទាំងលក្ខខណ្ឌនៃកិច្ចសន្យាដែលបានធ្វើជាមួយអាជ្ញាធរ។

(ខ) យល់ព្រមឱ្យអាជ្ញាធរ ត្រួតពិនិត្យលើសកម្មភាពនៅក្នុងតំបន់ដែលបានអនុញ្ញាតក្រោមអនុសញ្ញានេះ។

(គ) ផ្តល់លិខិតធានាចំពោះអាជ្ញាធរថា ខ្លួននឹងបំពេញតាមកាតព្វកិច្ចក្រោមកិច្ចសន្យាដោយស្មោះត្រង់។

(ឃ) គោរពតាមបទប្បញ្ញត្តិស្តីពីការផ្ទេរបច្ចេកវិទ្យា ដូចមានចែងក្នុងមាត្រា៥ នៃឧបសម្ព័ន្ធនេះ។

## មាត្រា៥

## ការផ្ទេរបច្ចេកវិទ្យា

១. នៅពេលដាក់បញ្ជូនផែនការការងារ អ្នកដាក់ពាក្យស្នើសុំនីមួយៗត្រូវផ្តល់ដល់អាជ្ញាធរនូវសេចក្តីលម្អិតទូទៅអំពីសម្ភារគ្រឿងបរិក្ខារ និងវិធីសាស្ត្រប្រើប្រាស់ក្នុងការអនុវត្តសកម្មភាពនៅក្នុងតំបន់ ព្រមទាំងព័ត៌មានពាក់ព័ន្ធផ្សេងទៀតមិនស្ថិតក្រោមកម្មសិទ្ធិបញ្ញា ស្តីពីចរិតលក្ខណៈនៃបច្ចេកវិទ្យា និងព័ត៌មានអំពីប្រភពនៃបច្ចេកវិទ្យាទាំងនេះ។

២. ប្រតិបត្តិករទាំងអស់ត្រូវជូនដំណឹងដល់អាជ្ញាធរអំពីការកែប្រែណាមួយទៅលើសេចក្តីលម្អិត និងព័ត៌មានខាងលើដែលត្រូវផ្តល់ស្របតាមកថាខណ្ឌទី១ ក្នុងករណីដែលមានការកែប្រែគួរឱ្យកត់សម្គាល់ទៅលើបច្ចេកវិទ្យា ឬការបង្កើតបច្ចេកវិទ្យាថ្មីៗ។

៣. គ្រប់កិច្ចសន្យាស្តីពីការអនុវត្តសកម្មភាពនៅក្នុងតំបន់ ត្រូវមានការសន្យាដូចខាងក្រោមពីអ្នកចុះកិច្ចសន្យា៖

(ក) ត្រូវផ្តល់ដល់សហគ្រាសនូវលក្ខខណ្ឌផ្នែកពាណិជ្ជកម្មឱ្យបានត្រឹមត្រូវ និងសមស្រប តាមការស្នើឡើងរបស់អាជ្ញាធរ បច្ចេកវិទ្យាដែលប្រើប្រាស់ក្នុងការអនុវត្តសកម្មភាពនៅក្នុងតំបន់ក្រោមកិច្ចសន្យាដែលអ្នកចុះកិច្ចសន្យាមានសិទ្ធិស្របច្បាប់ក្នុងការផ្ទេរបន្ត។ ការផ្ទេរនេះត្រូវធ្វើឡើងតាមមធ្យោបាយផ្តល់អាជ្ញាបណ្ណ ឬមធ្យោបាយដទៃទៀតដែលសមស្រប ដែលអ្នកចុះកិច្ចសន្យាត្រូវមានការចរចាជាមួយសហគ្រាស ហើយដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀងបន្ថែមលើកិច្ចសន្យាជាធរមាន។ ការសន្យានេះអាចនឹងត្រូវធ្វើឡើងតែក្នុងករណីដែលសហគ្រាសយល់ថាមិនអាចស្វែងរកបច្ចេកវិទ្យាដូចគ្នានេះ ឬបច្ចេកវិទ្យាដែលមានប្រសិទ្ធភាព និងតម្លៃប្រើប្រាស់សមមូលនឹងបច្ចេកវិទ្យាទាំងនេះបាននៅលើទីផ្សារសេរីក្រោមលក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវនិងសមស្របប៉ុណ្ណោះ។

(ខ) ត្រូវទទួលបានការធានាជាលាយលក្ខណ៍អក្សរពីម្ចាស់កម្មសិទ្ធិនៃបច្ចេកវិទ្យាដែលបានប្រើប្រាស់សម្រាប់អនុវត្តសកម្មភាពនៅក្នុងតំបន់ក្រោមកិច្ចសន្យាដែលជាទូទៅមិនអាចស្វែងរកបាននៅលើទីផ្សារសេរី ហើយដែលមិនមានចែងនៅក្នុងកថាខណ្ឌរង(ក) ដែលម្ចាស់កម្មសិទ្ធិនឹងត្រូវផ្តល់បច្ចេកវិទ្យាទាំងនេះដល់សហគ្រាសដែលទទួលបានអាជ្ញាបណ្ណ ឬតាមរយៈមធ្យោបាយដទៃទៀតដែលសមស្របទៅតាមការស្នើសុំរបស់អាជ្ញាធរ និងស្ថិតក្រោមលក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវនិងសមស្រប នៅក្នុងលក្ខណៈដូចគ្នានឹងការផ្តល់ជូនដល់អ្នកចុះកិច្ចសន្យាដែរ។ ដោយឡែកកាលបើពុំទទួលបានការធានានេះទេ នោះអ្នកចុះកិច្ចសន្យាពុំមានសិទ្ធិប្រើប្រាស់បច្ចេកវិទ្យាទាំងនេះសម្រាប់អនុវត្តសកម្មភាពនៅក្នុងតំបន់បានឡើយ។

(គ) ត្រូវទទួលពីម្ចាស់កម្មសិទ្ធិតាមរយៈការអនុវត្តកិច្ចសន្យាជាធរមាន និងតាមការស្នើសុំពីសហគ្រាស និងបើសិនការធ្វើបែបនេះនាំទៅដល់ការបង្កើតបន្ទុកចំណាយដ៏ច្រើនសន្ធឹកសន្ធាប់ចំពោះអ្នកចុះកិច្ចសន្យានូវសិទ្ធិស្របច្បាប់ក្នុងការផ្ទេរទៅដល់សហគ្រាសនូវបច្ចេកវិទ្យាដែលអ្នកចុះកិច្ចសន្យាប្រើប្រាស់សម្រាប់អនុវត្តសកម្មភាពនៅក្នុងតំបន់ក្រោមកិច្ចសន្យា ដែលអ្នកចុះកិច្ចសន្យាពុំមានសិទ្ធិស្របច្បាប់ក្នុងការផ្ទេរបន្ត ហើយដែលជាទូទៅពុំអាចស្វែងរកបាននៅលើទីផ្សារសេរី។ ដោយឡែកក្នុងករណីដែលអ្នកចុះកិច្ចសន្យានិងម្ចាស់កម្មសិទ្ធិលើបច្ចេកវិទ្យាមានទំនាក់ទំនងផ្នែកពាណិជ្ជកម្មយ៉ាងមុតមាំ នោះកម្រិតនៃទំនាក់ទំនងនិងការត្រួតត្រា ឬឥទ្ធិពលរវាងគ្នា ត្រូវមានទំនាក់ទំនងជាមួយនឹងការកំណត់ថាតើរាល់វិធានការត្រូវបានធ្វើឡើងឱ្យអស់ពីលទ្ធភាព ដើម្បីទទួលបានសិទ្ធិខាងលើដែរឬយ៉ាងណា។ ក្នុងករណីដែលអ្នកចុះកិច្ចសន្យាមានអានុភាព ត្រួតត្រាលើម្ចាស់កម្មសិទ្ធិ នោះករណីដែលអ្នកចុះកិច្ចសន្យាមិនទទួលបានសិទ្ធិស្របច្បាប់ នឹងត្រូវធ្វើការពិចារណាដោយផ្អែកលើលក្ខណសម្បត្តិរបស់អ្នកចុះកិច្ចសន្យាផ្ទាល់ នៅក្នុងការបំពេញពាក្យស្នើសុំជាបន្តបន្ទាប់ ដើម្បីស្នើសុំការអនុម័តលើផែនការការងារក្រោយទៀត។

(ឃ) ត្រូវជួយសម្រួលតាមការស្នើសុំពីសហគ្រាស ដើម្បីឱ្យសហគ្រាសអាចមានលទ្ធភាពទទួលបានបច្ចេកវិទ្យាក្រោមអាជ្ញាបណ្ណ ដូចបានកំណត់ក្នុងកថាខណ្ឌរង(ខ) ឬតាមមធ្យោបាយដទៃទៀតដែលសមស្របនិងផ្អែកតាមលក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវនិងសមស្រប កាលបើសហគ្រាសធ្វើការសម្រេចក្នុងការចរចាដោយផ្ទាល់ជាមួយនឹងម្ចាស់កម្មសិទ្ធិលើបច្ចេកវិទ្យា។

(ង) ត្រូវចាត់វិធានការដូចដែលបានកំណត់ក្នុងកថាខណ្ឌរង (ក) (ខ) (គ) និង(ឃ) ដើម្បីជាប្រយោជន៍សម្រាប់រដ្ឋកំពុងអភិវឌ្ឍន៍ ឬបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ដែលបានដាក់ស្នើសុំកិច្ចសន្យាក្រោមមាត្រា៩នៃឧបសម្ព័ន្ធនេះ ក្នុងលក្ខខណ្ឌដែលវិធានការទាំងនេះមានវិសាលភាពគ្របដណ្តប់លើការធ្វើអាជីវកម្មលើផ្នែកណាមួយនៃតំបន់បម្រុងទុក ដែលស្នើឡើងដោយអ្នកចុះកិច្ចសន្យា ស្របតាមមាត្រា៨នៃឧបសម្ព័ន្ធនេះ និងប្រសិនបើសកម្មភាពក្រោមកិច្ចសន្យាដែលស្នើឡើងដោយ រដ្ឋកំពុងអភិវឌ្ឍន៍ណាមួយ ឬដោយបណ្តារដ្ឋកំពុងអភិវឌ្ឍន៍ មិនមានការពាក់ព័ន្ធនឹងការផ្ទេរបច្ចេកវិទ្យាទៅដល់រដ្ឋទីបី ឬពលរដ្ឋនៃរដ្ឋទីបីនោះ។ កាតព្វកិច្ចក្រោមបទប្បញ្ញត្តិនេះត្រូវអនុវត្តចំពោះអ្នកចុះកិច្ចសន្យា តែក្នុងករណីដែលបច្ចេកវិទ្យាពុំត្រូវបានស្នើសុំពីសហគ្រាស ឬបច្ចេកវិទ្យាមិនត្រូវបានផ្ទេរពីអ្នកចុះកិច្ចសន្យានោះទៅដល់សហគ្រាសប៉ុណ្ណោះ។

៤.	ដូចគ្នានឹងបទប្បញ្ញត្តិដទៃទៀតដែរ ក្នុងករណីដែលកើតមានវិវាទណាមួយទាក់ទងនឹងការសន្យាដែលតម្រូវឡើងក្នុងកថាខណ្ឌទី៣ នោះត្រូវធ្វើការដោះស្រាយស្របតាមខ្លឹមសារនៃផ្នែកទី១១ ហើយក្នុងករណីមានការបំពានលើការសន្យាទាំងនេះ នោះវាអាចនឹងនាំទៅដល់ការព្យួរ ឬការបញ្ចប់កិច្ចសន្យា ឬ ការផាកពិន័យជាប្រាក់ស្របតាមមាត្រា១៨ នៃឧបសម្ព័ន្ធនេះ។ ក្នុងករណីដែលមានវិវាទទៅលើការ កំណត់ថាតើការផ្តល់ជូនរបស់អ្នកចុះកិច្ចសន្យាធ្វើឡើងផ្អែកតាមលក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវនិងសមស្របយ៉ាងណានោះ ភាគីនីមួយៗអាចដាក់បញ្ជូនករណីវិវាទនោះដើម្បីធ្វើការដោះស្រាយជាស្ថាពរដោយមជ្ឈត្តិករផ្នែកពាណិជ្ជកម្ម ស្របតាមវិធានមជ្ឈត្តិការរបស់គណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកច្បាប់ពាណិជ្ជកម្ម UNCITRAL ឬវិធានមជ្ឈត្តការដទៃទៀតដែលអាចនឹងកំណត់នៅក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។ ប្រសិនបើការស្រាវជ្រាវរកឃើញថាការផ្តល់ជូនដែលស្នើឡើងដោយអ្នកចុះកិច្ចសន្យាមិនបានធ្វើឡើងត្រឹមត្រូវតាមលក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវនិងសមស្របទេនោះ អ្នកចុះកិច្ចសន្យាត្រូវបានផ្តល់រយៈពេល៤៥ថ្ងៃ ដើម្បីកែតម្រូវលើការផ្តល់ជូនដែលស្នើឡើងឱ្យល្អប្រសើរឡើងវិញនៅមុនពេលដែលអាជ្ញាធរចាត់វិធានការណាមួយ ស្របតាមមាត្រា១៨ នៃឧបសម្ព័ន្ធនេះ។

៥.	ប្រសិនបើសហគ្រាសពុំមានលទ្ធភាពទទួលបានផ្អែកតាមលក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវនិងសមស្របនូវបច្ចេកវិទ្យាដែលសមស្រប ដើម្បីអាចដំណើរការឱ្យទាន់ពេលវេលានូវការទាញយក និងការធ្វើប្រព្រឹត្តិកម្មរ៉ែពីក្នុងតំបន់ទេនោះ ក្រុមប្រឹក្សាឬអង្គសន្និបាតអាចកោះប្រជុំបណ្តារដ្ឋភាគីដែលមានសមាសភាពអ្នកដែលបានចូលរួមសកម្មភាពនៅក្នុងតំបន់ អ្នកដែលបានផ្តល់ការធានាចំពោះអង្គភាពដែលចូលរួមសកម្មភាពនៅក្នុងតំបន់ និងរដ្ឋភាគីដទៃទៀតដែលមានលទ្ធភាពអាចទទួលបានបច្ចេកវិទ្យាទាំងនេះ។ បណ្តារដ្ឋទាំងនេះត្រូវពិគ្រោះពិភាក្សាគ្នា និងត្រូវចាត់វិធានការដែលមានប្រសិទ្ធភាព ដើម្បីធានាថាបច្ចេកវិទ្យាទាំងនេះត្រូវបានផ្តល់ជូនដល់សហគ្រាសផ្អែកតាមលក្ខខណ្ឌផ្នែកពាណិជ្ជកម្មដែលត្រឹមត្រូវនិងសមស្រប។ បណ្តារដ្ឋនីមួយៗទាំងនេះត្រូវមានវិធានការគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាទាំងនេះ នៅក្នុងក្របខ័ណ្ឌច្បាប់របស់ខ្លួន។

៦.	ដោយឡែក ក្នុងករណីដែលមានកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មជាមួយសហគ្រាស ការផ្ទេរបច្ចេកវិទ្យានឹងត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការផ្នែកពាណិជ្ជកម្មដែលបានបង្កើតឡើង។

៧.	ការសន្យាដែលតម្រូវឡើងក្រោមកថាខណ្ឌទី៣ ត្រូវដាក់បញ្ចូលជាផ្នែកមួយនៅក្នុងកិច្ចសន្យានីមួយៗសម្រាប់អនុវត្តសកម្មភាពនៅក្នុងតំបន់ រហូតរយៈពេល១០ឆ្នាំ បន្ទាប់ពីការចាប់ផ្តើមដំណើរការផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្មរបស់សហគ្រាស និងអាចស្នើឡើងនៅក្នុងរយៈពេលនោះ។

៨.	សម្រាប់គោលបំណងនៃមាត្រានេះ ពាក្យ "បច្ចេកវិទ្យា" សំដៅដល់គ្រឿងបរិក្ខារឯកទេស និងចំណេះធ្វើផ្នែកបច្ចេកទេស រាប់បញ្ចូលទាំងសៀវភៅណែនាំបច្ចេកទេស គំនូសប្លង់ សេចក្តីណែនាំអំពីរបៀបប្រើប្រាស់ការបណ្តុះបណ្តាល ព្រមទាំងការណែនាំ និងជំនួយផ្នែកបច្ចេកទេស ដែលចាំបាច់សម្រាប់ការងារដំឡើង ថែទាំជួសជុល និងដំណើរការប្រព័ន្ធដោយចីរភាព និងសិទ្ធិស្របច្បាប់ក្នុងកាប្រើប្រាស់គ្រឿងបរិក្ខារទាំងនេះ សម្រាប់គោលបំណងប្រើប្រាស់មិនផ្តាច់មុខ។

## មាត្រា៦

## ការអនុម័តឯកភាពលើផែនការការងារ

១. ប្រាំមួយខែបន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន ហើយបន្ទាប់ពីនោះ នៅរៀងរាល់ខែទីបួន អាជ្ញាធរត្រូវចាប់ផ្តើមពិចារណាលើផែនការការងារដែលបានស្នើឡើង។

២. នៅពេលពិចារណាលើពាក្យស្នើសុំការអនុម័តលើផែនការការងារក្នុងទម្រង់ជាកិច្ចសន្យា ជាដំបូងបំផុតអាជ្ញាធរត្រូវពិនិត្យឱ្យច្បាស់ថាតើៈ

(ក) អ្នកដាក់ពាក្យស្នើសុំបានគោរពតាមនីតិវិធីដែលបានកំណត់ឡើងសម្រាប់ការដាក់ពាក្យស្នើសុំអនុលោមតាមមាត្រា៤ នៃឧបសម្ព័ន្ធនេះ និងបានធ្វើការធានាអះអាង ដែលកំណត់ដោយមាត្រានោះជូនដល់អាជ្ញាធរដែរឬទេ។ ក្នុងករណីមិនមានការគោរពអនុវត្តតាមនីតិវិធីទាំងនេះ ឬមិនមានរាល់ការធានាអះអាងទាំងនេះ នោះត្រូវទុកពេលឱ្យអ្នកដាក់ពាក្យស្នើសុំចំនួន៤៥ថ្ងៃ ដើម្បីដំណោះស្រាយកង្វះខាតទាំងនេះ។

(ខ) អ្នកដាក់ពាក្យស្នើសុំមានលក្ខណៈសម្បត្តិចាំបាច់គ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា៤ នៃឧបសម្ព័ន្ធនេះដែរឬទេ។

៣. ផែនការការងារដែលបានស្នើឡើងទាំងអស់ត្រូវបានពិចារណាទៅតាមលំដាប់លំដោយនៃការទទួលបាន។ ផែនការការងារដែលបានស្នើឡើងត្រូវមានលក្ខណៈស្របទៅតាម និងត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញានេះ ព្រមទាំងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ រាប់បញ្ចូលទាំងផ្នែកដែលចែងអំពីលក្ខខណ្ឌប្រតិបត្តិ ការចូលរួមចំណែកហិរញ្ញប្បទាន និងការធានាអះអាងដែលពាក់ព័ន្ធនឹងការផ្ទេរបច្ចេកវិទ្យា។ ប្រសិនបើផែនការការងារដែលបានស្នើឡើងមានលក្ខណៈស្របទៅតាមលក្ខខណ្ឌទាំងនេះ អាជ្ញាធរត្រូវផ្តល់ការអនុម័តលើផែនការទាំងនោះ ក្នុងលក្ខខណ្ឌថាផែនការទាំងនោះអនុលោមតាមលក្ខខណ្ឌដែលមានឯកភាព និងគ្មានការរើសអើងដែលបានកំណត់ក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ លើកលែងតែៈ

(ក) ផ្នែកណាមួយ ឬផ្នែកទាំងមូលនៃតំបន់ស្ថិតនៅក្រោមផែនការការងារដែលបានស្នើឡើងត្រូវបានបញ្ចូលក្នុងផែនការការងារដែលបានអនុម័ត ឬ ផែនការការងារដែលបានដាក់ជូនពីមុន ប៉ុន្តែនៅមិនទាន់បានពិចារណាជាស្ថាពរដោយអាជ្ញាធរ។

(ខ) ផ្នែកណាមួយ ឬផ្នែកទាំងមូលនៃតំបន់ស្ថិតនៅក្រោមផែនការការងារដែលបានស្នើឡើងត្រូវបានបដិសេធដោយអាជ្ញាធរ អនុលោមទៅតាមមាត្រា១៦២ នៃកថាខណ្ឌទី២(ម) ឬ

(គ) ផែនការការងារដែលបានស្នើឡើងត្រូវបានដាក់ជូន ឬធានាដោយរដ្ឋភាគីដែលមានក្នុងដៃរួចមកហើយនូវៈ

(i) ផែនការការងារក្នុងការស្វែងរុករក និងការធ្វើអាជីវកម្មដុំរ៉ែពហុលោហធាតុក្នុងតំបន់មិនបម្រុងទុក ដែលក្នុងនោះរួមជាមួយនឹងផ្នែកណាមួយនៃតំបន់ស្ថិតនៅក្រោមពាក្យស្នើសុំអនុម័តលើផែនការការងារ មានផ្ទៃក្រឡាលើសពី ៣០ ភាគរយ នៃផ្ទៃក្រឡារង្វង់៤០០ ០០០ គីឡូម៉ែត្រក្រឡា នៅជុំវិញផ្ចិតនៃផ្នែកណាមួយរបស់តំបន់ដែលស្ថិតនៅក្រោមផែនការការងារដែលបានស្នើឡើង។

(ii) ផែនការការងារក្នុងការស្វែងរុករក និងការធ្វើអាជីវកម្មជុំវិញពហុលោហធាតុក្នុងតំបន់មិនបម្រុងទុក ដែលបូករួមបញ្ចូលគ្នា ស្មើនឹង២ភាគរយនៃផ្ទៃក្រឡាបាតសមុទ្រសរុប ដែលមិនត្រូវបានបម្រុងទុក ឬបដិសេធសម្រាប់ការធ្វើអាជីវកម្ម អនុលោមទៅតាមមាត្រា១៦២ នៃកថាខណ្ឌទី២(ម)។

៤. ដើម្បីស្របតាមបទដ្ឋានដែលបានកំណត់ក្នុងកថាខណ្ឌទី៣(គ) ផែនការការងារដែលបានដាក់ជូនដោយក្រុមហ៊ុនសហកម្មសិទ្ធិឬសម្ព័ន្ធអាជីវកម្មត្រូវបានរាប់ផ្អែកតាមមូលដ្ឋានសមាមាត្រ ក្នុងចំណោមរដ្ឋភាគីជានាដែលពាក់ព័ន្ធ អនុលោមតាមកថាខណ្ឌទី៣ នៃមាត្រា៤ នៃឧបសម្ព័ន្ធនេះ។ អាជ្ញាធរអាចអនុម័តលើផែនការការងារដែលស្ថិតនៅក្រោមកថាខណ្ឌទី៣ (គ) ប្រសិនបើខ្លួនកំណត់ឃើញថា ការអនុម័តបែបនេះនឹងមិនអនុញ្ញាតឱ្យរដ្ឋភាគី ឬ អង្គភាពដែលខ្លួនជានាមានសិទ្ធិផ្តាច់មុខក្នុងការធ្វើសកម្មភាពនៅក្នុងតំបន់ ឬ ក្នុងការហាមឃាត់មិនឱ្យរដ្ឋភាគីផ្សេងទៀតធ្វើសកម្មភាពនៅក្នុងតំបន់នោះទេ។

៥. ទោះបីជាមានចែងដូចក្នុងកថាខណ្ឌទី៣(ក) ក៏ដោយ បន្ទាប់ពីបញ្ចប់រយៈពេលបណ្តោះអាសន្នដែលបានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា១៥១ ផ្អែកតាមវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធី អាជ្ញាធរអាចរៀបចំនីតិវិធី និងលក្ខណវិនិច្ឆ័យផ្សេងទៀត ស្របតាមអនុសញ្ញានេះ សម្រាប់ធ្វើសេចក្តីសម្រេចថាតើអ្នកដាក់ពាក្យស្នើសុំមួយណាត្រូវទទួលបានការអនុម័តលើផែនការការងារ ក្នុងករណីមានការជ្រើសរើសក្នុងចំណោមអ្នកដាក់ពាក្យស្នើសុំតំបន់ដែលបានស្នើឡើង។ នីតិវិធី និងលក្ខណវិនិច្ឆ័យទាំងនេះនឹងធានាបាននូវការទទួលបានការអនុម័តលើផែនការការងារ ផ្អែកលើមូលដ្ឋានសមធម៌និងមិនរើសអើង។

## មាត្រា៧
## ការជ្រើសរើសក្នុងចំណោមអ្នកដាក់ពាក្យស្នើសុំការអនុញ្ញាតផលិតកម្ម

១. រយៈពេលប្រាំមួយខែបន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន និងបន្ទាប់ពីនោះ នៅរៀងរាល់ខែទីបួន អាជ្ញាធរត្រូវចាប់ផ្តើមពិចារណាលើពាក្យស្នើសុំការអនុញ្ញាតផលិតកម្មដែលបានដាក់ជូនក្នុងរយៈពេលចុងក្រោយ។ អាជ្ញាធរត្រូវចេញជូននូវសេចក្តីអនុញ្ញាតតាមការដាក់ពាក្យស្នើសុំ ប្រសិនបើអាចអនុម័តលើពាក្យស្នើសុំទាំងនោះបាន ដោយមិនលើសពីដែនកំណត់ផលិតកម្ម ឬ បំពានលើកាតព្វកិច្ចរបស់អាជ្ញាធរ ក្រោមកិច្ចព្រមព្រៀង ឬកិច្ចសម្របសម្រួលស្តីពីទំនិញដែលមានខ្លួនជាភាគី ដូចមានចែងក្នុងមាត្រា១៥១។

២. នៅពេលដែលការជ្រើសរើសត្រូវធ្វើឡើងក្នុងចំណោមអ្នកដាក់ពាក្យស្នើសុំ ការអនុញ្ញាតផលិតកម្មដោយសារដែនកំណត់ផលិតកម្មដែលបានកំណត់ក្នុង កថាខណ្ឌទី២ដល់កថាខណ្ឌ៧ នៃមាត្រា១៥១ ឬដោយសារកាតព្វកិច្ចរបស់អាជ្ញាធរ ក្រោមកិច្ចព្រមព្រៀងឬកិច្ចសម្របសម្រួលស្តីពីទំនិញដែលមានខ្លួនជាភាគី ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា១៥១ នោះអាជ្ញាធរត្រូវធ្វើការជ្រើសរើសផ្អែកលើកម្មវត្ថុ និងបទដ្ឋានមិនរើសអើងដែលបានកំណត់ក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់ខ្លួន។

៣. ក្នុងការអនុវត្តកថាខណ្ឌទី២ អាជ្ញាធរត្រូវផ្តល់អាទិភាពដល់អ្នកដាក់ពាក្យស្នើសុំទាំងឡាយណាដែលៈ

(ក) ផ្ដល់ការធានាលើសមត្ថភាពអនុវត្តការងារល្អជាង ដោយពិចារណាទៅលើលិខិតបញ្ជាក់អំពីហិរញ្ញវត្ថុនិងបច្ចេកទេសរបស់ពួកគេ ព្រមទាំងសមត្ថភាពការងាររបស់ពួកគេ ប្រសិនបើមាន ក្រោមផែនការការងារដែលទទួលបានការអនុម័តមុនៗ។

(ខ) ផ្ដល់នូវអត្ថប្រយោជន៍ហិរញ្ញវត្ថុនាពេលអនាគតហ័សជាងគេដល់អាជ្ញាធរ ដោយពិចារណាថាតើផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្មត្រូវបានកំណត់ចាប់ផ្ដើមនៅពេលណា។

(គ) បានធ្វើការវិនិយោគរួចមកហើយនូវធនធាន និងកិច្ចប្រឹងប្រែងច្រើនបំផុតទៅលើការធ្វើបុរេសនាឬការស្វែងរុករក។

៤. អ្នកដាក់ពាក្យស្នើសុំដែលមិនត្រូវបានជ្រើសរើសក្នុងរយៈពេលណាមួយនោះ ត្រូវមានអាទិភាពនៅក្នុងរយៈពេលបន្តបន្ទាប់ទៀតរហូតដល់ពួកគេទទួលបានការអនុញ្ញាតផលិតកម្ម។

៥. ការជ្រើសរើសត្រូវធ្វើឡើងដោយពិចារណាទៅលើតម្រូវការក្នុងការពង្រឹងឱកាសសម្រាប់រដ្ឋភាគីទាំងអស់ក្នុងការចូលរួមសកម្មភាពក្នុងតំបន់ និងក្នុងការបង្ការឯកាធិកម្មលើសកម្មភាពទាំងនោះ ដោយមិនគិតអំពីប្រព័ន្ធសង្គម និងសេដ្ឋកិច្ច ឬទីតាំងភូមិសាស្ត្ររបស់ពួកគេនោះទេ ដើម្បីចៀសវាងការរើសអើងរដ្ឋ ឬប្រព័ន្ធណាមួយ។

៦. នៅពេលណាដែលមានតំបន់បម្រុងទុកតិចជាងតំបន់មិនបម្រុងទុកស្ថិតនៅក្រោមការធ្វើអាជីវកម្មនោះពាក្យស្នើសុំការអនុញ្ញាតផលិតកម្មទាក់ទងនឹងតំបន់បម្រុងទុកត្រូវមានអាទិភាព។

៧. សេចក្ដីសម្រេចដែលលើកឡើងក្នុងមាត្រានេះត្រូវធ្វើឡើងភ្លាមៗតាមដែលអាចធ្វើបាន បន្ទាប់ពីបិទរយៈពេលនីមួយៗ។

## មាត្រា៨
## ការបម្រុងទុកតំបន់

ពាក្យស្នើសុំតំបន់បម្រុងទុកនីមួយៗក្រៅពីពាក្យស្នើសុំដែលបានដាក់ជូនដោយសហគ្រាស ឬ ដោយអង្គភាពផ្សេងទៀត ត្រូវបង្ហាញអំពីផ្ទៃក្រឡាសរុបមិនចាំបាច់ត្រូវតែជាតំបន់ជាប់គ្នាមិនដាច់ ដែលមានទំហំធំគ្រប់គ្រាន់និងតម្លៃពាណិជ្ជកម្មតាមការប៉ាន់ប្រមាណគ្រប់គ្រាន់អាចមានប្រតិបត្តិការរ៉ែចំនួនពីរ។ អ្នកដាក់ពាក្យស្នើសុំត្រូវបង្ហាញនិយាមកា ដែលចែកតំបន់ជាចំនួនពីរផ្នែកមានតម្លៃពាណិជ្ជកម្មតាមការប៉ាន់ប្រមាណស្មើគ្នា និងដាក់ជូននូវទិន្នន័យទាំងអស់ដែលខ្លួនទទួលបានទាក់ទិននឹងផ្នែកទាំងពីរ។ ដោយមិនប៉ះពាល់ទៅដល់សិទ្ធិអំណាចរបស់អាជ្ញាធរអនុលោមទៅតាមមាត្រា១៧ នៃឧបសម្ព័ន្ធនេះ ទិន្នន័យដែលត្រូវដាក់ជូនស្ដីពីដុំរ៉ែពហុលោហធាតុត្រូវទាក់ទងទៅនឹងផែនទី សំណាកគំរូ ភាពសម្បូរនិងសមាសធាតុលោហធាតុរបស់វា។ ក្នុងរវាង៤៥ថ្ងៃ បន្ទាប់ពីទទួលបានទិន្នន័យបែបនេះ អាជ្ញាធរត្រូវកំណត់ថាតើផ្នែកមួយណាត្រូវបម្រុងទុកទាំងស្រុង សម្រាប់ការអនុវត្តសកម្មភាពរបស់អាជ្ញាធរតាមរយៈសហគ្រាស ឬក្រោមកិច្ចសហការជាមួយរដ្ឋកំពុងអភិវឌ្ឍន៍។ ការកំណត់នេះអាចពន្យារពេល៤៥ថ្ងៃ បន្ថែមទៀតប្រសិនបើអាជ្ញាធរស្នើសុំឱ្យអ្នកជំនាញឯករាជ្យវាយតម្លៃថាតើទិន្នន័យទាំងអស់ ដែលតម្រូវឱ្យមានក្រោមមាត្រានេះត្រូវបានដាក់ជូនសព្វគ្រប់ហើយឬនៅ។ តំបន់ដែលបានកំណត់ត្រូវក្លាយជាតំបន់បម្រុងទុកភ្លាមៗ នៅពេលដែលផែនការការងារសម្រាប់តំបន់មិនបម្រុងទុកត្រូវបានអនុម័ត ហើយកិច្ចសន្យាត្រូវបានចុះហត្ថលេខា។

## មាត្រា៩

## សកម្មភាពក្នុងតំបន់បម្រុងទុក

១. សហគ្រាសត្រូវទទួលបានឱកាសធ្វើការសម្រេចថាតើខ្លួនមានបំណងអនុវត្តសកម្មភាពក្នុងតំបន់បម្រុងទុកនីមួយៗឬទេ។ សេចក្តីសម្រេចនេះអាចធ្វើឡើងនៅពេលណាមួយក៏បាន លើកលែងតែអាជ្ញាធរទទួលបានការជូនដំណឹង អនុលោមទៅតាមកថាខណ្ឌទី៤ ដែលជាករណីសហគ្រាសត្រូវធ្វើការសម្រេចរបស់ខ្លួនក្នុងរវាងថិរវេលាសមហេតុផលមួយ។ សហគ្រាសអាចសម្រេចធ្វើអាជីវកម្មលើតំបន់បែបនេះ ក្នុងលក្ខណៈជាបុត្រសម្ព័ន្ធជាមួយនឹងរដ្ឋ ឬអង្គភាពដែលមានចំណាប់អារម្មណ៍។

២. សហគ្រាសអាចធ្វើកិច្ចសន្យាសម្រាប់ការអនុវត្តផ្នែកនៃសកម្មភាពរបស់ខ្លួន អនុលោមតាមមាត្រា១២ នៃឧបសម្ព័ន្ធទី៤។ សហគ្រាសក៏អាចចូលរួមជាបុត្រសម្ព័ន្ធ សម្រាប់ការអនុវត្តសកម្មភាពបែបនោះជាមួយនឹងអង្គភាពណាមួយដែលមានសិទ្ធិធ្វើសកម្មភាពនៅក្នុងតំបន់ អនុលោមទៅតាមកថាខណ្ឌទី២(ខ) នៃមាត្រា១៥៣ ផងដែរ។ នៅពេលពិចារណាលើបុត្រសម្ព័ន្ធបែបនេះ សហគ្រាសត្រូវផ្តល់ជូនរដ្ឋភាគីដែលជារដ្ឋកំពុងអភិវឌ្ឍន៍ និងប្រជាជាតិរបស់ពួកគេនូវឱកាសចូលរួមយ៉ាងមានប្រសិទ្ធភាព។

៣. អាជ្ញាធរអាចចែងក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និង នីតិវិធីរបស់ខ្លួនអំពីលក្ខខណ្ឌសារជាតុ និងនីតិវិធីទាក់ទងនឹងកិច្ចសន្យា និងបុត្រសម្ព័ន្ធទាំងនោះ។

៤. រដ្ឋភាគីណាមួយដែលជារដ្ឋកំពុងអភិវឌ្ឍន៍ ឬរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយដែលធានាដោយខ្លួន និងត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដោយខ្លួន ឬដោយរដ្ឋកំពុងអភិវឌ្ឍន៍ផ្សេងទៀតដែលជាអ្នកដាក់ពាក្យស្នើសុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬក្រុមណាមួយខាងលើ អាចជូនដំណឹងដល់អាជ្ញាធរថាខ្លួនមានបំណងដាក់ជូននូវផែនការការងារ អនុលោមទៅតាមមាត្រា៦ នៃឧបសម្ព័ន្ធនេះ ទាក់ទិននឹងតំបន់បម្រុងទុក។ ផែនការការងារត្រូវបានពិចារណា ប្រសិនបើសហគ្រាសសម្រេច អនុលោមទៅតាមកថាខណ្ឌទី១ ថាខ្លួនមិនមានបំណងអនុវត្តសកម្មភាពក្នុងតំបន់នោះ។

## មាត្រា១០

## បុរេមានិងអាទិភាពក្នុងចំណោមអ្នកដាក់ពាក្យស្នើសុំ

ប្រតិបត្តិករដែលទទួលបានការអនុម័តលើផែនការការងារសម្រាប់តែការស្វែងរុករកតែម្យ៉ាង ដូចមានចែងក្នុងកថាខណ្ឌទី៤(គ) នៃមាត្រា៣ នៃឧបសម្ព័ន្ធនេះ ត្រូវមានបុរេមា និងអាទិភាពក្នុងចំណោមអ្នកដាក់ពាក្យស្នើសុំសម្រាប់ផែនការការងារដែលគ្របដណ្តប់លើការធ្វើអាជីវកម្មលើតំបន់ និងធនធានដដែល។ ទោះបីជាយ៉ាងណា បុរេមា និងអាទិភាពបែបនេះអាចត្រូវបានដកហូតវិញ ប្រសិនបើសមត្ថភាពការងារប្រតិបត្តិករមិនអាចទទួលយកបាន។

## មាត្រា១១

## ការរៀបចំរួមគ្នា

១. កិច្ចសន្យាអាចផ្តល់នូវការរៀបចំរួមគ្នារវាងអ្នកចុះកិច្ចសន្យា និងអាជ្ញាធរតាមរយៈសហគ្រាស ក្នុងទម្រង់ជាបុត្រសម្ព័ន្ធ ឬការបែងចែកផល ក៏ដូចជាទម្រង់ផ្សេងទៀតនៃការរៀបចំរួមគ្នា ដែលត្រូវមានការការពារដូចគ្នាទល់នឹងការកែសម្រួល ការផ្អាក ឬការបញ្ចប់កិច្ចសន្យាជាមួយនឹងអាជ្ញាធរ។

២. អ្នកចុះកិច្ចសន្យាដែលធ្វើការរៀបចំរួមគ្នាបែបនេះជាមួយនឹងសហគ្រាសអាចទទួលបាននូវរង្វាន់លើកទឹកចិត្តហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រា១៣ នៃឧបសម្ព័ន្ធនេះ។

៣. ដៃគូក្នុងបុត្រសម្ព័ន្ធជាមួយនឹងសហគ្រាសត្រូវទទួលខុសត្រូវលើប្រាក់ទូទាត់ដែលតម្រូវឱ្យមានក្រោមមាត្រា១៣ នៃឧបសម្ព័ន្ធនេះ ក្នុងទំហំមួយទៅតាមភាគហ៊ុនរបស់ខ្លួនក្នុងបុត្រសម្ព័ន្ធនោះ អនុលោមទៅតាមរង្វាន់លើកទឹកចិត្តហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រានោះ។

## មាត្រា១២

## សកម្មភាពដែលអនុវត្តដោយសហគ្រាស

១. សកម្មភាពនៅក្នុងតំបន់ដែលអនុវត្តដោយសហគ្រាស អនុលោមទៅតាម កថាខណ្ឌទី២(ក) នៃមាត្រា១៥៣ ត្រូវគ្រប់គ្រងដោយផ្នែកទី១១ វិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ និងសេចក្តីសម្រេចពាក់ព័ន្ធរបស់អាជ្ញាធរ។

២. រាល់ផែនការការងារដែលបានដាក់ជូនដោយសហគ្រាសត្រូវអមដោយភស្តុតាងដែលបញ្ជាក់អំពីសមត្ថភាពហិរញ្ញវត្ថុនិងបច្ចេកទេសរបស់ខ្លួន។

## មាត្រា១៣

## លក្ខខណ្ឌហិរញ្ញវត្ថុនៃកិច្ចសន្យា

១. ក្នុងការរៀបចំវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីដែលពាក់ព័ន្ធនឹងលក្ខខណ្ឌហិរញ្ញវត្ថុនៃកិច្ចសន្យារវាងអាជ្ញាធរ និងអង្គភាពដែលមានលើកឡើងក្នុងកថាខណ្ឌទី២(ខ) នៃមាត្រា១៥៣ និងក្នុងការចរចាអំពីលក្ខខណ្ឌហិរញ្ញវត្ថុទាំងនោះ អនុលោមតាមផ្នែកទី១១ និងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីទាំងនោះ អាជ្ញាធរត្រូវគោរពតាមកម្មវត្ថុខាងក្រោម៖

(ក) ធានាបាននូវប្រាក់ចំណូលខ្ពស់បំផុតសម្រាប់អាជ្ញាធរចេញពីប្រាក់ចំណូលបានពីផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម។

(ខ) ទាក់ទាញការវិនិយោគ និងបច្ចេកវិទ្យាសម្រាប់ការស្វែងរុករក និងការធ្វើអាជីវកម្មលើតំបន់

(គ) ធានាបាននូវសមភាពនៃការកំណត់ហិរញ្ញវត្ថុនិងកាតព្វកិច្ចហិរញ្ញវត្ថុសមស្រប សម្រាប់អ្នកចុះកិច្ចសន្យា។

(ឃ) ផ្តល់នូវរង្វាន់លើកទឹកចិត្តផ្អែកលើមូលដ្ឋានដែលមានការឯកភាពនិងមិនរើសអើង សម្រាប់អ្នកចុះកិច្ចសន្យាអនុវត្តការសម្រុះសម្រួលរួមគ្នាជាមួយនឹងសហគ្រាស និងរដ្ឋកំពុងអភិវឌ្ឍន៍ ឬប្រជាជាតិរបស់ពួកគេ ដើម្បីជំរុញដល់ការផ្ទេរបច្ចេកវិទ្យា និងការបណ្តុះបណ្តាលបុគ្គលិករបស់អាជ្ញាធរ និងរបស់រដ្ឋកំពុងអភិវឌ្ឍន៍។

(ង) ជួយឱ្យសហគ្រាសអាចចូលរួមក្នុងអាជីវកម្មរ៉ែបាតសមុទ្រប្រកបដោយប្រសិទ្ធភាព ក្នុងពេលតែមួយជាមួយនឹងអង្គភាព ដែលមានលើកឡើងក្នុងកថាខណ្ឌទី២(ខ) នៃមាត្រា១៥៣ និង

(ច) ធានាថា ដោយសាររង្វាន់លើកទឹកចិត្តហិរញ្ញប្បទានដែលបានផ្តល់ជូនដល់អ្នកចុះកិច្ចសន្យាក្រោមកថាខណ្ឌទី១៤ ក្រោមលក្ខខណ្ឌកិច្ចសន្យាដែលបានពិនិត្យអនុលោមតាមមាត្រា១៩ នៃឧបសម្ព័ន្ធនេះ ឬក្រោមបទប្បញ្ញត្តិនៃមាត្រា១១ នៃឧបសម្ព័ន្ធនេះ ទាក់ទិននឹងបុត្រសម្ព័ន្ធ អ្នកចុះកិច្ចសន្យាមិនត្រូវបានទទួលការឧបត្ថម្ភ ដើម្បីទទួលបានអត្ថប្រយោជន៍ដែលអាចប្រកួតប្រជែងជាមួយនឹងអ្នកស្វែងរុករករ៉ែដីគោកទេ។

២. ថ្លៃសេវាកម្មនឹងត្រូវបានគិតសម្រាប់ចំណាយរដ្ឋបាលសម្រាប់ការដំណើរការដាក់ពាក្យស្នើសុំការអនុម័តលើផែនការការងារ ក្នុងទម្រង់ជាកិច្ចសន្យា ហើយត្រូវបានកំណត់យកក្នុងចំនួន៥០០ ០០០ ដុល្លារអាម៉េរិកក្នុងពាក្យស្នើសុំមួយ។ តម្លៃនេះនឹងត្រូវពិនិត្យឡើងវិញពីពេលមួយទៅពេលមួយដោយក្រុមប្រឹក្សា ដើម្បីធានាបានថាវាគ្របដណ្តប់លើចំណាយរដ្ឋបាលដែលបានកើតមាន។ ប្រសិនបើចំណាយរដ្ឋបាលបែបនេះដែលកើតមានឡើងដោយសារអាជ្ញាធរនៅក្នុងការដំណើរការដាក់ពាក្យស្នើសុំមានចំនួនតិចជាងចំនួនទឹកប្រាក់ដែលបានកំណត់ នោះអាជ្ញាធរត្រូវផ្ទេរទឹកប្រាក់ដែលនៅសល់ជូនអ្នកដាក់ពាក្យស្នើសុំវិញ។

៣. អ្នកចុះកិច្ចសន្យាត្រូវបង់កម្រៃសេវាកម្មប្រចាំឆ្នាំដែលបានកំណត់ចំនួន១ លានដុល្លារអាម៉េរិក បន្ទាប់ពីកាលបរិច្ឆេទដែលកិច្ចសន្យាចូលជាធរមាន។ ប្រសិនបើកាលបរិច្ឆេទចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្មដែលបានអនុម័ត ត្រូវបានអូសបន្លាយដោយសារការយឺតយ៉ាវក្នុងការចេញនូវការអនុញ្ញាតផលិតកម្ម អនុលោមតាមមាត្រា១៥១ កម្រៃសេវាកម្មប្រចាំឆ្នាំដែលបានកំណត់ត្រូវបោះបង់ចោលសម្រាប់រយៈពេលដែលបានអូសបន្លាយ។ បន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម អ្នកចុះកិច្ចសន្យាត្រូវបង់កម្រៃផលិតកម្ម ឬកម្រៃសេវាកម្មប្រចាំឆ្នាំដែលបានកំណត់ តាមចំនួនមួយណាដែលច្រើនជាង។

៤. ក្នុងរវាងមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម អនុលោមទៅតាមកថាខណ្ឌទី៣ អ្នកចុះកិច្ចសន្យាត្រូវជ្រើសរើសធ្វើការចូលរួមចំណែកហិរញ្ញប្បទានរបស់ខ្លួនជូនដល់អាជ្ញាធរតាមរយៈ៖

(ក) បង់តែកម្រៃផលិតកម្មប៉ុណ្ណោះ ឬ

(ខ) បង់បន្សំរួមបញ្ចូលគ្នារវាងកម្រៃផលិតកម្ម និងចំណែកក្នុងចំណូលសុទ្ធ។

៥. (ក) ប្រសិនបើអ្នកចុះកិច្ចសន្យាជ្រើសរើសធ្វើការចូលរួមចំណែកហិរញ្ញប្បទានរបស់ខ្លួនជូនអាជ្ញាធរតាមរយៈការបង់តែកម្រៃផលិតកម្មប៉ុណ្ណោះនោះ វាត្រូវកំណត់តាមភាគរយនៃតម្លៃទីផ្សាររបស់លោហធាតុដែលបានធ្វើប្រព្រឹត្តិកម្មដែលបានផលិតពីដុំរ៉ែពហុលោហធាតុដែលទាញយកពីតំបន់ដែលស្ថិតនៅក្រោមកិច្ចសន្យា។ ភាគរយនេះត្រូវកំណត់ដូចតទៅ៖

(i) ឆ្នាំទី១-១០ នៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ៥ភាគរយ

(ii) ឆ្នាំទី១១ រហូតដល់ចុងរយៈពេលផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ១២ភាគរយ

(ខ) តម្លៃទីផ្សារខាងលើគឺជាផលិតផលនៃបរិមាណលោហធាតុដែលបានធ្វើប្រព្រឹត្តិកម្មដែលបានផលិតចេញពីដុំរ៉ែពហុលោហធាតុទាញយកពីតំបន់ស្ថិតនៅក្រោមកិច្ចសន្យា និងតម្លៃមធ្យមសម្រាប់លោហធាតុទាំងនោះក្នុងឆ្នាំសារពើពន្ធពាក់ព័ន្ធ ដូចបានកំណត់ក្នុងកថាខណ្ឌទី៧ និងកថាខណ្ឌទី៨។

៦. ប្រសិនបើអ្នកចុះកិច្ចសន្យាជ្រើសរើសធ្វើការចូលរួមចំណែកហិរញ្ញប្បទានរបស់ខ្លួនជូនដល់អាជ្ញាធរតាមរយៈការបង់រួមបញ្ចូលគ្នារវាងកម្រៃផលិតកម្ម និងចំណែកក្នុងចំណូលសុទ្ធ នោះការទូទាត់ត្រូវកំណត់ដូចតទៅ៖

(ក) កម្រៃផលិតកម្ម ត្រូវកំណត់ជាភាគរយនៃតម្លៃទីផ្សារ ដែលបានកំណត់អនុលោមតាមកថាខណ្ឌរង (ខ) របស់លោហធាតុដែលបានធ្វើប្រព្រឹត្តិកម្មដែលបានផលិតចេញពីដុំរ៉ែពហុលោហធាតុទាញយកពីតំបន់ស្ថិតនៅក្រោមកិច្ចសន្យា។ ភាគរយនេះត្រូវកំណត់ដូចតទៅ៖

(i) រយៈពេលទីមួយនៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ២ភាគរយ

(ii) រយៈពេលទីពីរនៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ៤ភាគរយ

ប្រសិនបើក្នុងរយៈពេលទីពីរនៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ដូចបានកំណត់ក្នុងកថាខណ្ឌរង (ឃ) ផលពីការវិនិយោគក្នុងឆ្នាំសារពើពន្ធណាមួយ ដូចបានកំណត់ក្នុងកថាខណ្ឌរង (ឋ) ធ្លាក់ក្រោម ១៥ភាគរយ ដោយសារការទូទាត់កម្រៃផលិតកម្ម ៤ភាគរយ នោះកម្រៃផលិតកម្មត្រូវគិត ២ភាគរយ ជំនួសឱ្យ ៤ភាគរយ ក្នុងឆ្នាំសារពើពន្ធនោះ។

(ខ) តម្លៃទីផ្សារខាងលើគឺជាផលិតផលនៃបរិមាណលោហធាតុដែលបានធ្វើប្រព្រឹត្តិកម្មផលិតចេញពីដុំរ៉ែពហុលោហធាតុទាញចេញពីតំបន់ស្ថិតនៅក្រោមកិច្ចសន្យា និងតម្លៃមធ្យមសម្រាប់លោហធាតុទាំងនោះក្នុងឆ្នាំសារពើពន្ធពាក់ព័ន្ធ ដូចបានកំណត់ក្នុងកថាខណ្ឌទី៧និងកថាខណ្ឌទី៨។

(គ) (i) ចំណែកនៃចំណូលសុទ្ធរបស់អាជ្ញាធរត្រូវបានកាត់ចេញពីចំណែកនៃចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យា ដែលទទួលបានពីការធ្វើអាជីវកម្មធនធានរ៉ែនៃតំបន់ស្ថិតនៅក្រោមកិច្ចសន្យា តទៅហៅថា ចំណូលសុទ្ធដែលសម្រេចបាន។

(ii) ចំណែកនៃចំណូលសុទ្ធដែលសម្រេចបានរបស់អាជ្ញាធរត្រូវបានកំណត់ អនុលោមតាមកាលវិភាគបន្ថែមខាងក្រោម៖

| ចំណែកនៃចំណូលសុទ្ធដែលសម្រេចបាន | ភាគហ៊ុនរបស់អាជ្ញាធរ | |
|---|---|---|
| | រយៈពេលទីមួយនៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម | រយៈពេលទីពីរនៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម |
| ចំណែកដែលតំណាងឱ្យផលពីការវិនិយោគដែលមានភាគរយច្រើនជាង ០ភាគរយ ប៉ុន្តែតិចជាង ១០ភាគរយ | ៣៥ភាគរយ | ៤០ភាគរយ |
| ចំណែកដែលតំណាងឱ្យផលពីការវិនិយោគ ១០ភាគរយ ឬ ច្រើនជាង ប៉ុន្តែតិចជាង២០ ភាគរយ | ៤២.៥ភាគរយ | ៥០ភាគរយ |
| ចំណែកដែលតំណាងឱ្យផលពីការវិនិយោគដែលស្មើនឹង ២០ភាគរយ ឬ ច្រើនជាង | ៥០ ភាគយ | ៧០ ភាគរយ |

(ឃ) (i) រយៈពេលទីមួយនៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ដែលមានលើកឡើងក្នុងកថាខណ្ឌរង (ក) និង (គ) ត្រូវចាប់ផ្តើមក្នុងឆ្នាំសារពើពន្ធទីមួយនៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម និងបញ្ចប់ក្នុងឆ្នាំសារពើពន្ធដែលក្នុងនោះ ចំណាយលើការអភិវឌ្ឍជាមួយនឹងការប្រាក់របស់អ្នកចុះកិច្ចសន្យាលើចំណែកដែលមិនអាចកាត់កងមកវិញត្រូវបានកាត់កងយ៉ាងពេញលេញដោយប្រើអតិរេកសាច់ប្រាក់ផ្ទាល់របស់ខ្លួនដូចតទៅ៖

ក្នុងឆ្នាំសារពើពន្ធទីមួយដែលបានកើតមាននូវចំណាយលើការអភិវឌ្ឍ ចំណាយលើការអភិវឌ្ឍដែលមិនអាចកាត់កងមកវិញ ត្រូវស្មើគ្នានឹងចំណាយលើការអភិវឌ្ឍដកអតិរេកសាច់ប្រាក់ក្នុងឆ្នាំនោះ។ ក្នុងឆ្នាំសារពើពន្ធបន្តបន្ទាប់ទៀតនីមួយៗ ចំណាយលើការអភិវឌ្ឍដែលមិនអាចកាត់កងមកវិញត្រូវស្មើគ្នានឹងចំណាយលើការអភិវឌ្ឍដែលមិនបានកាត់កងមកវិញនៅចុងឆ្នាំសារពើពន្ធចុងក្រោយបូករួមជាមួយការប្រាក់របស់វាក្នុងអត្រា ១០ភាគរយ ក្នុងមួយឆ្នាំ បូករួមជាមួយចំណាយលើការអភិវឌ្ឍដែលបានកើតមានក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន រួចដកអតិរេកសាច់ប្រាក់របស់អ្នកចុះកិច្ចសន្យាក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន។ ឆ្នាំសារពើពន្ធដែលក្នុងនោះ ចំណាយលើការអភិវឌ្ឍដែលមិនអាចកាត់កងមកវិញមានលទ្ធផលស្មើសូន្យជាលើកដំបូងត្រូវជាឆ្នាំសារពើពន្ធដែលក្នុងនោះ ចំណាយលើការអភិវឌ្ឍ របស់អ្នកចុះកិច្ចសន្យាជាមួយនឹងការប្រាក់របស់វាលើចំណែកដែលមិនអាចកាត់កងមកវិញបាននោះត្រូវបានកាត់កងគ្នាអស់ទាំងស្រុងជាមួយនឹងអតិរេកសាច់ប្រាក់របស់ខ្លួន។ អតិរេកសាច់ប្រាក់របស់អ្នកចុះកិច្ចសន្យាក្នុងឆ្នាំសារពើពន្ធណាមួយត្រូវជាប្រាក់ចំណូលដុលរបស់ខ្លួនដកចំណាយប្រតិបត្តិការរបស់ខ្លួន និងដកប្រាក់ដែលខ្លួនបង់ជូនអាជ្ញាធរក្រោមកថាខណ្ឌរង(គ) ចេញ។

(ii) រយៈពេលទីពីរនៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ត្រូវចាប់ផ្តើមក្នុងឆ្នាំសារពើពន្ធ បន្ទាប់ពីបញ្ចប់រយៈពេលទីមួយនៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម និងត្រូវបន្តរហូតដល់បញ្ចប់កិច្ចសន្យា។

(ង) "ចំណូលសុទ្ធដែលសម្រេចបាន " មានន័យថាជា លទ្ធផលនៃចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យា និងអនុបាតនៃចំណាយលើការអភិវឌ្ឍក្នុងវិស័យរ៉ែទៅនឹងចំណាយលើការអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យា។ ប្រសិនបើអ្នកចុះកិច្ចសន្យាចូលរួមក្នុងការធ្វើអាជីវកម្មរ៉ែ ដឹកជញ្ជូនដុំរ៉ែពហុលោហធាតុ និងផលិតកម្មជាចម្បងនូវលោហធាតុដែលបានធ្វើប្រព្រឹត្តិកម្មចំនួនបីគឺ កូបាល់ ទង់ដែង និងនីកែល នោះចំនួនចំណូលសុទ្ធដែលសម្រេចបានមិនត្រូវតិចជាង ២៥ភាគរយនៃចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យាឡើយ។ អនុលោមទៅតាមកថាខណ្ឌរង (ឈ) ក្នុងករណីផ្សេងទៀតទាំងអស់ រាប់បញ្ចូលទាំងករណីដែលអ្នកចុះកិច្ចសន្យាចូលរួមក្នុងការធ្វើអាជីវកម្មរ៉ែ ដឹកជញ្ជូនដុំរ៉ែពហុលោហធាតុ និងផលិតកម្មជាចម្បងនូវលោហធាតុដែលបានធ្វើប្រព្រឹត្តិកម្មចំនួនបួន គឺកូបាល់ ទង់ដែង ម៉ង់កាណែស និងនីកែល នោះនៅក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់ខ្លួន អាជ្ញាធរអាចចែងអំពីកម្រិតទាបបំផុតសមស្របដែលត្រូវមានទំនាក់ទំនងដូចគ្នាជាមួយនឹងករណីនីមួយៗដែលមានកម្រិតទាបបំផុត ២៥ភាគរយមានចំពោះករណីលោហធាតុចំនួនបីដូច្នេះដែរ។

(ច) "ចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យា"មានន័យថាជា ប្រាក់ចំណូលដុលរបស់អ្នកចុះកិច្ចសន្យា ដកចំណាយប្រតិបត្តិការរបស់ខ្លួន រួចដកប្រាក់ទូទាត់របស់ខ្លួនលើចំណាយលើការអភិវឌ្ឍដូចបានកំណត់ក្នុងកថាខណ្ឌរង (៣)។

(ឆ) (i) ប្រសិនបើអ្នកចុះកិច្ចសន្យាចូលរួមក្នុងការធ្វើអាជីវកម្មរ៉ែ ការដឹកជញ្ជូនដុំរ៉ែពហុលោហធាតុ និងផលិតកម្មលោហធាតុដែលបានធ្វើប្រព្រឹត្តិកម្ម នោះ"ប្រាក់ចំណូលដុលរបស់អ្នកចុះកិច្ចសន្យា" មានន័យថាជាចំណូលដុលទទួលបានពីការលក់លោហធាតុដែលបានធ្វើប្រព្រឹត្តិកម្ម និងប្រាក់ផ្សេងទៀតដែលចាត់ទុកយ៉ាងសមហេតុផលទទួលបានពីប្រតិបត្តិការក្រោមកិច្ចសន្យា អនុលោមតាមវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ។

(ii) ក្នុងគ្រប់ករណីទាំងអស់ក្រៅពីករណីដែលបានចែងក្នុងកថាខណ្ឌរង (ឆ)(i) និង (ឈ)

(iii) "ប្រាក់ចំណូលដុលរបស់អ្នកចុះកិច្ចសន្យា" មានន័យថាជា ចំណូលដុលបានមកពីការលក់លោហធាតុពាក់កណ្តាលប្រព្រឹត្តិកម្មពីដុំរ៉ែពហុលោហធាតុដែលទាញចេញពីតំបន់ស្ថិតនៅក្រោមកិច្ចសន្យា និងប្រាក់ផ្សេងទៀតដែលចាត់ទុកយ៉ាងសមហេតុផលទទួលបានពីប្រតិបត្តិការក្រោមកិច្ចសន្យា អនុលោមតាមវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ។

(ជ) "ចំណាយលើការអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យា"មានន័យថា៖

(i) ចំណាយទាំងអស់កើតឡើងមុនការចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ដែលពាក់ព័ន្ធផ្ទាល់ទៅការអភិវឌ្ឍសមត្ថភាពផលិតកម្មលើតំបន់ដែលស្ថិតនៅក្រោមកិច្ចសន្យា និងសកម្មភាពពាក់ព័ន្ធដូចគ្នានេះសម្រាប់ប្រតិបត្តិការក្រោមកិច្ចសន្យានៅក្នុងគ្រប់ករណីទាំងអស់ លើកលែងតែករណីដែលមានកំណត់ក្នុងកថាខណ្ឌរង (ឈ) ស្របតាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅរួមមាន ចំណាយ គ្រឿងចក្រ គ្រឿងបរិក្ខារ នាវា រោងចក្រប្រព្រឹត្តិកម្ម សំណង់ អគារ ដី ផ្លូវ ការធ្វើបុរេសនានិងការស្វែងរុករកលើតំបន់ដែលស្ថិតនៅក្រោមកិច្ចសន្យា ការស្រាវជ្រាវនិងអភិវឌ្ឍ ផលប្រយោជន៍ ភតិសន្យាដែលតម្រូវ អាជ្ញាបណ្ណនិងកម្រៃ និង

(ii) ការចំណាយប្រហាក់ប្រហែលនឹងអ្វីដែលបានចែងក្នុង (i) ខាងលើ ដែលបានកើតឡើងបន្ទាប់ពីការចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ហើយចាំបាច់ដើម្បីអនុវត្តផែនការការងារ លើកលែងតែការចំណាយដែលអាចរាប់បញ្ចូលក្នុងចំណាយប្រតិបត្តិការ។

(ឈ) ប្រាក់ចំណូលពីការលក់ទ្រព្យមូលធន និងតម្លៃទីផ្សារនៃទ្រព្យមូលធនទាំងនោះ ដែលលែងមានតម្រូវការសម្រាប់ប្រតិបត្តិការក្រោមកិច្ចសន្យានិងដែលមិនត្រូវបានលក់ ត្រូវកាត់ចេញពីចំណាយលើការអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យាក្នុងអំឡុងពេលនៃឆ្នាំសារពើពន្ធដែលពាក់ព័ន្ធ។ នៅពេលការកាត់ចេញទាំងនេះលើសចំណាយលើការអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យា ការកាត់ចេញដែលលើសត្រូវបន្ថែមទៅប្រាក់ចំណូលដុលរបស់អ្នកចុះកិច្ចសន្យា។

(ញ) ចំណាយលើការអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យាដែលកើតឡើងមុនពេលចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្មដូចមានចែងក្នុងកថាខណ្ឌ (ជ) (ឈ) និង (ឍ)(៤) នឹងត្រូវប្រមូលវិញជា ១០ ដំណាក់កាលប្រចាំឆ្នាំដែលមានចំនួនប្រាក់ស្មើៗគ្នា គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម។ ចំណាយលើការអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យា ដែលកើតឡើងក្រោយពេលចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ដូចចែងក្នុងកថាខណ្ឌ (ជ)(២) និង (ឍ)(៤) ត្រូវប្រមូលវិញជា ១០ ដំណាក់កាលប្រចាំឆ្នាំ ឬតិចជាង ១០ ដំណាក់កាលដែលមានចំនួនប្រាក់ស្មើគ្នា ដើម្បីធានាការទទួលបានមកវិញគ្រប់ចំនួន នៅមុនពេលបញ្ចប់នៃកិច្ចសន្យា។

(ដ) "ចំណាយប្រតិបត្តិការរបស់អ្នកចុះកិច្ចសន្យា" មានន័យថា រាល់ការចំណាយទាំងអស់ដែលកើតឡើងក្រោយការចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ក្នុងប្រតិបត្តិការផលិតកម្មនៅតំបន់ក្រោមកិច្ចសន្យា និង សកម្មភាពពាក់ព័ន្ធប្រតិបត្តិការក្នុងកិច្ចសន្យា អនុលោមតាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅដែល រួមមានដូចជាកម្រៃសេវាកម្មប្រចាំឆ្នាំ ឬកម្រៃផលិតកម្ម ដោយជ្រើសរើសយកជម្រើសណាមួយ ដែលច្រើនជាង ការចំណាយលើប្រាក់ឈ្នួល ប្រាក់បៀវត្ស អត្ថប្រយោជន៍និយោជិត សម្ភារៈសេវាកម្ម ថ្លៃដឹកជញ្ជូន ចំណាយប្រព្រឹត្តិកម្មនិងផ្សព្វផ្សាយទីផ្សារ ការប្រាក់ ឧបករណ៍និងសេវាផ្គត់ផ្គង់ ការរក្សាបរិស្ថានសមុទ្រ កម្រៃរដ្ឋបាល និងដំណើរការដែលទាក់ទងជាក់លាក់នឹងប្រតិបត្តិការក្រោមកិច្ចសន្យា ព្រមទាំងការខាតបង់សុទ្ធណាមួយខាងប្រតិបត្តិការដែលទូទាត់ក្នុងបញ្ជីគណនីឆ្នាំបន្ទាប់ ឬឆ្នាំមុន ដូចចែងក្នុងកិច្ចសន្យានេះ។ ការខាតបង់សុទ្ធលើប្រតិបត្តិការអាចយកមកទូទាត់ក្នុងបញ្ជីគណនីសម្រាប់ ២ឆ្នាំបន្ទាប់ជាប់ៗគ្នា លើកលែងតែ ២ឆ្នាំចុងក្រោយ ដែលការខាតបង់នេះអាចយកមកទូទាត់បញ្ជីគណនីសម្រាប់ ២ឆ្នាំមុនបាន។

(ឋ) ប្រសិនបើអ្នកចុះកិច្ចសន្យាចូលរួមក្នុងអាជីវកម្មរ៉ែ ដឹកជញ្ជូនដុំរ៉ែពហុលោហធាតុ និងផលិតកម្មនៃលោហធាតុដែលបានធ្វើប្រព្រឹត្តិកម្ម និងពាក់កណ្តាលប្រព្រឹត្តិកម្ម "ចំណាយលើការអភិវឌ្ឍក្នុងវិស័យរ៉ែ" មានន័យថា ចំណែកនៃចំណាយលើការអភិវឌ្ឍរបស់ អ្នកចុះកិច្ចសន្យាទាក់ទងដោយផ្ទាល់នឹងការធ្វើអាជីវកម្មធនធានរ៉ែនៅតំបន់ក្រោមកិច្ចសន្យា អនុលោមតាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅ ហើយវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ មានជាអាទិ៍ កម្រៃដាក់ពាក្យស្នើសុំ កម្រៃសេវាកម្មប្រចាំឆ្នាំ និងប្រសិនជាមាន ចំណាយការធ្វើបុរេសនានិងការស្វែងរុករកនៅក្នុងតំបន់ក្រោមកិច្ចសន្យា ព្រមទាំងចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍន៍។

(ឌ) "ផលពីការវិនិយោគ" ក្នុងឆ្នាំសារពើពន្ធណាមួយ មានន័យថា អនុបាតនៃ ចំណូលសុទ្ធ នៅក្នុងឆ្នាំនោះ លើការចំណាយអភិវឌ្ឍក្នុងវិស័យរ៉ែ។ ក្នុងគោលបំណងគណនាអនុបាតនេះ ចំណាយលើការអភិវឌ្ឍក្នុងវិស័យរ៉ែត្រូវរាប់បញ្ចូលថ្លៃដើមគ្រឿងបរិក្ខារថ្មី ឬការផ្លាស់ប្តូរគ្រឿងបរិក្ខារក្នុងវិស័យរ៉ែ ដកនឹងថ្លៃដើមគ្រឿងបរិក្ខារដែលដាក់ជំនួសនោះ។

(ឍ) ប្រសិនបើអ្នកចុះកិច្ចសន្យាប្រតិបត្តិការអាជីវកម្មរ៉ែតែមួយគត់ៈ

(i) "ចំណូលសុទ្ធ" មានន័យថាប្រាក់ចំណូលសុទ្ធទាំងអស់របស់អ្នកចុះកិច្ចសន្យា។

(ii) "ចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យា" ត្រូវកំណត់និយមន័យក្នុងកថាខណ្ឌ (ច)។

(iii) "ចំណូលសរុបរបស់អ្នកចុះកិច្ចសន្យា" មានន័យថា ប្រាក់សរុបដែលបានមកពីការលក់ដុំរ៉ែពហុលោហធាតុ និងប្រាក់ដទៃទៀតដែលទទួលបានសមស្របពីប្រតិបត្តិការតាមកិច្ចសន្យា អនុលោមតាម វិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ។

(iv) "ការចំណាយអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យា" មានន័យថា រាល់ការចំណាយទាំងអស់ដែលកើតឡើងមុនពេលចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ដូចចែងក្នុងកថាខណ្ឌ (ជ)(i) និងរាល់ការចំណាយអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យាទាំងអស់ ដែលកើតឡើងក្រោយពេលចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម ដូចចែងក្នុងកថាខណ្ឌ(ជ)(ii) ដែលទាក់ទងដោយផ្ទាល់នឹងអាជីវកម្មធនធានរ៉ែនៅតំបន់ដែលចែងក្នុងកិច្ចសន្យា អនុលោមតាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅ។

(v) "ការចំណាយប្រតិបត្តិការរបស់អ្នកចុះកិច្ចសន្យា" មានន័យថា រាល់ការចំណាយប្រតិបត្តិការទាំងអស់ ដូចចែងក្នុងកថាខណ្ឌ (ដ) ដែលទាក់ទងផ្ទាល់នឹងអាជីវកម្មធនធានរ៉ែ នៅតំបន់ដែលចែងក្នុងកិច្ចសន្យា អនុលោមតាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅ។

(vi) "ផលវិនិយោគ" ក្នុងឆ្នាំគណនេយ្យណាមួយមានន័យថា អនុបាតនៃចំណូលសុទ្ធរបស់អ្នកចុះកិច្ចសន្យា នៅក្នុងឆ្នាំនោះ លើការចំណាយអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យា។ ក្នុងគោលបំណងគណនា អនុបាតនេះ ការចំណាយអភិវឌ្ឍរបស់អ្នកចុះកិច្ចសន្យាត្រូវរាប់បញ្ចូលការចំណាយលើគ្រឿងបរិក្ខារថ្មី ឬការផ្លាស់ប្តូរគ្រឿងបរិក្ខារដកនឹងថ្លៃដើមគ្រឿងបរិក្ខារដែលត្រូវបានជំនួសនោះ។

(ណ) ការចំណាយដូចមានចែងក្នុងកថាខណ្ឌរង (ជ) (ដ) (ឋ) និង (ឍ) ទាក់ទងនឹងការប្រាក់ដែលត្រូវបង់ដោយអ្នកចុះកិច្ចសន្យា ត្រូវអនុញ្ញាតរហូតដល់កម្រិតដែលអាជ្ញាធរបានឯកភាពលើអនុបាតរវាងបំណុលនិងទុន ព្រមទាំងអត្រាការប្រាក់សមស្របទាក់ទងនឹងទម្លាប់ពាណិជ្ជកម្មដែលមានស្រាប់ នៅគ្រប់កាលៈទេសៈទាំងអស់អនុលោមតាមកថាខណ្ឌទី១ នៃមាត្រា៤ នៃឧបសម្ព័ន្ធនេះ។

(គ) ការចំណាយដូចមានចែងក្នុងកថាខណ្ឌនេះមិនត្រូវយកមកបកស្រាយ ដើម្បីរាប់បញ្ចូល ទាំងការបង់ពន្ធចំណូលក្រុមហ៊ុន ឬកម្រៃប្រហាក់ប្រហែលដែលកំណត់ដោយរដ្ឋទាក់ទងនឹងប្រតិបត្តិការរបស់ អ្នកចុះកិច្ចសន្យាឡើយ។

៧. (ក) "លោហធាតុដែលបានធ្វើប្រព្រឹត្តិកម្ម" ដូចមានចែងក្នុងកថាខណ្ឌទី៥ និងកថាខណ្ឌទី៦ មានន័យថា លោហធាតុក្នុងទ្រង់ទ្រាយដើមបំផុតដែលជាធម្មតា ត្រូវបានធ្វើពាណិជ្ជកម្មនៅលើទីផ្សារអន្តរជាតិ។ ក្នុងគោលបំណងនេះ អាជ្ញាធរត្រូវកំណត់ឱ្យច្បាស់ពីទីផ្សារអន្តរជាតិពាក់ព័ន្ធ នៅក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និង នីតិវិធីហិរញ្ញវត្ថុរបស់ខ្លួន។ ចំពោះលោហធាតុមិនមែនសម្រាប់គោលបំណងពាណិជ្ជកម្មនៅលើទីផ្សារ "លោហធាតុ ដែលបានធ្វើប្រព្រឹត្តិកម្ម" មានន័យថា លោហធាតុក្នុងទ្រង់ទ្រាយដើមបំផុត ដែលជាធម្មតាត្រូវបានធ្វើពាណិជ្ជកម្ម ក្នុងប្រតិបត្តិការជំហោងដៃ។

(ខ) ប្រសិនបើអាជ្ញាធរមិនអាចធ្វើការកំណត់បរិមាណលោហធាតុដែលបានធ្វើប្រព្រឹត្តិកម្មពីដុំ រ៉ែពហុលោហធាតុយកចេញពី តំបន់ក្រោមកិច្ចសន្យាដូចមានចែងក្នុងកថាខណ្ឌទី៥(ខ) និងកថាខណ្ឌទី៦(ខ) បរិមាណត្រូវកំណត់ផ្អែកលើសមាសធាតុលោហធាតុនៃដុំរ៉ែ ប្រសិទ្ធភាពនៃប្រព្រឹត្តិកម្មនៃការទាញយក និងកត្តា ពាក់ព័ន្ធដទៃទៀត អនុលោមតាមវិធានច្បាប់ បទប្បញ្ញត្តិ នីតិវិធីរបស់អាជ្ញាធរ និងស្របតាមគោលការណ៍គណនេយ្យ ដែលត្រូវបានទទួលស្គាល់ជាទូទៅ។

៨. ប្រសិនបើទីផ្សារអន្តរជាតិផ្តល់ជាយន្តការកំណត់តម្លៃចំពោះលោហធាតុដែលបានធ្វើប្រព្រឹត្តិកម្មដុំរ៉ែ ពហុលោហធាតុ និងលោហធាតុពាក់កណ្តាលប្រព្រឹត្តិកម្មពីដុំរ៉ែ តម្លៃជាមធ្យមនៅលើទីផ្សារនោះត្រូវយកមកប្រើប្រាស់។ ក្នុងករណីដទៃទៀត អាជ្ញាធរត្រូវកំណត់តម្លៃសមរម្យចំពោះទំនិញ អនុលោមតាមកថាខណ្ឌទី៩ បន្ទាប់ពីបាន ពិគ្រោះយោបល់ជាមួយនឹងអ្នកចុះកិច្ចសន្យារួច។

៩. (ក) ការចំណាយ ចំណូល និងផលទុន និងការកំណត់តម្លៃទាំងអស់ ដែលលើកឡើងក្នុង មាត្រានេះ ត្រូវជាលទ្ធផលទីផ្សារសេរី ឬប្រតិបត្តិការជំហោងដៃ។ បើគ្មានទេនោះ វាត្រូវកំណត់ដោយអាជ្ញាធរ បន្ទាប់ពីពិគ្រោះយោបល់ជាមួយនឹងអ្នកចុះកិច្ចសន្យា ហាក់បីដូចជាវាជាលទ្ធផលទីផ្សារសេរី ឬប្រតិបត្តិការជំហោងដៃ ដោយពិចារណាលើប្រតិបត្តិការពាក់ព័ន្ធនៅលើទីផ្សារដទៃទៀត។

(ខ) ក្នុងគោលបំណងធានាលើការគោរពតាម និងការអនុវត្តបទប្បញ្ញត្តិនៃកថាខណ្ឌនេះ អាជ្ញាធរត្រូវអនុវត្តតាមគោលការណ៍និងការបកស្រាយចំពោះប្រតិបត្តិការជំហោងដៃដែលបានអនុម័ត និងបកស្រាយ ដោយគណៈកម្មការអង្គការសហប្រជាជាតិស្តីពីសាជីវកម្មពហុជាតិ ក្រុមអ្នកជំនាញទទួលបន្ទុកសន្ធិសញ្ញាសារពើពន្ធ រវាងប្រទេសកំពុងអភិវឌ្ឍនិងអភិវឌ្ឍនិងអង្គការអន្តរជាតិដទៃទៀត ហើយត្រូវកំណត់វិធានច្បាប់និងនីតិវិធី គណនេយ្យរួម និងដែលត្រូវបានទទួលស្គាល់ជាទូទៅ និងវិធីជ្រើសរើសគណនេយ្យករឯករាជ្យដោយអ្នកចុះកិច្ចសន្យា ដែលអាជ្ញាធរអាចទទួលយកបាននៅក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់ខ្លួន ក្នុងគោលបំណងដើម្បី ធ្វើសវនកម្មអនុលោមតាមវិធានច្បាប់ បទប្បញ្ញត្តិនិងនីតិវិធីទាំងនោះ។

១០. អនុលោមតាមវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ អ្នកចុះកិច្ចសន្យាត្រូវផ្តល់ ទិន្នន័យហិរញ្ញវត្ថុដល់គណនេយ្យករ ដែលត្រូវការដើម្បីកំណត់ការគោរពតាមមាត្រានេះ។

១១. ការចំណាយ ចំណូល និងផលទុនទាំងអស់ ព្រមទាំងតម្លៃទាំងអស់ ដែលលើកឡើងក្នុងមាត្រានេះ ត្រូវកំណត់តាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ជាទូទៅ និងតាមវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុរបស់អាជ្ញាធរ។

១២. ការបង់ប្រាក់ឱ្យអាជ្ញាធរ តាមកថាខណ្ឌទី៥ និង៦ ត្រូវធ្វើឡើងដោយសេរី ជារូបិយវត្ថុដែលមានដោយសេរី និងអាចប្រើការបានប្រកបដោយប្រសិទ្ធភាព នៅលើទីផ្សារប្តូរប្រាក់អន្តរជាតិសំខាន់ៗ ឬតាមជម្រើសរបស់អ្នកចុះកិច្ចសន្យា ជាវត្ថុសមមូលនឹងលោហធាតុដែលបានធ្វើប្រព្រឹត្តិកម្មក្នុងតម្លៃទីផ្សារ។ តម្លៃទីផ្សារត្រូវកំណត់អនុលោមតាមកថាខណ្ឌទី៥(ខ)។ រូបិយវត្ថុដែលមានដោយសេរី និងអាចប្រើការបានប្រកបដោយប្រសិទ្ធភាពនៅលើទីផ្សារប្តូរប្រាក់អន្តរជាតិសំខាន់ៗត្រូវបានកំណត់ក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ អនុលោមតាមទម្លាប់អនុវត្តនៃរូបិយវត្ថុអន្តរជាតិនាពេលបច្ចុប្បន្ន។

១៣. រាល់កាតព្វកិច្ចហិរញ្ញវត្ថុទាំងអស់របស់អ្នកចុះកិច្ចសន្យាចំពោះអាជ្ញាធរ ក៏ដូចជាកម្រៃ ការចំណាយចំណូល និងផលទុនទាំងអស់របស់អ្នកចុះកិច្ចសន្យា ដែលលើកឡើងក្នុងមាត្រានេះ ត្រូវកែប្រែដោយកំណត់វាក្នុងតម្លៃថេរទាក់ទងនឹងឆ្នាំមូលដ្ឋាន។

១៤. ដោយពិចារណាលើអនុសាសន៍របស់គណៈកម្មការរៀបចំផែនការសេដ្ឋកិច្ច និងគណៈកម្មការច្បាប់ និងបច្ចេកទេស អាជ្ញាធរអាចអនុម័តវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីដែលផ្តល់ការលើកទឹកចិត្តដល់អ្នកចុះកិច្ចសន្យាជាទូទៅនិងគ្មានការរើសអើង ដើម្បីសម្រេចគោលបំណងដូចមានចែងក្នុងកថាខណ្ឌទី១។

១៥. ក្នុងករណីមានវិវាទរវាងអាជ្ញាធរ និងអ្នកចុះកិច្ចសន្យាលើការបកស្រាយ ឬការអនុវត្តលក្ខខណ្ឌហិរញ្ញវត្ថុនៃកិច្ចសន្យា ភាគីណាមួយអាចបញ្ជូនវិវាទនោះទៅធ្វើមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលចងកាតព្វកិច្ចប្រសិនបើភាគីទាំងពីរមិនបានព្រមព្រៀងគ្នាដោះស្រាយវិវាទតាមវិធីផ្សេងទៀតទេនោះ អនុលោមតាមកថាខណ្ឌទី២នៃមាត្រា១៨៨។

## មាត្រា១៤
## ការផ្ទេរទិន្នន័យ

១. អនុលោមតាមវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ និងតាមប្រការ និងលក្ខខណ្ឌនៃផែនការការងារ ប្រតិបត្តិករត្រូវផ្ទេររាល់ទិន្នន័យទាំងអស់ទៅឱ្យអាជ្ញាធរ ដែលចាំបាច់ និងពាក់ព័ន្ធនឹងការអនុវត្តអំណាច និងមុខងាររបស់ស្ថាប័នចម្បងនៃអាជ្ញាធរទាក់ទងនឹងតំបន់ក្រោមផែនការការងារ ក្នុងរយៈពេលដែលកំណត់ដោយអាជ្ញាធរ។

២. ទិន្នន័យដែលផ្ទេរទាក់ទងនឹងតំបន់ដែលចែងក្នុងផែនការការងារ ដែលត្រូវចាត់ទុកជាសិទ្ធិកម្មសិទ្ធិអាចប្រើប្រាស់បានតែសម្រាប់គោលបំណងដូចមានចែងក្នុងមាត្រានេះប៉ុណ្ណោះ។ ទិន្នន័យដែលចាំបាច់សម្រាប់អាជ្ញាធររៀបចំវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីទាក់ទងនឹងការការពារបរិស្ថាន និងសុវត្ថិភាពដែនសមុទ្រ មិនត្រូវចាត់ទុកជាសិទ្ធិកម្មសិទ្ធិ លើកលែងតែទិន្នន័យ គំនូសប្លង់គ្រឿងបរិក្ខារ។

៣.	ទិន្នន័យដែលផ្ទេរទៅឱ្យអាជ្ញាធរដោយអ្នកធ្វើបុរេសនាអ្នកដាក់ពាក្យស្នើសុំកិច្ចសន្យា ឬអ្នកចុះកិច្ចសន្យាដែលចាត់ទុកជាសិទ្ធិកម្មសិទ្ធិ មិនត្រូវបញ្ចេញដោយអាជ្ញាធរទៅឱ្យសហគ្រាស ឬជនណាម្នាក់ដែលនៅក្រៅអាជ្ញាធរទេ ប៉ុន្តែទិន្នន័យស្តីពីតំបន់បម្រុងទុកអាចបញ្ចេញឱ្យសហគ្រាសបាន។ ទិន្នន័យដែលផ្ទេរដោយបុគ្គលនោះទៅឱ្យសហគ្រាសមិនត្រូវបញ្ចេញដោយសហគ្រាសទៅឱ្យអាជ្ញាធរ ឬទៅឱ្យជនណាម្នាក់ដែលនៅក្រៅអាជ្ញាធរឡើយ។

## មាត្រា១៥
## កម្មវិធីបណ្តុះបណ្តាល

អ្នកចុះកិច្ចសន្យាត្រូវរៀបចំកម្មវិធីអនុវត្តសម្រាប់បណ្តុះបណ្តាលបុគ្គលិករបស់អាជ្ញាធរ និងរដ្ឋកំពុងអភិវឌ្ឍន៍ដែលរាប់បញ្ចូលការចូលរួមរបស់បុគ្គលិកធ្វើសកម្មភាពនៅតំបន់ដែលចែងក្នុងកិច្ចសន្យា អនុលោមតាមកថាខណ្ឌទី២ នៃមាត្រា១៤៤។

## មាត្រា១៦
## សិទ្ធិស្វែងរុករក និងធ្វើអាជីវកម្មផ្តាច់មុខ

អនុលោមតាមផ្នែកទី១១ និងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់ខ្លួន អាជ្ញាធរត្រូវផ្តល់សិទ្ធិផ្តាច់មុខដល់ប្រតិបត្តិករដើម្បីស្វែងរុករកនិងធ្វើអាជីវកម្មនៅតំបន់ក្រោមផែនការការងារលើប្រភេទធនធានជាក់លាក់ ហើយត្រូវធានាថាគ្មានអង្គភាពដទៃទៀតប្រតិបត្តិការនៅតំបន់ដដែលសម្រាប់ធនធានប្រភេទផ្សេងទៀត ក្នុងរបៀបដែលអាចជ្រៀតជ្រែកដល់ប្រតិបត្តិការរបស់ប្រតិបត្តិករឡើយ។ ប្រតិបត្តិករត្រូវមានការធានាដល់សិទ្ធិកាន់កាប់ អនុលោមតាមកថាខណ្ឌទី៦ នៃមាត្រា១៥៣។

## មាត្រា១៧
## វិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ

១.	អាជ្ញាធរត្រូវអនុម័តនិងអនុវត្តជាទូទៅនូវវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធី អនុលោមតាមកថាខណ្ឌទី២(ច)(ii) មាត្រា១៦០ និងកថាខណ្ឌ(ណ)(ii) នៃមាត្រា១៦២ សម្រាប់ការអនុវត្តមុខងាររបស់ខ្លួនដូចមានចែងក្នុងផ្នែកទី១១ ស្តីពីបញ្ហាដូចខាងក្រោម៖

(ក)	នីតិវិធីរដ្ឋបាលទាក់ទងនឹងការធ្វើបុរេសនា ការស្វែងរុករក និងការធ្វើអាជីវកម្មនៅតំបន់។

(ខ)	ប្រតិបត្តិការ៖

(i)	ផ្ទៃក្រឡាតំបន់

(ii)	រយៈពេលប្រតិបត្តិការ

(iii)	លក្ខខណ្ឌលទ្ធផលការងាររួមមានការធានា អនុលោមតាមកថាខណ្ឌទី៦(គ) មាត្រា៤ នៃឧបសម្ព័ន្ធនេះ។

(iv)	ប្រភេទធនធាន

(v)	ការបោះបង់តំបន់

(vi)	របាយការណ៍វឌ្ឍនភាព

(vii)	ការផ្តល់ទិន្នន័យ

(viii) ការត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការ

(ix) ការបង្ការការជ្រៀតជ្រែកលើសកម្មភាពដទៃទៀតនៅបរិស្ថានសមុទ្រ។

(x) ការផ្ទេរសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកចុះកិច្ចសន្យា។

(xi) នីតិវិធីសម្រាប់ផ្ទេរបច្ចេកវិទ្យាដល់រដ្ឋកំពុងអភិវឌ្ឍន៍ អនុលោមតាមមាត្រា១៤៤ និងនីតិវិធីសម្រាប់ការចូលរួមដោយផ្ទាល់របស់រដ្ឋកំពុងអភិវឌ្ឍន៍។

(xii) និយាម និងទម្លាប់អនុវត្តនៃអាជីវកម្មរ៉ែ ដែលរួមមានបទដ្ឋាន និងទម្លាប់អនុវត្ត ដែលទាក់ទងនឹងសុវត្ថិភាពប្រតិបត្តិការ ការអភិរក្សធនធាននិងការការពារបរិស្ថានសមុទ្រ

(xiii) និយមន័យនៃផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម

( xiv) បទដ្ឋានកំណត់ពីលក្ខណៈសម្បត្តិរបស់អ្នកដាក់ពាក្យស្នើសុំ។

(គ) បញ្ហាហិរញ្ញវត្ថុ៖

(i) ការបង្កើតវិធានច្បាប់គណនេយ្យ និងចំណាយដែលមានលក្ខណៈទូទៅ និងមិនរើសអើង ព្រមទាំងវិធីជ្រើសរើសសវនករ ។

(ii) ការបែងចែកចំណូលប្រតិបត្តិការ ។

(iii) ការលើកទឹកចិត្តដែលលើកឡើងក្នុងមាត្រា១៣ នៃឧបសម្ព័ន្ធនេះ

(ឃ) ការអនុវត្តសេចក្តីសម្រេចដែលបានធ្វើឡើងអនុលោមតាមកថាខណ្ឌទី១០ នៃមាត្រា១៥១ និងកថាខណ្ឌទី២(ឃ)នៃមាត្រា១៦៤។

២. វិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីលើបញ្ហាខាងក្រោម ត្រូវឆ្លុះបញ្ចាំងឱ្យបានពេញលេញនូវកម្មវត្ថុនៃលក្ខណវិនិច្ឆ័យពិតច្បាស់ ដែលចែងដូចតទៅ ៖

(ក) ផ្ទៃក្រឡាតំបន់៖

អាជ្ញាធរត្រូវកំណត់ផ្ទៃក្រឡាតំបន់សមស្របសម្រាប់ការស្វែងរុករក ដែលអាចមានទំហំធំពីរដងស្មើនឹងតំបន់សម្រាប់ធ្វើអាជីវកម្ម ក្នុងគោលបំណងដើម្បីអនុញ្ញាតប្រតិបត្តិការស្វែងរុករកឱ្យបានល្អិតល្អន់។ ផ្ទៃក្រឡាតំបន់នឹងត្រូវគណនាផ្អែកតាមលក្ខខណ្ឌនៃមាត្រា៨ ក្នុងឧបសម្ព័ន្ធនេះ ស្តីពីការបម្រុងទុកតំបន់ ក៏ដូចជាលក្ខខណ្ឌផលិតកម្មស្របតាមមាត្រា១៥១ អនុលោមតាមលក្ខខណ្ឌកិច្ចសន្យា ដោយពិចារណាលើបច្ចេកវិទ្យាទំនើបដែលមានសម្រាប់អាជីវកម្មរ៉ែនៅបាតសមុទ្រ និងលក្ខណៈរូបពាក់ព័ន្ធនៃតំបន់។ តំបន់មិនត្រូវមានទំហំតូចពេក ឬធំពេកទេ ដែលចាំបាច់ដើម្បីសម្រេចនូវគោលបំណងនេះ។

(ខ) រយៈពេលប្រតិបត្តិការ៖

(i) ការធ្វើបុរេសនាត្រូវមានរយៈពេលមិនកំណត់។

(ii) ការស្វែងរុករក គួរមានរយៈពេលគ្រប់គ្រាន់ដើម្បីធ្វើការវាស់ស្ទង់តំបន់ឱ្យបានល្អិតល្អន់ ការធ្វើគំនូសប្លង់ និងការសាងសង់គ្រឿងបរិក្ខារអាជីវកម្មរ៉ែសម្រាប់តំបន់ ក៏ដូចជាការធ្វើគំនូសប្លង់ និងការសាងសង់រោងចក្រប្រព្រឹត្តិកម្មខ្នាតតូចនិងមធ្យមក្នុងគោលបំណងដំណើរការគម្រោងសាកល្បងអាជីវកម្មរ៉ែនិងប្រព្រឹត្តិកម្ម។

(iii) រយៈពេលធ្វើអាជីវកម្មគួរទាក់ទងនឹងអាយុកាលសេដ្ឋកិច្ចនៃគម្រោងអាជីវកម្មរ៉ែ ដោយពិចារណាលើកត្តាផ្សេងៗ ដូចជាតំហយចុះធនធានរ៉ែ វាយុកាលប្រើប្រាស់នៃគ្រឿងបរិក្ខារធ្វើអាជីវកម្មរ៉ែនិងឋបនកម្មប្រព្រឹត្តិកម្ម និងការនៅមានបេក្ខភាពធ្វើពាណិជ្ជកម្ម។ ការធ្វើអាជីវកម្មគួរមានរយៈពេលគ្រប់គ្រាន់ដើម្បីអនុញ្ញាតការទាញយករ៉ែក្នុងលក្ខណៈពាណិជ្ជកម្មពីតំបន់ ហើយគួររាប់បញ្ចូលរយៈពេលសមស្របសម្រាប់ការសាងសង់ប្រព័ន្ធអាជីវកម្មរ៉ែ និងប្រព្រឹត្តិកម្មខ្នាតពាណិជ្ជកម្ម ដែលក្នុងអំឡុងរយៈពេលនេះ មិនគួរតម្រូវឱ្យមានផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្មឡើយ។ ប៉ុន្តែរយៈពេលសរុបនៃការធ្វើអាជីវកម្មគួរខ្លីល្មម ដើម្បីផ្តល់ឱកាសដល់អាជ្ញាធរកែប្រែប្រការ និងលក្ខខណ្ឌនៃផែនការការងារ នៅពេលដែលអាជ្ញាធរពិចារណាលើការបន្តរយៈពេល ដោយអនុលោមតាមវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីដែលអាជ្ញាធរបានអនុម័ត ក្រោយការអនុម័តលើផែនការការងារ។

(គ) លក្ខខណ្ឌលទ្ធផលការងារ៖

ក្នុងអំឡុងដំណាក់កាលស្វែងរុករក អាជ្ញាធរត្រូវតម្រូវឱ្យប្រតិបត្តិករធ្វើការចំណាយតាមកំណត់ពេលដែលទាក់ទងសមស្របនឹងផ្ទៃក្រឡាតំបន់ក្រោមផែនការការងារ និងការចំណាយជាយថាហេតុផ្សេងៗពីប្រតិបត្តិករពិតប្រាកដដែលមានបំណងដាក់ឱ្យដំណើរការផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្មនៅតំបន់ ក្នុងរយៈពេលដែលកំណត់ដោយអាជ្ញាធរ។ ការចំណាយដែលតម្រូវនោះមិនគួរកំណត់ឡើងនៅកម្រិតដែលនឹងបំបាក់ទឹកចិត្តប្រតិបត្តិករដែលមានបច្ចេកវិទ្យាចំណាយតិចជាងបច្ចេកវិទ្យាដែលប្រើប្រាស់ទូទៅនោះទេ។ អាជ្ញាធរត្រូវកំណត់រយៈពេលអតិបរមាដើម្បីសម្រេចបាននូវផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម បន្ទាប់ពីដំណាក់កាលស្វែងរុករកបានបញ្ចប់ ហើយដំណាក់កាលធ្វើអាជីវកម្មបានចាប់ផ្តើម។ ដើម្បីកំណត់រយៈពេលនេះ អាជ្ញាធរគួរពិចារណាថា ការសាងសង់ប្រព័ន្ធអាជីវកម្មរ៉ែ និងប្រព្រឹត្តិកម្មទ្រង់ទ្រាយធំមិនអាចចាប់ផ្តើមបានទេ រហូតទាល់តែបញ្ចប់ដំណាក់កាលស្វែងរុករក និងចាប់ផ្តើមដំណាក់កាលធ្វើអាជីវកម្ម។ ដូច្នោះ រយៈពេលសម្រាប់ដាក់ ដំណើរការផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្មនៅតំបន់ គួរពិចារណាលើពេលវេលាចាំបាច់ចំពោះការសាងសង់នេះ បន្ទាប់ពីបញ្ចប់ដំណាក់កាលស្វែងរុករក ហើយគួរទុករយៈពេលសមស្របចំពោះការពន្យារពេលកម្មវិធី សាងសង់ដែលមិនអាចចៀសវាងបាន។ នៅពេលសម្រេចបាននូវផលិតកម្មដែលមានលក្ខណៈជាពាណិជ្ជកម្ម ក្នុងដែនកំណត់សមស្រប និងដោយពិចារណាកត្តាពាក់ព័ន្ធទាំងអស់ អាជ្ញាធរត្រូវតម្រូវឱ្យប្រតិបត្តិកររក្សាផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្មសម្រាប់រយៈពេលនៃផែនការការងារទាំងមូល។

(ឃ) ប្រភេទធនធាន៖

ក្នុងការកំណត់ប្រភេទធនធានដែលត្រូវបានអនុម័តក្នុងផែនការការងារ អាជ្ញាធរត្រូវសង្កត់ធ្ងន់លើលក្ខណៈដូចតទៅ៖

(i) ធនធានខ្លះតម្រូវឱ្យប្រើប្រាស់វិធីសាស្ត្រធ្វើអាជីវកម្មរ៉ែស្រដៀងគ្នា។ និង

(ii) ធនធានមួយចំនួនអាចអភិវឌ្ឍក្នុងពេលដំណាលគ្នា ដោយគ្មានការជ្រៀតជ្រែកហួសហេតុរវាងប្រតិបត្តិករដែលអភិវឌ្ឍធនធានផ្សេងៗគ្នានៅតំបន់តែមួយនោះឡើយ។

គ្មានប្រការណាមួយក្នុងកថាខណ្ឌនេះ ត្រូវរារាំងអាជ្ញាធរមិនឱ្យផ្តល់ការអនុម័តលើផែនការការងារទាក់ទងនឹងប្រភេទធនធានច្រើនជាងមួយនៅតំបន់តែមួយ ទៅឱ្យអ្នកដាក់ពាក្យស្នើសុំតែមួយនោះឡើយ។

(ង) ការលះបង់តំបន់៖

ប្រតិបត្តិករអាចបោះបង់សិទ្ធិទាំងស្រុង ឬមួយផ្នែកនៅតំបន់ក្រោមផែនការការងារ នៅពេលណាក៏បាន ដោយគ្មានការពិន័យអ្វីឡើយ។

(ច) ការការពារបរិស្ថានសមុទ្រ៖

វិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីត្រូវរៀបចំឡើង ដើម្បីធានាឱ្យមានការការពារបរិស្ថានសមុទ្រប្រកបដោយប្រសិទ្ធភាពពីផលប៉ះពាល់មិនល្អ ដែលកើតចេញដោយផ្ទាល់ពីសកម្មភាពនៅតំបន់ ឬពីការប្រព្រឹត្តិកម្មលើនាវានូវរ៉ែបានមកពីការដ្ឋានអាជីវកម្មរ៉ែដែលនាវានៅផ្ទាល់ពីលើ ដោយពិចារណាលើកម្រិតដែលផលប៉ះពាល់មិនល្អនោះអាចកើតចេញដោយផ្ទាល់ពីការខួងអណ្តូង ការបូម ការខួងយកសំណាក និងការកាយ និងពីការបោះចោល ការចាក់ចោល និងការបញ្ចេញកម្ទេចកំណរ សំណល់ ឬសំណល់រាវដទៃទៀត។

(ឆ) ផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្ម

ផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្មត្រូវបានចាត់ទុកថាបានចាប់ផ្តើម ប្រសិនបើប្រតិបត្តិករចាប់ផ្តើមប្រតិបត្តិការទាញយកទ្រង់ទ្រាយធំ ដែលផលិតបានបរិមាណវត្ថុធាតុដើមគ្រប់គ្រាន់ ដែលចង្អុលបង្ហាញយ៉ាងច្បាស់ថា គោលបំណងចម្បងគឺការផលិតទ្រង់ទ្រាយធំ មិនមែនជាការផលិតដើម្បីប្រមូល វិភាគព័ត៌មាន ឬសាកល្បងគ្រឿងបរិក្ខារ ឬរោងចក្រឡើយ។

## មាត្រា១៨
## ទោសប្បញ្ញត្តិ

១. សិទ្ធិរបស់អ្នកចុះកិច្ចសន្យាជាប់កិច្ចសន្យាអាចត្រូវបានព្យួរទុក ឬដកហូត តែក្នុងករណីខាងក្រោមប៉ុណ្ណោះ៖

(ក) ករណីដែលអ្នកចុះកិច្ចសន្យាធ្វើសកម្មភាពដែលរំលោភបំពានធ្ងន់ធ្ងរមិនរាងចាល និងដោយចេតនានូវលក្ខខណ្ឌមូលដ្ឋាននៃកិច្ចសន្យា ផ្នែកទី១១ និងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ បើទោះបីជាមានការព្រមានពីអាជ្ញាធរក៏ដោយ។ ឬ

(ខ) ករណីដែលអ្នកចុះកិច្ចសន្យាខកខានមិនគោរពតាមសេចក្តីសម្រេចស្ថាពរ និងចងកាតព្វកិច្ចចេញដោយស្ថាប័នដោះស្រាយវិវាទ ដែលអ្នកចុះកិច្ចសន្យាត្រូវអនុវត្ត និងគោរពតាម។

២. ក្នុងករណីមានការរំលោភកិច្ចសន្យាដែលមិនបានចែងក្នុងកថាខណ្ឌទី១(ក) ឬជាការជំនួសការព្យួរ ឬការ ដកហូតសិទ្ធិដូចមានចែងក្នុងកថាខណ្ឌទី១(ក) អាជ្ញាធរអាចដាក់ពិន័យជាប្រាក់លើអ្នកចុះកិច្ចសន្យាដែលមានចំនួនស្មើនឹងកម្រិតធ្ងន់ធ្ងរនៃការរំលោភបំពាននោះ។

៣. លើកលែងតែមានដីកាបន្ទាន់តាមកថាខណ្ឌទី២ (ព)នៃមាត្រា១៦២ អាជ្ញាធរមិនអាចអនុវត្តសេចក្តីសម្រេចទាក់ទងនឹងប្រាក់ពិន័យ ការព្យួរ ឬការដកហូតសិទ្ធិបានទេ រហូតទាល់តែអ្នកចុះកិច្ចសន្យាទទួលបានឱកាសសមស្រប ក្នុងការប្រើគ្រប់មធ្យោបាយតាមផ្លូវតុលាការដែលខ្លួនមាន អនុលោមតាមជំពូកទី៥ នៃផ្នែកទី១១។

## មាត្រា១៩
## ការធ្វើវិសោធនកម្មកែសម្រួលលើកិច្ចសន្យា

១. នៅក្នុងករណី ឬកាលៈទេសៈណាមួយដែលភាគីនីមួយៗយល់ឃើញថា នឹងធ្វើឱ្យកិច្ចសន្យា មានវិសមធម៌ ឬមិនអាចសម្រេចគោលបំណងដូចមានចែងក្នុងកិច្ចសន្យា ឬក្នុងផ្នែកទី១១ បណ្តាភាគីត្រូវធ្វើការចរចា ដើម្បីកែប្រែកិច្ចសន្យា ផ្អែកតាមករណីជាក់ស្តែងនីមួយៗ។

២. កិច្ចសន្យាដែលធ្វើឡើងស្របតាម កថាខណ្ឌទី៣ នៃមាត្រា១៥៣ មិនអាចធ្វើការកែប្រែបានឡើយ លើកលែងតែមានការឯកភាពពីបណ្តាភាគី។

## មាត្រា២០
## ការផ្ទេរសិទ្ធិនិងកាតព្វកិច្ច

សិទ្ធិ និងកាតព្វកិច្ចក្នុងកិច្ចសន្យាអាចផ្ទេរបាន តែក្នុងករណីមានការឯកភាពពីអាជ្ញាធរប៉ុណ្ណោះ និងអនុលោមតាមវិធានច្បាប់ បទប្បញ្ញត្តិ និងបែបបទរបស់អាជ្ញាធរ។ អាជ្ញាធរមិនត្រូវបដិសេធផ្តល់ការឯកភាពលើការផ្ទេរដោយគ្មានមូលហេតុច្បាស់លាស់នោះឡើយ ប្រសិនបើអ្នកទទួលការផ្ទេរមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយទទួលយករាល់កាតព្វកិច្ចទាំងអស់របស់ម្ចាស់ផ្ទេរ ហើយប្រសិនបើការផ្ទេរនោះមិនផ្តល់ផែនការការងារឡើយ ដែលការត្រូវបានហាមឃាត់មិនឱ្យអនុម័តទេ តាមកថាខណ្ឌទី៣(គ) មាត្រា៦ នៃឧបសម្ព័ននេះ។

## មាត្រា២១
## ច្បាប់ដែលត្រូវអនុវត្ត

១. កិច្ចសន្យានេះស្ថិតក្រោមការគ្រប់គ្រងដោយលក្ខខណ្ឌនៃកិច្ចសន្យា វិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ ផ្នែកទី១១ និងវិធានច្បាប់ដទៃទៀតនៃច្បាប់អន្តរជាតិ ដែលមានខ្លឹមសារមិនផ្ទុយនឹងខ្លឹមសារនៃអនុសញ្ញានេះ។

២. សេចក្តីសម្រេចស្ថាពររបស់តុលាការ ឬសាលាជំនុំជម្រះដែលមានយុត្តាធិការក្រោមអនុសញ្ញានេះ ទាក់ទងនឹងសិទ្ធិនិងកាតព្វកិច្ចរបស់អាជ្ញាធរនិងអ្នកចុះកិច្ចសន្យា ត្រូវអាចយកទៅអនុវត្តបាននៅក្នុងទឹកដីរបស់រដ្ឋភាគីនីមួយៗ។

៣. គ្មានរដ្ឋភាគីណាមួយអាចដាក់លក្ខខណ្ឌអនុវត្តលើអ្នកចុះកិច្ចសន្យា ដែលផ្ទុយនឹងផ្នែកទី១១ឡើយ។ ទោះជាយ៉ាងនេះក្តី ការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីបរិស្ថាន ឬច្បាប់ និងបទប្បញ្ញត្តិដទៃទៀតដោយរដ្ឋភាគីចំពោះអ្នកចុះកិច្ចសន្យាដែល ខ្លួនឧបត្ថម្ភ ឬចំពោះនាវាដែលដោតទង់ជាតិរបស់ខ្លួន យ៉ាងតឹងរ៉ឹងជាងអ្វីដែលចែងក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និងបែបបទរបស់អាជ្ញាធរដែលអនុម័តអនុលោមតាមកថាខណ្ឌទី២ (ច) នៃមាត្រា១៧ នៃឧបសម្ព័ន្ធនេះ មិនត្រូវចាត់ទុកថា ផ្ទុយនឹងផ្នែក ១១ ឡើយ។

## មាត្រា២២

## ការទទួលខុសត្រូវ

អ្នកចុះកិច្ចសន្យាត្រូវទទួលខុសត្រូវ ឬមានភារៈទទួលខុសត្រូវចំពោះការខូចខាតណាមួយដែលកើតចេញពីអំពើខុសឆ្គងក្នុងប្រតិបត្តិការរបស់ខ្លួន ដោយពិចារណាលើសកម្មភាពរួមចំណែកឬការធ្វេសប្រហែសដោយអាជ្ញាធរផងដែរ។ ដូចគ្នាផងដែរ អាជ្ញាធរត្រូវទទួលខុសត្រូវ ឬមានភារៈទទួលខុសត្រូវចំពោះការខូចខាតណាមួយ ដែលកើតចេញពីការអនុវត្តអំណាច និងមុខងាររបស់ខ្លួន ដែលរួមមានការរំលោភកថាខណ្ឌទី២ នៃមាត្រា១៦៨ អំពើខុសឆ្គងក្នុងប្រតិបត្តិករបស់ខ្លួន ដោយពិចារណាលើសកម្មភាពរួមចំណែកឬការធ្វេសប្រហែសដោយអ្នកចុះកិច្ចសន្យាផងដែរ។ ភារៈទទួលខុសត្រូវក្នុងរាល់ករណីទាំងអស់ត្រូវជាការទទួលខុសត្រូវចំពោះចំនួនខូចខាតជាក់ស្តែង។

## ឧបសម្ព័ន្ធទី៤

## លក្ខន្តិកៈរបស់សហគ្រាស

### មាត្រា១

### គោលបំណង

១. សហគ្រាសគឺជាស្ថាប័នរបស់អាជ្ញាធរដែលត្រូវអនុវត្តសកម្មភាពដោយផ្ទាល់នៅតំបន់អនុលោមតាមកថាខណ្ឌទី២(ក) នៃមាត្រា១៥៣ ព្រមទាំងដឹកជញ្ជូន ប្រព្រឹត្តិកម្មនិងដាក់លក់រ៉ែនៅទីផ្សារ ដែលទាញយកបានពីតំបន់។

២. ក្នុងការអនុវត្តគោលបំណង និងក្នុងការអនុវត្តមុខងាររបស់ខ្លួន សហគ្រាសត្រូវធ្វើសកម្មភាពអនុលោមតាមអនុសញ្ញានេះ និងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

៣. ក្នុងការអភិវឌ្ឍធនធាននៃតំបន់ អនុលោមតាមមាត្រា១ សហគ្រាសត្រូវប្រតិបត្តិការអនុលោមតាមគោលការណ៍ពាណិជ្ជកម្មត្រឹមត្រូវ ដោយស្ថិតក្រោមលក្ខខណ្ឌនៃអនុសញ្ញានេះ។

### មាត្រា២

### ទំនាក់ទំនងជាមួយអាជ្ញាធរ

១. អនុលោមតាមមាត្រា១៧០ សហគ្រាសត្រូវធ្វើសកម្មភាពអនុលោមតាមគោលនយោបាយទូទៅរបស់អង្គសន្និបាតនិងសេចក្ដីណែនាំរបស់ក្រុមប្រឹក្សា។

២. អនុលោមតាមកថាខណ្ឌទី១ សហគ្រាសត្រូវមានស្វ័យភាពក្នុងប្រតិបត្តិការរបស់ខ្លួន។

៣. គ្មានប្រការណាមួយក្នុងអនុសញ្ញានេះត្រូវកំណត់ឱ្យសហគ្រាសទទួលខុសត្រូវចំពោះសកម្មភាព ឬកាតព្វកិច្ចរបស់អាជ្ញាធរ ឬកំណត់ឱ្យអាជ្ញាធរទទួលខុសត្រូវចំពោះសកម្មភាព ឬកាតព្វកិច្ចរបស់សហគ្រាសឡើយ។

### មាត្រា៣

### ការកម្រិតកំណត់លើការទទួលខុសត្រូវ

ដោយមិនគិតដល់កថាខណ្ឌទី៣ មាត្រា១១ នៃឧបសម្ព័ន្ធនេះ គ្មានសមាជិកអាជ្ញាធរណាមួយត្រូវទទួលខុសត្រូវចំពោះសកម្មភាព ឬកាតព្វកិច្ចរបស់សហគ្រាស ដោយសារមូលហេតុខ្លួនជាសមាជិកនោះឡើយ។

### មាត្រា៤

### រចនាសម្ព័ន្ធ

សហគ្រាសត្រូវមានក្រុមប្រឹក្សាភិបាលមួយរូប អគ្គនាយកមួយរូប និងបុគ្គលិកមួយចំនួនដែលចាំបាច់ ដើម្បីអនុវត្តមុខងាររបស់ខ្លួន។

## មាត្រា៥
## ក្រុមប្រឹក្សាភិបាល

១. ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិក១៥នាក់ ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយអង្គសន្និបាត អនុលោមតាម កថាខណ្ឌទី២(គ)នៃមាត្រា១៦០។ ក្នុងការបោះឆ្នោតសមាជិកក្រុមប្រឹក្សាភិបាល ត្រូវយកចិត្តទុកដាក់លើគោលការណ៍បែងចែកតាមភូមិសាស្ត្រឱ្យបានត្រឹមត្រូវ។ ក្នុងការដាក់ឈ្មោះបេក្ខជនឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាភិបាល សមាជិកនៃអាជ្ញាធរត្រូវចងចាំពីសេចក្តីត្រូវការត្រូវជ្រើសតាំងបេក្ខជនដែលមានកម្រិតសមត្ថភាពខ្ពស់បំផុត ដោយមានលក្ខណៈសម្បត្តិក្នុងវិស័យពាក់ព័ន្ធ ដើម្បីធានានូវលទ្ធភាព និងជោគជ័យរបស់សហគ្រាស។

២. សមាជិកក្រុមប្រឹក្សាភិបាលត្រូវបោះឆ្នោតសម្រាប់អាណត្តិ ៤ ឆ្នាំ ហើយអាចត្រូវបោះឆ្នោតជាថ្មីបាន។ ហើយត្រូវយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវលើគោលការណ៍ប្តូរវេនសមាជិកភាព។

៣. សមាជិកក្រុមប្រឹក្សាភិបាលត្រូវបន្តកាន់តំណែងរហូតទាល់តែអ្នកបន្តវេនត្រូវបានបោះឆ្នោត។ ប្រសិនបើតំណែងសមាជិកក្រុមប្រឹក្សាណាម្នាក់នៅទំនេរ អង្គសន្និបាតត្រូវជ្រើសរើសសមាជិកថ្មីឱ្យកាន់តំណែងសម្រាប់អាណត្តិដែលនៅសល់ អនុលោមតាមកថាខណ្ឌទី២(គ) នៃមាត្រា១៦០ ។

៤. សមាជិកក្រុមប្រឹក្សាភិបាលត្រូវធ្វើសកម្មភាពក្នុងមុខតំណែងរបស់ខ្លួន។ ក្នុងការបំពេញករណីកិច្ចសមាជិកមិនត្រូវស្វែងរក ឬទទួលសេចក្តីណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយឡើយ។ សមាជិកនីមួយៗនៃអាជ្ញាធរត្រូវគោរពឯករាជ្យភាពរបស់សមាជិកក្រុមប្រឹក្សាភិបាល ហើយមិនត្រូវខិតខំជះឥទ្ធិពលលើសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ក្នុងការបំពេញករណីកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាលឡើយ។

៥. សមាជិកក្រុមប្រឹក្សាភិបាលនីមួយៗត្រូវទទួលប្រាក់បៀវត្ស ដែលត្រូវបង់ចេញពីមូលនិធិរបស់សហគ្រាស។ ចំនួនប្រាក់បៀវត្សត្រូវកំណត់ដោយអង្គសន្និបាត តាមអនុសាសន៍របស់ក្រុមប្រឹក្សា។

៦. ក្រុមប្រឹក្សាភិបាលត្រូវដំណើរការជាធម្មតា នៅទីស្នាក់ការរបស់សហគ្រាស និងត្រូវជួបប្រជុំឱ្យបានញឹកញាប់ដូចដែលកិច្ចការរបស់សហគ្រាសអាចតម្រូវឱ្យជួបប្រជុំ។

៧. សមាជិក ២ ភាគ ៣ នៃក្រុមប្រឹក្សាភិបាលត្រូវបង្កើតជាកូរ៉ុម។

៨. សមាជិកក្រុមប្រឹក្សាភិបាលនីមួយៗត្រូវមានសំឡេងឆ្នោត ១។ រាល់កិច្ចការទាំងអស់ដែលដាក់នៅចំពោះមុខក្រុមប្រឹក្សាភិបាលត្រូវសម្រេចដោយសំឡេងភាគច្រើនរបស់សមាជិក។ ប្រសិនបើសមាជិកណាម្នាក់មានទំនាស់ផលប្រយោជន៍លើបញ្ហាណាមួយដែលដាក់នៅចំពោះមុខក្រុមប្រឹក្សាភិបាលមិនត្រូវបោះឆ្នោតលើបញ្ហានោះឡើយ។

៩. សមាជិកណាម្នាក់នៃអាជ្ញាធរអាចស្នើសុំព័ត៌មានពីក្រុមប្រឹក្សាភិបាលទាក់ទងនឹងប្រតិបត្តិការរបស់ក្រុមប្រឹក្សាភិបាលដែលប៉ះពាល់ដល់សមាជិកនោះ។ ក្រុមប្រឹក្សាភិបាលត្រូវខិតខំផ្តល់ព័ត៌មាននោះ។

xxx

## មាត្រា៦
## អំណាចនិងមុខងាររបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវដឹកនាំប្រតិបត្តិការរបស់សហគ្រាស។ ស្ថិតក្រោមអនុសញ្ញានេះ ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តអំណាចដែលចាំបាច់ដើម្បីបំពេញគោលបំណងរបស់សហគ្រាស ដែលរួមមានអំណាច៖

(ក) បោះឆ្នោតជ្រើសរើសប្រធានពីចំណោមសមាជិក ។

(ខ) អនុម័តវិធានច្បាប់នីតិវិធី ។

(គ) ព្រាងនិងដាក់ផែនការការងារជាលាយលក្ខណ៍អក្សរផ្លូវការជូនក្រុមប្រឹក្សា អនុលោមតាមកថាខណ្ឌទី៣ នៃមាត្រា១៥៣ និង កថាខណ្ឌទី២(ញ)នៃមាត្រា១៦២។

(ឃ) រៀបចំផែនការការងារ និងកម្មវិធីដើម្បីអនុវត្តសកម្មភាពដែលចែងក្នុងមាត្រា១៧០

(ង) រៀបចំនិងដាក់ពាក្យស្នើសុំការអនុញ្ញាតផលិតកម្មជូនក្រុមប្រឹក្សា អនុលោមតាមកថាខណ្ឌទី២ ទៅទី៧ នៃមាត្រា១៥១។

(ច) អនុញ្ញាតការចរចារទាក់ទងនឹងការទទួលបច្ចេកវិទ្យាដែលរួមមានបច្ចេកវិទ្យាដូចចែងក្នុងកថាខណ្ឌទី៣(ក) (គ) និង (ឃ) មាត្រា៥ នៃឧបសម្ព័ន្ធ៣ និងអនុម័តលើលទ្ធផលនៃការចរចាទាំងនោះ។

(ឆ) បង្កើតប្រការ និងលក្ខខណ្ឌ និងអនុញ្ញាតការចរចាទាក់ទងនឹងការវិនិយោគរួមទុន និងកិច្ចសហប្រតិបត្តិអាជីវកម្មក្រោមរូបភាពដទៃទៀតដែលលើកឡើងក្នុងមាត្រា៩ និងមាត្រា១១ នៃឧបសម្ព័ន្ធទី៣ និងអនុម័តលើលទ្ធផលនៃកិច្ចចរចាទាំងនោះ។

(ជ) ផ្តល់អនុសាសន៍ដល់អង្គសន្និបាតថាតើចំណែកចំណូលសុទ្ធរបស់សហគ្រាសគួររក្សាទុកជាមូលនិធិបម្រុង អនុលោមតាមកថាខណ្ឌទី២(ច) នៃមាត្រា១៦០ និងមាត្រា១០ នៃឧបសម្ព័ន្ធនេះ។

(ឈ) ឯកភាពលើថវិកាប្រចាំឆ្នាំរបស់សហគ្រាស។

(ញ) អនុញ្ញាតលើការងារលទ្ធកម្មទំនិញនិងសេវាកម្ម អនុលោមតាមកថាខណ្ឌទី៣ នៃមាត្រា១២ នៃឧបសម្ព័ន្ធនេះ។

(ដ) ដាក់របាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សា អនុលោមតាមមាត្រា៩ នៃឧបសម្ព័ន្ធនេះ។

(ឋ) ដាក់សេចក្តីព្រាងវិធានច្បាប់ទាក់ទងនឹងការរៀបចំ ការគ្រប់គ្រង ការតែងតាំង និងការបញ្ឈប់បុគ្គលិករបស់សហគ្រាសជូនក្រុមប្រឹក្សា ដើម្បីទទួលបានការអនុម័តពីអង្គសន្និបាត ហើយអនុម័តបទប្បញ្ញត្តិដើម្បីផ្តល់សុពលភាពលើវិធានច្បាប់នោះ។

(ឌ) ខ្ចីប្រាក់ និងដាក់វត្ថុបញ្ចាំ ឬប្រាតិភោគដទៃទៀត ដូចដែលខ្លួនអាចកំណត់អនុលោមតាមមាត្រា១១ កថាខណ្ឌទី២ នៃឧបសម្ព័ន្ធនេះ។

(ឍ) ចូលរួមក្នុងនីតិវិធីច្បាប់ ចុះកិច្ចព្រមព្រៀង និងប្រតិបត្តិការ និងចាត់វិធានច្បាប់ដទៃទៀត អនុលោមតាមមាត្រា១៣ នៃឧបសម្ព័ន្ធនេះ

(ណ) ប្រគល់អំណាចមិនដាច់ខាតទៅឱ្យអគ្គនាយក និងគណៈកម្មាធិការរបស់ខ្លួន ដោយស្ថិតក្រោមលក្ខខណ្ឌទទួលបានការឯកភាពពីក្រុមប្រឹក្សា។

## មាត្រា៧

## អគ្គនាយក និងបុគ្គលិករបស់សហគ្រាស

១. តាមអនុសាសន៍របស់ក្រុមប្រឹក្សា និងការជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល អង្គសន្និបាតត្រូវបោះឆ្នោតជ្រើសរើសអគ្គនាយកសហគ្រាស ដែលមិនមែនជាសមាជិកនៃក្រុមប្រឹក្សាភិបាល។ អគ្គនាយកត្រូវកាន់តំណែង សម្រាប់អាណត្តិជាកំណត់ ដែលមិនត្រូវលើសពី ៥ ឆ្នាំឡើយ ហើយអាចត្រូវបានបោះឆ្នោតជ្រើសរើសជាថ្មី សម្រាប់អាណត្តិបន្ថែមទៀត។

២. អគ្គនាយកត្រូវជាតំណាងផ្លូវច្បាប់ និងជាប្រធានប្រតិបត្តិរបស់សហគ្រាស ហើយត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខក្រុមប្រឹក្សាភិបាលលើប្រតិបត្តិការរបស់សហគ្រាស។ អគ្គនាយកត្រូវទទួលខុសត្រូវលើការរៀបចំ ការគ្រប់គ្រង ការតែងតាំង និងការបញ្ឈប់បុគ្គលិកសហគ្រាស អនុលោមតាមវិធានច្បាប់ និងបទប្បញ្ញត្តិដែលលើកឡើងក្នុងកថាខណ្ឌរង (ឋ) មាត្រា៦ នៃឧបសម្ព័ន្ធនេះ។ អគ្គនាយកត្រូវចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយគ្មានសិទ្ធិបោះឆ្នោត ហើយអាចចូលរួមក្នុងកិច្ចប្រជុំអង្គសន្និបាតនិងក្រុមប្រឹក្សាដោយគ្មានសិទ្ធិបោះឆ្នោតនៅពេលស្ថាប័នទាំងនេះពិភាក្សាលើបញ្ហាទាក់ទងនឹងសហគ្រាស។

៣. ក្នុងការជ្រើសរើសនិងជួលបុគ្គលិក និងក្នុងការកំណត់លក្ខខណ្ឌសេវាកម្ម ត្រូវពិចារណាជាចម្បងលើភាពចាំបាច់ត្រូវធានាកម្រិតប្រសិទ្ធភាពខ្ពស់ និងសមត្ថភាពបច្ចេកទេស។ ស្ថិតក្រោមលក្ខខណ្ឌនៃការពិចារណានេះត្រូវយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវលើការជ្រើសរើសបុគ្គលិកឱ្យបានស្មើភាពគ្នាផ្អែកតាមភូមិសាស្ត្រ។

៤. ក្នុងការបំពេញករណីកិច្ចរបស់ខ្លួន អគ្គនាយកនិងបុគ្គលិកមិនត្រូវស្វែងរក ឬទទួលសេចក្ដីណែនាំពីរដ្ឋាភិបាល ឬប្រភពដទៃទៀតពីខាងក្រៅសហគ្រាសឡើយ។ អគ្គនាយកនិងបុគ្គលិកមិនត្រូវធ្វើសកម្មភាពណាមួយដែលអាចឆ្លុះបញ្ចាំងពីជំហររបស់ខ្លួនក្នុងឋានៈជាមន្ត្រីអន្តរជាតិនៃសហគ្រាសឡើយ ដោយអគ្គនាយកនិងបុគ្គលិកទទួលខុសត្រូវចំពោះសហគ្រាសតែមួយគត់។ រដ្ឋភាគីនីមួយៗសន្យាគោរពលក្ខណៈអន្តរជាតិនៃការទទួលខុសត្រូវរបស់អគ្គនាយកនិងបុគ្គលិក ហើយមិនត្រូវខិតខំជះឥទ្ធិពលលើអគ្គនាយកនិងបុគ្គលិកក្នុងការបំពេញករណីកិច្ចរបស់ពួកគេឡើយ។

៥. ការទទួលខុសត្រូវដែលចែងក្នុងកថាខណ្ឌទី២ នៃមាត្រា១៦៨ អនុវត្តស្មើភាពគ្នាចំពោះបុគ្គលិកសហគ្រាស។

## មាត្រា៨

## ទីតាំង

សហគ្រាសត្រូវមានការិយាល័យចម្បងនៅអាសនៈរបស់អាជ្ញាធរ។ សហគ្រាសអាចបង្កើតការិយាល័យដទៃទៀតក្នុងរដ្ឋភាគីណាមួយ ដោយមានការយល់ព្រមពីរដ្ឋភាគីនោះ។

## មាត្រា៩

## របាយការណ៍និងរបាយការណ៍ហិរញ្ញវត្ថុ

១. ក្នុងរយៈពេលមិនលើសពី ៣ ខែបន្ទាប់ពីចប់ឆ្នាំហិរញ្ញវត្ថុនីមួយៗ សហគ្រាសត្រូវដាក់របាយការណ៍ប្រចាំឆ្នាំ ក្នុងនោះមានរបាយការណ៍សវនកម្មគណនេយ្យជូនក្រុមប្រឹក្សាពិនិត្យ និងត្រូវបញ្ជូនរបាយការណ៍ខ្លីពីស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍ចំណេញនិងខាតបង់ដែលបង្ហាញលទ្ធផលនៃប្រតិបត្តិការរបស់ខ្លួនជូនក្រុមប្រឹក្សា ក្នុងរយៈពេលសមស្រប។

២.	សហគ្រាសត្រូវចុះផ្សាយរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ដទៃទៀត ដែលខ្លួនយល់ថាសមស្រប។

៣.	គ្រប់របាយការណ៍ និងរបាយការណ៍ហិរញ្ញវត្ថុទាំងអស់ ដែលលើកឡើងក្នុងមាត្រានេះ ត្រូវចែកជូនសមាជិកនៃអាជ្ញាធរ។

## មាត្រា១០

## ការបែងចែកផលចំណូលសុទ្ធ

១.	អនុលោមតាមកថាខណ្ឌទី៣ សហគ្រាសត្រូវបង់កម្រៃសួយសារជូនអាជ្ញាធរ តាមមាត្រា១៣ នៃឧបសម្ព័ន្ធ៣ ឬអ្វីផ្សេងទៀតដែលមានតម្លៃសមមូល។

២.	តាមអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល អង្គសន្និបាតត្រូវកំណត់ចំណែកខ្លះនៃចំណូលសុទ្ធរបស់សហគ្រាសត្រូវរក្សាទុកជាមូលនិធិបម្រុងរបស់សហគ្រាស។ ចំណូលដែលនៅសល់ត្រូវផ្ទេរទៅឱ្យអាជ្ញាធរ។

៣.	ក្នុងអំឡុងរយៈពេលដំបូងដែលមិនត្រូវលើសពី ១០ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមផលិតកម្មដែលមានលក្ខណៈពាណិជ្ជកម្មដោយសហគ្រាស ដែលតម្រូវឱ្យសហគ្រាសត្រូវមានលទ្ធភាពអាចឧបត្ថម្ភខ្លួនឯងបាន អង្គសន្និបាតត្រូវលើកលែងសហគ្រាសមិនឱ្យបង់ប្រាក់ដែលលើកឡើងក្នុងកថាខណ្ឌទី១ ហើយត្រូវទុករាល់ចំណូលសុទ្ធទាំងអស់របស់សហគ្រាសជាប្រាក់បម្រុងរបស់សហគ្រាស។

## មាត្រា១១

## ហិរញ្ញវត្ថុ

១.	មូលនិធិរបស់សហគ្រាសត្រូវរួមមាន ៖

(ក)	ចំនួនប្រាក់ដែលទទួលបានពីអាជ្ញាធរ អនុលោមតាមកថាខណ្ឌទី២ (ខ) នៃមាត្រា១៧៣។

(ខ)	វិភាគទានដោយស្ម័គ្រចិត្តដែលបង់ដោយរដ្ឋភាគី ក្នុងគោលបំណងដើម្បីគាំទ្រសកម្មភាពរបស់សហគ្រាស។

(គ)	ចំនួនប្រាក់ដែលសហគ្រាសខ្ចី អនុលោមតាមកថាខណ្ឌទី២ និងកថាខណ្ឌទី៣។

(ឃ)	ចំណូលរបស់សហគ្រាសពីប្រតិបត្តិការ។

(ង)	មូលនិធិដទៃទៀតដែលសហគ្រាសមាន ដើម្បីផ្តល់លទ្ធភាពដល់សហគ្រាសដើម្បីចាប់ផ្តើមប្រតិបត្តិការឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងដើម្បីអនុវត្តមុខងាររបស់ខ្លួន។

២.	(ក)	សហគ្រាសត្រូវមានសិទ្ធិអំណាចខ្ចីប្រាក់ និងដាក់វត្ថុធានា ឬប្រាតិភោគដទៃទៀតដែលខ្លួនអាចកំណត់។ មុនពេលដាក់លក់ជាសាធារណៈនូវកាតព្វកិច្ចរបស់ខ្លួននៅលើផ្សារហិរញ្ញវត្ថុ ឬរូបិយវត្ថុរបស់រដ្ឋភាគី សហគ្រាសត្រូវទទួលបានការឯកភាពពីរដ្ឋភាគីនោះ។ ចំនួនប្រាក់ខ្ចីសរុបត្រូវមានការឯកភាពពីក្រុមប្រឹក្សាតាមអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល។

(ខ)	រដ្ឋភាគីត្រូវខិតខំប្រឹងប្រែងគ្រប់មធ្យោបាយសមស្របទាំងអស់ ដើម្បីជួយដល់ការដាក់ពាក្យខ្ចីប្រាក់ដោយសហគ្រាសពីផ្សារមូលធន និងពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ។

៣. (ក) សហគ្រាសត្រូវទទួលបានមូលនិធិដែលចាំបាច់ដើម្បីស្វែងរុករកនិងធ្វើអាជីវកម្មនៅការដ្ឋានរ៉ែមួយ ហើយដឹកជញ្ជូន ធ្វើប្រព្រឹត្តិកម្មនិងលក់រ៉ែដែលទាញយកបានពីការដ្ឋាននោះ និងនីកែល ទង់ដែង កូបាល់ និងម៉ង់កាណែស ព្រមទាំងបង់ការចំណាយរដ្ឋបាលដំបូងរបស់ខ្លួន។ ចំនួនមូលនិធិនោះ និងលក្ខណវិនិច្ឆ័យ និងកត្តាកែតម្រូវ ត្រូវដាក់បញ្ចូលដោយគណៈកម្មការត្រៀមរៀបចំ ទៅក្នុងសេចក្ដីព្រាងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

(ខ) រដ្ឋភាគីទាំងអស់ត្រូវបង់សហគ្រាសចំនួនប្រាក់ស្មើនឹងពាក់កណ្ដាលនៃមូលនិធិដែលចែងក្នុងកថាខណ្ឌរង(ក) តាមរយៈកម្ចីគ្មានការប្រាក់រយៈពេលវែង អនុលោមតាមទំហំនៃការវាយតម្លៃ សម្រាប់ថវិកាជាប្រចាំរបស់អង្គការសហប្រជាជាតិដែលនៅជាធរមានពេលធ្វើការវាយតម្លៃនោះ ដែលកែតម្រូវពិចារណាលើរដ្ឋដែលមិនមែនជាសមាជិកអង្គការសហប្រជាជាតិ។ បំណុលដែល បង្កើតឡើងដោយសហគ្រាសក្នុងការរកមូលនិធិពាក់កណ្ដាលទៀត ត្រូវធានាដោយរដ្ឋភាគីទាំងអស់ អនុលោមតាមទំហំដដែលនៃការវាយតម្លៃនោះ។

(គ) ប្រសិនបើចំនួនប្រាក់វិភាគទានរបស់រដ្ឋភាគីមានចំនួនតិចជាងមូលនិធិ ដែលផ្ដល់ឱ្យសហគ្រាសតាមកថាខណ្ឌរង(ក) អង្គសន្និបាតត្រូវពិចារណាកម្រិតខ្វះខាត ក្នុងសម័យប្រជុំដំបូងរបស់ខ្លួន ហើយអនុម័តដោយមតិរួមលើវិធានច្បាប់ការដោះស្រាយបញ្ហាខ្វះខាតនេះ ដោយពិចារណាកាតព្វកិច្ចរបស់រដ្ឋភាគីតាមកថាខណ្ឌរង(ក) និង(ខ) និងអនុសាសន៍របស់គណៈកម្មការត្រៀមរៀបចំ។

(ឃ) (i) ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន ឬក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីដាក់លិខិតូបករណ៍នៃការផ្ដល់សច្ចាប័ន ឬលិខិតូបករណ៍ចូលជាភាគី មួយណាក៏ដោយដែលកើតក្រោយគេ រដ្ឋភាគីនីមួយៗត្រូវដាក់តម្កល់ លិខិតសន្យាគ្មានការប្រាក់ មិនអាចផ្ទេរបាន និងមិនអាចលុបចោលបាន នៅនឹងសហគ្រាស ដែលមានចំនួនជាកម្ចីគ្មានការប្រាក់នៃ ចំណែករបស់រដ្ឋភាគី អនុលោមតាមកថាខណ្ឌរង(ខ)។

(ii) ក្រុមប្រឹក្សាភិបាលត្រូវរៀបចំតារាងបង្ហាញពីទំហំ និងពេលវេលាសម្រាប់ហិរញ្ញប្បទានបង់លើចំណាយរដ្ឋបាលរបស់ខ្លួន និងសកម្មភាពដែលអនុវត្តដោយសហគ្រាស អនុលោមតាមមាត្រា១៧០ ផ្នែកទី១២ នៃឧបសម្ព័ន្ធនេះ ក្នុងពេលឆាប់ៗបន្ទាប់ពីអនុសញ្ញាចូលជាធរមាន និងនៅពេលក្រោយៗមកជាប្រចាំឆ្នាំ ឬក្នុងអំឡុងរយៈពេលសមស្របដទៃទៀត។

(iii) រដ្ឋភាគីត្រូវទទួលបានការជូនដំណឹងពីសហគ្រាសតាមរយៈអាជ្ញាធរ អំពីចំណែកមូលនិធិរៀងៗខ្លួន អនុលោមតាមកថាខណ្ឌរង(ខ) ដែលត្រូវការសម្រាប់ការចំណាយ។ សហគ្រាសត្រូវប្ដូរលិខិតសន្យាជាសាច់ប្រាក់ ដែលអាចត្រូវការដើម្បីបង់ការចំណាយ លើកឡើងក្នុងតារាងទាក់ទងនឹងកម្ចីគ្មានការប្រាក់។

(iv) នៅពេលទទួលបានសេចក្ដីជូនដំណឹងរួច រដ្ឋភាគីត្រូវផ្ដល់លិខិតធានាបំណុលក្នុងចំនួនជាចំណែករបស់ខ្លួនឱ្យសហគ្រាស អនុលោមតាមលិខិតធានាបំណុលក្នុងកថាខណ្ឌរង(ខ)។

(ង) (i) ប្រសិនបើសហគ្រាសស្នើសុំ រដ្ឋភាគីអាចផ្តល់លិខិតធានាបំណុលបន្ថែមពីលើមូលនិធិដែលផ្តល់តាមទំហំនៃការវាយតម្លៃ ក្នុងកថាខណ្ឌរង(ខ)។

(ii) ជំនួសលិខិតធានាបំណុល រដ្ឋភាគីអាចបង់វិភាគទានស្ម័គ្រចិត្តដល់សហគ្រាសក្នុងចំនួនដែលស្មើនឹងចំណែកបំណុលនោះ ដែលខ្លួនទទួលខុសត្រូវធានា។

(ច) ការបង់សងបំណុលមានការប្រាក់ត្រូវមានអាទិភាពលើការបង់សងបំណុលដទៃទៀត។ ការបង់សងបំណុលគ្មានការប្រាក់ត្រូវធ្វើឡើងអនុលោមតាមតារាងដែលអនុម័តដោយអង្គសន្និបាត តាមអនុសាសន៍របស់ក្រុមប្រឹក្សា និងយោបល់របស់ក្រុមប្រឹក្សាភិបាល។ ក្នុងការអនុវត្តមុខងារនេះ ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តតាម បទប្បញ្ញត្តិ វិធានច្បាប់ បទបញ្ជា និងនីតិវិធីពាក់ព័ន្ធរបស់អាជ្ញាធរ ដែលត្រូវពិចារណាពីសារសំខាន់ត្រូវធានាឱ្យមានដំណើរការប្រកបដោយប្រសិទ្ធភាពរបស់សហគ្រាស និងជាពិសេសត្រូវធានាឯករាជ្យភាពហិរញ្ញវត្ថុរបស់សហគ្រាស។

(ឆ) មូលនិធិដែលមានសម្រាប់សហគ្រាសត្រូវជារូបិយវត្ថុដែលមានដោយសេរី និងអាចប្រើប្រាស់បានប្រកបដោយប្រសិទ្ធភាពនៅលើទីផ្សារប្តូរប្រាក់អន្តរជាតិចម្បង។ រូបិយវត្ថុទាំងនេះត្រូវកំណត់នៅក្នុងវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ អនុលោមតាមទម្លាប់អនុវត្តផ្នែករូបិយវត្ថុអន្តរជាតិនាពេលបច្ចុប្បន្ន។ លើកលែងតែដូចមានចែងក្នុងកថាខណ្ឌទី២ គ្មានរដ្ឋភាគីណាត្រូវរក្សា ឬដាក់កម្រិតលើការកាន់កាប់ ប្រើប្រាស់ ឬផ្លាស់ប្តូរមូលនិធិទាំងនេះដោយសហគ្រាសឡើយ។

(ជ) "លិខិតធានាបំណុល" គឺជាលិខិតសន្យារបស់រដ្ឋភាគីចំពោះម្ចាស់ឥណទានរបស់សហគ្រាសដោយសន្យាបង់ កាតព្វកិច្ចហិរញ្ញវត្ថុរបស់សហគ្រាសដែលធានាដោយលិខិតធានានេះ តាមសមាមាត្រអនុលោមតាមទំហំសមស្រប បន្ទាប់ពីម្ចាស់ឥណទានជូនដំណឹងរដ្ឋភាគីអំពីការខកខាន ដោយសហគ្រាស។ នីតិវិធីបង់ប្រាក់លើកាតព្វកិច្ចទាំងនោះត្រូវអនុលោមតាមវិធានច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីរបស់អាជ្ញាធរ។

៤. មូលនិធិ ទ្រព្យសកម្ម និងការចំណាយរបស់សហគ្រាសត្រូវរក្សាទុកដោយឡែកពីមូលនិធិ ទ្រព្យសកម្ម និងការចំណាយរបស់អាជ្ញាធរ។ មាត្រា១ មិនរារាំងសហគ្រាសមិនឱ្យធ្វើការព្រមព្រៀងជាមួយនឹងអាជ្ញាធរទាក់ទងនឹងឋបនភណ្ឌ បុគ្គលិក និងសេវាកម្ម និងការព្រមព្រៀងបង់សងលើការចំណាយរដ្ឋបាលដែលបង់ដោយសហគ្រាស ឬអាជ្ញាធរដែលជាតំណាងឱ្យភាគីម្ខាងទៀត។

៥. កំណត់ត្រា សៀវភៅ និងបញ្ជីរបស់សហគ្រាស រាប់បញ្ចូលទាំងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវធ្វើសវនកម្មជាប្រចាំឆ្នាំ ដោយសវនករឯករាជ្យដែលតែងតាំងដោយក្រុមប្រឹក្សា។

## មាត្រា១២
## ប្រតិបត្តិការ

១. សហគ្រាសត្រូវស្នើគម្រោងអនុវត្តសកម្មភាពអនុលោមតាមមាត្រា១៧០ ជូនក្រុមប្រឹក្សា។ សំណើនោះត្រូវរាប់បញ្ចូលផែនការការងារជាលាយលក្ខណ៍អក្សរជាផ្លូវការសម្រាប់សកម្មភាពនៅតំបន់ អនុលោមតាមកថាខណ្ឌទី៣ នៃមាត្រា១៥៣ ព្រមទាំងរាល់ព័ត៌មាននិងទិន្នន័យដទៃទៀត ដែលអាចតម្រូវតាមភាពជាក់ស្តែងសម្រាប់ការវាយតម្លៃដោយគណៈកម្មការបច្ចេកទេសនិងច្បាប់ សម្រាប់ការឯកភាពពីក្រុមប្រឹក្សា។

២. នៅពេលក្រុមប្រឹក្សាឯកភាព សហគ្រាសត្រូវអនុវត្តគម្រោងផ្អែកតាមផែនការការងារជាលាយលក្ខណ៍អក្សរជាផ្លូវការដែលចែងក្នុងកថាខណ្ឌទី១។

៣. (ក) ប្រសិនបើសហគ្រាសមិនមានទំនិញនិងសេវាកម្ម ដែលត្រូវការសម្រាប់ប្រតិបត្តិការរបស់ខ្លួនទេនោះ សហគ្រាសអាចធ្វើលទ្ធកម្មបាន។ ក្នុងគោលបំណងលទ្ធកម្មនោះ សហគ្រាសត្រូវអញ្ជើញឱ្យមានការដេញថ្លៃ និងប្រគល់កិច្ចសន្យាដល់អ្នកដេញថ្លៃដែលផ្តល់គុណភាព តម្លៃ និងពេលប្រគល់បានល្អប្រសើរបំផុត។

(ខ) ប្រសិនបើមានការដេញថ្លៃច្រើនជាងមួយដែលផ្តល់គុណភាព តម្លៃ និងពេលប្រគល់បានល្អប្រសើរបំផុត សហគ្រាសត្រូវប្រគល់កិច្ចសន្យា អនុលោមតាម៖

(i) គោលការណ៍មិនរើសអើងខាងនយោបាយ ឬការពិចារណាដទៃទៀត ដែលមិនពាក់ព័ន្ធនឹងការអនុវត្តការងារប្រកបដោយការយកចិត្តទុកដាក់និងប្រសិទ្ធភាព និង

(ii) សេចក្តីណែនាំដែលបានអនុម័តដោយក្រុមប្រឹក្សាទាក់ទងនឹងបុរេមាដែលត្រូវផ្តល់ដល់ទំនិញនិងសេវាកម្មដែលមានប្រភពពីរដ្ឋកំពុងអភិវឌ្ឍន៍ ដែលរួមមានរដ្ឋមិនជាប់សមុទ្រនិងរដ្ឋដែលភូមិសាស្ត្រមិនអំណោយផល។

(គ) ក្រុមប្រឹក្សាភិបាលអាចអនុម័តវិធានច្បាប់ដែលកំណត់ស្ថានការណ៍ពិសេស ដែលអាចលះបង់លក្ខខណ្ឌអញ្ជើញចូលរួមដេញថ្លៃ ដែលជាប្រយោជន៍ល្អប្រសើរបំផុតរបស់សហគ្រាស។

៤. សហគ្រាសត្រូវមានសិទ្ធិកម្មសិទ្ធិលើរ៉ែ និងសារធាតុដែលបានធ្វើប្រព្រឹត្តិកម្មទាំងអស់ដែលខ្លួនផលិតបាន។

៥. សហគ្រាសត្រូវលក់ទំនិញរបស់ខ្លួនដោយគ្មានការរើសអើង។ សហគ្រាសមិនត្រូវផ្តល់ការបញ្ចុះតម្លៃដែលមិនមានលក្ខណៈពាណិជ្ជកម្ម។

៦. ដោយមិនប៉ះពាល់ដល់សិទ្ធិអំណាចទូទៅ ឬពិសេសដែលប្រគល់ឱ្យសហគ្រាស ក្រោមបទប្បញ្ញត្តិដទៃណាមួយក្នុងអនុសញ្ញានេះ សហគ្រាសត្រូវអនុវត្តសិទ្ធិអំណាចដែលកើតចេញពីអាជីវកម្មរបស់ខ្លួន តាមភាពចាំបាច់។

៧. សហគ្រាសមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការនយោបាយរបស់រដ្ឋភាគី ហើយក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន សហគ្រាសក៏មិនត្រូវទទួលឥទ្ធិពលនយោបាយពីរដ្ឋភាគីពាក់ព័ន្ធផងដែរ។ មានតែការពិចារណាខាងពាណិជ្ជកម្មប៉ុណ្ណោះដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន ហើយការពិចារណាទាំងនេះត្រូវថ្លឹងថ្លែងដោយគ្មានលំអៀង ដើម្បីអនុវត្តគោលបំណងដែលចែងក្នុងមាត្រា១ នៃឧបសម្ព័ន្ធនេះ។

## មាត្រា១៣

## ស្ថានភាពគតិយុត្ត បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

១. ដើម្បីផ្ដល់លទ្ធភាពដល់សហគ្រាសក្នុងការអនុវត្តមុខងាររបស់ខ្លួន ឋានៈ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលចែងក្នុងមាត្រានេះត្រូវប្រគល់ឱ្យសហគ្រាសក្នុងទឹកដីរបស់រដ្ឋភាគី។ ដើម្បីបង្កើតប្រសិទ្ធភាពដល់គោលការណ៍នេះ សហគ្រាសនិងរដ្ឋភាគីអាចចុះកិច្ចព្រមព្រៀងពិសេស ប្រសិនបើចាំបាច់។

២. សហគ្រាសមានសមត្ថភាពផ្លូវច្បាប់ដែលចាំបាច់ដើម្បីអនុវត្តមុខងាររបស់ខ្លួន និងសម្រេចគោលបំណងរបស់ខ្លួន ហើយជាពិសេស មានសមត្ថភាព ៖

(ក) ចុះកិច្ចសន្យា កិច្ចការរួម ឬកិច្ចការដទៃទៀត ក្នុងនោះមានកិច្ចព្រមព្រៀងជាមួយរដ្ឋ និងអង្គការអន្តរជាតិ។

(ខ) ទិញយក ជួល កាន់កាប់ និងលក់អចលនទ្រព្យ និងចលនទ្រព្យ។

(គ) ធ្វើជាភាគីនៅក្នុងនីតិវិធីបណ្ដឹង។

៣. (ក) បណ្ដឹងអាចធ្វើឡើងប្រឆាំងនឹងសហគ្រាសតែក្នុងតុលាការមានសមត្ថកិច្ចក្នុងទឹកដីរដ្ឋភាគីដែលសហគ្រាស៖

(i) មានការិយាល័យ ឬបរិក្ខណ្ឌ។

(ii) បានតែងតាំងភ្នាក់ងារក្នុងគោលបំណងទទួលយកសេវាកម្ម ឬការជូនដំណឹងពីនីតិវិធី។

(iii) បានចុះកិច្ចសន្យាចំពោះទំនិញ ឬសេវាកម្ម។

(iv) បានចេញមូលបត្រ ឬ

(v) បានធ្វើសកម្មភាពពាណិជ្ជកម្ម។

(ខ) ទ្រព្យសម្បត្តិនិងទ្រព្យសកម្មរបស់សហគ្រាស ទោះនៅទីកន្លែងណាក៏ដោយ និងកាន់កាប់ដោយអ្នកណាក៏ដោយ ត្រូវមានអភ័យឯកសិទ្ធិពីរាល់ការរឹបអូស ឃាត់ទុក ឬការអនុវត្តដីកាគ្រប់រូបភាពទាំងអស់មុនពេលប្រគល់សេចក្ដីសម្រេចស្ថាពរប្រឆាំងសហគ្រាស។

៤. (ក) ទ្រព្យសម្បត្តិនិងទ្រព្យសកម្មរបស់សហគ្រាស ទោះនៅទីកន្លែងណាក៏ដោយ និងកាន់កាប់ដោយអ្នកណាក៏ដោយ ត្រូវមានអភ័យឯកសិទ្ធិពីរាល់ការស្នើយក ការរឹបអូស អស្សាមិករណ៍ ឬការរឹបអូសក្នុងរូបភាពផ្សេងទៀត ដោយចំណាត់ការអង្គនីតិប្រតិបត្តិ ឬអង្គនីតិបទប្បញ្ញត្តិ។

(ខ) ទ្រព្យសម្បត្តិនិងទ្រព្យសកម្មរបស់សហគ្រាស ទោះនៅទីកន្លែងណាក៏ដោយ និងកាន់កាប់ដោយអ្នកណាក៏ដោយ ត្រូវមានអភ័យសិទ្ធិពីការកំហិត បទប្បញ្ញត្តិ ការគ្រប់គ្រង ការបង្អាក់ប្រភេទណាក៏ដោយដែលមានលក្ខណៈរើសអើង។

(គ) សហគ្រាសនិងបុគ្គលិករបស់ខ្លួនត្រូវគោរពច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក នៅក្នុងរដ្ឋ ឬទឹកដីដែលសហគ្រាសឬបុគ្គលិកសហគ្រាសអាចធ្វើអាជីវកម្ម ឬក៏ធ្វើសកម្មភាព។

(ឃ) រដ្ឋភាគីត្រូវធានាថា សហគ្រាសមានសិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងអស់ដែលរដ្ឋបានផ្តល់ឱ្យអង្គភាពនានាដែលធ្វើសកម្មភាពពាណិជ្ជកម្មក្នុងទឹកដីរបស់រដ្ឋ។ សិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងនេះត្រូវផ្តល់ឱ្យសហគ្រាស ក្នុងលក្ខណៈដូចគ្នានឹងសិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលរដ្ឋភាគីបានផ្តល់ឱ្យអង្គភាពនានាដែលធ្វើពាណិជ្ជកម្មស្រដៀងគ្នា។ ប្រសិនបើរដ្ឋភាគីផ្តល់បុព្វសិទ្ធិពិសេសដល់រដ្ឋកំពុងអភិវឌ្ឍន៍ ឬអង្គភាពពាណិជ្ជកម្មរបស់រដ្ឋកំពុងអភិវឌ្ឍនោះ សហគ្រាសត្រូវទទួលបានបុព្វសិទ្ធិទាំងនោះក្នុងលក្ខខណ្ឌពិសេសដូចគ្នា។

(ង) រដ្ឋភាគីអាចផ្តល់ការលើកទឹកចិត្ត សិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិពិសេសដល់សហគ្រាស ដោយមិនមានកាតព្វកិច្ចផ្តល់ការលើកទឹកចិត្ត សិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិពិសេសដល់អង្គភាពពាណិជ្ជកម្មដទៃទៀតឡើយ។

៥. សហគ្រាសត្រូវធ្វើការចរចាជាមួយនឹងប្រទេសម្ចាស់ផ្ទះ ដែលខ្លួនតាំងការិយាល័យ និងបរិក្ខារនៅប្រទេសនោះ ដើម្បីទទួលបានការលើកលែងពន្ធផ្ទាល់ និងប្រយោល។

៦. រដ្ឋភាគីនីមួយៗត្រូវចាត់វិធានច្បាប់ការចាំបាច់ ដែលចាំបាច់ដើម្បីផ្តល់ប្រសិទ្ធភាពដល់គោលការណ៍ដែលចែងក្នុងឧបសម្ព័ន្ធនេះ តាមលក្ខខណ្ឌច្បាប់ក្នុងស្រុករបស់ខ្លួន ហើយត្រូវជូនដំណឹងដល់សហគ្រាសអំពីវិធានច្បាប់ជាក់លាក់ដែលបានធ្វើនោះ។

៧. សហគ្រាសអាចលះបង់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិណាមួយ ដែលចែងក្នុងមាត្រានេះ ឬកិច្ចព្រមព្រៀងពិសេស ដែលលើកឡើងក្នុងកថាខណ្ឌទី១ ដល់កម្រិតនិងក្នុងលក្ខខណ្ឌដែលខ្លួនអាចកំណត់។

**ឧបសម្ព័ន្ធទី៥**

**ភាពផ្សះផ្សា**

**ផ្នែកទី១**

**នីតិវិធីផ្សះផ្សាអនុលោមតាមផ្នែកទី១ នៃជំពូកទី១៥**

មាត្រា១

**ការផ្ដើមនីតិវិធី**

អនុលោមតាមមាត្រា២៨៤ ប្រសិនបើបណ្ដាភាគីវិវាទបានព្រមព្រៀងគ្នាក្នុងការដាក់វិវាទទៅធ្វើការផ្សះផ្សាក្រោមផ្នែកនេះ ភាគីណាមួយអាចផ្ដើមនីតិវិធីបានតាមរយៈសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ភាគីវិវាទមួយឬច្រើនម្ខាងទៀត។

មាត្រា២

**បញ្ជីឈ្មោះអ្នកផ្សះផ្សា**

បញ្ជីឈ្មោះអ្នកផ្សះផ្សាត្រូវរៀបចំឡើងនិងរក្សាទុកដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។ រាល់រដ្ឋភាគីនីមួយៗមានសិទ្ធិជ្រើសតាំងអ្នកផ្សះផ្សា ៤រូប ដែលម្នាក់ៗត្រូវជាបុគ្គលដែលមានកេរ្តិ៍ឈ្មោះល្អបំផុតខាងយុត្តិធម៌ មានសមត្ថភាពនិងសុចរិតភាព។ ឈ្មោះបុគ្គលដែលត្រូវបានជ្រើសតាំងនោះ បង្កើតបានជាបញ្ជីឈ្មោះ។ ប្រសិនបើនៅពេលណាមួយដែលអ្នកផ្សះផ្សាដែលត្រូវបានជ្រើសតាំងដោយរដ្ឋភាគីនៅក្នុងបញ្ជីឈ្មោះនោះមានចំនួនតិចជាង ៤ រូប រដ្ឋភាគីមានសិទ្ធិជ្រើសតាំងបន្ថែមទៀតតាមការចាំបាច់។ ឈ្មោះអ្នកផ្សះផ្សាម្នាក់ត្រូវមាននៅក្នុងបញ្ជីឈ្មោះរហូតដល់រដ្ឋភាគីដែលបានធ្វើការជ្រើសតាំងអ្នកផ្សះផ្សានោះបានដកឈ្មោះខ្លួនចេញ ប៉ុន្តែអ្នកផ្សះផ្សាដែលត្រូវបានដកចេញនោះត្រូវបន្តការងាររបស់ខ្លួនក្នុងគណៈកម្មការផ្សះផ្សាណាមួយដែលខ្លួនត្រូវបានជ្រើសតាំងរហូតទាល់តែនីតិវិធីផ្សះផ្សានៅក្នុងគណៈកម្មការនោះត្រូវបានបញ្ចប់។

មាត្រា៣

**ការបង្កើតគណៈកម្មការផ្សះផ្សា**

ប្រសិនបើគ្មានការព្រមព្រៀងផ្សេងដោយភាគីទេនោះ គណៈកម្មការផ្សះផ្សាត្រូវបង្កើតឡើងដូចខាងក្រោម៖

(ក) ដោយស្ថិតក្រោមលក្ខខណ្ឌនៃកថាខណ្ឌរង (ឆ) គណៈកម្មការផ្សះផ្សាត្រូវមានសមាជិក៥រូប។

(ខ) ភាគីដែលផ្ដើមនីតិវិធីផ្សះផ្សាត្រូវចាត់តាំងអ្នកផ្សះផ្សាពីររូប ដែលត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះដូចមានចែងក្នុងមាត្រា២ នៃឧបសម្ព័ន្ធនេះ ដោយម្នាក់ក្នុងចំណោមនោះ អាចជាពលរដ្ឋរបស់ខ្លួនប្រសិនបើភាគីមិនមានការព្រមព្រៀងផ្សេងពីនេះ។ ការចាត់តាំងនេះត្រូវរួមបញ្ចូលក្នុងសេចក្ដីជូនដំណឹងដូចមានចែងក្នុងមាត្រា១ នៃឧបសម្ព័ន្ធនេះ។

(គ) ភាគីវិវាទម្ខាងទៀតត្រូវតែងតាំងអ្នកផ្សះផ្សាពីររូប តាមរបៀបដូចមានចែងក្នុងកថាខណ្ឌរង (ខ) ក្នុងរយៈពេល ២១ ថ្ងៃ បន្ទាប់ពីទទួលបានសេចក្ដីជូនដំណឹងដូចមានចែងក្នុងមាត្រា១ នៃឧបសម្ព័ន្ធនេះ។ ប្រសិនបើគ្មានការចាត់តាំងក្នុងរយៈពេលនោះទេ ក្នុងរយៈពេលមួយសប្ដាហ៍បន្ទាប់ពីផុតកំណត់រយៈពេលនោះ ភាគីដែលផ្ដើមនីតិវិធីអាចបញ្ចប់នីតិវិធីបានដោយជូនដំណឹងទៅភាគីម្ខាងទៀត ឬស្នើសុំទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិធ្វើការចាត់តាំងអនុលោមតាមកថាខណ្ឌរង (ង)។

(ឃ) ក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីអ្នកផ្សះផ្សា៤រូប ត្រូវបានចាត់តាំង អ្នកផ្សះផ្សាទាំង៤ ត្រូវតែងតាំងអ្នកផ្សះផ្សា៥ ដែលត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះដូចមានចែងក្នុងមាត្រា២ នៃឧបសម្ព័ន្ធនេះ ដែលនឹងត្រូវធ្វើជាប្រធាន។ ប្រសិនបើគ្មានការតែងតាំងក្នុងរយៈពេលនេះទេ ក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីផុតកំណត់រយៈពេលនោះ ភាគីណាមួយអាចស្នើសុំអគ្គលេខាធិការនៃអង្គការសហប្រជាជាតិធ្វើការចាត់តាំងអនុលោមតាមកថាខណ្ឌរង (ង)។

(ង) ក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីទទួលបានសំណើដូចមានចែងក្នុងកថាខណ្ឌរង (គ) ឬ (ឃ) អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវធ្វើការចាត់តាំងដែលកាំពាច់ ពេញពីបញ្ជីឈ្មោះដូចមានចែងក្នុងមាត្រា២ នៃឧបសម្ព័ន្ធនេះ ដោយពិគ្រោះយោបល់ជាមួយគូភាគីវិវាទ។

(ច) ក្នុងករណីតំណែងអ្នកផ្សះផ្សាទំនេរ ត្រូវធ្វើការចាត់តាំងតាមរបៀបដែលបានកំណត់សម្រាប់ការចាត់តាំងដំបូង។

(ឆ) ភាគីពីរឬច្រើនដែលកំណត់តាមការព្រមព្រៀងថា ពួកគេមានផលប្រយោជន៍ដូចគ្នា ត្រូវធ្វើការចាត់តាំងអ្នកផ្សះផ្សា២រូបរួមគ្នា។ នៅពេលភាគីពីរឬច្រើនមានផលប្រយោជន៍ដោយឡែកពីគ្នា ឬគ្មានការព្រមព្រៀងថាពួកគេមានផលប្រយោជន៍ដូចគ្នា ពួកគេត្រូវចាត់តាំងអ្នកផ្សះផ្សាដោយឡែកពីគ្នា។

(ជ) ក្នុងវិវាទដែលពាក់ព័ន្ធភាគីច្រើនជាងពីរ ដែលមានផលប្រយោជន៍ដោយឡែកពីគ្នា ឬប្រសិនបើគ្មានការព្រមព្រៀងថាពួកគេមានផលប្រយោជន៍ដូចគ្នា គូភាគីត្រូវអនុវត្តតាមកថាខណ្ឌរង (ក) ដល់ (ច) តាមដែលអាចធ្វើទៅបាន។

## មាត្រា៤
## នីតិវិធី

ប្រសិនបើភាគីគ្មានការព្រមព្រៀងផ្សេងទេនោះ គណៈកម្មការផ្សះផ្សាត្រូវកំណត់នីតិវិធីរបស់ខ្លួន។ ដោយមានការយល់ព្រមពីភាគីវិវាទ គណៈកម្មការអាចអញ្ជើញរដ្ឋភាគីណាមួយឱ្យដាក់ទស្សនៈរបស់ខ្លួន ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ សេចក្តីសម្រេចរបស់គណៈកម្មការទាក់ទងនឹងបញ្ហានីតិវិធី របាយការណ៍ និងអនុសាសន៍ត្រូវសម្រេចដោយសំឡេងភាគច្រើនរបស់សមាជិក។

## មាត្រា៥
## ដំណោះស្រាយដោយមិត្តភាព

គណៈកម្មការអាចទាញចំណាប់អារម្មណ៍របស់ភាគីចំពោះវិធានការណាមួយដែលអាចសម្រួលឱ្យមានដំណោះស្រាយវិវាទដោយមិត្តភាព។

## មាត្រា៦
## មុខងាររបស់គណៈកម្មការ

គណៈកម្មការត្រូវស្តាប់ ពិនិត្យការអះអាងនិងការបដិសេធ និងលើកសំណើដល់ភាគីក្នុងគោលបំណងរកដំណោះស្រាយដោយមិត្តភាព។

## មាត្រា៧
## របាយការណ៍

១. គណៈកម្មការត្រូវរាយការណ៍ ក្នុងរយៈពេល ១២ ខែបន្ទាប់ពីគណៈកម្មការត្រូវបានបង្កើត។ របាយការណ៍នេះត្រូវកត់ត្រាការព្រមព្រៀងគ្នា ការមិនព្រមព្រៀងរបស់គូភាគី និងការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងអង្គហេតុនិងអង្គច្បាប់ដែលពាក់ព័ន្ធនឹងវិវាទ និងអនុសាសន៍ដែលគណៈកម្មការយល់ថាសមស្រប សម្រាប់ការដោះស្រាយវិវាទដោយមិត្តភាព។ របាយការណ៍នេះត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបញ្ជូនទៅឱ្យគូភាគីវិវាទភ្លាម។

២. របាយការណ៍របស់គណៈកម្មការរួមទាំងសេចក្តីសន្និដ្ឋានឬអនុសាសន៍ផង មិនចងកាតព្វកិច្ចលើគូភាគីទេ។

## មាត្រា៨
## ការបញ្ចប់

នីតិវិធីផ្សះផ្សាត្រូវបញ្ចប់នៅពេលទទួលបានដំណោះស្រាយសមស្របណាមួយ ឬនៅពេលដែលគូភាគីបានទទួលយក ឬភាគីណាមួយបានបដិសេធអនុសាសន៍ក្នុងរបាយការណ៍តាមរយៈសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរផ្ញើទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ឬរយៈពេល ៣ខែ បានកន្លងផុតគិតចាប់ពីកាលបរិច្ឆេទបញ្ជូនរបាយការណ៍ទៅគូភាគី។

## មាត្រា៩
## កម្រៃនិងការចំណាយ

កម្រៃនិងការចំណាយរបស់គណៈកម្មការជាបន្ទុករបស់គូភាគីវិវាទ។

## មាត្រា១០
## សិទ្ធិរបស់គូភាគីក្នុងការកែប្រែនីតិវិធី

គូភាគីវិវាទអាចកែប្រែបទប្បញ្ញត្តិណាមួយនៃឧបសម្ព័ន្ធនេះតាមការព្រមព្រៀងដែលការកែប្រែនេះអនុវត្តចំពោះតែវិវាទរបស់ពួកគេតែប៉ុណ្ណោះ។

# ជំពូកទី២
# លក្ខខណ្ឌត្រូវចូលរួមជាភាតព្វកិច្ចក្នុងនីតិវិធីផ្សះផ្សា អនុលោមតាមផ្នែកទី៣ នៃជំពូកទី១៥

## មាត្រា១១
## ការផ្តួចផ្តើមនីតិវិធីផ្សះផ្សា

១. អនុលោមតាមផ្នែកទី៣ នៃជំពូកទី១៥ ភាគីណាមួយនៃវិវាទអាចផ្តួចផ្តើមនីតិវិធីផ្សះផ្សាក្រោមជំពូកនេះតាមរយៈសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីមួយឬច្រើនម្ខាងទៀត។

២. បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងតាមកថាខណ្ឌទី១ ភាគីវិវាទមានកាតព្វកិច្ចចូលរួមក្នុងនីតិវិធីផ្សះផ្សា។

## មាត្រា១២

## ការខកខានឆ្លើយតបឬចូលរួមនីតិវិធីផ្សះផ្សា

ការខកខានរបស់ភាគីមួយឬច្រើននៃវិវាទក្នុងការឆ្លើយតបនឹងសេចក្តីជូនដំណឹងអំពីការចាប់ផ្តើមនីតិវិធីផ្សះផ្សាឬចូលរួមក្នុងនីតិវិធីផ្សះផ្សា មិនរារាំងដំណើរការនីតិវិធីផ្សះផ្សានោះទេ។

## មាត្រា១៣

## សមត្ថកិច្ច

ការមិនឯកភាពនឹងសមត្ថកិច្ចរបស់គណៈកម្មការក្នុងការផ្សះផ្សាវិវាទនៅក្នុងផ្នែកនេះ ត្រូវសម្រេចដោយគណៈកម្មការ។

## មាត្រា១៤

## ការអនុវត្តផ្នែកទី១

មាត្រា២ ដល់មាត្រា១០ នៃផ្នែកទី១ នៃឧបសម្ព័ន្ធនេះ ត្រូវអនុវត្តដោយអនុលោមតាមផ្នែកនេះ។

# ឧបសម្ព័ន្ធទី៦
# លក្ខន្តិកៈរបស់តុលាការអន្តរជាតិនីតិសមុទ្រ

## មាត្រា១
## បទប្បញ្ញត្តិទូទៅ

១. តុលាការអន្តរជាតិសម្រាប់នីតិសមុទ្រត្រូវបានបង្កើតឡើង និងប្រព្រឹត្តទៅអនុលោមតាមបទប្បញ្ញត្តិនៃអនុសញ្ញានិងលក្ខន្តិកៈនេះ។

២. ទីតាំងរបស់តុលាការត្រូវស្ថិតនៅទីក្រុងហាំបឺក សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។

៣. តុលាការអាចតាំងទីកន្លែង និងអនុវត្តមុខងាររបស់ខ្លួននៅទីកន្លែងផ្សេងបាន នៅពេលដែលយល់ឃើញថាចាំបាច់។

៤. បែបបទក្នុងការបញ្ជូនវិវាទទៅតុលាការត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃជំពូកទី១១ និងជំពូកទី១៥។

# ផ្នែកទី១
# អង្គការចាត់តាំងតុលាការ

## មាត្រា២
## សមាសភាព

១. តុលាការត្រូវជាអង្គមួយដែលមានសមាជិកឯករាជ្យចំនួន ២១ រូប ដែលត្រូវបានបោះឆ្នោតចេញពីក្នុងចំណោមបុគ្គលដែលមានកេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់បំផុតថាយុត្តិធម៌ និងសុចរិត និងមានសមត្ថភាពដែលត្រូវបានទទួលស្គាល់នៅក្នុងនីតិសមុទ្រ។

២. នៅក្នុងតុលាការទាំងមូលត្រូវធានាថាមានអ្នកតំណាងមកពីបណ្តាប្រព័ន្ធច្បាប់ចម្បងៗនៅពិភពលោក និងការបែងចែកតាមតំបន់ភូមិសាស្ត្រប្រកបដោយសមធម៌។

## មាត្រា៣
## សមាជិកភាព

១. សមាជិកចំនួន២រូបរបស់តុលាការមិនត្រូវមានសញ្ជាតិដូចគ្នានោះទេ។ សម្រាប់គោលបំណងនៃសមាជិកភាពនៅក្នុងតុលាការនេះ បុគ្គលដែលបានចាត់ទុកថាមានសញ្ជាតិលើសពីមួយ បុគ្គលនោះត្រូវបានកំណត់ថាជាពលរដ្ឋនៃរដ្ឋដែលបុគ្គលនោះអនុវត្តសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយជាប្រចាំ។

២. នៅក្នុងតំបន់ភូមិសាស្ត្រនីមួយៗដែលកំណត់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវមានសមាជិកយ៉ាងតិច៣រូប។

## មាត្រា៤
## ការជ្រើសតាំង និងការបោះឆ្នោត

១. រដ្ឋភាគីនីមួយៗអាចជ្រើសតាំងមិនលើសពីពីររូប នូវបុគ្គលដែលមានគុណវុឌ្ឍិដូចមានចែងនៅក្នុងមាត្រា២ នៃឧបសម្ព័ន្ធនេះ។ សមាជិករបស់តុលាការត្រូវបានបោះឆ្នោតពីបញ្ជីបុគ្គលដែលបានជ្រើសតាំងនោះ។

២. យ៉ាងហោចណាស់រយៈពេលបីខែមុនការបោះឆ្នោត អគ្គលេខាធិការនៃអង្គការសហប្រជាជាតិក្នុងករណីការបោះឆ្នោតលើកដំបូង និងមន្ត្រីកាន់បញ្ជីរបស់តុលាការចំពោះការបោះឆ្នោតជាបន្តបន្ទាប់ ត្រូវចេញលិខិតអញ្ជើញទៅបណ្តារដ្ឋភាគីដើម្បីធ្វើការជ្រើសតាំងសម្រាប់តួនាទីជាសមាជិករបស់តុលាការក្នុងរយៈពេលពីរខែ។ អគ្គលេខាធិការត្រូវរៀបចំបញ្ជីតាមលំដាប់តួអក្សររបស់បុគ្គលដែលបានជ្រើសតាំងទាំងអស់ជាមួយនឹងការបញ្ជាក់អំពីរដ្ឋសមាជិកដែលបានជ្រើសតាំងបុគ្គលទាំងនោះនិងត្រូវផ្ញើជូនបណ្តារដ្ឋភាគីមុនថ្ងៃទី៧នៃខែចុងក្រោយ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ។

៣. ក្រោយអនុសញ្ញានេះចូលជាធរមានរយៈពេល៦ខែ ការបោះឆ្នោតលើកទី១ត្រូវបានធ្វើឡើង។

៤. សមាជិករបស់តុលាការត្រូវបានជ្រើសតាំងដោយសន្លឹកឆ្នោតសម្ងាត់។ ការបោះឆ្នោតត្រូវរៀបចំឡើងនៅក្នុងកិច្ចប្រជុំរបស់បណ្តារដ្ឋភាគីដែលកោះប្រជុំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងករណីការបោះឆ្នោតទី១ និងដោយនីតិវិធីដែលបានព្រមព្រៀងដោយបណ្តារដ្ឋភាគីក្នុងករណីការបោះឆ្នោតបន្តបន្ទាប់។ កូរ៉ុមនៅក្នុងកិច្ចប្រជុំរបស់រដ្ឋភាគីត្រូវកំណត់ ចំនួនពីរភាគបី។ បណ្តាបុគ្គលដែលត្រូវបានបោះឆ្នោតជ្រើសតាំង ត្រូវតែជាបេក្ខជនដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេបង្អស់ ដែលចំនួនភាគច្រើនពីរភាគបីនៃបណ្តារដ្ឋភាគីមានវត្តមាននិងបោះឆ្នោត ក្នុងលក្ខខណ្ឌដែលចំនួនភាគច្រើននោះរួមបញ្ចូលចំនួនភាគច្រើនរបស់បណ្តារដ្ឋភាគី។

## មាត្រា៥

## អាណត្តិនៃមុខតំណែង

១. សមាជិករបស់តុលាការត្រូវបានជ្រើសតាំងសម្រាប់អាណត្តិ៩ឆ្នាំ និងអាចត្រូវបានបោះឆ្នោតជ្រើសតាំងសាជាថ្មី ប៉ុន្តែក្នុងលក្ខខណ្ឌដែលសមាជិកដែលត្រូវបានបោះឆ្នោតជ្រើសតាំងនៅសម័យបោះឆ្នោតលើកទី១ អាណត្តិរបស់សមាជិកចំនួន៧រូបត្រូវផុតកំណត់នៅពេលចុងឆ្នាំទី៣ និងអាណត្តិរបស់សមាជិកចំនួន៧រូបបន្ថែមនោះត្រូវផុតកំណត់នៅចុងឆ្នាំទី៦។

២. សមាជិករបស់តុលាការដែលអាណត្តិរបស់ខ្លួនមានរយៈពេលបីឆ្នាំនិងប្រាំមួយឆ្នាំដូចមានចែងខាងលើជិតផុតកំណត់នៅចុងរយៈពេលដំបូង ត្រូវបានជ្រើសរើសតាមរយៈការចាប់ឆ្នោតដោយអគ្គលេខាធិការអង្គការសហប្រជាជាតិភ្លាមៗបន្ទាប់ពីការបោះឆ្នោតលើកទី១។

៣. សមាជិករបស់តុលាការត្រូវបន្តបំពេញករណីកិច្ចរបស់ខ្លួនរហូតដល់តំណែងនោះត្រូវបានបំពេញ។ ទោះបីជាត្រូវបានជំនួសក៏ដោយ សមាជិកនោះត្រូវបញ្ចប់រាល់ដំណើរការនីតិវិធីដែលខ្លួនបានចាប់ផ្តើមមុន កាលបរិច្ឆេទនៃការជំនួសរបស់ខ្លួន។

៤. ក្នុងករណីនៃការលាលែងរបស់សមាជិកតុលាការ លិខិតលាលែងត្រូវផ្ញើជូនទៅប្រធានតុលាការ។ នៅពេលលិខិតនេះត្រូវបានទទួល ដំណែងនោះត្រូវនៅចំហ។

## មាត្រា៦
## មុខតំណែងដែលនៅចំហ

១. តំណែងដែលនៅចំហត្រូវបំពេញដោយវិធីដូចគ្នានឹងការបោះឆ្នោតជ្រើសតាំងលើកទី១ ដោយអនុលោមតាមបទប្បញ្ញត្តិដូចតទៅ៖ ក្នុងរយៈពេល១ខែនៃដំណែងនៅចំហ មន្ត្រីកាន់បញ្ជីត្រូវរៀបចំចេញលិខិតអញ្ជើញដូចមានចែងនៅក្នុងមាត្រា៤ នៃឧបសម្ព័ន្ធនេះ ហើយកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងត្រូវកំណត់ដោយប្រធានតុលាការ ក្រោយពីបានពិគ្រោះយោបល់ជាមួយនឹងបណ្តារដ្ឋភាគី។

២. សមាជិករបស់តុលាការមួយរូបដែលត្រូវបានបោះឆ្នោតជ្រើសតាំងដើម្បីជំនួសសមាជិកដែលអាណត្តិពុំទាន់ចប់ ត្រូវបំពេញមុខងារសម្រាប់អាណត្តិដែលនៅសល់របស់អ្នកកាន់តំណែងចាស់។

## មាត្រា៧
## សកម្មភាពដែលមានវិសមិតភាព

១. គ្មានសមាជិកណាមួយរបស់តុលាការអាចបំពេញមុខងារនយោបាយ ឬរដ្ឋបាល ឬមានទំនាក់ទំនងយ៉ាងសកម្មក្នុងការពាក់ព័ន្ធជាមួយ ឬមានផលប្រយោជន៍ហិរញ្ញវត្ថុនៅក្នុងប្រតិបត្តិការរបស់សហគ្រាសណាមួយដែលពាក់ព័ន្ធនឹងការស្វែងរុករក ឬការធ្វើអាជីវកម្មលើធនធានសមុទ្រ ឬបាតសមុទ្រ ឬការប្រើប្រាស់សមុទ្រឬបាតសមុទ្រជាលក្ខណៈពាណិជ្ជកម្ម។

២. គ្មានសមាជិកណាម្នាក់របស់តុលាការអាចធ្វើសកម្មភាពជាអ្នកតំណាង អ្នកប្រឹក្សា ឬមេធាវីការពារនៅក្នុងសំណុំរឿងទាំងអស់។

៣. រាល់មន្ទិលសង្ស័យលើចំណុចទាំងអស់នេះត្រូវដោះស្រាយដោយសេចក្តីសម្រេចនៃសមាជិកតុលាការផ្សេងទៀតដែលមានវត្តមានដោយសំឡេងភាគច្រើន។

## មាត្រា៨
## លក្ខខណ្ឌពាក់ព័ន្ធនឹងការចូលរួមរបស់បណ្តាសមាជិកនៅក្នុងសំណុំរឿងក្តីណាមួយ

១. គ្មានសមាជិកណាម្នាក់របស់តុលាការអាចចូលរួមនៅក្នុងការសម្រេចចិត្តនៃសំណុំរឿងណាមួយ ក្នុងករណីដែលសមាជិកនោះបានបំពេញតួនាទីជាអ្នកតំណាង អ្នកប្រឹក្សា ឬមេធាវីការពារសម្រាប់ភាគីណាមួយកន្លងមក ឬជាសមាជិកនៃតុលាការ ឬអង្គជំនុំជម្រះជាតិឬអន្តរជាតិ ឬក្នុងតួនាទីណាក៏ដោយ។

២. ក្រោមមូលហេតុពិសេស ប្រសិនសមាជិករបស់តុលាការម្នាក់យល់ឃើញថាខ្លួនពុំគួរចូលរួមនៅក្នុងការសម្រេចចិត្តនៃសំណុំរឿងមួយទេ សមាជិកនោះត្រូវជូនដំណឹងមកកាន់ប្រធានតុលាការ។

៣. ប្រសិនបើប្រធានតុលាការយល់ឃើញថា ក្រោមមូលហេតុពិសេសសមាជិកម្នាក់នៃតុលាការមិនគួរចូលរួមនៅក្នុងសំណុំរឿងណាមួយ នោះប្រធានតុលាការត្រូវជូនដំណឹងដល់សមាជិកនោះ។

៤. រាល់មន្ទិលសង្ស័យលើចំណុចទាំងអស់នេះត្រូវដោះស្រាយដោយសេចក្តីសម្រេចនៃសមាជិកតុលាការផ្សេងទៀតដែលមានវត្តមានដោយសំឡេងភាគច្រើន។



៩៣

### មាត្រា៩
### ផលវិបាកនៃការឈប់បំពេញលក្ខខណ្ឌតម្រូវ

តាមរយៈការយល់ឃើញជាឯកច្ឆន្ទពីសំណាក់បណ្ដាសមាជិករបស់តុលាការ ប្រសិនបើសមាជិកម្នាក់បានឈប់បំពេញលក្ខខណ្ឌតម្រូវនោះ ប្រធានតុលាការត្រូវប្រកាសថាតំណែងសមាជិកនេះចំហរ។

### មាត្រា១០
### បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

សមាជិករបស់តុលាការត្រូវមានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិការទូតនៅពេលបំពេញការងាររបស់តុលាការ។

### មាត្រា១១
### ការប្រកាសជាឱឡារិករបស់បណ្ដាសមាជិក

មុនចូលកាន់តំណែង រាល់សមាជិករបស់តុលាការត្រូវធ្វើការប្រកាសជាឱឡារិកជាសាធារណៈថាខ្លួននឹងអនុវត្តអំណាចរបស់ខ្លួនដោយអព្យាក្រឹត្យនិងប្រកបដោយសម្បជញ្ញៈ។

### មាត្រា១២
### ប្រធាន អនុប្រធាន និងមន្ត្រីកាន់បញ្ជី

១. តុលាការត្រូវជ្រើសបោះឆ្នោតតាំងប្រធាន អនុប្រធានសម្រាប់អាណត្តិ៣ឆ្នាំ។ ប្រធាន និងអនុប្រធានអាចត្រូវបានបោះឆ្នោតជ្រើសតាំងឡើងវិញបាន។

២. តុលាការត្រូវតែងតាំងមន្ត្រីកាន់បញ្ជីរបស់ខ្លួន និងអាចតែងតាំងមន្ត្រីក្នុងតួនាទីបែបនេះទៀតនៅក្នុងករណីចាំបាច់។

៣. ប្រធានតុលាការ និងមន្ត្រីកាន់បញ្ជីត្រូវស្នាក់នៅនៅទីកន្លែងរបស់តុលាការ។

### មាត្រា១៣
### កូរ៉ុម

១. សមាជិកទាំងអស់របស់តុលាការត្រូវមានវត្តមាន។ ការបង្កើតតុលាការតម្រូវឱ្យមានកូរ៉ុមនៃសមាជិកជាប់ឆ្នោតចំនួន ១១រូប។

២. អនុលោមតាមមាត្រា១៧ នៃឧបសម្ព័ន្ធ នេះតុលាការត្រូវសម្រេចថាសមាជិករូបណានឹងក្លាយជាតុលាការសម្រាប់វិនិច្ឆ័យវិវាទណាមួយ ដោយពិចារណាទៅលើការបំពេញមុខងារប្រកបដោយប្រសិទ្ធភាពនៃអង្គជំនុំជម្រះដូចមានចែងនៅក្នុងមាត្រា១៤ និងមាត្រា១៥ នៃឧបសម្ព័ន្ធនេះ។

៣. គ្រប់វិវាទ និងពាក្យសុំទាំងអស់ដែលបានដាក់មកតុលាការ ត្រូវទទួលការពិនិត្យនិងសម្រេចដោយតុលាការ លើកលែងតែមានការអនុវត្តមាត្រា១៤ នៃឧបសម្ព័ន្ធ ឬគូភាគីស្នើសុំថាវិវាទនិងពាក្យសុំនេះត្រូវដោះស្រាយដោយអនុលោមតាមមាត្រា១៥ នៃឧបសម្ព័ន្ធនេះ។

### មាត្រា១៤
### អង្គជំនុំជម្រះវិវាទបាតសមុទ្រ

អង្គជំនុំជម្រះវិវាទបាតសមុទ្រត្រូវបានបង្កើតឡើងដោយអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកទី៤ នៃឧបសម្ព័ន្ធនេះ។ យុត្តាធិការ អំណាច និងមុខងាររបស់អង្គជំនុំជម្រះវិវាទបាតសមុទ្រ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងនៅក្នុងផ្នែកទី៥ នៃជំពូកទី១១។

### មាត្រា១៥
### វង្គជំនុំជម្រះវិវាទពិសេស

១. តុលាការអាចបង្កើតសភាពិសេស ដោយមានសមាភាពសមាជិកដែលជាប់ឆ្នោតចំនួន៣រូប ឬច្រើនជាងនេះ ដោយពិចារណាលើភាពចាំបាច់ក្នុងការដោះស្រាយប្រភេទវិវាទជាក់លាក់។

២. តុលាការត្រូវបង្កើតសភាសម្រាប់ដោះស្រាយវិវាទជាក់លាក់ណាមួយដែលបានដាក់មកតុលាការ ក្នុងករណីមានការស្នើសុំពីគូភាគី។ សមាសភាពនៃអង្គជំនុំជម្រះវិវាទនេះ ត្រូវកំណត់ដោយតុលាការជាមួយដោយមានការយល់ព្រមពីគូភាគី។

៣. ក្នុងគោលបំណងដើម្បីបំពេញការងារបានលឿន ជាប្រចាំឆ្នាំតុលាការត្រូវបង្កើតសភាដែលមានសមាសភាពពីសមាជិកដែលបានជាប់ឆ្នោតចំនួន៥រូប ដែលអាចពិនិត្យនិងសម្រេចលើវិវាទតាមរយៈនីតិវិធីសង្ខេប។ សមាជិកបម្រុង២រូប ត្រូវបានជ្រើសរើសសម្រាប់គោលបំណងនៃការជំនួសសមាជិកដែលពុំអាចចូលរួមនៅក្នុងដំណើរការនីតិវិធីណាមួយ។

៤. ប្រសិនបើគូភាគីស្នើសុំ វិវាទត្រូវបានពិនិត្យនិងសម្រេចដោយសភានេះ ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រានេះ។

៥. សាលក្រមដែលធ្វើឡើងដោយអង្គជំនុំជម្រះវិវាទណាមួយដែលអនុលោមតាមមាត្រានេះ និងមាត្រា ១៤ នៃឧបសម្ព័ន្ធនេះ ត្រូវចាត់ថាបានចេញដោយតុលាការ។

### មាត្រា១៦
### វិធានរបស់តុលាការ

តុលាការត្រូវបង្កើតវិធានសម្រាប់អនុវត្តមុខងាររបស់ខ្លួន។ ជាពិសេស តុលាការត្រូវកំណត់វិធាននីតិវិធី។

### មាត្រា១៧
### សញ្ជាតិរបស់សមាជិក

១. បណ្ដាសមាជិកនៃតុលាការ ដែលមានសញ្ជាតិរបស់គូភាគីណាមួយនៃវិវាទត្រូវរក្សាសិទ្ធិក្នុងការចូលរួមជាសមាជិកនៃតុលាការ។

២. នៅពេលបើកសវនាការលើវិវាទ ប្រសិនបើតុលាការដាក់បញ្ចូលសមាជិកម្នាក់ដែលមានសញ្ជាតិនៃភាគីម្ខាងទៅក្នុងអង្គជំនុំជម្រះ ភាគីម្ខាងទៀតអាចជ្រើសរើសបុគ្គលណាម្នាក់ ឱ្យចូលរួមជាសមាជិកនៃតុលាការបាន។

៣. នៅពេលបើកសវនាការលើវិវាទ ប្រសិនបើតុលាការមិនបានដាក់បញ្ចូលសមាជិកម្នាក់ដែលមានសញ្ជាតិរបស់ភាគីណាមួយក្នុងអង្គជំនុំជម្រះទេ ភាគីនីមួយៗអាចជ្រើសរើសបុគ្គលណាម្នាក់ ឱ្យចូលរួមជាសមាជិកនៃតុលាការបាន។

៤. មាត្រានេះអនុវត្តចំពោះបណ្ដាសភាដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥ នៃឧបសម្ព័ន្ធនេះ។ ក្នុងករណីនេះ ដោយពិគ្រោះយោបល់ជាមួយនឹងគូភាគី ប្រធានត្រូវស្នើសុំសមាជិកជាក់លាក់ច្រើនរូបតាមការចាំបាច់នៅក្នុងការបង្កើតសភា ដើម្បីឱ្យសមាជិកនោះផ្តល់កន្លែងដល់សមាជិកនៃតុលាការដែលមានសញ្ជាតិរបស់គូភាគីពាក់ព័ន្ធ ហើយប្រសិនបើបរាជ័យឬប្រសិនបើសមាជិកនោះមិនអាចមានវត្តមាន ត្រូវផ្តល់កន្លែងដល់សមាជិកដែលគូភាគីបានជ្រើសរើសជាក់លាក់។

៥. ប្រសិនបើមានភាគីច្រើនមានផលប្រយោជន៍តែមួយ ស្របតាមគោលបំណងនៃបទប្បញ្ញត្តិនីតិវិធី ពួកគេត្រូវបានចាត់ទុកថាជាភាគីមួយប៉ុណ្ណោះ។ មន្ទិលសង្ស័យណាមួយលើបំណុចនេះត្រូវដោះស្រាយដោយសេចក្តីសម្រេចរបស់តុលាការ។

៦. សមាជិកដែលត្រូវបានជ្រើសរើសអនុលោមតាមកថាខណ្ឌទី២ ទី៣ និងទី៤ ត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២ មាត្រា៨ និងមាត្រា១១ នៃឧបសម្ព័ន្ធនេះ។ សមាជិកទាំងនោះត្រូវចូលរួមក្នុងការធ្វើសេចក្តីសម្រេចដោយស្មើភាពគ្នាយ៉ាងពេញលេញជាមួយនឹងសមាជិកដទៃទៀត។

## មាត្រា១៨

## លាភការរបស់សមាជិក

១. សមាជិកជ្រើសតាំងម្នាក់ៗនៃតុលាការត្រូវទទួលបានប្រាក់វិភាជន៍ប្រចាំឆ្នាំនិងប្រាក់វិភាជន៍ពិសេសសម្រាប់ចំនួនថ្ងៃដែលខ្លួនបំពេញមុខងារ ប៉ុន្តែចំនួនប្រាក់វិភាជនន៍ពិសេសសរុបក្នុងឆ្នាំមួយដែលត្រូវបង់ឱ្យសមាជិកណាម្នាក់ មិនត្រូវលើសចំនួនប្រាក់វិភាជន៍ប្រចាំឆ្នាំឡើយ។

២. ប្រធានត្រូវទទួលបានប្រាក់វិភាជន៍ពិសេសប្រចាំឆ្នាំ។

៣. អនុប្រធានត្រូវទទួលបានប្រាក់វិភាជន៍ពិសេសសម្រាប់ចំនួនថ្ងៃដែលខ្លួនបំពេញតួនាទីជាប្រធាន។

៤. សមាជិកដែលត្រូវបានជ្រើសរើសតាមមាត្រា១៧ នៃឧបសម្ព័ន្ធនេះ ក្រៅពីសមាជិកជ្រើសតាំងរបស់តុលាការ ត្រូវទទួលបានប្រាក់សំណងសម្រាប់ចំនួនថ្ងៃដែលខ្លួនបានបំពេញមុខងារ។

៥. ប្រាក់បៀវត្សរ៍ ប្រាក់វិភាជន៍ និងប្រាក់សំណង ត្រូវកំណត់ពីពេលមួយទៅពេលមួយនៅក្នុងកិច្ចប្រជុំរបស់រដ្ឋភាគី ដោយពិចារណាលើទំហំការងាររបស់តុលាការ។ ប្រាក់ទាំងនេះមិនអាចបន្ថយបានទេ ក្នុងអំឡុងអាណត្តិកាន់តំណែង។

៦. ប្រាក់បៀវត្សរ៍របស់មន្ត្រីកាន់បញ្ជី (អគ្គលេខាធិការ) ត្រូវកំណត់ក្នុងកិច្ចប្រជុំរបស់រដ្ឋភាគី តាមសំណើរបស់តុលាការ។

៧. បទបញ្ញាដែលត្រូវបានអនុម័តក្នុងកិច្ចប្រជុំរបស់រដ្ឋភាគី ត្រូវកំណត់លក្ខខណ្ឌដែលអាចបង់ប្រាក់សោធននិវត្តន៍ដល់សមាជិកតុលាការនិងដល់មន្ត្រីកាន់បញ្ជី (អគ្គលេខាធិការ) និងលក្ខខណ្ឌដែលត្រូវបង់សងថ្លៃធ្វើដំណើរឱ្យសមាជិកតុលាការនិងមន្ត្រីកាន់បញ្ជី (អគ្គលេខាធិការ) វិញ។

៨. ប្រាក់បៀវត្សរ៍ ប្រាក់វិភាជន៍ និងប្រាក់សំណងមិនត្រូវជាប់ពន្ធអ្វីទាំងអស់។

## មាត្រា១៩

## ការចំណាយរបស់តុលាការ

១. ការចំណាយរបស់តុលាការត្រូវទទួលបន្ទុកដោយរដ្ឋភាគីនិងអាជ្ញាធរ តាមលក្ខខណ្ឌនិងបែបបទដែលត្រូវសម្រេចក្នុងកិច្ចប្រជុំរបស់រដ្ឋភាគី។

២. នៅពេលបុគ្គលមួយក្រៅពីរដ្ឋភាគីឬអាជ្ញាធរក្លាយជាភាគីនៃសំណុំរឿងដែលបញ្ជូនមកតុលាការ តុលាការនឹងកំណត់ចំនួនប្រាក់ដែលភាគីនោះត្រូវចូលរួមចំណែកបង់លើការចំណាយរបស់តុលាការ។

## ផ្នែកទី២
## សមត្ថកិច្ច
### មាត្រា២០
### ការចូលទៅដោះស្រាយវិវាទដោយតុលាការ

១. តុលាការត្រូវបើកចំហចំពោះរដ្ឋភាគី។

២. តុលាការត្រូវបើកចំហចំពោះបុគ្គលនានាក្រៅពីរដ្ឋភាគីក្នុងសំណុំរឿងណាមួយដូចមានចែងច្បាស់ក្នុងជំពូកទី១១ ឬក្នុងសំណុំរឿងណាមួយដែលបញ្ជូនមកតុលាការស្របតាមការព្រមព្រៀងផ្សេងទៀត ដែលផ្តល់យុត្តាធិការដល់តុលាការហើយដែលត្រូវបានទទួលយកបានដោយគូភាគីទាំងអស់នៃសំណុំរឿង។

### មាត្រា២១
### យុត្តាធិការ

តុលាការមានយុត្តាធិការលើវិវាទនិងពាក្យសុំទាំងអស់ដែលបញ្ជូនមកតុលាការដោយអនុលោមតាមអនុសញ្ញានេះ និងរាល់បញ្ហាទាំងអស់ដូចមានចែងជាក់លាក់ក្នុងកិច្ចព្រមព្រៀងណាមួយដែលផ្តល់យុត្តាធិការដល់តុលាការ។

### មាត្រា២២
### ការលើកឡើងពីវិវាទដែលស្ថិតក្រោមលក្ខខណ្ឌកិច្ចព្រមព្រៀងដទៃទៀត

ប្រសិនបើគូភាគីទាំងអស់នៃសន្ធិសញ្ញាឬអនុសញ្ញាដែលចូលជាធរមានរួចហើយ និងដែលពាក់ព័ន្ធនឹងកម្មវត្ថុដូចមានចែងក្នុងអនុសញ្ញានេះមានការព្រមព្រៀងគ្នា វិវាទណាមួយដែលទាក់ទងនឹងការបកស្រាយឬការអនុវត្តសន្ធិសញ្ញាឬអនុសញ្ញានោះអាចបញ្ជូនមក**តុលាការ**បានដោយអនុលោមតាមកិច្ចព្រមព្រៀងនោះ។

### មាត្រា២៣
### ច្បាប់អនុវត្តន៍

តុលាការត្រូវសម្រេចលើវិវាទនិងពាក្យសុំទាំងអស់ដោយអនុលោមតាមមាត្រា២៩៣។

## ផ្នែកទី៣
## នីតិវិធី
### មាត្រា២៤
### ការចាប់ផ្តើមនៃនីតិវិធី

១. តាមករណីជាក់ស្តែង វិវាទត្រូវបញ្ជូនទៅផ្សះផ្សានៅតុលាការ តាមរយៈសេចក្តីជូនដំណឹងនៃកិច្ចព្រមព្រៀងពិសេស ឬតាមរយៈពាក្យសុំជាលាយលក្ខណ៍អក្សរ ដោយផ្ញើទៅមន្ត្រីកាន់បញ្ជី។ ក្នុងករណីមួយណាក៏ដោយ កម្មវត្ថុនៃវិវាទ និងភាគីវិវាទត្រូវចង្អុលបង្ហាញឱ្យច្បាស់លាស់។

២. មន្ត្រីកាន់បញ្ជី ត្រូវជូនដំណឹងភ្លាមៗពីកិច្ចព្រមព្រៀងពិសេស ឬពាក្យសុំទៅកាន់ភាគីពាក់ព័ន្ធទាំងអស់។

៣. មន្ត្រីកាន់បញ្ជី ក៏ត្រូវជូនដំណឹងរដ្ឋភាគីទាំងអស់។

## មាត្រា២៥
## វិធានការបណ្ដោះអាសន្ន

១. ដោយអនុលោមតាមមាត្រា២៩០ តុលាការនិងអង្គជំនុំជម្រះវិវាទបាតសមុទ្រ ត្រូវមានអំណាចក្នុងការកំណត់វិធានការបណ្ដោះអាសន្ន។

២. ប្រសិនបើតុលាការមិនទាន់ដំណើរការ ឬមិនមានចំនួនសមាជិកគ្រប់គ្រាន់ដើម្បីបង្កើតកូរ៉ុមទេ នោះវិធានការបណ្ដោះអាសន្នត្រូវកំណត់ដោយសភានេះ នូវនីតិវិធីសង្ខេបដែលបង្កើតឡើងក្រោមកថាខណ្ឌទី៣ នៃមាត្រា១៥ នៃឧបសម្ព័ន្ធនេះ។ បើទោះបីមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រា១៥ នៃឧបសម្ព័ន្ធនេះក៏ដោយ វិធានការបណ្ដោះអាសន្ននេះអាចអនុប័តបាន តាមសំណើរបស់ភាគីណាមួយនៃវិវាទ។ វិធានការបណ្ដោះអាសន្នទាំងនោះត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការកែតម្រូវដោយតុលាការ។

## មាត្រា២៦
## សវនាការ

១. សវនាការត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន ឬប្រសិនបើប្រធានមិនអាចធ្វើជាប្រធានបានទេនោះអនុប្រធានត្រូវដឹកនាំ។ ប្រសិនបើប្រធាន និងអនុប្រធានមិនអាចធ្វើជាប្រធានបាន ចៅក្រមជាន់ខ្ពស់នៃតុលាការត្រូវធ្វើជាប្រធាន។

២. សវនាការត្រូវធ្វើឡើងជាសាធារណៈ លុះត្រាតែតុលាការសម្រេចផ្ទុយពីនេះ ឬប្រសិនបើភាគីទាមទារឱ្យបិទការចូលរួមពីសាធារណៈ។

## មាត្រា២៧
## ដំណើរការនៃសំណុំរឿង

តុលាការត្រូវចេញដីកាស្ដីពីដំណើរការនៃសំណុំរឿង ត្រូវសម្រេចទម្រង់ និងពេលវេលាដើម្បីឱ្យភាគីវិវាទរៀបចំការទាញហេតុផលរបស់ខ្លួន និងធ្វើការរៀបចំវិធានការនានាទាក់ទងនឹងការប្រមូលភស្តុតាង។

## មាត្រា២៨
## ការខកខាន

នៅពេលភាគីណាមួយមិនបានបង្ហាញខ្លួននៅចំពោះមុខតុលាការ ឬខកខានមិនបានការពារសំណុំរឿងរបស់ខ្លួន ភាគីម្ខាងទៀតអាចស្នើសុំតុលាការបន្តនីតិវិធី និងចេញសេចក្ដីសម្រេច។ អវត្តមានរបស់ភាគី ឬការខកខានរបស់ភាគីក្នុងការការពារសំណុំរឿងមិនត្រូវចាត់ទុកជាការរារាំងនៃដំណើរការនីតិវិធី។ មុនពេលចេញសេចក្ដីសម្រេចតុលាការត្រូវបំពេញលក្ខខណ្ឌផ្ទាល់ខ្លួន ដោយមិនត្រឹមតែលើយុត្តាធិការលើវិវាទប៉ុណ្ណោះទេ ប៉ុន្តែក៏ទៅលើការទាមទារនេះដែលដែលមានមូលដ្ឋានច្បាស់លាស់ផ្អែកលើអង្គហេតុ និងអង្គច្បាប់។

## មាត្រា២៩
## សំឡេងភាគច្រើនសម្រាប់សេចក្ដីសម្រេច

១. រាល់វិវាទទាំងអស់ត្រូវសម្រេចដោយសំឡេងភាគច្រើននៃសមាជិករបស់តុលាការដែលមានវត្តមាន។

២. ក្នុងករណីមានសំឡេងស្មើគ្នា ប្រធានឬសមាជិកនៃតុលាការដែលជំនួសប្រធាន ត្រូវធ្វើការបោះឆ្នោតសម្រេច។

## មាត្រា៣០
## សាលក្រម

១. សាលក្រមត្រូវបញ្ជាក់ពីមូលហេតុដែលជាមូលដ្ឋាននៃការសម្រេចសេចក្ដី។

២. សាលក្រមត្រូវមានសរសេរឈ្មោះសមាជិកតុលាការដែលចូលរួមធ្វើសាលក្រម។

៣. ក្នុងករណីផ្នែកណាមួយ ឬទាំងស្រុងនៃសាលក្រម មិនមែនជាការសម្រេចសេចក្ដីដោយឯកច្ឆន្ទរបស់សមាជិកតុលាការទេ នោះសមាជិកត្រូវមានសិទ្ធិថ្លែងការដោយឡែក។

៤. សាលក្រមត្រូវមានហត្ថលេខារបស់ប្រធាន និងមន្ត្រីកាន់បញ្ជី។ សាលក្រមត្រូវអានដោយបើកចំហរនៅតុលាការ និងដោយបានជូនដំណឹងឱ្យបានត្រឹមត្រូវដល់ភាគីវិវាទ។

## មាត្រា៣១
## សំណើសុំអន្តរាគមន៍

១. ប្រសិនបើរដ្ឋភាគីណាមួយយល់ឃើញថា ផលប្រយោជន៍ស្របច្បាប់របស់ខ្លួនត្រូវប៉ះពាល់ដោយសារសេចក្ដីសម្រេចទាក់ទងនឹងវិវាទ នោះរដ្ឋភាគីអាចដាក់សំណើសុំការអនុញ្ញាតទៅតុលាការដើម្បីធ្វើការអន្តរាគមន៍។

២. បន្ទាប់ពីមានការស្នើសុំ តុលាការត្រូវសម្រេចលើសំណើនេះ។

៣. ប្រសិនបើសំណើសុំអន្តរាគមន៍ត្រូវបានផ្ដល់ដោយតុលាការ សេចក្ដីសម្រេចរបស់តុលាការទាក់ទងនឹងវិវាទត្រូវចងកាតព្វកិច្ចលើរដ្ឋភាគីដែលធ្វើអន្តរាគមន៍នោះ ដរាបណាសេចក្ដីសម្រេចនានារបស់តុលាការពាក់ព័ន្ធនឹងបញ្ហាដែលរដ្ឋភាគីបានស្នើសុំធ្វើការអន្តរាគមន៍។

## មាត្រា៣២
## សិទ្ធិអន្តរាគមន៍ក្នុងករណីការបកស្រាយឬការអនុវត្ត

១. នៅពេលណាមានការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ មន្ត្រីកាន់បញ្ជីត្រូវជូនដំណឹងទៅកាន់រដ្ឋភាគីទាំងអស់ឱ្យបានឆាប់រហ័ស។

២. នៅពេលណាដែលមាន ការបកស្រាយ និងអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិណាមួយដោយយោងតាមមាត្រា២១ និងមាត្រា២២ នៃឧបសម្ព័ន្ធនេះ មន្ត្រីកាន់បញ្ជីត្រូវជូនដំណឹងភាគីទាំងអស់នៃកិច្ចព្រមព្រៀងនេះ។

៣. ភាគីនីមួយៗ ដែលចែងក្នុងកថាខណ្ឌទី១ និងទី២ មានសិទ្ធិធ្វើការអន្តរាគមន៍ក្នុងនីតិវិធី។ ក្នុងករណីដែលភាគីប្រើប្រាស់សិទ្ធិនេះ ការបកស្រាយដែលមានក្នុងសាលក្រមនឹងត្រូវចងកាតព្វកិច្ចស្មើគ្នាលើភាគីនោះ។

## មាត្រា៣៣
## ភាពជាស្ថាពរ និងការចងកាតព្វកិច្ចនៃសេចក្ដីសម្រេច

១. សេចក្ដីសម្រេចរបស់តុលាការជាសេចក្ដីសម្រេចស្ថាពរ ហើយភាគីទាំងអស់នៃវិវាទត្រូវអនុវត្តតាម។

២. ក្រៅពីភាគីនៃវិវាទ សេចក្ដីសម្រេចមិនមានអនុភាពគតិយុត្តក្នុងការចងកាតព្វកិច្ចទេ ។

៣. ក្នុងករណីដែលមានវិវាទលើអត្ថន័យ ឬវិសាលភាពនៃសេចក្ដីសម្រេច តុលាការត្រូវបកស្រាយសេចក្ដីសម្រេចឱ្យតបតាមសំណើរបស់ភាគីណាមួយ។

## មាត្រា៣៤
## សោហ៊ុយ

ភាគីនីមួយៗត្រូវទទួលបន្ទុកសោហ៊ុយផ្ទាល់ខ្លួន លុះត្រាតែតុលាការមិនមានការសម្រេចផ្សេងពីនេះ។

## ផ្នែកទី៤
## អង្គជំនុំជម្រះវិវាទបាតសមុទ្រ
### មាត្រា៣៥
### សមាសភាព

១. អង្គជំនុំជម្រះវិវាទបាតសមុទ្រដូចមានចែងក្នុងមាត្រា១៤ នៃឧបសម្ព័ន្ធនេះត្រូវមានសមាសភាពសមាជិកចំនួន១១នាក់ ដែលត្រូវជ្រើសតាំងដោយសំឡេងភាគច្រើននៃសមាជិកជាប់ឆ្នោតរបស់តុលាការចេញពីក្នុងចំណោមសមាជិកជាប់ឆ្នោតទាំងនោះ។

២. ក្នុងការជ្រើសតាំងសមាជិកអង្គជំនុំជម្រះវិវាទបាតសមុទ្រ ត្រូវធានាឱ្យបាននូវភាពជាតំណាងនៃប្រព័ន្ធច្បាប់ចម្បងៗរបស់ពិភពលោកនិងរបាយភូមិសាស្ត្រប្រកបដោយសមធម៌។ អង្គជំនុំជម្រះវិវាទ និងអាជ្ញាធរអាចអនុម័តអនុសាសន៍ដែលមានលក្ខណៈទូទៅ ទាក់ទងនឹងភាពជាតំណាងនិងរបាយភូមិសាស្ត្រនេះ។

៣. សមាជិកនៃអង្គជំនុំជម្រះវិវាទត្រូវជ្រើសតាំងរៀងរាល់ ៣ឆ្នាំម្ដង ហើយអាចត្រូវបានជ្រើសតាំងសម្រាប់អាណត្តិទី២ បាន។

៤. អង្គជំនុំជម្រះវិវាទត្រូវបោះឆ្នោតជ្រើសរើសប្រធានពីក្នុងចំណោមសមាជិកដែលនឹងកាន់តំណែងសម្រាប់អាណត្តិរបស់អង្គជំនុំជម្រះវិវាទ។

៥. ប្រសិនបើនីតិវិធីបណ្ដឹងនៅបន្ត នៅចុងអាណត្តិ ៣ឆ្នាំរបស់អង្គជំនុំជម្រះវិវាទ អង្គជំនុំជម្រះវិវាទនោះត្រូវបញ្ចប់នីតិវិធី ក្នុងសមាសភាពដើមរបស់ខ្លួន។

៦. ប្រសិនបើមានតំណែងទំនេរនៅក្នុងអង្គជំនុំជម្រះវិវាទ **តុលាការ**ត្រូវជ្រើសរើសអ្នកស្នងបន្តពីក្នុងចំណោមសមាជិកជាប់ឆ្នោតរបស់ខ្លួន ដែលត្រូវកាន់តំណែងសម្រាប់រយៈពេលដែលនៅសល់របស់អ្នកកាន់តំណែងមុន។

៧. កូរ៉ុមសមាជិក៧នាក់ នៃសមាជិកដែលត្រូវបានជ្រើសតាំងដោយ**តុលាការ** ជាចំនួនត្រូវការដើម្បីបង្កើតអង្គជំនុំជម្រះវិវាទ។

### មាត្រា៣៦
### អង្គជំនុំជម្រះវិវាទចំពោះកិច្ច

១. អង្គជំនុំជម្រះវិវាទបាតសមុទ្រត្រូវបង្កើតអង្គជំនុំជម្រះវិវាទចំពោះកិច្ច ដែលមានសមាជិក៣នាក់ ដើម្បីធ្វើចំណាត់ការលើវិវាទដែលបានបញ្ជូនមកខ្លួន អនុលោមតាមកថាខណ្ឌទី១(ខ) នៃមាត្រា១៨៨។ សមាសភាពរបស់អង្គជំនុំជម្រះវិវាទចំពោះកិច្ចនេះ ត្រូវកំណត់ដោយអង្គជំនុំជម្រះវិវាទបាតសមុទ្រ ដោយមានការឯកភាពពីគូភាគី។

២. ប្រសិនបើគូភាគីមិនឯកភាពលើសមាសភាពរបស់អង្គជំនុំជម្រះវិវាទចំពោះកិច្ចទេនោះ ភាគីនីមួយៗនៃវិវាទ ត្រូវតែងតាំងសមាជិកម្នាក់ ហើយសមាជិកទី៣ ត្រូវតែងតាំងតាមការព្រមព្រៀងរបស់ពួកគេ។ ប្រសិនបើគូភាគីមិនឯកភាព ឬប្រសិនបើភាគីណាមួយខកខានមិនបានតែងតាំង ប្រធានអង្គជំនុំជម្រះវិវាទបាតសមុទ្រត្រូវធ្វើការតែងតាំងសមាជិកម្នាក់ឬច្រើននាក់ភ្លាមៗចេញពីក្នុងចំណោសមាជិករបស់ខ្លួន បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគូភាគី។

៣. សមាជិកនៃអង្គជំនុំជម្រះវិវាទចំពោះកិច្ចមិនត្រូវជាអ្នកដែលកំពុងបម្រើការងារជូន ឬជាពលរដ្ឋនៃភាគីណាមួយក្នុងវិវាទឡើយ។

## មាត្រា៣៧
## ការចូលទៅដោះស្រាយវិវាទដោយអង្គជំនុំជម្រះវិវាទ

អង្គជំនុំជម្រះវិវាទត្រូវបើកចំហរចំពោះរដ្ឋគូភាគី **អាជ្ញាធរ** និងអង្គភាពដទៃទៀតដូចមានចែងក្នុងផ្នែកទី៥ នៃជំពូកទី១១។

## មាត្រា៣៨
## ច្បាប់អនុវត្ត

បន្ថែមពីលើបទប្បញ្ញត្តិនៃមាត្រា២៩៣ អង្គជំនុំជម្រះវិវាទបាតសមុទ្រនេះ ត្រូវអនុវត្តៈ

(ក) វិធានច្បាប់ បទបញ្ជា និងនីតិវិធីរបស់**អាជ្ញាធរ**ដែលត្រូវបានអនុម័តអនុលោមតាមអនុសញ្ញានេះ។ និង

(ខ) លក្ខខណ្ឌនៃកិច្ចសន្យាទាក់ទងនឹងសកម្មភាពនៅក្នុង**តំបន់**ចំពោះបញ្ហាដែលទាក់ទងនឹងកិច្ចសន្យាទាំងនោះ។

## មាត្រា៣៩
## ការអនុវត្តសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះវិវាទ

សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះវិវាទអាចត្រូវយកទៅអនុវត្តនៅក្នុងទឹកដីរបស់រដ្ឋភាគីតាមរបៀបដូចគ្នានឹងសាលក្រម ឬដីការបស់តុលាការជាន់ខ្ពស់បំផុតនៃរដ្ឋភាគីដែលការសុំអនុវត្តសេចក្ដីសម្រេចត្រូវបានធ្វើឡើងក្នុងទឹកដីរដ្ឋនោះ។

## មាត្រា៤០
## ការអនុវត្តផ្នែកដទៃទៀតនៃឧបសម្ព័ន្ធនេះ

១. ផ្នែកដទៃទៀតនៃឧបសម្ព័ន្ធនេះដែលមិនផ្ទុយនឹងផ្នែកនេះត្រូវយកមកអនុវត្តចំពោះអង្គជំនុំជម្រះវិវាទ។

២. ក្នុងការអនុវត្តមុខងាររបស់ខ្លួនទាក់ទងនឹងការប្រឹក្សាយោបល់ អង្គជំនុំជម្រះវិវាទត្រូវយកបទប្បញ្ញត្តិនៃឧបសម្ព័ន្ធនេះដែលទាក់ទងនឹងនីតិវិធីនៅចំពោះមុខ**តុលាការ**មកប្រើប្រាស់ជាមគ្គុទេសក៍ ក្នុងកម្រិតដែលអង្គជំនុំជម្រះវិវាទទទួលស្គាល់ថាអាចយកមកអនុវត្តបាន។

# ផ្នែកទី៥
# វិសោធនកម្ម

## មាត្រា៤១
## វិសោធនកម្ម

១. រាល់វិសោធនកម្មទៅលើឧបសម្ព័ន្ធនេះ ក្រៅពីវិសោធនកម្មលើជំពូកទី៤ អាចនឹងធ្វើទៅបានតែតាមមាត្រា៣១៣ ឬតាមសំឡេងគាំទ្រជាឯកច្ឆន្ទៈនៅក្នុងសន្និសីទដែលត្រូវបានកោះប្រជុំស្របតាមអនុសញ្ញានេះតែប៉ុណ្ណោះ។

២. វិសោធនកម្មលើជំពូកទី៤ អាចនឹងធ្វើទៅបានដោយស្របតាមមាត្រា៣១៤ប៉ុណ្ណោះ។

៣. តុលាការអាចដាក់ស្នើសុំធ្វើវិសោធនកម្មលើលក្ខន្តិកៈនេះ ក្នុងករណីដែលតុលាការគិតថាចាំបាច់ ដោយការទំនាក់ទំនងជាលាយលក្ខណ៍អក្សរទៅកាន់រដ្ឋភាគីដើម្បីសុំការពិចារណា ស្របតាមកថាខណ្ឌទី១និងទី២។

## ឧបសម្ព័ន្ធទី៧
## មជ្ឈត្តការ
### មាត្រា១
### ការផ្ដួចផ្ដើមបណ្ដឹង

ដោយអនុលោមតាមប្បញ្ញត្តិនៃជំពូកទី១៥ ភាគីវិវាទណាមួយអាចដាក់ពាក្យបណ្ដឹងឱ្យមានដំណើរការជំនុំជម្រះតាមនីតិវិធីមជ្ឈត្តការដូចមានចែងនៅក្នុងឧបសម្ព័ន្ធនេះដោយលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅដល់ភាគីម្ខាងទៀតឬបណ្ដាភាគីវិវាទ។ លិខិតជូនដំណឹងនេះត្រូវអមជាមួយសេចក្ដីថ្លែងការណ៍នៃការទាមទារ និងមូលហេតុនៃការទាមទារនោះ។

### មាត្រា២
### បញ្ជីឈ្មោះមជ្ឈត្តករ

១. អគ្គលេខាធិការអង្គការសហប្រជាជាតិមានភារកិច្ចរៀបចំ និងគ្រប់គ្រងបញ្ជីឈ្មោះមជ្ឈត្តករ។ រដ្ឋភាគីនីមួយៗមានសិទ្ធិជ្រើសតាំងមជ្ឈត្តករចំនួនបួនរូប ដែលសុទ្ធតែមានបទពិសោធផ្នែកកិច្ចការសមុទ្រ និងមានកេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់បំផុតថាយុត្តិធម៌ មានសមត្ថភាព និងសុចរិត។ ឈ្មោះបុគ្គលដែលត្រូវបានជ្រើសតាំង ត្រូវបញ្ចូលទៅក្នុងបញ្ជីឈ្មោះមជ្ឈត្តករ។

២. ប្រសិនបើនៅពេលណាមួយមជ្ឈត្តករដែលរដ្ឋភាគីមួយបានជ្រើសតាំងចូលទៅក្នុងបញ្ជីឈ្មោះមជ្ឈត្តករមានចំនួនតិចជាងបួនរូប រដ្ឋភាគីនោះមានសិទ្ធិជ្រើសតាំងមជ្ឈត្តករបន្ថែមតាមការចាំបាច់។

៣. ឈ្មោះរបស់មជ្ឈត្តករ ត្រូវនៅតែស្ថិតនៅក្នុងបញ្ជីឈ្មោះនេះរហូតដល់ពេលដែលមានការដកចេញវិញដោយរដ្ឋភាគីដែលបានធ្វើការជ្រើសតាំងរូបលោក មានន័យថា មជ្ឈត្តកររូបនោះនៅតែបន្តធ្វើការនៅក្រុមប្រឹក្សាមជ្ឈត្តការដែលខ្លួនត្រូវបានជ្រើសតាំងឱ្យបម្រើការងាររហូតដល់ការបញ្ចប់នីតិវិធីនៅក្រុមប្រឹក្សាមជ្ឈត្តការនោះ។

### មាត្រា៣
### ការបង្កើតក្រុមប្រឹក្សាមជ្ឈត្តការ

សម្រាប់គោលបំណងនៃដំណើរការនីតិវិធីតាមឧបសម្ព័ន្ធនេះ លើកលែងតែក្នុងករណីភាគីព្រមព្រៀងគ្នាផ្សេងពីនេះ ក្រុមប្រឹក្សាមជ្ឈត្តការត្រូវបានបង្កើតឡើងដូចខាងក្រោម៖

(ក) ក្រុមប្រឹក្សាមជ្ឈត្តការត្រូវមានសមាជិក៥រូប លើកលែងតែក្នុងករណីដូចមានចែង ក្នុងកថាខណ្ឌរង (ឆ)។

(ខ) ភាគីដើមបណ្ដឹងត្រូវជ្រើសតាំងសមាជិកមួយរូប ដែលជាអាទិភាពត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះដូចមានចែងនៅក្នុងមាត្រា២ នៃឧបសម្ព័ន្ធនេះ ដែលមជ្ឈត្តកររូបនេះក៏អាចជាពលរដ្ឋរបស់ខ្លួនផងដែរ។ ការជ្រើសតាំងនេះត្រូវបញ្ចូលទៅក្នុងលិខិតជូនដំណឹងដូចមានចែងក្នុងមាត្រា១ នៃឧបសម្ព័ន្ធនេះ។

(គ) នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងដូចមានចែងក្នុងមាត្រា១ នៃឧបសម្ព័ន្ធនេះ ភាគីវិវាទម្ខាងទៀតត្រូវជ្រើសតាំងសមាជិកមួយរូប ដែលជាអាទិភាពត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះមជ្ឈត្តករដែលអាចជាពលរដ្ឋរបស់ខ្លួនផងដែរ។ ប្រសិនបើពុំមានការជ្រើសតាំងសមាជិកនៅក្នុងរយៈពេលនេះទេ ភាគីដើមបណ្ដឹងអាចស្នើសុំឱ្យមានការជ្រើសតាំងនេះតាមកថាខណ្ឌរង (ង) នៅក្នុងរយៈពេលពីរសប្ដាហ៍ក្រោយផុតកំណត់រយៈពេលខាងលើ។

(ឃ) ចំណែកសមាជិកបីរូបផ្សេងទៀត ត្រូវជ្រើសតាំងដោយផ្អែកលើការព្រមព្រៀងគ្នារវាងភាគី។ ជាអាទិភាព ពួកគេត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះមជ្ឈត្តករ ប៉ុន្តែពួកគេត្រូវតែជាពលរដ្ឋរបស់រដ្ឋទីបី លើកលែងតែគូភាគីបានព្រមព្រៀងគ្នាផ្សេងពីនេះ។ ភាគីវិវាទត្រូវជ្រើសតាំងប្រធានក្រុមប្រឹក្សាមជ្ឈត្តការចេញពីក្នុងចំណោមសមាជិកទាំងបីរូបនេះ។ ប្រសិនបើ នៅក្នុងរយៈពេល៦០ថ្ងៃបន្ទាប់ពីទទួលបានលិខិតជូនដំណឹងដូចមានចែងនៅក្នុងមាត្រា១នៃឧបសម្ព័ន្ធនេះ ភាគីមិនអាចឈានដល់ការព្រមព្រៀងគ្នាលើការជ្រើសតាំងសមាជិកមួយរូប ឬច្រើនរូបនៃក្រុមប្រឹក្សា ដែលត្រូវជ្រើសតាំងតាមរយៈការព្រមព្រៀងឬទៅលើការជ្រើសតាំងប្រធានក្រុមប្រឹក្សានោះរាល់ការតែងតាំងនៅសេសសល់ដោយអនុលោមតាមកថាខណ្ឌរង (ង) នៅពេលមានសំណើពីភាគីណាមួយនៃវិវាទ។ សំណើនេះត្រូវធ្វើឡើងក្នុងរយៈពេលពីរសប្ដាហ៍ក្រោយផុតកំណត់រយៈពេល៦០ថ្ងៃខាងលើ។

(ង) ប្រសិនបើភាគីមិនបានព្រមព្រៀងគ្នាថា រាល់ការជ្រើសតាំងតាមកថាខណ្ឌរង (គ) និង (ឃ) ត្រូវធ្វើឡើងដោយបុគ្គលមួយរូប ឬរដ្ឋទីបីដែលជ្រើសរើសដោយភាគីទេ នោះប្រធានតុលាការអន្តរជាតិនីតិសមុទ្រ ចាំបាច់ត្រូវធ្វើការជ្រើសតាំងទាំងនេះ។ ប្រសិនបើប្រធានតុលាការអន្តរជាតិនីតិសមុទ្រមិនអាចបំពេញការងាររបស់ខ្លួនបាន តាមកថាខណ្ឌរងនេះ ឬប្រធានជាពលរដ្ឋនៃភាគីមួយនៃវិវាទនោះ ការជ្រើសតាំង ត្រូវធ្វើឡើងដោយសមាជិកដែលមានបទពិសោធច្រើនជាងគេបន្ទាប់ពីប្រធានតុលាការអន្តរជាតិនីតិសមុទ្រ ដែលជាអ្នកមានពេលវេលាគ្រប់គ្រាន់និងដែលមិនមែនជាពលរដ្ឋនៃភាគីវិវាទ។ រាល់ការជ្រើសតាំង តាមកថាខណ្ឌរងនេះ ត្រូវជ្រើសចេញពីបញ្ជីឈ្មោះមជ្ឈត្តករដូចមានចែងក្នុងមាត្រា២នៃឧបសម្ព័ន្ធនេះ នៅក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីទទួលបានសំណើពីភាគីណាមួយនៃវិវាទ និង ដោយមានការពិគ្រោះយោបល់ជាមួយគូភាគីវិវាទ។ សមាជិកដែលត្រូវបានជ្រើសតាំងត្រូវមានសញ្ជាតិផ្សេងៗគ្នា និងមិនត្រូវធ្វើការឬរស់នៅជាអចិន្ត្រៃយ៍នៅក្នុងដែនដីរបស់ភាគីវិវាទ ឬមិនមែនជាពលរដ្ឋរបស់ភាគីវិវាទឡើយ។

(ច) រាល់មុខតំណែងទំនេរនឹងត្រូវបំពេញតាមនីតិវិធីដែលបានកំណត់សម្រាប់ការជ្រើសតាំងលើកដំបូង។

(ឆ) បណ្ដាភាគីដែលមានផលប្រយោជន៍រួមគ្នា ត្រូវព្រមព្រៀងគ្នាជ្រើសតាំងសមាជិកមួយរូបសម្រាប់វេទិកា។ ក្នុងករណីដែលភាគីច្រើនមានផលប្រយោជន៍ដាច់ដោយឡែកពីគ្នា ឬក្នុងករណីដែលមិនមានការព្រមព្រៀងគ្នាថាតើមានផលប្រយោជន៍រួមគ្នាដែរឬទេ ភាគីនីមួយៗ ត្រូវជ្រើសតាំងសមាជិកមួយរូបសម្រាប់វេទិកា។ ចំនួនសមាជិកវេទិកាដែល ត្រូវបានជ្រើសតាំងដាច់ដោយឡែកដោយបណ្ដាភាគី ត្រូវតែមានចំនួន មួយរូបតិចជាងសមាជិកវេទិកា ដែលត្រូវបានជ្រើសតាំងរួមគ្នា។

(ជ) ក្នុងករណីមានវិវាទពាក់ព័ន្ធនឹងភាគីលើសពីពីរ បទប្បញ្ញត្តិនៃកថាខណ្ឌរង (ក) ដល់ (ច) ត្រូវយកមកអនុវត្តឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។

### មាត្រា៤

### មុខងាររបស់តុលាការមជ្ឈត្តការ

តុលាការមជ្ឈត្តការដែលត្រូវបានបង្កើតឡើងតាមមាត្រា៣នៃឧបសម្ព័ន្ធនេះ ត្រូវដំណើរការដោយអនុលោមតាមឧបសម្ព័ន្ធនេះ និងបទប្បញ្ញត្តិផ្សេងទៀតនៃអនុសញ្ញានេះ។

### មាត្រា៥

### នីតិវិធី

លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ តុលាការមជ្ឈត្តការត្រូវកំណត់នីតិវិធីរបស់ខ្លួនដោយធានាថា រាល់ភាគីមានឱកាសពេញលេញក្នុងការបញ្ចេញយោបល់ និងការពាររឿងក្ដីរបស់ខ្លួន។

### មាត្រា៦

### ករណីកិច្ចរបស់ភាគីវិវាទ

ភាគីវិវាទត្រូវសម្របសម្រួលការងាររបស់តុលាការមជ្ឈត្តការ ហើយជាពិសេស ដោយអនុលោមតាមច្បាប់របស់ខ្លួន ព្រមទាំងការប្រើប្រាស់គ្រប់មធ្យោបាយដែលខ្លួនមាន ត្រូវ ៖

(ក)ផ្ដល់ឱ្យតុលាការមជ្ឈត្តការនូវរាល់ឯកសារ ឋបនីយកណ្ឌ និងព័ត៌មានពាក់ព័ន្ធទាំងអស់ និង

(ខ) បើចាំបាច់ អនុញ្ញាតឱ្យតុលាការមជ្ឈត្តការដើកាកោះហៅសាក្សី ឬអ្នកជំនាញ និងទទួលភស្តុតាង ព្រមទាំងចុះពិនិត្យទីតាំងដែលពាក់ព័ន្ធនឹងករណីវិវាទបាន។

### មាត្រា៧

### ការចំណាយ

លើកលែងតែតុលាការមជ្ឈត្តការបានសម្រេចផ្សេងពីនេះដោយកាលៈទេសៈដោយឡែកនៃរឿងក្ដី ការចំណាយចំពោះតុលាការមជ្ឈត្តការ រួមទាំងលាភការរបស់សមាជិកខ្លួន ត្រូវជាបន្ទុកស្មើៗគ្នារបស់ភាគីវិវាទ ។

### មាត្រា៨

### ការទាមទារឱ្យមានសំឡេងភាគច្រើនចំពោះការធ្វើសេចក្ដីសម្រេច

សេចក្ដីសម្រេចរបស់តុលាការមជ្ឈត្តការ ត្រូវធ្វើឡើងដោយសំឡេងឆ្នោតភាគច្រើននៃសមាជិករបស់ខ្លួន។ អវត្តមាន ឬអនុបវាទដោយសមាជិកតិចជាងពាក់កណ្ដាល នឹងមិនរារាំងតុលាការមជ្ឈត្តការ មិនឱ្យធ្វើសេចក្ដីសម្រេចនោះទេ។ ក្នុងករណីមានសំឡេងឆ្នោតស្មើគ្នា នោះប្រធានតុលាការមជ្ឈត្តការ មានសំឡេងឆ្នោតឧត្តមានុភាព។

## មាត្រា៩

## ការមិនចូលបង្ហាញខ្លួន

ប្រសិនបើភាគីណាមួយនៃវិវាទមិនបានចូលបង្ហាញខ្លួនចំពោះមុខតុលាការមជ្ឈត្តការ ឬខកខានមិនបានការពារខ្លួន នោះភាគីម្ខាងទៀតអាចស្នើសុំតុលាការមជ្ឈត្តការឱ្យបន្តនីតិវិធី និងចេញមជ្ឈត្តវិនិច្ឆ័យ។ ករណីភាគីណាមួយអវត្តមាន ឬខកខានមិនបានការពារខ្លួន ករណីនេះនឹងមិន រារាំង ដំណើរការនីតិវិធី ឡើយ។ មុនពេលចេញមជ្ឈត្តវិនិច្ឆ័យតុលាការមជ្ឈត្តការត្រូវធានាថាខ្លួនមិនត្រឹមតែមានសមត្ថកិច្ចលើវិវាទប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវធានាផងដែរថា ការប្តឹងទាមទារមានមូលដ្ឋានត្រឹមត្រូវទាំងអង្គហេតុ និងទាំងអង្គច្បាប់។

## មាត្រា១០

## មជ្ឈត្តវិនិច្ឆ័យ

មជ្ឈត្តវិនិច្ឆ័យរបស់តុលាការមជ្ឈត្តការ ត្រូវផ្តោតតែទៅលើកម្មវត្ថុនៃវិវាទប៉ុណ្ណោះ និងត្រូវមានសំអាងហេតុ។ មជ្ឈត្តវិនិច្ឆ័យត្រូវដាក់ឈ្មោះរបស់សមាជិកដែលបានចូលរួម និងកាលបរិច្ឆេទចេញមជ្ឈត្តវិនិច្ឆ័យ។ សមាជិកនៃតុលាការមជ្ឈត្តការអាចភ្ជាប់នូវមតិដោយឡែក ឬមតិជំទាស់របស់ខ្លួននៅក្នុងមជ្ឈត្តវិនិច្ឆ័យនេះបានផងដែរ។

## មាត្រា១១

## លក្ខណៈស្ថាពរនៃមជ្ឈត្តវិនិច្ឆ័យ

មជ្ឈត្តវិនិច្ឆ័យត្រូវចូលជាស្ថាពរនិងគ្មានបណ្តឹងឧទ្ធរណ៍ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាជាមុនឱ្យមាននីតិវិធីឧទ្ធរណ៍។ ភាគីវិវាទត្រូវអនុវត្តឱ្យស្របតាមមជ្ឈត្តវិនិច្ឆ័យនេះ។

## មាត្រា១២

## ការបកស្រាយ ឬការអនុវត្តមជ្ឈត្តវិនិច្ឆ័យ

១. ក្នុងករណីភាគីវិវាទខ្វែងគំនិតគ្នាចំពោះ ការបកស្រាយ ឬរបៀបអនុវត្តមជ្ឈត្តវិនិច្ឆ័យ ភាគីណាមួយអាចបញ្ជូនការខ្វែងគំនិតគ្នានេះទៅកាន់តុលាការមជ្ឈត្តការដែលចេញមជ្ឈត្តវិនិច្ឆ័យនេះ។ រាល់មុខតំណែងទំនេរក្នុងវេទិកានេះ នឹងត្រូវបំពេញតាមរបៀបនៃការជ្រើសតាំងសមាជិកតុលាការមជ្ឈត្តវិនិច្ឆ័យនាលើកដំបូង។

២. ការខ្វែងគំនិតគ្នានេះអាចនឹងត្រូវបញ្ជូនទៅកាន់តុលាការ ឬវេទិកាមួយទៀតស្របតាមមាត្រា២៨៧ ដោយមានការយល់ព្រម ពីភាគីវិវាទទាំងអស់។

## មាត្រា១៣

## ការអនុវត្តចំពោះនីតិបុគ្គលផ្សេងទៀតក្រៅពីរដ្ឋភាគី

បទប្បញ្ញត្តិនៃឧបសម្ព័ន្ធនេះ ត្រូវយកមកអនុវត្តដូចគ្នាចំពោះរាល់វិវាទដែលពាក់ព័ន្ធនឹងនីតិបុគ្គលផ្សេងទៀតក្រៅពីរដ្ឋភាគីផងដែរ។

## ឧបសម្ព័ន្ធទី៨
## មជ្ឈត្តការពិសេស
### មាត្រា១
### ការផ្តួចផ្តើមបណ្តឹង

ដោយអនុលោមតាមបទប្បញ្ញត្តិនៃជំពូកទី១៥ ភាគីណាមួយនៃវិវាទដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តមាត្រានៃអនុសញ្ញានេះ ទាក់ទងនឹង (១)ជលផល (២)ការការពារនិងការអភិរក្សបរិស្ថានសមុទ្រ (៣) ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ឬ(៤)ការធ្វើនាវាចរណ៍ រាប់បញ្ចូលទាំងការបំពុលពីនាវានិងការបំពុលដោយការចាក់កាកសំណល់ចោល អាចដាក់ពាក្យប្តឹងទៅកាន់នីតិវិធីមជ្ឈត្តការពិសេស ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនេះ ដោយលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀត ឬបណ្តាភាគីនៃវិវាទ។ លិខិតជូនដំណឹងនេះត្រូវអមជាមួយសេចក្តីថ្លែងការណ៍នៃការទាមទារ និងមូលហេតុនៃការទាមទារនោះផងដែរ។

### មាត្រា២
### បញ្ជីឈ្មោះអ្នកជំនាញ

១. បញ្ជីឈ្មោះអ្នកជំនាញ នឹងត្រូវបង្កើតឡើង និងគ្រប់គ្រងទៅតាមវិស័យនីមួយៗ (១)ជលផល (២)ការការពារនិងការអភិរក្សបរិស្ថានសមុទ្រ (៣)ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ឬ(៤)ការធ្វើនាវាចរណ៍ រាប់បញ្ចូលទាំងការបំពុលពីនាវា និងការបំពុលដោយការចាក់កាកសំណល់ចោល។

២. បញ្ជីឈ្មោះអ្នកជំនាញត្រូវបានរៀបចំនិងគ្រប់គ្រងតាមវិស័យដូចជា វិស័យជលផលដោយអង្គការស្បៀងអាហារនិងកសិកម្មនៃរង្គការសហប្រជាជាតិ វិស័យការពារនិងអភិរក្សបរិស្ថានសមុទ្រដោយអង្គការកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ វិស័យការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រដោយគណៈកម្មការអន្តររដ្ឋាភិបាលទទួលបន្ទុកភូមិសាស្ត្រមហាសមុទ្រ ហើយវិស័យនាវាចរណ៍រួមទាំងការបំពុលពីនាវានិងការបំពុលដោយការចាក់កាកសំណល់ចោលដោយអង្គការនាវាចរណ៍សមុទ្រអន្តរជាតិ។ ឬជាជម្រើស គ្រប់ករណីខាងលើ បញ្ជីឈ្មោះអ្នកជំនាញត្រូវរៀបចំនិងគ្រប់គ្រងដោយអង្គភាពចំណុះដែលអង្គការ កម្មវិធី ឬគណៈកម្មការពាក់ព័ន្ធបានប្រគល់ភារកិច្ចជូន។

៣. រដ្ឋភាគីនីមួយៗមានសិទ្ធិជ្រើសតាំងអ្នកជំនាញចំនួនពីររូបតាមវិស័យនីមួយៗ ដែលមានសមត្ថភាពនិងមានការទទួលស្គាល់ជាទូទៅផ្នែកច្បាប់ វិទ្យាសាស្ត្រ ឬបច្ចេកទេស និងមានកេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់បំផុតថាយុត្តិធម៌ និងសុចរិត ។ ឈ្មោះបុគ្គលដែលត្រូវបានជ្រើសតាំងតាមវិស័យនីមួយៗ ត្រូវបញ្ចូលក្នុងបញ្ជីឈ្មោះឱ្យបានត្រឹមត្រូវ។

៤. ប្រសិនបើនៅពេលណាមួយអ្នកជំនាញដែលរដ្ឋភាគីមួយបានជ្រើសតាំងទៅក្នុងបញ្ជីឈ្មោះអ្នកជំនាញមានចំនួនតិចជាងពីររូប រដ្ឋភាគីនោះមានសិទ្ធិជ្រើសតាំងអ្នកជំនាញបន្ថែមតាមការចាំបាច់។

៥. ឈ្មោះអ្នកជំនាញ ត្រូវស្ថិតនៅក្នុងបញ្ជីឈ្មោះនេះ រហូតដល់ពេលដែលមានការដកចេញវិញដោយរដ្ឋភាគីដែលបានធ្វើការជ្រើសតាំងនោះ មានន័យថាអ្នកជំនាញរូបនោះនៅតែបន្តបម្រើការងារតុលាការមជ្ឈត្តការពិសេស ដែលខ្លួនត្រូវបានជ្រើសតាំងឱ្យបម្រើការងាររហូតដល់បញ្ចប់នីតិវិធីនៅតុលាការមជ្ឈត្តការពិសេសនោះ។

## មាត្រា៣
## ការបង្កើតតុលាការមជ្ឈត្តការពិសេស

សម្រាប់គោលបំណងនៃដំណើរការនីតិវិធីតាមឧបសម្ព័ន្ធនេះ លើកលែងតែភាគីព្រមព្រៀងគ្នាផ្សេងពីនេះ តុលាការមជ្ឈត្តការពិសេសត្រូវបានបង្កើតឡើងដូច ខាងក្រោម ៖

(ក) តុលាការមជ្ឈត្តការពិសេសត្រូវមានសមាជិក៥រូប លើកលែងតែក្នុងករណីដូចមានចែងនៅក្នុងកថាខណ្ឌរង (ឆ) ។

(ខ) ភាគីដើមបណ្តឹងត្រូវជ្រើសតាំងសមាជិកពីររូប ដែលជាអាទិភាពត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះសមស្រប ឬពីបណ្តាបញ្ជីឈ្មោះដូចមានចែងក្នុងមាត្រា២ នៃឧបសម្ព័ន្ធនេះ ដែលទាក់ទងនឹងបញ្ហាវិវាទ ដែលសមាជិកមួយរូបអាចជាពលរដ្ឋរបស់ខ្លួនបានផងដែរ។ ការជ្រើសតាំងនេះ ត្រូវបញ្ចូលទៅក្នុងលិខិតជូនដំណឹងដូចមានចែងក្នុងមាត្រា១នៃឧបសម្ព័ន្ធនេះ។

(គ) នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងដូចមានចែងក្នុងមាត្រា១ នៃឧបសម្ព័ន្ធនេះ ភាគីវិវាទម្ខាងទៀតត្រូវជ្រើសតាំងសមាជិកពីររូប ដែលជាអាទិភាពត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះសមស្រប ឬបញ្ជីឈ្មោះដែលទាក់ទងនឹងបញ្ហាវិវាទ ដែលក្នុងនោះសមាជិកមួយរូបក៏អាចជាពលរដ្ឋរបស់ខ្លួនបានផងដែរ។ ប្រសិនបើពុំមានការជ្រើសតាំងសមាជិកនៅក្នុងរយៈពេលនេះទេ ភាគីដើមបណ្តឹងអាចស្នើសុំឱ្យមានការជ្រើសតាំងនេះតាមកថាខណ្ឌរង(ង) នៅក្នុងរយៈពេលពីរសប្តាហ៍ក្រោយផុតកំណត់រយៈពេលខាងលើ។

(ឃ) ភាគីវិវាទត្រូវព្រមព្រៀងលើការជ្រើសតាំងប្រធានតុលាការមជ្ឈត្តការពិសេស ដែលជាអាទិភាពត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះសមស្រប ប៉ុន្តែត្រូវតែជាពលរដ្ឋរបស់រដ្ឋទីបី លើកលែងតែភាគីបានព្រមព្រៀងគ្នាផ្សេងពីនេះ។ ប្រសិនបើនៅក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីទទួលបានលិខិតជូនដំណឹងដូចមានចែងក្នុងមាត្រា១នៃឧបសម្ព័ន្ធនេះ ភាគីមិនអាចឈានដល់ការព្រមព្រៀងគ្នាលើការជ្រើសតាំងប្រធានតុលាការទេនោះ ការជ្រើសតាំងនេះ ត្រូវធ្វើដោយអនុលោមតាមកថាខណ្ឌរង (ង) នៅពេលមានសំណើពីភាគី វិវាទណាមួយ។ សំណើនេះត្រូវធ្វើឡើងនៅក្នុងរយៈពេលពីរសប្តាហ៍ក្រោយផុតកំណត់រយៈពេល ៣០ ថ្ងៃខាងលើ។

(ង) លើកលែងតែភាគីមិនបានព្រមព្រៀងគ្នា ការជ្រើសតាំងខាងលើត្រូវធ្វើឡើងដោយបុគ្គលមួយរូប ឬរដ្ឋទីបីដែលជ្រើសតាំងដោយភាគីទេ នោះអគ្គលេខាធិការអង្គការសហប្រជាជាតិ ចាំបាច់ត្រូវជ្រើសតាំងក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលសំណើដូចមានចែងក្នុងកថាខណ្ឌរង(គ) និង(ឃ)។ រាល់ការជ្រើសតាំងតាមកថាខណ្ឌរងនេះ ត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះសមស្រប ឬបញ្ជីឈ្មោះអ្នកជំនាញដូចមានចែងក្នុងមាត្រា២នៃឧបសម្ព័ន្ធនេះ ដោយមានការពិគ្រោះយោបល់គ្នាជាមួយភាគីវិវាទ និងអង្គការអន្តរជាតិដែលសមស្រប។ សមាជិកដែលត្រូវបានជ្រើសតាំងនេះត្រូវមានសញ្ជាតិផ្សេងៗគ្នា និងមិនត្រូវធ្វើការឬរស់នៅជាអចិន្ត្រៃយ៍នៅក្នុងដែនដីរបស់ភាគីវិវាទ ឬមិនមែនជាពលរដ្ឋរបស់ភាគីវិវាទឡើយ។

(ច) រាល់មុខតំណែងនៅទំនេរត្រូវបំពេញតាមនីតិវិធីដែលបានកំណត់សម្រាប់ការជ្រើសតាំងនាលើកដំបូង។

(ឆ) បណ្តាភាគីដែលមានផលប្រយោជន៍រួមគ្នា ត្រូវព្រមព្រៀងគ្នាជ្រើសតាំងសមាជិកមួយរូបសម្រាប់តុលាការមជ្ឈត្តការ។ ក្នុងករណីដែលភាគីភាគច្រើនមានផលប្រយោជន៍ដាច់ដោយឡែកពីគ្នា ឬក្នុងករណីដែលមិនមានការព្រមព្រៀងគ្នាថាតើមានផលប្រយោជន៍រួមគ្នាដែរឬទេ នោះភាគីនីមួយៗត្រូវជ្រើសតាំងសមាជិកមួយរូបសម្រាប់តុលាការមជ្ឈត្តការនេះ។

(ជ) ក្នុងករណីមានវិវាទពាក់ព័ន្ធនឹងភាគីលើសពីពីរ បទប្បញ្ញត្តិនៃកថាខណ្ឌរង (ក) ដល់ (ច) ត្រូវយកមកអនុវត្តឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។

## មាត្រា៤

## បទប្បញ្ញត្តិទូទៅ

មាត្រា៤ ដល់មាត្រា១៣ នៃឧបសម្ព័ន្ធទី៧ ត្រូវយកមកអនុវត្តដូចគ្នាចំពោះរាល់កិច្ចដំណើរការនីតិវិធីនៅមជ្ឈត្តការពិសេស ដោយអនុលោមតាមឧបសម្ព័ន្ធនេះ។

## មាត្រា៥

## ការស្វែងរកការពិត

១. ភាគីនៃវិវាទដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលទាក់ទងនឹងវិស័យ (១)ជលផល (២)ការការពារនិងការអភិរក្សបរិស្ថានសមុទ្រ (៣)ការស្រាវជ្រាវវិទ្យាសាស្ត្រអំពីសមុទ្រ ឬ (៤)ការធ្វើនាវាចរណ៍ រាប់បញ្ចូលទាំងការបំពុលពីនាវា និងការបំពុលដោយការចាក់កាកសំណល់ចោល អាចព្រមព្រៀងគ្នាគ្រប់ពេលវេលាលើកសំណើសុំបង្កើតតុលាការមជ្ឈត្តការពិសេសដោយអនុលោមតាមមាត្រា៣ នៃឧបសម្ព័ន្ធនេះ ដើម្បីធ្វើការអង្កេត និងស្វែងរកការពិតដែលជាមូលហេតុនាំឱ្យកើតមានវិវាទ។

# ឧបសម្ព័ន្ធទី៩
# ការចូលរួមរបស់អង្គការអន្តរជាតិ

## មាត្រា១
## ការប្រើប្រាស់វាក្យសព្ទ

សម្រាប់គោលបំណងនៃមាត្រា៣០៥ និងឧបសម្ព័ន្ធនេះ "អង្គការអន្តរជាតិ" សំដៅដល់អង្គការអន្តររដ្ឋាភិបាល ដែលបង្កើតឡើងដោយរដ្ឋជាច្រើន ហើយដែលរដ្ឋជាសមាជិកបានផ្ទេរសមត្ថកិច្ចលើការចាត់ចែងបញ្ហាដែលស្ថិតក្រោមអនុសញ្ញានេះ រួមមានសមត្ថកិច្ចចុះសន្ធិសញ្ញាពាក់ព័ន្ធនឹងបញ្ហាទាំងនោះផងដែរ។

## មាត្រា២
## ហត្ថលេខា

អង្គការអន្តរជាតិអាចចុះហត្ថលេខាលើអនុសញ្ញានេះបាន ប្រសិនបើសមាជិកភាគច្រើនរបស់ខ្លួនគឺជាហត្ថលេខីនៃអនុសញ្ញានេះ។ នៅពេលចុះហត្ថលេខា អង្គការអន្តរជាតិត្រូវធ្វើសេចក្តីប្រកាសបញ្ជាក់រាល់បញ្ហាដែលស្ថិតក្រោមអនុសញ្ញានេះនិងសមត្ថកិច្ចពាក់ព័ន្ធនឹងបញ្ហាទាំងនេះ ត្រូវបានសមាជិកដែលជាហត្ថលេខីនៃអនុសញ្ញាបានផ្ទេរមកឱ្យខ្លួន ព្រមទាំងបញ្ជាក់ពីលក្ខណៈ និងទំហំនៃសមត្ថកិច្ចនោះផងដែរ។

## មាត្រា៣
## ការបញ្ជាក់និងការចូលរួមជាផ្លូវការ

១. អង្គការអន្តរជាតិអាចតម្កល់លិខិតបញ្ជាក់ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការ ប្រសិនបើសមាជិកភាគច្រើនរបស់ខ្លួនបានតម្កល់លិខិតស្តីពីការផ្តល់សច្ចាប្រណ័តឬការចូលរួមជាហត្ថលេខីរួចហើយនោះ។

២. លិខិតដែលបានតម្កល់ដោយអង្គការអន្តរជាតិ ត្រូវរួមមានការសន្យា និងសេចក្តីប្រកាសដូចមានចែងនៅក្នុងមាត្រា៤ និងមាត្រា៥ នៃឧបសម្ព័ន្ធនេះផងដែរ។

## មាត្រា៤
## ទំហំនៃការចូលរួម និងសិទ្ធិ និងកាតព្វកិច្ច

១. លិខិតស្តីពីការបញ្ជាក់ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរបស់អង្គការអន្តរជាតិ ត្រូវមានការ សន្យាយល់ព្រមទទួលយកសិទ្ធិនិងកាតព្វកិច្ចរបស់បណ្តារដ្ឋនៅក្រោមអនុសញ្ញានេះ ដែលទាក់ទងនឹងបញ្ហាដែលរដ្ឋជាសមាជិករបស់ខ្លួននិងជាភាគីនៃអនុសញ្ញានេះ បានផ្ទេរសមត្ថកិច្ចលើការចាត់ចែងមកឱ្យខ្លួន។

២. អង្គការអន្តរជាតិគឺជាភាគីនៃអនុសញ្ញានេះក្នុងទំហំដែលខ្លួនមានសមត្ថកិច្ចស្របតាមសេចក្តីប្រកាសលិខិតទំនាក់ទំនងព័ត៌មាន ឬលិខិតជូនដំណឹងដូចមានចែងនៅក្នុងមាត្រា៥ នៃឧបសម្ព័ន្ធនេះ។

៣. អង្គការអន្តរជាតិត្រូវអនុវត្តសិទ្ធិនិងបំពេញកាតព្វកិច្ចដែលបណ្តារដ្ឋជាសមាជិករបស់ខ្លួននិងជាភាគីនៃអនុសញ្ញាទាក់ទងនឹងបញ្ហាដែលរដ្ឋជាសមាជិកទាំងនោះបានផ្ទេរសមត្ថកិច្ចលើការចាត់ចែងមកឱ្យខ្លួន។ រដ្ឋជាសមាជិកនៃអង្គការអន្តរជាតិមិនត្រូវអនុវត្តនូវសមត្ថកិច្ចដែលខ្លួនបានផ្ទេរទៅឱ្យអង្គការរួចហើយនោះឡើយ។

៤. នៅគ្រប់ករណីទាំងអស់ ការចូលរួមរបស់អង្គការអន្តរជាតិនៅក្នុងអនុសញ្ញានេះ នឹងមិននាំឱ្យកើនឡើងនូវភាពជាតំណាងរបស់រដ្ឋជាសមាជិករបស់ខ្លួនដែលជារដ្ឋភាគីនោះឡើយ រួមមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តផងដែរ។

៥. នៅគ្រប់ករណីទាំងអស់ ការចូលរួមរបស់អង្គការអន្តរជាតិនៅក្នុងអនុសញ្ញានេះនឹងមិនផ្តល់នូវសិទ្ធិណាមួយនៅក្រោមអនុសញ្ញានេះទៅឱ្យរដ្ឋជាសមាជិករបស់អង្គការដែលមិនមែនជារដ្ឋភាគីនៃអនុសញ្ញានេះឡើយ។

៦. ក្នុងករណីមានភាពផ្ទុយគ្នារវាងកាតព្វកិច្ចរបស់អង្គការអន្តរជាតិនៅក្រោមអនុសញ្ញានេះ ជាមួយនឹងកាតព្វកិច្ចរបស់អង្គការអន្តរជាតិនៅក្រោមកិច្ចព្រមព្រៀងបង្កើតអង្គការ ឬសកម្មភាពណាមួយដែលពាក់ព័ន្ធនោះ កាតព្វកិច្ចនៅក្រោមអនុសញ្ញានេះត្រូវមានឧត្តមានុភាព។

## មាត្រា៥
## សេចក្តីប្រកាស លិខិតជូនដំណឹង និងលិខិតទំនាក់ទំនង

១. លិខិតស្តីពីការបញ្ជាក់ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរបស់អង្គការអន្តរជាតិត្រូវមានសេចក្តីប្រកាសបញ្ជាក់ពីបញ្ហាដែលស្ថិតក្រោមអនុសញ្ញានេះ ហើយសមត្ថកិច្ចពាក់ព័ន្ធនឹងបញ្ហាទាំងនេះត្រូវបានរដ្ឋជាសមាជិកអង្គការអន្តរជាតិនិងជាភាគីនៃអនុសញ្ញាបានផ្ទេរមកឱ្យខ្លួន។

២. រដ្ឋជាសមាជិករបស់អង្គការអន្តរជាតិត្រូវធ្វើសេចក្តីប្រកាសបញ្ជាក់រាល់បញ្ហាដែលស្ថិតក្រោមអនុសញ្ញានេះនិងសមត្ថកិច្ចពាក់ព័ន្ធនឹងបញ្ហាទាំងនេះដែលខ្លួនបានផ្ទេរទៅឱ្យអង្គការអន្តរជាតិនៅពេលដែលខ្លួនផ្តល់សច្ចានុម័ត ឬនៅពេលខ្លួនចូលជាសមាជិកអនុសញ្ញានេះ ឬនៅពេលដែលអង្គការអន្តរជាតិដាក់លិខិតស្តីពីការបញ្ជាក់ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការ ដោយកំណត់យកសេចក្តីប្រកាសចុងក្រោយ។

៣. បណ្តារដ្ឋជាសមាជិករបស់អង្គការអន្តរជាតិនិងជាភាគីនៃអនុសញ្ញានេះ ត្រូវសន្មត់ថាមានសមត្ថកិច្ចលើរាល់បញ្ហាដែលស្ថិតក្រោមអនុសញ្ញានេះ ទោះបីជាមានការផ្ទេរសមត្ថកិច្ចពាក់ព័ន្ធនឹងបញ្ហាទាំងនេះមិនត្រូវបានរដ្ឋទាំងនោះធ្វើការប្រកាសជូនដំណឹង ឬទំនាក់ទំនងឱ្យដឹងច្បាស់តាមរយៈមាត្រានេះក៏ដោយ។

៤. អង្គការអន្តរជាតិ និងរដ្ឋជាសមាជិករបស់ខ្លួនដែលជារដ្ឋភាគីនៃអនុសញ្ញានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ស្ថាប័នរក្សាទុកឯកសារនៃអនុសញ្ញានេះឱ្យបានជ្រាបអំពីការប្រែប្រួលនៃការបែងចែកសមត្ថកិច្ច រួមមានការផ្ទេរសមត្ថកិច្ចថ្មីៗដែលបានបញ្ជាក់នៅក្នុងសេចក្តីប្រកាសក្រោមកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រានេះ។

៥. រដ្ឋភាគីនៃអនុសញ្ញានេះមានសិទ្ធិស្នើឱ្យអង្គការអន្តរជាតិនិងរដ្ឋជាសមាជិករបស់អង្គការអន្តរជាតិដែលជារដ្ឋភាគីអនុសញ្ញាផ្តល់ព័ត៌មានបញ្ជាក់អ្នកមានសមត្ថកិច្ចពាក់ព័ន្ធនឹងវិវាទជាក់លាក់ដែលបានកើតឡើង។ អង្គការអន្តរជាតិនិងរដ្ឋជាសមាជិករបស់អង្គការអន្តរជាតិត្រូវផ្តល់ព័ត៌មាននេះក្នុងរយៈពេលសមស្របណាមួយ។ អង្គការអន្តរជាតិនិងរដ្ឋជាសមាជិករបស់អង្គការអន្តរជាតិក៏មានសិទ្ធិផ្តួចផ្តើមផ្តល់ព័ត៌មាននេះដោយខ្លួនឯងផងដែរ។

៦. សេចក្តីប្រកាស លិខិតជូនដំណឹង និងលិខិតទំនាក់ទំនងព័ត៌មាននៅក្រោមមាត្រានេះ ត្រូវបញ្ជាក់ពីស្ថានភាពនិងទំហំសមត្ថកិច្ចដែលបានផ្ទេរ។

## មាត្រា៦
## ភារកិច្ច និងការទទួលខុសត្រូវ

១. ភាគីដែលមានសមត្ថកិច្ចនៅក្រោមមាត្រា៥ នៃឧបសម្ព័ន្ធនេះ ត្រូវទទួលខុសត្រូវលើករណីដែលខ្លួនមិនបានបំពេញកាតព្វកិច្ច ឬករណីបំពានផ្សេងៗទៀតមកលើអនុសញ្ញានេះ។

២. រដ្ឋភាគីនៃអនុសញ្ញានេះអាចស្នើឱ្យអង្គការអន្តរជាតិ ឬរដ្ឋជាសមាជិករបស់អង្គការអន្តរជាតិដែលជារដ្ឋភាគីនៃអនុសញ្ញានេះ ផ្តល់ព័ត៌មានបញ្ជាក់អំពីអ្នកទទួលខុសត្រូវពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ដែលបានលើកឡើង។ អង្គការអន្តរជាតិ និងរដ្ឋជាសមាជិកដែលពាក់ព័ន្ធត្រូវផ្តល់ព័ត៌មាននេះ។ភាគីដែលមិនផ្តល់ព័ត៌មាននេះនៅក្នុងរយៈពេលសមស្របណាមួយ ឬព័ត៌មានដែលផ្តល់ឱ្យមានលក្ខណៈផ្ទុយគ្នានឹងត្រូវទទួលខុសត្រូវរួមនិងចំណែករបស់ខ្លួន។

## មាត្រា៧
## ការដោះស្រាយវិវាទ

១. នៅពេលឬក្រោយពេលដែលអង្គការអន្តរជាតិបានតម្កល់លិខិតស្តីពីការបញ្ជាក់ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរួច អង្គការអន្តរជាតិមានសិទ្ធិសរសេរលិខិតជាលាយលក្ខណ៍អក្សរជ្រើសរើសយកមធ្យោបាយមួយឬច្រើន ដើម្បីដោះស្រាយវិវាទដែលទាក់ទងនឹងការបកស្រាយឬការអនុវត្តអនុសញ្ញានេះ ដូចមានចែងនៅក្នុងមាត្រា២៨៧ កថាខណ្ឌទី១ (ក) (គ) ឬ (ឃ) ។

២. ជំពូកទី១៥ ត្រូវអនុវត្តដូចគ្នាផងដែរចំពោះករណីវិវាទរវាងបណ្តារដ្ឋភាគីនៃអនុសញ្ញានេះ ដែលក្នុងនោះមានភាគីជាអង្គការអន្តរជាតិមួយឬច្រើន។

៣. ក្នុងករណីដែលអង្គការអន្តរជាតិមួយនិងរដ្ឋជាសមាជិករបស់ខ្លួនមួយឬច្រើនគឺជាភាគីរួមនៃវិវាទឬជាភាគីមានផលប្រយោជន៍រួម នោះអង្គការអន្តរជាតិនេះនឹងត្រូវចាត់ទុកថាបានទទួលយកនីតិវិធីតែមួយសម្រាប់ដោះស្រាយវិវាទដូចគ្នានឹងរដ្ឋជាសមាជិកផងដែរ ប៉ុន្តែក្នុងករណីដែលរដ្ឋជាសមាជិកសម្រេចជ្រើសរើសយកតុលាការយុត្តិធម៌អន្តរជាតិ ដោយផ្អែកលើមាត្រា២៨៧ វិញ នោះអង្គការអន្តរជាតិនិងរដ្ឋជាសមាជិកដែលពាក់ព័ន្ធត្រូវចាត់ទុកថាបានទទួលយកដំណើរការមជ្ឈត្តកម្មតាមឧបសម្ព័ន្ធទី៧ លើកលែងតែបណ្តាភាគីនៃវិវាទបានព្រមព្រៀងគ្នាផ្ទុយពីនេះ។

## មាត្រា៨
## ភាពអាចអនុវត្តបាននៃជំពូកទី១៧

ជំពូកទី១៧ ត្រូវអនុវត្តដូចគ្នាផងដែរចំពោះអង្គការអន្តរជាតិ លើកលែងតែចំណុចខាងក្រោម៖

(ក) លិខិតស្តីពីការបញ្ជាក់ ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរបស់អង្គការអន្តរជាតិ មិនត្រូវលើកយកមកពិចារណានៅក្នុងការអនុវត្តកថាខណ្ឌទី១ មាត្រា៣០៨ នោះទេ។

(ខ) (i) អង្គការអន្តរជាតិមានសមត្ថកិច្ចផ្តាច់មុខពាក់ព័ន្ធនឹងការអនុវត្តមាត្រា៣១២ ដល់មាត្រា៣១៥ ក្នុងកម្រិតដែលអង្គការអន្តរជាតិមានសមត្ថកិច្ចនៅក្រោមមាត្រា៥ នៃឧបសម្ព័ន្ធនេះ លើកម្មវត្ថុទាំងមូលនៃការធ្វើវិសោធនកម្ម។

(ii) សម្រាប់គោលបំណងនៃការអនុវត្តកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា៣១៦ អង្គការអន្តរជាតិមានសមត្ថកិច្ចក្រោមមាត្រា៥ នៃឧបសម្ព័ន្ធនេះ លិខិតស្តីពីការបញ្ជាក់ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរបស់អង្គការអន្តរជាតិទៅលើវិសោធនកម្មមួយត្រូវបានចាត់ទុកជាលិខិតូបករណ៍ដែលផ្តល់សច្ចានុម័តឬចូលជាសមាជិករបស់រដ្ឋជាសមាជិកនីមួយៗដែលជារដ្ឋភាគីនៃអនុសញ្ញា។

(iii) លិខិតស្តីពីការបញ្ជាក់ឬការចូលរួមក្នុងអនុសញ្ញាជាផ្លូវការរបស់អង្គការអន្តរជាតិមិនត្រូវលើកយកមកពិចារណានៅក្នុងការអនុវត្តកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា៣១៦ ពាក់ព័ន្ធនឹងវិសោធនកម្មផ្សេងទៀតទេ។

(គ) (i) អង្គការអន្តរជាតិមិនអាចដកខ្លួនពីអនុសញ្ញានេះស្របតាមមាត្រា៣១៧ បាននោះទេ ប្រសិនរដ្ឋសមាជិកអង្គការអន្តរជាតិនេះគឺជារដ្ឋភាគីអនុសញ្ញា និងនៅតែបន្តបំពេញបានតាមគុណវុឌ្ឍិដូចមានចែងនៅក្នុងមាត្រា១ នៃឧបសម្ព័ន្ធនេះ។

(ii) អង្គការអន្តរជាតិអាចដកខ្លួនពីអនុសញ្ញានេះបាន ប្រសិនបើអង្គការអន្តរជាតិពុំមានរដ្ឋជាសមាជិករបស់ខ្លួនស្ថិតនៅជារដ្ឋភាគីអនុសញ្ញា ឬប្រសិនបើអង្គការអន្តរជាតិពុំបំពេញបានតាមគុណវុឌ្ឍិដូចមានចែងនៅក្នុងមាត្រា១ នៃឧបសម្ព័ន្ធនេះ។ ការដកខ្លួននេះនឹងមានប្រសិទ្ធភាពភ្លាមៗ។